ការដោះស្រាយបញ្ហាជីវិត



កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ
សិក្សាអំពីភាពជាអ្នកដឹកនាំក្នុងគ្រិស្តបរិស័ទ

ការដោះស្រាយបញ្ហាជីវិត


មធ្យោបាយរបស់គ្រិស្តបរិសុទ្ធ

បោះពុម្ពផ្សាយលើកទី មួយ

ដោយ លោក ដូរ៉ូធី អិល. ចន

សៀវភៅសម្រាប់សិក្សាដោយខ្លួនឯង

បង្កើតឡើង ដោយសហប្រតិបត្តិការជាមួយបុគ្គលិក សាកលវិទ្យាល័យ គ្លូបល



GLOBAL
UNIVERSITY

Address of the Global University office in your area:

Global University – Battambang CAM Office
Salaa Hope – AOG
Phom Romcheck 4, Khum Ratanak
Krong Battambang,Battambang, CAMBODIA

Developed in cooperation with Global University Staff

School for Evangelism and Discipleship
Global University
1211 South Glenstone
Springfield, MO 65804
USA

Translated from the Third Edition 2006 (English)
First Edition 2026 (Khmer)
© 2026 Global University
All rights reserved

© 2026 CS6161KHM
Khmer: *Solving Life's Problems* by Dorothy L. Johns

Unless otherwise indicated, Scripture quotations are from The Khmer Standard Version © 2005 United Bible Societies.
Used by permission. All rights reserved.

PN 01.26.01

www.globaluniversity.edu
www.globalreach.org (Free pdf download)

Khmer version by Battambang CAM Translation office
Project Editor: Kelly Robinette
Head Translator: សែម សិទ្ធី (Sem Sithee)
Translation Staff:
សិទ្ធី ធីម៉ូថៃ (Sithee Thimothay)

Additional Proofreading: សែម សិទ្ធី (Sem Sithee)

- និស្សិតត្រូវដាក់ពាក្យ និង ចុះឈ្មោះជាផ្លូវការ ដើម្បីទទួលបានការទទួលស្គាល់
- និស្សិតអាចចុះឈ្មោះដោយផ្ញើអ៊ីមែល ទៅកាន់ globaluniversitycambodia@gmail.com.គេក៏អាច ផ្ញើសារទៅកាន់ sed@globaluniversity.edu ដើម្បីស្វែងរក ការិយាល័យ ដែលនៅក្នុងប្រទេសរបស់ពួកគេ ដើម្បីចុះឈ្មោះ

តារាងមាតិកា

កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ ៤
សេចក្តីណែនាំ ៥

ជំពូកទី មួយ គ្រឹះមូលដ្ឋានព្រះគម្ពីរសម្រាប់ការដោះស្រាយបញ្ហា

១ ប្រភពរបស់បញ្ហា ១៦
២ ការស្វែងរកដំណោះស្រាយ តាមមធ្យោបាយរបស់គ្រិស្តបរិស័ទ ៤០
៣ គោលការណ៍របស់គ្រិស្តបរិស័ទក្នុងការដោះស្រាយបញ្ហា ៦៩

ជំពូកទី ពីរ បញ្ហាក្នុងការទំនាក់ទំនង

៤ បញ្ហានៅក្នុងការទំនាក់ទំនងសង្គម ៩៨
៥ បញ្ហាគ្រួសារ ១២៧
៦ បញ្ហានៃជីវិតនៅលីវ ១៥៤

ជំពូកទី បី ផ្លែកពិសេសនៃបញ្ហា

៧ រឿងទាក់ទងផ្លូវភេទទៅតាមផែនការរបស់ព្រះជាម្ចាស់ ១៨០
៨ ការយកឈ្នះ លើការបាក់ទឹកចិត្ត ២០៣
៩ ការរងទុក្ខ និង សេចក្តីស្លាប់ ២២៩
១០ ការរក្សាក្តីសង្ឃឹម ២៥៧

អក្ខរានុក្រម ២៧៦
ឯកសារយោង ២៨៥
ចម្លើយសម្រាប់ការប្រឡងផ្ទាល់ខ្លួន ២៨៦
ការប្រឡងតាមជំពូក ២៩៤
អវសានកថា ៣០៩
កម្រងសំណួរសម្រាប់និស្សិត ៣១១

កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ

ភាពពេញវ័យរបស់គ្រិស្តបរិស័ទ Christian Maturity

ព្រះរាជ្យ ឫទ្ធានុភាព និង សិរីរុងរឿង Kingdom, Power, and Glory

ថ្មគ្រឹះនៃសេចក្តីពិត Cornerstones of Truth

ក្រុមជំនុំគ្រិស្តបរិស័ទទាក់ទងនឹងព័ន្ធកិច្ច The Christian Church in Ministry

អំណោយទានខាងឯវិញ្ញាណ Spiritual Gifts

ការដោះស្រាយបញ្ហាជីវិត Solving Life´s Problems

ការអធិស្ឋាន និង ការថ្វាយបង្គំ Prayer and Worship

ជំរំ ព្រះវិហារ និង ព្រះរាជវាំង Tents, Temples and Palaces

មានជីវិតរស់នៅក្នុងព្រះគ្រិស្ត Alive in Christ

ការចាប់ផ្តើមក្រុមជំនុំថ្មី Starting New Churches

ការអធិប្បាយ និង ការបង្រៀន Preaching and Teaching

មនុស្ស កិច្ចការ និង គោលដៅ People, Tasks and Goals

គ្រិស្តបរិស័ទដែលមានទំនួលខុសត្រូវThe Responsible Christian

ការស្វែងយល់ព្រះគម្ពីរ Understanding the Bible

ទីប្រឹក្សា គ្រូបង្រៀន និង មគ្គទេសក៍ Counselor, Teacher and Guide

ការជួយគ្រិស្តបរិស័ទឲ្យលូតលាស់ Helping Christians Grow

ការចែកចាយដំណឹងល្អ Sharing the Good New

ការរស់នៅដ៏ពេញបរិបូណ៌ Abundant Living

កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ

The Christian Service Series

ការដោះស្រាយបញ្ហាជីវិត (Solving Life's Problems) គឺជាមុខវិជ្ជាទីប្រាំមួយក្នុងចំណោមមុខវិជ្ជាទាំង១៨ ហើយដែល ស្ថិត នៅក្នុងវគ្គសិក្សាទីមួយ។ ក្នុងកម្មវិធីនៃភាពជាសាវ័កដ៏ជាក់ស្តែងមួយនេះ សម្រាប់អ្នកដឹកនាំថ្មីៗ។ កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ គឺជាការសិក្សាមួយដើម្បីជួយសិស្សឲ្យបានលូតលាស់ នៅក្នុងទំនាក់ទំនងរបស់ពួកគេជាមួយនឹងព្រះគ្រិស្ត និង ទំនាក់ទំនងជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រមទាំងឲ្យបានយល់កាន់តែប្រសើរឡើង អំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់ពួកគេ។

សិស្សនឹងបានសិក្សា អំពីប្រធានបទមូលដ្ឋានគ្រឹះនៃគ្រិស្តបរិស័ទ ដោយមានការបែងចែកជាមូលបទប្រាំមួយយ៉ាង នៅក្នុងវគ្គនីមួយៗ។ វគ្គសិក្សាទាំងនេះ សរសេរតាមបែបសន្ទនា និង មានភាពងាយស្រួលក្នុងការអាន។ តារាងខាងក្រោមនេះ បង្ហាញពីការរៀបចំវគ្គសិក្សានីមួយៗ សម្រាប់កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ។

មូលបទ Theme	វគ្គទី១ Unit One	វគ្គទី២ Unit Two	វគ្គទី៣ Unit Three
ជីវិតខាងឯវិញ្ញាណ Spiritual Life	ភាពពេញវ័យរបស់គ្រិស្តបរិស័ទ Christian Maturity	ការអធិស្ឋាន និង ការថ្វាយបង្គំ Prayer and Worship	គ្រិស្តបរិស័ទដែលចេះទទួលខុសត្រូវ The Responsible Christian
ព្រះគម្ពីរ The Bible	ព្រះរាជ្យ ឫទ្ធានុភាព និង សិរីរុងរឿង Kingdom, Power, and Glory	ជំរំ ព្រះវិហារ និង ព្រះរាជវាំង Tents, Temples and Palaces	ការស្វែងយល់ព្រះគម្ពីរ Understanding the Bible
ទេវសាស្ត្រ Theology	ថ្មគ្រឹះនៃសេចក្តីពិត Cornerstones of Truth	ជីវិតរស់នៅក្នុងព្រះគ្រិស្ត Alive in Christ	ទីប្រឹក្សា គ្រូបង្រៀន និង មគ្គុទេសក៍ Counselor, Teacher and Guide
ក្រុមជំនុំ The Church	ក្រុមជំនុំគ្រិស្តបរិស័ទ ទាក់ទងនឹងព័ន្ធកិច្ច The Christian Church in Ministry	ការចាប់ផ្តើមក្រុមជំនុំថ្មី Starting New Churches	ការជួយគ្រិស្តបរិស័ទឲ្យលូតលាស់ Helping Christians Grow
កិច្ចបម្រើ Service	អំណោយទានខាងឯវិញ្ញាណ Spiritual Gifts	ការអធិប្បាយ និង ការបង្រៀន Preaching and Teaching	ការចែកចាយដំណឹងល្អ Sharing the Good News
ក្រមសីលធម៌របស់គ្រិស្តបរិស័ទ Christian Ethics	ការដោះស្រាយបញ្ហាជីវិត Solving Life's Problems	មនុស្ស កិច្ចការ និង គោលដៅ People, Tasks and Goals	ការរស់នៅដ៏ពេញបរិបូណ៌ Abundant Living

កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ



សៀវភៅសិក្សាថ្នាល់ខ្លួននេះ គឺជាសៀវភៅមួយក្បាលក្នុងចំណោមសៀវភៅចំនួន១៨ក្បាល(មុខវិជ្ជា) នៃមុខវិជ្ជាបណ្តុះបណ្តាល ការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ នៃសាកលវិទ្យាល័យ គ្លូបល។ សញ្ញាសំគាល់នៅខាងឆ្វេងដៃនេះ សម្រាប់បង្ហាញអំពីលំដាប់លំដោយនៃការសិក្សា មុខវិជ្ជានេះ ដែលត្រូវបែងចែកជា ៣វគ្គដែលមាន ៦ មុខវិជ្ជាក្នុងវគ្គនីមួយៗ។ *ការដោះស្រាយបញ្ហាជីវិត* ជាមុខវិជ្ជាទី៦ ក្នុងវគ្គទី១ ។

វគ្គទាំងអស់ ត្រូវបានរៀនចំ ដើម្បីនាំអ្នក ឲ្យសិក្សាមុខវិជ្ជានេះ ជាលក្ខណៈប្រព័ន្ធសម្រាប់កម្មវិធីសិក្សាទាំងអស់នេះ ។ ទោះជាយ៉ាងណា អ្នកក៏អាចសិក្សា តែមុខវិជ្ជានេះមួយ ឬក៏អាចសិក្សា មុខវិជ្ជាផ្សេងៗទៀតនៅក្នុងកម្មវិធីសិក្សានេះ តាមរបៀបណាក៏បាន។

សម្ភារសិក្សានៅក្នុងកម្មវិធី ការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទនេះ ត្រូវបានបង្កើតឡើង តាមរបៀបដែលអាចរៀនដោយខ្លួនឯង សម្រាប់អ្នកបម្រើព័ន្ធកិច្ចគ្រិស្តបរិស័ទ គ្រប់ជាតិសាសន៍ និង គ្រប់វប្បធម៌។ កម្មវិធីនេះនឹង ផ្តាល់ជូននិស្សិត នូវចំណេះដឹង និង ជំនាញ ព្រះគម្ពីរ សម្រាប់ការបម្រើជាក់ស្តែងរបស់គ្រិស្តបរិស័ទ។

កំណត់សំគាល់

សូមអានការណែនាំដំបូង នៃមុខវិជ្ជានេះដោយប្រុងប្រយ័ត្នបំផុត។ ដោយធ្វើតាម ការណែនាំនេះ អ្នកនឹងអាចសម្រេចគោលដៅមុខវិជ្ជារបស់អ្នក ហើយអ្នកនឹងគ្មានការលំបាកក្នុងការប្រឡង ក្នុងជំពូករបស់អ្នកឡើយ។

សេចក្តីណែនាំ

មានទស្សនៈវិទូធ្លាប់បានសរសេរឡើងថា៖ "ជីវិតគឺជាចន្លោះមួយពីភាពទទេទៅដល់ភាពទទេ ដែលលាយឡំដោយទឹកភ្នែក" ។ ប្រាកដណាស់ វាមិនមែនជាទស្សនៈវិស័យរបស់គ្រិស្តបរិស័ទនោះទេ ដែលថាជីវិតគឺចាប់ផ្តើមពីភាពគ្មានអ្វីសោះ ទៅដល់ភាពគ្មានអ្វីសោះ ហើយពេញដោយទឹកភ្នែក
នោះ ។ យ៉ាងណាមិញ សូម្បីតែក្នុងចំណោមពួកយើងដែលជាគ្រិស្តបរិស័ទក៏បានឆ្លងកាត់ទឹកភ្នែកនិង ការសាកល្បងដែរ ហើយយើងត្រូវការជំនួយដើម្បីស្វែងរកចម្លើយសម្រាប់បញ្ហារបស់យើង។

តើគោលបំណងរបស់ជីវិតគឺជាអ្វី? ហេតុអ្វីបានជាមនុស្សបរិសុទ្ធ ត្រូវរងទុក្ខ? ហេតុអ្វីបានជាមានការឈឺចាប់ ទុក្ខសោក និង សេចក្តីសំអប់ជាច្រើននៅក្នុងពិភពលោក? តើអ្វី ជាប្រភពនៃបញ្ហាទាំងនោះ ហើយធ្វើយ៉ាងណាទើបគ្រិស្តបរិស័ទអាចចៀសផុតពីបញ្ហាទាំងនោះបាន? តើបញ្ហាទាំងអស់សុទ្ធតែមកពីអំពើបាបនៅក្នុងជីវិតរបស់យើងមែនដែរឬទេ? តើយើងអាចទៅណា ដើម្បីរកបានចម្លើយសម្រាប់បញ្ហាជីវិតបាន? ទាំងនេះគឺជាសំណួរខ្លះៗដែលយើងនឹង គិតពិចារណានៅក្នុងមុខវិជ្ជានេះ។

សម្រាប់បញ្ហាខ្លះដែលយើងប្រឈមមុខ គ្មានដំណោះស្រាយច្បាស់លាស់ណាមួយសម្រាប់វានោះទេ។ ប៉ុន្តែ ព្រះគម្ពីរក៏បានផ្តល់ការនាំផ្លូវសម្រាប់ការស្វែងរកដំណោះស្រាយសម្រាប់បញ្ហាជាច្រើនដែលយើងត្រូវប្រឈមមុខផងដែរ ហើយវាក៏បង្ហាញយើងពីរបៀបដែលយើងអាចចៀសផុតពីបញ្ហាជាច្រើនបានផងដែរ។

ការដែលគ្រិស្តបរិស័ទត្រូវបានចាញ់ក្រោមបញ្ហានោះ មិនមែនជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេ។ ប្រសិនបើយើងចូលទៅកាន់ទ្រង់ដើម្បីសូមជំនួយ ទ្រង់នឹងប្រទានអ្នកជួយដោះស្រាយបញ្ហាដែលនឹងផ្តល់ទិសដៅឲ្យយើង និងជួយយើងកែប្រែបញ្ហារបស់យើងទៅជាជ័យជម្នះវិញ ។

នៅពេលដែលយើងសិក្សាមុខវិជ្ជានេះ ចូរដាក់គោលការណ៍នៃការដោះស្រាយបញ្ហានេះ ទៅក្នុងហេតុការណ៍ដែលកើតឡើងនៅក្នុងជីវិតរបស់អ្នក នោះអ្នកនឹងរកឃើញព្រះពរដ៏អស្ចារ្យ ក្នុងការដើរតាមអ្នកដោះស្រាយបញ្ហារបស់អ្នក គឺព្រះយេស៊ូគ្រិស្ត ដើម្បីនឹងជួយអ្នកនៅពេលណាដែលអ្នកថ្វាយបញ្ហារបស់អ្នកទៅដល់ទ្រង់! គោលការណ៍ដែលអ្នករៀននេះ ក៏នឹងជួយអ្នកនៅក្នុងការបម្រើ អ្នកដទៃដែលមានបញ្ហាផងដែរ។

ការរៀបរាប់អំពីមុខវិជ្ជា

ការដោះស្រាយបញ្ហាជីវិត៖ មធ្យោបាយរបស់គ្រិស្តបរិស័ទ គឺជាការសិក្សាមួយអំពីប្រភពនៃបញ្ហា វិធីសាស្ត្រនៃការដោះស្រាយបញ្ហា និង របៀបនៃការស្វែងរកដំណោះស្រាយ ដែលចេញពីទស្សនៈវិស័យរបស់គ្រិស្តបរិស័ទ។ បញ្ហាចម្បងៗ គឺបានលើកយកមកនិយាយ ដូចជាបញ្ហានៅក្នុងសង្គម និងទំនាក់ទំនងគ្រួសារ បញ្ហារបស់មនុស្សនៅលើវ បញ្ហាដែលទាក់ទងនឹងផ្លូវភេទរបស់មនុស្ស និង បញ្ហាផ្សេងទៀតដែលទាក់ទងទៅនឹងការរងទុក្ខ និង សេចក្តីស្លាប់។ ដោះស្រាយតាមព្រះគម្ពីរគឺបានផ្តល់ជូនសម្រាប់បញ្ហាក្នុងផ្នែកទាំងនេះ ហើយគោលការណ៍គឺត្រូវបានបង្កើតឡើងដែលផ្តល់នូវគ្រឹះមូលដ្ឋានដ៏រឹងមាំមួយសម្រាប់ឲ្យគ្រិស្តបរិស័ទស្វែងរកដំណោះស្រាយសម្រាប់បញ្ហារបស់ពួកគេ និង ដើម្បីជួយអ្នកដទៃផ្សេងទៀតដែលត្រូវការ។ មានការសង្កត់ធ្ងន់ទៅលើ ក្តីសង្ឃឹមដ៏ពិតប្រាកដរបស់គ្រិស្តបរិស័ទ ដែលវាផ្អែកលើការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូគ្រិស្ត ដែលទ្រង់ជាអ្នកដោះស្រាយបញ្ហារបស់គ្រិស្តបរិស័ទ។

វត្ថុបំណងរបស់មេរៀន

នៅពេលដែលអ្នកបញ្ចប់មុខវិជ្ជានេះ អ្នកអាចនឹង ៖

១. បកស្រាយពីប្រភពនៃបញ្ហានៅក្នុងជីវិតរបស់គ្រិស្តបរិស័ទ។
២. ពិភាក្សាអំពីរបៀបក្នុងការស្វែងរកដំណោះស្រាយសម្រាប់បញ្ហារបស់អ្នកដោយផ្អែកលើសេចក្តីបង្រៀនរបស់ព្រះគម្ពីរ។
៣. ដឹងពីដំណាក់កាល នៅក្នុងវិធីសាស្ត្រទាំងពីរយ៉ាង នៃការដោះស្រាយបញ្ហា ហើយ យកវាទៅប្រើនៅក្នុងស្ថានភាពដែលមានបញ្ហានៅក្នុងជីវិតរបស់អ្នកផ្ទាល់ ដើម្បីរកបានដំណោះស្រាយដែលត្រឹមត្រូវ។
៤. រកឃើញដំណោះស្រាយតាមបែបព្រះគម្ពីរសម្រាប់បញ្ហាពិសេសៗរបស់គ្រិស្តបរិស័ទ។
៥. ជួយអ្នកដទៃប្រឈមមុខជាមួយនឹងបញ្ហារបស់គេ តាមទស្សនៈវិស័យរបស់គ្រិស្តបរិស័ទ និង រកដំណោះស្រាយដោយផ្អែកលើគោលការណ៍នៅក្នុងព្រះគម្ពីរ។
៦. បញ្ជាក់អះអាងពីការជឿទុកចិត្ត និង សេចក្តីសង្ឃឹមរបស់អ្នកលើព្រះយេស៊ូគ្រិស្ត នៅក្នុងគ្រប់កាលៈទេសៈទាំងអស់ ដើម្បីផ្តល់ជ័យជម្នះឲ្យអ្នក និងជួយអ្នកដើម្បីឲ្យក្លាយជាមនុស្សជោគជ័យ។

សៀវភៅមេរៀន

អ្នកនឹងប្រើប្រាស់សៀវភៅ *ការដោះស្រាយបញ្ហាជីវិត* ដែលសរសេរឡើងដោយអ្នកស្រី រ៉ូដ្ហ៊ូធី អិល. ចន នេះ ទាំងជាសៀវភៅមេរៀន និង ជាសៀវភៅមគ្គុទេសក៍ក្នុងការសិក្សា មុខវិជ្ជានេះផង។ ក្រៅពីនោះ អ្នកត្រូវការ តែព្រះគម្ពីរតែប៉ុណ្ណោះ។

មុនពេលដែលអ្នកចាប់ផ្តើម

របៀបរៀនមុខវិជ្ជានេះ

មុខវិជ្ជានេះត្រូវបានសរសេរឡើង ដើម្បីឲ្យអ្នកអាចយកទៅសិក្សាដោយខ្លួនឯងបាន។ យ៉ាងណាក៏ដោយអ្នកអាចរៀនមុខវិជ្ជានេះតាមការរៀបចំក្រុមផ្សេងៗ។ ប្រសិនបើអ្នករៀនដោយខ្លួនឯង ការរៀនរបស់អ្នក អាចបានចប់គ្រប់ជ្រុងជ្រោយ ដោយធ្វើតាមការណែនាំ នៅក្នុងសេចក្តីណែនាំនេះ។ ប្រសិនបើអ្នករៀនជាក្រុម សូមធ្វើតាមការណែនាំបន្ថែមផ្សេងដែលគ្រូរបស់អ្នកដាក់ឲ្យ ដោយយកចិត្តទុកដាក់។

វិធីប្រើប្រាស់សៀវភៅនេះ

ពេលវេលាដែលអ្នកត្រូវការ សម្រាប់រៀនមេរៀននីមួយៗ អាស្រ័យទៅតាមផ្នែកខុសៗគ្នា ទៅលើចំណេះដឹងរបស់អ្នកចំពោះមុខវិជ្ជា និង ភាពស្ទាត់ជំនាញរបស់អ្នកក្នុងការសិក្សារៀនសូត្រ មុនពេលចាប់ផ្តើមមុខវិជ្ជានោះ។ ពេលវេលាដែលអ្នកត្រូវចំណាយ ក៏អាស្រ័យទៅលើ ថាតើអ្នកអាចធ្វើតាមការណែនាំបានខ្ជាប់ខ្ជួនប៉ុនណា ហើយតើអ្នកបានបង្កើនភាពស្ទាត់ជំនាញ ដែលចាំបាច់ក្នុងការសិក្សាដោយខ្លួនឯងនេះ បានល្អប៉ុនណាដែរ។ ការដាក់គម្រោងកាលវិភាគសិក្សារបស់អ្នក ជាប្រយោជន៍ឲ្យអ្នកអាចចំណាយពេលវេលាគ្រប់គ្រាន់ដើម្បីសម្រេចបានគោលដៅដែលអ្នកនិពន្ធបានដាក់ឲ្យ ក៏ដូចជាគោលដៅផ្ទាល់ខ្លួនរបស់អ្នកផងដែរ។

មេរៀននីមួយៗ រួមបញ្ចូលទាំងសេចក្តីណែនាំ គម្រោង និងវត្ថុបំណងដើម្បីនាំផ្លូវការសិក្សារបស់អ្នក មានទាំងសកម្មភាពក្នុងការរៀន ពាក្យសំខាន់ លំហាត់អនុវត្តន៍ក្នុងមេរៀន និងលំហាត់ប្រឡងផ្ទាល់ខ្លួននៅចុងមេរៀននីមួយៗ។ ចម្លើយនៃលំហាត់អនុវត្តន៍ មាននៅចុងបញ្ចប់មេរៀននីមួយៗ ហើយចម្លើយនៃលំហាត់ប្រឡងផ្ទាល់ខ្លួន មាននៅខាងចុងបញ្ចប់នៃសៀវភៅ ដូច្នេះអ្នកអាចរំឭកដំណើរការនៃការរៀនសូត្ររបស់អ្នកបាន។

គំនិតយោបល់សម្រាប់ការសិក្សា

១. ញែកពេលវេលាឲ្យបានស្ងប់ស្ងាត់ និង ទៀងទាត់ សម្រាប់ការសិក្សារបស់អ្នក។ វាមានភាពងាយស្រួលក្នុងការផ្តោតអារម្មណ៍ជាជាង ប្រសិនបើការសិក្សាជាផ្នែកមួយនៃទម្លាប់របស់អ្នក។

២. អធិស្ឋានមុនពេលដែលអ្នកចាប់ផ្តើមការសិក្សារៀនសូត្ររបស់អ្នក។ ដោយមានព្រះគម្ពីរមួយ រួមទាំងព្រះវិញ្ញាណដ៏វិសុទ្ធ និង មុខវិជ្ជានេះ អ្នកនឹងបាននៅក្នុងថ្នាក់រៀននៃព្រះវិញ្ញាណដ៏វិសុទ្ធ។ ទូលសូម ព្រះជាម្ចាស់ដើម្បីឲ្យទ្រង់ជួយអ្នក ស្វែងយល់មេរៀននេះ ហើយយកវានៅដាក់ក្នុងជីវិតរបស់អ្នក។

៣. អានសេចក្តីណែនាំ គម្រោង និងគោលដៅ។ វានឹងផ្តល់ជូនអ្នកនូវសេចក្តីសង្ខេបទូទៅរបស់មេរៀន ជួយអ្នកឲ្យផ្តោតការយកចិត្តទុកដាក់របស់អ្នកទៅលើចំណុចសំខាន់ក្នុងពេលដែលអ្នកកំពុងសិក្សា ហើយវានឹងប្រាប់អ្នកពីអ្វីដែលអ្នកត្រូវរៀន។

៤. អានមេរៀនដោយប្រុងប្រយ័ត្ន។ បើកមើលខគម្ពីរយោង និងធ្វើការកត់ត្រា ដែលអាចមានប្រយោជន៍។ ខគម្ពីរ ជួយបញ្ជាក់បន្ថែមពីលើចំណុចសំខាន់របស់មេរៀន។

៥. ឆ្លើយលំហាត់អនុវត្តន៍ នៅក្នុងចន្លោះដែលបានដាក់ឲ្យ។ ចម្លើយដែលវែងអាចសរសេរនៅក្នុងសៀវភៅកត់ត្រាក៏បាន។ ពេលអ្នកសរសេរ ចម្លើយរបស់អ្នកសូម កត់ត្រាលេខរៀង និងចំណងជើងមេរៀនផងដែរ។ **សូមកុំមើលចម្លើយ ភ្លាមៗឡើយ។** ការឆ្លើយចម្លើយដោយខ្លួនឯង នឹងជួយឲ្យអ្នកចងចាំមេរៀនដែលអ្នកបានរៀន។ បន្ទាប់ពីឆ្លើយលំហាត់អនុវត្តន៍រួចហើយ ផ្ទៀងផ្ទាត់ចម្លើយរបស់អ្នកជាមួយចម្លើយដែលបានផ្តល់ជូននៅខាងចុងនៃមេរៀន បន្ទាប់មកពិនិត្យមើលសាឡើងវិញនូវចម្លើយដែលអ្នកឆ្លើយ
ខុស។ ចម្លើយដែលយើងឲ្យ គឺមិននៅតាមលំដាប់លំដោយលេខរៀងទេ ដូច្នេះអ្នកនឹងមិនអាចមើលឃើញចម្លើយនៃសំណួរបន្ទាប់ដោយចៃដន្យឡើយ។ លំហាត់អនុវត្តន៍ទាំងនេះពិតជាសំខាន់ខ្លាំងណាស់។ ពួកវានឹងជួយឲ្យអ្នកបានចងចាំគំនិតសំខាន់របស់មេរៀនហើយប្រើប្រាស់គោលការណ៍ដែលអ្នកបានរៀនហើយ។

៦. នៅចុងបញ្ចប់នៃមេរៀននីមួយៗ ចូរធ្វើលំហាត់ប្រឡងផ្ទាល់ខ្លួន បន្ទាប់មកពិនិត្យមើលចម្លើយរបស់អ្នកដោយប្រើ ចម្លើយសំខាន់នៅផ្នែកខាងក្រោយនៃសៀវភៅ។

៧. នៅចុងបញ្ចប់នៃជំពូកនីមួយៗ សូមឆ្លើយសំណួរការប្រឡងតាមជំពូកនោះ។

៨. ចំណាយពេលវេលារបស់អ្នក និង រៀននៅកន្លែងស្ងប់ស្ងាត់។

របៀបឆ្លើយសំណួរសិក្សា

មានលំហាត់សិក្សា និង សំណួរប្រឡងផ្ទាល់ខ្លួនជាច្រើនប្រភេទនៅក្នុងសៀវភៅនេះ។ នៅខាងក្រោមនេះជាមួយឧទាហរណ៍នៃប្រភេទសំណួរនីមួយៗ និងរបៀបឆ្លើយសំណួរ។ ការពន្យល់បញ្ជាក់បន្ថែមនឹងផ្តល់ជូនសម្រាប់ប្រភេទសំណួរផ្សេងៗទៀត។

សំណួរពហុជម្រើស

សំណួរពហុជម្រើសតម្រូវឲ្យអ្នកជ្រើសរើសចម្លើយមួយក្នុងចំណោមចម្លើយដែលបានឲ្យ។

ឧទាហរណ៍

១. កណ្ឌគម្ពីរសរុបមានចំនួន

ក. ១០០កណ្ឌ

ខ. ៦៦កណ្ឌ

គ. ២៧កណ្ឌ

ចម្លើយត្រឹមត្រូវគឺ ខ. ៦៦កណ្ឌ។ អ្នកអាចគូសរង្វង់ជុំវិញ អក្សរ ខ. ដូចដែលបានបង្ហាញនៅខាងលើ។

(សម្រាប់សំណួរពហុជម្រើសខ្លះ មានចម្លើយត្រឹមត្រូវលើសពីមួយ។ ក្នុងករណីនេះ ចូរគូសរង្វង់ជុំវិញអក្សរ នៃចម្លើយត្រឹមត្រូវនីមួយៗ។)

ចម្លើយត្រូវ/ខុស

ចំណុចឬ សំណួរត្រូវ/ខុស តម្រូវឲ្យអ្នកជ្រើសរើសចម្លើយពីរ ឬ បី ដែលត្រឹមត្រូវ។

ឧទាហរណ៍

១. តើឃ្លាប្រយោគខាងក្រោមនេះ ប្រយោគណាខ្លះ ដែលត្រឹមត្រូវ?

(ក.) ព្រះគម្ពីរជាព្រះរាជសារសម្រាប់ ពួកអ្នកជឿនៅសព្វថ្ងៃនេះ។

ខ. ព្រះគម្ពីរសរុបទាំងអស់ មាន១២០កណ្ឌ។

(គ.) ព្រះវិញ្ញាណដ៏វិសុទ្ធបានបំភ្លឺឲ្យអ្នកនិពន្ធតាក់តែងព្រះគម្ពីរ

ប្រយោគ ក. និង គ. គឺជាចម្លើយត្រឹមត្រូវ។ អ្នកត្រូវគូសរង្វង់ពីលើអក្សរ ទាំងពីរនេះ ដូចបានបង្ហាញក្នុងឧទាហរណ៍ស្រាប់។

សំណួរផ្គូផ្គង

សំណួរផ្គូផ្គង តម្រូវឲ្យអ្នកផ្គូផ្គងអ្វីដែលត្រូវគ្នា។

ឧទាហរណ៍

៣. ចូរសរសេរលេខនៃឈ្មោះអ្នកដឹកនាំ នៅពីមុខប្រយោគដែលនិយាយពីសកម្មភាពពួកគេបានធ្វើ។

1 ក) បានទទួលក្រឹត្យវិន័យ នៅលើភ្នំស៊ីណៃ ១) ម៉ូសេ

2 ខ) បានដឹកនាំជនជាតិអ៊ីស្រាអែល ឆ្លងកាត់ទន្លេយ័រដាន់ ២) យ៉ូស្វេ

2 គ) បានដើរក្បួនជុំវិញ ក្រុងយេរីខូ

1 ឃ) បានរស់នៅក្នុងវាំងរបស់ស្តេចផារ៉ោន

ឃ្លា ក) និង ឃ) និយាយអំពី លោកម៉ូសេ ហើយ ឃ្លា ខ) និង គ) និយាយអំពីលោកយ៉ូស្វេ។ អ្នកត្រូវតែ សរសេរលេខ ១ នៅត្រង់ ក) និង ឃ) ហើយសរសេរលេខ ២ នៅត្រង់ ខ) និង គ) ដូចបានបង្ហាញក្នុងឧទាហរណ៍ស្រាប់។

ការប្រឡងតាមជំពូក

នៅចុងបញ្ចប់នៃ មុខវិជ្ជានេះ អ្នកនឹងឃើញការប្រឡងតាមជំពូក និង តារាងចម្លើយ។ សូមធ្វើតាមការណែនាំដែលបានដាក់ជូនដោយប្រុងប្រយ័ត្ន។ ឆ្លើយសំណួរទាំងអស់ រួចផ្ញើតារាងចម្លើយរបស់អ្នកទៅឲ្យគ្រូរបស់អ្នកធ្វើការកែតម្រូវ។ បន្ទាប់មកអ្នកអាចធ្វើការ រំឭកសាឡើងវិញនូវមុខវិជ្ជានេះ ហើយ និង សំណួរដែលទាក់ទងជាមួយព្រះគម្ពីរដែលគិតថាពិបាកសម្រាប់អ្នក ។ ការរំឭកសាឡើងវិញ នូវវគ្គបំណងលំហាត់អនុវត្តន៍ និង ចម្លើយប្រឡងផ្ទាល់ខ្លួន និងលំហាត់ក្នុងជំពូក វាជួយអ្នកឲ្យត្រៀមខ្លួនសម្រាប់ការប្រឡងបញ្ចប់។ សម្រាប់និស្សិតដែលរៀនតាមរយៈការិយាល័យជាតិ ឬ ក្រុមសិក្សាតាមតំបន់ អាចទាក់ទងគ្រូ ឬ អ្នកដឹកនាំរបស់ពួកគេ ដើម្បីទទួលបានព័ត៌មានអំពីការប្រឡងតាមជំពូក។ ប្រសិនបើ អ្នកមិនបានរៀនជាផ្លូវការតាមរយៈសាកលវិទ្យាល័យគ្លូបល ឬក្រុមសិក្សាទេ អ្នកនៅតែអាចទទួលបានផលប្រយោជន៍ពីការប្រឡងសម្រាប់ជំពូកនេះដែរ។

ជំនួយបន្ថែម

គេក៏អាចចូលទៅកាន់ www.globalreach.org សម្រាប់ធនធានបន្ថែមទៀត។

អំពីអ្នកនិពន្ធ

អ្នកស្រី ដូរ៉ូធី អិល. ចន ធ្លាប់បានបង្រៀននៅក្នុងសាលាបឋមសិក្សាមួយនៅក្នុងទីក្រុងញូយ៉ក និង រដ្ឋមីសស៊ូរី នៃសហរដ្ឋអាមេរិក។ គាត់ក៏បានបង្រៀននៅឯ មហាវិទ្យាល័យព្រះគម្ពីរសង់ត្រាល់ នៅទីក្រុង ស្ត្រីង ហ្វៀល នៃរដ្ឋមីសស៊ូរីផងដែរ។

អ្នកស្រី ចន បានទទួលបរិញ្ញាប័ត្រតន្ត្រីពីសាលាតន្ត្រី អ៊ីស្ទើន នៅរ៉ូឆេសស្ទើ ទីក្រុងញូយ៉ក។ គាត់ បានទទួលសញ្ញាប័ត្រអនុបណ្ឌិតខាងវិទ្យាសាស្ត្រអប់រំពី សាកលវិទ្យាល័យរដ្ឋនៃទីក្រុងញូយ៉ក នៅឯ ប្រ៊ុគផត (Brockport) ក្រុងញូយ៉ក។ គាត់បានធ្វើការសិក្សាអប់រំទាំងអស់នៅ មហាវិទ្យាល័យ ជ្រូរី , មហា វិទ្យាល័យសង់ត្រាល់ និង សាកលវិទ្យាល័យមីសស៊ូរី នៅក្នុងក្រុងស្ត្រីង ហ្វៀល នៃរដ្ឋមីសស៊ូរី។



ជំពូកទីមួយ៖
គ្រឹះមូលដ្ឋានព្រះគម្ពីរ
សម្រាប់ការដោះស្រាយបញ្ហា

<u>មេរៀន</u>

១ ប្រភពរបស់បញ្ហា
២ ការស្វែងរកដំណោះស្រាយ តាមមធ្យោបាយរបស់គ្រិស្តបរិស័ទ
៣ គោលការណ៍របស់គ្រិស្តបរិស័ទសម្រាប់ការដោះស្រាយបញ្ហា

មេរៀនទី ១ ប្រភពរបស់បញ្ហា

មុនពេលដែលព្រះយេស៊ូសុគតនៅលើឈើឆ្កាង ទ្រង់បានមានព្រះបន្ទូលទៅកាន់ពួកសាវ័ករបស់ទ្រង់អំពីអ្វីដែលអាចនឹងកើតឡើងចំពោះពួកគេ បន្ទាប់ពីទ្រង់យាងត្រឡប់ទៅឯស្ថានបរមសុខវិញ។ រឿងមួយដែលព្រះអង្គមានព្រះបន្ទូលគឺ "អ្នករាល់គ្នាជួបនឹងទុក្ខវេទនានៅក្នុងលោក ប៉ុន្តែ ចូរមានសង្ឃឹមឡើង! ខ្ញុំបានឈ្នះលោកនេះហើយ។" (គម្ពីរយ៉ូហាន ១៦:៣៣)។ បន្ទាប់មកព្រះយេស៊ូបានអធិស្ឋានសម្រាប់ពួកសាវ័ករបស់ទ្រង់ "ឱព្រះបិតាដ៏វិសុទ្ធអើយ! សូមថែរក្សាអ្នកទាំងនោះ ដោយព្រះនាមព្រះអង្គផង ...ទូលបង្គំមិនអង្វរព្រះអង្គ អោយយកគេចេញពីលោកនេះឡើយ គឺសូមទ្រង់មេត្តាការពារគេពីអំណាចមារ*កំណាចវិញ។" (គម្ពីរយ៉ូហាន១៧:១១,១៥)។

ដរាបណាយើងមានជីវិតរស់នៅក្នុងពិភពលោកនេះ យើងនឹងមានបញ្ហា។ តើបញ្ហាទាំងអស់នេះមកពីណា? តើយើងអាចធ្វើអ្វី ដើម្បីបញ្ឈៀសមិនឲ្យវាកើតឡើងបានទេ? តើហេតុអ្វីបានជាព្រះជាម្ចាស់អនុញ្ញាតឲ្យគ្រិស្តបរិស័ទឆ្លងកាត់ការលំបាក និង ការសាកល្បង?

នៅក្នុងមេរៀននេះ យើងនឹងពិចារណាអំពីប្រភពនៃបញ្ហារបស់យើង និង ហេតុផលដែលយើងទាំងអស់គ្នាត្រូវប្រឈមជាមួយនឹងបញ្ហា។ ការស្វែងយល់ពី *មូលហេតុ* ដែលរឿងរ៉ាវកើតឡើង វានឹងជួយយើងឲ្យយល់ពីរបៀបស្វែងរកដំណោះស្រាយ ឬ ធ្វើឲ្យបញ្ហារបស់យើងក្លាយទៅជាឱកាសដើម្បីបានលូតលាស់នៅក្នុងបទពិសោធន៍ជាគ្រិស្តបរិស័ទរបស់ពួកយើង។ នៅពេលដែលយើងសិក្សាមេរៀននេះ សូមអ្នកគិតអំពីបញ្ហានៅក្នុងជីវិតរបស់អ្នកផ្ទាល់ និង អំពីប្រភពរបស់វាផង។ នៅពេលដែលអ្នកបានស្គាល់ពីប្រភពនៃបញ្ហាហើយ អ្នកអាចនឹងពិចារណាអំពីដំណោះស្រាយដ៏សមស្របបាន។ ការស្គាល់ពីប្រភពក៏អាចជួយអ្នកបញ្ឈៀសបញ្ហាមួយចំនួន ហើយនោះក៏ជាដំណោះស្រាយដ៏ល្អប្រសើរជាងគេបំផុតផងដែរ។

គម្រោងមេរៀន

ក. លទ្ធផលនៃអំពើបាប
ខ. លទ្ធផលនៃឥទ្ធិពលខាងក្រៅ
គ. លទ្ធផលនៃជម្រើសរបស់យើង
ឃ. លទ្ធផលនៃការយកព្រះហឫទ័យទុកដាក់របស់ព្រះជាម្ចាស់សម្រាប់យើង

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. ស្គាល់ពីឫសគល់នៃបញ្ហា។
២. ផ្តល់ឧទាហរណ៍អំពីបញ្ហាដែលជាលទ្ធផលបានមកពីការរស់នៅរបស់យើង ក្នុងពិភពលោកដែលហិនហោចដោយសារអំពើបាបមួយនេះ។
៣. ប្រាប់អំពីជម្រើសដែលមនុស្សអាចនឹងជ្រើសយក ប្រសិនបើពួកគេប្រាថ្នាចង់បញ្ឈៀសបញ្ហាដែលបណ្តាលមកពីអំពើបាបផ្ទាល់ខ្លួនរបស់ពួកគេ។
៤. ស្គាល់ពីឧទាហរណ៍នៃបញ្ហាខ្លះ ដែលជាលទ្ធផលបានមកពីឥទ្ធិពលពីខាងក្រៅ ដែលអ្នកមិនអាចគ្រប់គ្រងវាបាន។
៥. បកស្រាយពីទំនាក់ទំនងនៃបញ្ហា ជាមួយនឹងការវិនិច្ឆ័យដែលខុសឆ្គង។
៦. ជ្រើសរើសយកគំរូល្អៗដែលអ្នកអាចនឹងជ្រើសយក ទោះបីជាអ្នកបានដឹងថាវាអាចនឹងធ្វើឲ្យមានបញ្ហាក៏ដោយ។
៧. រៀបរាប់ពីភាពខុសគ្នារវាងគោលបំណងរបស់សាតាំងដែលវាល្បួង និង បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលសាកល្បងយើង។
៨. កំណត់សារដែលនៅក្នុងគម្ពីររ៉ូម៨:១៧,២៨-២៩ ដែលទាក់ទងទៅនឹងបញ្ហាដែលយើងប្រឈមមុខ។
៩. បកស្រាយពីរបៀបដែលការសាកល្បងរបស់យើង អាចជាប្រយោជន៍សម្រាប់ទំនាក់ទំនងរបស់យើង ជាមួយនឹងមនុស្សដទៃ និង ជាមួយព្រះជាម្ចាស់។

សកម្មភាពក្នុងការសិក្សា

១. អានសេចក្តីណែនាំនៅក្នុងសៀវភៅសិក្សាឯករាជ្យនេះ ហើយសិក្សាវត្ថុបំណងនៃមុខវិជ្ជាដោយការប្រុងប្រយ័ត្ន។
២. អាន ផ្នែកការណែនាំ គម្រោង និងវត្ថុបំណង របស់មេរៀននេះ ។
៣. មើលចំណុចពាក្យសំខាន់។ អ្នកនឹងរកឃើញនិយមន័យរបស់ពាក្យទាំងនោះនៅក្នុងអក្ខរានុក្រមនៅចុងបញ្ចប់នៃសៀវភៅសិក្សាមួយនេះ។ ត្រូវប្រាកដថាអ្នកបានឃើញនិយមន័យពាក្យទាំងឡាយណាដែលមិនសូវច្បាស់សម្រាប់អ្នក។
៤. ចូរអានគម្ពីរលោកុប្បត្តិជំពូក១ ជំពូក២ និង ជំពូក៣ ដែលជាគោលសំខាន់សម្រាប់មេរៀននេះ។
៥. សិក្សាសេចក្តីសង្ខេបការរីវត្តនៃមេរៀន ទៅតាមផ្នែកនីមួយៗ សូមអានខគម្ពីរទាំងអស់ដែលបានដាក់ឲ្យ និង ឆ្លើយសំណួរសិក្សាទាំងអស់។ ត្រូវប្រាកដថាអ្នកអាចបំពេញតាមវត្ថុបំណងនៃផ្នែកនីមួយៗ មុនពេលដែលអ្នកបន្តទៅផ្នែកបន្ទាប់ទៀត។
៦. ធ្វើការប្រឡងផ្ទាល់ខ្លួន នៅចុងបញ្ចប់នៃមេរៀន ហើយពិនិត្យចម្លើយរបស់អ្នកជាមួយនឹងចម្លើយដែលបានផ្តល់ជូននៅចុងបញ្ចប់នៃសៀវភៅសិក្សានេះ។ រំឭកចំណុចណាដែលអ្នកបានឆ្លើយខុស។

ពាក្យសំខាន់

ការយល់ដឹងពីពាក្យសំខាន់ដែលយើងដាក់ឲ្យនៅខាងផ្នែកដំបូងនៃគ្រប់មេរៀន នឹងជួយអ្នកនៅពេលដែលអ្នករៀន។ អ្នកនឹងឃើញមាន តារាងពាក្យសំខាន់ដែលតម្រៀបតាមលំដាប់លំដោយព្យញ្ជនៈ និង អត្ថន័យរបស់វាក្នុងអក្ខរានុក្រមនៅផ្នែកខាងក្រោយនៃសៀវភៅសិក្សាផ្ទាល់ខ្លួននេះ។ ប្រសិនជា អ្នកនៅមានមន្ទិលសង្ស័យ អំពីអត្ថន័យនៃពាក្យណាមួយនៅក្នុងតារាងនេះ អ្នកអាចរកមើលវានៅពេលនេះក៏បាន ឬ នៅពេលអ្នកបានឃើញវា ក្នុងអំឡុងពេលអានមេរៀនរបស់អ្នក។ សូមចំណាយពេលសិក្សាពីនិយមន័យនៃពាក្យថ្មីៗទាំងអស់ ដោយពួកវាមានភាពចាំបាច់ណាស់ដើម្បីទទួលបានការស្វែងយល់យ៉ាងពេញលេញ នៅក្នុងមុខវិជ្ជានេះ។

គុណប្រយោជន៍	ភាពអសីលធម៌	របស់ចាំបាច់
ចំណុះ	ទាក់ទង	បន្សុទ្ធ
មេត្តាធម៌	ធំពេញវ័យ	ចំរាញ់
គោរពតាម	ការបៀតបៀន	ដំណោះស្រាយ
គ្រោះមហន្តរាយ	ការស៊ូទ្រាំ	

ក. លទ្ធផលនៃអំពើបាប

វត្ថុបំណងទី១. *ស្គាល់ពីឫសគល់នៃបញ្ហាផ្សេងៗ។*

អំពើបាបរបស់លោកអដាំ

លោកអដាំ និង នាងអេវ៉ាត្រូវបានបង្កើតមកជាមនុស្សដ៏ល្អឥតខ្ចោះ នៅក្នុងពិភពលោកដ៏ឥតខ្ចោះមួយនេះ (គម្ពីរលោកុប្បត្តិជំពូក២)។ពួកគេមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងព្រះជាម្ចាស់ ហើយពួកគេគ្មានបញ្ហាអ្វីសោះឡើយ ប៉ុន្តែព្រះជាម្ចាស់បានប្រទានឲ្យពួកគេមានអំណាចធ្វើការ*ជ្រើសរើស* ក្នុងការស្តាប់បង្គាប់ និង ការបម្រើទ្រង់។

មានឥទ្ធិពលអាក្រក់មួយនៅក្នុងពិភពលោក គឺជាសាតាំងដែលព្រះយេស៊ូបានហៅថា "មារកំណាច" (គម្ពីរយ៉ូហាន ១៧:១៥)។ វារស់នៅក្នុងសួនអេដែនក្នុងទម្រង់ជាសត្វពស់មួយក្បាល។ ព្រះគម្ពីរមិនបានប្រាប់យើងថាវាបានទៅនៅទីនោះដោយរបៀបណាឡើយ ប៉ុន្តែយើងបានអាននៅក្នុងគម្ពីរលោកុប្បត្តិជំពូក៣ អំពីរបៀបដែលសត្វពស់ (សាតាំង) បានប្រើប្រាស់ឥទ្ធិពលអាក្រក់របស់វា ដើម្បីល្បួងលោកអដាំ និង នាងអេវ៉ា ដើម្បីឲ្យពួកគេមិនស្តាប់ព្រះជាម្ចាស់។ ការមិនស្តាប់បង្គាប់របស់ពួកគេបាននាំឲ្យមានបណ្តាសាមកលើផែនដីទាំងមូល។ ផែនដី និង មនុស្សជាតិទាំងអស់ត្រូវបានខូចខាតដោយសារតែអំពើបាបមួយនេះ។ នេះគឺចំណុចចាប់ផ្តើមនៃ សេចក្តីឈឺចាប់, ទុក្ខសោក, ការលំបាក, គ្រោះមហន្តរាយ និង ការងារពិបាកៗ។

លំហាត់អនុវត្តន៍

---

១. តើប្រយោគមួយណា នៅខាងក្រោមនេះដែលអាចរៀបរាប់សង្ខេបពីអ្វីដែលយើងទើបបាន ពិភាក្សាគ្នាទាក់ទងនឹងប្រភព និង ឫសគល់នៃបញ្ហាផ្សេងៗរបស់យើងបាន?

ក) សាតាំងគឺជាមូលហេតុនៃគ្រប់បញ្ហារបស់យើង។

ខ) អំពើបាបរបស់លោកអដាំ និង នាងអេវ៉ាគឺជាប្រភពនៃគ្រប់បញ្ហារបស់យើង។

គ) ឥទ្ធិពលអាក្រក់របស់សាតាំង និង ការមិនស្តាប់បង្គាប់របស់មនុស្ស បាននាំឲ្យមានបណ្តាសាមកលើផែនដីទាំងមូល ហើយក៏ជាប្រភពនៃបញ្ហាផ្សេងៗផងដែរ។

ពិភពលោកដែលខូចខាតដោយអំពើបាប

វត្ថុបំណងទី២. *ផ្តល់ឧទាហរណ៍អំពីបញ្ហាដែលជាលទ្ធផលបានមកពីការរស់នៅរបស់យើង ក្នុងពិភពលោក ដែលហិនហោចដោយសារអំពើបាបមួយនេះ។*

ព្រះគម្ពីរលោកុប្បត្តិ៣:១៦-១៩ មានកត់ត្រាអំពីបណ្តាសាដែលបានមកលើផែនដី ជាលទ្ធផលនៃអំពើបាប។ យើងចាស់ ហើយស្លាប់ក៏ដោយសារតែបណ្តាសាមួយនេះ។ ដោយសារតែអំពើបាប ផែនដីគឺមិនល្អឥតខ្ចោះនោះទេ ហើយថែមទាំងមានគ្រោះមហន្តរាយដូចជា ការអត់ឃ្លាន ទឹកជំនន់ និង ការរញ្ជួយដីផង។ ដោយសារតែអំពើបាប យើងត្រូវរែទនាទល់នឹង ខ្យល់ ព្យុះភ្លៀង និង សត្វព្រៃកំណាច និង សត្វ

ល្អិត ដើម្បីនឹងផ្គត់ផ្គង់អាហារសម្រាប់ការលូតលាស់របស់យើង។ ទោះបីយើងមិនមែនជាកសិករទាំងអស់គ្នាក៏ដោយ ការរស់នៅរបស់យើងត្រូវពឹងផ្អែកលើការផ្គត់ផ្គង់មួយនេះ។
ដោយសារតែអំពើបាបរបស់យើង ក្មេងៗខ្លះបានកើតមកជាមួយនឹងការខូចខាតខួរក្បាល ពិការដៃជើង ឬ មានជំងឺ។

លំហាត់អនុវត្តន៍

២ សូមគិតពិចារណា អំពីតំបន់ដែលអ្នករស់នៅ។ តើអ្នកអាចផ្តល់ឧទាហរណ៍អំពីបញ្ហាខ្លះៗដែលអ្នកបានឃើញ និង បានប្រឈមមុខ ដែលជាលទ្ធផលនៃពិភពលោកដែលបានខូតខាតដោយអំពើបាបនេះបានដែរឬទេ?

.....

.....

.....

.....

និស្ស័យពេញដោយបាបផ្ទាល់ខ្លួនរបស់យើង

វត្ថុបំណងទី៣. *ប្រាប់អំពីជម្រើសដែលមនុស្សអាចនឹងជ្រើសយក ប្រសិនបើពួកគេប្រាថ្នាចង់បញ្ចៀសបញ្ហាដែលបណ្តាលមកពីអំពើបាបផ្ទាល់ខ្លួនរបស់ពួកគេ។*

អ្នកប្រហែលជាធ្លាប់បានឮអំពីរឿងមួយដែលនិយាយអំពីក្មេងប្រុសម្នាក់ ដែលត្រូវបានតាមទាន់នៅពេលដែលកំពុងធ្វើខុស។ នៅពេលដែលម្តាយរបស់គេសួរគេថា ហេតុអ្វីបានជាគេធ្វើយ៉ាងដូច្នោះ គេបានតបថា " អារក្សវ៉ានាំខ្ញុំឲ្យធ្វើ!" វាងាយស្រួលណាស់ក្នុងការចោទបញ្ហារបស់យើងទាំងអស់ទៅលើអារក្ស (សាតាំង) ប៉ុន្តែការពិតគឺថា បញ្ហារបស់យើងជាច្រើនគឺជាលទ្ធផលនៃនិស្ស័យដែលពេញដោយបាបរបស់យើង។

យើងទទួលបានអំណាចក្នុងការសម្រេចចិត្តជ្រើសរើសរវាងការបម្រើព្រះជាម្ចាស់ ឬ មិនបម្រើទ្រង់។ នៅពេលដែលយើងធ្វើអំពើបាប វាគឺជាបញ្ហានៃការជម្រើសផ្ទាល់ខ្លួនរបស់យើង ហើយយើងមានទំនួលខុសត្រូវដោយផ្ទាល់ចំពោះអំពើបាបរបស់យើង។ នៅក្នុងព្រះគម្ពីររ៉ូម ៥:១២ យើងបានអាន "តាមរយៈមនុស្សតែម្នាក់ បាប*បានចូលមកក្នុងពិភពលោក ហើយតាមរយៈបាប សេចក្តីស្លាប់ក៏ចូលមកដែរ។ ហេតុនេះហើយបានជាសេចក្តីស្លាប់រាលដាលដល់មនុស្សគ្រប់ៗរូប ព្រោះគ្រប់គ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប។"

លំហាត់អនុវត្តន៍

៣ សូមអានគម្ពីរអេសាយ ៥៣:៦ គម្ពីរអេសាយ ៦៤:៦ គម្ពីរសុភាសិត ២០:៩ គម្ពីររ៉ូម ៣:២៣ និងគម្ពីរ១យ៉ូហាន ១:៨។ តើប្រយោគមួយណា នៅខាងក្រោមនេះ អាចរៀបរាប់បានល្អជាងគេ អំពីសារដែលត្រូវបានលើកយកមកនិយាយម្តងហើយម្តងទៀតនៅក្នុងខគម្ពីរទាំងនេះ?

ក) មនុស្សខ្លះមានបាបច្រើនជាមនុស្សខ្លះទៀត។

ខ) លោកអដាំជាអ្នកបង្កឲ្យយើងមាននិស្ស័យបាប។

គ) មនុស្សទាំងអស់កើតមកជាមួយនឹងនិស្ស័យមានបាប ហើយមនុស្សទាំងអស់គឺមានទោស ដោយអំពីបាបផ្ទាល់ខ្លួន។

ខគម្ពីរទាំងនេះ បានធ្វើឲ្យឃើញកាន់តែច្បាស់ថា យើងរាល់គ្នាគឺកើតមកជាមួយនឹងសមត្ថភាពក្នុងការធ្វើអំពើបាប ហើយយើងទាំងអស់គ្នាទទួលខុសត្រូវ សម្រាប់ជម្រើសរបស់យើងក្នុងការធ្វើល្អ ឬ ធ្វើអាក្រក់។ បញ្ហារបស់យើងគឺជាលទ្ធផលបានមកពីកាយវិការមានបាបដែលយើងបានធ្វើ មកពីពាក្យសំដីដែលយើងបាននិយាយដោយមិនបានប្រុងប្រយ័ត្ន ឬ ឥរិយាបថមានបាប ដូចជា ការធ្វើតាមអំពើចិត្ត ភាពអាត្មានិយម ភាពលោភលន់ ការច្រណែន ឬ អាទិភាពដែលខុស។

ព្រះគម្ពីរបានកត់ត្រាអំពីរឿងមួយនៅពេលដែលព្រះយេស៊ូបានប្រោសបុរសម្នាក់ដែលបានឈឺតាំងពីយូរណាស់មកហើយ។ ក្រោយមកព្រះយេស៊ូបានទតឃើញបុរសនោះនៅក្នុងព្រះវិហារ ហើយទ្រង់បានប្រទានការណែនាំទៅគាត់ដូច្នេះថា "ឥឡូវនេះ អ្នកបានជាហើយ កុំប្រព្រឹត្តអំពើបាបទៀតអោយសោះ ក្រែងលោកើតការអាក្រក់ដល់អ្នក លើសមុនទៅទៀត" (គម្ពីរយ៉ូហាន ៥:១៤)។ ជាក់ស្តែង នៅក្នុងរឿងនេះ វាគឺជាអំពើបាបរបស់បុរសម្នាក់នេះហើយ ដែលជាមូលហេតុបណ្តោយឲ្យគាត់មានជំងឺ។

មនុស្សដែលធ្វើបាបខ្លួនប្រាណរបស់ពួកគេ ដោយការប្រើប្រាស់ថ្នាំញៀនគ្រោះថ្នាក់ ឬ ថ្នាំជក់ ដោយការស៊ីផឹកហួសប្រមាណ ដោយអំពើអសីលធម៌ ឬ ដោយការប្រព្រឹត្តអំពើបាបផ្សេងទៀត ជាលទ្ធផល គេអាចមានបញ្ហាធ្ងន់ធ្ងរទៅលើរូបកាយ។ នៅពេលដែលយើងមិនស្តាប់ព្រះជាម្ចាស់ និង ព្រះបន្ទូលរបស់ទ្រង់ យើងអាចនាំបញ្ហាជាច្រើនមកដាក់ខ្លួន ដូចជាការបាត់បង់ផ្ទះសំបែង ការបាត់បង់ទំនាក់ទំនង ទុក្ខសោក ក្តីវេទនា ជំងឺ ឬ រហូតដល់ថ្នាក់ស្លាប់ទៀតផង។ គម្ពីររ៉ូម ៦:២៣ បានរំឭកយើងថា " លទ្ធផលនៃបាប គឺសេចក្តីស្លាប់" ។ នេះមិនគ្រាន់តែនិយាយអំពីការស្លាប់ខាងឯរូបកាយនោះទេ តែក៏និយាយអំពីការស្លាប់ខាងឯវិញ្ញាណ ដែលជាការបែកចេញពីព្រះជាម្ចាស់ជារៀងរហូតនោះផងដែរ។

មានពេលខ្លះ របៀបដែលឆ្លើយតបជាមួយនឹងបញ្ហា អាចបង្កើតបានជាបញ្ហាបន្ថែមទៀត។ ឥរិយាបថអាក្រក់ ឬ វិញ្ញាណដែលចេះតែភ្ជួញភ្ជែរ គឺជាការឆ្លើយតបដែលពេញដោយបាបទៅចំពោះកាលៈទេសៈរបស់យើង។ នៅពេលដែលរឿងនេះកើតឡើង បញ្ហារបស់យើងអាចយកឈ្នះលើយើងបាន ហើយធ្វើឲ្យយើងបាត់បង់ទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់។ នៅពេលក្រោយ យើងនឹងបានឃើញនៅ

ក្នុងមេរៀននេះ ថាតិរិយាបថល្អ នឹងជួយយើងឲ្យប្រែបញ្ហារបស់យើងទៅជាជ័យជំនះបាន ហើយលទ្ធផលនឹងទទួលបានការលូតលាស់ខាងឯវិញ្ញាណ។

លំហាត់អនុវត្តន៍

៤ តើយើងអាចធ្វើអ្វីបាន ដើម្បីបញ្ឈៀសបញ្ហា ដែលបណ្តាលមកពីអំពើបាបផ្ទាល់ខ្លួនរបស់យើង?

.....

វាគឺជាកំហុសមួយដែលយើងនិយាយថា យើងអាចបញ្ឈៀសបញ្ហាទាំងអស់ដែលទាក់ទងនឹងអំពើបាបបាន ដោយការរស់នៅជីវិតមួយដែលមិនប្រព្រឹត្តអំពើបាបសោះ។ បទពិសោធន៍របស់អ្នកផ្ទាល់នឹងប្រាប់អ្នកថា ទោះបីជាអ្នកខំប្រឹងយ៉ាងណា អ្នកមិនល្អឥតខ្ចោះនោះទេ ហើយទោះបីជាអ្នកទទួលបានជ័យជម្នះលើអំពើបាបក៏ដោយ ក៏មានពេលខ្លះនិស្ស័យបាបចាស់របស់អ្នកនឹងធ្វើឲ្យអ្នកបរាជ័យជាមិនខាន។ ដូច្នេះ ម្តងហើយម្តងទៀត អ្នកនឹងមានបញ្ហាដែលជាលទ្ធផលនៃការបរាជ័យផ្ទាល់ខ្លួនរបស់អ្នក។ ប៉ុន្តែរឿងពិតដ៏អស្ចារ្យនោះគឺថា ទោះបីជាយើងមានបាប ដ៏ព្រះជាម្ចាស់នៅតែស្រឡាញ់យើង ហើយទ្រង់នឹងជួយយើងស្វែងរកដំណោះស្រាយសម្រាប់បញ្ហាទាំងអស់របស់យើង នៅពេលដែលយើងលន់តួបាបរបស់យើង ហើយស្រែករកព្រះនាមទ្រង់ ដើម្បីសុំជំនួយ។

នៅមេរៀនក្រោយៗ ទៀត យើងនឹងទៅមើលអំពីឧទាហរណ៍ជាក់លាក់អំពីរបៀបដែលអំពើបាបបង្កឲ្យមានបញ្ហា និង អ្វីដែលយើងអាចធ្វើបានដើម្បីបញ្ឈៀស ឬ យកឈ្នះលើបញ្ហាទាំងអស់នោះបាន។

ខ. លទ្ធផលនៃឥទ្ធិពលខាងក្រៅ

វត្ថុបំណងទី៤. *ស្គាល់ពីឧទាហរណ៍នៃបញ្ហាខ្លះ ដែលជាលទ្ធផលបានមកពីឥទ្ធិពលពីខាងក្រៅដែលអ្នកមិនអាចគ្រប់គ្រងវាបាន។*

យើងបានឃើញថាបញ្ហារបស់មនុស្សគឺជាលទ្ធផលនៃអំពើបាប។ ដោយសារតែអំពើបាប យើងត្រូវរស់នៅក្នុងពិភពលោកដែលខូចខាត។ អំពើបាបបាននាំបណ្តាសាមកលើពិភពលោកទាំងមូល ហើយឥទ្ធិពលរបស់សាតាំងនៅក្នុងពិភពលោកនេះបាននាំឲ្យមាន ភាពវឹកវរ ភាពច្របូកច្របល់ បញ្ហា និង ការអស់សង្ឃឹម។ មនុស្សគ្រប់រូបកើតមកជាមួយនឹងនិស្ស័យបាប (រ៉ូម ៣:២៣)។

តើនេះមានន័យថា បញ្ហារបស់យើងសុទ្ធតែបង្កឡើងដោយសារអំពើបាបផ្ទាល់ខ្លួនមែនដែរឬទេ? មិនមែននោះទេ! បញ្ហាជាច្រើនដែលយើងប្រឈមមុខគឺត្រូវបានបង្កឡើងដោយឥទ្ធិពលដែលនៅក្រៅការគ្រប់គ្រងរបស់យើងទាំងស្រុង។ តើឥទ្ធិពលទាំងនោះមានអ្វីខ្លះ?

គ្រោះធម្មជាតិ

នៅពេលដែលកប៉ាល់ទីតានិក ត្រូវបានកសាងឡើងនៅក្នុងឆ្នាំ១៩១២ វាគឺជានាវាដែលធំជាងគេនៅលើលោក។ អ្នកជំនាញបាននិយាយថា នាវានេះគឺមិនអាចនឹងលិចបានទេ។ ប៉ុន្តែនៅយប់ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩១២ វាបានបុកនឹងផ្ទាំងទឹកកកអណ្តែត ហើយបានលិចនៅក្នុងអំឡុងពេលនៃការធ្វើដំណើរ ជាលើកទីមួយរបស់វា ពីប្រទេសអង់គ្លេស ទៅកាន់សហរដ្ឋអាមេរិក។ មានអ្នកដំណើរប្រមាណ ១៥០០ នាក់ក្នុងចំណោម២២០០នាក់បានបាត់បង់ជីវិត មុនពេលដែលគេអាចសង្គ្រោះបាន។ គ្មាននរណាម្នាក់ អាចគិតដល់ថា ផ្ទាំងទឹកកកអណ្តែតមួយអាចទំលុះប្រហោងដែលអាចធ្វើឲ្យវាលិចក្នុងរយៈពេលត្រឹមតែ ពីរម៉ោងកន្លះយ៉ាងដូច្នេះទេ។

សូមគិតដល់បញ្ហាទាំងអស់ដែលបណ្តាលមកពីគ្រោះមហន្តរាយទាំងនេះ! ប្រាកដណាស់ មាន គ្រិស្តបរិស័ទជាច្រើននាក់ដែលបានបាត់បង់មនុស្សជាទីស្រឡាញ់នៅក្នុងឧបទ្វរហេតុមួយនេះ។ លទ្ធផល ដែលទទួលបានពីបញ្ហានេះគឺទុក្ខសោក ការឈឺចាប់ ភាពគ្រាំគ្រា ហើយលទ្ធផលនៃហេតុការណ៍នេះមិន ត្រូវអាចសន្មតថាមកពីអំពើបាបផ្ទាល់ខ្លួនរបស់នរណាម្នាក់បានទេ។ វាគឺជាលទ្ធផលនៃគ្រោះធម្មជាតិតែ ប៉ុណ្ណោះ។

អ្នកប្រហែលជាធ្លាប់ជា ជនរងគ្រោះម្នាក់នៅក្នុងគ្រោះមហន្តរាយ ដូចជាទឹកជំនន់ រញ្ជួយដី ខ្យល់ព្យុះ ឬ ភាពអត់ឃ្លានផងដែរ។ ឬ អ្នកប្រហែលជាធ្លាប់ឆ្លងកាត់បញ្ហានៅក្នុងគ្រួសាររបស់អ្នក ដូចជាជំងឺ សេចក្តីស្លាប់ ជំងឺផ្លូវចិត្ត បញ្ហាខាងហិរញ្ញវត្ថុ ឬស្ថានភាពផ្សេងៗទៀតដែលអ្នកមិនអាចគ្រប់គ្រងបាន។ ប្រាកដណាស់ ឫសគល់ដែលនាំឲ្យមានបញ្ហាទាំងនេះ គឺជាបណ្តាសាដែលធ្លាក់មកលើពិភពលោក ដោយសារលោកអដាំ និង នាងអេវ៉ានៅក្នុងសួនច្បារអេដែន ប៉ុន្តែពួកវាមិនមែនជាលទ្ធផលដែល បានមក ពីអំពើបាបផ្ទាល់ខ្លួននោះឡើយ។ ព្រះគម្ពីរបានចែងយ៉ាងច្បាស់ថា ទាំងគ្រិស្តបរិស័ទដែលល្អបរិសុទ្ធ ទាំង អ្នកមិនជឿដែលមានបាប អាចនឹងជួបប្រឈមជាមួយនឹងបញ្ហា ដោយសារតែយើងរស់នៅក្នុងពិភពលោក ដែលត្រូវបានផ្តាសាដោយសារតែអំពើបាប។

លំហាត់អនុវត្តន៍

---

៥ សូមអានគម្ពីរម៉ាថាយ ២៤:៤-៩ ដែលជាខគម្ពីររៀបរាប់ពីអ្វីដែលអ្នកជឿអាចរំពឹងទុកថានឹងកើត មាននៅពេលដែល ការយាងត្រឡប់មកជាលើកទីពីររបស់ព្រះគ្រិស្ត ខិតជិតមកដល់។ តើមាន គ្រោះមហន្តរាយអ្វីខ្លះដែលលើសពីការគ្រប់គ្រងរបស់អ្នកជឿ ត្រូវបានរៀបរាប់នៅក្នុងខគម្ពីរនេះ?

.....

សកម្មភាពរបស់អ្នកដទៃ

នៅក្នុងពេលមានវិបត្តិសេដ្ឋកិច្ច មានជំនួញជាច្រើនត្រូវបានបរាជ័យ និង មានមនុស្សជាច្រើនបានបាត់បង់ការងាររបស់ពួកគេ។ រឿងនេះអាចកើតឡើងចំពោះអ្នក មិនមែនតាមរយៈកំហុសរបស់អ្នកផ្ទាល់នោះទេ។ ប្រធានរបស់អ្នកអាចសម្រេចចិត្តបញ្ជូនអ្នកទៅធ្វើការនៅកន្លែងផ្សេងមួយទៀត ហើយបង្កើតបញ្ហាថ្មីសម្រាប់គ្រួសាររបស់អ្នកទាំងមូល។ អាចនឹងមាននរណាម្នាក់ បើកបរយានយន្តមិនបានមើលឃើញផ្លាកសញ្ញាឲ្យឈប់ ហើយបុកចំយានយន្តរបស់អ្នក បង្កឲ្យមានការខូចខាត និង របួស។ អាចមានអ្នកជិតខាង មានការយល់ច្រឡំចំពោះទង្វើរបស់អ្នក និង ចោទប្រកាន់អ្នកថាបានធ្វើអំពើខុសឆ្គងដោយអយុត្តិធម៌។ អ្នកអាចត្រូវបានគេតម្រូវឲ្យការពារប្រទេសរបស់អ្នកនៅក្នុងសមរភូមិ នៅពេលដែលខ្មាំងសត្រូវប្រកាសសង្គ្រាមជាមួយប្រទេសរបស់អ្នក។ អ្នកអាចជាជនរងគ្រោះនៅក្នុងឧក្រិដ្ឋកម្មមួយ។ ទាំងអស់នេះជាគំរូខ្លះៗនៃបញ្ហា ធំក្តីតូចក្តី ដែលធ្លាក់មកលើយើងដោយសារតែការសម្រេចចិត្តរបស់អ្នកដទៃដែលវាស្ថិតនៅក្រៅពីការគ្រប់គ្រងរបស់យើងទាំងស្រុង។

ដោយសារតែនិស្ស័យរបស់យើងគឺត្រូវមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ទោះក្តីរីករាយ និងក្តីសុខសាន្តរបស់យើង ពេលខ្លះស្ថិតនៅលើការសម្រេចចិត្តរបស់អ្នកដទៃ។ យើងនឹងផ្តល់ការយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងមេរៀននេះ អំពីការដោះស្រាយបញ្ហានៅក្នុងទំនាក់ទំនងជាមួយអ្នកដទៃ និង ការឆ្លើយតបទៅកាន់បញ្ហាបានមកពីការសម្រេចចិត្តរបស់អ្នកដែលយើងប្រឈមមុខ ។

លំហាត់អនុវត្តន៍

---

៦ ចូរធ្វើការពិចារណា ពីស្ថានភាពខាងក្រោមនេះ និង គូសរង្វង់ជុំវិញអក្សរដែលនៅខាងមុខស្ថានភាពទាំងឡាយណាដែលអាចបណ្តាលមកពីឥទ្ធិពលដែលនៅក្រៅពីការគ្រប់គ្រងរបស់អ្នក។

ក) មនុស្សជាទីស្រឡាញ់ បានបាត់បង់ជីវិតនៅក្នុងការធ្លាក់យន្តហោះ។

ខ) អ្នកដាំដំណាំរបស់អ្នកឃឺតយ៉ាវ ធ្វើឲ្យវាមិនអាចលូតលាស់។

គ) មានចោរម្នាក់ទំលុះចូលផ្ទះរបស់អ្នក និង ប្លន់យកទ្រព្យសម្បត្តិរបស់អ្នក។

ឃ) អ្នកបានភ្លេចកាបូបលុយរបស់អ្នកនៅកន្លែងទូទាត់ប្រាក់នៅផ្សារលក់សាច់ ហើយមានគេលួចយកវាបាត់។

ង) ថៅកែរបស់អ្នក បានដកអ្នកចេញ ដោយសារតែអ្នកមានទម្លាប់មកធ្វើការយឺតពេល។

ច) គ្រោះរញ្ជួយដីមួយបានបំផ្លាញផ្ទះរបស់អ្នក ហើយអ្នកក៏មានរបួសទៀត។

ឆ) អ្នកបាត់បង់ការងាររបស់អ្នកដោយសារតែអ្នកមានជំងឺយ៉ាងធ្ងន់ធ្ងរ។

គ. លទ្ធផលនៃជម្រើសរបស់យើង

កំហុសនៅក្នុងការវិនិច្ឆ័យ

វគ្គបំណងទី៥. *បកស្រាយពីទំនាក់ទំនងនៃបញ្ហាផ្សេងៗ ជាមួយនឹងការវិនិច្ឆ័យដែលខុសឆ្គង។*

"ប្រសិនបើខ្ញុំបើកបរក្នុងល្បឿនយឺតជាងនេះបន្តិច ឧបទ្ទវហេតុនេះប្រហែលមិនអាចកើតឡើងបាននោះទេ"!

"ប្រសិនបើខ្ញុំប្រុងប្រយ័ត្នជាងនេះ ខ្ញុំប្រហែលជាមិនរអិលដួលនោះទេ"!

"ប្រសិនបើខ្ញុំបានដឹងរឿងទាំងអស់មុន ខ្ញុំប្រហែលជាអាចនឹងធ្វើការសម្រេចចិត្តបានត្រឹមត្រូវមិនខាន"!

តើអ្នកធ្លាប់បានដឹងខ្លួនឯងថាបាននិយាយពាក្យទាំងនេះ ក្រោយពេលមានអ្វីមួយដែលអ្នកបានធ្វើបង្កទៅជាបញ្ហាដែរឬទេ? នៅពេលដែលធ្វើសកម្មភាពរបស់យើង នោះយើងត្រូវធ្វើការសម្រេចចិត្តជាច្រើន។ មានការសម្រេចចិត្តខ្លះ ទទួលបានផលល្អ ហើយយើងក៏សប្បាយចិត្ត។ មានខ្លះទៀត អាចជាការសម្រេចចិត្តខុស ហើយវាបង្កឲ្យមានបញ្ហាផ្សេងៗ។ វាមិនចាំបាច់ ជាការសម្រេចចិត្តប្រកបដោយបាបនោះទេ ប៉ុន្តែវាអាចបង្កឡើងដោយការមិនប្រុងប្រយ័ត្ន ភាពរឹងរួស ឬ ការបែងចែកអាទិភាពមិនច្បាស់លាស់ ឬ វាប្រហែលជាការគិតគូរយ៉ាងប្រុងប្រយ័ត្ន ។ យើងបានធ្វើការសម្រេចចិត្ត ដែលបានពិចារណាលើអ្វីដែលល្អជាងគេបំផុត ហើយលទ្ធផលគឺមិនដូចជាអ្វីដែលយើងបានរំពឹងទុកទៅវិញ។ ដោយសារតែយើងគ្មានប្រាជ្ញាដ៏ល្អឥតខ្ចោះ យើងច្បាស់ជាធ្វើឲ្យមានកំហុស ម្តងហើយម្តងទៀត។ ទោះបីជានៅក្នុងស្ថានភាពបែបនេះគ្មានជាប់ទាក់ទងជាមួយនឹងអំពើបាបក៏ដោយ យើងក៏ត្រូវតែប្រឈមមុខជាមួយនឹងបញ្ហាដែលកើតឡើងពីវាផងដែរ។

នៅពេលដែលកូនក្មេងកំពុងរៀនដើរ ពួកគេជំពប់ជើង និង ដួលជាច្រើនលើកច្រើនសា។ ប៉ុន្តែពួកគេរៀនពីបទពិសោធន៍របស់គេ ពីរបៀបក្នុងការការពារឲ្យផុតពីការដួលនោះ រហូតដល់ពេលពួកគេអាចគ្រប់គ្រងចលនារបស់ពួកគេបានពេញលេញ ហើយអាចដើរបានដោយមិនដួលសោះ។ ដូចគ្នានេះផងដែរ យើងរៀនពីកំហុសរបស់យើង ក្នុងការផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការដឹងពីការប្រុងប្រយ័ត្នកាន់តែខ្លាំង នៅក្នុងការធ្វើការសម្រេចចិត្តរបស់យើង។ នេះគឺជាដំណើរការនៃការលូតលាស់របស់យើង។

លំហាត់អនុវត្តន៍

---

៧ តើបញ្ហាផ្សេងៗរបស់យើងអាចទាក់ទងទៅនឹងកំហុសនៃការវិនិច្ឆ័យ យ៉ាងដូចម្តេច?

.....

.....

៨ នៅពេលដែលយើងបានបង្កបញ្ហាចំពោះខ្លួនឯង តាមរយៈកំហុសនៃការវិនិច្ឆ័យមួយ តើយើងអាចរៀនបានអ្វីខ្លះពីស្ថានភាពមួយនេះ?

.....

.....

ជម្រើសដែលបានពិចារណាយ៉ាងប្រុងប្រយ័ត្ន

វត្ថុបំណងទី៦. *ជ្រើសរើសយកគំរូល្អៗដែលអ្នកអាចនឹងជ្រើសយក ទោះបីជាអ្នកបានដឹងថាវាអាចនឹងធ្វើឲ្យមានបញ្ហាផ្សេងៗក៏ដោយ។*

មិនមែនគ្រប់ជម្រើសដែលបង្កឲ្យមានបញ្ហា ទាំងអស់សុទ្ធជាជម្រើសអាក្រក់នោះទេ។ មានពេលខ្លះយើងធ្វើការសម្រេចចិត្តដែលយើងដឹងថាល្អ និងត្រឹមត្រូវ ទោះបីជាវាអាចបង្កឲ្យមានបញ្ហាផ្សេងៗក៏ដោយ។

មានគំរូជាច្រើននៅក្នុងព្រះគម្ពីរ អំពីជម្រើសប្រភេទនេះ។ នៅក្នុងគម្ពីរដានីយ៉ែលជំពូក៣ យើងធ្លាប់បានអានរឿង ដែលនិយាយអំពីបុរសជនជាតិហេប្រឺវ័យក្មេងបីនាក់ ដែល*មិន* ព្រមលត់ជង្គង់ ហើយថ្វាយបង្គំរូបសំណាកមាសរបស់ស្តេចឡើយ ទោះបីជាការសម្រេចចិត្តរបស់ពួកគេអាចនាំឲ្យគេបាត់បង់ជីវិតដ៏ដោយ។ នៅពេលដែលស្តេចបានជ្រាបពីការបដិសេធរបស់ពួកគេ ទ្រង់ក្រោធយ៉ាងខ្លាំង ហើយបញ្ជាឲ្យពួកគេធ្វើការបកស្រាយ។ ខាងក្រោមនេះគឺជាការបកស្រាយរបស់ពួកគេ៖

លោកសាដ្រាក់ លោកមែសាក់ និងលោកអបេឌ-នេកោ ទូលព្រះចៅនេប៊ូក្នេសាវិញថា៖ «ទូលបង្គំយើងខ្ញុំមិនបាច់ឆ្លើយនឹងព្រះករុណាអំពីរឿងនេះទេ។ បពិត្រព្រះរាជា ព្រះដែលទូលបង្គំ យើង ខ្ញុំគោរពបំរើ ពិតជាអាចរំដោះទូលបង្គំយើងខ្ញុំ គឺព្រះអង្គនឹងរំដោះយើងខ្ញុំអោយរួចពីភ្លើងដ៏ សន្ធោសន្ធៅ និងអោយយើងខ្ញុំ រួចពីព្រះហស្តរបស់ព្រះករុណាជាមិនខាន។ ទោះបីព្រះអង្គមិនរំដោះយើងខ្ញុំក្តី សូមព្រះករុណាជ្រាបអោយបានច្បាស់ថា ទូលបង្គំយើងខ្ញុំមិនព្រមគោរពបំរើ ព្រះទាំងប៉ុន្មានរបស់ព្រះករុណាឡើយ ហើយយើងខ្ញុំក៏មិនព្រមក្រាបថ្វាយបង្គំរូបបដិមាមាសដែលព្រះករុណាបានកសាងនេះដែរ! (គម្ពីរដានីយ៉ែល ៣:១៦-១៨)

នៅក្នុងរឿងនេះ ព្រះជាម្ចាស់ *បាន* សង្គ្រោះពួកគេពីសេចក្តីស្លាប់ ក្នុងនាមជាបន្ទាល់សម្រាប់ឫទ្ធានុភាពរបស់ទ្រង់ ប៉ុន្តែបុរសទាំងបីនាក់នេះ ក៏សុខចិត្តស្លាប់ ជាជាងការមិនស្តាប់បង្គាប់ព្រះជាម្ចាស់ផងដែរ។

នៅក្នុងព័ន្ធកិច្ចទាំងមូលរបស់លោកប៉ូល លោកបានជ្រើសរើសចែកចាយដំណឹងល្អ ទោះបីវាបាននាំឲ្យមានការបៀតបៀនក៏ដោយ។ មានគ្រាមួយដែលលោកកំពុងចែកចាយនៅក្រុងលីស្ត្រា ហើយមហាជនបានខឹងយ៉ាងខ្លាំង ដល់ថ្នាក់គប់លោកនឹងដុំថ្ម ហើយអូសលោកយកទៅក្រៅក្រុងថែមទៀតផង ដោយពួកគេបានគិតថាលោកបានស្លាប់បាត់ទៅហើយ (គម្ពីរកិច្ចការ ១៤:១៩)។

លំហាត់អនុវត្តន៍

៩ ចូរអានគម្ពីរកិច្ចការ ១៤:២០-២១។ តើលោកប៉ូលបានធ្វើអ្វីទៀត ក្រោយពេលដែលត្រូវបានគេគប់នឹងដុំថ្ម និង ទុកចោលឲ្យស្លាប់រួចមក?

.....

.....

១០ តើលោកប៉ូលបាននិយាយអ្វីខ្លះ ទៅកាន់ពួកសាវ័កផ្សេងៗទៀតនៅក្នុងខគម្ពីរនោះ (គម្ពីរកិច្ចការ ១៤:២២)?

.....

.....

ការសម្រេចចិត្តរបស់លោកប៉ូល ក្នុងការចែកចាយទោះបីជាត្រូវទទួលបានការបៀតបៀនក៏ដោយ ហើយលទ្ធផលចុងក្រោយ គាត់ត្រូវបានគេចាប់ដាក់គុក អស់រយៈពេលយ៉ាងយូរ។ ទីបំផុត លោកត្រូវបានសម្លាប់ ដោយពួកអ្នកដែលស្អប់ដំណឹងល្អ។ ពាក្យរបស់លោកនៅក្នុងគម្ពីរភីលីព ១:១២-១៤ គឺពិតជាបានលើកទឹកចិត្តយើងខ្លាំងណាស់៖

> បងប្អូនអើយ ខ្ញុំចង់អោយបងប្អូនជ្រាបថា ហេតុការណ៍ដែលកើតមានដល់ខ្ញុំនោះ បែរជាជួយដំណឹងល្អវិញទេ គឺនៅក្នុងសាលាកាត់ក្តីទាំងមូល និងនៅគ្រប់ទីកន្លែងឯទៀតៗមនុស្សម្នាបានឃើញយ៉ាងច្បាស់ថា ខ្ញុំជាប់ឃុំឃាំងព្រោះតែព្រះគ្រិស្ត។ ដោយឃើញខ្ញុំជាប់ឃុំឃាំងដូច្នេះ បងប្អូនភាគច្រើនទុកចិត្តលើព្រះអម្ចាស់ ហើយរឹតតែមានចិត្តក្លាហានប្រកាសព្រះបន្ទូលឥតភ័យខ្លាចអ្វីឡើយ។

ប្រវត្តិសាស្ត្រនៃក្រុមជំនុំបានផ្តល់ជាឧទាហរណ៍យ៉ាងច្រើនអំពីគ្រិស្តបរិស័ទដែលបានជ្រើសរើសការរងទុក្ខ និង ការស្លាប់ ជាជាងការលះបង់ទីបន្ទាល់គ្រិស្តបរិស័ទរបស់ពួកគេ។ មានគំរូជាច្រើនទៀតនៃបេសកជនដូចជាលោក ចីម អ៊ីឡត ដែលលោកបានស្លាប់នៅក្នុងកណ្តាប់ដៃ ជនជាតិភាគតិច អរកា ដែលជាកុលសម្ព័ន្ធមួយនៅអាមេរិកខាងត្បូង ដែលលោកខំនាំដំណឹងល្អទៅកាន់ពួកគេនោះ។ ការជ្រើសរើសរបស់លោក គឺត្រូវបានបង្ហាញ ឲ្យឃើញច្បាស់នៅក្នុងពាក្យទាំងនេះ ដែលលោកបានសរសេរយ៉ាងខ្លីក្នុងពេលដែលលោកជិតស្លាប់៖

> *អ្នកដែលឲ្យ អ្វីដែលគាត់មិនអាចទុកដើម្បីចំណេញ និង អ្វីដែលគាត់មិនអាចបាត់បង់ផង នោះមិនមែនជាមនុស្សល្ងង់ទេ។*

លោក ចីម អ៊ីឡត សុខចិត្តជ្រើសរើសយក តម្លៃដែលអស់កល្បជានិច្ច ជាជាងផលប្រយោជន៍ដែលបានភ្លាមៗ ពីតម្លៃនៃលោកីយ៍នេះ។ ជាលទ្ធផល តាមរយៈការស្លាប់របស់លោក ចីម បានធ្វើឲ្យប្រពន្ធរបស់គាត់ អ្នកស្រីអេលីសាបែត អាចឈោងចាប់កុលសម្ព័ន្ធ អរកា ជាមួយនឹង សន្ត រ៉ាដែល ដែលប្អូនប្រុសរបស់គាត់ឈ្មោះថា នេត ក៏ជាទុក្កបុគ្គល (អ្នកស្លាប់ដោយសាសនារបស់ខ្លួន) ជាមួយនឹងលោកចីម អ៊ីឡត ។ មានសមាជិកជាច្រើននៅក្នុងកុលសម្ព័ន្ធបានទទួលយកព្រះគ្រិស្តជាព្រះសង្គ្រោះដោយផ្ទាល់របស់ពួកគេ ដោយបានឃើញពីការប្តេជ្ញាលះបង់របស់ស្ត្រីទាំងពីររូបនេះ។

> ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា គ្រាប់ស្រូវធ្លាក់ដល់ដី ហើយបើមិនងាប់ទេ គ្រាប់នោះនៅតែមួយដដែល។ ផ្ទុយទៅវិញ បើគ្រាប់ស្រូវនោះងាប់វានឹងបង្កើតផលបានច្រើន។ អ្នកណាស្រឡាញ់ជីវិតរបស់ខ្លួន អ្នកនោះនឹងបាត់បង់ជីវិតទៅ រីឯអ្នកដែលមិនជំពាក់ចិត្តនឹងជីវិត របស់ខ្លួន ក្នុងពិភពលោកនេះទេនឹងរក្សាជីវិតខ្លួនអោយនៅស្ថិតស្ថេរអស់កល្បជានិច្ច។
> (គម្ពីរយ៉ូហាន ១២:២៤-២៥)

លំហាត់អនុវត្តន៍

---

១១ តើជម្រើសមួយណា នៅខាងក្រោមនេះ ដែលអ្នកអាចគិតថា ជាការជម្រើសល្អ ទោះបីជាវាអាចនឹងបង្កឲ្យមានបញ្ហាផ្សេងៗក៏ដោយ? ចូរគូសរង្វង់នៅជុំវិញអក្សរនៅខាងមុខប្រយោគដែលអ្នកជ្រើសរើស។

ក) អ្នកជ្រើសរើស ការពារមិត្តភក្តិម្នាក់ដែលបានប្រព្រឹត្តបទឧក្រិដ្ឋមួយ ដោយប្រាប់ថា គាត់បាននៅជាមួយអ្នកស្របពេលដែលហេតុការណ៍នោះកើតឡើង។

ខ) អ្នកជ្រើសរើសបញ្ចប់ទំនាក់ទំនងស្នេហា ដែលអាចធ្វើឲ្យអ្នកឈានទៅរកការរៀបអាពាហ៍ពិពាហ៍ជាមួយនឹងអ្នកមិនជឿម្នាក់ ទោះបីជាអ្នកស្រឡាញ់មនុស្សម្នាក់នោះខ្លាំងយ៉ាងណាដ៏ដោយ។

គ) អ្នកជ្រើសរើសការអោនក្បាលអរព្រះគុណព្រះជាម្ចាស់សម្រាប់អាហារ មុនពេលដែលអ្នក បរិភោគ ទោះបីជាមានអ្នកមិនជឿនៅទីនោះដែលអាចសើចចំអកអ្នកក៏ដោយ។

ឃ) អ្នកធ្វើការសម្រេចចិត្តដោយមិនបានដឹងពីរឿងរ៉ាវសំខាន់ ទាំងអស់ជាមុនសិន។

ឃ. លទ្ធផលនៃការយកព្រះហឫទ័យទុកជាក់របស់ព្រះជាម្ចាស់សម្រាប់យើង

វត្ថុបំណងទី៧. *រៀបរាប់ពីភាពខុសគ្នារវាងគោលបំណងរបស់សាតាំងដែលវាល្បួង និង បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលសាកល្បងយើង។*

តើហេតុអ្វីបានជាព្រះដែលល្អ អនុញ្ញាតឲ្យមនុស្សរបស់ទ្រង់រងទុក្ខយ៉ាងដូច្នេះ? បើទ្រង់ពិតជា ខ្វល់ព្រះទ័យអំពីពួកយើងមែន ហេតុអ្វីបានជាទ្រង់មិនសង្គ្រោះយើងឲ្យផុតពីគ្រប់បញ្ហារបស់យើងតែម្តងទៅ? នៅពេលដែលបញ្ហារបស់អ្នក ហាក់បីដូចជាលើសពីសមត្ថភាពរបស់អ្នក តើអ្នកធ្លាប់សួរសំណួរបែបនេះដែរឬទេ ?

ពេលខ្លះព្រះជាម្ចាស់ក៏បានសង្គ្រោះយើង ឲ្យផុតពីបញ្ហាដែរ។ យើងបានឃើញរួចមកហើយពីរបៀបដែលទ្រង់បានសង្គ្រោះបុរសជនជាតិហេប្រឺ ពីឡភ្លើងដែលឆេះយ៉ាងសន្ធោសន្ធៅនោះហើយ។ អ្នកក៏អាចនឹងធ្លាប់ ទទួលបានការប្រោសឲ្យជាពីជំងឺយ៉ាងអស្ចារ្យ ឬ ព្រះជាម្ចាស់ធ្លាប់បានបំពេញតម្រូវការរបស់អ្នកតាមរបៀបមួយដែលអ្នកមិនបានរំពឹងទុកជាមុន ឬ មិនអាចបកស្រាយបានផង
ដែរ។ យើងអរសប្បាយនៅពេលដែលការនេះកើតឡើង ប៉ុន្តែយើងអាចដឹងពីការនេះ នៅពេលណាដែលព្រះជាម្ចាស់អនុញ្ញាតឲ្យមានការឈឺចុក្ខកើតឡើង។ ទ្រង់មិនធ្វើដូច្នេះដោយសារតែទ្រង់សប្បាយព្រះទ័យជាមួយនឹងទុក្ខលំបាករបស់យើងនោះទេ ប៉ុន្តែដោយសារតែទ្រង់ខ្វល់ពីយើង ហើយព្រះហឫទ័យខ្វល់ខ្វាយរបស់ទ្រង់ គឺលើសពីបញ្ហាក្នុងមួយរយៈពេលខ្លីរបស់យើង។ សូមមើលពីមូលហេតុខ្លះៗដែលព្រះជាម្ចាស់ទ្រង់អនុញ្ញាតឲ្យយើងឆ្លងកាត់បញ្ហាជាច្រើននោះ។

ដើម្បីបន្សុទ្ធយើង និង បញ្ជាក់ពីជំនឿរបស់យើង

មានរឿងដំណាលពី ស្ពានផ្លូវរថភ្លើងមួយដែល ចាស់ និង ទ្រុឌទ្រោម។ វាពិតជាប្រឈមមុខនឹងការដួលរលំ ប្រសិនបើមានរថភ្លើងឆ្លងកាត់លើវា ដូច្នេះហើយក្រុមហ៊ុនផ្លូវរថភ្លើងនោះក៏បានសាងសង់វាសាជាថ្មីឡើងវិញទាំងស្រុង ដើម្បីធ្វើឲ្យវាមានសុវត្ថិភាព និង រឹងមាំ។ នៅពេលដែលការងារសាងសង់បញ្ចប់ កម្មវិធីឧទ្ទិសមួយ បានប្រកាសជូនសមាគមន៍ទាំងមូល។ ចំណុចដែលសំខាន់ នៅក្នុងកម្មវិធីនោះគឺនៅពេលដែលមានរថភ្លើង *ពីរគ្រឿង* ឆ្លងកាត់ស្ពាននោះក្នុងពេលតែមួយ។ តើអ្នកទទួលខុសត្រូវនោះ គេព្យាយាមធ្វើឲ្យស្ពាននោះរលំ ឬយ៉ាងណា? ទេ ! ពួកគេប្រាកដក្នុងចិត្តណាស់ ថាវានឹងមិនរលំទេ។ គោលបំណងរបស់ពួកគេគឺបញ្ជាក់បង្ហាញទៅកាន់មនុស្សក្នុងសហគមន៍ថា ឥឡូវនេះស្ពាននេះវារឹងមាំណាស់ ហើយមិនដួលរលំនៅពេលមានសម្ពាធនោះទេ។

មានចំណុចសំខាន់មួយនៅត្រង់នេះ។ តើព្រះជាម្ចាស់កំពុងបញ្ឆោតយើងមែនទេ? អត់ទេ! តើព្រះជាម្ចាស់កំពុងសាកល្បងយើងមែនទេ? ប្រាកដណាស់! រវាង *ការបញ្ឆោត* នរណាម្នាក់ឲ្យធ្វើអំពើអាក្រក់ និង *ការសាកល្បង* អ្វីមួយដើម្បីបង្ហាញពីគុណភាពល្អរបស់វា គឺពិតជាមានភាពខុសគ្នាដាច់ស្រឡះ។

លំហាត់អនុវត្តន៍

១២ ចូរអានគម្ពីរយ៉ាកុប ១:២-៤ និង គម្ពីរយ៉ាកុប ១២:១៧ ហើយឆ្លើយសំណួរទាំងអស់នេះ៖

ក) តើគ្រិស្តបរិស័ទគួរតែប្រឈមមុខជាមួយនឹងបញ្ហារបស់គេដោយរបៀបណា?.....

ខ) តើហេតុអ្វីបានជាគេមានឥរិយាបថយ៉ាងដូច្នេះ? .....

.....

គ) តើព្រះជាម្ចាស់បោកបញ្ឆោតឲ្យយើងធ្វើអាក្រក់មែនទេ?

.....

ឃ) តើនរណាជាអ្នកទទួលខុសត្រូវចំពោះអំពើអាក្រក់ដែលយើងធ្វើ? (សូមមើលនៅក្នុងគម្ពីរយ៉ូហាន ១៧:១៥)

.....

.....

មានមូលហេតុមួយ ក្នុងការបង្គាប់ឲ្យយើងរាល់គ្នាមានអំណរ ទោះបីនៅក្នុងពេលដែលមានបញ្ហាក៏ដោយ។ គម្ពីរនេហេមា ៨:១០ បានផ្តល់មូលហេតុមួយសម្រាប់យើង៖ "មិនត្រូវកើតទុក្ខព្រួយឡើយ ព្រោះអំណរដែលមកពីព្រះអម្ចាស់ ជាកម្លាំងរបស់អ្នករាល់គ្នា"។ អំណាររបស់យើងនៅក្នុងព្រះអម្ចាស់ បានផ្តល់កម្លាំងឲ្យយើងដើម្បីស៊ូទ្រាំ និងយកឈ្នះលើបញ្ហារបស់យើងបាន។

លំហាត់អនុវត្តន៍

១៣ ចូរអានគម្ពីរ១ ពេត្រុស ១:៦-៧។ ខគម្ពីរនេះ ក៏បានប្រាប់យើងឲ្យអរសប្បាយ ទោះបីជាយើងមានទុក្ខសោកនៅក្នុងគ្រប់បញ្ហាគ្រប់បែបយ៉ាង។ តើអ្វីជា គោលបំណងនៃបញ្ហាទាំងអស់នេះ ?

.....

.....

លោកពេត្រុសក៏បានប្រាប់នៅក្នុងខគម្ពីរនេះដែរ អំពីមាសដែលត្រូវបានសាកល្បង និង បន្សុទ្ធ ឬ ចំរាញ់ ដោយដុតវាជាមួយភ្លើង ប៉ុន្តែគេមិនអាចបំផ្លាញវាបានឡើយ។ ជំនឿរបស់យើងគឺល្អប្រសើរជាងមាសទៅទៀត ដោយសារតែតម្លៃដ៏អស់កល្បរបស់វា និង ដោយវាត្រូវបានបន្សុទ្ធ ឬចំរាញ់ ដោយបញ្ហាដែលយើងបានឆ្លងកាត់។

ទោះបីជាព្រះជាម្ចាស់អនុញ្ញាតឲ្យយើងឆ្លងកាត់ការសាកល្បង ទ្រង់ក៏សន្យាថានឹងគង់នៅជាមួយយើងផងដែរ។ នៅក្នុងគម្ពីរ១កូរិនថូស ១០:១៣ យើងបានរកឃើញរឿងទាំងនេះ៖

១. ព្រះជាម្ចាស់ នឹងមិនអនុញ្ញាតឲ្យយើងទទួលការសាកល្បងដែលលើសពីកម្លាំងរបស់យើង ក្នុងការទ្រាំទ្របាននោះទេ (ការខិតខំព្យាយាម និង ស្មោះត្រង់) ។

២. ទ្រង់នឹងប្រទានកម្លាំងឲ្យយើង ដើម្បីតស៊ូជាមួយនឹងបញ្ហារបស់យើង។

៣. ទ្រង់នឹងប្រទានមធ្យោបាយ ដើម្បីឲ្យយើងអាចគេចផុតពីបញ្ហារបស់យើងបាន។
(ដំណោះស្រាយ)

លំហាត់អនុវត្តន៍

---

១៤ ដោយយោងទៅតាម ខគម្ពីរទាំងនេះ សូមធ្វើការបកស្រាយសំណួរខាងក្រោម៖

ក) តើគោលបំណងរបស់សាតាំងក្នុងការល្បួងយើង គឺជាអ្វី?

.....

ខ) តើអ្វី ជាគោលបំណងរបស់ព្រះជាម្ចាស់ក្នុងការសាកល្បងយើង។

.....

ដើម្បីឲ្យមានសណ្ឋានរបស់ព្រះគ្រិស្តនៅក្នុងយើង

វត្ថុបំណងទី៨. *កំណត់សារដែលនៅក្នុងគម្ពីរ៉ូម៨:១៧,២៨-២៩ ដែលទាក់ទងទៅនឹងបញ្ហាដែលយើងប្រឈមមុខ។*

បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ សម្រាប់អ្នក និង ខ្ញុំ គឺឲ្យយើងបានក្លាយដូចជាព្រះយេស៊ូ។ ជីវិតមួយនេះ គឺជាការរៀបចំ សម្រាប់ជីវិតដ៏អស់កល្បជានិច្ចរបស់យើង នៅឯនគរស្ថានសួគ៌ ហើយព្រះជាម្ចាស់គឺសព្វព្រះហឫទ័យនឹងជួយយើង ឲ្យពេញវ័យនៅក្នុងជីវិតជាគ្រិស្តបរិស័ទរបស់យើង ដើម្បីឲ្យយើងបានកាន់តែដូចជាព្រះគ្រិស្ត។ ប្រសិនបើយើងចូលទៅប្រឈមមុខជាមួយបញ្ហារបស់យើង ដោយឥរិយាបថត្រឹមត្រូវ ទ្រង់នឹងប្រើប្រាស់វា សម្រាប់ផលប្រយោជន៍របស់យើង ដើម្បីនឹង អភិវឌ្ឍឲ្យមានលក្ខណៈរបស់ព្រះគ្រិស្តនៅក្នុងយើង។

ខ្ញុំនឹកចាំពីស្ត្រីពីរនាក់ ដែលពួកគាត់ម្នាក់ៗត្រូវមើលថែទាំ សាច់ញាតិដែលឈឺជិតស្លាប់ អស់រយៈពេលយ៉ាងយូរ។ មានស្ត្រីម្នាក់ ប្រែទៅជាតូចចិត្ត និង ទៅជាមនុស្សដែលរអ៊ូរទាំ អាណិតខ្លួនឯង។ គ្មាននរណាម្នាក់ចង់នៅក្បែរនាងនោះទេ។ ចំណែកឯស្ត្រីម្នាក់ទៀត នាងក៏គិតថា បញ្ហារបស់នាងក៏ពិបាកទ្រាំទ្រដែរ តែនាងបែរជាចេះអត់ធ្មត់ ជាមនុស្សពេញដោយក្តីស្រឡាញ់ និង ជាទីបន្ទាល់នៃព្រះគុណរបស់ព្រះជាម្ចាស់ ដើម្បីផ្តល់កម្លាំងនិង អំណរ ទោះបីនៅក្នុងពេលដែលមានការលំបាកយ៉ាងណាក្តី។ នាងបានកែប្រែបញ្ហារបស់នាងឲ្យទៅជាជ័យជម្នះ ដោយអនុញ្ញាតឲ្យវាបង្កើតបុគ្គលិកលក្ខណៈរបស់ព្រះគ្រិស្តនៅក្នុងនាង។

លំហាត់អនុវត្តន៍

១៥ ចូរអានគម្ពីររ៉ូម ៨:១៧, ២៨-២៩ ហើយជ្រើសរើស ប្រយោគដែលបង្ហាញយ៉ាងត្រឹមត្រូវ អំពីសារដែលត្រូវបានលើកឡើង នៅក្នុងខគម្ពីរទាំងនោះ។

ក) ប្រសិនបើយើងស្រឡាញ់ព្រះជាម្ចាស់ ទ្រង់នឹង អនុញ្ញាតឲ្យមានតែការល្អកើតឡើងនៅក្នុងជីវិតយើងតែប៉ុណ្ណោះ។

ខ) អស់អ្នកណាស្រឡាញ់ព្រះជាម្ចាស់ និង មានជំនឿក្នុងទ្រង់ ក្នុងការដឹកនាំពួកគេ នោះនឹងទទួលបានប្រយោជន៍ខាងឯវិញ្ញាណ តាមរយៈបញ្ហាដែលពួកគេឆ្លងកាត់។

គ) ផ្នែកមួយនៃដំណើរការ ធ្វើខ្លួនឲ្យមានសណ្ឋានដូចជាព្រះគ្រិស្ត គឺជាការចែករំលែកជាមួយ ទុក្ខលំបាករបស់ទ្រង់។

ឃ) នៅក្នុងការធ្វើការសម្រាប់រឿងល្អៗដែលកើតឡើងចំពោះយើង បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺដើម្បីធ្វើឲ្យយើងបានដូចជាបុត្ររបស់ទ្រង់។

លោកប៉ូលបានបង្ហាញ យ៉ាងច្បាស់ៗនៅក្នុង គម្ពីរ២កូរិនថូស ៤:៧-១០៖

> យើងមានមុខងារដ៏ប្រសើរនេះ ប្រៀបបីដូចជាឆ្នាំងដីដែលមានកំណប់នៅខាងក្នុង ដើម្បីអោយមនុស្សលោកឃើញថា ឫទ្ធានុភាពដ៏ប្រសើរខ្ពង់ខ្ពស់នេះជាឫទ្ធានុភាពរបស់ព្រះជាម្ចាស់ មិនមែនជារបស់យើងទេ។ គេសង្កត់សង្កិនយើងគ្រប់យ៉ាងមែន តែយើងមិនភ័យបារម្ភអ្វីឡើយ យើងទ័លច្រកមែន តែយើងនៅតែទៅមុខរួច គេបៀតបៀនយើងមែន តែព្រះជាម្ចាស់មិនបោះបង់យើងចោលឡើយ គេវាយដំយើងមែន តែយើងមិនស្លាប់បាត់បង់ជីវិតឡើយ។ ក្នុងរូប កាយយើង យើងផ្ទុកសេចក្តីឈឺចាប់របស់ព្រះយេស៊ូជានិច្ច ដើម្បីអោយគេឃើញព្រះជន្មរបស់ ព្រះអង្គនៅក្នុងរូបកាយយើង។
>
> វាគឺជាឫទ្ធានុភាពរបស់ព្រះជាម្ចាស់ដែលនៅក្នុងយើងទេ ដែលធ្វើឲ្យយើងអាចទ្រាំទ្របន្ទុករបស់យើងបាន ដោយមិនចុះចាញ់ មិនអស់សង្ឃឹម ឬ ត្រូវខ្ទិចខ្ទាំនោះ។ ហើយគោលបំណងនៃការនេះ គឺថាព្រះយេស៊ូអាចបង្ហាញអង្គទ្រង់នៅក្នុងយើងរាល់គ្នា! ពិតជាជ័យជម្នះមួយដ៏ថ្លៃថ្លាណាស់!

ដើម្បីធ្វើឲ្យយើងអាចជួយអ្នកដទៃ

វត្ថុបំណងទី៩. *បកស្រាយពីរបៀបដែលការសោកល្វងរបស់យើង អាចជាប្រយោជន៍សម្រាប់ទំនាក់ទំនង របស់យើងជាមួយនឹងមនុស្សដទៃ និង ជាមួយព្រះជាម្ចាស់។*

មូលហេតុមួយទៀត ដែលព្រះជាម្ចាស់អនុញ្ញាតឲ្យយើងស៊ូទ្រាំនឹងការលំបាក គឺដើម្បីជួយយើងក្នុងការឆ្លើយតបឲ្យបានកាន់តែប្រសើរ ជាមួយនឹងតម្រូវការរបស់អ្នកដទៃ។ នរណាដែលធ្លាប់តែឯកា អាចស្វែងរកអ្នកដទៃទៀតដែលឯកាដូចគ្នា។ ឪពុកម្តាយដែលមានកូនធ្លាប់រងទុក្ខ ពួកគាត់មានចិត្តអាណិតមេត្តាខ្លាំងចំពោះឪពុកម្តាយដែលមានកូនកំពុងរងទុក្ខដូចគ្នា។ យើងត្រូវបានគេស្គាល់ រួមជាមួយអស់អ្នកដែលបានឆ្លងកាត់បញ្ហាដូចគ្នានឹងយើងដែរ។ ទីបន្ទាល់ផ្ទាល់ខ្លួនរបស់យើង អំពីឫទ្ធានុភាព និង ព្រះពរ

របស់ព្រះជាម្ចាស់ នៅពេលដែលយើងឆ្លងកាត់ការលំបាក នឹងជួយឲ្យអ្នកដទៃសំឡឹងមើលទៅកាន់ទ្រង់ និង មិនអស់សង្ឃឹមនោះទេ។ លោកប៉ូលបានបង្ហាញពីរឿងនេះ នៅក្នុងគម្ពីរ ២កូរិនថូស ១:៣-៤៖

> "សូមលើកតម្កើងព្រះជាម្ចាស់ ជាព្រះបិតារបស់ព្រះយេស៊ូ ជាអម្ចាស់នៃយើង។ ព្រះអង្គជាព្រះបិតាប្រកបដោយព្រះហឫទ័យមេត្តាករុណា និងជាព្រះដែលជួយសំរាលទុក្ខគ្រប់បែបយ៉ាងទាំងអស់។ ព្រះអង្គសំរាលទុក្ខយើង នៅពេលយើងមានទុក្ខវេទនាសព្វបែបយ៉ាង ដើម្បីអោយ យើងអាចសំរាលទុក្ខអស់អ្នកដែលមានទុក្ខវេទនា ព្រោះព្រះជាម្ចាស់ប្រទានអោយយើងផ្ទាល់បានធូរស្បើយរួចហើយដែរ។"

លំហាត់អនុវត្តន៍

---

១៦ ចូរជ្រើសរើសចម្លើយដែលត្រឹមត្រូវ។ គម្ពីរ២កូរិនថូស ១:៣-៤ បង្ហាញយើងថា

ក) ព្រះជាម្ចាស់មានបំណងព្រះទ័យនាំបញ្ហាឲ្យកើតមានលើយើង ដើម្បីឲ្យយើងនឹងអាចជួយអ្នកដទៃដែលមានបញ្ហាដូចគ្នានោះដែរ។

ខ) ព្រះជាម្ចាស់ខ្វល់ព្រះទ័យនឹងយើង ពេលដែលយើងមានទុក្ខលំបាក ហើយទ្រង់សព្វព្រះទ័យឲ្យយើងបានមានការខ្វល់ខ្វាយចំពោះអ្នកដទៃដូចគ្នាដែរ។

ដើម្បីបង្រៀនយើងឲ្យពឹងផ្អែកលើទ្រង់

ខ្ញុំបានឮគ្រិស្តបរិស័ទជាច្រើន បង្ហាញអារម្មណ៍ថា បន្ទុកដែលពួកគេកំពុងរែក មិនអាចនឹងរែកតែម្នាក់ឯងបានទេ ប៉ុន្តែពួកគេបានដឹងពីកម្លាំង និង ជំនួយរបស់ព្រះជាម្ចាស់នៅក្នុងបញ្ហានោះផងដែរ។ រឿងនេះត្រូវបានបញ្ជាក់នៅក្នុង គម្ពីរ១ពេត្រុស ៥:៧ ៖ "ចូរផ្ទេរទុក្ខកង្វល់ទាំងប៉ុន្មានរបស់បងប្អូនទៅព្រះអង្គទៅ ដ្បិតទ្រង់យកព្រះហឫទ័យទុកដាក់នឹងបងប្អូន។"

លោកសាវ័កប៉ូល បានស្គាល់ពីគុណប្រយោជន៍នៃការរងទុក្ខលំបាកនេះ នៅក្នុងគម្ពីរ ២កូរិនថូស ១:៨-១០៖

> បងប្អូនអើយ យើងចង់អោយបងប្អូនជ្រាបយ៉ាងច្បាស់អំពីទុក្ខវេទនាដែលកើតមានដល់យើងនៅស្រុកអាស៊ីនេះ។ យើងបានរងទុក្ខយ៉ាងខ្លាំងហួសពីកម្លាំងដែលយើងអាចទ្រាំបាន រហូតដល់យើងអស់សង្ឃឹមថានឹងរស់រានមានជីវិតតទៅមុខទៀតផង។ យើងនឹកក្នុងចិត្តថា គេនឹងដាក់ទោសយើងដល់ស្លាប់។ រឿងនេះកើតឡើង ដើម្បីកុំអោយយើងពឹងផ្អែកលើខ្លួនឯង គឺពឹងផ្អែកលើព្រះជាម្ចាស់ ដែលប្រោសមនុស្សស្លាប់អោយរស់ឡើងវិញ។ ព្រះអង្គបានរំដោះយើងអោយរួចផុតពីការស្លាប់ដ៏សែនវេទនានេះ ហើយព្រះអង្គក៏នឹងរំដោះយើងតទៅមុខទៀតដែរ។ ពិតមែនហើយយើងសង្ឃឹមថា ព្រះអង្គនឹងរំដោះយើងទៀតជាមិនខាន។

លោកប៉ូលបានដឹងថា លោកអាចពឹងផ្អែកលើព្រះជាម្ចាស់បាន មិនត្រឹមតែសម្រាប់បញ្ហាក្នុងអតីតកាលនោះទេ ប៉ុន្តែនៅទុក្ខលំបាកនាថ្ងៃអនាគតផងដែរ។

លំហាត់អនុវត្តន៍

១៧ ចូរប្រៀបធៀបគម្ពីរ២កូរិនថូស ១:៨-១០ ជាមួយនឹង គម្ពីរ១កូរិនថូស ១០:១៣។ តើមានសេចក្តីពិតអ្វី ដែលបានបញ្ជាក់នៅក្នុងខគម្ពីរទាំងពីរនោះ?

.....

.....

១៨ តើបញ្ហាមានប្រយោជន៍យ៉ាងដូចម្តេច សម្រាប់ទំនាក់ទំនងរបស់យើងជាមួយនឹងអ្នកដទៃ ព្រមទាំងព្រះជាម្ចាស់ផងនោះ?

.....

.....

១៩ ដោយលំហាត់នេះ ជាលំហាត់ចុងក្រោយនៅក្នុងមេរៀននេះ ចូរធ្វើតារាងនិយាយអំពីបញ្ហាដែលយើងកំពុងប្រឈមមុខក្នុងពេលនេះ។ បន្ទាប់មក មើលទៅក្នុងមេរៀន ហើយរកមើលថាអ្នកអាចស្គាល់ពីប្រភពនៃបញ្ហានីមួយៗបានដែរឬទេ? ចូរសរសេរប្រភពបញ្ហា នៅក្បែរបញ្ហានីមួយៗ ។ នៅពេលដែលយើង ចូលទៅក្នុងមេរៀនបន្ទាប់ អ្នកនឹងចាប់ផ្តើមឃើញពីមធ្យោបាយស្វែងរកដំណោះស្រាយ សម្រាប់បញ្ហារបស់អ្នក។

នៅក្នុងមេរៀននេះ យើងបានសិក្សាអំពីប្រភពនៃបញ្ហា។ យើងបានឃើញថា វត្តមាននៃអំពើអាក្រក់នៅក្នុងពិភពលោកនេះគឺជាឫសគល់ នៃបញ្ហារបស់យើង ប៉ុន្តយើងអាចប្រែបញ្ហារបស់យើងឲ្យទៅជាជ័យជម្នះបាន ដោយអនុញ្ញាតឲ្យព្រះជាម្ចាស់ ធ្វើការនៅក្នុងយើងឲ្យបានល្អ តាមរយៈបញ្ហាទាំងនោះ និង កែច្នៃយើងឲ្យទៅជាក្នុងសណ្ឋានរបស់ព្រះគ្រិស្ត និង ធ្វើឲ្យយើងទៅជាបាវបម្រើដ៏មានប្រយោជន៍របស់ព្រះជាម្ចាស់។

នៅក្នុងមេរៀនបន្ទាប់ យើងនឹងមើលទៅលើរបៀបដែលគ្រិស្តបរិស័ទ ចូលទៅកាន់ការដោះស្រាយបញ្ហា និង អំពីធនធានដែលព្រះជាម្ចាស់បានប្រទានឲ្យយើងដើម្បីប្រឈមមុខជាមួយបញ្ហារបស់យើង ក្នុងរបៀបវិជ្ជមាន ដើម្បីឲ្យព្រះនាមរបស់ទ្រង់បានថ្កើងឡើងនៅក្នុងគ្រប់អ្វីៗដែលយើងធ្វើ។

ការប្រឡងផ្ទាល់ខ្លួនឯង

សំណួរពហុជម្រើសៗ ចូរជ្រើសរើសចម្លើយ ដែលសំក្តិសមបំផុតសម្រាប់សំណួរខាងក្រោយ។

១ លោកអដាំ និង នាងអេវ៉ាគ្មាន.....សោះឡើយ រហូតដល់ពេលដែលពួកគេលែងស្តាប់បង្គាប់ព្រះជាម្ចាស់។
   ក) ជម្រើស
   ខ) បញ្ហា
   គ) ការរួបរួមជាព្រះជាម្ចាស់
   ឃ) ការវិនិច្ឆ័យ

២ យើងអាចបញ្ឈៀសបញ្ហាដែលបង្កឡើងដោយអំពើបាបផ្ទាល់ខ្លួនបានដោយ
   ក) ស្តាប់បង្គាប់ព្រះជាម្ចាស់ និង ព្រះបន្ទូលរបស់ទ្រង់។
   ខ) ធ្វើអ្វីៗដែលយើងមានអារម្មណ៍ថាត្រឹមត្រូវ
   គ) ធ្វើតាមគំរូរបស់លោកអដាំ

៣ ព្រះគម្ពីរប្រាប់យើងថា យើងនឹងទទួលបានឫទ្ធានុភាពដ៏វិសុទ្ធអស្ចារ្យ នៅពេលដែលយើង ប្រឈមមុខជាមួយបញ្ហារបស់យើងដោយ
   ក) ភាពភ័យខ្លាច
   ខ) ទុក្ខវេទនា
   គ) ការប្តេជ្ញាចិត្ត
   ឃ) អំណរ

៤ បំណងរបស់សាតាំងគឺ
   ក) ជួយយើង
   ខ) សាកល្បងយើង
   គ) ល្បួងយើង
   ឃ) ចំរាញ់យើង

៥ តើប្រយោគណាមួយដែលត្រឹមត្រូវ?
   ក) មនុស្សគ្រប់គ្នាសុទ្ធតែមានទោសនៃបាបផ្ទាល់ខ្លួន។
   ខ) យើងក្លាយជាមនុស្សមានបាបក៏ដោយសារតែអំពើបាបរបស់លោកអដាំ។
   គ) យើងមិនទទួលខុសត្រូវដោយផ្ទាល់ នៅពេលដែលយើងធ្វើអំពើបាបនោះទេ ព្រោះសាតាំងជាអ្នកល្បួងយើងឲ្យធ្វើអំពើបាបនោះ។
   ឃ) មានមនុស្សខ្លះជាមនុស្សមានបាបតាំងពីកំណើតរបស់គេ ហើយមានអ្នកខ្លះទៀតកើតមកជាគ្រិស្តបរិស័ទ ព្រោះឪពុកម្តាយរបស់ពួកគេជាគ្រិស្តបរិស័ទ។

៦ នៅពេលដែលមានរឿងអ្វីមួយកើតឡើង ដែលបណ្តាលឲ្យមានបញ្ហា ដំបូងបំផុតយើងត្រូវតែប្រុងប្រយ័ត្នអំពី

ក) ការឆ្លើយតបដែលខុស

ខ) អ្វីដែលមនុស្សដទៃទៀតនឹងគិត

គ) ភាពសុខសាន្តរបស់ខ្លួនយើង

៧ ពួកសាវ័កប៉ុល និង លោក ថីម អ៊ីឡត ធ្វើទីបន្ទាល់មកកាន់យើងរាល់គ្នា ថាការខ្វល់ខ្វាយធំជាង គេរបស់យើងគួរតែជា

ក) ក្តីរីករាយផ្ទាល់ខ្លួន

ខ) តម្លៃដ៏អស់កល្បជានិច្ច

គ) ការបញ្ចៀសបញ្ហា

ឃ) បំពេញតម្រូវការបច្ចុប្បន្នរបស់យើង

៨ *រក្សាទុក* មានន័យថា

ក) បញ្ចៀសបញ្ហា

ខ) បន្តទៅមុខជាមួយគោលបំណងរបស់អ្នក និង មិនបោះបង់ចោលឡើយ។

គ) ដោះស្រាយបញ្ហារបស់អ្នកដោយការខិតខំប្រឹងប្រែងខ្លួនឯង

ឃ) ចុះចូលជាមួយនឹងសេចក្តីល្បួងរបស់សាតាំង

៩ តើណាមួយខាងក្រោមនេះ មិនមែនជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ក្នុងការសាកល្បងយើង?

ក) ធ្វើឲ្យយើងកាន់តែដូចជាព្រះគ្រិស្ត។

ខ) ចំរាញ់យើង

គ) ល្បួងឲ្យយើងធ្វើអំពើអាក្រក់

ឃ) បន្សុទ្ធយើង

សំណួរផ្ដួផ្ដង តើអ្នកអាចនឹងសំគាល់ប្រភពរបស់បញ្ហានីមួយបានដោយរបៀបណា? ចូរសរសេរ អក្សរ នៃចម្លើយរបស់អ្នកនៅក្នុងចន្លោះបន្ទាត់ នៅពីមុខបញ្ហានីមួយៗខាងក្រោមនេះ។

.....១០ "ខ្ញុំបានគិតថា ខ្ញុំកំពុងធ្វើរឿងត្រឹមត្រូវហើយ នៅពេលដែលខ្ញុំបដិសេធការងារមួយនោះ ប៉ុន្តែឥឡូវនេះខ្ញុំឃើញថា ខ្ញុំគួរតែបានទទួលយកការងារនោះ ព្រោះចៅហ្វាយរបស់ខ្ញុំកំពុងតែបិទជំនួញរបស់គាត់ហើយ។

.....១១ "នៅពេលដែលខ្ញុំមានជំងឺ ខ្ញុំបានចាប់ផ្តើមដឹងថា ខ្ញុំបានធ្វេសប្រហែសចំពោះវេលាផ្ទាល់ខ្លួនសម្រាប់ការអធិស្ឋាន និង សិក្សាព្រះគម្ពីរ។"

.....១២ "គាត់ជួបឧបទ្ទវហេតុមួយ នៅពេលដែលកំពុងបើកបរនៅក្រោមឥទ្ធិពលស្រា"

.....១៣ "ខ្ញុំត្រូវការអាវធំមួយសម្រាប់រដូវរងា ប៉ុន្តែខ្ញុំបានប្រើប្រាក់សន្សំរបស់ខ្ញុំជួយទិញ ព្រះគម្ពីរសម្រាប់គម្រោងរបស់បេសកជន។"

.....១៤ "គាត់បានលួចចម្លងនៅពេលដែលកំពុងប្រឡងហើយមិនត្រូវបានអនុញ្ញាតឲ្យបន្តរៀនទៀតនោះទេ។

.....១៥ " មានការរញ្ជួយដីមួយនៅភូមិស្រុករបស់ខ្ញុំ ហើយមានមនុស្សជាច្រើនបានបាត់បង់ជីវិត"។

.....១៦ "ភូមិស្រុកទាំងមូល បានរងទុក្ខពីការឆ្លងជំងឺអាសន្នរោគ ហើយមនុស្សជាច្រើនបានស្លាប់បាត់បង់ជីវិត។

ក) ពិភពលោកដែលខូតខាតដោយអំពើបាប

ខ) អំពើបាបផ្ទាល់ខ្លួន

គ) ឥទ្ធិពលមកពីខាងក្រៅ

ឃ) កំហុសក្នុងការវិនិច្ឆ័យ

ង) ជម្រើសដែលបានពិចារណាយ៉ាងប្រុងប្រយ័ត្ន

ច) ព្រះជាម្ចាស់កំពុងធ្វើការជាមួយយើង

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

ចម្លើយទាំងនេះត្រូវបាន ដាក់ឆ្លាស់គ្នាដើម្បីកុំឲ្យអ្នកមើលឃើញចម្លើយនៃសំណួរបន្ទាប់ដោយចៃដន្យ មុនពេលដែលអ្នកបានសរសេរចម្លើយខ្លួនឯង។ សូមកុំបើកមើលចម្លើយភ្លាមៗ តែសូមសរសេរចម្លើយរបស់អ្នកសម្រាប់សំណួរនីមួយៗ មុនពេលដែលអ្នកប្រៀបធៀបជាមួយចម្លើយដែលយើងបានផ្តល់ឲ្យ។ ធ្វើដូច្នេះជួយឲ្យអ្នកចងចាំអ្វីៗដែលអ្នកបានរៀន។

១០ "យើងត្រូវឆ្លងកាត់ទុក្ខវេទនាជាច្រើន ដើម្បីអោយបានចូលក្នុងព្រះរាជ្យ*របស់ព្រះជាម្ចាស់"។

១ គ) ឥទ្ធិពលអាក្រក់របស់សាតាំង និង ការមិនស្តាប់បង្គាប់របស់មនុស្ស បាននាំឲ្យមានបណ្តាសាមកលើផែនដីទាំងមូល ហើយក៏ជាប្រភពនៃបញ្ហាផងដែរ។

១១ ចម្លើយ **ខ)** គឺជាជម្រើសល្អមួយ ទោះបីជាវាអាចបង្កឲ្យអ្នករងទុក្ខក៏ដោយ ព្រោះវាត្រូវបានធ្វើឡើងនៅក្នុងការស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ (យើងពិភាក្សាពីរឿងនេះបន្ថែមនៅក្នុងមេរៀនមួយផ្សេងទៀត។) ចម្លើយ **គ)** ក៏ជាជម្រើសដ៏ល្អមួយផងដែរ ព្រោះវាលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ ហើយជាទីបន្ទាល់នៃសេចក្តីស្រឡាញ់របស់អ្នកសម្រាប់ទ្រង់។ ចម្លើយ **ក)** គឺជាជម្រើសខុស ព្រោះវាមានរួមបញ្ចូលភាពមិនស្មោះត្រង់។ ចម្លើយ **ឃ)** គឺជាជម្រើសខុស ព្រោះវាគឺផ្អែកទៅលើការវិនិច្ឆ័យដែលខុសឆ្គង។

២ ចម្លើយរបស់អ្នក។ ឧទាហរណ៍មួយនៅក្នុងតំបន់របស់ខ្ញុំគឺ មានដើមឈើមួយចំនួនកំពុងតែងាប់ ព្រោះពួកវាត្រូវបានសត្វល្អិតបំផ្លាញ។

១២ ក) ជាមួយនឹងអំណរ

ខ) ដើម្បីនឹងឲ្យពួកគេបង្កើតបានជាការស៊ូទ្រាំ ដែលនាំទៅរកភាពពេញវ័យខាងឯវិញ្ញាណ។ (*ការស៊ូទ្រាំ* មានន័យថា "បន្តធ្វើដោយមានគោលបំណងមួយ ឬ ការរំពឹងទុកមួយ ឬ មិនបោះបង់ចោល"។ សម្រាប់គ្រិស្តបរិស័ទវាមានន័យថា ការបន្តជីវិតជាគ្រិស្តបរិស័ទរបស់ពួកគេដោយមានភាពស្មោះត្រង់ ទោះបីជាត្រូវលះបង់អ្វីក៏ដោយ។)

គ) ទេ មិនដែលសោះឡើយ!

ឃ) យើងត្រូវបានទាក់ចិត្ត (ល្បួង) ដោយសាតាំង ហើយយើងបានចុះចូលជាមួយបំណងចិត្តអាក្រក់ៗរបស់យើង។

៣ គ) មនុស្សទាំងអស់កើតមកជាមួយនឹងនិស្ស័យមានបាប ហើយមនុស្សទាំងអស់គឺមានទោសដោយអំពីបាបផ្ទាល់ខ្លួន។

១៣ សាកល្បងជំនឿរបស់យើង ដើម្បីឲ្យបញ្ជាក់ថាវាជាជំនឿពិតប្រាកដ។

៤ ស្តាប់បង្គាប់តាមព្រះជាម្ចាស់ និង ព្រះបន្ទូលរបស់ទ្រង់។

១៤ ក) ដើម្បីនាំឲ្យយើងធ្វើអំពើអាក្រក់ ដើម្បីឲ្យយើងធ្លាក់ចុះ

ខ) ដើម្បីនាំឲ្យយើងចេះស៊ូទ្រាំ ដើម្បីបញ្ជាក់ថាជំនឿរបស់យើងគឺជាជំនឿពិត (ឥតក្លែងក្លាយ)

៥ សង្គ្រាម ភាពអត់ឃ្លាន រញ្ជួយដី ការបៀតបៀន និង សេចក្តីស្លាប់

១៥ ខ) អស់អ្នកណាស្រឡាញ់ព្រះជាម្ចាស់ និង មានជំនឿក្នុងទ្រង់ ក្នុងការដឹកនាំពួកគេ នោះនឹងទទួលបានប្រយោជន៍ខាងឯវិញ្ញាណ តាមរយៈបញ្ហាដែលពួកគេឆ្លងកាត់។

គ) ផ្នែកមួយនៃដំណើរការ ធ្វើខ្លួនឲ្យមានសណ្ដានដូចជាព្រះគ្រិស្ត គឺជាការចែករំលែកជាមួយទុក្ខលំបាករបស់ទ្រង់។

ឃ) នៅក្នុងការធ្វើការសម្រាប់រឿងល្អៗដែលកើតឡើងចំពោះយើង បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺដើម្បីធ្វើឲ្យយើងបានដូចជាបុត្ររបស់ទ្រង់។

៦ ដោយយោងទៅតាមភស្តុតាងដែលបានផ្តល់ឲ្យ អ្នកគួរគូសរង្វង់ជុំវិញ ក), គ), ច),និង ឆ)។ ចម្លើយ ខ), ឃ) និង ង) គឺហាក់បីដូចជាមានពាក់ព័ន្ធនឹងទំនួលខុសត្រូវ។

១៦ ខ) ព្រះជាម្ចាស់ខ្វល់ព្រះទ័យនឹងយើង ពេលដែលយើងមានទុក្ខលំបាក ហើយទ្រង់សព្វព្រះទ័យឲ្យយើងបានមានការខ្វល់ខ្វាយចំពោះអ្នកដទៃដូចគ្នាដែរ។ (នេះគឺជារបៀបមួយដែលព្រះជាម្ចាស់ ធ្វើឲ្យមានការល្អចេញពីស្ថានភាពដែល មើលទៅហាក់បីដូចជាគ្មានការល្អនៅក្នុងវា សោះ។)

៧ ជម្រើសដែលមិនប្រុងប្រយ័ត្ន ឬ លង់ខ្លៅ អាចបណ្តាលឲ្យមានបញ្ហា។

១៧ ព្រះជាម្ចាស់នឹងមិនដាក់បញ្ហា ដែលលើសពីការទ្រាំទ្ររបស់យើងឡើយ។

៨ ចម្លើយរបស់អ្នក។ អ្នកអាចរៀនប្រុងប្រយ័ត្នបន្ថែមទៀតក្នុងការធ្វើការសម្រេចចិត្ត។

១៨ នៅពេលដែលយើងឆ្លងកាត់បញ្ហា យើងកាន់តែមានសេចក្តីអាណិតអាសូរចំពោះ អ្នកដែលកំពុងឆ្លងកាត់បញ្ហាស្រដៀងគ្នានោះដែរ។ យើងក៏បែរទៅរកព្រះជាម្ចាស់ សូមជំនួយ និង រៀនជឿទុកចិត្តទ្រង់បន្ថែមទៀតដែរ។

៩ លោកក៏ក្រោកឡើង ហើយចេញដំណើរទៅទីក្រុងមួយទៀត (ក្រុងឌើបេ) ដែលនៅទីនោះលោកបន្តការចែកចាយដំណឹងល្អអំពីព្រះគ្រិស្តទៀត។

១៩ ចម្លើយរបស់អ្នក។

ជំពូក ២ ការស្វែងរកដំណោះស្រាយ តាមមធ្យោបាយរបស់គ្រិស្តបរិស័ទ

"ខ្ញុំមានចិត្ត ត្រេកអរសប្បាយយ៉ាងខ្លាំង .... ខ្ញុំអាចហាមាត់និយាយតទល់នឹងខ្មាំងសត្រូវវិញ ខ្ញុំមានអំណរយ៉ាងខ្លាំង ព្រោះព្រះអង្គសង្គ្រោះខ្ញុំ។" (គម្ពីរសាំយ៉ូអែល ២:១)

តើពាក្យទាំងនេះ ស្តាប់ទៅដូចជាពាក្យដែលមកពីមនុស្សដែលមានក្តីអស់សង្ឃឹមខ្លាំងនៅក្នុងជីវិតដែលប្រកបដោយបញ្ហាធ្ងន់ធ្ងរដែរឬទេ? ទេ! ស្តាប់ទៅ វាដូចទីបន្ទាល់របស់មនុស្សម្នាក់ដែលកំពុងរស់នៅប្រកបដោយភាពជោគជ័យ និង ទំនុកចិត្ត ដែលពេញដោយអំណរទៅវិញ។ វាជាសំដីរបស់នាងហាណាដែលជីវិតរបស់នាងត្រូវ គាប់សង្កត់ជាមួយនឹងបញ្ហាជាច្រើន។ បញ្ហារបស់នាងគឺជាលទ្ធផលមកពី ការធ្វើជាប្រពន្ធម្នាក់ក្នុងចំណោមប្រពន្ធទាំងពីររបស់លោកអែលកាណា ហើយនាងមិនអាចមានកូនបាន។ ប្រពន្ធម្នាក់ទៀតបានសើចចំអកនាង ហើយធ្វើឲ្យជីវិតរបស់នាងវេទនាយ៉ាងខ្លាំង ព្រោះតែនាងជាស្ត្រីអា។ នាងហាណាត្រូវបានគ្រប់គ្រងដោយវិញ្ញាណភាពសោកសៅ ហើយបានជូតទឹកភ្នែកជាច្រើនដងដោយសារតែបញ្ហាទាំងអស់នេះ។ នាងបរិភោគអាហារមិនសូវបាន ។ ភាពសោកសៅរបស់នាងក៏ជាបញ្ហាមួយសម្រាប់ប្តីរបស់នាងដែរ ដ្បិតលោកស្រឡាញ់នាងខ្លាំងណាស់។

តើស្ត្រីម្នាក់ដែលមានបញ្ហា យ៉ាងច្រើនយ៉ាងនេះ ជាមនុស្សម្នាក់ដែលអាចនិយាយពាក្យនៅក្នុងគម្ពីរ ១សាំយ៉ូអែល ២:១? នាងបានយកបញ្ហារបស់នាងចូលទៅកាន់ព្រះជាម្ចាស់។ នាងតាំងចិត្តយ៉ាងជាក់ថាព្រះជាម្ចាស់កំពុងតែទន្ទឹងរង់ចាំស្តាប់នាង។ ការតាំងចិត្តនេះបាននាំឲ្យមានសន្តិភាពនៅក្នុងដួងចិត្តរបស់នាង តាំងពីមុនពេលដែលបញ្ហារបស់នាងត្រូវបានដោះស្រាយមកម្ល៉េះ។ "នាងក៏ចេញទៅ ហើយបរិភោគម្ហូបអាហារ ព្រមទាំងមានទឹកមុខស្រស់បស់ឡើងវិញ។" (គម្ពីរ១សាំយ៉ូអែល ១:១៨) ។ ក្រោយមកព្រះជាម្ចាស់បានប្រទានកូនប្រុសម្នាក់ដែលតែងតែ ប្រាថ្នាចង់បានតាំងពីយូរណាស់មកហើយ។ ជីវិតរបស់នាងបាន ត្រឡប់ទៅជាល្អ នៅពេលដែលនាងបានយកបញ្ហារបស់នាង ថ្វាយទៅកាន់ព្រះអម្ចាស់។ នៅក្នុងមេរៀននេះ យើងនឹងសិក្សាអំពីមធ្យោបាយរបស់គ្រិស្តបរិស័ទក្នុងការស្វែងរកដំណោះស្រាយសម្រាប់បញ្ហារបស់យើង។ ព្រះជាម្ចាស់បានប្រទានជំនួយជាច្រើន សម្រាប់ឲ្យយើងស្វែងរកដំណោះស្រាយ។ ប្រសិនបើយើងយកបន្ទុកដ៏ធ្ងន់របស់យើងថ្វាយទៅកាន់ទ្រង់ ជាមួយនឹងចិត្តស្មោះត្រង់ និង ស្តាប់បង្គាប់ យើងក៏អាចនឹងនិយាយដូចជានាងហាណាដែរ ថា "ព្រះអម្ចាស់បានបំពេញអំណរនៅក្នុងដួងចិត្តរបស់ខ្ញុំ!"

គម្រោងមេរៀន

ក. ដោះស្រាយបញ្ហាអំពើបាប ដំបូងបង្អស់

ខ. ឲ្យព្រះគម្ពីរធ្វើជាអ្នកនាំផ្លូវរបស់អ្នក

គ. ប្រើប្រាស់ធនធានផ្សេងៗទៀតរបស់អ្នក

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបានបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. ដាក់គោលការណ៍ដែលបានផ្តល់ជូនសម្រាប់ដោះស្រាយបញ្ហាអំពើបាប ទៅក្នុងស្ថានភាពផ្ទាល់ខ្លួនរបស់អ្នក។

២. ផ្តល់មូលហេតុពីរយ៉ាង អំពីមូលហេតុដែលព្រះគម្ពីរគួរតែជាអ្នកដឹកនាំរបស់យើងនៅក្នុងការស្វែងរកដំណោះស្រាយបញ្ហា។

៣. ស្គាល់ពីឧទាហរណ៍អំពីក្រឹត្យវិន័យដែលត្រូវបានល្មើស និង បញ្ហាដែលអាចបណ្តាលមកពីពួកវា។

៤. ចំណាំតរិយាបថណាដែលផ្ទុយពី តរិយាបថដែលនឹងជួយអ្នកចៀសផុតពីបញ្ហាបាន។

៥. ប្រើព្រះគម្ពីរ ១កូរិនថូស ១៣:៤-៨ ដើម្បីពន្យល់ថា តើអ្វីជាក្តីស្រឡាញ់ ហើយអ្វីមិនមែនជាក្តីស្រឡាញ់ និង អ្វីដែលក្តីស្រឡាញ់ធ្វើ ហើយអ្វីដែលក្តីស្រឡាញ់មិនធ្វើ។

៦. ដឹងតាមរយៈខគម្ពីរ អំពីរបៀបដែលការអធិស្ឋាន និង ព្រះវិញ្ញាណដ៏វិសុទ្ធនឹងជួយអ្នកដោះស្រាយបញ្ហា។

៧. ជ្រើសរើសឧទាហរណ៍ ដែលអធិប្បាយពីការប្រើប្រាស់ សុភនិច្ឆ័យ ឬ ហេតុផល មកដោះស្រាយបញ្ហា។

៨. ស្គាល់ពាក្យពិតដែលទាក់ទងនឹង ការប្រើប្រាស់យ៉ាងសមស្រប នៃមនសិការ និង ការគ្រប់គ្រងខ្លួនឯង។

៩. វិភាគរំកិលញែកពីអារម្មណ៍របស់អ្នក អំពីការស្វែងរកជំនួយពីអ្នកដទៃសម្រាប់បញ្ហារបស់ខ្លួន និង ប្រៀបធៀបអារម្មណ៍របស់អ្នកទៅជាមួយតរិយាបថទាំងប៉ុន្មានដែលបានណែនាំនៅក្នុងមេរៀននេះ។

សកម្មភាពនៅក្នុងការសិក្សា

១. សូមអានគម្ពីរនិក្ខមនំ ២០:១-១៧ និង គម្ពីរម៉ាថាយ ជំពូក៥ដល់ ជំពូក៧ ដែលជាឯកសារយោងសម្រាប់មេរៀននេះ។ នៅពេលដែលអ្នកអានមេរៀនទៅមុខ សូមអានខគម្ពីរទាំងអស់ដែលបានដាក់ឲ្យ។

២. សិក្សាមេរៀនទៅតាម ផែនការសិក្សាដែលបានផ្តល់ជូនហើយ នៅក្នុងសកម្មភាពការសិក្សាសម្រាប់មេរៀនទី១។

៣. បើកមើលពាក្យសំខាន់ទាំងឡាយណាដែលអ្នកមិនដឹង។ អ្នកនឹងរកឃើញវានៅក្នុងអក្ខរានុក្រមនៅចុងបញ្ចប់នៃសៀវភៅមេរៀននេះ។

៤. ធ្វើសំណួរនៃការប្រឡងផ្ទាល់ខ្លួន ហើយផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក។

ពាក្យសំខាន់

ការបំបិទ	មនសិការ	ការពិន័យ
ការទទួលស្គាល់	ល្មោភ	ទស្សនៈវិស័យ
ឥរិយាបថ	ការជំទាស់	គោលការណ៍
ជាប់ទោស	ញាណដឹង	ខាងឯផ្លូវចិត្ត
សារភាព	ការអានលំទោន	ឆាប់ប្រតិកម្ម

ក. ដោះស្រាយបញ្ហាអំពើបាបដ៏មួចបង្គស់

វត្ថុបំណងទី១. *ដាក់គោលការណ៍ដែលបានផ្តល់ជូនសម្រាប់ដោះស្រាយបញ្ហាអំពើបាប ទៅក្នុងស្ថាន ភាពផ្ទាល់ខ្លួនរបស់អ្នក។*

បញ្ហាដ៏ធំបំផុតដែលយើងរាល់គ្នានឹងត្រូវតែដោះស្រាយ គឺជាបញ្ហានៃអំពើបាប ហើយបញ្ហានេះក៏មានដំណោះស្រាយមួយផងដែរ! នៅក្នុងមេរៀនទី១ យើងបានអានខគម្ពីរខ្លះៗដែលប្រាប់យើងថា មនុស្សគ្រប់គ្នាសុទ្ធតែបានធ្វើអំពើបាប ថាគ្មាននរណាម្នាក់សុចរិត ហើយថាយើងទាំងអស់គ្នាសុទ្ធមានទោសនៅចំពោះព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ ដោយសារបាបរបស់យើង។ យើងក៏បានឃើញផងដែរថា ការដាក់ទោសសម្រាប់អំពើបាបគឺជាសេចក្តីស្លាប់ ជាការផ្តាច់ចេញពីព្រះជាម្ចាស់ជារៀងរហូត។

មុនពេលដែលយើងអាចចូលទៅដោះស្រាយបញ្ហារបស់យើងផ្សេង ដោយទស្សនៈវិស័យត្រឹមត្រូវបាន ដំបូងយើងត្រូវដោះស្រាយបញ្ហាអំពើបាបសិន។ មុនពេលដែលយើងអាចជួយអ្នកដទៃស្វែងរកដំណោះស្រាយសម្រាប់បញ្ហាដែលពួកគេកំពុងប្រឈមមុខ យើងត្រូវបង្ហាញពួកគេថាពួកគេត្រូវដោះស្រាយបញ្ហាអំពើបាបនៅក្នុងជីវិតរបស់ពួកគេសិន។ ព្រះយេស៊ូគ្រិស្តគឺជាចម្លើយតែមួយគត់សម្រាប់បញ្ហានោះ។ យើងចូលមកកាន់ទ្រង់ និងទទួលបានការអត់ទោស តាមរយៈ *ការលន់តួបាប* និង *ជំនឿ*។ យើងរក្សាទំនាក់ទំនងរបស់យើងជាមួយទ្រង់ជាព្រះអម្ចាស់ និង ព្រះសង្គ្រោះរបស់យើង តាមរយៈ *ការស្តាប់បង្គាប់*។

ការលន់តួបាប

លំហាត់អនុវត្តន៍

---

១ ចូរអានគម្ពីរ១យ៉ូហាន ១:៩ និង គម្ពីរ រ៉ូម ១០:៩-១០ ។ តើរឿងពីរយ៉ាងដែលមនុស្សមានបាបត្រូវលន់តួ មានអ្វីខ្លះ?

.....

២ តើមានរឿងអ្វីកើតឡើង នៅពេលដែលយើងលន់តួបាបរបស់យើងទៅកាន់ព្រះជាម្ចាស់?

.....

ការលន់តួរួមមានការសុខចិត្តទទួលស្គាល់ថាយើងជាមនុស្សមានបាប ស្តាយក្រោយចំពោះអំពើបាបរបស់យើង និង យល់ព្រមថាយើងនឹងមិនប្រព្រឹត្តអំពើបាបទៀតទេ។ វាក៏ជាការទទួលស្គាល់ថាព្រះគ្រិស្តគឺជាព្រះអម្ចាស់ និង ជាម្ចាស់នៃជីវិតរបស់យើងផងដែរ។ វាគឺជាការសុខចិត្តទុកចិត្តថ្វាយជីវិតរបស់យើងទាំងស្រុងទៅក្នុងព្រះហស្តរបស់ទ្រង់។

ជំនឿ

លំហាត់អនុវត្តន៍

៣ តើអ្វី ដែលមនុស្សមានបាបត្រូវតែជឿ? (ចូរមើលគម្ពីររ៉ូម ១០:៩)

.....

ជាមួយនឹងការសុគតរបស់ព្រះគ្រិស្តនៅលើឈើឆ្កាង និង ការមានព្រះជន្មរស់ពីសុគតឡើងវិញ ព្រះជាម្ចាស់បានបញ្ចប់ផែនការនៃការប្រោសលោះរបស់ទ្រង់ ដើម្បីឲ្យមនុស្សជាតិអាចត្រឡប់ទៅរកទំនាក់ទំនងជាមួយទ្រង់ឡើងវិញ។ ព្រះគ្រិស្តបានក្លាយជាការបង់ថ្លៃសម្រាប់បាបរបស់យើង។ ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់គឺជាផ្នែកមួយយ៉ាងសំខាន់នៃផែនការរបស់ទ្រង់។ នៅក្នុងគម្ពីរ ១កូរិនថូស ១៥:១៧, ២១-២២។ យើងអានដូចតទៅនេះ៖

> បើព្រះគ្រិស្តមិនបានរស់ឡើងវិញទេ ជំនឿរបស់បងប្អូនគ្មានន័យអ្វីទាល់តែសោះ (គ្មានសង្ឃឹម) បងប្អូននៅតែជាប់បាបដដែល។....បើមនុស្សលោកត្រូវស្លាប់ព្រោះតែមនុស្សម្នាក់ គេក៏នឹង រស់ឡើងវិញដោយសារមនុស្សតែម្នាក់ដែរ។ មនុស្សទាំងអស់បានស្លាប់រួមជាមួយលោកអដាំយ៉ាងណាគេក៏នឹងរស់ឡើងវិញរួមជាមួយព្រះគ្រិស្តយ៉ាងនោះដែរ។

នៅពេលដែលយើងទទួលស្គាល់ថា ព្រះគ្រិស្តបានយកឈ្នះលើសេចក្តីស្លាប់ និង ផ្នូរមនុស្សស្លាប់ យើងក៏ទទួលស្គាល់ថាទ្រង់បានប្រទានមធ្យោបាយឲ្យយើងទទួលបានការអត់ទោសសម្រាប់បាបរបស់យើង និង យកឈ្នះលើវាផងដែរ។ យើងជឿថាទ្រង់មានឫទ្ធានុភាពជួយយើងឲ្យឈ្នះលើសេចក្តីល្បួង និង រស់នៅក្នុងជីវិតបរិសុទ្ធមួយ។ យើងក៏ជឿថា ទ្រង់នឹងដឹកនាំជីវិតរបស់យើងនៅពេលដែលយើងដាក់ការទុកចិត្តរបស់អ្នកនៅក្នុងទ្រង់ ហើយជឿថា ទ្រង់នឹងរៀបចំយើងសម្រាប់ជីវិតដ៏អស់កល្បជានិច្ចនៅឯនគរស្ថានសួគ៌ជាមួយទ្រង់។

លំហាត់អនុវត្តន៍

៤ ហេតុអ្វីបានជាការរស់ឡើងវិញរបស់ព្រះគ្រិស្តមានសារៈសំខាន់ម្ល៉េះសម្រាប់ការប្រោសលោះរបស់យើង? ចូរផ្សារភ្ជាប់រឿងនេះទៅជាមួយនឹងអំពើបាបរបស់លោកអដាំ។

.....

ការស្តាប់បង្គាប់

នៅពេលដែលយើងបានលន់តួបាបរបស់យើង និង ទទួលស្គាល់ថាព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់ដែលរស់ឡើងវិញ និង ជាម្ចាស់របស់យើងហើយ យើងត្រូវរស់នៅក្នុងជីវិតដែលស្តាប់បង្គាប់ទ្រង់ និង ព្រះបន្ទូលរបស់ទ្រង់។ នេះគឺជារបៀបដែលយើងបង្ហាញក្តីស្រឡាញ់របស់យើងសម្រាប់ទ្រង់។ ព្រះយេស៊ូបានបញ្ជាក់ពីសារៈសំខាន់នៃការស្តាប់បង្គាប់នៅក្នុងព្រះបន្ទូលរបស់ទ្រង់ទៅកាន់ពួកសាវ័កថា: "ប្រសិនបើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ អ្នករាល់គ្នាពិតជាកាន់តាមបទបញ្ជារបស់ខ្ញុំ....អ្នកណាមានបទបញ្ជារបស់ខ្ញុំ និងប្រតិបត្តិតាម គឺអ្នកនោះហើយដែលស្រឡាញ់ខ្ញុំ។ ព្រះបិតារបស់ខ្ញុំស្រឡាញ់អ្នកដែលស្រឡាញ់ខ្ញុំ ហើយខ្ញុំក៏ស្រឡាញ់អ្នកនោះដែរ....អ្នកណាស្រឡាញ់ខ្ញុំអ្នកនោះនឹងប្រតិបត្តិតាមពាក្យខ្ញុំ។" (គម្ពីរយ៉ូហាន ១៤: ១៥,២១,២៣)

នៅក្នុងចំណុចបន្ទាប់ទៀត យើងនឹងទៅកាន់សេចក្តីបង្រៀនខ្លះៗរបស់ព្រះយេស៊ូ និង មើលពីរបៀបដែលការស្តាប់បង្គាប់បទបញ្ជារបស់ទ្រង់ នឹងជួយយើងបញ្ឈៀសបានបញ្ហាជាច្រើន និង រកឃើញដំណោះស្រាយសម្រាប់អ្នកដទៃផ្សេងទៀត។

លំហាត់អនុវត្តន៍

---

៥ តើអ្នកបានដោះស្រាយបញ្ហារបស់អ្នកហើយឬនៅ? ចូរធ្វើការសាកល្បងខ្លួនឯង ដោយគូសគ្រីស ទៅលើការឆ្លើយតបដ៏សមស្របសម្រាប់ប្រយោគនីមួយៗ។

	បាទ/ចាស	**ទេ**
ខ្ញុំឃើញថា មនុស្សគ្រប់គ្នារួមទាំងខ្ញុំផង សុទ្ធតែជាមនុស្សមានបាប។		
ខ្ញុំបានលន់តួអំពើបាបរបស់ខ្ញុំទៅកាន់ព្រះជាម្ចាស់។		
ខ្ញុំបានទទួលស្គាល់ថាព្រះយេស៊ូជាព្រះអម្ចាស់របស់ខ្ញុំ។		
ខ្ញុំជឿថា ព្រះគ្រិស្តបានរស់ពីស្លាប់ឡើងវិញ ហើយបានប្រទានឲ្យខ្ញុំឈ្នះលើអំពើបាប សេចក្តីស្លាប់ និង ផ្នូរមនុស្សស្លាប់ ដោយការរស់ឡើងវិញរបស់ទ្រង់។		
ខ្ញុំជឿ ថាប្រសិនបើព្រះគ្រិស្ត អាចដោះស្រាយបញ្ហាអំពើបាបនៅក្នុងជីវិតរបស់ខ្ញុំបាន ទ្រង់ក៏អាចជួយខ្ញុំស្វែងរកដំណោះស្រាយសម្រាប់បញ្ហាផ្សេងទៀតរបស់ខ្ញុំបានដែរ។		
ខ្ញុំចង់ស្តាប់បង្គាប់ព្រះគ្រិស្ត និង ព្រះបន្ទូលរបស់ទ្រង់។		
ខ្ញុំជឿថាការស្តាប់បង្គាប់នឹងជួយខ្ញុំបញ្ឈៀសបានបញ្ហាជាច្រើន។		

អ្នកនឹងទទួលបន្ថែមទៀត តាមរយៈការសិក្សាមុខវិជ្ជា *មានជីវិតនៅក្នុងព្រះគ្រិស្ត* របស់សាកលវិទ្យាល័យគ្លូបល សរសេរដោយលោកដាវីឌ ខូនខេន ដែលសិក្សាកាន់តែស៊ីជម្រៅជាមួយនឹងបញ្ហាអំពើបាប និង ជំហានទាក់ទងនឹងដំណោះស្រាយរបស់វា។

ខ. ឲ្យព្រះគម្ពីរធ្វើជាអ្នកនាំផ្លូវរបស់អ្នក

វត្ថុបំណងទី២ *ផ្តល់មូលហេតុពីរយ៉ាង អំពីមូលហេតុដែលព្រះគម្ពីរគួរតែជាអ្នកដឹកនាំរបស់យើង នៅក្នុងការស្វែងរកដំណោះស្រាយបញ្ហា។*

ក្រោយពីយើងបានក្លាយជាគ្រិស្តបរិស័ទហើយ យើងមិនស្វែងរកដំណោះស្រាយណាផ្សេងដើម្បីរំដោះយើងឲ្យរួចពីកន្លែងលំបាកនោះទេ។ យើងស្វែងរកដំណោះស្រាយដែលមកពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលស្ថិតស្ថេរជាប់ជាមួយរបៀបរស់នៅរបស់គ្រិស្តបរិស័ទ។ របៀបដែលអ្នកជឿដែលជាគ្រិស្តបរិស័ទដោះស្រាយបញ្ហារបស់ពួកគេគឺមានសារៈសំខាន់ណាស់។

ទីមួយ គ្រិស្តបរិស័ទ បានប្តេជ្ញាចិត្តចំពោះជីវិតដែលស្តាប់បង្គាប់ព្រះយេស៊ូគ្រិស្ត។ ដូច្នេះ ដំណោះស្រាយដែលអាចកើតមានឡើងត្រូវតែ ធ្វើនៅក្នុងការបំភ្លឺដោយបទគម្ពីរ ជាពិសេសដោយសេចក្តីបង្រៀនរបស់ព្រះយេស៊ូ និង សាវ័ករបស់ទ្រង់។ មានបទគម្ពីរជាច្រើន និយាយយ៉ាងច្បាស់ៗទៅលើប្រធានបទ នៃសកម្មភាពត្រឹមត្រូវ និង សុចរិតទៀងត្រង់។ ដំណោះស្រាយដែលផ្ទុយពីបទគម្ពីរបានចែងគឺត្រូវតែ ច្រានចោល!

ទីពីរ ព្រះគម្ពីរគឺជា សៀវភៅក្បួនប្រតិបត្តិការរបស់ព្រះជាម្ចាស់សម្រាប់យើង។ នៅពេលដែលសហគ្រិន (អ្នកផលិត) លក់គ្រឿងម៉ាស៊ីនដ៏ស្មុគស្មាញមួយ គេផ្តល់ជូនមកជាមួយនូវ សៀវភៅក្បួនប្រតិបត្តិការមួយក្បាល ដែលជាការណែនាំបកស្រាយពីរបៀបធ្វើឲ្យម៉ាស៊ីននោះធ្វើការបានល្អ។ គេត្រូវបានធ្វើតាមការណែនាំទាំងនេះ ប្រសិនបើចង់ឲ្យម៉ាស៊ីននោះធ្វើការបានសមស្រប។ នៅក្នុងរបៀបដូចគ្នានោះដែរ មនុស្សត្រូវបានបង្កើតឡើងដោយព្រះជាម្ចាស់ ហើយទ្រង់ជ្រាបពីអ្វីដែលអាចធ្វើឲ្យជីវិតរបស់មនុស្សទទួលបានជោគជ័យ។ ព្រះគម្ពីរគឺជា "សៀវភៅក្បួនប្រតិបត្តិការ" ដែលទ្រង់បានប្រទានមកឲ្យ។ ការប្រមាថ (មិនព្រមទទួល) ឬ បដិសេធ ការណែនាំរបស់ព្រះជាម្ចាស់ គឺជាការនាំរឿងវ៉ាវ និង បញ្ហាមកដាក់ខ្លួនហើយ។ យើងបានឃើញនៅក្នុងមេរៀនទី១ ថា *ការមិនស្តាប់បង្គាប់គឺនាំមកនូវគ្រោះមហន្តរាយ!*

វាមិនអាចទៅរួចទេ ក្នុងការរៀបរាប់ពីបទគម្ពីរទាំងអស់ដែល និយាយអំពីរបៀបដែលយើងគួររស់ក្នុងជីវិតរបស់យើង។ ពេលដែលយើងរៀនមុខវិជ្ជានេះទៅមុខទៀត និង ពិភាក្សាពីបញ្ហាផ្សេងៗដែលជាក់លាក់ យើងនឹងឃើញពីអ្វីដែលព្រះគម្ពីរបានចែងអំពីបញ្ហាទាំងនេះ ប៉ុន្តែមានការណែនាំជាទូទៅខ្លះទៀត អ្នកអាចឃើញមាននៅក្នុង ក្រឹត្យវិន័យទាំងដប់ប្រការ (គម្ពីរនិក្ខមនំ ២០:១-១៧) និង ការចែកចាយរបស់ព្រះយេស៊ូនៅលើភ្នំ (គម្ពីរម៉ាថាយ ៥-៧) យើងក៏ចង់ពិចារណាខ្លះៗដែរ។

លំហាត់អនុវត្តន៍

៦ បកស្រាយយ៉ាងខ្លីៗ អំពីមូលហេតុពីរយ៉ាងដែលព្រះគម្ពីរគួរតែជាមគ្គទេសក៍របស់យើង។

.....

.....

ក្រឹត្យវិន័យទាំងដប់ប្រការ

វត្ថុបំណងទី៣ *ស្គាល់ពីឧទាហរណ៍អំពីក្រឹត្យវិន័យដែលត្រូវបានល្មើស និង បញ្ហាដែលអាចបណ្តាលមកពីពួកវា។*

មានសេចក្តីបង្រៀនដ៏ពេញនិយមមួយដែលនិយាយថា ៖ " តាំងពីពេលព្រះយេស៊ូបានបង់ថ្លៃសម្រាប់ទោសនៃអំពើបាបរបស់យើងហើយ យើងលែងស្ថិតនៅក្រោមច្បាប់ ហើយយើងមានសេរីភាពពេញលេញ ក្នុងការរស់នៅក្នុងជីវិតតាមជម្រើសរបស់យើង" ។ វាគឺជារឿងពិត ដែលព្រះគ្រិស្តបានរំដោះយើងឲ្យរួចផុតពីចំណងនៃបាប ប៉ុន្តែសូមវិភាគពីព្រះបន្ទូលរបស់ទ្រង់នៅក្នុងគម្ពីរម៉ាថាយ ៥:១៧-១៨៖

សុំកុំនឹកស្មានថាខ្ញុំមកលុបបំបាត់គម្ពីរវិន័យ ឬគម្ពីរព្យាការី*ចោលឡើយ។ ខ្ញុំមិនមែនមកលុបបំបាត់ទេ គឺខ្ញុំមកធ្វើអោយគម្ពីរមានអត្ថន័យពេញលក្ខណៈទៅវិញ។ ខ្ញុំសុំប្រាប់អោយអ្នក រាល់គ្នាបានដឹងច្បាស់ថា ដរាបណាផ្ទៃមេឃ និងផែនដីនៅស្ថិតស្ថេរដរាបនោះគ្មានក្បៀស ឬបន្តក់ណាមួយក្នុងគម្ពីរវិន័យ*ត្រូវរលុបបាត់ឡើយ គឺគម្ពីរទាំងមូលនឹងនៅស្ថិតស្ថេររហូតដល់ទីបំផុត។

ព្រះគ្រិស្តមិនមែនមកបំបាត់ច្បាប់សីលធម៌របស់ព្រះជាម្ចាស់នោះទេ *ប៉ុន្តែ* ទ្រង់*ប្រទានឲ្យពួកយើងនូវអំណោចក្នុងការស្តាប់បង្គាប់តាមច្បាប់ទាំងនោះវិញ* ។ ឥឡូវនេះសូមយកពេល ដើម្បីអានគម្ពីរ និក្ខមនំ ២០:១-១៧ និង គម្ពីរម៉ាថាយជំពូក៥ ទៅដល់ជំពូក ៧។ អ្នកនឹងឃើញថាព្រះគ្រិស្តរំពឹងឲ្យអ្នកដើរតាមទ្រង់ ជាអ្នកអង្កេតដ៏ប្រុងប្រយ័ត្ននៃក្រឹត្យវិន័យរបស់ទ្រង់ និង ឲ្យបានលើសពីនេះទៀតនៅក្នុងការប្តេជ្ញាចិត្តបញ្ឈៀសអ្វីៗដែលអាច*នាំឲ្យមាន* ការមិនស្តាប់បង្គាប់។

គោលបំណងនៅក្នុងមេរៀននេះ គឺចង់ជួយអ្នកស្វែងរកដំណោះស្រាយបញ្ហារបស់អ្នក។ ដើម្បីឲ្យមានគ្រិះមូលដ្ឋានសមស្របនៅក្នុងការប្រឈមមុខជាមួយនឹងបញ្ហារបស់អ្នក តាមទស្សនៈវិស័យរបស់គ្រិស្តបរិស័ទ អ្នកត្រូវតែដឹងពីអ្វីដែលព្រះគម្ពីរនិយាយថាជាជំនួយរបស់អ្នក។ ដើម្បីជាចំណុចចាប់ផ្តើម យើងនឹងប្រៀបធៀបក្រឹត្យវិន័យទាំងដប់ប្រការ (ច្បាប់សីលធម៌របស់ព្រះជាម្ចាស់) ជាមួយនឹង ខគម្ពីរដែលទាក់ទងនៅក្នុងកណ្ឌគម្ពីរសម្ព័ន្ធមេត្រីថ្មី។ ខគម្ពីរនេះ និយាយអំពីអាកប្បកិរិយារបស់យើង ជាអ្វីដែលយើង*ធ្វើ* ។ ចូរស្វែងរក ខគម្ពីរនីមួយៗ នៅក្នុងព្រះគម្ពីររបស់អ្នក ហើយអានវាដោយយកចិត្តទុកដាក់។

ក្រឹត្យវិន័យទាំងដប់ប្រការ គម្ពីរនិក្ខមនំ ២០:៣-១៧		**ខគម្ពីរសម្ព័ន្ធមេត្រីថ្មីដែលទាក់ទង** គម្ពីរម៉ាថាយ ១៩:១៧-១៩; គម្ពីររ៉ូម១៣:៨-១០; គម្ពីរ១កូរិនថូស ៦:៩-១១
១. ខ៣	មិនត្រូវគោរពព្រះណាផ្សេង ក្រៅពីយើងឡើយ	គម្ពីរម៉ាកុស ១២:២៩-៣០
២. ខ៤-៥	មិនត្រូវឆ្លាក់រូបអ្វី ឬយកវត្ថុដែលជាតំណាងអ្វីមួយ .... មិនត្រូវក្រាបថ្វាយបង្គំរូបព្រះទាំងនោះ ឬគោរពបំរើរូបទាំងនោះឡើយ។	គម្ពីរម៉ាថាយ ៤:១០; គម្ពីរ១យ៉ូហាន ៥:២១
៣. ខ៧	មិនត្រូវយកព្រះនាមរបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នក ទៅប្រើឥតបានការនោះឡើយ	គម្ពីរម៉ាថាយ ៥:៣៣-៣៧; គម្ពីរម៉ាថាយ ៦:៩; គម្ពីរយ៉ាកុប ៥:១២; គម្ពីរយ៉ាកុប ៣:១០
៤. ខ៨	ចូររំលឹកថ្ងៃសប្ប័ទ* ហើយញែកថ្ងៃនោះជាថ្ងៃដ៏វិសុទ្ធ	គម្ពីរ លូកា ៤:១៦; គម្ពីរហេប្រឺ ១០:២៥ (គួរគត់សម្គាល់ផងដែរថា៖ ព្រះយេស៊ូបានរស់ពីស្លាប់ឡើងវិញ នៅក្នុងថ្ងៃដំបូងនៃសប្តាហ៍។ ចាប់តាំងពីថ្ងៃនោះមក មានគ្រិស្តបរិស័ទជាច្រើន បានញែកថ្ងៃនោះជាថ្ងៃរបស់ព្រះអម្ចាស់។ សូមមើលគម្ពីរកិច្ចការ ២០:៧; គម្ពីរវិវរណៈ ១:១០)
៥. ខ១២	ចូរគោរពមាតាបិតារបស់អ្នក	គម្ពីរម៉ាថាយ ១៥:៤; គម្ពីរអេភេសូ ៦:១; គម្ពីរកូឡូស ៣:២០; គម្ពីរ១ធីម៉ូថេ៥:១-២
៦. ខ១៣	កុំសម្លាប់មនុស្ស។	គម្ពីរម៉ាថាយ ៥:២១-២៥; ១៩:១៧-១៩; គម្ពីររ៉ូម១៣:៨-១០; គម្ពីរ១ពេត្រុស៤:១៥
៧. ខ១៤	កុំប្រព្រឹត្តអំពើផិតក្បត់។	គម្ពីរទីតុស១:៦; គម្ពីរម៉ាថាយ ៥:២៧-២៨, ៣១-៣២; ១៩:៤,៩; គម្ពីររ៉ូម៧:៣; គម្ពីរ១កូរិនថូស៦:៩

ក្រឹត្យវិន័យទាំងដប់ប្រការ	ខគម្ពីរសម្ព័ន្ធមេត្រីថ្មីដែលទាក់ទង
៨. ខ១៥ កុំលួចប្លន់គេ។	គម្ពីរម៉ាថាយ ១៩:១៨; គម្ពីររ៉ូម១៣:៩; គម្ពីរអេភេសូ ៤:២៨; គម្ពីរ១ពេត្រុស៤:១៥
៩. ខ១៦ កុំធ្វើសាក្សីក្លែងក្លាយ ដែលនាំអោយអ្នកដទៃមានទោស	គម្ពីរម៉ាថាយ ៥:៤៣-៤៤; ១៩:១៨; គម្ពីរកូឡូស ៤:៦; គម្ពីរទីតុស ២:៨; គម្ពីរយ៉ាកុប ៣:២-១០
១០. ខ១៧ កុំលោភលន់ចង់បានផ្ទះរបស់អ្នកដទៃ កុំលោភលន់ចង់បានប្រពន្ធគេ ឬក៏លោភលន់ចង់បានអ្នកបំរើប្រុសអ្នកបំរើស្រី គោ លា ឬអ្វីផ្សេងទៀតដែលជារបស់គេឡើយ	គម្ពីរម៉ាកុស១២:៣១; គម្ពីររ៉ូម ១៣:១០; គម្ពីររ៉ូម ១៥:១-២; គម្ពីរកាឡាទី ៥:១៤; គម្ពីរយ៉ាកុប២:៨

លំហាត់អនុវត្តន៍

៧ ចូរកំណត់សម្គាល់ប្រាប់ថាតើក្រឹត្យវិន័យមួយណាដែលត្រូវបានគេល្មើស ប្រាប់ពីបញ្ហាដែលអាចកើតមានឡើងដោយសារតែអាកប្បកិរិយាខាងក្រោមនេះ៖

អាកប្បកិរិយា	ក្រឹត្យវិន័យដែលត្រូវបានល្មើស	លទ្ធផលដែលអាចកើតមានឡើង
ក) ការងាររបស់លោកយ៉ូសែបក្លាយជារឿងដែលសំខាន់ជាងគេនៅក្នុងជីវិតរបស់គាត់ គឺសំខាន់លើសពីទំនាក់ទំនងរបស់គាត់ជាមួយនឹងព្រះជាម្ចាស់ ឬគ្រួសាររបស់គាត់ទៅទៀត។		
ខ) មិត្តម្នាក់របស់ហោនរី បានលួចក្រដាសប្រឡង ហើយបានឲ្យច្បាប់ចម្លងមួយទៅឲ្យគាត់ ដើម្បីឲ្យគាត់អាចនឹងដឹងចម្លើយមុនពេលដែលគាត់ធ្វើការប្រឡងនៅក្នុងថ្នាក់របស់គាត់។		
គ) លោកហូមើរ បានទាក់ចិត្តជាមួយនឹងស្ត្រីដែលរៀបការហើយម្នាក់ ដែលគាត់ធ្វើការជាមួយ ហើយគាត់បានមិនស្មោះត្រង់ជាមួយនឹងប្រពន្ធរបស់គាត់។		
ឃ) នាងម៉ាថើរី មានចិត្តច្រណែនព្រោះអ្នកជិតខាងរបស់នាងមានឡានថ្មីមួយគ្រឿង។ នាងដើរប្រាប់មិត្តភក្តិរបស់នាងថា គាត់បានឡាននោះមកដោយអំពើទុច្ចរិត។		

៨ ចូរដាក់លំហាត់នេះទៅក្នុងបញ្ហានៅក្នុងជីវិតរបស់អ្នក ឬ បញ្ហារបស់មនុស្សដទៃទៀតដែលអ្នកស្គាល់។ ចូរសរសេរពីអាកប្បកិរិយាដែលបង្កើតឲ្យមានបញ្ហានៅក្នុងសៀវភៅកត់ត្រាមួយទៀតរបស់អ្នក កំណត់សំគាត់ថាតើក្រឹត្យវិន័យមួយណាដែលត្រូវបានល្មើស ហើយប្រាប់ថាតើបញ្ហាអ្វីដែលជាលទ្ធផលដែលបានមកពីអាកប្បកិរិយានោះ។

ព្រះជាម្ចាស់មិនបានប្រទានក្រឹត្យវិន័យទាំងនេះមក ដើម្បីឲ្យយើងក្លាយជាទាសកររបស់ទ្រង់នោះទេ។ ទ្រង់បានប្រទានពួកវាមកឲ្យយើង ព្រោះទ្រង់ជ្រាបថា ការស្តាប់បង្គាប់តាមបទបញ្ញត្តិទាំងនេះអាចជួយយើង ជៀសផុតពីបញ្ហាជាច្រើន និង មានជីវិតមួយដ៏រីករាយ និង បរិបូរណ៍។

ឥរិយាបថ "ជា"

វគ្គបំណងទី៤. *ចំណាំឥរិយាបថណាដែលផ្ទុយពី ឥរិយាបថដែលនឹងជួយអ្នកជៀសផុតពីបញ្ហាបាន។*

ថ្ងៃមួយខ្ញុំបានឮ ការសន្ទានអំពីស្ត្រីម្នាក់ ដែលបានផ្លាស់ទីលំនៅរបស់នាង ជាច្រើន គីឡូម៉ែត្រពីផ្ទះដើមរបស់នាង។ មានមនុស្សម្នាក់បាននិយាយថា "អ្នកស្រី រ៉ែ បានប្តូរទៅនៅទីនោះដោយសារតែនាងមិនសប្បាយចិត្ត"។

មិត្តម្នាក់ទៀតបានតបទៅវិញថា "នាងនៅតែមិនសប្បាយចិត្ត នៅទីនោះ ព្រោះតែនាងត្រូវតែយកខ្លួនឯងទៅជាមួយដែរ!"

មិត្តម្នាក់នោះបាននិយាយពីសេចក្តីពិតដ៏សំខាន់មួយ។ ប្រសិនបើឥរិយាបថរបស់អ្នកមិនត្រឹមត្រូវនោះទេ គ្មានដំណោះស្រាយ *ពីក្រៅ* ណាមួយដែលអាចជាជំនួយជានិរន្តរ៍ សម្រាប់បញ្ហានោះបានឡើយ។ ប៉ុន្តែនៅពេលដែលអ្នកចូលទៅប្រឈមមុខជាមួយបញ្ហារបស់អ្នកដោយឥរិយាបថមួយដែលត្រឹមត្រូវ អ្នកអាចរំពឹងបាននូវជ័យជម្នះលើបញ្ហានោះបាន ទោះបីជាដំណោះស្រាយដែលស្របបំណងរបស់អ្នកកើតមានឬ អត់ក៏ដោយ។

ព្រះយេស៊ូមានរឿងជាច្រើនដែលព្រះអង្គមានព្រះបន្ទូលអំពីឥរិយាបថ។ គម្ពីរសុភមង្គលដ៏ពិត ដែលជាផ្នែកមួយនៃសេចក្តីបង្រៀនរបស់ទ្រង់នៅលើភ្នំ ដែលជារឿយៗត្រូវបានគេហៅថា "ឥរិយាបថ ជា" ព្រោះវាបានរៀបរាប់ពីអ្វីដែលយើងគួរតែធ្វើខ្លួនជា។

ប្រសិនបើអ្នកបានសិក្សាមុខវិជ្ជាដំបូងនៅក្នុងកម្មវិធីសិក្សានេះ គឺ *ភាពពេញវ័យរបស់គ្រិស្តបរិស័ទ* សរសេរដោយលោករីក ហូវ៉ាត (Rick Howard) នោះអ្នកនឹងបានគិតពិចារណាពីសេចក្តីបង្រៀន អំពីសុភមង្គលដ៏ពិតរួចហើយ (2007, 157)។ សេចក្តីបង្រៀននេះត្រូវបានគេកត់ត្រាទុកនៅក្នុងគម្ពីរម៉ាថាយ ៥:៣-១០ ។ ទាំងនេះគឺជាឥរិយាបថនៃដួងចិត្ត និង លក្ខណៈដែលព្រះវិញ្ញាណដ៏វិសុទ្ធនឹងបង្កើតឲ្យមាននៅក្នុងអស់អ្នកជឿដែលអនុញ្ញាតឲ្យទ្រង់ធ្វើការនៅក្នុងគេ។

លំហាត់អនុវត្តន៍

៩ នៅក្នុងលំហាត់នេះ យើងនឹងសង្ខេបអំពីមតិរបស់លោកវីក ហ្វ៉ាត ទៅលើសុភមង្គលដ៏ពិតនីមួយៗ នៅជួរខាងឆ្វេង ។ នៅក្នុងជួរខាងស្តាំ យើងនឹងរៀបរាប់ឥរិយាបថដែល ផ្ទុយពីអ្វីដែលព្រះយេស៊ូបានបង្រៀន។ ចូរផ្គូផ្គងឥរិយាបថខុសឆ្គងនីមួយៗទៅជាមួយនឹងឥរិយាបថត្រឹមត្រូវដែលផ្ទុយនឹងវា។ តើអ្នកអាចឃើញពីរបៀបដែល ឥរិយាបថខុសឆ្គង អាចជាប្រភពនៃបញ្ហា ឬ របៀបដែលវាអាចធ្វើឲ្យបញ្ហាដែលមានស្រាប់កាន់តែធ្ងន់ឡើងៗដែរឬទេ? (សូមមើលគម្ពីរ ម៉ាថាយ៥:៣-១០)

.....ក) ខ៣៖ អ្នកដាក់ចិត្តក្រខ្សត់ គឺជាឥរិយាបថពឹងផ្អែកលើព្រះជាម្ចាស់	១) ដោយចេតនា (ចង់ដើរផ្លូវខ្លួនឯង)
.....ខ) ខ៤៖ អ្នកដែលសោកសៅ គឺជាឥរិយាបថនៃការរងទុក្ខដោយអំពើបាបដែលបណ្តាលឲ្យមានការសារភាព និង ការលន់តួ។	២) មិនស្តាប់បង្គាប់ ៣) អំណួត ៤) ឯករាជ្យ
.....គ) ខ៥៖ អ្នកមានចិត្តស្លូតបូត គឺជាឥរិយាបថបន្ទាបខ្លួន និង ចុះចូលជាមួយព្រះជាម្ចាស់។	៥) គ្មានសង្ឃឹម ៦) ពេញដោយបាប
.....ឃ) ខ៦៖ អ្នកដែលស្រេកឃ្លានសេចក្តីសុចរិត គឺជា ឥរិយាបថនៃការស្តាប់បង្គាប់។	៧) មិនចេះអត់ទោស ៨) អ្នកបង្កបញ្ហា
.....ង) ខ៧៖ អ្នកមានចិត្តមេត្តាករុណា គឺជាឥរិយាបថនៃការលើកលែងទោស។	
.....ច) ខ៨៖ អ្នកមានចិត្តបរិសុទ្ធ គឺជាឥរិយាបថភាពបរិសុទ្ធ។	
.....ឆ) ខ៩៖ អ្នកកសាងសន្តិភាព គឺជាឥរិយាបថរបស់មនុស្សដែលចង់បង្កើតសន្តិភាព (សូមមើលគម្ពីរ យ៉ាកុប ៣:១៧-១៨)	
.....ជ) ខ១០៖ អ្នកដែលត្រូវគេបៀតបៀនព្រោះតែបានធ្វើតាមសេចក្តីសុចរិត គឺជាឥរិយាបថនៃការជឿព្រះជាម្ចាស់ក្នុងគ្រប់រឿងទាំងអស់។	

សេចក្តីស្រឡាញ់គឺជាគន្លឹះ

វត្ថុបំណងទី៥ *ប្រើព្រះគម្ពីរ ១កូរិនថូស ១៣:៤-៨ ដើម្បីពន្យល់ថា តើអ្វីជាក្តីស្រឡាញ់ ហើយអ្វីមិនមែនជាក្តីស្រឡាញ់ និង អ្វីដែលក្តីស្រឡាញ់ធ្វើ ហើយអ្វីដែលក្តីស្រឡាញ់មិនធ្វើ។*

នៅគ្រប់កន្លែងក្នុងព្រះគម្ពីរ សេចក្តីស្រឡាញ់ត្រូវបានបង្ហាញថាជាគន្លឹះ ស្វែងរកដំណោះស្រាយសម្រាប់គ្រប់បញ្ហាទាំងអស់។ មានគ្រាមួយ មនុស្សម្នាក់បានទូលសួរព្រះយេស៊ូថា៖ "ក្នុងបណ្តាបទបញ្ជា* ទាំងអស់ តើបទបញ្ជាណាសំខាន់ជាងគេ?" (គម្ពីរម៉ាកុស ១២:២៨) ។ ព្រះយេស៊ូមានព្រះបន្ទូលតបយ៉ាងដូច្នេះ៖

នេះជាបទបញ្ជាទីមួយ: "ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នកអោយអស់ពីចិត្តគំនិត អស់ពីស្មារតី អស់ពីប្រាជ្ញា និងអស់ពីកម្លាំងកាយ"។ រីឯបទបញ្ជាទីពីរមានចែងថា "ត្រូវស្រឡាញ់បងប្អូនឯទៀតៗអោយបានដូច ស្រឡាញ់ខ្លួនឯង"។ គ្មានបទបញ្ជាណាសំខាន់ជាងបទបញ្ជាទាំងពីរនេះទេ" ។ (គម្ពីរម៉ាកុស ១២:១៩-៣១)

លំហាត់អនុវត្តន៍

---

១០ ចូរអានគម្ពីរ១កូរិនថូស ១៣:៤-៨ ហើយសរសេរនៅក្នុងចន្លោះដែលត្រឹមត្រូវ អំពីអ្វីជាក្តីស្រឡាញ់ និង អ្វីដែលមិនមែនជាក្តីស្រឡាញ់ ព្រមទាំង អ្វីដែលក្តីស្រឡាញ់ធ្វើ និង អ្វីដែលក្តីស្រឡាញ់មិនធ្វើ។

អ្វីដែលជាក្តីស្រឡាញ់	**អ្វីដែលមិនមែនជាក្តីស្រឡាញ់**	**អ្វីដែលក្តីស្រឡាញ់ធ្វើ**	**អ្វីដែលក្តីស្រឡាញ់មិនធ្វើ**
.....	.....	.....	.....
.....	.....	.....	.....
	.....	.....	.....
	.....	.....	.....
		.....	.....

សាកគិតអំពីបញ្ហាទាំងអម្បាលម៉ាន ដែលអាចនឹងត្រូវបានបញ្ចៀសឲ្យផុត បើសិនយើងប្តេជ្ញាចិត្តដើម្បីបង្ហាញក្តីស្រឡាញ់ដូចដែលលោកប៉ូលបានរៀបរាប់នោះ! នោះគឺជាឥរិយាបថដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យយើងមាន ហើយប្រសិនបើយើងមានវាហើយ ហើយមិនចាំបាច់បារម្ភអំពីការធ្វើល្មើសច្បាប់នោះទេ។ នៅក្នុងគម្ពីររ៉ូម ១៣:៨-១០ លោកសាវ័កប៉ូលបានសំដែងដូច្នេះ៖

មិនត្រូវជំពាក់អ្វីនរណា ក្រៅពីជំពាក់សេចក្តីស្រឡាញ់គ្នាទៅវិញទៅមកនោះឡើយ ដ្បិតអ្នកណាស្រឡាញ់អ្នកដទៃ អ្នកនោះប្រតិបត្តិតាមក្រឹត្យវិន័យ*ពេញលក្ខណៈ ព្រោះមានសេចក្តីចែង ទុកមកថា «កុំប្រព្រឹត្តអំពើផិតក្បត់ កុំសម្លាប់មនុស្ស កុំលួចទ្រព្យសម្បត្តិគេ កុំមានចិត្តលោភលន់» ព្រមទាំងមានបទបញ្ជាឯទៀតដែលសរុបមកក្នុងពាក្យតែមួយនេះថា: «ចូរស្រឡាញ់បងប្អូនឯទៀតៗ អោយបានដូចស្រឡាញ់ខ្លួនឯងដែរ»។ អ្នកមានចិត្តស្រឡាញ់មិនដែលប្រព្រឹត្តអាក្រក់ចំពោះបងប្អូនឯទៀតៗឡើយ ដ្បិតសេចក្តីស្រឡាញ់ធ្វើអោយក្រឹត្យវិន័យបាន ពេញលក្ខណៈ។

លំហាត់អនុវត្តន៍

---

១១ ព្រះគ្រិស្តបំពេញក្រឹត្យវិន័យជាមួយនឹង.....

១២ យើងអាចបំពេញក្រឹត្យវិន័យជាមួយនឹង.....

យើងបានអធិប្បាយខ្លីៗអំពីរបៀបដែលព្រះគម្ពីរផ្តល់ឲ្យយើងនូវមគ្គទេសក៍ សម្រាប់ការដោះស្រាយបញ្ហា នៅក្នុងចំណុចនេះ។ អ្នកអាចនឹងត្រូវបកមកមើលមេរៀនទាំងនេះវិញ នៅពេលដែលយើងសិក្សាមុខវិជ្ជានេះបន្តទៅមុខទៀត ហើយអ្នកត្រូវបន្តមើលនៅក្នុងព្រះគម្ពីរ ដើម្បីស្វែងរកចម្លើយសម្រាប់បញ្ហាជាក់លាក់។ សេចក្តីបង្រៀនរបស់ព្រះយេស៊ូ និង ពួកសាវក គឺពោរពេញដោយ ការណែនាំជាក់ស្តែងសម្រាប់ជីវិតរៀងរាល់ថ្ងៃរបស់យើង ហើយយើងអាចទទួលបានកាន់តែច្រើនពីការអានព្រះបន្ទូលរបស់ព្រះជាម្ចាស់រៀងរាល់ថ្ងៃ និង យកសេចក្តីពិតនៅក្នុងនោះទៅអនុវត្តនៅស្ថានភាពផ្ទាល់ខ្លួនរបស់យើង។

គ. ប្រើប្រាស់ធនធានផ្សេងៗទៀតរបស់អ្នក

ការអធិស្ឋាន និង ការនាំផ្លូវពីព្រះវិញ្ញាណដ៏វិសុទ្ធ

វត្ថុបំណងទី៦. *ដឹងតាមរយៈខគម្ពីរ អំពីរបៀបដែលការអធិស្ឋាន និង ព្រះវិញ្ញាណដ៏វិសុទ្ធនឹងជួយអ្នកដោះស្រាយបញ្ហា។*

នៅក្នុងព័ន្ធកិច្ចផ្ទាល់ខ្លួនសម្រាប់អ្នកមួយនេះ ព្រះជាម្ចាស់អង្គទ្រង់ផ្ទាល់ នឹងជួយដោះស្រាយបញ្ហារបស់អ្នក។ អ្នកអាចយកបញ្ហានោះទៅថ្វាយព្រះជាម្ចាស់តាមរយៈ ការអធិស្ឋាន ហើយទ្រង់នឹងបង្ហាញដំណោះស្រាយឲ្យអ្នកឃើញដើម្បីបានដឹងថាអ្វីដែលអ្នកត្រូវតែធ្វើ ឬ ទ្រង់អាចនឹងធ្វើការតាមកាលៈទេសៈដើម្បីឲ្យបញ្ហានោះត្រូវបានដោះស្រាយតាមរបៀបផ្សេងទៀត។ ដើម្បីទទួលបានទំនាក់ទំនងប្រភេទនេះជាមួយនឹងព្រះជាម្ចាស់ ចូរបង្កើតទម្លាប់ទាក់ទងជាមួយទ្រង់ឲ្យបានខ្ជាប់ខ្ជួន។

លំហាត់អនុវត្តន៍

១៣ ចូរអានខគម្ពីរដែលមាននៅក្នុងជួរស្តាំ ។ សំគាល់នូវអ្វីដែលខគម្ពីរនីមួយៗ ផ្តល់ឲ្យជារបៀបដែលការអធិស្ឋាននឹងជួយយើង។ បន្ទាប់មកចូរផ្គូផ្គង់ខគម្ពីរនីមួយៗទៅជាមួយរបៀបដោះ ស្រាយបញ្ហាដែលនៅក្នុងជួរខាងឆ្វេង។

.....ក) យកឈ្នះលើសេចក្តីល្បួង	១) គម្ពីរ១កូរិនថូស ១៦:១
.....ខ) ទទួលបានអំណរ	២) គម្ពីរម៉ាថាយ ២៦:៤១
.....គ) បង្កើតឲ្យមានការស៊ូទ្រាំ	៣) គម្ពីរយ៉ាកុប ៥:១៣
.....ឃ) ទទួលបានកម្លាំង	៤) គម្ពីរអេភេសូ ៦:១៨
.....ង) ដោះស្រាយទុក្ខវេទនា (ទុក្ខលំបាក)	៥) គម្ពីរយ៉ូហាន ១៦:២៤

គម្ពីរយ៉ូហាន ១៦:១៣ បានសន្យាថា ព្រះវិញ្ញាណដ៏វិសុទ្ធនឹងនាំផ្លូវអ្នកនៅក្នុងសេចក្តីពិតទាំងអស់។ អ្នកក៏អាចពឹងផ្អែកលើព្រះវិញ្ញាណ ក្នុងការដឹកនាំផ្លូវប្រចាំថ្ងៃរបស់អ្នក។ *ទ្រង់នឹងតែងតែដឹកនាំអ្នកយោងទៅតាមគោលការណ៍ព្រះគម្ពីរជានិច្ច។*

> ព្រះបន្ទូលរបស់ព្រះអង្គជាចង្កៀងបំភ្លឺជំហាន ទូលបង្គំ និងជាពន្លឺបំភ្លឺផ្លូវរបស់ទូលបង្គំ។ ទូលបង្គំសូមសន្យាដោយឥតងាករេថា ទូលបង្គំនឹងប្រតិបត្តិតាមវិន័យ ដ៏សុចរិតដែលព្រះអង្គបង្គាប់មក។ (គម្ពីរទំនុកតម្កើង ១១៩:១០៥-១០៦)

ការអធិស្ឋានជាញឹកញាប់ ដែលថ្វាយការសរសើរតម្កើង និង ការអរព្រះគុណ ត្រូវមានភ្ជាប់ជាមួយនឹង*ការស្តាប់បង្គាប់* ផងដែរ។ យើងធ្លាប់បាននិយាយអំពីការស្តាប់បង្គាប់ពីមុនរួចមកហើយ។ នៅក្នុងខគម្ពីរដែលអ្នកទើបតែនឹងបានអាន តើអ្នកបានសំគាល់ឃើញថា អ្នកនិពន្ធបានផ្សារភ្ជាប់ពន្លឺសម្រាប់បំភ្លឺផ្លូវរបស់គាត់ ទៅជាមួយនឹង ការដែល គាត់នឹងរក្សាក្តីសន្យារបស់គាត់ ថានឹងស្តាប់បង្គាប់ការណែនាំរបស់ព្រះជាម្ចាស់រហូតដែរឬទេ? ការអធិស្ឋានដែលទទួលបានការឆ្លើយតប និង ការស្តាប់បង្គាប់ គឺមានទំនាក់ទំនងគ្នាទៅវិញទៅមក។ បញ្ហាដែលមិនអាចដោះស្រាយបាន អាចនឹងត្រូវបានដោះស្រាយតាមរយៈការអធិស្ឋាន!

លំហាត់អនុវត្តន៍

១៤ ចូរអានគម្ពីរលូកា ១២:១២ គម្ពីរយ៉ូហាន ១៤:២៦ និង គម្ពីរ១កូរិនថូស ២:១៣ ហើយចូរបកស្រាយពីអ្វីដែលខគម្ពីរទាំងនេះប្រាប់យើង ថាព្រះវិញ្ញាណដ៏វិសុទ្ធនឹងធ្វើសម្រាប់យើង។

.....

សុភនិច្ឆ័យ(ការត្រិះរិះល្អ) និង ហេតុផល

វត្ថុបំណងទី៧ *ជ្រើសរើសឧទាហរណ៍ ដែលអធិប្បាយពីការប្រើប្រាស់ សុភនិច្ឆ័យ ឬ ហេតុផល មកដោះស្រាយបញ្ហា។*

ព្រះជាម្ចាស់បានប្រទានលទ្ធភាពសម្រាប់ ការពិចារណារឿងពិតជាក់ស្តែង និង ការធ្វើការវិនិច្ឆ័យ។ ទ្រង់ប្រាកដជារំពឹងឲ្យយើងប្រើប្រាស់សមត្ថភាពនេះហើយ។ អ្នកប្រហែលជាបានប្រើប្រាស់ សុភនិច្ឆ័យ និង រកហេតុផល មកដោះស្រាយបញ្ហាច្រើនជារៀងរាល់ថ្ងៃ។ តាមពិតទៅ វាក្លាយទៅជាដំណើរការមួយដដែលៗ ដែលអ្នកអាចនឹងមើលរំលង។

ឧទាហរណ៍ មិត្តរបស់ខ្ញុំម្នាក់ មានបញ្ហាជាមួយនឹងក្មេងៗជិតខាងរបស់នាង។ មានក្មេងប្រាំពីរនាក់មានទម្លាប់មកលេងនៅក្នុងធ្លាមុខផ្ទះរបស់នាងរាល់ព្រឹក ជាមួយកូនទាំងពីរនាក់របស់នាង ហើយពួកគេតែងតែនៅទីនោះពេញមួយថ្ងៃ ។ ដំបូង នាងថាគិតពីរឿងរ៉ាវទាំងអស់៖

១. វាជារឿងល្អ ដែលកូនរបស់នាងនៅជិតៗ ដើម្បីឲ្យនាងដឹងថាពួកគេកំពុងតែធ្វើអ្វី។
២. កូនរបស់នាងត្រូវការ នៅក្បែរក្មេងឯទៀតៗ ឲ្យបានញឹកញាប់។
៣. ការដែលមានក្មេងជាច្រើនមកលេងនៅក្នុងធ្លារបស់នាងពេញមួយថ្ងៃ គឺគួរឲ្យរំខាន និង មិនស្រួលសម្រាប់នាងទេ។

មានដំណោះស្រាយតាមសុភនិច្ឆ័យមួយចំនួន សម្រាប់បញ្ហាមួយនេះ។ មិត្តរបស់ខ្ញុំបានប្រើប្រាស់ការត្រិះរិះរបស់នាងមកកំណត់ពេលវេលាដែលក្មេងៗអាចមកលេងនៅក្នុងធ្លារបស់នាងបាន។ នាងបានជ្រើសរើសដំណោះស្រាយយ៉ាងសាមញ្ញមួយសម្រាប់បញ្ហានេះ។

យើងក៏ធ្លាប់បានឆ្លងកាត់ ពេលខ្លះដែលដំណោះស្រាយរបស់ព្រះជាម្ចាស់ ពិតជាមិនធម្មតាទេសម្រាប់បញ្ហារបស់យើង! ទ្រង់អាចនឹងនាំអ្នកទៅក្នុងផ្លូវដែលមនុស្សឯទៀត មិនងាយស្រួលក្នុងការស្វែងយល់នោះឡើយ។ យ៉ាងណាក៏ដោយ សម្រាប់ស្ថានភាពធម្មតានៅក្នុងជីវិត សុភនិច្ឆ័យ និង សមត្ថភាពក្នុងការរកហេតុផលរបស់យើង គឺជាឧបករណ៍ដ៏សំខាន់ក្នុងការដោះស្រាយបញ្ហា។

លំហាត់អនុវត្តន៍

១៥ តើដំណោះស្រាយណាខ្លះ នៅខាងក្រោមនេះ ដែលអ្នកគិតថាជាដំណោះស្រាយមិនសមហេតុផលសម្រាប់បញ្ហាដែលទើបតែបានលើកឡើងនៅខាងលើនោះ?

ក) ស្តីបន្ទោសម្តាយរបស់ក្មេងទាំងនោះ ដែលមិនបានឃាត់កូនៗឲ្យនៅក្នុងធ្លារបស់ខ្លួនឯង។

ខ) រៀបចំជាមួយនឹងម្តាយក្មេងឯទៀតៗ ដើម្បីឲ្យកូនៗរបស់ពួកគេបានលេងនៅក្នុងធ្លា ផ្សេងៗជារៀងរាល់ថ្ងៃ។

គ) មិនអនុញ្ញាតឲ្យកូនរបស់នាង នៅលេងនៅក្នុងធ្លានោះទៀត ដើម្បីឲ្យក្មេងៗដទៃឈប់មកទីនោះ ទៀត។

ឃ) ប្រាប់ក្មេងៗឯទៀតថា ពួកគេអាចមកលេងនៅក្នុងធ្លារបស់នាងបានដរាបណាគេបានសុំការអនុញ្ញាតពីនាងជាមុនសិន។

១៦ តើឧទាហរណ៍ណាខ្លះខាងក្រោមនេះ ជាឧទាហរណ៍នៃការប្រើប្រាស់សុភនិច្ឆ័យ និង ហេតុផលសម្រាប់ដោះស្រាយរបស់យើង។ ចូរគូសរង្វង់ជុំវិញអក្សរដែលនៅខាងមុខចម្លើយរបស់អ្នក។

ក) សិក្សារៀនសូត្រដោយយកចិត្តទុកដាក់ ដើម្បីប្រឡងជាប់។

ខ) បង្កើតដោះសារ ចំពោះកំហុសដ៏ឆោតល្ងង់ដែលយើងបានធ្វើ។

គ) សម្រាក ក្រោយពីធ្វើការយ៉ាងនឿយហត់។

ឃ) ឆ្លងផ្លូវទៅម្ខាងទៀត ដើម្បីគេចមុខពីមនុស្សដែលមានចិត្តអាក្រក់។

ង) សុំទោស នៅពេលដែលអ្នកបាន ធ្វើឲ្យមនុស្សម្នាក់ទាស់ចិត្ត។

ច) រងចាំទិញនាឡិកាថ្មីមួយ ក្រោយពេលដែលបង់រ៉ាក់យប័ត្រផ្សេងៗរួចរាល់។

ឆ) នៅឲ្យឆ្ងាយពីមនុស្សដែលមានឥទ្ធិពលមិនល្អមកលើយើង។

មនសិការ និង ការគ្រប់គ្រងខ្លួនឯង

វត្ថុបំណងទី៨. *ស្គាល់ពីពាក្យពិតដែលទាក់ទងនឹង ការប្រើប្រាស់យ៉ាងសមស្រប នៃមនសិការ និង ការគ្រប់គ្រងខ្លួនឯង។*

មនសិការ គឺជាពាក្យដែលយើងប្រើប្រាស់ដើម្បីហៅ សម្លេង ឬ "អារម្មណ៍" មួយនៅក្នុងយើងដែលប្រាប់យើងថាអ្វីដែលល្អ និង អ្វីដែលអាក្រក់។ មានពេលខ្លះមនសិការរបស់អ្នកអាចជាគ្រឿងជំនួយអ្នកដោះស្រាយបញ្ហា។ ខ្ញុំនិយាយ *ពេលខ្លះ* ព្រោះប្រសិនបើអ្នកព្រងើយកន្តើយ ចំពោះមនសិការរបស់អ្នក សាររបស់វាក៏នឹងមិនច្បាស់លាស់ដែរ។ រឿងដ៏គួរឲ្យសោកស្តាយនេះ ត្រូវបានបង្រៀននៅក្នុង គម្ពីរ៉ូម១: ១៨-៣២។ រឿងនេះត្រូវបានបកស្រាយនៅក្នុងខទី២៨៖ "ដោយពួកគេយល់ថា មិនបាច់ស្គាល់ព្រះជាម្ចាស់យ៉ាងច្បាស់ ព្រះអង្គក៏បណ្តោយគេទៅតាមគំនិតឥតពិចារណារបស់ខ្លួន គឺអោយគេប្រព្រឹត្តអំពើដែលមិនត្រូវប្រព្រឹត្ត។" នៅពេលដែលមនសិការរបស់អ្នកបញ្ចេញសញ្ញាប្រកាសអាសន្ន ហើយអ្នកនៅតែព្រងើយកន្តើយ នោះអ្នកកំពុងតែប្រើប្រាស់វាខុសហើយ។

ប្រសិនបើអ្នកទូលសូមឲ្យព្រះវិញ្ញាណដ៏វិសុទ្ធ នាំផ្លូវអ្នក និង ប្រសិនបើអ្នកស្តាប់បង្គាប់សេចក្តីបង្រៀនរបស់ទ្រង់ អ្នកអាចពឹងផ្អែកលើមនសិការរបស់អ្នក ក្នុងការដាស់តឿនអ្នកអំពីអ្វីដែលខុសឆ្គងបាន។ ប្រសិនបើអ្នកឆាប់ទទួលអារម្មណ៍ដឹង ពីការដាស់តឿននៃមនសិការរបស់អ្នក នោះអ្នកនឹងមានអារម្មណ៍ថាមានទោសនៅពេលណាដែលអ្នកបានធ្វើរឿងខុសឆ្គង ហើយអ្នកនឹងទូលសូមការលើកលែងទោសពីព្រះជាម្ចាស់ជាមិនខាន។ រក្សាមនសិការរបស់អ្នកឲ្យឆាប់ទទួលអារម្មណ៍ដឹង ដោយការយកចិត្តទុកដាក់ទៅលើ សម្លេងដាស់តឿននៅក្នុងវា! ក្រោយមកទៀត វាអាចជាឧបករណ៍ដ៏មានតម្លៃក្នុងការជួយអ្នកដោះស្រាយបញ្ហា។ វានឹងជួយអ្នកឲ្យដឹងថាតើដំណោះស្រាយមួយណាដែលគួរតែច្រានចោល។

មានបីផ្នែកដែល *ការគ្រប់គ្រងខ្លួនឯង* មានភាពចាំបាច់នៅក្នុងការបញ្ចៀសបញ្ហា ឬ ដោះស្រាយបញ្ហាដែលមានស្រាប់ ដែលយើងបាននាំមកដាក់លើខ្លួនឯង។ វាគឺជាការគ្រប់គ្រង *គំនិត ពាក្យសំដី* និង *អាកប្បកិរិយា* ។ ខ្ញុំបានផ្សារភ្ជាប់ទៅជាមួយនឹង មនសិការ ព្រោះមនសិការរបស់អ្នកនឹងដាស់តឿនអ្នកនៅពេលដែលអ្នកទន់ខ្សោយនៅក្នុងផ្នែកទាំងអស់។

គំនិត គឺជាឫសគល់នៃពាក្យសំដី និង សកម្មភាពមកខាងក្រៅ។ ព្រះយេស៊ូបានបង្រៀនថា ការសម្លាប់មនុស្សមានឫសគល់របស់វា នៅក្នុងគំនិត និង ពាក្យសំដីដែលមានកំហឹង ឯអំពីកំផិត ចាប់ផ្តើមជាមួយការគិតមិនស្អាតស្អំ (គម្ពីរម៉ាថាយ ៥:២១-៣០)។ គំនិតរបស់អ្នកគឺស្ថិតនៅក្នុងការគ្រប់គ្រងដោយផ្ទាល់របស់អ្នក។ អ្នកអាចបដិសេធមិនរស់នៅក្នុងគំនិតដែលនឹងនាំអ្នកទៅរកបញ្ហាបាន។ ចូរធ្វើតាមសេចក្តីបង្រៀននៅក្នុង ខគម្ពីរ៖

> ជាទីបញ្ចប់ បងប្អូនអើយ សូមបងប្អូនគិតតែអំពីអ្វីៗដែលពិត ថ្លៃថ្នូរ សុចរិត បរិសុទ្ធ គួរអោយស្រឡាញ់ គួរអោយគោរព និងគំនិតណាដែលល្អឥតខ្ចោះ គួរអោយកោតសរសើរ។
> (គម្ពីរភីលីព ៤:៨)

មធ្យោបាយមួយដើម្បីដាក់ការគិតល្អៗទៅក្នុងគំនិតរបស់អ្នកគឺ ត្រូវអានសៀវភៅដែលជំរុញចិត្ត និងជួយអ្នក។ មានសៀវភៅគ្រិស្តបរិស័ទល្អៗជាច្រើន ដែលអាចផ្តល់ការយល់ដឹងជ្រៅជ្រះទៅក្នុងបញ្ហា និងបទពិសោធន៍របស់គ្រិស្តបរិស័ទដទៃទៀត។ នៅពេលដែលខ្ញុំអានសៀវភៅបែបនោះ និង រៀនពីរបៀបដែលព្រះជាម្ចាស់បាននាំផ្លូវ អ្នកដទៃក្នុងការដោះស្រាយបញ្ហារបស់គេ ខ្ញុំទទួលបានការលើកទឹកចិត្តថា ទ្រង់ក៏នឹងនាំផ្លូវខ្ញុំដូចគ្នា។ គ្រិស្តបរិស័ទគួរតែមានការប្រុងប្រយ័ត្នចំពោះជម្រើស សៀវភៅ ទស្សនាវដ្តី កម្មវិធីទូរទស្សន៍ ឬ វិទ្យុ និង ការកំសាន្តតាមបែបផ្សេងៗ ដើម្បីឲ្យពួកគេអាចគ្រប់គ្រងគំនិតរបស់ពួកគេដោយប្រុងប្រយ័ត្ន។

ការគ្រប់គ្រង *ពាក្យសំដី* ប្រហែលជាកិច្ចការដ៏ពិបាកបំផុតមួយ។ លោកសាវ័កយ៉ាកុបប្រាប់យើងនៅក្នុងគម្ពីរយ៉ាកុប ៣:២ ថា៖ " យើងទាំងអស់គ្នាតែងតែធ្វើខុសជាច្រើន។ អ្នកណាឥតធ្វើខុសដោយពាក្យសំដី អ្នកនោះជាមនុស្សគ្រប់លក្ខណៈ អាចត្រួតលើខ្លួនឯងទាំងមូលបាន។" ចូរអានខទី៣ ដល់ខទី១២ នៅក្នុងជំពូកនេះដែរ។ ខទាំងនេះបញ្ជាក់ឲ្យឃើញថា អណ្តាតអាចជាអាវុធដ៏គ្រោះថ្នាក់យ៉ាងណា។ ប្រាកដណាស់ វាអាចបង្កបញ្ហាដ៏ធំសម្រាប់យើង ប្រសិនបើយើងមិនគ្រប់គ្រងវាទេនោះ។

លំហាត់អនុវត្តន៍

១៧ ចូរអានគម្ពីរសុភាសិត ១០:១៩; ១៧:២៨ និង ៣០:៣២។ តើសារបន្ទូលនៅក្នុងគម្ពីរនេះគឺជាអ្វី? ចូរជ្រើសរើសចម្លើយត្រឹមត្រូវ។

ក) មិនត្រូវនិយាយជាមួយអ្នកណាដែលឆ្លាតវៃជាងអ្នកឡើយ។

ខ) ប្រុងប្រយ័ត្នចំពោះអ្វីដែលអ្នកនិយាយ ត្រូវគ្រប់គ្រងអណ្តាត។

គ) អ្នកអាចបង្ហាញ ថាអ្នកឆ្លាតវៃយ៉ាងណា ដោយការនិយាយអ្វីដែលនៅក្នុងគំនិតរបស់អ្នក។

១៨ តើសារបន្ទូលដែលនៅក្នុងគម្ពីរសុភាសិត ២១:២៣ និង ១០:១៤។

.....

ទាំងនេះគឺជាលទ្ធផលខ្លះៗដែលបានមកពីការមិនគ្រប់គ្រងអណ្តាត៖

១. *វាបំបែកបំបាក់មិត្តភក្តិ* (គម្ពីរសុភាសិត ១៦:២៨)៖ "អ្នកអុជអាលរមែងបំផ្លាញមិត្តភាព។"

២. *វាបង្កឲ្យមានរបួសធ្ងន់*(គម្ពីរសុភាសិត ១៨:៨)៖ "ពាក្យសំដីរបស់មនុស្សអុជអាល ប្រៀបដូច ជាចំណីយ៉ាងឆ្ងាញ់ជាប់ក្នុងចិត្ត"។

៣. *វាបង្កឲ្យមានជំលោះរវាងបងប្អូន* (គម្ពីរសុភាសិត ៦:១៦, ១៩)៖ "មានអំពើ....ដែលព្រះអម្ចាស់មិនសព្វព្រះហឫទ័យ ....ធ្វើជាសាក្សីក្លែងក្លាយ ដែលពោលពាក្យមិនពិត និងការបង្កជំលោះបំបាក់បំបែកបងប្អូន។"

នៅពេលដែលអ្នកបានរៀនគ្រប់គ្រងគំនិត និង ពាក្យសំដីរបស់អ្នកបានល្អហើយ អ្នកក៏អាចនឹងគ្រប់គ្រងអាកប្បកិរិយារបស់អ្នកបានល្អប្រសើរផងដែរ។ នៅក្នុងការធ្វើរឿងទាំងនេះ អ្នកត្រូវការជំនួយពីព្រះវិញ្ញាណដ៏វិសុទ្ធ ព្រោះនិស្ស័យបាបរបស់អ្នកអាចនាំអ្នកឲ្យធ្វើអ្វីដែលខុសឆ្គងបាន។ លោកសាវ័កប៉ូលបានដឹងពីរឿងនេះ ។ លោកបានពិភាក្សាអំពីវានៅក្នុងគម្ពីរ រ៉ូម ៧:១៨-១៩ និង ២៤:២៥៖

ដ្បិតខ្ញុំដឹងថា អ្វីៗដែលល្អមិនស្ថិតនៅក្នុងខ្ញុំទេ ពោលគឺមិនស្ថិតនៅក្នុងខ្ញុំដែលមានន័ស្ស័យលោកីយ៍ទេ។ ខ្ញុំមានឆន្ទៈនឹងធ្វើអំពើល្អ តែខ្ញុំគ្មានសមត្ថភាពនឹងប្រព្រឹត្តអំពើល្អបានឡើយ។ ខ្ញុំមិនប្រព្រឹត្តអំពើល្អ ដែលខ្ញុំចង់ធ្វើនោះទេ តែបែរជាប្រព្រឹត្តអំពើអាក្រក់ដែលខ្ញុំមិនចង់ធ្វើទៅវិញ។ .... ខ្ញុំវេទនាណាស់! តើនរណានឹងដោះលែងខ្ញុំអោយរួចពីរូបកាយ ដែលតែងតែស្លាប់នេះ បាន? សូមអរព្រះគុណព្រះជាម្ចាស់ តាមរយៈព្រះយេស៊ូគ្រិស្តជាអម្ចាស់នៃយើង!

លំហាត់អនុវត្តន៍

១៩ ចូរគូសរង្វង់ជុំវិញអក្សរនៃប្រយោគត្រឹមត្រូវដែលទាក់ទងនឹង មនសិការ និង ការគ្រប់គ្រងខ្លួនឯង។

ក) មនសិការរបស់ខ្ញុំគឺជា "សម្លេងនៅខាងក្នុង" មួយដែលព្រះជាម្ចាស់បានប្រទានមកឲ្យខ្ញុំដើម្បីនាំផ្លូវខ្ញុំបែរចេញពីបាប។

ខ) នៅពេលដែលខ្ញុំបដិសេធមនសិការរបស់ខ្ញុំ វានឹងនៅតែផ្តល់សញ្ញាដាស់តឿងយ៉ាងច្បាស់មកកាន់ខ្ញុំ អំពីអ្វីដែលខុសឆ្គង។

គ) ខ្ញុំអាចទុកចិត្តមនសិការរបស់ខ្ញុំ ក្នុងការផ្តល់សញ្ញាត្រឹមត្រូវមកឲ្យខ្ញុំ ដរាបណាខ្ញុំអនុញ្ញាតឲ្យព្រះវិញ្ញាណដ៏វិសុទ្ធនាំផ្លូវ និង បង្រៀនខ្ញុំ។

ឃ) អ្វីដែលខ្ញុំនិយាយ និង ធ្វើ មានឫសគល់របស់វា នៅក្នុងអ្វីដែលខ្ញុំគិត។

ង) អ្វីដែលខ្ញុំអាន និង ស្តាប់ គ្មានឥទ្ធិពលនៅក្នុងជីវិតរបស់ខ្ញុំជារៀងរហូតនោះទេ។

ច) ប្រសិនបើខ្ញុំរៀនគ្រប់គ្រងអណ្តាតរបស់ខ្ញុំ ខ្ញុំនឹងគ្មានបញ្ហាអ្វី ក្នុងការគ្រប់គ្រងផ្នែកផ្សេងៗទៀតនៅក្នុងជីវិតរបស់ខ្ញុំឡើយ។

ឆ) ខ្ញុំត្រូវការឫទ្ធានុភាពរបស់ព្រះយេស៊ូគ្រិស្តនៅក្នុងជីវិតរបស់ខ្ញុំ ដើម្បីឲ្យខ្ញុំអាចអនុវត្តការគ្រប់គ្រងខ្លួនឯងបានយ៉ាងជោគជ័យ។

អ្នកដទៃ

វត្ថុបំណងទី៩ *វិភាគវែកញែកពីអារម្មណ៍របស់អ្នក អំពីការស្វែងរកជំនួយពីអ្នកដទៃសម្រាប់បញ្ហារបស់ ខ្លួន និង ប្រៀបធៀបអារម្មណ៍របស់អ្នកទៅជាមួយឥរិយាបថទាំងប៉ុន្មានដែលបានណែនាំនៅក្នុងមេរៀននេះ។*

បញ្ហាជាច្រើនរបស់អ្នកអាចត្រូវបានដោះស្រាយ ដោយការដើរតាមមនសិការ ការប្រើប្រាស់សុភនិច្ឆ័យ និង ហេតុផល។ អ្នកអាចរកឃើញដំណោះស្រាយសម្រាប់បញ្ហាឯទៀតតាមរយៈការអធិស្ឋាន និង ការនាំផ្លូវរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ពេលខ្លះបញ្ហាមួយ អាចធ្ងន់ធ្ងៃ និង មានលក្ខណៈផ្ទាល់ខ្លួនដែលអ្នកគួរតែយកវាទៅថ្វាយព្រះជាម្ចាស់តែមួយគត់ ហើយអនុញ្ញាតឲ្យទ្រង់បង្កើតបានជាដំណោះស្រាយនៅក្នុងចិត្តរបស់អ្នក ប៉ុន្តែព្រះជាម្ចាស់ទ្រង់តែងតែប្រើប្រាស់អ្នកដទៃ ជាឧបករណ៍របស់ទ្រង់សម្រាប់ជួយអ្នកស្វែងរកដំណោះស្រាយចំពោះបញ្ហារបស់អ្នក។

មិត្តភក្តិ និង មនុស្សដែលខ្វល់ខ្វាយ។ អ្នកប្រហែលជាកំពុងចាប់ផ្តើមស្វែងរក មិត្តដ៏ឈ្លាសវៃ និង ល្អស្មោះត្រង់ម្នាក់ (បុគ្គលម្នាក់ដែលអាចជឿទុកចិត្តបានក្នុងការរក្សារឿងសម្ងាត់បាន)។ មិត្តភក្តិ មានគុណប្រយោជន៍មួយគឺ មិនជាប់ជំពាក់ខាងអារម្មណ៍នៅក្នុងបញ្ហាឡើយ។ ដោយសារតែគេស្ថិតនៅក្រៅស្ថានភាពនោះ គេអាចមើលមកបញ្ហារបស់យើងពីជ្រុងមួយផ្សេងទៀត។ យោបល់របស់គេគួរតែផ្តែកទៅលើការបង្រៀននៅក្នុងខគម្ពីរ។

មិត្តភក្តិដែលជាគ្រិស្តបរិស័ទតែងតែអាចជាព្រះពរសម្រាប់គ្នាទៅវិញទៅមកនៅក្នុងរឿងនេះ។ ក្រុមអធិស្ឋាន ថ្នាក់ថ្ងៃអាទិត្យ និងក្រុមតូចៗផ្សេងទៀត ដែលនៅក្នុងក្រុមជំនុំ អាចធ្វើការចែកចាយ និងអធិស្ឋានរួមគ្នា។ ខ្ញុំបានឃើញ ដំណោះស្រាយដ៏អស្ចារ្យជាច្រើនសម្រាប់បញ្ហាបានកើតមានឡើង ជាលទ្ធផលនៃការអធិស្ឋានរួមគ្នា របស់ក្រុមគ្រួសារនៅក្នុងក្រុមជំនុំ ដែលមានចិត្តខ្វល់ខ្វាយ។

ម្យ៉ាងវិញទៀត *អ្នក* អាចជាមិត្តដែល នរណាម្នាក់កំពុងត្រូវការ។ ខ្ញុំសង្ឃឹមថាការសិក្សាមុខវិជ្ជានេះនឹងជួយអ្នក កាន់តែឆាប់ទទួលអារម្មណ៍ដឹងពីតម្រូវការរបស់អ្នកដទៃ និង អាចមានសមត្ថភាពកាន់តែប្រសើរដើម្បីជួយពួកគេស្វែងរកដំណោះស្រាយសម្រាប់បញ្ហារបស់ពួកគេ។

អ្នកជំនាញប្រឹក្សាយោបល់ ។ មានបញ្ហាខ្លះទៀតដែលធ្ងន់ឡើង និង ស្មុគស្មាញខ្លាំងណាស់ដែលមធ្យោបាយដ៏ល្អបំផុតរបស់ព្រះជាម្ចាស់ក្នុងការជួយអ្នកគឺមានតែតាមរយៈយោបល់របស់បុគ្គលដែលមានចំណេះដឹង និង ការហ្វឹកហ្វឺនជាពិសេស។ បញ្ហាខាង ជំងឺ និង ផ្លូវចិត្ត តែងតែត្រូវការជំនួយពិសេសប្រភេទនេះ។ ក៏មានបញ្ហាដែល ពិបាក និង សំងាត់ ដែលមិនគួរនឹងចែកចាយជាមួយមិត្តភក្តិបានទេ ព្រោះពួកគេប្រហែលជាគ្មានចំណេះដឹងគ្រប់គ្រាន់ដើម្បីជួយអ្នកស្វែងរកដំណោះស្រាយដ៏ល្អបំផុតបានឡើយ។

នៅក្នុងករណីនេះ អ្នកគួរតែស្វែងរកយោបល់របស់អ្នកជំនាញ ពីគ្រូគង្វាល អ្នកប្រឹក្សាយោបល់អាជីព គ្រូពេទ្យដែលជាគ្រិស្តបរិស័ទ ឬ អ្នកដទៃបានធ្វើឲ្យកង្វល់របស់អ្នកទៅជាការសិក្សាពិសេសរបស់គេ។ ព្រះជាម្ចាស់អាចប្រើប្រាស់ ការវិនិច្ឆ័យរបស់ពួកគេ ដូចដែលទ្រង់អាចប្រើការវិនិច្ឆ័យរបស់អ្នកផងដែរ។ ត្រូវតែប្រាកដថា អ្នកជ្រើសរើសអ្នកប្រឹក្សាយោបល់ជាគ្រិស្តបរិស័ទ ឬ អ្នកប្រឹក្សាយោបល់ដែលនឹងមិនជំទាស់នឹងគោលការណ៍របស់គ្រិស្តបរិស័ទនៅក្នុងជីវិតរបស់អ្នកនោះទេ។

លំហាត់អនុវត្តន៍

២០ មនុស្សមានអារម្មណ៍ខុសៗគ្នា ទាក់ទងនឹងការចែកចាយពីបញ្ហារបស់ពួកគេជាមួយអ្នកដទៃ។ ចូរសរសេរ **ស** សម្រាប់ ការយល់ស្រប និង **ម** សម្រាប់ការមិនយល់ស្រប នៅពីមុខប្រយោគ ខាងក្រោម ដើម្បីជាប្រយោជន៍ក្នុងការធ្វើការវិភាគវែកញែកពីអារម្មណ៍ផ្ទាល់ខ្លួន និង បទ ពិសោធន៍របស់អ្នក បន្ទាប់មកធ្វើការប្រៀបធៀបចម្លើយរបស់អ្នកជាមួយនឹង យោបល់ដែល វិជ្ជមាន ដែលយើងបានបង្កើតឡើង។

.....ក) ខ្ញុំមិនចង់រំខានអ្នកដទៃជាមួយនឹងបញ្ហារបស់ខ្ញុំនោះទេ។

.....ខ) ការសុំជំនួយ ចំពោះបញ្ហាមួយ វាអាចជាសញ្ញានៃភាពទន់ខ្សោយ។

.....គ) ខ្ញុំគ្មានមិត្តភក្តិជាគ្រិស្តបរិស័ទណាម្នាក់ដែលខ្ញុំអាចចែករំលែកបញ្ហារបស់ខ្ញុំជាមួយបានឡើយ។

.....ឃ) វាពិតជាគួរឲ្យខ្មាស់ណាស់ ដែលឲ្យនរណាម្នាក់ដឹងថាខ្ញុំមានបញ្ហានោះ។

.....ង) ខ្ញុំមិនចែករំលែកបញ្ហារបស់ខ្ញុំក៏ដោយព្រោះតែ មនុស្សមានបញ្ហាផ្ទាល់ខ្លួន គ្រប់គ្រាន់ហើយសម្រាប់ឲ្យគេគិត។

.....ច) ខ្ញុំបានរៀនមកថា អ្នកមិនគួរទុកចិត្តអ្នកដទៃជាមួយបញ្ហារបស់អ្នកឡើយ។

.....ឆ) មិត្តភក្តិរបស់ខ្ញុំ មិនចង់មកខ្វល់ខ្វាយជាមួយបញ្ហារបស់ខ្ញុំទេ។

.....ជ) ខ្ញុំតែងតែទទួលបានជំនួយសម្រាប់បញ្ហារបស់ខ្ញុំពីមិត្តភក្តិជាគ្រិស្តបរិស័ទ។

.....ឈ) ខ្ញុំតែងតែបានជួយមិត្តរបស់ខ្ញុំជាមួយនឹងបញ្ហារបស់ពួកគេ។

.....ញ) មនុស្សគ្រប់គ្នាសុទ្ធតែមានបញ្ហា ដូច្នេះហើយវាគ្មានអ្វីគួរឲ្យអាម៉ាស់នោះទេ ក្នុងការទទួលស្គាល់ថាអ្នកត្រូវការជំនួយចំពោះបញ្ហានោះ។

.....ដ គ្រិស្តបរិស័ទគួរតែពឹងផ្អែកលើអភ័យឯកសិទ្ធិក្នុងការចែករំលែកសេចក្តីអធិស្ឋានអំពីបន្ទុកក្នុងចិត្តជាមួយនឹងបងប្អូនប្រុសស្រីនៅក្នុងព្រះគ្រិស្ត។

.....ថ អ្នកប្រឹក្សាយោបល់ដ៏ឈ្លាសវៃ នឹងរក្សាទុកបញ្ហារបស់អ្នកនៅជាមួយគាត់ លុះត្រាតែអ្នកសុំឲ្យគាត់ចែករំលែកវាជាមួយអ្នកដទៃ។

នៅក្នុងមេរៀននេះ យើងបានពិភាក្សាអំពីមធ្យោបាយរបស់គ្រិស្តបរិស័ទក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហារបស់យើង។ នៅក្នុងមេរៀនបន្ទាប់ យើងនឹងពិភាក្សាគ្នា អំពីគោលការណ៍ចម្បងសម្រាប់ការដោះស្រាយបញ្ហា និង របៀបដែលអ្នកអាចយកគោលការណ៍ទាំងនេះទៅអនុវត្តសម្រាប់បញ្ហានៅក្នុងជីវិតរបស់អ្នកផ្ទាល់។ យើងសង្ឃឹមថាការសិក្សានេះ នឹងជួយធ្វើឲ្យជីវិតរបស់អ្នកចម្រើនឡើង និងជាការលើកទឹកចិត្តមួយសម្រាប់អ្នកផងដែរ។

ការប្រឡងផ្ទាល់ខ្លួន

សំណួរពហុជម្រើស ៗ ចូរជ្រើសរើសចម្លើយល្អបំផុត សម្រាប់បំពេញប្រយោគខាងក្រោមនេះ។

១ ការសារភាពបាប រួមបញ្ចូលទាំងការ ទទួលស្គាល់ថា ខ្ញុំបានធ្វើអំពើបាប និង ថា
   ក) ព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ។
   ខ) ខ្ញុំស្រឡាញ់អ្នកជិតខាងរបស់ខ្ញុំ។
   គ) ព្រះយេស៊ូគឺជាព្រះអម្ចាស់។

២ បញ្ហាសំខាន់បំផុត ដែលខ្ញុំនឹងត្រូវប្រឈមមុខនៅក្នុងជីវិតរបស់ខ្ញុំគឺ
   ក) ភាពអាត្មានិយម
   ខ) បញ្ហាអំពើបាប
   គ) ខ្វះការគ្រប់គ្រងខ្លួនឯង

៣ ការរស់ឡើងវិញរបស់ព្រះគ្រិស្ត គឺមានសារៈសំខាន់ណាស់សម្រាប់ការប្រោសលោះរបស់ខ្ញុំ ព្រោះ
   ក) វាផ្តល់មធ្យោបាយដើម្បីឲ្យខ្ញុំបានរួចពីការផ្តន្ទាទោសនៃសេចក្តីស្លាប់បាន។
   ខ) វាទាក់ទងទៅនឹងអំពើបាបរបស់លោកអដាំ និង និស្ស័យបាបរបស់ខ្ញុំ។
   គ) គឺជាភស្តុតាងតែមួយគត់របស់ខ្ញុំ ថាព្រះគ្រិស្តគឺជាបុត្រារបស់ព្រះជាម្ចាស់។
   ឃ) វាផ្តល់ឲ្យខ្ញុំមានជ័យជម្នះលើបាបបាន។

៤ យើងបង្ហាញពីក្តីស្រឡាញ់របស់យើងសម្រាប់ព្រះគ្រិស្តបានតាមរយៈ
   ក) ការនិយាយថា យើងស្រឡាញ់ទ្រង់។
   ខ) ការមិនព្រមមានចិត្តខឹង។
   គ) ការជៀសវាងបញ្ហា។
   ឃ) ការស្តាប់តាមព្រះបន្ទូលរបស់ទ្រង់។

៥ ដោះស្រាយទាំងអស់ដែលអាចធ្វើបាន ត្រូវតែធ្វើនៅក្នុងពន្លឺរបស់
   ក) សុភនិច្ឆ័យ
   ខ) មនសិការ
   គ) បទគម្ពីរ
   ឃ) យោបល់របស់មិត្តភក្តិ

ត្រូវ/ ខុសៗ ចូរសរសេរអក្សរ ត នៅពីមុខប្រយោគដែលត្រឹមត្រូវ និង អក្សរ ខ នៅពីមុខប្រយោគដែលខុស។

.....៦ ព្រះគម្ពីរមានផ្ទុក ការណែនាំរបស់ព្រះជាម្ចាស់សម្រាប់ ការបញ្ឈៀសបញ្ហា។

.....៧ ព្រះគ្រិស្តយាងមកដើម្បី ផ្លាស់ប្តូរក្រឹត្យវិន័យ។

.....៨ សេចក្តីបង្រៀនរបស់ព្រះគ្រិស្ត ទាមទារឲ្យយើងធ្វើតិចជាងការបង្រៀននៅក្នុងគម្ពីរក្រឹត្យវិន័យ សម្ព័ន្ធមេត្រីចាស់។

.....៩ ព្រះគ្រិស្តបានបញ្ជាក់ អំពីអ្វីដែលយើងគួរធ្វើ ឲ្យបានច្រើនតាមតែអ្វីដែលយើងគួរធ្វើ។

.....១០ ឥរិយាបថដែលខុសឆ្គងអាចធ្វើឲ្យគ្រប់បញ្ហាកាន់តែធ្ងន់ឡើង។

.....១១ ការអធិស្ឋាន និង ការនាំផ្លូវពីព្រះវិញ្ញាណដ៏វិសុទ្ធ មានភាពចាំបាច់តែនៅពេលដែលសុភនិច្ឆ័យរបស់យើង បរាជ័យតែប៉ុណ្ណោះ។

.....១២ បទបញ្ជាដែលសំខាន់ជាងគេគឺជា ការគ្រប់គ្រងអណ្តាតរបស់អ្នក។

.....១៣ ក្រឹត្យវិន័យ គឺត្រូវបានបង្គ្រប់ន័យ ដោយឥរិយាបថនៃក្តីស្រឡាញ់។

.....១៤ មនសិការរបស់មនុស្សគឺ ដូចគ្នានឹងការនាំផ្លូវរបស់ព្រះវិញ្ញាណដ៏វិសុទ្ធដែរ។

.....១៥ យើងត្រូវតែរក្សាគ្រប់គ្រងគំនិតរបស់យើង ប្រសិនបើយើងគ្រប់គ្រង ពាក្យសំដី និង អាកប្បកិរិយារបស់យើង។

.....១៦ មធ្យោបាយដ៏ល្អមួយ ដើម្បីសាកល្បង យោបល់របស់មិត្តភក្តិ គឺត្រូវដឹងថាវាស្របជាមួយនឹងបទគម្ពីរដែរឬទេ។

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១១ សេចក្តីស្រឡាញ់

១ ពួកគេត្រូវតែសារភាពបាបរបស់ពួកគេ និង សារភាពថាព្រះយេស៊ូគ្រិស្តគឺព្រះអម្ចាស់របស់គេ។

១២ សេចក្តីស្រឡាញ់

២ ទ្រង់លើកលែងទោសឲ្យយើង ទ្រង់សំអាត (បន្សុទ្ធ) យើង ហើយទ្រង់សង្គ្រោះយើងឲ្យរួចផុតពីការផ្តន្ទាទោសនៃអំពើបាប។

១៣ ក) ២) គម្ពីរម៉ាថាយ ២៦:៤១

ខ) ៥) គម្ពីរយ៉ូហាន ១៦:២៤

គ) ៤) គម្ពីរអេភេសូ ៦:១៨

ឃ) ១) គម្ពីរ១កូរិនថូស ១៦:១

ង) ៣) គម្ពីរយ៉ាកុប ៥:១៣

៣ ថាព្រះជាម្ចាស់បានប្រោសឲ្យព្រះយេស៊ូគ្រិស្តមានព្រះជន្មរស់ពីសេចក្តីស្លាប់។

១៤ ទ្រង់នឹងបង្រៀនយើង។

៤ សេចក្តីស្លាប់បានចូលមកក្នុងពិភពលោកតាមរយៈអំពើបាបរបស់លោកអដាំ។ ដោយសារតែយើងមាននិស្ស័យបាបមកពីលោក យើងក៏កើតមកនៅក្នុងអំពើបាបតែម្តង។ ការរស់ឡើងវិញរបស់ព្រះគ្រិស្ត បានជួយរំដោះយើងឲ្យរួចផុតពីការផ្តន្ទាទោសនៃអំពើបាប ដែលជាសេចក្តីស្លាប់នោះ។ ដោយសារតែព្រះគ្រិស្ត យើងអាចមានជីវិតអស់កល្បជានិច្ច។

១៥ ចម្លើយ ក) និង គ) អាចជាដំណោះស្រាយដែលមិនសមហេតុផល។

៥ ជាចម្លើយរបស់អ្នក។ ប្រសិនបើអ្នកបានដោះស្រាយបញ្ហានៃអំពើបាបនៅក្នុងជីវិតរបស់អ្នក ហើយ អ្នកគួរតែអាចឆ្លើយថា បាទ/ចាស ចំពោះគ្រប់ប្រយោគទាំងអស់នេះ។ តើអ្នកយើញពីភាពចាំបាច់ ក្នុងការដោះស្រាយបញ្ហាដ៏សំខាន់មួយនេះមុនពេលដែលអ្នកទៅដោះស្រាយបញ្ហារបស់អ្នកដទៃដែរឬទេ ?

១៦ ចម្លើយ ក), គ), ង) និង ឆ) ជាឧទាហរណ៍ត្រឹមត្រូវ ។ ចម្លើយ ង) ក៏អាចនឹងទាក់ទង ជាមួយនឹងមនសិការរបស់យើងផងដែរ។

៦ ទីមួយ ដើម្បីឲ្យអ្នកអាចស្តាប់បង្គាប់ព្រះគ្រិស្តបាន យើងត្រូវដឹងពីអ្វីដែលទ្រង់សព្វព្រះហឫទ័យឲ្យយើងធ្វើ។ យើងអាចរកឃើញ រឿងនេះនៅក្នុងការបង្រៀនរបស់ទ្រង់។ ទីពីរ ព្រះគម្ពីរមានផ្តុំកការណែនាំរបស់ព្រះជាម្ចាស់ អំពីរបៀបដែលយើង ជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់ គួរតែរស់នៅ ដើម្បីមានជីវិតដ៏ជោគជ័យមួយ។

១៧ ខ) ប្រុងប្រយ័ត្នចំពោះអ្វីដែលអ្នកនិយាយ ត្រូវគ្រប់គ្រងអណ្តាត។

៧ (ចម្លើយរបស់អ្នកប្រហែលជាមិនដូចចម្លើយរបស់ខ្ញុំទាំងស្រុងនោះទេ។ ខ្ញុំបានណែនាំលទ្ធផលចម្បងខ្លះៗ។ ប្រាកដណាស់ វាពិតជាមានលទ្ធផលជាច្រើនផ្សេងទៀត។)

ក្រឹត្យវិន័យដែលត្រូវបានល្មើស	**លទ្ធផលដែលអាចកើតមានឡើង**
ក) ទី១	បញ្ហាក្នុងគ្រួសារ, ការស្លាប់ខាងវិញ្ញាណ, ជាដើម
ខ) ទី៨	បាបរបស់គេនឹងត្រូវបានគេដឹង, មនុស្សគ្រប់គ្នានឹងដឹងពីអ្វីដែលគេបានធ្វើ, ពួកគេនឹងត្រូវបានបណ្តេញចេញពីសាលា, ជាដើម
គ) ទី៧ និង ទី១០	មានអារម្មណ៍អាម៉ាស់មុខ, ប្រពន្ធរបស់គាត់មិនសប្បាយចិត្ត, មានគ្រួសារពីរដែលត្រូវបែកបាក់ ជាដើម
ឃ) ទី៩ និង ទី១០	ខូចឈ្មោះរបស់អ្នកជិតខាងនោះ, នៅពេលដែលអ្នកជិតខាងនោះដឹងពីអ្វីដែលនាងបាននិយាយ, គេនឹងក្លាយទៅជាសត្រូវរបស់នាង ហើយនឹងរកមធ្យោបាយធ្វើបាបនាងដើម្បីជាការសងសឹក ជាដើម

១៨ ប្រសិនបើអ្នកមិនគ្រប់គ្រងអណ្តាតរបស់អ្នក អ្នកនឹងនាំបញ្ហា និង ភាពហិនហោចមកដាក់លើខ្លួនអ្នកហើយ។

៨ ចម្លើយរបស់អ្នក។ តើអ្នកឃើញ អំពីមូលហេតុដែលព្រះជាម្ចាស់ប្រទានក្រឹត្យវិន័យទាំងអស់មកឲ្យយើង និង មូលហេតុដែលព្រះយេស៊ូ និង គ្រូបង្រៀនដទៃទៀតនៅក្នុងសម័យសម្ព័ន្ធមេត្រីថ្មី ខំប្រឹងបញ្ជាក់ពីសារៈសំខាន់នៃការស្តាប់បង្គាប់ក្រឹត្យវិន័យទាំងនេះដែរឬទេ?

១៩ ក), គ), ឃ, ច), និង ឆ) ជាចម្លើយត្រឹមត្រូវ។

៩ ក) ៤) ឯករាជ្យ
ខ) ១) ដោយចេតនា(ចង់ដើរផ្លូវខ្លួនឯង) ឬ ៦) ពេញដោយបាប
គ) ៣) អំណត ឬ ១) ដោយចេតនា (ចង់ដើរផ្លូវខ្លួនឯង)
ឃ) ២) មិនស្តាប់បង្គាប់
ង) ៧) មិនចេះអត់ទោស
ច) ៦) ពេញដោយបាប
ឆ) ៨) អ្នកបង្កបញ្ហា
ជ) ៥) គ្មានសង្ឃឹម

២០ សង្ឃឹមថាអ្នក មិនបានយល់ស្របជាមួយនឹងប្រយោគ ក) ដល់ ឆ) ហើយយល់ស្របជាមួយនឹងប្រយោគ ជ) ដល់ ច)។

១0

អ្វីដែលជាក្តីស្រឡាញ់	**អ្វីដែលមិនមែនជាក្តីស្រឡាញ់**	**អ្វីដែលក្តីស្រឡាញ់ធ្វើ**	**អ្វីដែលក្តីស្រឡាញ់មិនធ្វើ**
-អត់ធ្មត់	-អួតបំប៉ាង	-រីករាយនឹងសេចក្តីពិត	-ឈ្នានីសគេ
-ជួយធុរៈគេ	-ប្រព្រឹត្តអំពើថោកទាប	-អត់ឱន	-វាយឫកខ្ពស់
	-ស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន	-ជឿ	-ចងគំនុំ
	មួម៉ៅ	-សង្ឃឹម	-អបអរនឹងអំពើទុច្ចរិត
		-ទ្រាំទ្រ	-សាបសូន្យ

ជំពូក ៣ គោលការណ៍របស់គ្រិស្តបរិស័ទក្នុងការដោះស្រាយបញ្ហា

ប្រសិនបើអ្នកនៅក្នុងទីឃុំឃាំង មានអ្នកយាមប្រដាប់ដោយអាវុធ នៅយាមជុំជិត និង បានដកហូតសិទ្ធិសេរីភាពរបស់អ្នកមិនឲ្យទៅណាមកណាបានតាមចិត្ត អ្នកប្រហែលជានឹងនិយាយថា អ្នកមានបញ្ហាមួយ ឬ បញ្ហាច្រើនជាក់ជាមិនខាន! អ្នកអាចនឹងមានអារម្មណ៍ថា ដំណោះស្រាយល្អបំផុតសម្រាបញ្ហានេះ អាចជាសេរីភាព!

នៅពេលដែលលោកសាវ័កប៉ូល បានដឹងថាខ្លួនគាត់ស្ថិតនៅក្នុងបញ្ហាបែបនេះ គាត់មិនបានឃើញថាវាជាបញ្ហាសោះឡើយ។ ផ្ទុយទៅវិញ លោកបានឃើញវាជាការចាត់តាំងដ៏វិសុទ្ធរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់លោក។ លោកបានចាត់ទុកវាជា *អភ័យឯកសិទ្ធិ* ដែលព្រះជាម្ចាស់ បានប្រទានមកឲ្យគាត់ដើម្បីការពារ និង បង្កើតបានជាដំណឹងល្អ (គម្ពីរភីលីព ១:៧) ។ លោកបានចាត់ទុកវាជា *ឱកាស* ដែលលោកបានទទួលមក ដើម្បីចែកចាយអំពីព្រះយេស៊ូគ្រិស្ត ជាមួយនឹងឆ្មាំយាមវាំង និង ជាមួយមិត្តរួមបេសកកម្មរបស់លោក នៅក្នុងទីក្រុង។នៅក្នុងមេរៀនទី១ យើងបាននិយាយអំពីការឆ្លើយតបរបស់លោកប៉ូលទៅនឹងការជាប់ឃុំឃាំងរបស់លោក។ លោកបានរីករាយ ព្រោះលោកបានដឹងថាព្រះជាម្ចាស់កំពុងតែប្រើប្រាស់លោក ទោះបីជាកំពុងនៅក្នុងគុកក៏ដោយ។

ទស្សនៈវិស័យដែលល្អបំផុត ក្នុងការប្រឈមមុខជាមួយនឹងបញ្ហា ប្រហែលជាត្រូវមើលពួកវា ថា ជាឱកាសដើម្បីអនុវត្តជំនឿ ដើម្បីអនុវត្តការទុកចិត្តព្រះអម្ចាស់ ដើម្បីបញ្ជាក់ពីភាពស្មោះត្រង់ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ និង ដើម្បីបានការទទួលស្គាល់ទ្រង់វិញផងដែរ។ ជំនឿជាគ្រិស្តបរិស័ទរបស់អ្នកនឹងបានកាន់តែរឹងមាំឡើងនៅពេលណាដែលអ្នកធ្វើការរួមជាមួយព្រះអម្ចាស់ដើម្បីស្វែងរកដំណោះស្រាយសម្រាប់បញ្ហាជីវិត។ ទ្រង់ពិតជាដំណោះស្រាយដ៏ត្រឹមត្រូវសម្រាប់បញ្ហាគ្រប់បែបយ៉ាង!

នៅក្នុងមេរៀននេះ យើងនឹងពិចារណាអំពីគោលការណ៍ខ្លះៗរបស់គ្រិស្តបរិស័ទ សម្រាប់ការដោះស្រាយបញ្ហា។នៅពេលដែលអ្នកធ្វើតាមគោលការណ៍ទាំងនេះ អ្នកអាចរំពឹងទុកថា ព្រះជាម្ចាស់នឹងធ្វើការរួមជាមួយអ្នក ហើយអ្នកអាចរំពឹងទុកថា នឹងបានឆ្លងកាត់បញ្ហាគ្រប់បែបយ៉ាង ជាមួយនឹងអំណរ និង ជ័យជម្នះ!

គម្រោងមេរៀន

ក. ចាប់ផ្តើមជាមួយនឹងរបៀបរបស់គ្រិស្តបរិស័ទ
ខ. ជៀសវាងការឆ្លើយតបដែលខុសឆ្គង
គ. ប្រើប្រាស់វិធីសាស្ត្របែបប្រព័ន្ធ
ឃ. អរសប្បាយ និង អរព្រះគុណ

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. វាយតម្លៃស្ថានភាពរបស់អ្នក ដែលទាក់ទងនឹងការបែកចេញ និង ការស្វែងរកបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។
២. ស្គាល់ពីការឆ្លើយតបខុសឆ្គងតាមរយៈឧទាហរណ៍ដែលបានផ្តល់ឲ្យ និង ធ្វើលំហាត់ផ្ទាល់ខ្លួន។
៣. បកស្រាយថា ហេតុអ្វីបានជាវាមានសារៈសំខាន់ម្ល៉េះ ដែលមិនត្រូវព្យាយាមដោះស្រាយបញ្ហារបស់អ្នក ដោយសមត្ថភាពមនុស្សតែម្យ៉ាងនោះ។
៤. ធ្វើតារាងតាមដានមួយ ដើម្បីតាមដានការដោះស្រាយស្ថានភាពរបស់បញ្ហា ដោយផ្អែកលើវិធីសាស្ត្រដែលបានផ្តល់ឲ្យ និង ដាក់តារាងតាមដាននោះទៅលើបញ្ហាដែលបានផ្តល់ឲ្យ។
៥. ប្រាប់ពីគោលការណ៍មួយដែលបកស្រាយពីអ្វីដែលបានជួយលោកសាវ័កប៉ូលឲ្យចេះស្កប់ចិត្តនៅក្នុងគ្រប់កាលៈទេសៈទាំងអស់។

សកម្មភាពក្នុងការសិក្សា

១. សិក្សាមេរៀននេះដោយយោងទៅតាម ការណែនាំដែលបានផ្តល់ឲ្យនៅក្នុងសកម្មភាពក្នុងការសិក្សា នៃមេរៀនទី១ ។ ត្រូវប្រាកដថា អ្នកបានអានខគម្ពីរទាំងអស់ដែលបានដាក់ឲ្យ និង ឆ្លើយរាល់សំណួរសិក្សាទាំងអស់ មុនពេលទៅបើកមើលចម្លើយដែលយើងផ្តល់ជូន នៅចុងបញ្ចប់នៃមេរៀន។
២. បើកទៅមើលពាក្យសំខាន់ ។ ប្រសិនបើពាក្យណាដែលអ្នកមិនធ្លាប់ជួបពីមុនមក ចូរមើលនិយមន័យរបស់វានៅក្នុងអក្ខរានុក្រម។
៣. ធ្វើការប្រឡងផ្ទាល់ខ្លួន នៅចុងបញ្ចប់នៃមេរៀន ហើយផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក។ ចូររំឭកចំណុចណាដែលអ្នកឆ្លើយមិនបានត្រឹមត្រូវ។
៤. បន្ទាប់ពីបានធ្វើការប្រឡងផ្ទាល់ខ្លួនរួចហើយ ចូររំឭកមេរៀនទី១ដល់ទី៣ (នៃជំពូកទីមួយ) ឡើងវិញ។ បន្ទាប់មកបំពេញ *ការប្រឡងជំពូកទីមួយ* ។

ពាក្យសំខាន់

ការចោទប្រកាន់
ការសម្របសម្រួល
កំណាច
ជម្រើស
ភាពល្វីងជូរចត់
ចំណែកថ្នាក់
ចិត្តអាសូរ
ចរិយាមារយាទ
ប្រឈមមុខ
ផលលំបាក
ច្រាស់
ដកចេញ
ភាពជ្រុលនិយម
សន្ទុះចិត្ត
សង្រួមចិត្ត
បំពាន
ប្រតិកម្មតប
ការចុះចាញ់
សងសឹក
អធិធម្មជាតិ
មិនចេះខឹង
ការដកចេញ

ក. ចាប់ផ្តើមជាមួយនឹងរបៀបរបស់ព្រះគ្រិស្តបរិសុទ្ធ

វត្ថុបំណងទី១. *វាយតម្លៃស្ថានភាពរបស់អ្នក ដែលទាក់ទងនឹងការបែកចេញ និង ការស្វែងរកបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។*

សំណួរសំខាន់ៗចំនួនពីរយ៉ាង

ថ្មីៗនេះខ្ញុំ បានឮអំពីគូស្វាមីភរិយាថ្មីមួយគូ ដែលបានសម្រេចចិត្តធ្វើការលែងលះគ្នា។ នៅពេលដែលគេបានរៀបអាពាហ៍ពិពាហ៍ ពួកគេគឺជាគ្រិស្តបរិស័ទដ៏រឹងមាំទាំងពីរនាក់ ដែលបានចូលរួមនៅក្នុងការថ្វាយបង្គំក្នុងព្រះវិហារ ប្រកបដោយជំនឿ ហើយអានព្រះគម្ពីរ និង អធិស្ឋានរួមគ្នាផងដែរ។ ប៉ុន្តែនៅពេលដែលគាត់កាន់តែជាប់រវល់ជាមួយនឹងការងាររបស់គាត់ ហើយប្រពន្ធរបស់គាត់កាន់តែរវល់ជាមួយកូនទាំងពីរនាក់ដែលបានកើតមកនៅក្នុងអំឡុងពេលបួនឆ្នាំដំបូងបន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍ហើយនោះ ជីវិតរបស់ពួកគេកាន់តែរវល់យ៉ាងខ្លាំង។ ទម្លាប់ប្រចាំថ្ងៃក្នុងការអានព្រះគម្ពីរ និង អធិស្ឋានរួមគ្នាកាន់តែថយចុះ ហើយពីមួយថ្ងៃទៅមួយថ្ងៃ ពួកគេកាន់តែមានហេតុផលច្រើន ដែលមិនឲ្យពួកគេទៅព្រះវិហារ។

ដូច្នេះហើយបានជា នៅពេលដែលបញ្ហាចាប់ផ្តើម ខិតចូលមកក្នុងជីវិតអាពាហ៍ពិពាហ៍របស់ពួកគេ ពួកគេមិនរៀបចំវិញ្ញាណរបស់ពួកគេ ក្នុងការប្រឈមមុខជាមួយនឹងបញ្ហាទាំងនោះឡើយ។ ទោះបីជាពួកគេបានដឹងយ៉ាងជាក់ច្បាស់ អំពីអ្វីដែលព្រះគម្ពីរបានបង្រៀនទាក់ទងទៅនឹងបញ្ហាជំនឿ និង ចរិយាមារយាទក៏ដោយ ពួកគេនៅតែមិនពេញចិត្ត អនុវត្តតាមសេចក្តីបង្រៀននេះឡើយ។ ពួកគេបានធ្វើឲ្យការសម្រេចចិត្តរួចជាស្រេច អំពីដំណោះស្រាយសម្រាប់បញ្ហារបស់ពួកគេ។ មិត្តភក្តិគ្រិស្តបរិស័ទជាច្រើនបានព្យាយាម បញ្ចុះបញ្ចូល ពួកគេឲ្យសម្រុះសម្រួលទំនាក់ទំនងរបស់ពួកគេ និង មិនធ្វើការលែងលះគ្នានោះទេ ប៉ុន្តែពួកគេបានធ្វើការសម្រេចចិត្តរួចទៅហើយ ។ ពួកគេមិនចង់ឮពីអ្វីដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់ថ្លែងអំពីការលែងលះនោះទេ ព្រោះតែ នៅពេលដែលពួកគេឮពីរឿងនេះ វាអាចប៉ះពាល់ដល់ការសម្រេចចិត្តរបស់ពួកគេ(សូមមើលនៅក្នុងគម្ពីរ ម៉ាកុស ១០:២-១២ និង គម្ពីរ ម៉ាថាយ៥:៣១-៣២)។ ពួកគេបានលែងលះគ្នា ភ្លាមៗ ហើយបានធ្វើឲ្យបញ្ហាមួយក្លាយទៅជាបញ្ហាកាន់តែធំ។

ដោយជ្រើសរើសយក មធ្យោបាយដោះស្រាយបញ្ហារបស់ពួកគេ ផ្ទុយទៅនឹងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលបានបង្ហាញឲ្យឃើញនៅក្នុងព្រះបន្ទូលរបស់ព្រះអង្គ គូស្វាមីភរិយាវ័យក្មេងមួយគូនេះ បានផ្តាច់ខ្លួនពួកគេចេញពីព្រះពរទាំងប៉ុន្មានខាងក្រោមនេះ៖

១. កម្លាំងដ៏អស្ចារ្យ ឆ្លងកាត់បញ្ហារបស់ពួកគេរហូតដល់ពេលដែលវាត្រូវបានដោះស្រាយ។
២. សន្តិភាពដែលបានមកពីការស្តាប់បង្គាប់
៣. ការដឹកនាំដែលបានមកពីព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីឲ្យបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ត្រូវបានគេដឹងឮ។
៤. ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ក្នុងការផ្តល់ចម្លើយដែលឥតព្រាងទុក និង អស្ចារ្យសម្រាប់បញ្ហា។

គូស្វាមីភរិយាទាំងពីរនាក់នេះ គឺជាឧទាហរណ៍នៃមនុស្សដែលមានចម្លើយខុសឆ្គងទៅកាន់សំណួរដ៏សំខាន់ពីរយ៉ាង ដែលខ្ញុំតែងតែសួរមកកាន់ខ្លួនឯង ហើយខ្ញុំចង់ចែកចាយជាមួយអ្នក ។ សំណួរនោះគឺ៖

១. តើខ្ញុំពិតជាចង់ដឹងអំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់បញ្ហានេះដែរឬទេ?

២. ក្រោយពេលដែលខ្ញុំបានដឹងអំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ហើយ តើខ្ញុំពិតជាចង់ធ្វើតាមដែរឬទេ ?

ប្រសិនបើ នៅពេលដែលអ្នកសួរសំណួរទាំងពីរនេះទៅកាន់ខ្លួនឯងហើយ អ្នកមិនអាចឆ្លើយថា បាទ/ចាស យ៉ាងច្បាស់ៗបានទេ នោះអ្វីដែលអ្នកត្រូវធ្វើដំបូងបំផុតគឺ ការចំណាយពេលរៀបចំវិញ្ញាណទូលសូមព្រះជាម្ចាស់ឲ្យទ្រង់ជួយអ្នកក្នុងការសម្រេចចិត្តនិយាយថា៖ "បាទ/ចាស ខ្ញុំចង់ស្វែងរក និង ធ្វើតាមដំណោះស្រាយរបស់ព្រះជាម្ចាស់សម្រាប់បញ្ហារបស់ខ្ញុំ។"

លំហាត់អនុវត្តន៍

---

១ ចូរប្រើប្រាស់អ្វីដែលអ្នកបានរៀននៅក្នុងមេរៀនទី១ និងទី២ មកឆ្លើយនឹងសំណួរទាំងនេះ៖

ក) ប្រាប់អំពីបញ្ហាដែលបានរៀបរាប់នៅក្នុងឧទាហរណ៍ដែលបានផ្តល់ជូននៅខាងលើ។

.....

ខ) ប្រាប់អំពីប្រភពនៃបញ្ហា។

.....

គ) ប្រសិនបើគូស្វាមីវ័យក្មេងនេះ ស្គាល់ពីបញ្ហាដ៏ពិតប្រាកដរបស់ពួកគេ និង ពីប្រភពរបស់វា ហើយទទួលស្គាល់វាផងនោះ តើអាចរកឃើញដំណោះស្រាយតាមសុភនិច្ឆ័យបែបណាដែល អាចនឹងជួយឲ្យពួកគេចូលទៅដោះស្រាយបញ្ហារបស់ពួកគេតាមរបៀបមួយដែរត្រឹមត្រូវ។

.....

ការរៀបចំខាងឯវិញ្ញាណ

ការរៀបចំខាងឯវិញ្ញាណ គឺជារឿងដ៏មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការដោះស្រាយបញ្ហាឲ្យបានជោគជ័យ។ នៅក្នុងពេលដែលមាន ភាពតានតឹងគឺជាពេលដែលត្រូវបានបង្កើនការអធិស្ឋានថ្វាយបង្គំ និង ការអានព្រះគម្ពីរ វាមិនមែនជាពេលដែលត្រូវកាត់បន្ថយវានោះឡើយ។ ការដោះស្រាយបញ្ហាមួយនៅក្នុងរបៀបដូចជាព្រះគ្រិស្ត គឺមិនមែនជាអ្វីដែលយើងអាចសម្រេចចិត្តថានឹងធ្វើនៅក្នុងពេលដែលបញ្ហាកើតឡើងភ្លាមៗនោះទេ។ បញ្ហាអាចនឹងកើតឡើងមួយរំពេច ហើយត្រូវធ្វើអ្វីម្យ៉ាងភ្លាមៗ។ គ្រិស្តបរិស័ទដែលឈ្លាសវៃ នឹងរក្សាឥរិយាបថនៃភាពរួចរាល់ខាងឯវិញ្ញាណ រួមជាមួយនឹងដួងចិត្ត និងគំនិតរបស់ពួកគេបន្តបើកចំហសម្រាប់ការនាំផ្លូវពីព្រះវិញ្ញាណដ៏វិសុទ្ធ។

លោកសាវ៉កបានផ្តល់ការណែនាំដ៏មានប្រយោជន៍ខ្លះៗ នៅក្នុងគម្ពីរ១ថេស្សាឡូនិក ៥:១៦-១៨, ២០-២២៖ "ចូរមានអំណរសប្បាយជានិច្ច ចូរអធិស្ឋានឥតឈប់ឈរ ចូរអរព្រះគុណព្រះជាម្ចាស់គ្រប់កាលៈទេសៈទាំងអស់ ....កុំមើលងាយការថ្លែងព្រះបន្ទូល ចូរពិចារណាមើលគ្រប់សេចក្តីទាំងអស់ ហើយស្រង់យកនូវសេចក្តីណាដែលល្អ។ ត្រូវចៀសចេញអោយផុតពីអំពើអាក្រក់គ្រប់បែបយ៉ាង។"

ការរៀបចំខាងឯវិញ្ញាណអាចមានរួមបញ្ចូលសកម្មភាពទាំងនេះ៖

១. មានពេលវេលាទៀងទាត់សម្រាប់ការអានព្រះគម្ពីរ ការរិះគិត (ការគិតពីអ្វីដែលអ្នកបានអាននោះ) និង ការអធិស្ឋានជារៀងរាល់ថ្ងៃ។ បើកចំហគំនិតរបស់អ្នកសម្រាប់អ្វីដែលព្រះគម្ពីរបង្រៀន។ អនុញ្ញាតឲ្យព្រះវិញ្ញាណដ៏វិសុទ្ធ ដឹកនាំគំនិតរបស់អ្នក។

២. ស្តាប់ការបង្រៀនបទបន្ទូល របស់គ្រូគង្វាល និង គ្រូបង្រៀនជាគ្រិស្តបរិស័ទផ្សេងទៀត។

៣. ការប្តេជ្ញានៅក្នុងចិត្តរបស់អ្នកថា ត្រូវគិតពីបញ្ហាទាំងអស់ទៅតាមអ្វីដែលព្រះគម្ពីរបង្រៀនអំពីវា ទោះបីជាដំណោះស្រាយតាមខគម្ពីរ ហាក់បីដូចជាពិបាកធ្វើតាមក៏ដោយ។

លំហាត់អនុវត្តន៍

---

២ សូមគិតពីបញ្ហាដែលអ្នកទើបតែនឹងមានថ្មីនេះ ឬ ធ្លាប់មានយូរមកហើយ។ ចូរវាយតម្លៃថាតើអ្នកបានរៀបចំវិញ្ញាណរបស់អ្នក ដើម្បីដោះស្រាយបញ្ហា និង ស្វែងរកបំណងព្រះហឫទ័យ របស់ព្រះជាម្ចាស់រួចជាស្រេចហើយ ឬ ក៏កំពុងតែរៀបចំនៅឡើយ។

	បាទ/ចាស	**ទេ**
ក) ខ្ញុំចង់ដឹងពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ទាក់ទងជាមួយនឹងបញ្ហានេះ។		
ខ) ខ្ញុំធ្លាប់បានសិក្សាព្រះគម្ពីរដើម្បីដឹងថាតើព្រះជាម្ចាស់បានប្រទានការណែនាំពិសេស អំពីបញ្ហាមួយនេះ ឬ ស្ថានភាពស្រដៀងគ្នានេះដែរឬទេ។		
គ) ខ្ញុំបានទូលសូមឲ្យព្រះវិញ្ញាណដ៏វិសុទ្ធនាំផ្លូវខ្ញុំដើម្បីឲ្យបានស្គាល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។		
ឃ) ប្រសិនបើខ្ញុំត្រូវការជំនួយបន្ថែមដើម្បីស្វែងរកការណែនាំរបស់ព្រះជាម្ចាស់ចំពោះស្ថានភាពនេះ ខ្ញុំនឹងប្រឹក្សាជាមួយនឹងគ្រូគង្វាល ឬ មិត្តភក្តិគ្រិស្តបរិស័ទដែលឈ្លាសវៃម្នាក់។		
ង) ខ្ញុំបានប្តេជ្ញាចិត្តស្តាប់បង្គាប់ព្រះជាម្ចាស់ និង ធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់ ទោះបីជាវាពិបាកសម្រាប់ខ្ញុំក៏ដោយ។		

ការរៀបចំខាងឯវិញ្ញាណទុកជាមុន នឹងជួយអ្នកឲ្យបានស្គាល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ផ្តល់កម្លាំងឲ្យអ្នក និង លើកទឹកចិត្តអ្នក ឲ្យប្រើប្រាស់ដំណោះស្រាយដ៏ល្អបំផុត និង រារាំងអ្នកមិនឲ្យធ្វើការសម្រេចចិត្តដែលអាចនាំឲ្យមានគ្រោះមហន្តរាយ។

ខ. ជៀសវាងការឆ្លើយតបដែលខុសឆ្គង

វត្ថុបំណងទី២. *ស្គាល់ពីការឆ្លើយតបខុសឆ្គងតាមរយៈឧទាហរណ៍ដែលបានផ្តល់ឲ្យ និង ធ្វើលំហាត់ផ្ទាល់ខ្លួន។*

ការរៀបចំខាងឯវិញ្ញាណ នឹងជួយអ្នកច្រានចោល និង ជៀសវាង របៀបដោះស្រាយស្ថានភាពបញ្ហាដែលមានលក្ខណៈទូលំទូលាយ តែខុសឆ្គងនោះ។ របៀបដែលខុសឆ្គងទាំងនេះ នឹងចូលទៅក្នុងចំណែកថ្នាក់ទាំងនេះ៖ កំហឹង, ការចុះចាញ់, និង ការខិតខំប្រឹងប្រែងរបស់មនុស្សតែមួយមុខ។ យើងនឹងពិចារណាសង្ខេបម្តងមួយៗ។

កំហឹង

មនុស្សជាច្រើនត្រូវបានគេធ្វើខុស ឬ បំពានលើ មានទំនោរចិត្តដំបូងថាត្រូវតែឆ្លើយតបជាមួយរបៀបដែលប្រកបដោយកំហឹង ឬ ឆេវឆាវ។ ការនេះអាចមានទម្រង់ជាច្រើនបែប៖ *កំហឹង* ដែលជះទៅលើអ្នកដទៃ ទៅលើព្រះជាម្ចាស់ ឬ ទៅលើកាលៈទេសៈរបស់យើង ; *ការចោទប្រកាន់* ឬស្តីបន្ទោសទៅលើអ្នកផ្សេងម្នាក់ទៀត និង សូម្បី *ការសងសឹក* ទៀតផង។ នៅពេលដែលយើងកំពុងតែឈឺចាប់ វាងាយណាស់ដែលយើងចង់ធ្វើបាបបុគ្គលម្នាក់ដែលធ្វើឲ្យយើងឈឺចាប់នោះ។ នេះមិនមែនជារបៀបដែលព្រះគ្រិស្តបង្រៀនឲ្យយើងឆ្លើយតបឡើយ ប៉ុន្តែវាក៏ជាកំហុសដែលកើតមានច្រើនដែរ។ របៀបរបស់ព្រះគ្រិស្តគឺដូចខាងក្រោមនេះ៖

> អ្នករាល់គ្នាធ្លាប់បានឮសេចក្តីថ្លែងទុកមកថា "ប្រសិនបើគេវាយភ្នែកអ្នកម្ខាង ត្រូវវាយភ្នែកគេតែម្ខាងវិញ ប្រសិនបើគេវាយអ្នកបាក់ធ្មេញមួយ ត្រូវវាយគេអោយបាក់ធ្មេញតែមួយដែរ"។ រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា កុំតបតនឹងមនុស្សកំណាចអោយសោះ បើមានគេទះ កំផ្លៀងស្តាំរបស់អ្នក ចូរបែរអោយគេទះម្ខាងទៀតទៅ។....អ្នករាល់គ្នាធ្លាប់បានឮសេចក្តីថ្លែងទុកមកថា "ចូរស្រឡាញ់បងប្អូនឯទៀតៗ ហើយស្អប់ខ្មាំងសត្រូវរបស់អ្នក"។ រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា ចូរស្រឡាញ់ខ្មាំងសត្រូវរបស់អ្នករាល់គ្នា ព្រមទាំងទូលអង្វរព្រះជា ម្ចាស់ សូមព្រះអង្គប្រទានពរអោយអស់អ្នកដែលបៀតបៀនអ្នករាល់គ្នាផង។ ធ្វើដូច្នេះ អ្នករាល់គ្នានឹងបានទៅជាបុត្ររបស់ព្រះបិតាដែលគង់នៅស្ថានបរមសុខ ។(គម្ពីរម៉ាថាយ ៥:៣៨-៣៩, ៤៣:៤៥)

ពិតណាស់ នៅពេលដែលយើងនាំឲ្យកំហឹងរបស់យើងទៅថ្វាយដល់ព្រះអម្ចាស់ យើងអាចទុកចិត្ត ថាទ្រង់នឹងថែរក្សាពួកយើង។ នៅក្នុងគម្ពីររ៉ូម ១២:១៩ លោកសាវ័កប៉ូលបានប្រាប់យើងថា "បងប្អូនជាទីស្រឡាញ់អើយ មិនត្រូវសងសឹកដោយខ្លួនឯងឡើយ គឺទុកអោយព្រះជាម្ចាស់សំដែងព្រះពិរោធចំពោះគេវិញ ដ្បិតមានចែងទុកមកថា: «ព្រះអម្ចាស់មានព្រះបន្ទូលថា "ការសងសឹកស្រេចតែលើយើង គឺយើងទេតើដែលនឹងតបទៅគេ"។

ព្រះគ្រិស្តគឺជាឧទាហរណ៍ដ៏ល្អឥតខ្ចោះមួយអំពីមនុស្សដែល "មិនចេះខឹង" នោះគឺមានន័យថា ទ្រង់មិនអនុញ្ញាតឲ្យអង្គទ្រង់ក្រោធឡើយ នៅពេលដែលមានគេធ្វើខុសមកលើទ្រង់។ ទ្រង់មិនដែល ឆ្លើយតបដោយកំហឹងនោះទេ។ នៅពេលដែលទ្រង់បានទតពីលើឈើឆ្កាងមក កាន់ទាហានរ៉ូម ដែលបានវាយទ្រង់ស្តោះទឹកមាត់ដាក់ទ្រង់ និង បានឆ្កាងទ្រង់នៅលើឈើឆ្កាងនោះ ទ្រង់បានអធិស្ឋានថា "ឱព្រះបិតាអើយ! សូមព្រះអង្គអត់ទោសអោយអ្នកទាំងនេះផង ដ្បិតគេមិនដឹងថាគេកំពុងធ្វើអ្វីឡើយ " (គម្ពីរលូកា២៣:៣៤) ។ នៅពេលដែលអ្នកមិនព្រមមានចិត្តខឹង ឬ ឆ្លើយតបដោយកំហឹង នៅពេលដែលនរណាម្នាក់ធ្វើខុសមកលើអ្នក អ្នកនឹងទទួលបានអំណរដ៏ពិតដែលដឹងថា អ្នកបានឆ្លងកាត់បញ្ហានោះ ដោយឥរិយាបថត្រឹមត្រូវ។ ការនេះពង្រឹងកម្លាំងអ្នក ដើម្បីនៅពេលដែលមានការបំពានមួយទៀតមកដល់ វានឹងមានភាពងាយស្រួលក្នុងការប្រឈមមុខជាមួយវាដោយគ្មានកំហឹង។

"ការមិនចេះខឹង" ទាមទារការអធិស្ឋាននិង ការអនុវត្ត ប៉ុន្តែវានឹងជាព្រះពរមួយនៅពេលដែលយើងអាចក្រឡេកមើលមកក្រោយវិញ ហើយអាចនិយាយថា " ខ្ញុំរីករាយណាស់ដែលខ្ញុំមិនបានឆ្លើយតបដោយកំហឹង ផ្ទុយទៅវិញខ្ញុំអាចបង្ហាញក្តីស្រឡាញ់ ទៅកាន់បុគ្គលដែលព្យាយាមបៀតបៀនខ្ញុំ"។

លំហាត់អនុវត្តន៍

---

៣ ចូរផ្គូផ្គង ការឆ្លើយតបដែលនៅក្នុងជួរខាងស្តាំ ទៅជាមួយនឹង ការរៀបរាប់អាកប្បកិរិយារបស់វា នៅក្នុងជួរខាងឆ្វេង។ ចូរសរសេរអក្សរនៃជម្រើសរបស់អ្នក នៅក្នុងចន្លោះបន្ទាត់នីមួយៗ។

.....ក)	"វាគឺជាកំហុសរបស់គាត់ដែលខ្ញុំមិនទទួលបានការងារនោះ។ គាត់ពិតជាមានបំណងរារាំងខ្ញុំមិនឲ្យទទួលបានវា"	១)	កំហឹង
		២)	ការចោទប្រកាន់
.....ខ)	"រឿងចុងក្រោយដែលខ្ញុំចង់ធ្វើ គឺជម្រះបញ្ជីជាមួយគេ!"	៣)	ទាស់ចិត្ត
.....គ)	"នាងបានធ្វើឲ្យខ្ញុំឈឺចាប់ខ្លាំងណាស់ ខ្ញុំនឹងមិននិយាយជាជាមួយនាងទៀតទេ!"	៤)	ការសងសឹក
.....ឃ)	"ខ្ញុំបានប្រាប់នាងត្រង់ៗនូវអ្វីដែលខ្ញុំគិត អំពីចរិតកោងកាច និង អាក្រក់របស់នាង។		

ការចុះចាញ់

ការចុះចាញ់ ឬ ការដកថយ អាចមានជាច្រើនទម្រង់។ ពេលខ្លះវាមានន័យថា ការរត់គេចពីបញ្ហា ឬ រកកន្លែងលាក់ខ្លួន។ អ្នកខ្លះ រត់គេចពីការពិតដោយ លង់ខ្លួនទៅក្នុងការញៀនថ្នាំ ការប្រមឹកស្រា ការស្វែងរកការសប្បាយបែបលោកីយ៍ ការបរិភោគច្រើន ឬ ការធ្វើការច្រើន ភាពងុបងល់ក្នុងសាសនា ឬ មធ្យោបាយជាច្រើនទៀត។ អ្នកស្មើរតែអាចលាក់ខ្លួននៅពីក្រោយអ្វីៗគ្រប់បែបយ៉ាងដើម្បីចង់គេចពីការប្រឈមមុខជាមួយនឹងសេចក្តីពិត។ (ពិតណាស់ វាក៏មានការដកថយដែលមានប្រយោជន៍មួយដែរ គឺនៅពេលដែលគ្រិស្តបរិស័ទម្នាក់ បានជ្រើសរើសយកការដើរចេញពីស្ថានការណ៍នោះដើម្បី *ជៀសវាង* បញ្ហា)។

ពេលខ្លះ ការចុះចាញ់អាចមានលក្ខណៈជាការរត់គេចខ្លួន។ ខ្ញុំស្គាល់ស្ត្រីវ័យក្មេងម្នាក់ដែលមិនទាន់រៀបការនៅឡើយ ហើយកំពុងរស់នៅជាមួយឪពុកម្តាយរបស់នាង។ នាងចាប់ផ្តើមព្រួយបារម្ភថានាងនឹងមិនបានរៀបការ និង ត្រូវមានទំនួលខុសត្រូវ ក្នុងការមើលថែឪពុកម្តាយដែលមានវ័យចំណាស់របស់នាង ស្របពេលដែលប្អូនប្រុស និង ប្អូនស្រីរបស់នាងដែលបានរៀបការហើយ គេមិនមានទំនួលខុសត្រូវនោះឡើយ។ មិនយូរប៉ុន្មាន នាងមានអារម្មណ៍ថា ស្រណោះខ្លួន និង មានភាពល្វីងជូរចត់ ដែលធ្វើឲ្យនាងសម្រេចចិត្តរៀបចំរបស់របររបស់នាង ហើយចាកចេញពីផ្ទះដោយមិនប្រាប់នរណាម្នាក់ឲ្យដឹងថានាងទៅកន្លែងណានោះទេ។

លក្ខណៈមួយទៀតនៃការចុះចាញ់គឺជាការ *ដកថយ* ។ មានស្ត្រីមេម៉ាយម្នាក់ដែលខ្ញុំស្គាល់ នាងមិនព្រមចេញពីផ្ទះរបស់នាងទាល់តែសោះ លើកលែងតែមានគ្រោះអាសន្នបន្ទាន់ ហើយនាងឈប់ទៅជួបគ្រួសារ និង មិត្តភក្តិរបស់នាងទៀត តាំងពីពេលដែលប្តីរបស់នាងបានទទួលមរណៈភាពបាត់ទៅ។ នាងពិតជាឯកា និង ក្រៀមក្រំខ្លាំងណាស់។

លំហាត់អនុវត្តន៍

---

៤ តើតរិយាបថណាខ្លះ នៅខាងក្រោមនេះ ដែលអ្នកឃើញមាននៅក្នុងមនុស្សដែលព្យាយាមរត់គេច ពីបញ្ហារបស់ពួកគេ ដោយការចុះចាញ់ និង ការដកថយ?

ក) ភាពមិនអាត្មានិយម

ខ) ភាពអាត្មានិយម

គ) ស្រណោះខ្លួន

ឃ) អំណរ

ង) សេចក្តីសង្ឃឹម

ច) ភាពល្វីងជូរចត់

ឆ) កំហឹង

៥ ចូរឆ្លើយសំណួរខាងក្រោមដោយ គូសគ្រីស ត្រង់ប្រអប់ *បាទ/ចាស* ឬ *ទេ*។

		បាទ/ចាស	**ទេ**
ក)	នៅពេលដែលរឿងរ៉ាវមិនស្របទៅតាមអ្វីដែលអ្នកចង់បាន តើអ្នកតែងតែឆ្លើយតបដោយកំហឹងមែនឬទេ?		
ខ)	នៅពេលដែលមានបញ្ហាកើតឡើង តើអ្នកព្យាយាមបន្ទោសវាទៅលើអ្នកដទៃ ទោះបីវាជាកំហុសរបស់អ្នកក៏ដោយមែនដែរឬទេ?		
គ)	តើមនុស្សតែងតែបំពានលើអ្នក មែនឬទេ?		
ឃ)	តើអ្នកមានអារម្មណ៍ភ្ជួញភ្ជែរ និង អវិជ្ជមានជាញឹកញាប់មែនឬទេ?		
ង)	ប្រសិនបើមាននរណាម្នាក់ធ្វើខុសមកលើអ្នក តើអ្នកគឺជាប្រភេទមនុស្សដែលមិនអាចនៅស្ងៀមបាន លុះត្រាតែអ្នកបានធ្វើអ្វីម្យ៉ាងដើម្បី សងសឹកគេវិញ មែនឬទេ?		
ច)	តើអ្នកធ្លាប់បានព្យាយាមចុះចាញ់ និង ដកខ្លួនចេញពីស្ថានភាពលំបាក ដោយមិនប្រឈមមុខជាមួយវាតាមរបៀបវិជ្ជមាន ដែរឬទេ?		

ការខិតខំប្រឹងប្រែងរបស់មនុស្សតែមួយមុខ

វត្ថុបំណងទី៣. *បកស្រាយថា ហេតុអ្វីបានជាវាមានសារៈសំខាន់ម្ល៉េះ ដែលមិនត្រូវព្យាយាមដោះស្រាយបញ្ហារបស់អ្នក ដោយសមត្ថភាពមនុស្សតែម្យ៉ាងនោះ។*

ខ្ញុំបានទុកការឆ្លើយតបដោយការជួយខ្លួនឯងនេះនៅក្រោយគេ ព្រោះវាមិនសុទ្ធតែអវិជ្ជមានទាំងអស់នោះទេ។ ព្រះជាម្ចាស់បានបង្កើតបំណងចិត្តរបស់មនុស្ស ឲ្យជាកម្លាំងវិជ្ជមានមួយដែលអាចឡើងផុតពីការលំបាកនៅក្នុងជីវិតតាមរបៀបដ៏អស្ចារ្យមួយ។ ប្រសិនបើគ្មានឫទ្ធានុភាពនៅក្នុង "ការគិតវិជ្ជមាន" នោះទេ អ្នកដែលមិនមែនជាគ្រិស្តបរិស័ទ មិនអាចនឹងមានជីវិតរស់បានឡើយ។ ប៉ុន្តែការទុកចិត្តទៅលើអំណាចឆន្ទៈរបស់មនុស្សថាជាធនធានចម្បងនៅក្នុងការដោះស្រាយ បញ្ហាជីវិត គឺមិនមែនជារបៀបរបស់គ្រិស្តបរិស័ទនោះទេ! បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺដើម្បីឲ្យបុត្រាបុត្រីរបស់ទ្រង់ ប្រឈមមុខជាមួយនឹងបញ្ហា ដោយឫទ្ធានុភាពដែលបានប្រោសព្រះគ្រិស្តឲ្យមានព្រះជន្មរស់នោះ ហើយដើម្បីឲ្យពួកគេប្រើប្រាស់បញ្ហារបស់ពួកគេទុកជាឱកាសសម្រាប់ទ្រង់បង្ហាញពីឫទ្ធានុភាព និង ព្រះគុណរបស់ទ្រង់។ ដូច្នេះ នៅក្នុងការជ្រើសរើសការឆ្លើយតបដើម្បីជៀសវាងបញ្ហា វាពិតជាមានសារៈសំខាន់ណាស់ដែលអ្នក *មិនត្រូវ* ព្យាយាមដោះស្រាយបញ្ហាដោយការខិតខំប្រឹងប្រែងរបស់មនុស្សតែមួយមុខនោះឡើយ ប៉ុន្តែត្រូវយកវាទៅថ្វាយព្រះជាម្ចាស់ដោយការអធិស្ឋានវិញ។

គ្មានបញ្ហាណាមួយដែលតូចពេក ក្នុងការនាំទៅថ្វាយព្រះអម្ចាស់នោះទេ។ នៅពេលដែលខ្ញុំកំពុងបើកឡានរបស់ខ្ញុំ ហើយខ្ញុំគ្មានពេលវេលាគ្រប់គ្រាន់ ជាមួយនឹងការងារជាច្រើនដែលខ្ញុំត្រូវធ្វើ ដល់ថ្នាក់ខ្ញុំអធិស្ឋានសម្រាប់កន្លែងចតឡានទៀតផង។ តើនេះគឺជារឿងឆោតល្ងង់ដែរឬទេ? អត់ទេ! ព្រះជាម្ចាស់គឺជាព្រះអាទិករដ៏ធំអស្ចារ្យនៃចក្រវាឡ ប៉ុន្តែទ្រង់ក៏ជាព្រះដែលជ្រាប សូម្បីនៅពេលណាដែលមានកូនចាបធ្លាក់ទៅលើដី និង ជាព្រះដែលអាចរាប់សរសៃសក់នៅលើក្បាលរបស់អ្នកអស់ផងដែរ (គម្ពីរម៉ាថាយ ១០:២៩-៣១) ។ ទ្រង់ក៏យកព្រះទ័យទុកដាក់ចំពោះបញ្ហាដែលតូចតាចបំផុតនៅក្នុងជីវិតរបស់អ្នក ហើយទ្រង់សព្វព្រះទ័យជួយអ្នកផងដែរ។ ដូច្នេះហើយ រឿងដែលសំខាន់បំផុតដែលអ្នកអាចធ្វើ ចំពោះការដោះស្រាយបញ្ហានៅក្នុងជីវិត គឺត្រូវដើរតាមការបង្គាប់របស់អ្នកនិពន្ធក្នុងគម្ពីរ សុភាសិត ៣:៥-៨។ ចូរអានខគម្ពីរនេះបន្ទាប់មកជ្រើសរើសចម្លើយសម្រាប់សំណួរខាងក្រោមនេះ។

លំហាត់អនុវត្តន៍

---

៦ សុភាសិតនេះប្រាប់អ្នក ឲ្យជឿលើ
   ក) អ្វីដែលអ្នកគិតថាអ្នកដឹង
   ខ) ព្រះអម្ចាស់

៧ សុភាសិតនេះក៏បានប្រាប់អ្នក មិនឲ្យផ្អែកលើ
   ក) អ្នកដទៃ
   ខ) ការយល់ដឹងរបស់អ្នកផ្ទាល់ (អ្វីដែលអ្នកគិតថាអ្នកដឹង)
   គ) អារម្មណ៍របស់អ្នក។

៨ ប្រសិនបើអ្នកចងចាំពីព្រះអម្ចាស់(ទទួលស្គាល់ទ្រង់) នៅក្នុងគ្រប់អ្វីៗទាំងអស់ដែលអ្នកធ្វើ អ្នកអាចរំពឹងក្នុងចិត្តបាន ថាទ្រង់នឹង
   ក) បង្ហាញអ្នកពីផ្លូវត្រឹមត្រូវដែលត្រូវដើរ។
   ខ) ប្រទានឲ្យអ្នកមានបញ្ហាតែបន្តិចបន្តួចតែប៉ុណ្ណោះ។

នៅពេលដែលអ្នកយកបញ្ហាតូចតាចទៅថ្វាយព្រះជាម្ចាស់ វាប្រហែលមានភាពងាយស្រួលជាងការដែលត្រូវទុកចិត្តលើទ្រង់នៅពេលអ្នកប្រឈមមុខជាមួយនឹងបញ្ហាដែលហាក់បីដូចជាគ្មានដំណោះស្រាយទាល់តែសោះនោះ។ នេះគឺជាឱកាសរបស់ព្រះជាម្ចាស់ ដើម្បីធ្វើការអស្ចារ្យនៅក្នុងជីវិតរបស់អ្នក អំណាចរបស់ទ្រង់គឺគ្មានដែនកំណត់ឡើយ នៅពេលដែលអ្នករៀនទុកចិត្តអ្វីៗគ្រប់បែបយ៉ាងនៅក្នុងព្រះហស្តរបស់ទ្រង់ ហើយទ្រង់នឹងមិនធ្វើឲ្យអ្នកខកបំណងឡើយ! (សូមមើលគម្ពីរអេភេសូ ៣:២០ និង គម្ពីរ១យ៉ូហាន ៥:១៤-១៥)។

លំហាត់អនុវត្តន៍

៩ ហេតុអ្វីបានជា វាមានសារៈសំខាន់ដែលមិនត្រូវ ដោះស្រាយបញ្ហារបស់អ្នក ដោយប្រើសមត្ថភាព របស់មនុស្សតែមួយមុខនោះ?

.....

.....

.....

ឃ. ប្រើប្រាស់វិធីសាស្ត្របែបប្រព័ន្ធ

វត្ថុបំណងទី៤. *ធ្វើតារាងតាមដានមួយ ដើម្បីតាមដានការដោះស្រាយស្ថានភាពរបស់បញ្ហា ដោយផ្អែកលើវិធី សាស្ត្រដែលបានផ្តល់ឲ្យ និង ដាក់តារាងតាមដាននោះទៅលើបញ្ហាដែលបានផ្តល់ឲ្យ។*

យើងបានចាក់គ្រឹះ ជាយូរមកហើយនៅក្នុងមេរៀននេះ សម្រាប់ការប្រើប្រាស់វិធីសាស្ត្របែបប្រព័ន្ធ ក្នុងការដោះស្រាយបញ្ហា ដោយផ្អែកលើគោលការណ៍របស់គ្រិស្តបរិស័ទ។ មានសៀវភៅជាច្រើន ត្រូវបានគេសរសេរឡើង ដើម្បីជួយមនុស្សដែលមានបញ្ហាគ្រប់ប្រភេទ។ នេះគឺជា មុខវិជ្ជាដ៏ស្មុគស្មាញមួយ ហើយមានមធ្យោបាយជាច្រើនសម្រាប់ការដោះស្រាយបញ្ហានោះ។ គោលបំណងរបស់យើងគឺ ចង់ផ្តល់ជូនអ្នកនូវការណែនាំខ្លះ ដែលនឹងជួយអ្នកឲ្យប្រឈមមុខជាមួយនឹងបញ្ហារបស់អ្នក ដោយឥរិយាបថត្រឹមត្រូវ និងវិញ្ញាណមួយដែលដូចជាព្រះគ្រិស្ត ប្រសិនបើអ្នកដើរតាមការណែនាំនោះមែន ហើយអនុញ្ញាតឲ្យព្រះជាម្ចាស់ប្រទានចម្លើយសម្រាប់បញ្ហានោះ។

បន្ទាប់ពីយើងបានពិភាក្សា ជំហានជាមូលដ្ឋានទាំងប្រាំមួយ នៅក្នុងវិធីសាស្ត្រជាប្រព័ន្ធនៃការដោះស្រាយបញ្ហានេះ យើងនឹងផ្តល់ឱកាសឲ្យអ្នក ស្វែងរកពីជំហានទាំងនោះ ដោយប្រើប្រាស់ស្ថានភាពបញ្ហាមួយដែលនៅក្នុងបទគម្ពីរ និង មួយទៀតដែលមាននៅក្នុងស្ថានភាពបច្ចុប្បន្ននេះ។ ដោយយើងនឹងពិភាក្សាអំពីបញ្ហាជាក់លាក់ នៅក្នុងមេរៀនក្រោយៗទៀត អ្នកនឹងមានឱកាស អនុវត្តជំហានទាំងនេះ ដើម្បីធ្វើការសម្រេចចិត្តចំពោះបញ្ហានៅក្នុងព្រះគម្ពីរ។ យើងខ្ញុំសង្ឃឹមថា ដោយធ្វើដូច្នេះ នឹងជួយអ្នកឲ្យធ្វើការអនុវត្តគោលការណ៍ទាំងនេះ នៅក្នុងបញ្ហាជាក់ស្តែងនៅក្នុងជីវិតរបស់អ្នកផ្ទាល់ ឬ នៅក្នុងជីវិតរបស់អ្នកដទៃដែលអ្នកចង់ជួយ។

ជំហានឆ្ពោះទៅរកការដោះស្រាយបញ្ហា	
វិធីសាស្ត្រ ក	**វិធីសាស្ត្រ ខ**
១. ស្គាល់បញ្ហា ក. ស្គាល់ប្រភព ខ. ស្វែងរកប្រភពដែលស៊ីជម្រៅជាងនេះ ២. ថ្វាយបញ្ហារបស់អ្នកទៅកាន់ព្រះជាម្ចាស់។ ៣. គិតអំពីដំណោះស្រាយទាំងអស់ដែលអាចមាន នៅក្រោមការបំភ្លឺពីសេចក្តីបង្រៀនរបស់បទគម្ពីរ។ (ចូរប្រើធនធានរបស់អ្នក) ៤. គិតអំពីផលវិបាកនៃជម្រើសទាំងអស់ ដែលអាចកើតមាន។ (ចូរប្រើធនធានរបស់អ្នក) ៥. ជ្រើសយកដំណោះស្រាយមួយ ហើយយកវាទៅប្រើប្រាស់។ ៦. វាយតម្លៃទៅលើលទ្ធផល ដែលបានមកពីដំណោះស្រាយរបស់អ្នក និង ធ្វើការកែតម្រូវផ្សេងៗដែលមាន។	(សម្រាប់បញ្ហាដែលហាក់បីដូចជាគ្មានដំណោះស្រាយ ភ្លាមៗ) ១. ស្គាល់បញ្ហា។ ២. ថ្វាយបញ្ហានោះទៅ កាន់ព្រះជាម្ចាស់។ ៣. រំពឹងថាព្រះជាម្ចាស់ធ្វើការដើម្បីប្រយោជន៍ របស់អ្នក។

វិធីសាស្ត្រ ក

ជំហានទី១ ស្គាល់បញ្ហា

មានបញ្ហាខ្លះ យើងមិនអាចស្គាល់វាបាន ដោយងាយៗនោះឡើយ។ តែមានខ្លះទៀត យើងអាចស្គាល់បានយ៉ាងងាយ។ ឧបមាថា ខ្ញុំត្រូវការលុយ ឬមានអ្នកជិតខាងដែលខ្ញុំមិនចូលចិត្ត ឬ ខ្ញុំសំគាល់ឃើញថា ភ្នែករបស់ខ្ញុំកាន់តែខ្សោយទៅៗ។ បញ្ហាប្រភេទនេះ ងាយសំគាល់ឃើញណាស់។

ប៉ុន្តែ ប្រសិនបើ ខ្ញុំមានអារម្មណ៍មិនសប្បាយចិត្ត តែមិនដឹងមូលហេតុអ្វី ឬ គេងមិនលក់ ឬ មានអារម្មណ៍ថា មិនស្រណុកចិត្ត តែមិនអាចបកស្រាយបាន ថាបញ្ហានេះមកពីមូលហេតុអ្វី នោះខ្ញុំត្រូវតែធ្វើការសង្ងៀមចិត្ត និង អធិស្ឋានជាពិសេសមួយ ដើម្បីរកឃើញប្រភពនៃបញ្ហាទាំងនោះ។ ខ្ញុំប្រហែលជាត្រូវការជំនួយពីខាងក្រៅ ដើម្បីរកប្រភពបញ្ហានោះផងដែរ។

ទីមួយ អ្នកត្រូវតែ*ស្គាល់ពី ប្រភពរបស់បញ្ហា*។ យើងបានរៀនរួចមកហើយ អំពីប្រភពនៃបញ្ហានៅក្នុងមេរៀនទី១។ នៅពេលណាដែល អ្នកបានស្គាល់ពីប្រភពបញ្ហានេះហើយ អ្នកនឹងអាចប្រឈមមុខជាមួយនឹងបញ្ហានោះបាន។ នៅពេលដែលអ្នកឃើញថាវា ជារឿងដែលអាចនឹងធ្វើការផ្លាស់ប្តូរបាន នោះអ្នកអាចឈានទៅកាន់ជំហានបន្ទាប់ទៀតបាន។

ទីពីរ អ្នកប្រហែលជាត្រូវ *រកមើលមូលហេតុស៊ីជម្រៅជាងនេះ* ។ ឧបមាថា ខ្ញុំខ្វះលុយសម្រាប់ទិញអាហារបរិភោគ ហើយប៉ុន្មានថ្ងៃទៀត ខ្ញុំក៏នឹងមិនទាន់ទទួលបានប្រាក់ខែរបស់ខ្ញុំដែរ ។វាប្រហែលមកពី ខ្ញុំមិនបានប្រុងប្រយ័ត្នចំពោះលុយរបស់ខ្ញុំ ហើយបានប្រើប្រាស់វាជាមួយរបស់ដែលមិនចាំបាច់ ។ ខ្ញុំអាចដោះស្រាយបញ្ហានេះបានយ៉ាងងាយ ដោយរៀបចំផែនការដោយប្រុងប្រយ័ត្ន នៅថ្ងៃមុខ ប៉ុន្តែប្រសិនបើខ្ញុំមើលឃើញថា តម្រូវការចាំបាច់ក្នុងជីវិតរបស់ខ្ញុំច្រើនជាង ចំណូលប្រចាំសប្តាហ៍របស់ខ្ញុំដែលអាចផ្គត់ផ្គង់

សម្រាប់តម្រូវការប្រចាំថ្ងៃនោះ ខ្ញុំត្រូវតែស្វែងរកដោះស្រាយដែលមានស្ថេរភាពជាងនេះ។ មូលហេតុស៊ីជម្រៅនោះគឺ ខ្ញុំត្រូវការលុយដើម្បីចំណាយសម្រាប់តម្រូវការចាំបាច់របស់ខ្ញុំច្រើនជាង អ្វីដែលខ្ញុំអាចរកបាន។ ខ្ញុំត្រូវតែ បង្កើនចំណូលរបស់ខ្ញុំ ឬ ត្រូវកាត់បន្ថយចំណាយរបស់ខ្ញុំ។

លំហាត់អនុវត្តន៍

១០ ចូរបង្កើតតារាងមួយនៅក្នុងសៀវភៅកត់ត្រារបស់អ្នក ហើយសរសេរសំណួរដែល អ្នកអាចប្រើប្រាស់នៅក្នុងការដោះស្រាយបញ្ហា។ អ្នកនឹងត្រូវសរសេរសំណួរបន្ថែមទៀត នៅពេលដែលអ្នកបន្តសិក្សាផ្នែកមួយនេះ។ ចូររំឭកជំហានទី១ម្តងទៀត ហើយសាកល្បងសរសេរ បី ឬ បួនសំណួរដើម្បីជួយអ្នកក្នុងការដើរតាមជំហានមួយនេះ។ ក្រោយពីបានសរសេរសំណួររបស់អ្នកហើយ ចូរផ្ទៀងផ្ទាត់សម្រាប់ចម្លើយរបស់ខ្ញុំ នៅចុងបញ្ចប់មេរៀននេះ ។

ជំហានទី២ ថ្វាយបញ្ហារបស់អ្នកទៅកាន់ព្រះជាម្ចាស់

ព្រះជាម្ចាស់ជាព្រះដែលធំជាងបញ្ហាគ្រប់បែបយ៉ាងដែលអ្នកមាន។ សូមក្រឡេកចេញពីបញ្ហារបស់អ្នក ហើយសំឡឹងទៅមើល ព្រះដែលជ្រាបគ្រប់ការទាំងអស់ ដែលមានប្រាជ្ញាលើសអ្វីទាំងអស់ ដែលមានក្តីស្រឡាញ់លើសគេ និង ជាព្រះដ៏មានឫទ្ធានុភាពលើសអ្វីគ្រប់យ៉ាង គឺព្រះយេស៊ូគ្រិស្ត។ ទ្រង់ខ្វល់ព្រះទ័យចំពោះអ្នក (គម្ពីរ ១ពេត្រុស ៥:៧) ។ ចូរនិយាយអំពីបញ្ហាថ្វាយទៅកាន់ព្រះជាម្ចាស់។ នោះគឺជាការនិយាយចេញមកឲ្យឮៗដោយពាក្យរបស់អ្នកផ្ទាល់។ ព្រះជាម្ចាស់ជ្រាបហើយថា បញ្ហានោះជាអ្វី ប៉ុន្តែទ្រង់សព្វព្រះហឫទ័យឲ្យយើងចូលទៅរកទ្រង់តាមរយៈការអធិស្ឋាន។

ការអធិស្ឋានប្រកបដោយភាពជាក់លាក់ ពិតជាមានសារៈសំខាន់ណាស់។ ខ្ញុំស្គាល់ស្ត្រីដែលជាគ្រិស្តបរិស័ទម្នាក់ គាត់បានកត់ត្រាសំណូមពរអធិស្ឋានរបស់គាត់ ព្រមទាំងបានកត់ត្រាថ្ងៃដែលគាត់ចាប់ផ្តើមអធិស្ឋានសម្រាប់សំណូមពរនីមួយៗ។ ក្រោយមកទៀត នៅពេលដែលមានការឆ្លើយតប គាត់បានតក់ត្រាថ្ងៃនោះទុកផងដែរ។ គាត់និយាយថា នៅពេលដែលគាត់បើកមើលកំណត់ត្រា វាបានជួយពង្រឹងជំនឿរបស់គាត់ ហើយឲ្យគាត់ឃើញថា ព្រះជាម្ចាស់ស្មោះត្រង់យ៉ាងណា។ ការធ្វើដូច្នេះ ក៏ជួយរំឭកគាត់ឲ្យអរព្រះគុណព្រះជាម្ចាស់សម្រាប់សេចក្តីអធិស្ឋានដែលទទួលបានការឆ្លើយតបទាំងនោះផងដែរ។

នៅពេលដែលអ្នកបាន បង្វែរគំនិតចេញពីបញ្ហារបស់អ្នកទៅរកព្រះអម្ចាស់ អ្នកនឹងមានអារម្មណ៍ថាមានបន្ទុកយ៉ាងធ្ងន់មួយបានរអិលចេញពីស្មារបស់អ្នក។ ការព្រួយបារម្ភត្រូវតែចេញឆ្ងាយពីអ្នក ព្រោះអ្នកទុកចិត្តលើព្រះគ្រិស្ត។ បន្ទុក ក៏ត្រូវចេញពីអ្នក ព្រោះទ្រង់មានបន្ទូលថា "អស់អ្នកដែលនឿយហត់ និងមានបន្ទុកធ្ងន់អើយ! ចូរមករកខ្ញុំ ខ្ញុំនឹងអោយអ្នករាល់គ្នាបានសំរាក។" (គម្ពីរម៉ាថាយ ១១:២៨)។ " ចូរផ្ទេរទុក្ខកង្វល់ទាំងប៉ុន្មានរបស់បងប្អូនទៅព្រះអង្គទៅ ដ្បិតទ្រង់យកព្រះហឫទ័យទុកដាក់នឹងបងប្អូន។" (គម្ពីរ ១ពេត្រុស ៥:៧)។ នេះគឺជា និយមន័យពិតប្រាកដនៃការប្តេជ្ញាៈ ការខ្វល់ខ្វាយ គ្រប់គ្រាន់នឹងជំរុញឲ្យ ធ្វើអ្វីដែលគួរធ្វើ និង ការជឿទុកចិត្ត ដែលដកការព្រួយបារម្ភ និងភាពភ័យខ្លាចឲ្យចេញឆ្ងាយ។

លំហាត់អនុវត្តន៍

១១ ចូរសរសេរបន្ថែមសំណួរទីប្រាំ ទៅក្នុងតារាងរបស់អ្នក ដោយយោងតាមជំហានទី២។

ជំហានទី៣ គិតអំពីដំណោះស្រាយទាំងអស់ដែលអាចមាន

យើងបានពិភាក្សាគ្នារួចមកហើយនៅក្នុងមេរៀនទី ២ អំពីរបៀបស្វែងរកដំណោះស្រាយ។ មានពេលខ្លះ ក៏មានដំណោះស្រាយជាច្រើន សម្រាប់បញ្ហាតែមួយ។ អ្វីដែលអ្នកគួរធ្វើ គឺស្វែងរកដំណោះស្រាយដែល *ល្អបំផុត* ។ សូមអនុវត្តជំហានទាំងនេះ សម្រាប់គ្រប់ដំណោះស្រាយទាំងអស់ដែលមាន។

១. ស្វែងរកគោលការណ៍តាមបទគម្ពីរ ដែលយកទៅអនុវត្តនៅក្នុងបញ្ហានោះបាន។ ច្រានចោលដំណោះស្រាយទាំងឡាយណាដែលមិន ដើរតាមគោលការណ៍នៃព្រះគម្ពីរ។

២. ស្វែងរកចម្លើយនៅក្នុងកន្លែងដែលសមរម្យ (ត្រឹមត្រូវ) ។ ចូរប្រើប្រាស់ធនធានរបស់អ្នក។ (សូមមើលមេរៀនទី២)

៣. ស្វែងរកបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

លំហាត់អនុវត្តន៍

១២ សូមសរសេរបន្ថែមសំណួរទី ៦ ដល់ទី៨ ទៅក្នុងតារាងរបស់អ្នក ដោយផ្អែកលើជំហានទី៣ នេះ។ អ្នកត្រូវសរសេរសំណួររបស់អ្នកសិន មុនពេលដែលអ្នកទៅមើលសំណួរដែលខ្ញុំបានសរសេរ។ ធ្វើដូច្នេះ នឹងជួយអ្នកឲ្យចងចាំអ្វីដែលអ្នកបានរៀន។

ជំហានទី៤ គិតអំពីផលវិបាកនៃជម្រើសទាំងអស់ ដែលអាចកើតមាន

សូមគិតពីផលវិបាកដែលអាចកើតមាន ចំពោះគូស្វាមីភរិយាដែលបានសម្រេចចិត្តថា ការលែងលះគ្នាគឺជាដំណោះស្រាយសម្រាប់បញ្ហារបស់ពួកគេ។ លទ្ធផលនៃគ្រួសារដែលបែកបាក់ មិនត្រឹមតែជះឥទ្ធិពលដល់ ប្តី និង ប្រពន្ធនោះឡើយ ប៉ុន្តែក៏ជះឥទ្ធិពលដល់កូនៗផងដែរ។ ដំណោះស្រាយដែលខុសមួយវាអាចបង្កើតឲ្យមានបញ្ហាធំជាង បញ្ហាដើមដំបូងទៅទៀត។ នោះជាមូលហេតុដែល វាជារឿងសំខាន់ណាស់ ក្នុងការច្រានចោលដំណោះស្រាយណា ដែលមិនស្របតាមការបង្រៀនរបស់បទគម្ពីរ។ ចូរប្រើប្រាស់ធនធានរបស់អ្នកដើម្បីធ្វើការកំណត់ ផលវិបាកអ្វីដែលអាចជាលទ្ធផលដែលបានមកពីការសម្រេចចិត្តរបស់អ្នក។

លំហាត់អនុវត្តន៍

១៣ ចូរសរសេរបន្ថែមសំណួរទី ៩ ទៅក្នុងតារាងរបស់អ្នកដោយផ្អែកលើជំហានទី៤។ សូមគិតពិចារណាពីតម្លៃដ៏អស់កល្បជានិច្ចនៃការសម្រេចចិត្តរបស់អ្នក ក៏ដូចជាតម្លៃក្នុងពេលបច្ចុប្បន្ននៅលើលោកីយ៍នេះផងដែរ។

ជំហានទី៥ : ជ្រើសយកដំណោះស្រាយមួយ ហើយយកវាទៅប្រើប្រាស់ៗ

អ្នកបានស្គាល់បញ្ហារបស់អ្នកហើយ អ្នកក៏បានថ្វាយបញ្ហានោះទៅកាន់ព្រះជាម្ចាស់ដោយការអធិស្ឋានដែរ។ អ្នកបានសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងយកចិត្តទុកដាក់ ដើម្បីស្វែងរកសេចក្តីបង្រៀនរបស់ទ្រង់ដែលទាក់ទងនឹងបញ្ហារបស់អ្នក ឬ បញ្ហាផ្សេងៗទៀតផងដែរ។ បើចាំបាច់ អ្នកត្រូវពិភាក្សាបញ្ហាអ្នកជាមួយនឹងមិត្តភក្តិដែលជាគ្រិស្តបរិស័ទ គ្រូគង្វាល ឬ អ្នកប្រឹក្សាយោបល់ផងដែរ។ អ្នកបានប្រើប្រាស់ការវិនិច្ឆ័យដ៏ល្អបំផុតរបស់អ្នក អ្នកត្រូវបានដឹកនាំដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីធ្វើការសម្រេចចិត្តថា បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ សម្រាប់អ្នកនៅក្នុងស្ថានភាពនោះ ជាអ្វី។ ឥឡូវនេះជាពេល ដែលត្រូវធ្វើតាមជម្រើសដែលអ្នកបានជ្រើសរើសហើយ។ ចូរជឿថាព្រះជាម្ចាស់នឹងជួយអ្នក ហើយទ្រង់នឹងគង់ជាមួយអ្នក នៅពេលដែលអ្នកបោះជំហានទៅមុខក្នុងការដោះស្រាយបញ្ហារបស់អ្នក។

ជំហានទី៦ : វាយតម្លៃទៅលើលទ្ធផល ដែលបានមកពីដំណោះស្រាយរបស់អ្នក និង ធ្វើការកែតម្រូវផ្សេងៗដែលមាន

ខ្ញុំបានបូកបញ្ចូលជំហាននេះ ព្រោះយើងត្រូវធ្វើការវាយតម្លៃលទ្ធផលរបស់ដំណោះស្រាយដែលយើងបានជ្រើសរើស។ មិនយូរប៉ុន្មាន ក្រោយពេលយើងបានធ្វើការដោះស្រាយបញ្ហាមួយហើយយើងឃើញថា ជម្រើសនោះមិនមែនជាជម្រើសល្អបំផុតនោះទេ ហើយវាចាំបាច់ត្រូវមានការកែតម្រូវបន្តែមទៀត។ មិនត្រូវអស់សង្ឃឹមឡើយ ប្រសិនបើអ្នកបានធ្វើទៅតាមការវិនិច្ឆ័យដ៏ល្អបំផុតរបស់អ្នក ក្រោយពីបានថ្វាយបញ្ហារបស់អ្នកទៅកាន់ព្រះជាម្ចាស់ហើយ និង បានទូលសូមការដឹកនាំរបស់ទ្រង់ ហើយក្រោយមកអ្នកឃើញថា ដំណោះស្រាយរបស់អ្នកត្រូវបរាជ័យក្នុងការទទួលបានលទ្ធផលដែលជាទីគាប់ចិត្តអ្នក។ ការដោះស្រាយបញ្ហា អាចរៀនបានតាមរយៈបទពិសោធន៍។ ការដោះស្រាយបញ្ហាមិនមែនជាទេពកោសល្យដែលអ្នកទទួលស្នងពីកំណើតនោះឡើយ។ នេះគឺជាពេលវេលាមួយដែលត្រូវមើលទៅក្នុងខ្លួនអ្នកដើម្បីមើលឃើញថាអ្នកបានថ្វាយខ្លួនរបស់អ្នកទាំងស្រុងទៅកាន់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយត្រៀមខ្លួនជាស្រេចដើម្បីដើរទៅកន្លែងណាដែលទ្រង់នាំផ្លូវទៅ។

លំហាត់អនុវត្តន៍

---

១៤ ដើម្បីសរុបតារាងរបស់អ្នក ចូរសរសេរបន្ថែម សំណួរទី១០ ដោយផ្អែកលើជំហានទី ៦។

ចូរចងចាំផងដែរថា មិនមែនគ្រប់ស្ថានភាពដែលមិនអំណោយផលទាំងអស់សុទ្ធតែជាបញ្ហាដែលត្រូវការ ដំណោះស្រាយប្រភេទនោះឡើយ។ ប្រសិនបើ បញ្ហានោះជាអ្វីដែលមិនអាចផ្លាស់ប្តូរបាន វាត្រូវការការកែតម្រូវតាមបែបផ្សេងទៀត។ សម្រាប់ដំណោះស្រាយប្រភេទនេះ ចូរទៅមើលនៅក្នុងវិធីសាស្ត្រ ខ។

វិធីសាស្ត្រ ខ

ជំហានទី១. ស្គាល់បញ្ហា

ប្រើប្រាស់ដំណើរការដូចនៅក្នុងវិធីសាស្ត្រ ក ដែរ។

ជំហានទី២. ថ្វាយបញ្ហានោះទៅកាន់ព្រះជាម្ចាស់

ប្រើប្រាស់ដំណើរការដូចនៅក្នុងវិធីសាស្ត្រ ក ដែរ។

ជំហានទី៣. រំពឹងថាព្រះជាម្ចាស់ធ្វើការដើម្បីប្រយោជន៍របស់អ្នក ។

នៅពេលដែលលោកសាវ័កប៉ូល បានឃើញថាខ្លួនលោកកំពុងតែជាប់ក្នុងគុក លោកបានដឹងថា លោកមិនអាចផ្លាស់ប្តូរស្ថានភាពនោះបានទេ។ ព្រះជាម្ចាស់មិនបានដោះគាត់ឲ្យចេញពីគុកនៅក្នុងពេលនោះ ដូចនៅពេលដែលទ្រង់បានធ្វើឲ្យព័ន្ធកិច្ចរបស់លោកប៉ូលមានភាពងាយស្រួលកន្លងមកនោះទេ (គម្ពីរកិច្ចការជំពូក១៦) ។ ប៉ុន្តែលោកប៉ូលបានរំពឹងទុកថា ទោះជាយ៉ាងណា ព្រះជាម្ចាស់នឹងធ្វើការសម្រាប់ប្រយោជន៍របស់លោក។ ជាលទ្ធផល ព្រះអម្ចាស់បានប្រើប្រាស់លោកតាមរបៀបដ៏អស្ចារ្យមួយ ក្នុងការចែកចាយដំណឹងល្អទោះបីជាលោកនៅជាប់ក្នុងគុកក៏ដោយ។

ដំណោះស្រាយដ៏ពិតប្រាកដ ចំពោះបញ្ហាប្រភេទនេះ គឺត្រូវទទួលដោយអំណរ នូវអ្វីដែលមិនអាចផ្លាស់ប្តូរបាន និង អនុញ្ញាតឲ្យស្ថានភាពនោះបានក្លាយទៅជាបទពិសោធន៍ដើម្បីឲ្យអ្នកបានលូតលាស់ និង កែច្នៃអ្នកឲ្យមានលក្ខណៈដូចជាព្រះគ្រិស្ត និង ធ្វើឲ្យអ្នកក្លាយជាមនុស្សដែលចេះខ្ជល់ខ្ជាយ និង មានចិត្តអាណិតអាសូរ។ ចូររំឭកខ្លួនឯងឲ្យបានញឹកញាប់ថា "អ្វីៗទាំងអស់ធ្សំគ្នាឡើង ដើម្បីអោយអស់អ្នកស្រឡាញ់ព្រះជាម្ចាស់ បានទទួលផលល្អ" (គម្ពីររ៉ូម ៨:២៨)។ មិនមែនជារឿងល្អទេ ដែលអ្នកខ្ជល់ខ្ជាយថា "ស្ថានការណ៍គួរតែទៅជាបែបណា ប្រសិនបើ....." ។ គំនិតបែបនោះ ជាការខាតបង់ពេលវេលា និងកម្លាំងឥតប្រយោជន៍។ អ្នកអាចរំពឹងឲ្យព្រះជាម្ចាស់ធ្វើការដើម្បីផលល្អរបស់អ្នក មិនថាស្ថានភាពរបស់អ្នកជាអ្វីក៏ដោយ។

លំហាត់អនុវត្តន៍

---

១៥ តើបញ្ហាណាខ្លះ ខាងក្រោមនេះ ដែលអ្នកអាចយកវិធីសាស្ត្រ ខ មកអនុវត្តជាមួយបាន?

ក) អ្នកបានបំពានទៅលើមិត្តភក្តិរបស់អ្នកយ៉ាងខ្លាំង ដោយអ្នកបាននិយាយអាក្រក់អំពីគាត់។

ខ) អ្នកត្រូវតែមើលថែ ឪពុកម្តាយមានជំងឺ និង ចាស់ជរា ដែលគាត់គ្មានអ្វីជាទីពឹងបាន។

គ) ប្តីរបស់អ្នកបានស្លាប់ ហើយឥឡូវនេះអ្នកនៅតែម្នាក់ឯង។

ឃ) កន្លែងដែលអ្នកស្នាក់នៅ មានសភាពចាស់ទ្រុឌទ្រោម ប៉ុន្តែវាជាកន្លែងតែមួយគត់ដែលអ្នកអាច មានលទ្ធភាពបង់ថ្លៃបានក្នុងពេលបច្ចុប្បន្ននេះ។

ង) កូនប្រុសវ័យជំទង់របស់អ្នកបាន រត់ចេញពីផ្ទះ ហើយអ្នកមិនដឹងថាគាត់នៅទីណានោះទេ។

ច) អ្នកចង់បន្តការសិក្សារបស់អ្នក ប៉ុន្តែឪពុកម្តាយរបស់អ្នកមិនអាចមានលទ្ធភាពជួយអ្នកបង់ថ្លៃបានទេ។

១៦ ចូរអានគម្ពីរដានីយ៉ែល ១: ១-២០ ហើយធ្វើតាមជំហានក្នុងការដោះស្រាយបញ្ហា ដោយសរសេរបទគម្ពីរ និង ទង្វើនៅពីក្រោយសំណួរនីមួយៗ នៅក្នុងតារាងរបស់អ្នក ដែលបង្ហាញពីរបៀបដែលលោកដានីយ៉ែលធ្វើការដោះស្រាយតាមផ្នែកនីមួយៗ ដោយមានជំនួយពីព្រះជាម្ចាស់ ។ ប្រសិនបើអ្នកមិនអាចរកឃើញចម្លើយនោះទេ សូមទុកចន្លោះនោះនៅទទេ។ ចូរផ្សារភ្ជាប់សំណួរ នីមួយៗទៅជាមួយនឹងស្ថានភាពរបស់លោកដានីយ៉ែល ឧទាហរណ៍៖ សំណួរទី១ គួរតែសួរយ៉ាងដូច្នេះ " តើបញ្ហារបស់លោកដានីយ៉ែលជាអ្វី?" រួចសរសេរចម្លើយនៅក្នុងសៀវភៅសរសេររបស់អ្នក។

១៧ ឥឡូវនេះ ចូរយកវិធីសាស្ត្រ ក និង វិធីសាស្ត្រ ខ ទៅអនុវត្តនៅក្នុងព្រឹត្តិការណ៍ដែលបានកត់ត្រានៅក្នុងគម្ពីរ ដានីយ៉ែល ៦:១- ២៨។ តើវិធីសាស្ត្រមួយណា ដែលអាចផ្តល់ដំណោះស្រាយនៅក្នុងករណីមួយនេះ?

.....

ឃ. អរសប្បាយ និង អរព្រះគុណ

វត្ថុបំណងទី៥. *ប្រាប់ពីគោលការណ៍មួយដែលបកស្រាយពីអ្វីដែលបានជួយលោកសាវ័កប៉ូល ឲ្យបានសប្បាយចិត្តនៅក្នុងគ្រប់កាល:ទេស:ទាំងអស់។*

គោលការណ៍ចុងក្រោយនៅក្នុងការឆ្លើយតបរបស់គ្រិស្តបរិស័ទចំពោះការដោះស្រាយបញ្ហា គឺការថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ ៖ "ចូរមានអំណរសប្បាយជានិច្ច ចូរអធិស្ឋានឥតឈប់ឈរ ចូរអរព្រះគុណព្រះជាម្ចាស់គ្រប់កាល:ទេស:ទាំងអស់ ដ្បិតព្រះអង្គសព្វព្រះហឫទ័យអោយបងប្អូន ដែលរួមជាមួយព្រះគ្រិស្តយេស៊ូធ្វើដូច្នេះឯង" (គម្ពីរ១ថែស្សាឡូនិក ៥:១៦-១៨)។ ចូរបន្តការសរសើរតម្កើងព្រះជាម្ចាស់។ នៅពេលណាដែលគំនិតរបស់អ្នក មិនគិតអំពីរឿងរ៉ាវចាំបាច់នោះទេ ចូរបង្កើតទម្លាប់ អនុញ្ញាតឲ្យ មានការសរសើរតម្កើងព្រះជាម្ចាស់យ៉ាងស្ងៀមស្ងាត់ហូរនៅក្នុងគំនិតរបស់អ្នក។ ការអនុវត្តយ៉ាងសាមញ្ញមួយនេះនឹងផ្លាស់ប្រែគំនិតរបស់អ្នក។ ចូរសរសើរតម្កើងទ្រង់ សម្រាប់ក្តីស្មោះត្រង់របស់ទ្រង់ សម្រាប់ការដែលទ្រង់ឈរជាមួយអ្នកក្នុងគ្រប់បញ្ហាទាំងអស់។

ចូរចែកចាយដំណឹងល្អរបស់អ្នកជាមួយអ្នកដទៃ ដូចលោកប៉ូលបានធ្វើដូច្នោះដែរ! លោកប៉ូលបានសរសេរអំពីភាពស្មោះត្រង់របស់គ្រិស្តបរិស័ទ នៅពេលដែលលោកសរសេរសំបុត្រផ្ញើទៅកាន់មិត្តភក្តិរបស់គាត់ដែលជាគ្រិស្តបរិស័ទនៅក្រុងភីលីព (គម្ពីរភីលីព ១:១២)។ លោកមិនចង់ឲ្យពួកគេមានអារម្មណ៍អាណិតលោកនោះទេ! លោកបានថ្លែងទាំងមានអំណរថា៖ " គឺគ្រប់ពេល ខ្ញុំទូលអង្វរព្រះជាម្ចាស់សំរាប់បងប្អូនទាំងអស់គ្នា ខ្ញុំទូលអង្វរដោយចិត្តរីករាយជាដរាប ព្រោះបងប្អូនរួមចំណែកក្នុងការផ្សាយដំណឹងល្អតាំងពីថ្ងៃដំបូង រហូតមកទល់សព្វថ្ងៃ" (គម្ពីរភីលីព ១:៤-៥) ។ លោកប៉ូលក៏បានចែកចាយពីពួកគេ អំពីរឿងខ្លះៗ ដែលលោកបានរៀននៅពេលដែលលោកបានអនុញ្ញាតឲ្យព្រះជាម្ចាស់ធ្វើការដោះស្រាយបញ្ហានៅក្នុងជីវិតរបស់គាត់៖

ខ្ញុំនិយាយដូច្នេះ មិនមែនមកពីខ្ញុំខ្វះខាតទេ ដ្បិតខ្ញុំបានរៀនអោយចេះស្កប់ចិត្ត ក្នុងគ្រប់កាលៈទេសៈ។ ទោះបីទ័លក្រក្តី មានបរិបូណ៌ក្តី ខ្ញុំក៏ចេះរស់ដែរ។ ខ្ញុំបានអប់រំចិត្តក្នុងគ្រប់កាលៈទេសៈ និងគ្រប់ទីកន្លែង គឺថាទោះបីបរិភោគឆ្អែតក្តី អត់ឃ្លានក្តី មានបរិបូណ៌ក្តី ឬខ្វះខាតក្តី ខ្ញុំស្កប់ចិត្តជានិច្ច។ ខ្ញុំអាចទ្រាំបានទាំងអស់ ដោយរួមជាមួយព្រះអង្គដែលប្រទានកម្លាំងអោយខ្ញុំ។ (គម្ពីរភីលីព ៤:១១-១៣)

លំហាត់អនុវត្តន៍

១៨ តើគោលការណ៍អ្វីខ្លះ នៅក្នុងមេរៀននេះ បានបកស្រាយអ្វីដែលបានជួយលោកប៉ូលបាន សប្បាយចិត្ត និង មានអំណរ នៅក្នុងស្ថានភាពគ្រប់ប្រភេទទាំងអស់?

....

១៩ បទគម្ពីរនេះ បង្ហាញថា គុណតម្លៃដែលសំខាន់អស្ចារ្យជាងគេបង្អស់សម្រាប់លោកប៉ូល គឺ

ក) គុណតម្លៃដែលនៅលើផែនដីក្នុងពេលបច្ចុប្បន្ន។

ខ) គុណតម្លៃដ៏អស់កល្បជានិច្ច។

នៅពេលដែលអ្នកដឹងថា ព្រះគ្រិស្តជាម្ចាស់លើគ្រប់ស្ថានភាពគ្រប់បែបយ៉ាង ដែលកើតមាននៅក្នុងជីវិតរបស់យើង ជាម្ចាស់ដែលខ្វល់ព្រះទ័យចំពោះយើង ហើយជាម្ចាស់ដែលតែងតែធ្វើការសម្រាប់ប្រយោជន៍ដ៏អស់កល្បជានិច្ចរបស់យើង យើងមិនអាចធ្វើអ្វីបានទេក្រៅពីសរសើរតម្កើងទ្រង់។ ទ្រង់ស័ក្តិសមទទួលការសរសើររបស់យើង!

ឥឡូវនេះ យើងត្រៀមខ្លួនរួចជាស្រេច ដើម្បីពិចារណាអំពីបញ្ហាពិសេសៗដែលកើតឡើងច្រើនទៅលើមនុស្ស ហើយជាបញ្ហាដែលអ្នកអាចនឹងត្រូវប្រឈមមុខ។ នៅក្នុងជំពូកបន្ទាប់ យើងនឹងពិភាក្សាគ្នាអំពីបញ្ហានៅក្នុងទំនាក់ទំនង។ យើងអធិស្ឋាន សូមឲ្យការសិក្សានេះ ក្លាយជាជំនួយដ៏ល្អសម្រាប់អ្នក។

ការប្រឡងផ្ទាល់ខ្លួន

នៅក្នុងការប្រឡងផ្ទាល់ខ្លួននេះ យើងនឹងរៀបរាប់អំពីស្ថានភាពបញ្ហាខ្លះៗ និង លទ្ធផលរបស់បញ្ហាទាំងនោះ បន្ទាប់មកយើងនឹងផ្តល់ឱកាសឲ្យអ្នកយកគោលការណ៍ នៅក្នុងមេរៀននេះទៅអនុវត្ត ដើម្បីឲ្យបានមើលឃើញថាវាអាចដោះស្រាយបាន តាមរបៀបមួយដែលល្អប្រសើរជាង។ ក្រោយពេល អ្នកបានធ្វើការប្រឡងផ្ទាល់ខ្លួននេះ រួចរាល់ហើយ ចូរប្រៀបធៀបចម្លើយរបស់អ្នកជាមួយនឹងចម្លើយរបស់យើង(ក្នុងមេរៀននេះ)។

១ រេម៉ន និង អាឡែន ជាកូនរបស់គ្រួគង្វាលម្នាក់នៃក្រុមជំនុំតូចមួយ ហើយគាត់មានចំណូលបន្តិចបន្តួចតែប៉ុណ្ណោះ។ រេម៉ន ប្រាថ្នាចង់ក្លាយជាវេជ្ជបណ្ឌិតម្នាក់។ នៅពេលដែលគាត់ ឈានដល់អាយុដែលអាចរៀនមហាវិទ្យាល័យបាន ឪពុកម្តាយរបស់គាត់បានសម្រេចចិត្តប្រើប្រាស់លុយដែលពួកគេបានសន្សំ ដើម្បីបញ្ជូនរេម៉នទៅរៀននៅសាលាវេជ្ជសាស្ត្រ។ នោះមានន័យថា ពួកគេគ្មាននៅសល់ប្រាក់សម្រាប់ជួយឲ្យអាឡែនចូលរៀនមហាវិទ្យាល័យបានទេ។ ឪពុកម្តាយរបស់នាងបានរំពឹងថា នាងនឹងអាចរៀបការ ហើយមិនត្រូវការការអប់រំនៅក្នុងមហាវិទ្យាល័យនោះទេ។ ប៉ុន្តែ អាឡែនក៏មានក្តីស្រមៃចង់រៀនមហាវិទ្យាល័យដែរ ហើយការសម្រេចចិត្តរបស់ឪពុកម្តាយរបស់នាង ពិតជាធ្វើឲ្យនាងខកបំណងខ្លាំងណាស់។ ដោយឪពុកម្តាយរបស់នាង មិនអាចជួយនាងបាន អាឡែនក៏កើតមានអារម្មណ៍ស្រណោះខ្លួនឯង។ នាងក៏ចាប់ផ្តើម ទាញខ្លួនឯងចូលទៅក្នុងពិភពមួយដែលមានតែនាងម្នាក់ឯង ចាប់ផ្តើមចំណាយពេលរបស់នាង ទួញសោកចំពោះការសម្រេចចិត្តរបស់ឪពុកម្តាយនាង។ ភាពក្រៀមក្រំយ៉ាងខ្លាំងនៅក្នុងគំនិតរបស់នាង ស្ទើរតែបំផ្លាញសុខភាពរបស់នាងទៅហើយ។ ជាច្រើនសប្តាហ៍ នាងបានសំរាកនៅក្នុងមន្ទីរពេទ្យដែល បងប្រុសរបស់នាងកំពុងតែធ្វើការហ្វឹកហាត់ការងារនៅទីនោះផងដែរ។ រេម៉នជាគ្រិស្តបរិស័ទ ដ៏ស្មោះត្រង់ម្នាក់។ អាឡែនក៏ជាគ្រិស្តបរិស័ទម្នាក់ផងដែរ ប៉ុន្តែនាងបានចុះចាញ់បញ្ហារបស់នាងទៅហើយ។

ក) តើបញ្ហារបស់អាឡែន ជាអ្វី?

.....

ខ) តើអ្វីជា ប្រភពនៃបញ្ហារបស់នាង?

.....

គ) តើអាឡែន ឆ្លើយតបទៅចំពោះបញ្ហារបស់នាងដោយរបៀបណា?

.....

ឃ) ប្រសិនបើ អាឡែនបានធ្វើតាមគោលការណ៍សម្រាប់ការដោះស្រាយបញ្ហា ដែលមាននៅក្នុងមេរៀននេះ តើនឹងអាចមានដំណោះស្រាយអ្វីសម្រាប់នាង? អ្នកប្រហែលជាអាចគិតឃើញច្រើនជាងមួយ។

.....

.....

.....

ង) តើបទគម្ពីរដែលយើងទើបនឹងបានរំឭក មានរៀបរាប់អ្វីខ្លះ អំពីមធ្យោបាយដែលអាឡែនគួរតែជ្រើសយកសម្រាប់ការស្វែងរកដំណោះស្រាយចំពោះបញ្ហារបស់នាង?

.....

២ លោក ច័រដាន គឺជាអ្នកជំនួយគ្រិស្តបរិស័ទម្នាក់ដែលជាម្ចាស់ផ្សារលក់សាច់មួយ។ នៅថ្ងៃមួយ គាត់បានទិញ សត្វចៀមខ្លះពីមិត្តរបស់គាត់ឈ្មោះ ដាវីឌ ដែលជាគ្រិស្តបរិស័ទម្នាក់ដែរ។ លោកច័រដានលោកបានពិឃាដ សត្វចៀមទាំងនោះ ប៉ុន្តែអ្នកត្រួតពិនិត្យសុខភាព មិនអនុញ្ញាតឲ្យដាក់លក់សាច់នោះឡើយ ដោយគេនិយាយថា សាច់នោះមានជំងឺ ហើយត្រូវតែបំផ្លាញចោល។ លោកច័រដាន ពិតជាខឹងចិត្តខ្លាំងណាស់ គាត់បានទៅរកលោកដាវីឌ ហើយទាមទារប្រាក់របស់លោកមកវិញ។ លោកដាវីឌ មិនទទួលស្គាល់ថាចៀមទាំងនោះមានជំងឺនៅពេលលក់នោះទេ ហើយក៏មិនព្រមសងប្រាក់វិញដែរ។ ដោយខឹងខ្លាំងណាស់ លោកច័រដាន បានដាក់ពាក្យបណ្តឹងលោកដាវីឌ។ នៅពេលដែលគ្រូគង្វាលរបស់ពួកគេបានឮអំពីបញ្ហានេះ គាត់បានព្យាយាមអញ្ជើញលោកដាវីឌ និង លោកច័រដានមក ហើយពិភាក្សាគ្នាអំពីបញ្ហានោះជាមួយគាត់ និងព្យាយាមដោះស្រាយបញ្ហាជាមួយមធ្យោបាយរបស់គ្រិស្តបរិស័ទ។ គ្រូគង្វាលបានរំឭកអ្នកទាំងពីរបទគម្ពីរហាមមិនឲ្យគ្រិស្តបរិស័ទយកជម្លោះរបស់ពួកគេទៅឲ្យពួកមនុស្សមិនបរិសុទ្ធ (គម្ពីរ ១កូរិនថូស ៦:១-៨) ។ ប៉ុន្តែ លោកច័រដានមិនព្រមស្តាប់ទេ ហើយបានឈានទៅរកការប្តឹងតែម្តង។ លោកច័រដាន និង លោកដាវីឌ លែងជាមិត្តនឹងគ្នាទៀតហើយ ព្រមទាំងធ្វើឲ្យក្រុមជំនុំបានអារម្មណ៍ថាបរាជ័យផងដែរ។

ក) តើគោលការណ៍ នៃការដោះស្រាយបញ្ហា អ្វីខ្លះដែលលោកច័រដាន គួរតែអនុវត្តតាមដើម្បីដោះស្រាយបញ្ហារបស់គាត់តាមបែបគ្រិស្តបរិស័ទ?

.....

.....

ខ) តើលទ្ធផលចុងក្រោយដែលបានមកពីអាកប្បកិរិយារបស់គាត់ ជាអ្វី?

.....

.....

គ) តើបញ្ហានោះគួរតែទៅជាយ៉ាងណាវិញ?

.....

.....

ឃ) ចូរអនុវត្តជំហាននៃការដោះស្រាយបញ្ហា ដើម្បីបង្ហាញឲ្យឃើញពីរបៀបដែលបញ្ហានេះគួរតែត្រូវបានដោះស្រាយយ៉ាងជោគជ័យ និងដើម្បីសរសើរតម្កើងព្រះជាម្ចាស់។ ចូរសរសេរចម្លើយរបស់អ្នកនៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

៣ លោកចេម និង អ្នកស្រី អែសធើរ បានរៀបការអស់រយៈពេលដប់ឆ្នាំមកហើយ ប៉ុន្តែពួកគេមិនមានកូនសោះ។ ពួកគាត់ទាំងពីរនាក់មានបំណងចង់បានកូនខ្លាំងណាស់ ហើយបានអធិស្ឋាន ជាច្រើនដងមកដែរ ដើម្បីឲ្យព្រះជាម្ចាស់បំពេញតម្រូវការរបស់ពួកគាត់។ ពួកគេបានស្វែងរក ជំនួយពីថ្នាំ ពេទ្យ ប៉ុន្តែគ្មានគ្រូពេទ្យណាអាចជួយគាត់បានឡើយ។ នៅក្នុងពេលជាមួយគ្នានោះ ដែរ ពួកគាត់បានថ្វាយការបម្រើរបស់ពួកគាត់ទៅគ្រួគង្វាល ដើម្បីធ្វើការជាមួយក្មេងៗ នៅក្នុង ក្រុមជំនុំ ហើយព្រះជាម្ចាស់បានប្រទានពរដល់ព័ន្ធកិច្ចរបស់ពួកគាត់ក្នុងការបង្រៀនក្មេងៗជាច្រើន និង បាននាំពួកគេមកឯព្រះអម្ចាស់។ ជីវិតរបស់ពួកគាត់ មានពោរពេញទៅដោយការ សរសើរតម្កើងសម្រាប់ព្រះជាម្ចាស់។

ក) តើវិធីសាស្ត្រនៃការដោះស្រាយបញ្ហាមួយណា ដែលបានយកមកអនុវត្តនៅត្រង់នេះ?

.....

ខ) ចូរប្រើប្រាស់តារាងរបស់អ្នក ដើម្បីបង្ហាញពីរបៀបដែលលោកចេម និង អ្នកស្រីអែសធើរ ដោះស្រាយបញ្ហារបស់ពួកគាត់។ ចូរសរសេរ ចម្លើយរបស់អ្នកនៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

៤ ចូរប្រើប្រាស់តារាងរបស់អ្នក សម្រាប់បញ្ហានៅក្នុងជីវិតរបស់អ្នកផ្ទាល់ ឬ នៅក្នុងជីវិតរបស់ នរណាម្នាក់ដែលអ្នកស្គាល់។ ចូរអនុវត្តជំហាននីមួយៗដែលបានផ្តល់ជូន ហើយជឿថាព្រះជាម្ចាស់នឹងជួយអ្នកដើម្បីស្វែងរកដំណោះស្រាយយ៉ាងត្រឹមត្រូវ។

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១០ ចម្លើយរបស់អ្នកគួរតែស្រដៀងនឹងចម្លើយទាំងនេះ៖

១. តើបញ្ហារបស់ខ្ញុំជាអ្វី?
២. តើប្រភពនៃបញ្ហានោះជាអ្វី?
៣. តើបញ្ហានោះមានប្រភពស៊ីជម្រៅជាងនេះ ដែលខ្ញុំគួរតែពិចារណាដែរឬទេ?
៤. តើបញ្ហានោះមាន ដំណោះស្រាយដ៏ជាក់លាក់មួយបានដែរឬទេ?

១ ចម្លើយរបស់អ្នក។ អ្នកគួរតែឆ្លើយដូចខាងក្រោមនេះ៖

ក) បញ្ហាពិតប្រាកដ គឺ*ការមិនស្តាប់បង្គាប់ព្រះជាម្ចាស់* ដែលរួមមាន ខកខានការអានព្រះបន្ទូលរបស់ទ្រង់ ខកខាកការអធិស្ឋាន និង មិនបានរក្សាថ្ងៃរបស់ទ្រង់ជាវិសុទ្ធ (ការចូលរួមក្នុងព្រះវិហារ)។

ខ) ប្រភពនៃបញ្ហាគឺជា និស្ស័យបាប។

គ) ដំណោះស្រាយតាមសុភនិច្ឆ័យគួរតែជា *ការលន់តួបាប* និង *ការស្តាប់បង្គាប់* ព្រះជាម្ចាស់។ ដំណោះស្រាយនេះនឹងរៀបចំវិញ្ញាណគូស្វាមីភរិយានោះ ឲ្យប្រឈមមុខជាមួយបញ្ហាផ្សេងៗទៀតដែលកើតមានឡើង។

១១ ៥. តើខ្ញុំបានទូលថ្វាយព្រះជាម្ចាស់អំពីបញ្ហានេះហើយឬនៅ?

២ ប្រសិនបើ អ្នកបានឆ្លើយថា *ទេ* ទៅចំពោះសំណួរណាមួយ ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យធ្វើតាមជំហានដែលចាំបាច់ដើម្បីធ្វើការកែតម្រូវស្ថានភាពនោះ។

១២ ៦. តើមានគោលការណ៍តាមបទគម្ពីរ សម្រាប់យកមកអនុវត្តនៅក្នុងបញ្ហានេះបានដែរឬទេ? តើគោលការណ៍ទាំងនោះមានអ្វីខ្លះ?
៧. តើខ្ញុំត្រូវការជំនួយពីមិត្តភក្តិ ឬ អ្នកប្រឹក្សាយោបល់ដែលជាគ្រិស្តបរិស័ទ ដើម្បីស្វែងរកដំណោះស្រាយនេះដែរឬទេ?
៨. តើដំណោះស្រាយអ្វីខ្លះ ដែលស្របទៅតាមសេចក្តីបង្រៀននៅក្នុងបទគម្ពីរ?

៣ ក) ២) ការចោទប្រកាន់

ខ) ៤) ការសងសឹក; ១) កំហឹង

គ) ៣) ទាស់ចិត្ត

ឃ) ១) កំហឹង

១៣ ៩. តាមការវិនិច្ឆ័យដែលល្អបំផុតរបស់ខ្ញុំ ក្រោយពេលធ្វើតាមជំហានដើម្បីស្វែងរកដំណោះស្រាយនេះហើយ តើដំណោះស្រាយមួយណា នឹងជាដំណោះស្រាយល្អបំផុតសម្រាប់ខ្ញុំ ក្នុងនាមជាគ្រិស្តបរិស័ទ?

៤ ខ) ភាពអាត្មានិយម

គ) ស្រណោះខ្លួន

ច) ភាពល្ងីងជូរចត់

ឆ) កំហឹង

១៤

១០. តើខ្ញុំពេញចិត្តជាមួយនឹងដំណោះស្រាយនោះហើយឬនៅ ឬ តើខ្ញុំត្រូវការធ្វើការកែតម្រូវអ្វីផ្សេងទៀតដែរឬទេ?

ចំណាំ៖ ប្រសិនបើ ត្រូវការការកែតម្រូវបន្ថែម ចូរអ្នកត្រឡប់ទៅជំហានទី១ ម្តងទៀត ហើយធ្វើការដោះស្រាយបញ្ហានោះម្តងទៀត។

៥ ប្រសិនបើ ចម្លើយរបស់អ្នកគឺ បាទ/ចាស ចំពោះសំណួរណាមួយ អ្នកត្រូវគិតគូរ និង អធិស្ឋានបន្ថែមទៀតដើម្បីស្វែងរកវិធីជ្ឈមានក្នុងការដោះស្រាយបញ្ហារបស់អ្នក។ ចូរទូលសូមព្រះអម្ចាស់ឲ្យជួយអ្នកស្គាល់ ការឆ្លើយតបដែលខុសឆ្គងទៅចំពោះបញ្ហានៅក្នុងថ្ងៃអនាគត និង អាចជៀសពីវាបាន។

១៥ អ្នកអាចយកវិធីសាស្ត្រ ខ ទៅប្រើប្រាស់នៅក្នុងបញ្ហា ខ), គ), ឃ) និង ង)បាន។ អ្នកអាចយក វិធីសាស្ត្រ ក ទៅប្រើប្រាស់នៅក្នុងបញ្ហា ក) និង ច)បាន។

៦ ខ) ព្រះអម្ចាស់

១៦

សំណួរ	ចម្លើយ
១. តើបញ្ហារបស់លោកដានីយ៉ែលមានអ្វីខ្លះ?	គាត់ត្រូវបានគេបង្ខំឲ្យបរិភោគអាហារដែលអាចនឹងធ្វើឲ្យគាត់មិនបរិសុទ្ធ ដោយយោងទៅតាមការណែនាំរបស់ព្រះជាម្ចាស់សម្រាប់ជនជាតិហេប្រឺ (គម្ពីរដានីយ៉ែល ១:៥,៨)
២. តើប្រភពនៃបញ្ហាជាអ្វី?	ស្តេច
៣. តើមានប្រភពដែលជ្រៅជាងនេះដែរឬទេ?	អត់ទេ
៤. តើអាចមានដំណោះស្រាយដ៏ប្រាកដមួយ ដែរឬទេ?	អាចមាន
៥. តើលោកដានីយ៉ែលបានទូលថ្វាយរឿងនេះទៅកាន់ព្រះជាម្ចាស់ដែរឬទេ?	បានទូល។ ការនេះត្រូវបានបង្ហាញឲ្យឃើញនៅក្នុងខទី៨ ទី៩ និង ទី១៧ ។ ព្រះជាម្ចាស់បាន ប្រោសប្រទានអោយលោកអាសផ្នាសជានាយកក្រុមមហាតលិក មានចិត្តអាណិតអាសូរដល់យុវជនដានីយ៉ែល និង មិត្តភក្តិរបស់គាត់។
៦. តើមានគោលការណ៍តាមបទគម្ពីរដែលអាចយកមកប្រើប្រាស់នៅក្នុងបញ្ហានេះបានដែរឬទេ?	ពិតជាមាន។ លោកដានីយ៉ែលបានដឹងថា ព្រះជាម្ចាស់បានប្រកាសថាអាហារខ្លះ គឺមិនបរិសុទ្ធនោះទេ។ (ឧទាហរណ៍ សូមមើលនៅក្នុងគម្ពីរលេវីវិន័យ ១០:៩ និង ជំពូកទី ១១)
៧. តើលោកដានីយ៉ែលត្រូវការជំនួយក្នុងការស្វែងរកដំណោះស្រាយដែរឬទេ?	មិនចាំបាច់ទេ។ លោកបានដឹងច្បាស់ថា អាហារនោះនឹងធ្វើប្រមាថលោក (ធ្វើឲ្យលោកមិនបរិសុទ្ធនៅចំពោះព្រះជាម្ចាស់) (ខទី៨)
៨. តើដំណោះស្រាយអ្វីដែលស្របទៅតាមសេចក្តីបង្រៀននៅក្នុងបទគម្ពីរ?	មិនត្រូវបរិភោគអាហារនោះឡើយ។
៩. តើដំណោះស្រាយអ្វីដែលលោកដានីយ៉ែលបានជ្រើសរើសថាសម្រាប់លោកក្នុងនាមជាមនុស្សដែលព្រះជាម្ចាស់បានជ្រើសរើសនោះ?	លោកជ្រើសយកការមិនបរិភោគអាហារនោះទេ។ លោកបានជ្រើសរើស ការសាកល្បងរយៈពេល១០ថ្ងៃដោយបរិភោគតែបន្លែ និងទឹកតែប៉ុណ្ណោះ (ខទី ១១ ដល់ ទី១៣) ។ លោកបានសុំឲ្យអាសផ្នាសជានាយកមហាតលិក និង អ្នកយាមជួយលោក ហើយលោកមិនបរិភោគអាហាររបស់ស្តេចនោះឡើយ។ ការសាកល្បងរយៈពេលដប់ថ្ងៃនោះ ទទួលបានជោគជ័យ ហើយប្រជាជនហេប្រឺក៏បន្តបរិភោគតែបន្លែ និង ទឹក ប៉ុណ្ណោះ (ខទី ៨, ១១ - ១៦)

១០. តើចាំបាច់ត្រូវមានការកែតម្រូវបន្ថែមទៀតដែរឬទេ?	មិនចាំបាច់ទេ។ ព្រះជាម្ចាស់សរសើរចំពោះការសម្រេចចិត្តរបស់លោកដានីយ៉ែល ដោយប្រទានពរដល់លោក (ខ១៧, ២០)

៧ ខ) ការយល់ដឹងរបស់អ្នកផ្ទាល់ (អ្វីដែលអ្នកគិតថាអ្នកដឹង)

១៧ វិធីសាស្ត្រ ខ គឺជាវិធីសាស្ត្រមួយដែលលោកដានីយ៉ែលបានប្រើប្រាស់នៅក្នុងរឿងរ៉ាវមួយនេះ លោកបានដោះស្រាយបញ្ហារបស់លោក ថ្វាយវាទៅកាន់ព្រះជាម្ចាស់ និង រំពឹងថាទ្រង់នឹងធ្វើការសម្រាប់ផលល្អរបស់លោក។ លោកមិនអាចនឹងស្តាប់បង្គាប់ស្តេច ដោយមិនល្មើសចំពោះព្រះជាម្ចាស់នោះឡើយ។ លោកបានជ្រើសរើសគុណតម្លៃដ៏អស់កល្បជានិច្ច ហើយព្រះជាម្ចាស់សរសើរការសម្រេចចិត្តរបស់លោក។

៨ ក) បង្ហាញអ្នកពីផ្លូវត្រឹមត្រូវដែលត្រូវដើរ។

១៨ គោលការណ៍នៃការទុកចិត្តលើព្រះជាម្ចាស់សម្រាប់ផលល្អរបស់លោក នៅក្នុងគ្រប់ស្ថានភាពទាំងអស់។

៩ ព្រោះ ការយល់ដឹងរបស់អ្នក មានដែនកំណត់ ហើយអ្នកមិនអាចដឹងពីដំណោះស្រាយល្អបំផុតនោះទេ ក៏ដោយសារតែ មានបញ្ហាខ្លះអាចដោះស្រាយបានដោយគ្រាន់តែទុកចិត្តលើព្រះជាម្ចាស់ ដែលព្រះអាចធ្វើរឿងដែលមិនអាចទៅរួចបាន។

១៩ ខ) គុណតម្លៃដ៏អស់កល្បជានិច្ច។

ការប្រឡងជំពូកទីមួយ

ពេលនេះ ដោយអ្នកបានបញ្ចប់ជំពូកទី១ ជាស្តាពរ អ្នកអាចឆ្លើយសំណួរការប្រឡងជំពូកទីមួយបានហើយ។ សូមរំឭកមេរៀនកន្លងមកឡើងវិញ មុនពេលដែលអ្នកចាប់ផ្តើម។ សូមធ្វើតាមការណែនាំដោយយកចិត្តទុកដាក់ ដើម្បីសម្រេចការប្រឡងនេះ ហើយសូមបន្តទៅជំពូកទីពីរទៀត។



ជំពូកទី ពីរ
បញ្ហាក្នុងការចំណាក់ចំនង

<u>មេរៀន</u>

៤ បញ្ហានៅក្នុងទំនាក់ទំនងសង្គម

៥ បញ្ហាគ្រួសារ

៦ បញ្ហានៃជីវិតនៅលីវ

មេរៀនទី ៤ បញ្ហានៅក្នុងការទំនាក់ទំនងសង្គម

ពេលខ្លះ យើងបានឮអំពីរឿងដែលអគ្គរដ្ឋទូតបរទេសដែលត្រូវបង្គាប់ឲ្យត្រឡប់ទៅប្រទេសគេវិញ ដោយមានទំនាស់រវាងប្រទេសរបស់គាត់ ជាមួយនឹងប្រទេសដែលគាត់បម្រើការជាតំណាងសម្រាប់ប្រទេសរបស់គាត់។ មានពេលខ្លះ ដែលអគ្គរដ្ឋទូតត្រូវបានគេសម្លាប់ដោយសារតែជម្លោះបែបនេះ។ សំណាងល្អ រឿងទាំងនេះ គ្រាន់តែជាលក្ខខណ្ឌពិសេស មិនមែនជាច្បាប់នោះទេ។ ភាគច្រើន អគ្គរដ្ឋទូតរវាងប្រទេសសន្តិភាពពីរ គឺត្រូវបានគេគោរព និង លើកតម្កើងទុកជា អ្នកមានសិទ្ធិអំណាចតំណាងឲ្យប្រទេសរបស់ពួកគេ ហើយអាកប្បកិរិយារបស់ពួកគេ បាននាំឲ្យមានការលើកតម្កើង និង ការគោរពសម្រាប់ប្រទេសរបស់ពួកគេ។

តើអ្នកដឹងទេថា អ្នកគឺជាអគ្គរាជទូតយ៉ាងដូច្នោះដែរ? អ្នកគឺជាប្រជាជននៅក្នុងអាណាចក្រនៃស្ថានបរមសុខ ដូច្នេះហើយ អ្នកជាតំណាងរបស់មហាក្សត្រនៃអាណាចក្រនោះ គឺព្រះអម្ចាស់ព្រះយេស៊ូគ្រិស្ត នៅលើផែនដីនេះ។ តាំងពីដើមដំបូងបង្អស់នៃប្រវត្តិសាស្ត្ររបស់មនុស្សជាតិ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺនាំមនុស្សជាតិឲ្យមានទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយទ្រង់ម្តងទៀត។ ប៉ុន្តែ សេចក្តីពិតដ៏អស្ចារ្យនោះគឺ ឥឡូវនេះ "ព្រះអង្គក៏ដាក់ព្រះបន្ទូលនៃការសំរុះសំរួល ឲ្យត្រូវគ្នាវិញនេះមកក្នុងយើងដែរ។ ដូច្នេះ យើងជារាជទូតរបស់ព្រះគ្រិស្ត គឺដូចជាព្រះជាម្ចាស់មានព្រះបន្ទូលដាស់តឿនបងប្អូន តាមរយៈយើងដែរ។" (គម្ពីរ២កូរិនថូស ៥:១៩-២០)។

វាប្រហែលជាងាយស្រួលសម្រាប់យើងជាង ក្នុងការប្រឈមមុខជាមួយនឹងបញ្ហានៅក្នុងការទំនាក់ទំនងសង្គម នៅកន្លែងធ្វើការ នៅសាលា នៅក្នុងក្រុមជំនុំ នៅសហគមន៍របស់យើង ប្រសិនបើយើងអាចផ្តោតសំខាន់ថា យើងជានរណា ហើយយើងជាកម្មសិទ្ធិរបស់អ្នកណានោះ! នៅក្នុងមេរៀននេះ យើងនឹងមើលទៅលើបញ្ហាធំៗខ្លះ នៅក្នុងពន្លឺនៃទំនាក់ទំនងរបស់យើងជាមួយនឹងព្រះគ្រិស្ត ហើយតាមរយៈទ្រង់ផងដែរ យើងមើលពីទំនាក់ទំនងរបស់យើងជាមួយអ្នកដែលមិនស្គាល់ទ្រង់ និង អ្នកដែលទទួលការជំរុញចិត្តពីបំណងប្រាថ្នាដ៏អាត្មានិយម។ តើគ្រិស្តបរិស័ទត្រូវប្រឈមមុខជាមួយនឹងបញ្ហាទាំងនេះ ដែលជាផ្នែកមួយនៃបទពិសោធន៍ប្រចាំថ្ងៃរបស់យើងបាន ដោយរបៀបណា? ព្រះគម្ពីរបានផ្តល់ការណែនាំល្អៗសម្រាប់របៀបដោយយើងគួរតែ *ធ្វើ* និង *ឆ្លើយតប* ។សូមអនុញ្ញាតឲ្យព្រះគម្ពីរបានឆ្លើយតបចំពោះតម្រូវការរបស់អ្នក ស្របពេលដែលអ្នកសិក្សាមេរៀនមួយនេះ។

គម្រោងមេរៀន

ក. ភាពលោភលន់
ខ. បំណងចង់បានហាន:
គ. ភាពក្មេងខ្ចីរបស់គ្រិស្តបរិស័ទ
ឃ. ភាពមានបាន និង ភាពក្រីក្រ
ង. ភាពអយុត្តិធម៌

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះអ្នកអាចនឹង៖

១. វាយតម្លៃឥរិយាបថរបស់អ្នក ដើម្បីកំណត់ថាអ្នកមានបញ្ហាជាមួយនឹងភាពលោភលន់ ឬទេ។
២. ស្គាល់សេចក្តីបង្រៀនរបស់ព្រះយេស៊ូ ទាក់ទងនឹងរបៀបយកឈ្នះបំណងចង់បានហាន:។
៣. រកឃើញដំណោះស្រាយសម្រាប់ភាពក្មេងខ្ចីរបស់គ្រិស្តបរិស័ទ នៅក្នុងគម្ពីរអេភេសូជំពូក ៤ និង ជំពូក៥ ហើយសរសេរដំណោះស្រាយទាំងនោះនៅក្នុងតារាងមួយ។
៤. ជ្រើសរើសប្រយោគដែលបកស្រាយបានយ៉ាងត្រឹមត្រូវ អំពីប្រភពដែលអាចឲ្យយើងមានភាពពេញវ័យនៅក្នុងព្រះគ្រិស្ត។
៥. ស្គាល់ដំណោះស្រាយនៅក្នុងព្រះគម្ពីរសម្រាប់បញ្ហាដែលទាក់ទងនឹង ភាពមានបាន និង ភាពក្រីក្រ។
៦. ស្វែងរក និង កែកំហុសនៅក្នុងពាក្យមួយឃ្លាដែលនិយាយទាក់ទងនឹងគុណតម្លៃរបស់គ្រិស្តបរិស័ទជាមួយនឹងបញ្ហាលុយ។
៧. ថ្លែងពីគោលការណ៍ដែលគួរតែដឹកនាំ ការឆ្លើយរបស់គ្រិស្តបរិស័ទម្នាក់ ដែលជាជនរងអំពើអយុត្តិធម៌។

សកម្មភាពនៃការសិក្សា

១. សិក្សាមេរៀននេះទៅតាមការណែនាំ ដែលបានផ្តល់ជូននៅក្នុងសកម្មភាពនៃការសិក្សានៅក្នុងមេរៀនទី១។ ចូរឆ្លើយ សំណួរសិក្សានីមួយៗឲ្យអស់មុនពេល អ្នកមើលចម្លើយដែលយើងបានផ្តល់ជូននៅចុងបញ្ចប់នៃមេរៀន។
២. នៅក្នុងមេរៀននេះ មានបទគម្ពីរយោងសំខាន់ៗជាច្រើន។ ចូរអានបទគម្ពីរនីមួយៗដោយយកចិត្តទុកដាក់នៅក្នុងព្រះគម្ពីររបស់អ្នក។
៣. ចូរសិក្សាពាក្យសំខាន់ និង និយមន័យរបស់វាផងដែរ។
៤. ធ្វើការប្រឡងផ្ទាល់ខ្លួន ហើយពិនិត្យមើលចម្លើយរបស់អ្នក។

ពាក្យសំខាន់

ភាពបោកប្រាស់	អយុត្តិធម៌	ឋានៈ
ចិត្តសប្បុរស	អាសអាភាស	អ្នកបម្រើ
សេចក្តីលោភលន់	ភាពក្រីក្រ	ឧត្តមភាព
ក្មេងខ្ចី	ការប្រមាថ	ថោកទាប
ភាពតូចទាប	ការបណ្តោយខ្លួន	

ក. ភាពលោភលន់

វគ្គបំណងទី១. *វាយតម្លៃវិធីរបស់អ្នក ដើម្បីកំណត់ថាអ្នកមានបញ្ហាជាមួយនឹងភាពលោភលន់ ឬទេ។*

យើងរស់នៅក្នុងពិភពលោកដែលរួបរួមគ្នា។ ខ្ញុំមានន័យថា ពិភពលោករបស់យើងគឺបង្កើតឡើងពីសហគមន៍ដែលមានមនុស្សរស់នៅ ធ្វើការងារ លេងកំសាន្ត និង ទាក់ទងគ្នាទៅវិញទៅមកតាមរបៀបផ្សេងៗជាច្រើន។ បុគ្គលគ្រប់រូបនៅក្នុងពិភពលោកនេះ ទទួលបានសិទ្ធិក្នុងការសម្រេចចិត្តដោយខ្លួនគេ។ មនុស្សគ្រប់រូប បានទទួលស្មងនិស្ស័យមួយដែលហាក់បីដូចជា មានទំនោរឆ្ពោះទៅរក ភាពអាត្មានិយម មហិច្ឆតា ការផ្គាប់បំណងផ្ទាល់ខ្លួន និង បំណងចង់ឲ្យមនុស្សគ្រប់រូបកោតសរសើរ។ ដូច្នេះ មិនចាំបាច់ឆ្ងល់ទេថា ហេតុអ្វីបានជាយើងបង្កបញ្ហាឲ្យគ្នាទៅវិញទៅមកច្រើនម្ល៉េះ ដោយសារតែអាកប្បកិរិយាខុសឆ្គងនោះ។

បញ្ហាដ៏ធំមួយនៅក្នុងទំនាក់ទំនងរបស់យើងជាមួយនឹងអ្នកដទៃ គឺ ភាពលោភលន់ ឬ សេចក្តីលោភ ដែលជាការចង់បានអ្វីជារបស់អ្នកដទៃ។ យើងចង់បានអំណាច ទ្រព្យ តំណែង មិត្តភក្តិ ភាពទាក់ទាញ និង ទេពកោសល្យរបស់នរណាម្នាក់ យើងចង់បានអ្វីៗដែលល្អបំផុតសម្រាប់ខ្លួនឯង ទោះបីជាមានការខាតបង់របស់អ្នកដទៃក៏ដោយ។ ក្រឹត្យវិន័យចុងក្រោយ ក្នុងក្រឹត្យវិន័យទាំងដប់ប្រការ គឺជាការព្រមានយ៉ាងធ្ងន់ៗ ទាស់នឹងការនេះ៖

> កុំលោភលន់ចង់បានផ្ទះរបស់អ្នកដទៃ កុំលោភលន់ចង់បានប្រពន្ធគេ ឬក៏លោភលន់ចង់បានអ្នកបំរើប្រុស អ្នកបំរើស្រី គោ លា ឬអ្វីផ្សេងទៀតដែលជារបស់គេឡើយ។
>
> (គម្ពីរនិក្ខមនំ ២០:១៧)

តើអ្នកតែងតែប្រៀបធៀបខ្លួនឯង ទៅនឹងអ្នកដទៃ និង ភាពជោគជ័យរបស់គេមែនឬទេ? ការនេះអាចជួយអ្នកនៅក្នុងប្រការមួយចំនួន ប៉ុន្តែវាអាចនឹងគ្រោះថ្នាក់ប្រសិនបើវា ធ្វើឲ្យអ្នកជ្រួលច្របល់ និង មិនពេញចិត្ត គ្រប់ពេល។ តើអ្នកគួរតែព្យាយាមបន្តធ្វើតាមមនុស្សគ្រប់គ្នាដែលអ្នកកោតសរសើរដែរឬទេ? មិនចាំបាច់នោះទេ ។ ប្រាកដណាស់ អ្នកអាចរៀនពីអ្នកដទៃបាន។ មនុស្សយើងសុទ្ធតែធ្វើដូច្នេះទាំងអស់គ្នា។ ប៉ុន្តែ ក្នុងពេលជាមួយគ្នានោះដែរ អ្នកគួរតែដឹងពីដែនកំណត់របស់អ្នក និង ទទួលស្គាល់ថាខ្លួនឯងជានរណា។ អ្នកក៏ត្រូវដឹងពីកម្លាំងរបស់ខ្លួន ហើយអភិវឌ្ឍវាឲ្យបានពេញលេញ ប៉ុន្តែកុំស្វែងរកធ្វើកិច្ចការណាដែលមិនអាចធ្វើបាន!

ខ្ញុំអាចរីករាយជាមួយនឹង អ្នកលេងវីយូឡុងក្នុងការប្រគុំតន្ត្រីមួយ ដោយមិនចាំបាច់ត្រូវធ្វើជាតន្ត្រីករ ឬ តូចចិត្តជាមួយនឹងតន្ត្រីករនោះទេ។ ខ្ញុំអាចកោតសរសើរ ផ្ទះ ឡាន ឬ កង់របស់អ្នកជិតខាងខ្ញុំ ហើយខ្ញុំអាចត្រេកអរជាមួយគាត់ដោយមិនចាំបាច់ត្រូវធ្វើដូចគាត់នោះទេ។ ព្រះគម្ពីរបានបង្រៀនថា យើងគួរតែ "ចូរអរសប្បាយជាមួយអស់អ្នកដែលអរសប្បាយ ចូរយំសោកជាមួយអស់អ្នកដែលយំសោក" (គម្ពីររ៉ូម១២:១៥) ។ ការអាណិតនរណាម្នាក់គឺមិនពិបាកទេ ប៉ុន្តែពេលខ្លះ ការអរសប្បាយជាមួយនរណាម្នាក់ គឺពិបាកណាស់ ជាពិសេសប្រសិនបើអ្នកមានអារម្មណ៍ច្រណែន។

ភាពលោភលន់ អាចនាំឲ្យមានអំពើបាបដែលបង្កឲ្យមានបញ្ហាផ្សេងទៀតដូចជា៖ ការកុហស ឬ ការលួចដើម្បីបានអ្វីដែលអ្នកចង់បាន ការខឹង ការប៉ះពាល់ដល់ទីបន្ទាល់ជាគ្រិស្តបរិស័ទរបស់អ្នក ការច្រណែន ការថ្នាំងថ្នាក់ក្នុងចិត្ត ការស្អប់ ការសងសឹក ការបោកបន្លំ... ដូច្នេះហើយបានជាព្រះជាម្ចាស់បញ្ជូល ការព្រមានទាក់ទងនឹងភាពលោភលន់ នៅក្នុងក្រឹត្យវិន័យទាំងដប់ប្រការនោះ។

លំហាត់អនុវត្តន៍

---

១ នៅក្នុងមេរៀនទី២ យើងបានពិភាក្សាអំពីដំណោះស្រាយមួយដែលយើងអាចធ្វើបាន សម្រាប់បញ្ហាទាក់ទងនឹងភាពលោភលន់។ ចូរប្រាប់ថា ដំណោះស្រាយជាអ្វី និង ចូរប្រាប់ពីបទគម្ពីរយោងដែលគាំទ្រដំណោះស្រាយនោះផងដែរ។

.....

២ ចូរអ្នកសាកល្បងខ្លួនឯង។ ប្រសិនបើចម្លើយរបស់អ្នកគឺ បាទ/ចាស នៅក្នុងសំណួរណាមួយ អ្នកត្រូវតែយកជំហាននៃការដោះស្រាយបញ្ហាមកអនុវត្តនៅក្នុងបញ្ហាភាពលោភលន់របស់អ្នក ហើយទូលសូមឲ្យព្រះជាម្ចាស់ ឲ្យជួយអ្នកបង្វែរបញ្ហានោះឲ្យទៅជា ឥរិយាបថនៃក្តីស្រឡាញ់វិញ។ អ្នកត្រូវជំនួសអក្សរ X ដោយឈ្មោះមនុស្ស ប្រសិនបើស្ថានភាពនោះត្រូវនឹងស្ថានភាពរបស់អ្នក។

	បាទ/ចាស	**ទេ**
ក) ខ្ញុំមានមិត្តភក្តិម្នាក់ដែលហាក់បីដូចជា ជោគជ័យគ្រប់អ្វីៗទាំងអស់ដែលគេធ្វើ ហើយខ្ញុំមានអារម្មណ៍ថាតូចទាបណាស់នៅចំពោះគាត់។		
ខ) ខ្ញុំមិនពេញចិត្តនឹងទេពកោសល្យដែលខ្ញុំមាននោះទេ ហើយខ្ញុំតែងតែប្រាថ្នា ចង់មានទេពកោសល្យដូច "X" ដែរ។		
គ) ខ្ញុំនឿយហត់នឹងភាពក្រីក្រណាស់។ ខ្ញុំប្រាថ្នាថា ខ្ញុំមានរបស់ល្អជាច្រើនដូច "X" ដែរ។		
ឃ) ខ្ញុំមានសិទ្ធិ ច្រណែននឹង "X" ដ្បិតចៅហ្វាយ ឬ ប្រធានរបស់ខ្ញុំ តែងតែធ្វើល្អជាមួយគាត់ ជាងជាមួយខ្ញុំ។		
ង) ខ្ញុំខឹងព្រះជាម្ចាស់ណាស់ ព្រោះខ្ញុំហាក់បីដូចជាទទួលបានការអាក្រក់គ្រប់រឿងទាំងអស់ ខណៈពេលដែលមិត្តរបស់ខ្ញុំ គេតែងតែមានអ្វីៗគ្រប់យ៉ាងដែលគេចង់បាន ឬ ត្រូវការ។		

	បាទ/ចាស	**ទេ**
ច) នៅពេលដែលមិត្តរួមការងាររបស់ខ្ញុំម្នាក់ត្រូវបានគេស្តីបន្ទោស ដោយសារតែបានធ្វើកំហុសមួយ វាធ្វើឲ្យខ្ញុំពេញចិត្តយ៉ាងខ្លាំង។		
ឆ) "X" មានរបស់មួយដែលខ្ញុំចង់បានខ្លាំងណាស់ ដែលខ្ញុំមិនអាចគិតពីអ្វីផ្សេងទៀតបានទេ។		

ខ. បំណងចង់បានឋានៈ

វគ្គបំណងទី២. *ស្គាល់សេចក្តីបង្រៀនរបស់ព្រះយេស៊ូ ទាក់ទងនឹងរបៀបយកឈ្នះបំណងចង់បានឋានៈ។*

មានមនុស្សម្នាក់ធ្លាប់បាននិយាយថា៖ "ពិភពលោកមិនទាន់បានឃើញពីអ្វី ដែលមនុស្សមិនខ្វល់ពីការស្វែងរកគុណសម្បត្តិសម្រាប់ខ្លួន អាចធ្វើសម្រាប់ព្រះរាជ្យរបស់ព្រះជាម្ចាស់នៅឡើយនោះទេ។"

និស្ស័យជាមនុស្សរបស់យើង គឺចង់ឲ្យអ្នកដទៃកត់សំគាល់ ចង់ទទួលបានការលើកតម្កើង តំណែង ការកោតសរសើរ ឋានៈ ការទទួលស្គាល់ និង អំណាច។ តើអ្នកធ្លាប់មានអារម្មណ៍ឈឺចាប់ ដោយសារតែអ្នកមិនទទួលបាន ការទទួលស្គាល់ដ៏សមរម្យចំពោះអ្វីដែលអ្នកបានធ្វើ ដែរឬទេ? ខ្ញុំធ្លាប់មានអារម្មណ៍បែបនេះ។ ប្រហែលមនុស្សគ្រប់គ្នា សុទ្ធតែធ្លាប់មានអារម្មណ៍បែបនេះ នៅពេលណាមួយ។ បញ្ហា កើតចំពោះមនុស្សដែលតែងតែស្រេកឃ្លានចង់ខ្ពស់ជាងគេ ចំពោះអ្នកដែលចង់គ្រប់គ្រង និងចង់ទទួលបានគុណសម្បត្តិសម្រាប់អ្វីដែលគេធ្វើបានសម្រេច។ បញ្ហាក៏កើតឡើងចំពោះមនុស្សដែលមានអារម្មណ៍ច្រណែន នៅពេលដែលអ្នកដទៃទទួលបានការកោតសរសើរ និង ទទួលស្គាល់ ឬ ចំពោះមនុស្សដែលថ្នាំងថ្នាក់ចិត្តនៅពេលដែលការធ្វើទានរបស់គេ មិនត្រូវបានគេមើលឃើញ។

ប៉ុន្តែព្រះយេស៊ូ មានឱសថសម្រាប់ព្យាបាលការឈឺចាប់ប្រភេទនេះ ព្រមទាំងរឿងគ្រោះថ្នាក់ផ្សេងទៀតដែលទាក់ទងនឹង ការស្វែងរកឋានៈផងដែរ។ ឱសថសម្រាប់ព្យាបាលនោះគឺមាននៅក្នុងយើង។ វាគឺជាឥរិយាបថដែលយើងបម្រើព្រះជាម្ចាស់។

ព្រះយេស៊ូបានជ្រាបពីអ្វីដែលនៅក្នុងមនុស្សម្នាក់ (គម្ពីរយ៉ូហាន ២:២៤-២៥) ។ ទ្រង់បានជ្រាបអំពីទំនោររបស់យើង ដែលមានអារម្មណ៍ច្រណែន និង មានបំណងចង់បានអំណាច។ នៅគ្រាដែលទ្រង់គង់នៅជាមួយពួកសាវ័ករបស់ទ្រង់នៅឡើយ ពួកគេបានប្រកែកគ្នាអំពីនរណាដែលនៅក្នុងចំណោមពួកគេដែលល្អជាងគេបង្អស់ (គម្ពីរលូកា ២២:២៤) ។ ទ្រង់បានមានបន្ទូលប្រាប់ពួកគេ កុំឲ្យធ្វើដូចជាពួកស្តេចដែលគ្មានសាសនា ដែលស្វែងរកអំណាច ហើយចង់សង្កត់សង្កិនមនុស្សដែលនៅក្រោមអំណាចរបស់ពួកគេ។ ទ្រង់មានព្រះបន្ទូលថា "ក្នុងចំណោមអ្នករាល់គ្នា អ្នកដែលធំជាងគេ ត្រូវធ្វើតូចជាងគេ ហើយអ្នកដែលដឹកនាំគេ ត្រូវបំរើគេវិញ។" (គម្ពីរលូកា ២២:២៥-២៦) ។

ព្រះយេស៊ូបានបង្ហាញពួកគេ ដោយទ្រង់ធ្វើជាគំរូសម្រាប់អ្វីដែលទ្រង់មានព្រះបន្ទូល ដោយការធ្វើជាអ្នកបម្រើម្នាក់។ នៅពេលបរិភោគអាហារចុងក្រោយក្នុងថ្ងៃបុណ្យចម្លង ព្រះយេស៊ូបានលាងជើងឲ្យសាវ័ករបស់ទ្រង់ ដែលវាជាការងាររបស់អ្នកបម្រើនោះទេ។ បន្ទាប់ពីបានធ្វើដូច្នេះហើយ ទ្រង់បានមានព្រះបន្ទូលដូចតទៅ៖

"តើអ្នករាល់គ្នាយល់អំពីកិច្ចការដែលខ្ញុំបានធ្វើ ចំពោះអ្នករាល់គ្នានេះឬទេ? អ្នករាល់គ្នាហៅខ្ញុំថាព្រះគ្រូ និងព្រះអម្ចាស់ នោះត្រូវមែន គឺខ្ញុំហ្នឹងហើយ!។ បើខ្ញុំជាព្រះអម្ចាស់ និងជាព្រះគ្រូបាន លាងជើងអោយអ្នករាល់គ្នាទៅហើយ អ្នករាល់គ្នាក៏ត្រូវតែលាងជើងអោយគ្នាទៅវិញទៅមកដែរ។ ខ្ញុំបានធ្វើជាគំរូអោយអ្នករាល់គ្នាប្រព្រឹត្ត ដូចខ្ញុំបានប្រព្រឹត្តដល់អ្នករាល់គ្នា។ ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា អ្នកបំរើមិនដែលធំជាងម្ចាស់ឡើយ រីឯអ្នកដែលគេចាត់អោយទៅ ក៏មិនដែលធំជាងអ្នកចាត់ខ្លួនអោយទៅនោះដែរ។ ប្រសិនបើអ្នករាល់គ្នាដឹងសេចក្តីនេះហើយប្រតិបត្តិតាម អ្នករាល់គ្នាមុខជាមានសុភមង្គលមិនខាន។" (គម្ពីរយ៉ូហាន ១៣:១២-១៧)

លំហាត់អនុវត្តន៍

---

៣ តើប្រយោគណាខ្លះ នៅខាងក្រោមនេះស្របតាមអ្វីដែលព្រះយេស៊ូព្យាយាមបង្រៀនពួកសាវ័ករបស់ទ្រង់ (ព្រមទាំងពួកយើងផង) អំពីការស្វែងរកឋានៈ? ចូរគូសរង្វង់ជុំវិញអក្សរដែលនៅខាងមុខចម្លើយត្រឹមត្រូវ។

ក) ព្រះយេស៊ូគឺជាព្រះអម្ចាស់ និង ជាម្ចាស់។

ខ) ព្រះយេស៊ូបានលាងជើងសាវ័ករបស់ទ្រង់ ព្រោះទ្រង់ចង់បង្ហាញពួកគេ ថាទ្រង់បន្ទាបខ្លួនយ៉ាងណា?

គ) ព្រះយេស៊ូដែល ជាព្រះលើអស់ទាំងព្រះ បានធ្វើកិច្ចការបម្រើដ៏តូចទាប តាមរយៈការលាង ជើងសាវ័កទ្រង់។

ឃ) ទោះបីជាព្រះជាម្ចាស់អាចនឹងប្រើពួកសាវ័កតាមរបៀបដ៏អស្ចារ្យយ៉ាងណាក៏ដោយពួកគេមិនត្រូវមើលទៅលើខ្លួនឯងថាជាមនុស្សអស្ចារ្យនោះទេ ប៉ុន្តែជាមនុស្សអ្នកបម្រើ និង ជាអ្នកនាំសារបន្ទូលវិញ។

ង) ពួកសាវ័កត្រូវតែ សម្រេចឲ្យបាន ពិធីលាងជើងឲ្យអស់អ្នកដែលមានឋានៈក្រោមគេ ។

ច) ដោយស្គាល់ថា ខ្លួនគេគ្រាន់តែជាអ្នកបម្រើ និង ជាអ្នកនាំសារ ពួកសាវ័កគឺត្រូវធ្វើកិច្ចការរបស់អ្នកបម្រើទៅចំពោះគ្នាទៅវិញទៅមក។

ឆ) ព្រះយេស៊ូ បានសន្យាថា នឹងប្រទានពរឲ្យពួកគេ ប្រសិនបើពួកគេអាចលាងជើងឲ្យគ្នាទៅវិញទៅមក។

ជ) ព្រះយេស៊ូ បានសន្យាថា នឹងប្រទានពរឲ្យពួកគេ ប្រសិនបើពួកគេអាចធ្វើជាអ្នកបម្រើសម្រាប់គ្នាទៅវិញទៅមក។

មានមេរៀនពីរយ៉ាង យើងអាចរៀនបានពីចំណុចនេះ ដែលនឹងជួយយើងឲ្យយកឈ្នះលើបញ្ហានៃការថ្នាំងថ្នាក់ចិត្ត អំណួត និង អារម្មណ៍ខ្ពស់ជាងគេ ឬ អារម្មណ៍តូចទាបជាងគេ។

១. អស់អ្នកដែលមានតំណែងជាអ្នកដឹកនាំ គឺត្រូវដូចជាអ្នកបម្រើដែរ។ តំណែងរបស់ពួកគេគួរតែជាមធ្យោបាយក្នុងការសរសើរតម្កើងព្រះគ្រិស្ត មិនមែនខ្លួនគេទេ។

២. អស់អ្នកដែលមានតំណែងតូចតាច ត្រូវតែបំពេញការងាររបស់ពួកគេ " ដូចធ្វើចំពោះព្រះអម្ចាស់" ដោយចាំថា ព្រះជាម្ចាស់គ្រប់គ្រងលើជីវិតរបស់ពួកគេ ហើយទ្រង់នឹងប្រទានពរឲ្យពួកគេ ប្រសិនបើពួកគេនៅវក្បាតរិយាបថជាអ្នកបម្រើ ទោះបីជាកាលៈទេសៈនោះហាក់ដូចជាលំបាកយ៉ាងក៏ដោយ។ មិនថាអ្នកមានតំណែងអ្វីនោះទេ អ្នកត្រូវតែបំពេញការងារនោះឲ្យអស់ពីសមត្ថភាពរបស់អ្នក។

ជីវិតនៃការបម្រើ ដោយមិនខ្វល់ខ្វាយពីហានៈ ជាគន្លឹះដែលនាំទៅរកការសប្បាយក្នុងចិត្ត និង ការផ្គាប់ព្រះទ័យព្រះអម្ចាស់។ បំណងចង់ក្លាយជាមនុស្សអស្ចារ្យជាងគេ គឺជា កម្លាំងបំផ្លិចបំផ្លាញមួយ។ វាបំផ្លាញសន្តិភាព ។ វាបំផ្លាញទំនាក់ទំនង។ វាបំផ្លាញការរួបរួមប្រកបជាមួយព្រះជាម្ចាស់។ សេរីភាពដ៏ពិតដើម្បីបង្ហាញពីព្រះគ្រិស្តឲ្យបានពេញលេញ បានមកនៅពេលដែលយើងសុខចិត្តលះបង់មហិច្ឆតាចង់បានហានៈរបស់យើង នៅក្នុងលោកីយ៍នេះ។ រង្វាន់ពិតប្រាកដរបស់យើង មិនមែននៅក្នុងជីវិតមួយនេះទេ៖ "ព្រះអង្គប្រទានជីវិតអស់កល្បជានិច្ច ដល់អស់អ្នកដែលព្យាយាមប្រព្រឹត្តអំពើល្អ ហើយស្វែងរកសិរីរុងរឿងកិត្តិយស និងអ្វីៗដែលមិនចេះសាបសូន្យ" (គម្ពីរ រ៉ូម ២:៧) ។ ទ្រង់នឹងប្រទានសិរីរុងរឿង និងកិត្តិយស ដល់អ្នកណាដែលមានមហិច្ឆតាក្នុងការធ្វើល្អ។

លំហាត់អនុវត្តន៍

---

៤ ចូរអានគម្ពីរលូកា ១៧:៥-១០។ តើប្រយោគមួយណានៅខាងក្រោមនេះ ដែលបង្ហាញបានយ៉ាងច្បាស់អំពីអ្វីដែលព្រះយេស៊ូបង្រៀននៅក្នុងរឿងមួយនេះ?

ក) វាគឺជារឿងធម្មតា ដែលយើងចង់បានការកោតសរសើរ សម្រាប់អ្វីដែលយើងបានធ្វើ ហើយយើងស័ក្តិសមទទួលបាន ការទទួលស្គាល់នៅពេលដែលយើងធ្វើការចែកទាន ។ នោះជាមូលហេតុដែលយើងចង់ជោគជ័យ។

ខ) នៅពេលដែលយើងធ្វើអ្វីដែលព្រះអម្ចាស់បញ្ជាឲ្យយើងធ្វើ យើងមិនគួរមើលឃើញតែការកោតសរសើរ និង ការតម្កើងខ្លួនឯងនោះទេ ប៉ុន្តែត្រូវប្រកាន់យកឥរិយាបថ "យើងខ្ញុំគ្រាន់តែជាអ្នកបំរើធម្មតាប៉ុណ្ណោះ គឺយើងខ្ញុំបានបំពេញកិច្ចការដែលយើងខ្ញុំត្រូវធ្វើ" វិញ។

គ) យើងមិនគួរទទួលស្គាល់ ឬលើកតម្កើងអស់អ្នកដែលធ្វើការចែកទាននោះទេ ព្រោះវានឹងធ្វើឲ្យពួកគេមានអារម្មណ៍ថាសំខាន់ និង ខ្ពង់ខ្ពស់ជាងគេ។

ប្រាកដណាស់ថា វាជារឿងធម្មតាដែលយើងចង់ទទួលបានការដឹងគុណនៅពេលដែលយើងធ្វើការងារបានល្អ ប៉ុន្តែបំណងចង់បានការកោតសរសើរ និង ការទទួលស្គាល់ មិនគួរជាការជំរុញចិត្តរបស់យើងក្នុងការធ្វើល្អនោះទេ។ ម្យ៉ាងវិញទៀត អស់អ្នកដែលមានតំណែងជាអ្នកដឹកនាំ អាចកាត់បន្ថយ សក្តា

នុពលដែលបង្កឲ្យមានបញ្ហានេះបាន តាមរយៈការកោតសរសើរទៅតាមការសមគួរ។ ពាក្យលើកទឹកចិត្ត នឹងជំរុញចិត្តមនុស្សឲ្យប្រឹងប្រែងធ្វើការកាន់តែខ្លាំងឡើង និង ប្រកបដោយតរិយាបថល្អ។

មិនមែនមនុស្សគ្រប់គ្នា អាចត្រូវបានត្រាស់ហៅឲ្យដឹកនាំនោះទេ។ ព្រះជាម្ចាស់នឹងមិនវិនិច្ឆ័យអ្នក តាមកម្រិតតំណែងរបស់អ្នកនោះទេ តែទៅតាមកម្រិតដែលអ្នកធ្វើកិច្ចការដែលជាតួនាទី*របស់អ្នក* បានល្អប៉ុនណា។ (សូមអានគម្ពីរម៉ាថាយ ២៥:១៤-៣០)

មានចម្រៀងមួយដែលមនុស្សភាគច្រើនធ្លាប់ស្គាល់ ច្រៀងថា៖ "ថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ សម្រាប់អ្វីដែលទ្រង់បានធ្វើ" ។ តើអ្នកអាចនិយាយបានទេថា "ថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ សម្រាប់អ្វីដែលខ្ញុំបានធ្វើ?"

គ. ភាពក្មេងខ្ចីរបស់គ្រិស្តបរិស័ទ

ឥស្តុតាងបង្ហាញពីភាពក្មេងខ្ចី

វត្ថុបំណងទី ៣. *រកឃើញដំណោះស្រាយសម្រាប់ភាពក្មេងខ្ចីរបស់គ្រិស្តបរិស័ទ នៅក្នុងគម្ពីរអេភេសូជំពូក ៤ និង ជំពូក៥ ហើយសរសេរដំណោះស្រាយទាំងនោះនៅក្នុងតារាងមួយ។*

នៅពេលដែលអ្នកក្លាយជាគ្រិស្តបរិស័ទម្នាក់ អ្នកមិនបានបាត់បង់ភាពជាមនុស្សរបស់អ្នក បំណងប្រាថ្នារបស់អ្នក អារម្មណ៍របស់អ្នក តម្រូវការរបស់អ្នក ឬ សមត្ថភាពក្នុងការឈឺចាប់នោះទេ ។ ទាំងនេះគឺជាអារម្មណ៍ដែលយើងត្រូវ ប្រឈមមុខជាមួយ ជារៀងរាល់ថ្ងៃនៅក្នុងទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃ។ ការយកឈ្នះអារម្មណ៍ទាំងនេះបាន គឺទាមទារពេលវេលា វាជាដំណើរការនៃការពេញវ័យរបស់គ្រិស្តបរិស័ទ។ អ្នកប្រហែលជាបានស្គាល់អ្នកណាម្នាក់ ក៏ប្រហែលជាគ្រិស្តបរិស័ទម្នាក់ ដែលតែងតែចង់បានជួរមុខគេ ដែលចង់បានកៅអីល្អបំផុត ដែលតែងតែមានអារម្មណ៍ត្រូវគេមើលងាយ ដែលនឹងរអ៊ូរទាំ រហូតគេទទួលបានអ្វីដែលល្អបំផុត។ នៅពេលដែលអ្វីៗកើតឡើងស្របទៅតាមការចង់បានរបស់គេ គេសប្បាយចិត្ត។ ពេលដែលមានបញ្ហាកើតឡើង ពួកគេមានការមិនពេញចិត្ត និង មួម៉ៅក្តៅក្រហាយ។

អ្នកក៏ប្រហែលជាធ្លាប់ស្គាល់គ្រិស្តបរិស័ទខ្លះ ដែលចំណាយពេលវេលារបស់គេ ខ្វល់ខ្វាយពីកូនរបស់គេ អំពីភាពខ្វះខាតលុយកាក់ អំពីអ្វីដែលនឹងកើតឡើងនៅពេលដែលពួកគេចាស់ទៅ។ នេះគឺជាសញ្ញាមួយទៀតដែលបង្ហាញពីភាពក្មេងខ្ចីរបស់គ្រិស្តបរិស័ទ។

ខ្ញុំស្គាល់ស្ត្រីមេម៉ាយជាគ្រិស្តបរិស័ទម្នាក់ ដែលនាងរវល់ និង ធ្វើការងារជាច្រើន តែនៅពេលខ្លះនាងក៏ប្រឈមមុខនឹងភាពឯកាដែរ។ តើគ្រិស្តបរិស័ទដែលពេញវ័យមានការតស៊ូប្រយុទ្ធដែរឬទេ? សំណួរនេះក៏អាចយកទៅប្រើជាមួយនឹងអារម្មណ៍ភ័យខ្លាច ព្រួយបារម្ភ ការបាក់ទឹកចិត្ត ការសង្ស័យ ភាពអាត្មានិយម កំហឹង និង អារម្មណ៍របស់មនុស្សជាច្រើនផ្សេងៗទៀត។ សូម្បីតែ គ្រិស្តបរិស័ទពេញវ័យ ក៏នៅតែតយុទ្ធ ជារៀងរាល់ថ្ងៃ ប៉ុន្តែពួកគេបានដឹងពីរបៀបយកឈ្នះបាន!

នៅក្នុងគម្ពីរអេភេសូជំពូក ៥ និង ជំពូក៦ លោកសាវ័កប៉ូលបានប្រឈមមុខនឹងការបង្ហាញឲ្យឃើញពីភាពក្មេងខ្ចី។ អ្នកនឹងសំគាល់ឃើញថា ភាពក្មេងខ្ចីភាគច្រើនគឺមានជាប់ទាក់ទងជាមួយនឹងទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃ។ លោកប៉ូលបាននិយាយទៅកាន់គ្រិស្តបរិស័ទ នៅក្នុងបទគម្ពីរមួយនេះ។

លោកបានព្រមានពួកគេមិនឲ្យបន្តរស់នៅក្នុងជីវិតដូចជាមនុស្សគ្មានសាសនានោះទេ។ បន្ទាប់មក ដើម្បីប្រាកដថាពួកគេអាចយល់អត្ថន័យអ្វីដែលលោកនិយាយបានពេញលេញ លោកបានផ្តល់ឲ្យពួកគេនូវការណែនាំច្បាស់លាស់ អំពីរបៀបទទួលបានភាពពេញវ័យ។

លំហាត់អនុវត្តន៍

---

៥ ចូរអានគម្ពីរ អេភេសូជំពូក ៤ និង ជំពូក៥ ហើយបំពេញតារាងខាងក្រោមដោយ គិតជាមុនសិន ថាតើបញ្ហាដែលបានរៀបរាប់មកនោះ គឺជាបញ្ហាដែលអ្នកកំពុងប្រឈមដែរឬទេ។ បន្ទាប់ ចូរសរ សេរ ដំណោះស្រាយដែលលោកសាវ័កប៉ូលបានផ្តល់ឲ្យសម្រាប់បញ្ហានីមួយៗ នៅក្នុងប្រអប់ ខាងស្តាំ។យើងបាន ផ្តល់ជូនដំណោះស្រាយទាំងនោះនៅខាងក្រោមតារាង។ ចូរស្វែងរកកន្លែង ស័ក្តិសមសម្រាប់ដំណោះស្រាយនីមួយៗ ហើយសរសេរវានៅក្នុងប្រអប់ដែលត្រឹមត្រូវ។

ខគម្ពីរយោង	**ប្រសិនបើខ្ញុំមានបញ្ហានេះ**	**ខ្ញុំនឹងធ្វើដូច្នេះ៖**
គម្ពីរអេភេសូ ក) ៤:២៥	ការនិយាយកុហក	
ខ) ៤:២៦	កំហឹង	
គ) ៤:២៨	ការលួច	
ឃ) ៤:២៩	និយាយពាក្យអាក្រក់	
ង) ៤:៣០	ធ្វើអោយព្រះវិញ្ញាណដ៏វិសុទ្ធ របស់ព្រះជាម្ចាស់ ព្រួយព្រះ ហឫទ័យ	
ច) ៤:៣១-៣២; ៥:១-២	ចិត្តជូរចត់ ចិត្តក្តៅក្រហាយ កំហឹង សំរែកឡូឡា ពាក្យជេរ ប្រមាថ ព្រមទាំងសេចក្តី អាក្រក់គ្រប់បែបយ៉ាង	
ឆ) ៥:៣-៥	សូម្បីតែនិយាយអំពីការប្រាស ចាកសីលធម៌អបាយមុខ ការ លោភលន់ ឬ ពោលពាក្យ ទ្រគោះបោះបោក ពាក្យ ឡេះឡោះ ឬពាក្យ អាសអាភាស	

ខគម្ពីរយោង	ប្រសិនបើខ្ញុំមានបញ្ហានេះ	ខ្ញុំនឹងធ្វើដូច្នេះ៖
ជ) ៥:៦-១១	ត្រូវបានមនុស្សអាក្រក់ នាំឲ្យប្រព្រឹត្តិអំពើបាប ត្រូវបានគេបោកបញ្ឆោត	
ឈ) ៥:១៥-១៦	មិនប្រុងប្រយ័ត្ន និង នៅរស់នៅក្នុងរបៀបមនុស្សឥតប្រាជ្ញា	
ញ) ៥:១៧	ធ្វើជាមនុស្សឥតគំនិត	
ដ) ៥:១៨	ស្រវឹងស្រា	

ដំណោះស្រាយ (លំដាប់លំដោយចម្លើយត្រូវបានច្របល់ចូលគ្នា។ ចូរស្វែងរកចម្លើយដែលស័ក្តិសម នៅក្នុងតារាងនីមួយៗ ហើយសរសេរលេខរៀងនៃចម្លើយនៅក្នុងប្រអប់ដែលត្រឹមត្រូវ។ ដំណោះស្រាយនីមួយៗ ត្រូវបានដកស្រង់ពីគម្ពីរអេភេសូជំពូក ៤ និងជំពូក៥ មក)។

១. កុំធ្វើអោយព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ព្រួយព្រះហឫទ័យ។
២. កុំទាក់ទងជាមួយមនុស្សបែបនោះ។ ត្រូវបកអាក្រាតពួកគេ។
៣. ព្យាយាមស្វែងរកអ្វីដែលព្រះអម្ចាស់សព្វព្រះហឫទ័យឲ្យអ្នកធ្វើ។
៤. បំពេញគំនិតរបស់អ្នកដោយការសរសើរតម្កើង និង អរព្រះគុណ។
៥. មិនត្រូវធ្វើអំពើបាប។ មិនត្រូវប្រកាន់ខឹង។
៦. ត្រូវមានចិត្តសប្បុរស ចេះអាណិតមេត្តាដល់គ្នាទៅវិញទៅមក ត្រូវប្រណីសន្តោសគ្នាទៅវិញទៅមក ឲ្យសេចក្តីស្រឡាញ់ដឹកនាំ។
៧. មិនត្រូវស្រវឹងស្រា ប៉ុន្តែត្រូវពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ។
៨. និយាយតែសេចក្តីពិត
៩. ប្រើពាក្យល្អមានប្រយោជន៍។
១០. រស់នៅជាមនុស្សដែលមានប្រាជ្ញា ។ ប្រើប្រាស់ឱកាសទាំងប៉ុន្មានឲ្យមានប្រយោជន៍។
១១. ឈប់លួច ហើយចាប់ផ្តើមធ្វើការងារ។ ផ្គត់ផ្គង់ខ្លួនអ្នក និង ជួយដល់អ្នកក្រីក្រ។

មធ្យោបាយតែមួយគត់ដែលអ្នកអាចទទួលបាន ភាពពេញវ័យជាគ្រិស្តបរិស័ទ គឺត្រូវបានចាប់ផ្តើមធ្វើអ្វីដែលជួយអ្នកឲ្យពេញវ័យ។ ត្រូវអនុវត្តតាមរយៈដំណោះស្រាយដែលអ្នកដាក់នៅក្នុងជីវិតអ្នក។

ប្រភពដើម្បីទទួលបានភាពពេញវ័យ

វត្ថុបំណងទី៤. *ជ្រើសរើសប្រយោគដែលបកស្រាយបានយ៉ាងត្រឹមត្រូវ អំពីប្រភពដែលអាចឲ្យយើងមានភាពពេញវ័យនៅក្នុងព្រះគ្រិស្ត។*

ការលូតលាស់មិនមែនកើតឡើងដោយចៃដន្យនោះទេ។ ការលូតលាស់ មិនមែនជាផលដែលបានមកពីអ្វីដែលព្រះជាម្ចាស់ធ្វើសម្រាប់អ្នក ស្របពេលដែលអ្នកនៅអង្គុយមិនធ្វើអ្វីសោះនោះទេ។ ប្រភពចាមពលពីរយ៉ាងសម្រាប់ភាពពេញវ័យរបស់គ្រិស្តបរិស័ទ៖ ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ និង *អំណាចនៃឆន្ទៈ* របស់អ្នកផ្ទាល់។

ឫទ្ធានុភាពរបស់ព្រះជាម្ចាស់

ប្រាកដណាស់ ឫទ្ធានុភាពរបស់ព្រះជាម្ចាស់គឺជាគ្រឹះដែលអំណាចឆន្ទៈរបស់អ្នកត្រូវតែពឹងផ្អែកលើ។ ការព្យាយាមធ្វើល្អ ដោយគ្មានការធ្វើឲ្យថ្មីនៅក្នុងព្រះគ្រិស្តជាមុន នោះយើងនឹងមិនអាចទទួលបានឥរិយាបថ ដែលលោកសាវ័កប៉ូលបានលើកឡើងនៅក្នុងគម្ពីរអេភេសូជំពូក៤ និង ជំពូក៥ បានឡើយ។ សូមអានគម្ពីរអេភេសូ ៤:១៥-១៦ ម្តងទៀត។ ចំណាំថា ព្រះគ្រិស្តគឺជាសិរសា ។ ផ្នែកទាំងអស់នៃរូបកាយបានចុះសម្រុង និង ធ្វើជាមួយគ្នា *នៅក្រោមការគ្រប់គ្រងរបស់ទ្រង់។* នៅក្នុងគម្ពីរអេភេសូ ៤:២៣ អ្នកឃើញថា អ្នក "ត្រូវប្រែគំនិតប្រាជ្ញា និងវិញ្ញាណអោយបានថ្មីឡើង" ។ ចុងក្រោយ នៅក្នុងគម្ពីរអេភេសូ ៦:១០ លោកសាវ័កប៉ូលប្រាប់យើងថា "ចូរទាញយកកម្លាំង ដោយរួមជាមួយព្រះអម្ចាស់ និងដោយសារព្រះចេស្តាដ៏ខ្លាំងក្លារបស់ព្រះអង្គ"។

ដូច្នេះ ដំបូងបង្អស់ គឺឫទ្ធានុភាពរបស់ព្រះជាម្ចាស់ហើយ ដែលប្រទានឲ្យយើងមានសមត្ថភាពក្នុងការរស់នៅសម្រាប់ទ្រង់ និង ធ្វើតាមអ្វីដែលយើងត្រូវបានបង្គាប់ឲ្យធ្វើនៅក្នុងគម្ពីរអេភេសូជំពូក៤ និង ជំពូក៥។

លំហាត់អនុវត្តន៍

---

៦ នេះគឺជារបៀបមួយទៀត ដើម្បីនិយាយពីជំហានដែលសំខាន់ជាងគេក្នុងការស្វែងរកដំណោះស្រាយសម្រាប់បញ្ហារបស់អ្នក (សូមមើលមេរៀនទី ២) ។ ព្រះជាម្ចាស់នឹងធ្វើឲ្យយើងបានថ្មីទាំងស្រុងនៅពេលដែលយើង

ក) ទទួលយកការណែនាំពីមិត្តភក្តិគ្រិស្តបរិស័ទ។

ខ) សារភាពបាប ទទួលជឿ និង ការធ្វើតាម ហើយដោះស្រាយបញ្ហាអំពើបាបមុនគេបង្អស់។

គ) ព្យាយាមធ្វើជាអ្នកជិតខាងដ៏ល្អ។

អំណាចឆន្ទៈ

គម្ពីរអេភេសូ ៤:២៧ ចែងថា៖ "កុំហុចឱកាសអោយមារមកល្បួងបងប្អូន។" នេះបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា យើងអាចផ្តល់ឱកាសឲ្យមារល្បួងយើងបាន។ ចំណាំថា នៅក្នុងគម្ពីរអេភេសូជំពូក៤ និង ជំពូក៥ មានការណែនាំជាច្រើនចំពោះអ្វីដែលយើងត្រូវ *ធ្វើ* ។ ព្រះជាម្ចាស់ទ្រង់មានកិច្ចការរបស់ទ្រង់ ហើយទ្រង់នឹងធ្វើកិច្ចការនោះដោយស្មោះត្រង់។ ប៉ុន្តែប្រសិនបើអ្នក និង ខ្ញុំមិនធ្វើកិច្ចការដែលជាចំណែករបស់យើងនោះទេ យើងនឹងមិនអាចលូតលាស់ទៅរកភាពពេញវ័យបានឡើយ ហើយយើងប្រហែលជាអាចបាត់បង់ទំនាក់ទំនងរបស់យើងជាមួយនឹងព្រះជាម្ចាស់ថែមទៀតផង។ យើងដាក់អំណាចនៃឆន្ទៈរបស់យើងឲ្យធ្វើការ ដោយ*ការស្តាប់បង្គាប់* តាមការណែនាំដែលប្រទានមកនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ តាមរយៈការស្តាប់បង្គាប់នេះហើយ ដែលយើងអាចឆ្ពោះទៅដល់ភាពពេញវ័យរបស់គ្រិស្តបរិស័ទ និង ឈ្នះលើបញ្ហានៃភាពក្មេងខ្ចីបាន។

លំហាត់អនុវត្តន៍

---

៧ ចូរគូសរង្វង់ជុំវិញអក្សរដែលនៅពីមុខចម្លើយត្រឹមត្រូវ ដែលបង្ហាញពីប្រភពដើម្បីទទួលបានភាពពេញវ័យរបស់គ្រិស្តបរិស័ទ។

ក) ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ដែលធ្វើឲ្យយើងបានថ្មីទាំងស្រុង មិនផ្អែកលើអាកប្បកិរិយារបស់យើងសូម្បីតែបន្តិច។

ខ) យើងប្រើអំណាចនៃឆន្ទៈរបស់យើងដើម្បីទទួលស្គាល់ព្រះគ្រិស្ត ជឿថាទ្រង់គឺជាព្រះអម្ចាស់ដ៏មានព្រះជន្មរស់របស់យើង និង ស្តាប់បង្គាប់តាមព្រះបញ្ជារបស់ទ្រង់។

គ) ការស្តាប់បង្គាប់ អាចកើតឡើងបាន ព្រោះមានឫទ្ធានុភាពរបស់ព្រះគ្រិស្តដែលនៅក្នុងយើង បន្ទាប់ពីទ្រង់បានធ្វើឲ្យយើងបានថ្មីទាំងស្រុង។

ឃ) បរាជ័យក្នុងការធ្វើតាមកិច្ចការដែលជាផ្នែករបស់យើង នឹងរារាំងយើងមិនឲ្យមានភាពពេញវ័យជាគ្រិស្តបរិស័ទបានឡើយ។

ង) ការស្តាប់បង្គាប់គឺជាគន្លឹះនាំទៅរកភាពពេញវ័យជាគ្រិស្តបរិស័ទ។

ច) បញ្ហាដែលកើតឡើងនៅក្នុងជីវិតរបស់គ្រិស្តបរិស័ទ គឺជាសញ្ញាបញ្ជាក់យ៉ាងច្បាស់អំពីភាពក្មេងខ្ចី។

លោកប៉ូលបានបន្តនៅក្នុងគម្ពីរអេភេសូជំពូក៦ ដើម្បីនិយាយពីអាវុធដែលយើងត្រូវការដើម្បីតយុទ្ធជាមួយភាពក្មេងខ្ចី។ *សេចក្តីពិត សេចក្តីសុចរិត* (ការរស់នៅត្រឹមត្រូវ) *ចិត្តប្រុងប្រៀបផ្សាយដំណឹងល្អ* (ទីបន្ទាល់របស់យើង) *ជំនឿ* និង *ព្រះបន្ទូលរបស់ព្រះជាម្ចាស់* ។ ការណែនាំចុងក្រោយរបស់លោក គឺ ត្រូវ *អធិស្ឋាន* (គម្ពីរអេភេសូ ៦:១៨)។

ភាពពេញវ័យរបស់គ្រិស្តបរិស័ទ រួមមានដំណើរការនៃការលូតលាស់ទៅមុខជានិច្ច។ រាល់លើកដែលអ្នកធ្វើការសម្រេចចិត្ត ធ្វើតាមបង្គាប់របស់ព្រះជាម្ចាស់ អ្នកបានរីកលូតលាស់ខាងឯវិញ្ញាណអ្នក។

ឃ. ភាពមានបាន និង ភាពក្រីក្រ

វត្ថុបំណងទី៥. *ស្គាល់ដំណោះស្រាយនៅក្នុងព្រះគម្ពីរសម្រាប់បញ្ហាដែលទាក់ទងនឹង ភាពមានបាន និង ភាពក្រីក្រ។*

ប្រាក់ ហាក់ដូចជារបស់ដ៏ត្រឹមត្រូវមួយ។ វាអាចទិញសេចក្តីសុខខាងរូបកាយ និង របស់ចាំបាច់នៅក្នុងជីវិតឲ្យយើងបាន ហើយវាអាចធ្វើរឿងល្អបាន ប្រសិនបើយើងប្រើវាឲ្យធ្វើ។ ប៉ុន្តែគម្ពីរ១ធីម៉ូថេ ៦:១០ បានព្រមានយើងថា៖ "ដ្បិតការស្រឡាញ់ប្រាក់ ជាឫសគល់នៃអំពើអាក្រក់គ្រប់បែបយ៉ាង។" ព្រះគម្ពីរបាននិយាយអំពីស្ថានសួគ៌តិចជាងនិយាយអំពីទ្រព្យសម្បត្តិដែលពេញដោយការបោកបញ្ឆោត និង ការល្បួងដ៏អាក្រក់របស់វា។

យើងបានរាប់បញ្ចូល ភាពមានបាន និង ភាពក្រីក្រនៅក្នុងបញ្ហានៅក្នុងទំនាក់ទំនងសង្គម ព្រោះមនុស្សជាច្រើនមានទោសកំហុសដោយការធ្វើអំពើអាក្រក់គ្រប់បែបយ៉ាងទាស់នឹងគ្នាទៅវិញទៅមក ដើម្បីគ្រាន់តែទទួលបានទ្រព្យសម្បត្តិខ្លួនគេ។ ប្រធានបទនេះ មានជាប់ទាក់ទងនឹង ការសិក្សារបស់យើងអំពីភាពលោភលន់ (សេចក្តីលោភ) ដែលនៅមេរៀនមុន។ យើងមិនអាចនឹង រាប់បញ្ចូលការព្រមានទាំងអស់ដែលមាននៅក្នុងបទបន្ទូលទាំងប៉ុន្មានទាក់ទង បំណងប្រាថ្នាចង់មានបានរបស់យើង និង អារម្មណ៍ភ័យខ្លាចភាពក្រីក្ររបស់យើងនោះបានឡើយ ប៉ុន្តែយើងសង្ឃឹមថាអាចផ្តល់ការណែនាំជាគោលខ្លះដែលនឹងជួយអ្នកជៀសវាងបញ្ហាដែលទាក់ទងជាមួយប្រាក់ និង ឥទ្ធិពលរបស់វាទៅលើទំនាក់ទំនងរបស់អ្នកជាមួយអ្នកដទៃ។ ដំបូង យើងនឹងនិយាយអំពីបញ្ហាដែលទាក់ទងជាមួយនឹង ភាពមានបាន និង ភាពក្រីក្រ។ បន្ទាប់មក យើងនឹងផ្តល់ដំណោះស្រាយតាមព្រះគម្ពីរ សម្រាប់បញ្ហាទាំងនេះ ដែលដំណោះស្រាយទាំងអស់នោះមានទាក់ទងនឹងឥរិយាបថរបស់យើងទៅកាន់ប្រាក់ និង អ្វីដែលលុយអាចធ្វើសម្រាប់យើងបាន។

បញ្ហាដែលទាក់ទងទៅនឹងភាពមានបាន

១. *ភាពមានបានគាប់សង្កត់យើង។* បុរសអ្នកមាន វ័យក្មេងម្នាក់ដែលបានទូលសួរព្រះយេស៊ូអំពីរបៀបទទួលបានជីវិតអស់កល្បជានិច្ច បានចាកចេញដោយក្រៀមក្រំ ព្រោះគាត់ត្រូវបានគាប់សង្កត់ (ចងរឹតជាប់) ដោយភាពមានបានរបស់គាត់ ហើយគាត់មិនអាចលះបង់វាបានឡើយ (គម្ពីរ ម៉ាថាយ ១៩:១៦-២២)។ ពេលខ្លះ ផ្ទុយពីការគ្រប់គ្រងទ្រព្យសម្បត្តិ យើងត្រូវបានទ្រព្យសម្បត្តិគ្រប់គ្រងទៅវិញ ពេលវេលារបស់យើងទាំងអស់ត្រូវបានចំណាយទៅលើ ការថែរក្សាទ្រព្យសម្បត្តិរបស់យើង ឬ ការព្យាយាមរកទ្រព្យសម្បត្តិបន្ថែមទៀត។

២. *ភាពមានបានផ្តល់អារម្មណ៍ខ្ពង់ខ្ពស់លើសគេ*។ តាមរបៀបរបស់លោកីយ៍ គឺត្រូវលើកតម្កើងអ្នកមានឲ្យខ្ពង់ខ្ពស់ជាងគេ។ ជារឿយៗ គ្រិស្តបរិស័ទក៏មានកំហុសដោយសារតែគេបានធ្វើរឿងដូចគ្នានេះដែរ។ ដោយមនុស្ស មើលទៅពួកគេជាមួយនឹងការលើកតម្កើងយ៉ាងខ្ពស់ ព្រមទាំងមានការកោតខ្លាចផងនោះ អ្នកមានទ្រព្យសម្បត្តិទាំងនោះ អាចគិតថាខ្លួនគេខ្ពង់ខ្ពស់ជាងអ្នកដទៃដែលមិនមានដល់គេ។

៣. *ភាពមានបានបំផ្លាញ ឬ ផ្លាស់ប្តូរគុណតម្លៃរបស់យើង* ។ វាងាយស្រួលណាស់ក្នុងការធ្លាក់នៅក្នុងអន្ទាក់នៃការឲ្យតម្លៃទ្រព្យសម្បត្តិ ជាងជីវិតខាងវិញ្ញាណ។ គ្រោះថ្នាក់នៃភាពមានបាន គឺជាទំនោរដែលទោរទៅរកការទុកចិត្តលើអ្វីដែលលុយអាចធ្វើបាន ជាជាងទុកចិត្តលើអ្វីដែលព្រះជាម្ចាស់ អាចធ្វើបាន។ លុយអាចធ្វើឲ្យអ្នកមានភាពងាយស្រួលខាងឯរូបកាយ ប៉ុន្តែវាមិនអាចសង្គ្រោះអ្នកបានឡើយ! ភាពមានបាន គឺពោរពេញដោយការបោកប្រាស់ (គម្ពីរម៉ាថាយ ១៣:២២) ។ ទ្រព្យសម្បត្តិមិននៅស្ថិតស្ថេរគង់វង្សរហូតទេ (គម្ពីរសុភាសិត ២៧:២៤) ។ សូមអានគម្ពីរ ទំនុកតម្កើង ៤៩ :១៦,២០; គម្ពីរម៉ាកុស ៤:១៩; គម្ពីរលូកា ៨:១៤; និង គម្ពីរលូកា ១២:១៨- ២១)។

លំហាត់អនុវត្តន៍

---

៨ ចូរជ្រើសរើសប្រយោគបំពេញដែលត្រឹមត្រូវ។ ខគម្ពីរខាងលើបានបង្ហាញឲ្យឃើញថា ភាពមានបានគឺពោរពេញដោយការបោកប្រាស់ ព្រោះវា

ក) មើលទៅហាក់បីដូចជាស្ថិតស្ថេរគង់វង្សណាស់ ប៉ុន្តែមិនមែនជាការពិតទេ។

ខ) អាចជឿលើអ្វី ដែលវាអាចនឹងធ្វើសម្រាប់យើងបាន។

គ) ធ្វើឲ្យយើងកាន់តែមានភាពងាយស្រួលខាងឯសាច់ឈាម។

---

៤. *ភាពមានបាននាំឲ្យមានការល្បួងឲ្យធ្វើអំពើបាប* ។ បុគ្គលម្នាក់អាចមានសីលធម៌ខ្ពស់ ប៉ុន្តែនៅ តែជាទាសករនៃសេចក្តីលោភលន់ និង មិនទទួលស្គាល់វាថាជាអំពើបាបទេ។ គម្ពីរអេភេសូ ៥:១-៦ ភ្ជាប់សេចក្តីលោភលន់ ជាមួយនឹងអំពើធឹតក្បាត់។ ភាពលោភលន់ ដាក់លុយនៅកន្លែងដែលទុកសម្រាប់ព្រះជាម្ចាស់។ វាធ្វើឲ្យមនុស្សមិនស្មោះត្រង់ ក្នុងការទាក់ទងជាមួយអ្នកដទៃ និង ធ្វើការអាក្រក់ផ្សេងៗ ដូចជា រស់នៅក្នុងភាពស្តុកស្តម្ភ និង ការបណ្តោយខ្លួនយ៉ាងស្រួលនៅ លើការខាតបង់របស់អ្នកដទៃ ឬ មិនបង់ថ្លៃឈ្នួលដោយស្មោះត្រង់ និង ដល់ថ្នាក់ធ្វើឲ្យមនុស្សធ្វើទុក្ខទោស និង សម្លាប់មនុស្សដទៃទៀតផង (សូមមើលគម្ពីរយ៉ាកុប ៥:១-៦)។

បញ្ហាដែលទាក់ទងទៅនឹងភាពក្រីក្រ

ជាច្រើនលើកច្រើនសា ភាពក្រីក្រភ្ជាប់ជាមួយនឹងបញ្ហាដ៏ពិត ។ មនុស្សដែលគ្មានលុយគ្រប់គ្រាន់តែងតែមានបញ្ហា ដែលពួកគេអាចនឹងគិតពីខាងសាច់ឈាមជាងខាងវិញ្ញាណ។ ពិភពលោកមួយភាគធំត្រូវបានញាំញីដោយភាពក្រីក្រ និង ភាពភ័យខ្លាចសេចក្តីអត់ឃ្លានដែលនៅជាមួយគ្នានោះដែរ។

១. *ការព្រួយបារម្ភ និង ភាពភ័យខ្លាច* ។ ការព្រួយបារម្ភ និង ការភ័យខ្លាច ថាតើយើងអាចនឹងផ្គត់ផ្គង់តម្រូវការខ្លួនយើង ឬ គ្រួសាររបស់យើងដោយរបៀបណា គឺជាបញ្ហាដែលមនុស្សជាច្រើនមានដូចគ្នា រួមបញ្ចូលទាំងគ្រិស្តបរិស័ទផងដែរ។ យើងព្រួយបារម្ភអំពីការបាត់បង់ការការងាររបស់យើង អំពីការធ្លាក់ខ្លួនឈឺ និង មិនអាចធ្វើការបាន និងមិនមានប្រាក់គ្រប់គ្រាន់ដើម្បីបង់ថ្លៃចំណាយផ្សេងៗបាន។ នេះគឺជាការឆ្លើយតបធម្មតាទៅនឹងបញ្ហាដ៏ជាក់ស្តែងមួយ។

២. *ការល្បួងទៅរកសេចក្តីទុច្ចរិត* ។ ទាំងអ្នកមាន និង អ្នកក្រ អាចត្រូវបានធ្វើទុក្ខដោយការល្បួង ឲ្យ ចង់បានទ្រព្យសម្បត្តិតាមរយៈអំពើទុច្ចរិត ប៉ុន្តែគេមានមូលហេតុផ្សេងពីគ្នា។ អ្នកក្រម្នាក់អាច រក លេសដើម្បីយកអ្វីម្យ៉ាងដែលជាកម្មសិទ្ធិចៅហ្វាយរបស់គាត់ អ្នកជិតខាងរបស់គាត់ ឬ ពីអ្នក មានណាម្នាក់។ ទោះជាយ៉ាងណា តម្រូវការរបស់គាត់ គឺចាំបាច់ជាងពួកអ្នកទាំងនោះ ។ ប៉ុន្តែ ក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ គិតសំដៅលើអំពើទុច្ចរិតទាំងអស់ មិនថាមូលហេតុអ្វីនោះទេ៖ "កុំ លួចប្លន់គេ" (គម្ពីរនិក្ខមនំ ២០:១៥)។ អំពើទុច្ចរិតដែលធំជាងគេបំផុត ដែលឃើញមានទាំងនៅ ក្នុងចំណោមអ្នកមាន និង អ្នកក្រ គឺការកេងប្រវ័ញ្ចអ្វីដែលជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់៖ "តើ មនុស្សកេងប្រវ័ញ្ចព្រះជាម្ចាស់ ដូចម្តេចបាន? អ្នករាល់គ្នាកេងប្រវ័ញ្ចយើង ហើយពោលថា "យើងខ្ញុំកេងប្រវ័ញ្ចព្រះអង្គដូចម្តេចខ្លះ?"។ គឺអ្នករាល់គ្នាកេងប្រវ័ញ្ច តង្វាយមួយភាគដប់ និង តង្វាយ ដែលអ្នករាល់គ្នាត្រូវញែកទុកសំរាប់យើង! (គម្ពីរម៉ាឡាគី ៣:៨)។

៣. *ការមានអារម្មណ៍ថា តូចទាបជាងគេ។* ដូចជាអ្នកមានដែលបានគិតថាខ្លួនគេ ខ្ពង់ខ្ពស់ជាងអ្នក ដទៃដែរ អ្នកក្រក៏ចេះតែគិតថា ខ្លួនគេតូចទាប ដែលមានសមត្ថភាពអន់ជាងអ្នកដែលមានប្រាក់ ច្រើនជាងខ្លួន។ ថ្វីដ្បិតតែ នេះគឺជាបញ្ហាដ៏ជាក់ស្តែងសម្រាប់មនុស្សជាច្រើន ប៉ុន្តែវាបានផ្អែកទៅ លើគុណតម្លៃមួយដែលខុស ដូចដែលយើងបានដឹងស្រាប់ហើយ។

៤. *ការគិតខុសអំពីការផ្គត់ផ្គង់របស់ព្រះជាម្ចាស់* ។ ដោយមានមូលហេតុមួយចំនួន ទោះបីជាមានការ និយាយអំពីភាពគ្រោះថ្នាក់របស់ភាពមានបាននៅក្នុងព្រះគម្ពីរយ៉ាងណាក៏ដោយ ក៏នៅមាន មនុស្សជាច្រើន យល់ច្រលំថា ការគោរពកោតខ្លាចព្រះជាម្ចាស់នឹង ទទួលបានការរីកចម្រើនខាង ហិរញ្ញវត្ថុទៅវិញ (គម្ពីរ ១ធីម៉ូថេ ៦:៥)។ ពួកគេតែងតែចែកចាយថា ប្រសិនបើអ្នកមានជំនឿ គ្រប់គ្រាន់ អ្នកអាចក្លាយជាអ្នកមាន ឬប្រសិនបើអ្នកមិនក្លាយជាអ្នកមានទេ អ្នកបានធ្វើឲ្យខុស ចំពោះព្រះជាម្ចាស់ដោយរបៀបណាមួយហើយ។ ពួកគេចូលទៅកាន់ព្រះជាម្ចាស់ជាមួយបំណងចិត្ត ដែលខុស គឺការស្វែងរកផលប្រយោជន៍ខាងឯសាច់ឈាមជាជាងប្រយោជន៍ខាងឯវិញ្ញាណ។ ព្រះគម្ពីរមានដំណោះស្រាយសម្រាប់គ្រប់បញ្ហាទាំងអស់ដែលយើងទើបនឹងបានសិក្សា។ នៅក្នុង លំហាត់បន្ទាប់ទៀតនេះ យើងនឹងផ្តល់ឱកាសឲ្យអ្នកស្វែងរក អ្វីដែលព្រះគម្ពីរនិយាយអំពីដំណោះ ស្រាយនីមួយៗ ដោយខ្លួនឯង។

លំហាត់អនុវត្តន៍

៩ នៅជួរខាងឆ្វេង យើងបានលើកឡើងបញ្ហាខ្លះៗ ជាមួយនឹងការរៀបរាប់មួយដែលផ្តល់ដំណោះស្រាយសម្រាប់បញ្ហានីមួយៗ។ នៅក្នុងជួរខាងស្តាំ យើងរៀបរាប់ខ្លីៗ អំពីបញ្ហាដែលអ្នកនឹងរកឃើញនៅក្នុងខគម្ពីរ។ ចូរផ្គូផ្គងដំណោះស្រាយនីមួយៗ (ជួរខាងស្តាំ) ជាមួយនឹងខគម្ពីរដែលទាក់ទងនឹងបញ្ហានោះ (ជួរខាងឆ្វេង)។ ចូរសរសេរលេខ នៃចម្លើយត្រឹមត្រូវនៅក្នុងចន្លោះបន្ទាត់។

.....ក) ទាសករនៃភាពមានបាន៖ គម្ពីរម៉ាថាយ ១៩:២១-២២,២៩

.....ខ) មានអារម្មណ៍ថាខ្ពង់ខ្ពស់ជាងគេ៖ គម្ពីរយ៉ាកុប ១:១០

.....គ)ការផ្លាស់ប្តូរ និងការបំផ្លាញគុណតម្លៃ៖ គម្ពីរលូកា ១២:៣២-៣៤

.....ឃ) ការល្បួងឲ្យធ្វើអំពើបាប៖ គម្ពីរ១ធីម៉ូថេ ៦:៩-១១

.....ង) ភាពភ័យខ្លាច និង ការព្រួយបារម្ភ៖ គម្ពីរម៉ាថាយ ៦:២៥-៣៤

.....ច) ការល្បួងឲ្យធ្វើអំពើទុច្ចរិត៖ គម្ពីរអេសាយ ៣៣:១៥-១៦

.....ឆ) ការមានអារម្មណ៍ថាតូចទាបជាងគេ៖ គម្ពីរយ៉ាកុប ១:៩-១០

.....ជ) ការគិតខុសអំពីការផ្គត់ផ្គង់របស់ព្រះជាម្ចាស់៖ គម្ពីរ១ធីម៉ូថេ ៦:៥-៨

១) ទុកចិត្តព្រះជាម្ចាស់ ស្វែងរកព្រះរាជ្យ និងភាពសុចរិតរបស់ទ្រង់ជាមុន ហើយទ្រង់នឹងផ្គត់ផ្គង់តម្រូវប្រចាំថ្ងៃរបស់អ្នក។

២) មនុស្សរបស់ព្រះជាម្ចាស់គួរជៀសឲ្យផុតពីបញ្ហានេះ ហើយតាមស្វែងរកអ្វីដែលជារបស់ព្រះជាម្ចាស់

៣) ត្រូវអរព្រះគុណព្រះជាម្ចាស់សម្រាប់តំណែងដ៏ខ្ពស់ជាកូនរបស់ព្រះជាម្ចាស់ និង ជាអ្នកបម្រើរបស់ទ្រង់។

៤) ត្រូវខ្វល់ខ្វាយពីរបស់ដែលមានគុណតម្លៃអស់កល្បជានិច្ច ជាងទ្រព្យសម្បត្តិនៅក្នុងលោកីយ៍ ដ្បិតទ្រព្យសម្បត្តិរបស់អ្នកនៅទីណា ចិត្តរបស់អ្នកនៅទីនោះ។

៥) ការគោរពកោតខ្លាចព្រះជាម្ចាស់គឺមិនផ្អែកទៅតាមទ្រព្យសម្បត្តិនៅលើផែនដីនោះទេ។

៦) ត្រូវដាក់ព្រះគ្រិស្ត និង អាណាចក្ររបស់ទ្រង់ជាទីមួយនៅក្នុងជីវិតរបស់អ្នក។

៧) ព្រះជាម្ចាស់នឹងប្រទាននំប៉័ង និង ទឹកឲ្យអ្នក។ (ទ្រង់នឹងប្រទានអ្វីទាំងអស់ដែលយើងត្រូវការ។)

៨) ចាត់ទុកខ្លួនអ្នកជា អ្នកបម្រើ ។ មិនត្រូវមានមោទនភាពជាមួយលុយរបស់អ្នកឡើយ តែជាមួយនឹងតំណែងតូចទាបរបស់អ្នកវិញ។

គុណតម្លៃរបស់គ្រិស្តបរិស័ទពាក់ព័ន្ធជាមួយនឹងលុយ

វត្ថុបំណងទី ៦. *ស្វែងរក និង កែកំហុសនៅក្នុងពាក្យមួយឃ្លាដែលនិយាយទាក់ទងនឹងគុណតម្លៃរបស់គ្រិស្តបរិស័ទពាក់ព័ន្ធជាមួយនឹងបញ្ហាលុយ។*

ទាំងនេះគឺជា ការណែនាំទូទៅ អំពើគុណតម្លៃដែលយើងគួរតែមាន ពាក់ព័ន្ធនឹង ទ្រព្យសម្បត្តិខាងសាច់ឈាម។ ការបង្កើតឥរិយាបថទាំងនេះបាន នឹងជួយអ្នកជៀសផុតពីគ្រោះថ្នាក់ដែលបណ្តាលមកពីលុយច្រើនពេក ឬ លុយតិចពេក។ ចូរអានបទគម្ពីរទាំងអស់ដែលបានផ្តល់ជូន។

១. *អ្នកគឺជាអ្នកមើលការខុសត្រូវលុយរបស់ព្រះជាម្ចាស់* (លូកា ១៦:១-១៣)។
គ្រិស្តបរិស័ទដែលមានការប្រុងប្រយ័ត្ន និងស្មោះត្រង់នៅក្នុងការងារពាក់ព័ន្ធជាមួយនឹងលុយ និង អ្នកដែលបានថ្វាយតង្វាយមួយភាគដប់នៃចំណូលរបស់គេទៅកាន់ព្រះជាម្ចាស់នឹងទទួលព្រះពរ (សូមមើលគម្ពីរម៉ាឡាគី ៣:៨-១១)។ ព្រះជាម្ចាស់បានតម្រូវថា ទ្រង់នឹងផ្គត់ផ្គង់តម្រូវការប្រចាំថ្ងៃរបស់យើង នៅពេលដែលយើងថ្វាយជីវិតរបស់យើងទៅកាន់ទ្រង់។ ប្រសិនបើ អ្នកគិតថា ខ្លួនអ្នកតែងតែមានតម្រូវខាងឯលុយកាក់ដើម្បីបំពេញតាមកាតព្វកិច្ចរបស់អ្នក ឬ ប្រសិនបើអ្នកតែងតែមានបញ្ហាជាបន្តបន្ទាប់ដូចជា ការចំណាយទាំងមិនបានព្រៀងទុក ជំងឺ ឬ បាត់បង់ការងារ ចូរអ្នកសួរខ្លួនឯងថា៖ "តើខ្ញុំជាអ្នកមើលខុសត្រូវលុយដ៏ស្មោះត្រង់របស់ព្រះជាម្ចាស់ឬទេ? តើខ្ញុំបានថ្វាយទៅទ្រង់ មួយភាគដប់នៃអ្វីដែលខ្ញុំជំពាក់ទ្រង់ហើយឬនៅ? តើខ្ញុំពិត ជាទុកចិត្តទ្រង់ក្នុងការផ្គត់ផ្គង់តម្រូវការរបស់ខ្ញុំដែរឬទេ?"

២. *កាតព្វកិច្ចរបស់ព្រះជាម្ចាស់ក្នុងការផ្គត់ផ្គង់តម្រូវការរបស់យើង គឺផ្អែកទៅលើការលះបង់របស់យើងសម្រាប់អាណាចក្ររបស់ទ្រង់* ។ ព្រះជាម្ចាស់បានតម្រូវថា ទ្រង់នឹងប្រទានអ្វីៗគ្រប់យ៉ាងដែលយើងត្រូវការ។ នៅក្នុងគម្ពីរម៉ាថាយ ៦:២៥-៣៤ ព្រះយេស៊ូបានមានព្រះបន្ទូលប្រាប់យើងម្តងហើយម្តងទៀតថា៖ "កុំខ្វល់ខ្វាយ" ។ វាពិតជាអំពើឆោតល្ងង់មួយ បើខ្ញុំសរសេរដំណោះស្រាយបញ្ហានៅក្នុងមេរៀននេះយ៉ាងសាមញ្ញបំផុតថា "កុំខ្វល់ខ្វាយ" នោះ ព្រោះខ្ញុំគ្មានអំណាចអ្វី ដើម្បីបំពេញតម្រូវការរបស់អ្នកបានឡើយ ប៉ុន្តែយើងមានព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពដែលរក្សាព្រះបន្ទូលសន្យារបស់ទ្រង់។ នៅពេលដែលទ្រង់មានព្រះបន្ទូលថា ទ្រង់នឹងបំពេញតម្រូវការខាងសាច់ឈាមយើង ប្រសិនបើយើងព្យាយាមផ្គាប់ព្រះទ័យរបស់ទ្រង់ ។ ទ្រង់មានឫទ្ធានុភាពដើម្បីបំពេញតាមការសន្យានោះ ហើយទ្រង់នឹងធ្វើតាមការសន្យានោះដែរ។!

លំហាត់អនុវត្តន៍

១០ ចូរអានខគម្ពីរខាងក្រោម ហើយសរសេរការសន្យា ឬ កាតព្វកិច្ចដែលព្រះជាម្ចាស់បានធ្វើចំពោះអ្នក ទៅតាមខគម្ពីរនីមួយៗ។

ក) គម្ពីរភីលីព ៤:១៩.....

ខ) គម្ពីរម៉ាថាយ ៦:២៥-៣៤.....

គ) គម្ពីរហេប្រឺ ១៣:៥-៦.....

---

១. *ទ្រព្យសម្បត្តិមិនអាចសង្គ្រោះអ្នកបានទេ។* ភាពមានបាននឹងក្លាយជាគ្មានតម្លៃនៅក្នុងថ្ងៃនៃការជំនុំជម្រះ (គម្ពីរសុភាសិត ១១:៤; គម្ពីរម៉ាថាយ ៦:១៩-២០)។

២. *ផលចំណេញដែលគ្រិស្តបរិស័ទគួរចាប់អារម្មណ៍គឺ ការគោរពកោតខ្លាចព្រះ និង ការសប្បាយចិត្ត* (គម្ពីរលូការ១២:១៥ , គម្ពីរ១ធីម៉ូថេ ៦:៦-៧)

៣. គុណតម្លៃដ៏ពិតខាងឯវិញ្ញាណគឺជាគុណតម្លៃដ៏អស់កល្បជានិច្ច (គម្ពីរកូឡូស ៣:១-៤)។

៤. *ចិត្តសប្បុរសឆ្ពោះទៅរកព្រះជាម្ចាស់គឺជាវិញ្ញាណត្រឹមត្រូវ សម្រាប់ទាំងអ្នកមាន និង អ្នកក្រ* ។ ព្រះជាម្ចាស់មិនត្រឹមតែរាប់អ្វីដែលអ្នកឲ្យនោះទេ ប៉ុន្តែទ្រង់ក៏រាប់ទាំងអ្វីដែលអ្នកនៅសេសសល់ទៀតផង។ ព្រះយេស៊ូបានមានព្រះបន្ទូលថា ស្ត្រីមេម៉ាយក្រីក្រម្នាក់ បានឲ្យច្រើនជាងអ្នកមានទាំងអស់នៅក្នុងព្រះវិហារ (គម្ពីរលូកា ២១:១-៤)។ លោកសាវ័កប៉ូលបាន និយាយសរសើរអ្នកក្រីក្រស្រុកម៉ាសេដូន ព្រោះមានអំណរខ្លាំងក្រៃលែង ហើយទោះបីគេក្រតោកយ៉ាកយ៉ាងណាក្តី ក៏គេនៅតែមានចិត្តសទ្ធាជ្រះថ្លាដ៏លើសលប់ដែរ" ហើយពួកគេថែមទាំងថ្វាយលើសពីសមត្ថភាពទៀតផង។ (គម្ពីរ២កូរិនថូស ៨:១-៥)។

លោកសាវ័កប៉ូលបាន រកឃើញថា នៅពេលដែលលោកបានថ្វាយជីវិតរបស់លោកទាំងស្រុងទៅព្រះយេស៊ូគ្រិស្ត អ្វីៗទាំងអស់ទទួលបានគុណតម្លៃថ្មីមួយ។ អ្វីដែលលោកធ្លាប់បានគិតថាមានសារៈសំខាន់ពីមុនមកគឺហាក់ដូចជាសម្រាម។ អ្វីដែលទាក់ទងនឹងព្រះគ្រិស្ត និង អំណាចនៃការរស់ឡើងវិញរបស់ព្រះអង្គ បានក្លាយទៅជារឿងសំខាន់លើសគេ (គម្ពីរភីលីព ៣:៧-១០)។ អ្នកជឿគ្រប់រូប នឹងដឹងថារឿងនេះជារឿងពិត។ យើងប្រើប្រាស់អ្វីៗដែលជារបស់លោកីយ៍ ប៉ុន្តែយើងមិនត្រូវបានស្រូបទាញឲ្យស្លុងចូលទៅក្នុងរបស់ទាំងនោះទេ(គម្ពីរ១កូរិនថូស ៧:៣១) ។ ការថ្វាយទៅកាន់ព្រះជាម្ចាស់ គឺជាអំណរ និងអភ័យឯកសិទ្ធិ ព្រោះទ្រង់យកបានកន្លែងទីមួយនៅក្នុងដួងចិត្តរបស់យើង។

លំហាត់អនុវត្តន៍

១១ ចូរអានប្រយោគនីមួយៗខាងក្រោមនេះ ដោយយកចិត្តទុកដាក់។ មានអ្វីម្យ៉ាងដែលមិនត្រឹមត្រូវនៅក្នុងប្រយោគទាំងអស់។ ចូរកែប្រយោគនីមួយៗ ដើម្បីឲ្យវាផ្តល់គុណតម្លៃដែលត្រឹមត្រូវមួយសម្រាប់គ្រិស្តបរិស័ទ ពាក់ព័ន្ធនឹងបញ្ហាលុយ។

ក) បរិមាណទ្រព្យសម្បត្តិដែលខ្ញុំមានក្នុងពេលនេះ នឹងមានតម្លៃខ្លាំងណាស់សម្រាប់ខ្ញុំ នៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យទោសខ្ញុំ។

.....

.....

ខ) ព្រះជាម្ចាស់ទាមទារឲ្យអ្នកមានធ្វើជាអ្នកទទួលខុសត្រូវដ៏ល្អសម្រាប់ទ្រព្យសម្បត្តិរបស់ទ្រង់។

.....

.....

គ) ព្រះជាម្ចាស់តម្រូវថាទ្រង់ត្រូវផ្គត់ផ្គង់តម្រូវការគ្រប់ទាំងអស់របស់មនុស្សគ្រប់គ្នា។

.....

.....

ឃ) យើងត្រូវដាក់ព្រះជាម្ចាស់ជាទីមួយ នៅក្នុងជីវិតរបស់យើង ដើម្បីឲ្យទ្រង់ថែរក្សាយើង។

.....

.....

ង) ចិត្តសប្បុរស គឺជាអ្វីម្យ៉ាងដែលមានតែអ្នកមានតែប៉ុណ្ណោះ អាចមាន។

.....

.....

១. ភាពអយុត្តិធម៌

វត្ថុបំណងទី៧. *ថ្លែងពីគោលការណ៍ដែលគួរតែដឹកនាំ ការឆ្លើយរបស់គ្រិស្តបរិស័ទម្នាក់ ដែលជាជនរងអំពើអយុត្តិធម៌។*

បញ្ហានៅក្នុងទំនាក់ទំនងសង្គម ដែលយើងបានពិភាក្សាមកដល់ចំណុចនេះ គឺមានទាក់ទងជាមួយនឹងតរិយាបថ និង អាកប្បកិរិយារបស់យើង។ ឥឡូវនេះ យើងចង់និយាយអំពី បញ្ហាដែលយើងធ្លាប់ប្រឈមមុខ ហើយជាបញ្ហាដែលយើងមិនអាចគ្រប់គ្រងបាន ឬ គ្រប់គ្រងបានតិចតួច។ នោះគឺជា បញ្ហានៃភាពអយុត្តិធម៌៖ នៅពេលដែលនរណាម្នាក់ធ្វើអាក្រក់ ឬ ខុសឆ្គងមកលើអ្នក ទាំងដែលអ្នកមិនសមនឹងទទួលបានវាឡើយ។

ឧបមាថា អ្នកធ្វើកិច្ចព្រមព្រៀងជំនួញជាមួយនឹងបងប្អូនគ្រិស្តបរិស័ទម្នាក់ ដែលគាត់បានកេងចំណេញលើអ្នក ហើយគាត់មិនព្រមធ្វើវាឲ្យបានត្រឹមត្រូវវិញនោះទេ។ ឧបមាថា អ្នកប្រឹងប្រែងធ្វើការយ៉ាងខ្លាំង និងលើសពីអ្វីដែលចៅហ្វាយរបស់អ្នកដាក់ឲ្យទៀត ហើយស្រាប់តែមេការរបស់អ្នកបានយកគុណសម្បត្តិដែលបានមកពីការងារដែលលើសនោះ។ ក៏ប្រហែលជាអ្នកបានធ្វើការងារយ៉ាងល្អ ហើយមានមិត្តអ្នករួមការងារដែលមានចិត្តច្រណែនម្នាក់ បានរាយការណ៍ថា អ្នកបានមិនយកចិត្តទុកដាក់ ឬ ខ្ជិលនៅក្នុងការងាររបស់អ្នក។ ឬមានមិត្តភក្តិម្នាក់ដែលត្រូវបានគេតាមទាន់នៅពេលដែលកំពុងលួចចម្លងនៅក្នុងសាលា បានប្រាប់ទៅកាន់គ្រូថា អ្នកក៏បានលួចចម្លងដែរ ទោះបីជាជាក់ស្តែងអ្នកមិនបានធ្វើផង។ ប្រហែលជាមាននរណាម្នាក់ដែលមានសមត្ថភាពតិចជាងអ្នក ត្រូវបានតម្លើងឲ្យកាន់តំណែងខ្ពស់ ហើយអ្នកមានអារម្មណ៍ថា អ្នកស័ក្តិសមចំពោះតំណែងនោះជាង។

ខ្ញុំជឿថាអ្នកអាចគិតឃើញរឿងរ៉ាវជាច្រើនផ្សេងទៀត ទាក់ទងនឹងពេលដែលភាពអយុត្តិធម៌ បានកើតឡើងទាស់នឹងអ្នក។ សំណួរដែលសំខាន់នោះគឺ តើអ្នកឆ្លើយតបយ៉ាងដូចម្តេច? តើអ្នកមានអារម្មណ៍ខឹង និយាយពាក្យមិនល្អទៅកាន់អ្នកដែលបានធ្វើខុសចំពោះអ្នក មានអារម្មណ៍ចុះចាញ់ មានអារម្មណ៍ស្រណោះខ្លួនឯង ឬ ភ្លូញភ្លែរឲ្យគេស្តាប់ ឬ? វាគឺជារឿងធម្មតា ដែលអ្នកចង់ក្រោកឈរតស៊ូសម្រាប់ "សិទ្ធិ" របស់អ្នក សម្រាប់អ្វីដែលអ្នកមានសិទ្ធិទទួលបាន ។ តើគ្រិស្តបរិស័ទគួរតែឆ្លើយតបយ៉ាងដូចម្តេចទៅនឹងកាលៈទេសៈបែបនេះ? តើដំណោះស្រាយរបស់គ្រិស្តបរិស័ទទៅចំពោះបញ្ហានៃភាពអយុត្តិធម៌មានអ្វីខ្លះ?

ខ្ញុំមានមិត្តភក្តិម្នាក់ឈ្មោះប៉ូល ដែលគាត់ជាមន្ត្រីប៉ូលីសម្នាក់ ។ នៅពេលដែលគាត់បានក្លាយជាគ្រិស្តបរិស័ទម្នាក់ ភ្លាមៗនោះ ជីវិតរបស់គាត់គឺពោរពេញដោយសេចក្តីអំណរ ហើយគាត់ចង់ចែករំលែកបទពិសោធន៍នៅក្នុងព្រះគ្រិស្ត ជាមួយនឹងមនុស្សគ្រប់គ្នាដែលគាត់បានជួប។ គ្មានអ្វីអាចនឹងផ្លាស់ប្តូរឥរិយាបថរីករាយរបស់គាត់បានឡើយ មានតែលោកពលបាលត្រីម្នាក់ ដែលមានហានៈលើគាត់។ មិត្តរបស់ខ្ញុំ តែងតែទៅធ្វើការជារៀងរាល់ព្រឹក ជាមួយចម្រៀងដែលច្រៀងនៅក្នុងចិត្តរបស់គាត់ គឺបានត្រឹមតែទទួលបានការស្វាគមន៍ ពីសំណាក់លោកពលបាលម្នាក់ដែលប្រកបដោយភាពល្ងីងជូរចត់ កោងកាច ចាំតែចាប់កំហុស និងមិនសប្បាយចិត្ត ដែលព្យាយាមធ្វើឲ្យជីវិតរបស់ប៉ូលវេទនាទៅវិញ។ ការឆ្លើយតបរបស់លោកប៉ូល គឺត្រូវតែស្ងាត់ស្ងៀម ត្រូវបានដុតបញ្ឆេះជាមួយនឹងកំហឹងដែលនៅខាងក្នុងហើយមិននិយាយអ្វីទាំងអស់ ហើយព្យាយាមគិតពីមធ្យោបាយ "សងសឹក" មេរបស់គាត់។ ប៉ុន្តែក្នុងព្រឹកមួយ មានគំនិតមួយបានលេចឡើងចំពោះប៉ូលៈ "ហេតុអ្វីបានខ្ញុំអនុញ្ញាតឲ្យ*គាត់* ដកយកអំណរ និងជ័យជំនះរបស់ខ្ញុំយ៉ាងដូច្នេះ? ឥរិយាបថអាក្រក់របស់គាត់គឺជា *របស់គាត់* មិនមែនរបស់ខ្ញុំឯណា! ខ្ញុំនឹងអរសប្បាយនៅក្នុងព្រះអម្ចាស់ មិនថាលោកពលបាលនោះធ្វើអ្វីមកលើខ្ញុំនោះទេ!" ជាលទ្ធផល ប៉ូលចាប់ផ្តើមបង្ហាញសេចក្តីស្រឡាញ់ និង ចិត្តសប្បុរស ទៅចំពោះគាត់ ហើយដល់ពេលមួយ ប៉ូលបានយកគាត់ធ្វើជាមិត្តដ៏ល្អថែមទៀតផង។

ប៉ូលបានរៀនពីសេចក្តីពិតមួយដែលបានរៀបរាប់នៅក្នុង គម្ពីរម៉ាថាយ ៥:១០-១២៖ អ្នកណាត្រូវគេបៀតបៀន ព្រោះតែបានធ្វើតាមសេចក្តីសុចរិត* អ្នកនោះមានសុភមង្គលហើយ ដ្បិតគេបានទទួលក្នុងព្រះរាជ្យ នៃស្ថានបរមសុខ! ប្រសិនបើមានគេត្មះតិះដៀល បៀតបៀន និងមានគេនិយាយអាក្រក់គ្រប់យ៉ាង បង្ខូចឈ្មោះអ្នករាល់គ្នា ព្រោះតែខ្ញុំ នោះអ្នករាល់គ្នាមានសុភមង្គលហើយ! ចូរអរសប្បាយរីករាយឡើង ព្រោះអ្នករាល់គ្នានឹងទទួលរង្វាន់យ៉ាងធំនៅស្ថានបរមសុខ ដ្បិតពួកព្យាការី*ដែលរស់នៅមុនអ្នករាល់គ្នា ក៏ត្រូវគេបៀតបៀនដូច្នោះដែរ។

បទគម្ពីរនេះបញ្ជាក់អំពីអ្វីដែលយើងបាននិយាយតាំងពីខាងដើមមេរៀននេះថា៖ យើងគឺជាឯកអគ្គរាជទូតរបស់ព្រះគ្រិស្ត ជាអ្នកតំណាងរបស់ទ្រង់ទៅកាន់លោកីយ៍។ អាកប្បកិរិយាល្អរបស់យើង នឹងទទួលបានការកោតសរសើរ និង ការគោរពសម្រាប់ព្រះវរបិតានាស្ថានបរមសុខ និង សម្រាប់ព្រះរាជរបស់ទ្រង់ផងដែរ។

ប្រាកដណាស់ មានពេលខ្លះ យើងអាចធ្វើការកែតម្រូវរឿងអយុត្តិធម៌ដែលបណ្តាលមកពីការយល់ច្រលំ។ ប៉ុន្តែនៅពេលដែល មានរឿងអយុត្តិធម៌មួយកើតមានឡើង អ្នកអាចឆ្លើយតបតាមរបៀបដូចជាព្រះគ្រិស្ត គឺទទួលស្គាល់ថាបញ្ហានោះមិនមែនជាបញ្ហារបស់អ្នកទេ តែជារបស់អ្នកដទៃវិញ ហើយទទួលស្គាល់ថា អ្នកមានព្រះវរបិតានៃស្ថានបរមសុខ ដែលចាំមើលថែអ្នក ហើយនឹងផ្តល់ជ័យជម្នះនៅក្នុងដួងចិត្តរបស់អ្នក។ មានពេលខ្លះ ទ្រង់អនុញ្ញាតឲ្យអ្នកទ្រាំទ្រនឹងភាពអយុត្តិធម៌ ប៉ុន្តែទ្រង់នឹងប្រើប្រាស់វាដើម្បីផលប្រយោជន៍ដ៏អស់កល្បជានិច្ច។

លំហាត់អនុវត្តន៍

---

១២ ចូរប្រាប់អំពីគោលការណ៍ដែលអាចនឹងជួយដឹកនាំការឆ្លើយតបរបស់គ្រិស្តបរិស័ទ ដែលជាជន រងគ្រោះនៅក្នុងភាពអយុត្តិធម៌។

.....

.....

ខ្ញុំមិនអាចគិតឃើញពីការសន្និដ្ឋានណាមួយសម្រាប់មេរៀនមួយនេះ ក្រៅតែពីជំរុញអ្នកឲ្យអានគម្ពីរម៉ូរ៉ូមជំពូក១២ ដោយយកចិត្តទុកដាក់ និង ដោយការសញ្ជឹងគិតពិចារណា។ ជំពូកនេះ បានផ្តល់នូវខគម្ពីរដែលជាការណែនាំយ៉ាងពេញលេញ សម្រាប់អស់អ្នកដែលចង់មានទំនាក់ទំនងត្រឹមត្រូវជាមួយព្រះជាម្ចាស់ និង ជាមួយអ្នកដទៃ។ ចូរអានបទគម្ពីរឲ្យបានញឹកញាប់ ហើយអនុញ្ញាតឲ្យបទគម្ពីរនេះធ្វើជាមគ្គទេសក៍សម្រាប់ទំនាក់ទំនងទាំងអស់របស់អ្នក។

លំហាត់អនុវត្តន៍

១៣ មុនពេលដែលអ្នកធ្វើការប្រឡងផ្ទាល់ខ្លួន ចូររំឭកអំពីបញ្ហាផ្សេងៗ នៅក្នុងទំនាក់ទំនងសង្គម។ ចូរគូសសំគាល់ បញ្ហាដែលអ្នកទើបនឹងឆ្លងកាត់ថ្មីៗ នៅក្នុងតារាងដែលបានផ្តល់ជូន។ បន្ទាប់មក សូមបកត្រឡប់ទៅមេរៀនទី ១ ដល់ ទី៣ ហើយយកគោលការណ៍សម្រាប់ការដោះស្រាយបញ្ហារបស់គ្រិស្តបរិស័ទមកអនុវត្ត ដើម្បីស្វែងរកដំណោះស្រាយសម្រាប់បញ្ហានីមួយៗ។ ត្រូវតែប្រាកដថា ដំណោះស្រាយរបស់អ្នក ផ្អែកទៅលើបទគម្ពីរ។ គោលបំណងរបស់យើង នៅក្នុងការបង្កើតលំហាត់នេះឡើង គឺជួយអ្នកឲ្យអនុវត្តតាមគោលការណ៍ដែលបានបង្រៀននៅក្នុងមេរៀននេះដោយផ្ទាល់ ដើម្បីឲ្យអ្នកអាចទទួលបានគុណសម្បត្តិ។ យើងជឿថាអ្នកនឹងធ្វើលំហាត់ប្រកបដោយបំណងចិត្តស្មោះត្រង់ ក្នុងការស្វែងរកដំណោះស្រាយសម្រាប់បញ្ហាដែលអាចកើតមាន នៅក្នុងជីវិតរបស់អ្នក។

នៅក្នុងមេរៀនបន្ទាប់របស់យើង យើងនឹងពិភាក្សាអំពីបញ្ហានៅក្នុងទំនាក់ទំនងគ្រួសារ។ មេរៀននេះគឺជាផ្នែកមួយនៃការយកចិត្តទុកដាក់យ៉ាងចាំបាច់សម្រាប់គ្រិស្តបរិស័ទគ្រប់រូប។ សូមព្រះអម្ចាស់ប្រទានពរអ្នក នៅពេលដែលអ្នកបន្តការសិក្សាទៅមុខទៀត។

ការប្រឡងផ្ទាល់ខ្លួន

សំណួរពហុជម្រើសៗ មានចម្លើយត្រឹមត្រូវមួយសម្រាប់សំណួរខាងក្រោម។ ចូរគូសរង្វង់ជុំវិញអក្សរនៃចម្លើយត្រឹមត្រូវ។

១ ភាពលោភលន់គឺជា
   ក) ស្មោះត្រង់។
   ខ) ការប្រៀបធៀបខ្លួនឯងជាមួយអ្នកដទៃ។
   គ) ការចង់បានអ្វីដែលជារបស់អ្នកដទៃ។
   ឃ) ព្យាយាមឲ្យបានល្អជាងគេ។

២ ព្រះយេស៊ូបានលាងជើងពួកសាវ័ករបស់ទ្រង់ ដើម្បីបង្ហាញពួកគេថាពួកគេត្រូវមានព័ន្ធកិច្ចនៃ
   ក) ការបម្រើគ្នាទៅវិញទៅមក។
   ខ) ភាពជាអ្នកដឹកនាំ។
   គ) ភាពអស្ចារ្យជាងគេ។
   ឃ) ឋានៈខ្ពស់។

៣ តើអ្វី ដែលផ្តល់គ្រឹះមូលដ្ឋានសម្រាប់ភាពពេញវ័យរបស់គ្រិស្តបរិស័ទ។
   ក) ការលន់តួបាប
   ខ) អំណាចនៃឆន្ទៈ
   គ) ការពង្រឹងកម្លាំងរបស់អ្នក
   ឃ) ឫទ្ធានុភាពរបស់ព្រះជាម្ចាស់។

៤ តើចម្លើយណាមួយនៅខាងក្រោមនេះ មិនមែនជាបញ្ហាដែលមិនសូវទាក់ទងជាមួយនឹងទ្រព្យសម្បត្តិ?
   ក) មានអារម្មណ៍ខ្ពង់ខ្ពស់ជាងគេ
   ខ) មានអារម្មណ៍តូចទាបជាងគេ។
   គ) ការបំផ្លាញគុណតម្លៃ
   ឃ) សេចក្តីល្បួងឲ្យធ្វើអំពើបាប។

៥ ទ្រព្យសម្បត្តិ គឺពេញដោយការបោកបញ្ឆោត ព្រោះទ្រព្យសម្បត្តិមិន
   ក) ស្ថិតស្ថេរគង់វង្សទេ។
   ខ) ចេះស្កប់ស្កល់ទេ។
   គ) នាំឲ្យមានភាពសប្បាយរីករាយទេ។
   ឃ) ធ្វើឲ្យអ្នកមានអារម្មណ៍ថាសំខាន់ទេ។

៦ ដំណោះស្រាយចំពោះភាពលោភលន់គឺ សេចក្តីស្រឡាញ់ ព្រោះសេចក្តីស្រឡាញ់
   ក) មិនមែនជាការអួត។
   ខ) ជាការទុកចិត្ត។
   គ) ជាការអត់ធ្មត់។
   ឃ) គឺមិនច្រណែន។

៧ គ្រិស្តបរិស័ទនឹងមិនស្វែងរកឋានៈ និង ការទទួលស្គាល់សម្រាប់ខ្លួន ប្រសិនជាគេចាត់ទុក តំណែងរបស់ពួកគេជា មូលហេតុក្នុងការ
   ក) ទទួលបានអំណាច
   ខ) សរសើរតម្កើងព្រះគ្រិស្ត
   គ) បន្ទាបខ្លួន
   ឃ) ដាក់ខ្លួន

៨ ដើម្បីធ្វើជាអ្នកទទួលខុសត្រូវដ៏ល្អសម្រាប់ទ្រព្យសម្បត្តិរបស់ព្រះជាម្ចាស់ អ្នកត្រូវ
   ក) យកឲ្យច្រើនតាមតែអាចធ្វើទៅបាន។
   ខ) មានអ្វីៗទាំងអស់ដែលអ្នកចង់បាន។
   គ) លក់អ្វីៗទាំងអស់ដែលអ្នកមានហើយចែកទានឲ្យអ្នកក្រ។
   ឃ) ដាក់ព្រះរាជ្យរបស់ព្រះជាម្ចាស់ជាទីមួយ ហើយចែកទានជាមួយនឹងចិត្តសប្បុរស។

៩ តួនាទីរបស់ព្រះជាម្ចាស់ក្នុងការផ្គត់ផ្គង់តម្រូវការរបស់អ្នក គឺផ្អែកទៅលើ
   ក) ឫទ្ធានុភាពរបស់ទ្រង់ក្នុងការផ្គត់ផ្គង់។
   ខ) ភាពចាំបាច់នៃតម្រូវការរបស់អ្នក។
   គ) ការប្តេជ្ញាចិត្តរបស់អ្នកទាំងស្រុងទៅចំពោះព្រះរាជ្យរបស់ព្រះជាម្ចាស់។
   ឃ) ថាតើអ្នកបារម្ភពីតម្រូវការនោះដែរ ឬទេ។

១០ ដំណោះស្រាយរបស់គ្រិស្តបរិស័ទទៅចំពោះភាពអយុត្តិធម៌គឺ
   ក) ទទួលយកភាពអយុត្តិធម៌តាមរបៀបដូចជាព្រះគ្រិស្ត ហើយទុកចិត្តថាព្រះជាម្ចាស់នឹងប្រទានឲ្យអ្នកមានជ័យជម្នះលើភាពអយុត្តិធម៌នោះ។
   ខ) អធិស្ឋានសូមឲ្យព្រះជាម្ចាស់ដាក់ទោស អ្នកដែលបានធ្វើខុសមកលើអ្នក។
   គ) ក្រោកឈរតស៊ូសម្រាប់សិទ្ធិរបស់អ្នក។
   ឃ) សងសឹកអ្នកដែលបានធ្វើខុសមកលើអ្នក។

ត្រូវ/ខុស។ ចូរសរសេរអក្សរ ត នៅក្នុងចន្លោះបន្ទាត់ ប្រសិនបើចម្លើយត្រឹមត្រូវ និងសរសេរអក្សរ ខ បើចម្លើយខុស។

.....១១ ព្រះយេស៊ូបានបង្រៀនថា អ្នកណាដែលបម្រើ គួរតែមានលក្ខណៈដូចជា អ្នកគ្រប់គ្រង។

.....១២ កម្រិតនៃការខិតខំប្រឹង ដែលមនុស្សម្នាក់គួរដាក់ទៅលើការងារមួយ គឺផ្អែកទៅលើសារៈសំខាន់នៃការងារនោះ។

.....១៣ អ្នកបម្រើដ៏ពិតម្នាក់គឺជាម្នាក់ដែលនិយាយថា ៖ "យើងខ្ញុំបានបំពេញកិច្ចការដែលយើងខ្ញុំត្រូវធ្វើ"។

.....១៤ ការសរសើរនរណាម្នាក់ នៅពេលដែលគេធ្វើការងារបានល្អ គឺជារឿងមិនត្រឹមត្រូវ។

.....១៥ គ្រិស្តបរិស័ទដែលពេញវ័យ គឺបានរួចផុតពីបញ្ហាទាំងអស់។

.....១៦ មធ្យោបាយដែលល្អបំផុតដើម្បីទទួលបានភាពពេញវ័យជាគ្រិស្តបរិស័ទ គឺត្រូវចាប់ផ្តើមធ្វើអ្វីៗ ដែលនឹងជួយអ្នកបានពេញវ័យ។

.....១៧ ព្រះជាម្ចាស់បានប្រទានរឿងជាច្រើនដែលយើងត្រូវធ្វើដើម្បីទទួលបានភាពពេញវ័យជាគ្រិស្តបរិស័ទ។

.....១៨ យើងប្រើអំណាចនៃឆន្ទៈឲ្យមានប្រយោជន៍តាមរយៈការស្តាប់បង្គាប់។

.....១៩ ភាពគ្រោះថ្នាក់របស់ទ្រព្យសម្បត្តិ គឺថា យើងអាចនឹងទុកចិត្តវាជាងទុកចិត្តព្រះជាម្ចាស់។

.....២០ ប្រសិនបើអ្នកមានជំនឿគ្រប់គ្រាន់ អ្នកអាចក្លាយជាអ្នកមានបាន។

ចម្លើយលំហាត់អនុវត្តន៍

៧ ក) ខុស

ខ) ត្រូវ

គ) ត្រូវ

ឃ) ត្រូវ

ង) ត្រូវ

ច) ខុស (ចំពោះបញ្ហាខ្លះ តែមិនប្រាកដថាទាំងអស់នោះទេ)។

១ *សេចក្តីស្រឡាញ់* គឺជាដំណោះស្រាយ ហើយ បទគម្ពីរយោងគឺ ១កូរិនថូសជំពូក១៣។ (ស្រឡាញ់តែងតែអត់ធ្មត់ ជួយធុរៈគេ ហើយមិនចេះឈ្នានីសគេទេ។ អ្នកមានចិត្តស្រឡាញ់មិនវាយឫកខ្ពស់ មិនអួតបំប៉ាងឡើយ។ អ្នកមានចិត្តស្រឡាញ់ មិនប្រព្រឹត្តអំពើថោកទាប មិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន មិនមួម៉ៅ មិនចងគំនុំ មិនអបអរនឹងអំពើទុច្ចរិតទេ តែរីករាយនឹងសេចក្តីពិតវិញ។ អ្នកមានចិត្តស្រឡាញ់ អត់ឱនអោយទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ ហើយទ្រាំទ្រទាំងអស់។សេចក្តីស្រឡាញ់មិនសាបសូន្យសោះឡើយ។)

៨ ក) មើលទៅហាក់បីដូចជាស្ថិតស្ថេរគង់វង្សណាស់ ប៉ុន្តែមិនមែនជាការពិតទេ។

២ តើចម្លើយរបស់អ្នកបង្ហាញឲ្យឃើញពីបញ្ហាណាមួយជាមួយនឹងភាពលោភលន់នៅក្នុងជីវិតរបស់អ្នកដែរឬទេ? ប្រសិនបើមាន ខ្ញុំសូមណែនាំឲ្យអ្នក ធ្វើតាមជំហានក្នុងការដោះស្រាយបញ្ហាជាមួយចិត្តស្មោះត្រង់ ដើម្បីកែតម្រូវបញ្ហានេះ និង បង្កើតវិធីសាបថដែលត្រឹមត្រូវផងដែរ។ ជំហានទាំងនេះមានផ្តល់ជូនរួចហើយ នៅក្នុងមេរៀនទី៣។

៩ ក) ៦) ត្រូវដាក់ព្រះគ្រិស្ត និង អាណាចក្ររបស់ទ្រង់ជាទីមួយនៅក្នុងជីវិតរបស់អ្នក។

ខ) ៨) ចាត់ទុកខ្លួនអ្នកជា អ្នកបម្រើ ។ មិនត្រូវមានមោទនភាពជាមួយលុយរបស់អ្នកឡើយ តែជាមួយនឹងតំណែងតូចទាបរបស់អ្នកវិញ។

គ) ៤) ត្រូវខ្វល់ខ្វាយពីរបស់ដែលមានតម្លៃអស់កល្បជានិច្ច ជាងទ្រព្យសម្បត្តិនៅក្នុងលោកីយ៍ ដ្បិតទ្រព្យសម្បត្តិរបស់អ្នកនៅទីណា ចិត្តរបស់អ្នកនៅទីនោះ។

ឃ) ២) មនុស្សរបស់ព្រះជាម្ចាស់គួរជៀសឲ្យផុតពីបញ្ហានេះ ហើយតាមស្វែងរកអ្វីដែលជារបស់ព្រះជាម្ចាស់។

ង) ១) ទុកចិត្តព្រះជាម្ចាស់ ស្វែងរកព្រះរាជ្យ និង ភាពសុចរិតរបស់ទ្រង់ជាមុន ហើយទ្រង់នឹងផ្គត់ផ្គង់តម្រូវការប្រចាំថ្ងៃរបស់អ្នក។

ច) ៧) ព្រះជាម្ចាស់នឹងប្រទាននំប៉័ង និង ទឹកឲ្យអ្នក។ (ទ្រង់នឹងប្រទានអ្វីៗទាំងអស់ដែលយើងត្រូវការ។)

ឆ) ៣) ត្រូវអរព្រះគុណព្រះជាម្ចាស់សម្រាប់តំណែងដ៏ខ្ពស់ជាកូនរបស់ព្រះជាម្ចាស់ និង ជាអ្នកបម្រើរបស់ទ្រង់។

ជ) ៥) ការគោរពកោតខ្លាចព្រះជាម្ចាស់គឺមិនផ្អែកទៅតាមទ្រព្យសម្បត្តិនៅលើផែនដីនោះទេ។

៣ ក), គ), ឃ), ច) និង ជ) ជាចម្លើយត្រឹមត្រូវ។

១០ ក) ទ្រង់នឹងបំពេញតម្រូវការរបស់អ្នក។

ខ) ប្រសិនបើអ្នកដាក់ព្រះរាជ្យព្រះជាម្ចាស់ជាទីមួយនៅក្នុងជីវិតរបស់អ្នក ទ្រង់នឹង ប្រទានអ្វីទាំងអស់ដែលអ្នកត្រូវការ។

គ) ទ្រង់នឹងមិនទុកអ្នកចោល និង មិនបោះបង់អ្នកចោលឡើយ។

៤ ចម្លើយ ខ) បង្ហាញពីអ្វីដែលព្រះយេស៊ូបានបង្រៀនយ៉ាងច្បាស់លាស់។ ប្រយោគពីរផ្សេងទៀតគឺតំណាងឲ្យឥរិយាបថរឹងចចេស និង ខុសឆ្គង។

១១ ក) បរិមាណទ្រព្យសម្បត្តិដែលខ្ញុំមានក្នុងពេលនេះ នឹងគ្មានតម្លៃអ្វីសម្រាប់ខ្ញុំ នៅថ្ងៃដែល ព្រះជាម្ចាស់វិនិច្ឆ័យទោសខ្ញុំនោះទេ។

ខ) ព្រះជាម្ចាស់ទាមទារឲ្យទាំងអ្នកមាន និង អ្នកក្រធ្វើជាអ្នកទទួលខុសត្រូវដ៏ល្អសម្រាប់ទ្រព្យសម្បត្តិរបស់ទ្រង់។

គ) ព្រះជាម្ចាស់តម្រូវថាទ្រង់ត្រូវផ្គត់ផ្គង់តម្រូវការរបស់អ្នកណាដែលទុកព្រះរាជ្យរបស់ព្រះអង្គជាទីមួយនៅក្នុងជីវិតរបស់គេ។

ឃ) យើងត្រូវដាក់ព្រះជាម្ចាស់ជាទីមួយ នៅក្នុងជីវិតរបស់យើង បន្ទាប់មកទុកចិត្តថាទ្រង់នឹងថែរក្សាយើង។

ង) គ្រិស្តបរិស័ទទាំងអស់ ទាំងអ្នកមាន និង អ្នកក្រ ត្រូវតែមានចិត្តសប្បុរស។

៥ ក) ៨. និយាយតែសេចក្តីពិត

ខ) ៥. មិនត្រូវធ្វើអំពើបាប។ មិនត្រូវប្រកាន់ខឹង។

គ) ១១. ឈប់លួច ហើយចាប់ផ្តើមធ្វើការងារ។ ផ្គត់ផ្គង់ខ្លួនអ្នក និង ជួយដល់អ្នកក្រីក្រ។

ឃ) ៩. ប្រើពាក្យល្អមានប្រយោជន៍។

ង) ១. កុំធ្វើអោយព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ព្រួយព្រះហឫទ័យ។

ច) ៦. ត្រូវមានចិត្តសប្បុរស ចេះអាណិតមេត្តាដល់គ្នាទៅវិញទៅមក ត្រូវប្រណីសន្តោសគ្នាទៅវិញទៅមក ឲ្យសេចក្តីស្រឡាញ់ដឹកនាំ។

ឆ) ៤. បំពេញគំនិតរបស់អ្នកដោយការសរសើរតម្កើង និង អរព្រះគុណ។

ជ) ២. កុំទាក់ទងជាមួយមនុស្សបែបនោះ។ ត្រូវបកអាក្រាតពួកគេ។

ឈ) ១០. រស់នៅជាមនុស្សដែលមានប្រាជ្ញា ។ ប្រើប្រាស់ឱកាសទាំងប៉ុន្មានឲ្យមានប្រយោជន៍។

ញ) ៣. ព្យាយាមស្វែងរកអ្វីដែលព្រះអម្ចាស់សព្វព្រះហឫទ័យឲ្យអ្នកធ្វើ។

ដ) ៧. មិនត្រូវស្រវឹងស្រា ប៉ុន្តែត្រូវពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធវិញ។

១២ ចម្លើយរបស់អ្នក។ ចម្លើយនោះគួរតែរួមបញ្ចូលគោលគំនិតនេះផង៖ គ្រិស្តបរិស័ទអាចឆ្លើយតប តាមរបៀបដូចជាព្រះគ្រិស្ត ទៅចំពោះភាពអយុត្តិធម៌ ដោយចងចាំថា ពួកគេជាអ្នកតំណាងព្រះវរបិតានៃស្ថានបរមសុខរបស់ពួកគេ ដែលទ្រង់ចាំមើលថែរក្សាពួកគេជានិច្ច។

៦ ខ) សារភាពបាប ទទួលជឿ និង ការធ្វើតាម ហើយដោះស្រាយបញ្ហាអំពើបាបមុនគេបង្អស់។

១៣ ចម្លើយរបស់អ្នក។

មេរៀនទី ៥ បញ្ហាគ្រួសារ

គ្រូបង្រៀនថ្នាក់ថ្ងៃអាទិត្យម្នាក់បានព្យាយាមជួយ សិស្សដែលមានអាយុប្រាំបីឆ្នាំម្នាក់របស់នាង ឲ្យបានយល់ថា ឋានសួគ៌មានលក្ខណៈយ៉ាងដូចម្តេច។ នាងបានធ្វើការសន្និដ្ឋាន ដោយនិយាយថា "អ្នកគ្រូចូលចិត្តប្រៀបធៀបស្ថានសួគ៌ទៅនឹងផ្ទះ របស់អ្នកគ្រូ ដែលវាជាកន្លែងពោរពេញដោយសេចក្តីស្រឡាញ់ និងជាកន្លែងដែលអ្នកគ្រូអាចរកបានសន្តិភាព និង ទទួលស្គាល់។ ប្រាកដណាស់ ឋានសួគ៌ គឺដូចជានៅផ្ទះដែរ។

មានក្មេងប្រុសម្នាក់បានមើលទៅកាន់នាងទាំងបើកភ្នែកធំៗ ហើយឆ្លើយតបវិញថា៖ "ប្រសិនបើឋានសួគ៌ដូចជាផ្ទះរបស់ខ្ញុំមែន ខ្ញុំមិនចង់ទៅទីនោះទេ!"

គ្រួសារគឺជាព្រះតម្រិះរបស់ព្រះជាម្ចាស់តាំងពីមុនការបង្កើតពិភពលោកនេះទៅទៀត។ លំដាប់លំដោយនៅក្នុងសង្គម និង នៅក្នុងក្រុមជំនុំគឺយោងទៅតាមលំដាប់លំដោយនៅក្នុងគ្រួសារ។ ព្រះជាម្ចាស់បានប្រទានវិន័យយ៉ាងជាក់លាក់ សម្រាប់ទំនួលខុសត្រូវរបស់ប្តី របស់ប្រពន្ធ និង របស់កូនៗ។ នៅពេលដែលវិន័យត្រូវបានគេធ្វើតាម ក្រុមគ្រួសារក៏បានរឹងមាំ ហើយសមាជិកគ្រប់រូបត្រូវបានបំពេញឲ្យបរិបូរណ៌ និង សប្បាយរីករាយ។ ប៉ុន្តែនៅពេលដែលវិន័យទាំងនេះត្រូវបានគេមិនអើពើរ គ្រួសារប្រាកដជាមានបញ្ហា ហើយអាចនឹងត្រូវបែកបាក់គ្នាថែមទៀតផង។

នៅក្នុងប្រទេសជាច្រើននៅលើពិភពលោកសព្វថ្ងៃនេះ គ្រួសារជាច្រើនកំពុងតែមានបញ្ហាពិតប្រាកដមែន។ នៅប្រទេសខ្លះ ចំណងអាពាហ៍ពិពាហ៍ជាង ៥០ភាគរយ ត្រូវបានបញ្ចប់ដោយការលែងលះគ្នា។ នៅក្នុងប្រទេសផ្សេងទៀត តំណែងជាប្រពន្ធ ស្ទើរតែទាបជាងអ្នកបម្រើទៅទៀត។ កូនៗដែលធំពេញវ័យនៅក្នុងគ្រួសារដ៏ក្រៀមក្រំបែបនេះ គឺអាចនឹងបង្កើតក្រុមគ្រួសារប្រភេទដូចគ្នានោះដែរ នៅពេលដែលពួកគេរៀបការ។ តើមានបញ្ហាអ្វីខ្លះដែល បំផ្លាញក្រុមគ្រួសារ ហើយតើព្រះគម្ពីរបានថ្លែងយ៉ាងដូចម្តេចអំពីបញ្ហាទាំងនោះ? នោះគឺជាប្រធានបទរបស់យើងនៅក្នុងមេរៀនទី៥នេះ ។ ប្រសិនបើឋានសួគ៌ក៏ដូចជាផ្ទះយ៉ាងដូច្នោះដែរ តើអ្នកចង់ទៅទីនោះដែរឬទេ? យើងខ្ញុំសូមលើកទឹកចិត្តលោកអ្នកឲ្យធ្វើការអនុវត្ត ដោយផ្ទាល់ខ្លួនទៅតាមការគួរ នៅពេលដែលអ្នកធ្វើការសិក្សាមេរៀននេះ។

គម្រោងមេរៀន

ក) បញ្ហារវាងប្តី និង ប្រពន្ធ
ខ) បញ្ហារបស់កូនៗ
គ) ដំណោះស្រាយនៅក្នុងព្រះគម្ពីរសម្រាប់បញ្ហានៅក្នុងគ្រួសារ

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. ប្រាប់ពីគោលការណ៍ពីរយ៉ាងដែលនឹងជួយដោះស្រាយបញ្ហាបណ្តាលមកពី ភាពខុសគ្នាខាងឯវិញ្ញាណរវាងប្តី និង ប្រពន្ធ។
២. ស្គាល់ពីតរិយាបថដែលនឹងជួយឲ្យប្តីប្រពន្ធដែលបានរៀបការហើយ ដោះស្រាយបញ្ហាតម្រូវការខាងផ្លូវភេទដែលខុសគ្នា បានយ៉ាងជោគជ័យ។
៣. ជ្រើសរើសយកការថ្លែងអំពីរបៀបដែលគ្រិស្តបរិស័ទគួរតែឆ្លើយតប នៅក្នុងករណីអំពើសហាយស្មន់ ដែលស្របជាមួយសេចក្តីបង្រៀនរបស់ព្រះគម្ពីរ។
៤. ប្រាប់ពីវិន័យទូទៅសម្រាប់ ការលែងលះគ្នាដែលយកទៅអនុវត្តជាមួយគ្រិស្តបរិស័ទ។
៥. ផ្សារភ្ជាប់ស្ថានភាពនៃបញ្ហាទៅនឹងដំណោះស្រាយត្រឹមត្រូវសម្រាប់បញ្ហានីមួយៗ។
៦. ជ្រើសរើសការថ្លែងដែល សង្ខេបយ៉ាងខ្លីៗអំពីតរិយាបថដែលឪពុកម្តាយគួរតែមាន នៅក្នុងការបណ្តុះបណ្តាលកូនៗរបស់ពួកគេ។
៧. សង្ខេបនៅក្នុងតារាងមួយ អំពីហានៈ និង ទំនួលខុសត្រូវរបស់សមាជិកម្នាក់ៗនៅក្នុងគ្រួសារ។

សកម្មភាពក្នុងការសិក្សា

១. សិក្សាតាមដំណើរវិវត្តនៃមេរៀន ដូចដែលអ្នកធ្លាប់ធ្វើ។ ត្រូវធ្វើឲ្យប្រាកដថា អ្នកបានអានខគម្ពីរទាំងប៉ុន្មានបានដាក់ឲ្យ និង បានចម្លើយសំណួរសិក្សានីមួយៗឲ្យរួចស្រេច មុនពេលបើកមើលចម្លើយដែលយើងបានផ្តល់ជូន។
២. បើកមើលនៅក្នុងអក្ខរានុក្រម សម្រាប់និយមន័យពាក្យសំខាន់ណាដែលអ្នកមិនទាន់បានស្គាល់។
៣. ធ្វើការប្រឡងផ្ទាល់ខ្លួន និង ផ្ទៀតផ្ទាត់ចម្លើយរបស់អ្នក។

ពាក្យសំខាន់

វ័យជំទង់	បង្អាប់	ប្តីប្រពន្ធ
បន្ទោកតម្លៃ	បណ្តោយតាម	រចនាសម្ព័ន្ធ
ភាពម៉ឺងម៉ាត់	ភាពធឹតក្បត់	ការចុះចូល
ជម្លោះ	ការបំបិទ	ជនរងគ្រោះ
រំខាន	រឹតបន្តឹង	ផ្ទឹម
បង្កកំហឹង		

ក) បញ្ហារខាងប្តី និង ប្រពន្ធ

យើងមិនអាចរៀបរាប់ និងស្វែងរកដំណោះស្រាយសម្រាប់បញ្ហាទាំងអស់ ដែលមាននៅក្នុងគ្រួសារ នៅក្នុងមេរៀនដ៏ខ្លីនេះបានឡើយ។ នៅក្នុងការពិភាក្សារបស់យើងអំពីទំនាក់ទំនងសង្គម យើងបាន និយាយរួចហើយអំពី បញ្ហាជាច្រើនផ្នែកដែលអាចយកទៅអនុវត្តនៅក្នុងស្ថានភាពគ្រួសារផងដែរ។ យើងនឹងខំប្រឹង ពិភាក្សាបញ្ហាដែលមានជាពិសេសសម្រាប់គ្រួសារនៅក្នុងមេរៀននេះ ព្រមទាំងស្វែងរកគោលការណ៍នៅក្នុងព្រះគម្ពីរដែលអាចផ្តល់ការណែនាំសម្រាប់បញ្ហានីមួយៗ។ ដំបូង យើងនឹងចូលទៅមើលអំពីបញ្ហាធ្ងន់ធ្ងរ ខ្លះទៀតដែលអាចកើតឡើងរវាងប្តី និង ប្រពន្ធ។

ភាពខុសគ្នាខាងឯវិញ្ញាណ

វត្ថុបំណងទី១. *ប្រាប់ពីគោលការណ៍ពីរយ៉ាងដែលនឹងជួយដោះស្រាយបញ្ហាបណ្តាលមកពីភាពខុសគ្នាខាងឯវិញ្ញាណរវាងប្តី និង ប្រពន្ធ។*

បញ្ហាកើតឡើងនៅក្នុងចំណងអាពាហ៍ពិពាហ៍ ព្រោះមានដៃគូម្ខាងគឺជាគ្រិស្តបរិស័ទ ហើយម្ខាងទៀតមិនមែនជាគ្រិស្តបរិស័ទ។ ជាច្រើនលើក គ្រិស្តបរិស័ទដែល បានរៀបការជាមួយនឹងអ្នកមិនជឿ គេគិតថា ក្រោយពីពួកគេបានរៀបការហើយ គេនឹងអាចនាំ ប្តីឬប្រពន្ធរបស់គេចូលទៅកាន់ព្រះអម្ចាស់បាន។ ប្រហែលជាប្តី ឬ ប្រពន្ធ បានក្លាយជាគ្រិស្តបរិស័ទក្រោយពេលដែលពួកគេបានរៀបការហើយ ប៉ុន្តែដៃគូម្ខាងទៀតមិនផ្លាស់ប្រែចិត្តដែរនោះទេ។ បញ្ហាដែលកើតឡើងពីស្ថានភាពបែបនេះគឺ ធ្ងន់ធ្ងរណាស់៖ ដៃគូដែលជាគ្រិស្តបរិស័ទ ចង់បានអ្វីដែលជារបស់ព្រះជាម្ចាស់ ចង់ចូលរួមថ្វាយបង្គំនៅព្រះវិហារ និង អភិវឌ្ឍភាពពេញវ័យជាគ្រិស្តបរិស័ទ ស្របពេលដែលដៃគូមិនទាន់បានទទួលការ
សង្គ្រោះ គឺត្រូវបានអូសទាញដោយការសប្បាយ និង ការចូលរួមជាមួយលោកីយ៍។ វាក៏មានការរំខានដល់ការចិញ្ចឹមបីបាច់ថែរក្សាកូនផងដែរ ហើយកូនៗប្រហែលជាមិនអាចទទួលយកព្រះគ្រិស្ត ជាព្រះអង្គសង្គ្រោះរបស់ពួកគេផងដែរ ដោយសារតែមានគំរូពីឪពុកម្តាយដែលមិនមែនជាគ្រិស្តបរិស័ទ។ មានពេលខ្លះអ្នកមិនជឿក៏អូសទាញដៃគូដែលជាគ្រិស្តបរិស័ទ ឲ្យចេញឆ្ងាយពីជំនឿលើព្រះជាម្ចាស់ ហើយនាំចូលទៅក្នុងអំពើបាប។

ប្រាកដណាស់ ដំណោះស្រាយដែលល្អបំផុតសម្រាប់បញ្ហានេះ ឬ បញ្ហាផ្សេងទៀត គឺត្រូវជៀសឲ្យផុតពីវា។ ការរៀបការជាមួយអ្នកមិនជឿត្រូវបានហាមប្រាម យោងទៅតាមគម្ពីរ២កូរិនថូស ៦:១៤-១៨៖

> សូមកុំសេពគប់ជាមួយអ្នកមិនជឿឡើយ។ តើសេចក្តីសុចរិត និងសេចក្តីទុច្ចរិតចូលរួមជាមួយគ្នាកើតឬទេ? តើពន្លឺ និងភាពងងឹត ចូលរួមជាមួយគ្នាកើតឬទេ? តើព្រះគ្រិស្ត* និងមារ*សាតាំងចុះសំរុងគ្នាកើតឬទេ? តើអ្នកជឿ និងអ្នកមិនជឿមានទំនាក់ទំនងអ្វីនឹងគ្នា? តើព្រះវិហារ*របស់ព្រះជាម្ចាស់ និងព្រះក្លែងក្លាយចូលគ្នាចុះឬទេ? យើងទាំងអស់គ្នាជាព្រះវិហាររបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មរស់ ។

លំហាត់អនុវត្តន៍

១. តើចម្លើយមួយណានៅខាងក្រោមនេះ មួយណាដែលអ្នកគិតថា ជាចម្លើយល្អបំផុតសម្រាប់សំណួរដែលយើងទើបនឹងបានអាន។

ក) វាអាចមានការព្រមព្រៀងខ្លះៗសម្រាប់ឧទាហរណ៍នីមួយៗ។

ខ) វាមិនអាចមានការព្រមព្រៀងបាននោះទេ រវាងរឿងទាំងនេះ ព្រោះរឿងនីមួយមានតម្លៃផ្ទុយគ្នា។

គ) ដរាបណា មានការគោរពតាមបែបបទគ្នាទៅវិញទៅមក រឿងទាំងនេះអាចធ្វើការជាមួយគ្នាបាន។

ប្រាកដណាស់ ចម្លើយចំពោះសំណួរទាំងនេះគឺថា ត្រូវ និង ខុស ពន្លឺ និង ភាពងងឹត ព្រះគ្រិស្ត និង សាតាំង មិនអាចចុះសង្រុងគ្នា ឬ ធ្វើជាដៃគូគ្នាបានឡើយ។ អ្នកជឿម្នាក់ និង អ្នកមិនជឿម្នាក់គ្មានអ្វីដែលដូចគ្នា ក្រៅតែពីតម្រូវការមូលដ្ឋានជាមនុស្សតែប៉ុណ្ណោះ។ មនុស្សមានវ័យក្មេង គេចង់រៀបការខ្លាំងពេក គេសុខចិត្តមើលរំលងអ្វីជាដែលការបង្រៀនដ៏សំខាន់នៅក្នុងព្រះគម្ពីរ គឺការបើកទ្វារជីវិតរបស់គេទទួលជីវិតដែលខ្ជោចចិត្ត និង ប្រកបដោយបញ្ហា។ ផ្លូវរបស់ព្រះជាម្ចាស់គឺ ជាផ្លូវដែលល្អបំផុត ហើយព្រះនឹងផ្គត់ផ្គង់គ្រប់តម្រូវការរបស់យើង ប្រសិនបើយើងនឹងស្តាប់បង្គាប់ទ្រង់។ យើងនឹងនិយាយអំពីរឿងនេះបន្ថែមទៀតនៅក្នុងមេរៀនបន្ទាប់ ដែលទាក់ទងនឹងការដោះស្រាយបញ្ហារបស់អ្នកដែលមិនទាន់រៀបការ។

សម្រាប់គ្រិស្តបរិស័ទដែលបានរៀបការជាមួយនឹងអ្នកមិនជឿហើយ ប្រហែលជាបានរៀបការតាំងពីមុនពេលដែលគាត់ក្លាយជាគ្រិស្តបរិស័ទទៅទៀត ។ លោកសាវ័កប៉ូលបានផ្តល់ការណែនាំពិសេសខ្លះៗនៅក្នុងគម្ពីរ១កូរិនថូស ៧:១២-១៦ ។ លោកប៉ូលបានលើកទឹកចិត្តគ្រិស្តបរិស័ទឲ្យបន្តជាមួយនឹងអាពាហ៍ពិពាហ៍នោះ ដរាបណា ដៃគូដែលមិនគោរពប្រណិបត្តិព្រះជាម្ចាស់នោះគឺសុខចិត្តនៅបន្តអាពាហ៍ពិពាហ៍នោះ។ គ្រិស្តបរិស័ទ មិនត្រូវជាម្នាក់ដែលចាក់ចេញនោះទេ។ សាជាថ្មីម្តងទៀត ព្រះជាម្ចាស់អាចប្រទាន ព្រះគុណ និងក្តីស្រឡាញ់ ដែលយើងត្រូវការ មាននរណាទៅដឹង? អ្នកមិនជឿ អាចត្រូវបានសង្គ្រោះនៅក្នុងពេលណាមួយ។ "បើគូស្រករដែលមិនជឿ ចាកចោលបងប្អូនដែលជាអ្នកជឿ អោយគេទៅចុះ បងប្អូនប្រុស ឬស្រីនោះគ្មានកំហុសអ្វីក្នុងរឿងនេះទេ។ ព្រះជាម្ចាស់បានត្រាស់ហៅយើងអោយមករស់ក្នុងសេចក្តីសុខសាន្ត" (គម្ពីរ១កូរិនថូស៧:១៥)។

លំហាត់អនុវត្តន៍

២ ហេតុអ្វីបានជាអ្នកគិតថាគ្រិស្តបរិស័ទត្រូវបានណែនាំឲ្យបន្តរស់នៅជាមួយអ្នកមិនជឿនៅក្នុងករណីមួយដែលយើងបានរៀបរាប់ខាងលើ? (សូមមើលគម្ពីរ ម៉ាថាយ ១៩:៤-៦)

.....

នៅក្នុងគ្រួសារជាច្រើន ម្តាយត្រូវតែទទួលទំនួលខុសត្រូវធ្វើជាអ្នកដឹកនាំខាងឯព្រលឹងវិញ្ញាណ។ នេះមិនមែនជាស្ថានភាពមួយដែលល្អនោះទេ ដ្បិតព្រះជាម្ចាស់បានបង្កើតប្តីឲ្យធ្វើជាក្បាលរបស់គ្រួសារ ព្រមទាំងធ្វើជាអ្នកដឹកនាំខាងឯវិញ្ញាណផងដែរ។ កូនៗតែងតែមើលទៅកាន់គំរូឪពុករបស់គេ ហើយឪពុកមិនអាចរំពឹងថាគ្រួសាររបស់គេនឹងអាចមានកម្រិតខាងឯវិញ្ញាណខ្ពស់ជាងគាត់បាន ឡើយ។

បញ្ហា ខាងឯវិញ្ញាណនៅក្នុងគ្រួសារអាចត្រូវបានដោះស្រាយដោយ ការស្តាប់បង្គាប់តាមគោលការណ៍បទគម្ពីរតែប៉ុណ្ណោះ។ នៅក្នុងផ្នែកចុងក្រោយ នៃមេរៀននេះ យើងនឹងពិភាក្សាអំពីគោលការណ៍របស់គ្រិស្តបរិស័ទសម្រាប់គ្រួសារ។ ប្រសិនបើអ្នកមានបញ្ហានៅក្នុងផ្នែកនេះនៃជីវិតគ្រួសាររបស់អ្នក អ្នកអាចផ្លាស់ប្តូរវាបានដោយការយកគោលការណ៍ទាំងនេះទៅអនុវត្តនៅក្នុងជីវិតរបស់អ្នកផ្ទាល់។

លំហាត់អនុវត្តន៍

---

៣ យើងអាចត្រឹមតែពិភាក្សា អំពីគោលការណ៍មូលដ្ឋាន២យ៉ាងប៉ុណ្ណោះ ដែលនឹងជួយកែតម្រូវ ឬ បញ្ឈៀសភាពខុសគ្នាខាងឯវិញ្ញាណរវាងប្តី និង ប្រពន្ធ ។ ចូរថ្លែងអំពីគោលការណ៍ដោយប្រើពាក្យរបស់អ្នកផ្ទាល់។

ក) .....

.....

ខ) .....

.....

តម្រូវការខុសគ្នាខាងឯផ្លូវភេទ

វត្ថុបំណងទី២. *ស្គាល់ពីវិធីបែបផែនដែលនឹងជួយឲ្យប្តីប្រពន្ធដែលបានរៀបការហើយ ដោះស្រាយបញ្ហាតម្រូវការខាងផ្លូវភេទដែលខុសគ្នា បានយ៉ាងជោគជ័យ។*

ពេលខ្លះនៅក្នុងចំណងអាពាហ៍ពិពាហ៍ តម្រូវការទំនាក់ទំនងផ្លូវភេទរបស់ដៃគូម្នាក់ មានច្រើនជាងម្នាក់ទៀត។ ការបដិសេធ មិនឲ្យមានទំនាក់ទំនងផ្លូវភេទ គឺផ្ទុយនៅបទគម្ពីរ លើកលែងតែមានការព្រមព្រៀងគ្នាទៅវិញទៅមក (សូមមើលនៅក្នុងគម្ពីរ១កូរិនថូស៧:៥) និងក្នុងរយៈពេលខ្លីមួយតែប៉ុណ្ណោះ។ ប្តី និង ប្រពន្ធដែលចង់ផ្គាប់តាមបំណងគ្នាទៅវិញទៅមក នឹងចុះចូលចំពោះគ្នាទៅវិញទៅមក ដោយយោងទៅតាមសេចក្តីបង្រៀនក្នុងព្រះគម្ពីរ (សូមមើលគម្ពីរ១កូរិនថូស ៧:៣-៤)។ នៅក្នុងពេលជាមួយគ្នានោះដែរ ដៃគូទាំងសងខាងនឹងមានអារម្មណ៍ដឹងពីតម្រូវការផ្សេងទៀតរបស់ដៃគូ ចំពោះការសំដែងក្តីស្រឡាញ់ និង មេត្រីភាព ដែលមិនផ្តោតទៅលើតែទំនាក់ទំនងខាងផ្លូវភេទនោះទេ។

ជីវិតខាងផ្លូវភេទ នៅក្នុងអាពាហ៍ពិពាហ៍ នឹងត្រូវលើកយកទៅពិភាក្សាបន្ថែមទៀតឲ្យបានពេញលេញ នៅក្នុងមេរៀនទី៧។ ប្តីប្រពន្ធរៀបការរួច ដែលធ្វើតាមសេចក្តីបង្រៀនរបស់ព្រះគម្ពីរនៅក្នុងប្រការនេះ នឹងឃើញថា ការបំពេញខាងផ្លូវភេទ នៅក្នុងអាពាហ៍ពិពាហ៍ ជួយនាំឲ្យមានការរួបរួមគ្នា សម្រាប់បញ្ហាក្នុងផ្នែកផ្សេងៗទៀតដែរ។

លំហាត់អនុវត្តន៍

---

៤ តើឥរិយាបថមួយណា នៅខាងក្រោមនេះ ដែលអាចជួយប្តីប្រពន្ធដែលបានរៀបការរួច ដោះស្រាយបញ្ហានៃភាពខុសគ្នាក្នុងតម្រូវការខាងផ្លូវភេទបាន?

ក) ប្រពន្ធត្រូវតែចុះចូលជានិច្ច។

ខ) មានបំណងចង់បំពេញឲ្យគ្នាទៅវិញទៅមក។

គ) កាត់បន្ថយទំនាក់ទំនងផ្លូវភេទ ដោយការព្រមព្រៀងគ្នាទៅវិញទៅមក។

ភាពមិនស្មោះត្រង់

វត្ថុបំណងទី៣. *រុជ្រាវរឿងសិយកការថ្លែងអំពីរបៀបដែលគ្រិស្តបរិស័ទគួរតែឆ្លើយតប នៅក្នុងករណីអំពើសហាយស្មន់ ដែលស្របជាមួយសេចក្តីបង្រៀនរបស់ព្រះគម្ពីរ។*

បញ្ហាដែលប្រហែលជាការគំរាមកំហែងដល់អាពាហ៍ពិពាហ៍ខ្លាំងបំផុតគឺភាពមិនស្មោះត្រង់ (ការមិនស្មោះត្រង់រឿងផ្លូវភេទ ឬ អំពើសហាយស្មន់)។ បញ្ហានេះ នឹងត្រូវយកទៅពិភាក្សានៅក្នុងមេរៀនទី ៧។ អំពើសហាយស្មន់ គឺត្រូវបានហាមឃាត់ដាច់ខាត នៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ និង សម្ពន្ធមេត្រីថ្មី ដូចដែលយើងបានឃើញនៅក្នុងមេរៀនទី២ យ៉ាងដូច្នោះដែរ។ នៅក្នុងមេរៀននេះ យើងចង់មើលទៅកាន់បញ្ហានេះតាមរយៈការយល់ឃើញរបស់ដៃគូដែលរងគ្រោះ ឬ ដែលត្រូវបានបំពាន។ តើអ្នកគួរឆ្លើយតបយ៉ាងដូចម្តេច ប្រសិនបើដៃគូរបស់អ្នកបានប្រព្រឹត្តអំពើសហាយស្មន់? តើអ្នកគួរតែសម្រេចចិត្ត លែងលះគ្នាភ្លាមៗ មែនឬទេ? តើអ្នកគួរតែបន្តចំណងអាពាហ៍ពិពាហ៍នោះទៀតទេ ប្រសិនបើការបំពាននោះនៅតែបន្តកើតឡើងម្តងហើយម្តងទៀតនោះ? នៅក្នុងបញ្ហានេះ មានបីផ្នែកដែលយើងចង់ធ្វើការពិចារណា៖

១. ប្រសិនបើ ប្តីប្រពន្ធដែលបានរៀបការហើយ នៅតែបន្តប្រព្រឹត្តអំពើសហាយស្មន់ តើអ្នកនៅតែមានតួនាទីបន្តរស់នៅក្នុងចំណងអាពាហ៍ពិពាហ៍នោះទៀតដែរឬទេ? យោងទៅតាមព្រះបន្ទូលរបស់ព្រះយេស៊ូនៅក្នុងគម្ពីរ ម៉ាថាយ១៩:៩ ការលែងលះ គឺត្រូវបានអនុញ្ញាតឲ្យធ្វើ នៅក្នុងករណីមានអំពើសហាយស្មន់ ៖ "ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា បុរសណាលែងភរិយា(លើកលែងតែរួមរស់ជាមួយគ្នា ដោយឥតបានរៀបការ) ហើយទៅរៀបការនឹងស្ត្រីម្នាក់ទៀត បុរសនោះឯងជាអ្នកប្រព្រឹត្តអំពើផិតក្បត់"។ ដូច្នេះ ប្តី ឬប្រពន្ធ គឺគ្មានកាតព្វកិច្ចអ្វី នឹងត្រូវបន្តរស់នៅជាមួយនឹងដៃគូដែលគ្មាន ភាពស្មោះត្រង់។

២. ប្រសិនបើចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ដោយសារតែភាពមិនស្មោះត្រង់ តើភាគីដែលត្រូវបានគេបំពាន អាចរៀបការម្តងទៀតបានដែរឬទេ? អ្នកប្រាជ្ញព្រះគម្ពីរ មិនមានការយល់ស្រប គ្នា

លើការបកស្រាយបទគម្ពីរដែលទាក់ទងនឹងរឿងនេះឡើយ។ យោងទៅតាមអ្នកប្រាជ្ញខ្លះ ព្រះបន្ទូលរបស់ព្រះយេស៊ូនៅក្នុង គម្ពីរម៉ាថាយ១៩:៩ បានអនុញ្ញាតឲ្យរៀបការម្តងទៀតនៅក្នុងករណីនេះ។ ការបកស្រាយរបស់ពួកគេគឺថា នៅពេលដែលមនុស្សម្នាក់បានប្រព្រឹត្តអំពើសហាវស្មន់ គេបានរំលាយចំណងដែលធ្វើឲ្យគេជា "សាច់ឈាម" តែមួយជាមួយដៃគូរបស់គេហើយ។ ដូច្នេះ ដៃគូរបស់គេមិនជាប់នឹងចំណងនោះទៀតឡើយ។ ប្រសិនបើនេះជាការពិតមែន ភាគី ដែលត្រូវបានគេបំពាន់នោះ អាចមានសេរីភាពក្នុងការរៀបការជាមួយនឹងមនុស្សម្នាក់ទៀត ដែលមិនស្ថិតនៅក្នុងចំណងនៃអាពាហ៍ពិពាហ៍បាន។ការបកស្រាយមួយទៀតនោះគឺថា ការលែងលះគ្នា ត្រូវបានអនុញ្ញាតនៅក្នុងករណីមានអំពើសហាយស្មន់ ប៉ុន្តែមិនអនុញ្ញាតឲ្យមានការ រៀបការម្តងទៀតនោះទេ។ យើងនឹងពិភាក្សាចំណុចនេះបន្ថែមទៀត នៅក្នុងប្រធានបទ *ការលែង លះគ្នា* ។

៣. មានរឿងជាច្រើនអាច ចូលរួមធ្វើឲ្យមានអំពើសហាយស្មន់បាន។ ដៃគូ ប្តីប្រពន្ធ ខ្លះអាចបដិសេធមិនព្រមមានទំនាក់ទំនងផ្លូវភេទជាមួយដៃគូរបស់ខ្លួន ដូច្នេះវាធ្វើឲ្យគាត់ត្រូវស្វែងរកនៅកន្លែងផ្សេងដើម្បីបំពេញតម្រូវការរបស់គាត់។ ឬមានពេលខ្លះ ដៃគូដែលមិនបានប្រុងប្រយ័ត្នខាងឯវិញ្ញាណរបស់ពួកគេ បានចុះចូលជាមួយនឹងការល្បួង។ ប្រាកដណាស់ ព្រះជាម្ចាស់មិនលើកលែងឲ្យអំពើណាមួយឡើយ ហើយអំពើទាំងពីរនោះសុទ្ធតែជាអំពើបាប។ ប៉ុន្តែ ឧបមាថា ភាគីដែលមិនស្មោះត្រង់នោះបានសារភាព និងពិតជាសោកស្តាយចំពោះអំពើបាបរបស់គេពិតមែន ហើយថែមទាំងសុំការអត់ទោសផងនោះ។ តើភាគីដែលត្រូវបានគេបំពាន គួរតែលើកលែងទោស និង ចាប់ផ្តើមចំណងទំនាក់ទំនងនោះសាជាថ្មីដែរឬទេ?

នេះប្រហែលជាកំហុស ពិបាកលើកលែងឲ្យខ្លាំងណាស់ សម្រាប់អ្នកណាដែលអាចនឹងឆ្លងកាត់នៅក្នុងជីវិតរបស់គេ។ ក្តីឈឺចាប់នៃ ទំនុកចិត្តដែលត្រូវបានគេបំផ្លាញ គឺវាចាក់ជ្រៅទៅក្នុងដួងចិត្តរបស់មនុស្សម្នាក់ ដែលធ្វើឲ្យគេពិបាកនឹងទុកចិត្តនរណាម្នាក់ម្តងទៀតណាស់ ប៉ុន្តែគោលការណ៍នៃការអត់ទោស គឺជាសេចក្តីបង្រៀនដ៏មានអំណាចនៅក្នុងបទគម្ពីរទាំងអស់។ ព្រះគ្រិស្តមិនត្រឹមតែបង្រៀនឲ្យមនុស្សចេះអត់ទោសនោះទេ (គម្ពីរម៉ាថាយ ៦:១៤) ប៉ុន្តែទ្រង់ក៏អត់ទោសឲ្យគេផងដែរ(គម្ពីរលូកា ៧:៤៧-៥០)។ ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យនឹងអំពើបាបនោះទេ ប៉ុន្តែទ្រង់ស្រឡាញ់មនុស្សមានបាបខ្លាំងណាស់ ដែលទ្រង់បានអនុញ្ញាត ឲ្យបុត្រាជាទីស្រឡាញ់របស់ទ្រង់រងរបួស រងការប្រមាថ និង ត្រូវបានគេឆ្កាង ដើម្បីឲ្យអំពើបាបរបស់យើងទទួលបានការអត់ទោស។ ព្រះគ្រិស្តបានអត់ទោសបាបឲ្យស្ត្រីម្នាក់ដែលត្រូវបានគេចាប់បានពេលកំពុងប្រព្រឹត្តអំពើសហាយស្មន់ (គម្ពីរយ៉ូហាន ៨:៣-១១) ។

តើមានក្តីស្រឡាញ់ណាទៀតដែលអាចបង្ហាញទៅកាន់ដៃគូរបស់ខ្លួន ក្រៅពីការផ្តល់នូវការអត់ទោសដូចដែលព្រះគ្រិស្តបានបង្ហាញសម្រាប់យើងនោះ? ប្រសិនបើអាចការពារចំណងអាពាហ៍ពិពាហ៍បាន និង គ្រួសារគ្រិស្តបរិស័ទត្រូវបានសង្គ្រោះ និង ប្រសិនបើប្តី និងប្រពន្ធអាចធ្វើការសន្យារបស់គេសាជាថ្មីម្តងទៀត ចំពោះគ្នាទៅវិញទៅមក និង ចំពោះព្រះជាម្ចាស់ផងនោះ ព្រះជាម្ចាស់នឹងប្រទានពរសម្រាប់អ្នកដែលអាចអត់ទោសនោះបាន។ នៅក្នុងករណីដូចនេះ ដៃគូទាំងសងខាងមិនគួរពិភាក្សាអំពីបញ្ហានោះសាជាថ្មីម្តងទៀត ជាមួយគ្នាទៅវិញទៅមក ឬ ជាមួយអ្នកផ្សេងទៀតទេ។ បញ្ហានោះត្រូវតែ អត់ទោស និង *បំភ្លេចចោល* តែមិនត្រូវភ្លេចអំណាចដែលអារក្សវាអាចនាំយើងឲ្យធ្វើអំពើបាបនោះទេ។

លំហាត់អនុវត្តន៍

៥ តើប្រយោគមួយណានៅខាងក្រោមនេះដែលបង្ហាញពីគោលការណ៍នៅក្នុងព្រះគម្ពីរដែល ទាក់ទងនឹងរបៀបដែលគ្រិស្តបរិស័ទគួរតែឆ្លើយតបទៅការប្រព្រឹត្តអំពើសហាយស្មន់របស់ដៃគូ។

ក) គ្រិស្តបរិស័ទត្រូវតែបន្តចំណងអាពាហ៍ពិពាហ៍ជាមួយដៃគូរបស់គេ នៅគ្រប់កាលៈទេសៈទាំងអស់។

ខ) ប្រសិនបើដៃគូម្ខាងប្រព្រឹត្តអំពើសហាយស្មន់ ដៃគូម្ខាងទៀតចាំបាច់ត្រូវចាក់ចេញ ហើយទៅរៀប ការជាមួយនឹងគ្រិស្តបរិស័ទម្នាក់ទៀត។

គ) ដៃគូប្តីប្រពន្ធ មានសេរីភាពអាចចាកចេញ ប្រសិនបើដៃគូម្ខាងទៀតបានប្រព្រឹត្តបាបក្នុងអំពើសហាយស្មន់។

ឃ) បាបនៃអំពើសហាយស្មន់ អាចនឹងត្រូវបានអត់ទោសឲ្យ ហើយចំណងអាពាហ៍ពិពាហ៍អាចបន្ត ទៅមុខទៀត។

៦ អ្នកប្រាជ្ញព្រះគម្ពីរខ្លះ បកស្រាយព្រះបន្ទូលរបស់ព្រះយេស៊ូនៅក្នុងគម្ពីរម៉ាថាយ ១៩:៩ ថាជាការអនុញ្ញាតឲ្យ

ក) ដៃគូដែលប្រព្រឹត្តអំពើសហាយស្មន់នោះអាច លែងលះ និងរៀបការម្តងទៀតបាន។

ខ) ដៃគូដែលរងគ្រោះ អាចលែងលះ និង រៀបការម្តងទៀតបាន។

គ) ដៃគូទាំងសងខាងអាចរៀបការម្តងទៀតបាន។

ការលែងលះ

វត្ថុបំណងទី ៤. *ប្រាប់ពីវិន័យទូទៅសម្រាប់ ការលែងលះគ្នាដែលយកទៅអនុវត្តជាមួយគ្រិស្តបរិស័ទ។*

បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ទាក់ទងនឹងការលែងលះគ្នានេះ គឺបានបង្ហាញយ៉ាងច្បាស់ៗនៅក្នុងគម្ពីរម៉ាឡាគីជំពូក២ ៖ "ព្រះអម្ចាស់ ជាព្រះនៃជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលថា ព្រះអង្គមិនសព្វព្រះហឫទ័យ នឹងការលែងលះគ្នាទេ" ។

នៅក្នុងបទបន្ទូល ព្រះជាម្ចាស់ មានព្រះបន្ទូលប្រាប់ថា មូលហេតុមួយដែលទ្រង់សព្វព្រះហឫទ័យឲ្យប្តី និង ប្រពន្ធ មានភាពស្មោះត្រង់ចំពោះគ្នាទៅវិញទៅមក គឺ ដើម្បីឲ្យកូនៗរបស់ពួកគេបានក្លាយជាមនុស្សរបស់ព្រះជាម្ចាស់ផងដែរ។ កូនៗរបស់គ្រិស្តបរិស័ទ ទទួលបានព្រះពរដ៏អស្ចារ្យជាច្រើន ដូចជាភាពនឹងនរ សីលធម៌ខ្ពស់ ក្តីស្រឡាញ់ មានទំនាក់ទំនងជាមួយនឹងឪពុកម្តាយ ការអធិស្ឋាន និង ការបង្រៀនព្រះគម្ពីរ។ មានបញ្ហាជាច្រើន ដែលអាចកើតឡើងទៅលើក្មេងដែលរងគ្រោះពីការលែងលះ។ ខ្ញុំស្គាល់គ្រូគង្វាលម្នាក់ដែលគាត់បានបង្រៀនជនល្មើសដែលជាក្មេងប្រុសចំនួន ៤០នាក់ ដែលត្រូវបានសមត្តកិច្ចដាក់នៅក្នុងលំនៅដ្ឋានពិសេសមួយ ដោយសារតែពួកគេបានប្រព្រឹត្តបទល្មើសផ្សេងៗ។ លោកគ្រូគង្វាលនោះ ប្រាប់ខ្ញុំថា បទពិសោធន៍ដែលក្មេងទាំងអស់នោះ មានស្រដៀងគ្នា គឺថា ឪពុកម្តាយរបស់គេ

បានលែងលះគ្នា។ ពិតណាស់ មិនមែនក្មេងដែលមានឪពុកម្តាយលែងលះទាំងអស់សុទ្ធតែប្រព្រឹត្តបទល្មើសនោះទេ ប៉ុន្តែភាគច្រើនពួកគេរងគ្រោះតាមរបៀបណាមួយ។

វិន័យទូទៅសម្រាប់ការលែងលះ ៖

១. ការលែងលះត្រូវបានហាមជាដាច់ខាត (ហាមផ្តាច់) សម្រាប់គ្រិស្តបរិស័ទ (គម្ពីរ១កូរិនថូស ៧:១០-១១)

២. ត្រូវតែហាមជាដាច់ខាត ការរៀបការជាមួយមនុស្សដែលបានលែងលះហើយ (គម្ពីរលូកា ១៦:១៨; គម្ពីរម៉ាថាយ ៥:៣២; ១៩:៩ និង គម្ពីរ ១កូរិនថូស ៧:១១)

៣. អ្នកដែលបានលែងលះគ្នាហើយ មិនត្រូវរៀបការម្តងទៀតទេ (គម្ពីរ១កូរិនថូស ៧:១០-១១)។ នៅខាងដើមមេរៀននេះ យើងបានពិភាក្សាអំពីមូលហេតុមួយដែលអនុញ្ញាតឲ្យគ្រិស្តបរិស័ទអាចលែងលះគ្នា ហើយរៀបការម្តងទៀតបាន ប៉ុន្តែទោះជានៅក្នុងករណីនោះ ក៏នៅតែមានទុក្ខទោសដែលបំផ្លាញកូនៗ និង បំផ្លាញគំរូរបស់គ្រិស្តបរិស័ទផងដែរ។

នៅក្នុងករណី ដែលការលែងលះបានកើតមានឡើង ហើយគ្មានមធ្យោបាយអ្វីអាចផ្សះផ្សា ចំណងអាពាហ៍ពិពាហ៍នោះវិញទេ ដោយសារតែគូដៃម្ខាងបានរៀបការម្តងទៀតហើយ សហគមន៍គ្រិស្តបរិស័ទអាចជាប្រភពដែលអាចកំសាន្ត និង ជួយដល់ដៃគូម្ខាងដែលត្រូវបានគេលែងលះនោះ។ ព្រះជាម្ចាស់មិនដែលបែរព្រះភ័ក្ត្ររបស់ទ្រង់ចេញពីនរណាម្នាក់ដែលបានស្រែករកជំនួយពីទ្រង់នោះឡើយ ហើយទ្រង់នឹងប្រទានកម្លាំង ដើម្បីកសាងជីវិតជាថ្មី និង ដើម្បីប្រឈមមុខនឹងបញ្ហាដែលបានមកពីការលែងលះនោះ។ នៅក្នុងមេរៀនទី ៦ យើងនឹងមើលទៅលើចំណុចនេះ តាមការយល់ឃើញរបស់បុគ្គលដែលនៅតែឯងក្រោយពីមានការលែងលះ។

ខ្ញុំស្គាល់ប្តីប្រពន្ធមួយគូដែលធ្លាប់បានលែងលះប្តីប្រពន្ធរបស់ពួកគេរៀងខ្លួនពីមុនមកជាច្រើនឆ្នាំមកហើយ មុនពេលដែលពួកគេបានរៀបរាប់ការជាមួយគ្នា។ មិនយូរប៉ុន្មានក្រោយពេលរៀបការ ពួកគេទាំងពីរបានក្លាយជាគ្រិស្តបរិស័ទ។ បុរសជាប្តី បានគ្របដណ្តប់ដោយអារម្មណ៍ថាមានទោស ដោយសារតែគាត់គិតថា គាត់កំពុងរស់នៅក្នុងភាពសហសស្នង់ជាមួយនឹងអាពាហ៍ពិពាហ៍លើកទីពីររបស់គាត់ តាំងពីពេលដែលគាត់បានលែងលះ ហើយរៀបការកន្លងមកនេះ។ លោកសាវ័កប៉ូលក៏បានផ្តល់ឲ្យនូវការណែនាំស្តីពីស្ថានភាពបែបនេះផងដែរ។

លំហាត់អនុវត្តន៍

---

៧ សូមអានគម្ពីរ១កូរិនថូស ៧:១៧-២៤។ តើខគម្ពីរនេះជាប់ទាក់ទងនឹងស្ថានភាពដែលយើងទើបបានរៀបរាប់ យ៉ាងដូចម្តេច?

.....

.....

៨ ដោយមិនចាំបាច់ ត្រឡប់ទៅមើលចំណុចមុន ចូរប្រាប់ពីវិន័យទូទៅសម្រាប់ការលែងលះ ដែលទាក់ទងនឹងគ្រិស្តបរិស័ទ។

.....

.....

បញ្ហាអាពាហ៍ពិពាហ៍ផ្សេងៗទៀត

វគ្គបំណែងទី៥. *ផ្សារភ្ជាប់ស្ថានភាពនៃបញ្ហាទៅនឹងដំណោះស្រាយត្រឹមត្រូវសម្រាប់បញ្ហានីមួយៗ។*

យើងនឹងនិយាយខ្លីៗអំពីបញ្ហាផ្សេងៗខ្លះទៀតដែលអាចធ្វើឲ្យមានការមិនសប្បាយចិត្ត និង ជម្លោះនៅក្នុងគ្រួសារ។

កង្វះការគោរពនិង ការទុកចិត្តគ្នាទៅវិញទៅមក

ខ្ញុំស្គាល់ប្តីម្នាក់ដែលហាក់បីដូចជារីករាយ នឹងការមើលងាយប្រពន្ធរបស់គាត់នៅចំពោះមុខអ្នកដទៃ។ ខ្ញុំក៏ស្គាល់ ប្រពន្ធម្នាក់ដែលហាក់បីដូចជា ស្វែងរកតែឱកាសដើម្បីមើលងាយប្តីរបស់នាង នៅក្នុងចំពោះមុខអ្នកដទៃ ដោយការជំទាស់ជាមួយគាត់ និង កែតម្រូវគ្រប់អ្វីដែលគាត់និយាយ។ ប្រហែលជាពួកគេប្រើប្រាស់វិធីសាស្ត្រនេះ ដើម្បីសងសឹក ចំពោះអាកប្បកិរិយាខ្លះរបស់ដៃគូខ្លួន ដូចជាខ្វះការបង្ហាញក្តីស្រឡាញ់ ឬ ខ្វះការចុះចូល ប៉ុន្តែនេះមិនមែនជារបៀបរបស់គ្រិស្តបរិស័ទក្នុងការដោះស្រាយបញ្ហានៅក្នុងទំនាក់ទំនងនោះឡើយ។ គំរូនៅក្នុងព្រះគម្ពីរគឺថា ប្តីត្រូវតែស្រឡាញ់ប្រពន្ធរបស់គាត់ ឲ្យស្មើនឹងក្តីស្រឡាញ់ដែលព្រះគ្រិស្តស្រឡាញ់ក្រុមជំនុំដែរ (គម្ពីរអេភេសូ ៥:២៥-២៨) ហើយប្រពន្ធត្រូវតែលើកតម្កើង និង គោរពប្តីរបស់នាង (គម្ពីរអេភេសូ ៥:៣៣)

ដៃគូទាំងសងខាងមិនត្រូវផ្តល់ហេតុផលដែលធ្វើឲ្យដៃគូរបស់ខ្លួនប្រច័ណ្ឌនោះឡើយ។ ប្តីប្រពន្ធគ្រិស្តបរិស័ទដែលមានបញ្ហានេះគួរតែពិភាក្សាគ្នា ដោយបើកចំហ និង ព្រមព្រៀងបញ្ចៀសរាល់ស្ថានភាពណាដែលអាចធ្វើឲ្យមានអារម្មណ៍ប្រច័ណ្ឌកើតមានឡើង។មនុស្សដែលប្រច័ណ្ឌ គ្រប់ពេលដោយគ្មានមូលហេតុអ្វីសោះ គេគួរតែទូលសូមឲ្យព្រះអម្ចាស់ជួយពួកគេ យកឈ្នះលើអារម្មណ៍បែបនោះ ហើយបង្កើតការទុកចិត្ត លើប្តីប្រពន្ធរបស់ខ្លួន។

លំហាត់អនុវត្តន៍

៩ ការប្រច័ណ្ឌ កើតឡើងនៅពេលដែលខ្វះ

ក) ការគោរព

ខ) ការចុះចូល

គ) ការប្តេជ្ញាចិត្ត

ឃ) ការទុកចិត្ត

កង្វះទំនាក់ទំនង

អ្នកខ្លះនិយាយថា "ប្តីរបស់ខ្ញុំមិនដែលនិយាយរកខ្ញុំសោះ" ។ នេះគឺជាការតួញត្អែររបស់ប្រពន្ធ ដែលប្រហែលជាបានចំណាយពេលវេលាពេញមួយថ្ងៃរបស់នាង មើលថែកូនៗតូច ហើយចង់មានទំនាក់ទំនងជាមួយប្តីរបស់ពួកគេ នៅពេលល្ងាច។ ដើម្បីមានអាពាហ៍ពិពាហ៍ដ៏ល្អមួយ ត្រូវមានទំនាក់ទំនងដ៏ល្អមួយជាមុនសិន។ ប្តីប្រពន្ធ គួរតែអាចចែករំលែកជាមួយគ្នាទៅវិញទៅមក បានច្រើនជាងនរណាទាំងអស់ ទាំងអំណរ និង ទុក្ខវេទនា ទាំងក្តីសង្ឃឹម និង ក្តីសុបិន ទាំងបញ្ហាធំ និង តូច ប្រចាំថ្ងៃរបស់ពួកគេ។

ការប្តេជ្ញាជ្រុល

ចិត្តវិទ្យាដ៏ល្បីល្បាញម្នាក់ បានហៅបញ្ហានេះថាជា បញ្ហាលេខមួយនៅក្នុងគ្រួសាររបស់គ្រិស្តបរិស័ទជាច្រើន រួមទាំងគ្រូគង្វាលខ្លះ និង អ្នកដែលធ្វើការងារព័ន្ធកិច្ចពេញពេល។ វាពិតជាងាយស្រួលក្នុងការចូលរួមជាមួយនឹងសកម្មភាពជាច្រើន នៅក្រៅផ្ទះ ដែលធ្វើឲ្យគ្មានពេលវេលាសម្រាប់ជីវិតគ្រួសារ។ ផ្ទះក្លាយជា កន្លែងសម្រាប់គ្រាន់តែ បរិភោគអាហារ ងូតទឹក និង គេងប៉ុណ្ណោះ។ គ្រួសារមួយត្រូវបានទ្រុឌទ្រោម នៅពេលដែលឪពុករវល់តែរកលុយ និង ការងារព័ន្ធកិច្ចដើម្បីបំពេញតម្រូវការខាងឯវិញ្ញាណរបស់អ្នកដទៃ។ គាត់ផ្តល់ខ្លួនគាត់ទាំងអស់សម្រាប់ការងារ ហើយទុកតែបន្តិចបន្តួច ឬគ្មានសោះសម្រាប់ប្រពន្ធ និងកូនៗរបស់គាត់។ ព្រះជាម្ចាស់សព្វព្រះទ័យឲ្យយើងប្រើប្រាស់ប្រាជ្ញាដែលទ្រង់បានប្រទានឲ្យ ទៅចាត់ចែងអាទិភាពត្រឹមត្រូវ នៅក្នុងជីវិតរបស់គាត់។ ប្រសិនបើប្តី ចង់ក្លាយជាអ្នកដឹកនាំខាងឯវិញ្ញាណនៅក្នុងគ្រួសារ គាត់ត្រូវចំណាយពេល ជាមួយគ្រួសាររបស់គាត់តាមការប្រកបគ្នា និង ការបណ្តុះបណ្តាល។

លំហាត់អនុវត្តន៍

---

១០ សូមអានគម្ពីរ១ធីម៉ូថេ ៣:១-១២ ។ តើលោកប៉ូលបានធ្វើការណែនាំអ្វី ទាក់ទងអ្នកដឹកនាំក្រុមជំនុំ ដែលបញ្ជាក់ថាពួកគេត្រូវយកចិត្តទុកដាក់ផ្តល់អាទិភាព ចំពោះគ្រួសាររបស់ពួកគេ?

.....

.....

បញ្ហាហិរញ្ញវត្ថុ

ប្តីប្រពន្ធត្រូវតែធ្វើការជាមួយគ្នាដើម្បីបង្កើតជាកញ្ចប់ថវិកាមួយដែលអាចបំពេញតម្រូវការរបស់ពួកគេ និង ជួយគេមិនឲ្យមានបន្ទុកពីបំណុលដែលពិបាកនឹងសង។ គ្រឹះមូលដ្ឋានដែលល្អបំផុតគឺ ថ្វាយដប់ភាគរយដំបូងនៃចំណូលរបស់គ្រួសារទៅកាន់ព្រះអម្ចាស់ដោយភាពស្មោះត្រង់ ដោយយោងទៅតាមសេចក្តីបង្រៀននៅក្នុងបទគម្ពីរ (គម្ពីរម៉ាឡាគី ៣:៨; គម្ពីរម៉ាថាយ ២៣:២៣)។ គ្រួសារជាច្រើនរងទុក្ខជាមួយនឹងបញ្ហាហិរញ្ញវត្ថុដែលមិនសមហេតុផល បញ្ហាជំងឺ និង ការចំណាយដោយឥតព្រៀងទុក ព្រោះតែពួកគេមិនមែនជាអ្នកដែលចូលចិត្តថ្វាយ ចំណែករបស់ព្រះជាម្ចាស់ដែលនៅក្នុងចំណូលរបស់គេនោះទេ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ បានបញ្ជាក់ម្តងហើយម្តងទៀត ពីគោលការណ៍នៃការថ្វាយ ។ យើងមិនអាច

ថ្វាយឲ្យលើសពីព្រះជាម្ចាស់បានទេ។ ទ្រង់បានសន្យាថា នឹងបំពេញតម្រូវការរបស់យើង នៅពេលដែលយើងស្មោះត្រង់ ជាមួយទ្រង់ (គម្ពីរកិច្ចការ ៦:៣៨)។

លោកសាវ័កប៉ូល បាននិយាយថា លោកបានរៀនឲ្យចេះស្កប់ចិត្ត មិនថាលោកមានច្រើនក្តី ឬតិចតួចក្តី (គម្ពីរភីលីព ៤:១១)។ ប្រាកដណាស់ ភាពសប្បាយរីករាយ មិនពឹងផ្អែកទៅលើទ្រព្យសម្បត្តិនោះទេ។ ព្រះជាម្ចាស់ មិនសព្វព្រះហឫទ័យឲ្យយើងព្រួយចិត្តអំពីការប្រមូលទ្រព្យនោះទេ ប៉ុន្តែទ្រង់សព្វព្រះទ័យឲ្យយើងទុកចិត្តទ្រង់ ក្នុងការផ្គត់ផ្គង់សម្រាប់តម្រូវការប្រចាំថ្ងៃរបស់យើង។

តារាងខុសគ្នាក្នុងការបណ្តុះបណ្តាលកូន

មានបញ្ហាជាច្រើន ដែលអាចកើតឡើង ដោយសារតែឪពុកម្តាយមិនយល់ស្របគ្នាលើការបណ្តុះបណ្តាល និងប្រៀនប្រដៅកូនៗរបស់ពួកគេ។ បញ្ហានេះអាចជៀសវាងបាន ដោយការធ្វើតាមគោលការណ៍ចិញ្ចឹមអប់រំកូនដែលបានចែងនៅក្នុងព្រះគម្ពីរ។ យើងនឹងពិភាក្សាគ្នាអំពីគោលការណ៍ខ្លះ នៅក្នុងចំណុចបន្ទាប់នៃមេរៀននេះ។ ឪពុកម្តាយគួរតែបង្ហាញពីការរួបរួមជានិច្ច នៅក្នុងការសម្រេចចិត្តណាមួយដែលទាក់ទងជាមួយនឹងកូនៗ ហើយពួកគេគួរតែពិភាក្សាអំពីភាពខុសគ្នាដោយសម្ងាត់ ដើម្បីកុំឲ្យកូនៗរបស់គេយកឱកាសដែលបានមកពីគំនិតផ្ទុយគ្នារបស់ពួកគេ ទៅបង្កើតជាបញ្ហាបន្ថែមទៀតរវាងឪពុកម្តាយរបស់គេ។

បញ្ហាដែលទាក់ទងនឹងសាច់ញាតិ

នៅពេលបុរសម្នាក់ រៀបការ គាត់ត្រូវចាកចេញពីឪពុកម្តាយរបស់គាត់ ហើយទៅនៅជាមួយប្រពន្ធរបស់គាត់ (គម្ពីរម៉ាថាយ ១៩:៥) ។ បន្ទាប់មក ទំនួលខុសត្រូវរបស់គាត់គឺសម្រាប់ប្រពន្ធ និង កូនៗរបស់គាត់ ហើយមិនអនុញ្ញាតឲ្យមានអ្វីផ្សេងមកបំផ្លាញការរួបរួមនៅក្នុងចំណងអាពាហ៍ពិពាហ៍របស់គាត់បានឡើយ។ ប៉ុន្តែព្រះគម្ពីរបាន បង្រៀនថា ប្រសិនបើមានសមាជិកគ្រួសារណា មានតម្រូវការចាំបាច់ យើងមិនត្រូវបែរចេញពីអ្នកដែលត្រូវការនោះឡើយ។ គម្ពីរ១ធីម៉ូថេ ៥:៤-៨ បានបន្ថែមទំនួលខុសត្រូវរបស់អ្នកជឿរួមបញ្ចូលទាំង តាយាយ បងប្អូន និង ស្ត្រីមេម៉ាយនៅក្នុងគ្រួសារផងដែរ។ នៅក្នុងខទី៨ បានបន្ថែមទៀតថា ៖ "អ្នកណាមិនរវល់ថែទាំសាច់ញាតិរបស់ខ្លួន ជាពិសេស មិនថែទាំអ្នកដែលនៅក្នុងក្រុមគ្រួសាររបស់ខ្លួនផ្ទាល់ អ្នកនោះបានក្បត់ជំនឿរបស់ខ្លួន ហើយអាក្រក់ជាងអ្នកមិនជឿទៅទៀត។"

លំហាត់អនុវត្តន៍

---

១១ ប្រសិនបើឪពុកម្តាយខាងប្តី ធ្វើការទាមទារដែលទាស់នឹងទំនួលខុសត្រូវរបស់គាត់សម្រាប់ប្រពន្ធនិង កូនរបស់គាត់ តើមួយណាដែលតែងតែជាអាទិភាពទីមួយសម្រាប់គាត់?

ក) ឪពុកម្តាយ

ខ) ប្រពន្ធ និង កូន

១២ ចូរផ្គូផ្គង បញ្ហានៅក្នុងអាពាហ៍ពិពាហ៍(ជួរខាងស្តាំ) ទៅនឹងដំណោះស្រាយដែលត្រឹមត្រូវ (ជួរខាងឆ្វេង) ។ ចូរសរសេរលេខនៃបញ្ហានីមួយៗនៅខាងមុខដំណោះស្រាយដែលអ្នកបានជ្រើសរើសសម្រាប់វា។

.....ក) កញ្ចាប់ថវិកាមួយដែលផ្តល់អាទិភាពឲ្យចំណែករបស់ព្រះជាម្ចាស់។

.....ខ) ដើរតាមគំរូរបស់ព្រះគម្ពីរ ដោយស្រឡាញ់ និង គោរពគ្នាទៅវិញទៅមក។

.....គ) ទុកចិត្តគ្នាទៅវិញទៅមក ព្រមទាំងធ្វើខ្លួនជាមនុស្សគួរឲ្យទុកចិត្តដែរ។

.....ឃ) ចំណាយពេលវេលា ឲ្យបានច្រើនជាមួយគ្រួសារ។

.....ង) ធ្វើតាមគោលការណ៍របស់គ្រិស្តបរិស័ទ ហើយបង្ហាញពីការរួបរួម។

.....ច) អាទិភាពទីមួយរបស់មនុស្សប្រុស គឺតម្រូវការគ្រួសារផ្ទាល់ខ្លួនរបស់គាត់ បន្ទាប់មកទើបជាតម្រូវការចាំបាច់របស់សមាជិកគ្រួសារដទៃផ្សេងទៀត។

.....ឆ) ចែករំលែកជាមួយគ្នាទៅវិញទៅមក។

១) ការប្តេជ្ញាជ្រុល

២) បញ្ហាទាក់ទងនឹងសាច់ញាតិ

៣) បញ្ហាហិរញ្ញវត្ថុ

៤) កង្វះការគោរព

៥) ភាពខុសគ្នាក្នុងការបណ្តុះបណ្តាលកូន

៦) កង្វះទំនាក់ទំនង

៧) ការប្រច័ណ្ឌ

ខ) បញ្ហារបស់ភ្ញូនៗ

វត្ថុបំណងទី៦. *ជ្រើសរើសការថ្លែងដែល សង្ខេបយ៉ាងខ្លីៗអំពីវិធីសាស្ត្រដែលឪពុកម្តាយគួរតែមាននៅក្នុងការបណ្តុះបណ្តាលកូនៗរបស់ពួកគេ។*

ការមិនស្តាប់បង្គាប់

ការមិនស្តាប់បង្គាប់ឪពុកម្តាយ គឺជាសញ្ញាបញ្ជាក់ថ្ងៃចុងក្រោយ។ ក្រឹត្យវិន័យតែមួយគត់ ដែលរួមជាមួយនឹងការសន្យាផងនោះ គឺថា៖ "ចូរគោរពមាតាបិតារបស់អ្នក ដើម្បីអោយអ្នកមានអាយុយឺនយូរ នៅលើដីដែលព្រះអម្ចាស់ជាព្រះនៃអ្នក ប្រទានដល់អ្នក" (គម្ពីរនិក្ខមនំ ២០:១២) ។ កូនៗត្រូវរៀនស្តាប់បង្គាប់តាមរយៈការបណ្តុះបណ្តាល និង ការប្រៀនប្រដៅយ៉ាងយកចិត្តទុកដាក់ ពីឪពុកម្តាយរបស់ពួកគេ៖ "ចូរអប់រំកូនក្មេងអោយមានទំលាប់ល្អតាំងពីតូច គេនឹងរក្សាទំលាប់នេះរហូតដល់ចាស់" (គម្ពីរសុភាសិត ២២:៦) ។ ការបណ្តុះបណ្តាលមិនកើតឡើងឯងៗ នោះទេ វាទាមទារឲ្យមានការប្តេជ្ញាចិត្ត និង ការស្ម័គ្រចិត្តគ្រប់គ្រងលើស្ថានការណ៍នោះផងដែរ ៖ "រីឯក្មេងដែលគេបណ្តោយអោយធ្វើអ្វីតាមចិត្ត តែងតែបំបាក់មុខម្តាយ" (គម្ពីរសុភាសិត ២៩:១៥)។ ឪពុកម្តាយមិនត្រូវអនុញ្ញាតឲ្យកូនមិនស្តាប់បង្គាប់គាត់ តាំងពីនៅតូចនោះទេ ប្រសិនបើគាត់ចង់គ្រប់គ្រងកូនបាននៅពេលវាធំឡើង។

បច្ចុប្បន្ននេះ ឪពុកម្តាយជាច្រើនមានអារម្មណ៍ក្រៀមក្រំ ដោយសារតែការបះបោរ របស់កូនៗដែលមានវ័យជំទង់របស់គាត់។ បន្ថែមពីលើ នេះទៀត គឺមានសេចក្តីល្បួងមកលើយុវជន ឲ្យសាកល្បងសេពគ្រឿងញៀន ឬ គ្រឿងស្រវឹង ឬ សាកល្បងជាមួយនឹងការរួមភេទ។ ក្រុមជំនុំ ក៏ទទួលផលប៉ះពាល់ពីបន្ទុកដែលក្រុមគ្រួសារបានរងនេះដែរ ព្រោះមានកូនស្រីដែលមិនទាន់រៀបការ មានផ្ទៃពោះ ឬ មានកូនប្រុសក្លាយជាអ្នកញៀនថ្នាំ ឬ កូនប្រុសឬកូនស្រី បានចាកចេញពីគ្រួសារហើយទៅស្វែងរកការសប្បាយតាមរបៀបមិនបរិសុទ្ធ។

ប្រសិនបើគ្រួសាររបស់អ្នកទទួលរងគ្រោះដោយសារតែបញ្ហាបែបនេះដែរ ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យពង្រឹងជំនឿរបស់អ្នក ហើយមិនត្រូវចុះចាញ់ឡើយ។ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ចំពោះអ្នក ហើយទ្រង់ស្រឡាញ់កូនដ៏រឹងចចេសរបស់អ្នកដែរ។ សូមទទួលការលើកទឹកចិត្តពីក្នុងរឿងកូនពៅដែលបាត់ហើយរកឃើញវិញ នៅក្នុងគម្ពីរលូកា ១៥:១១-៣២។

ឪពុកដែលនៅក្នុងរឿងនេះ មិនបានព្យាយាមហាមឃាត់មិនឲ្យកូនប្រុសរបស់គាត់ចាកចេញពីផ្ទះនោះទេ ប៉ុន្តែនៅក្នុងចិត្តរបស់គាត់ពិតជាដោយភាពក្រៀមក្រំនៅពេលដែលឃើញកូនប្រុសរបស់គាត់ចាកចេញទៅ។ ខ្ញុំជឿថា គាត់ក៏បានអធិស្ឋានសម្រាប់កូនប្រុសរបស់គាត់ទាំងថ្ងៃទាំងយប់ និងមិនដែលឈប់រំពឹងក្នុងចិត្តថាព្រះជាម្ចាស់នឹងធ្វើការល្អសម្រាប់កូនរបស់គាត់ក្នុងស្ថានភាពមួយនេះដែរ។ តើអ្នកគិតថាគាត់បានចេញទៅតាមផ្លូវស្វែងរកកូនរបស់គាត់ប៉ុន្មានដងក្នុងមួយថ្ងៃ? ព្រះគម្ពីរបានចែងថា កូនប្រុសរបស់គាត់បានសម្រេចចិត្តត្រឡប់មកផ្ទះវិញ ក្រោយពេលគេបានចំណាយប្រាក់របស់គេ និង បាត់បង់អ្វីៗគ្រប់បែបយ៉ាងដែលគេមាន " លុះគិតដូច្នោះហើយ កូនពៅក៏វិលត្រឡប់ទៅរកឪពុកវិញ។ កាលឪពុកឃើញកូនពីចម្ងាយ គាត់មានចិត្តអាណិតអាសូរក្រៃលែងក៏រត់ទៅទទួលកូន ហើយឱបថើបទៀតផង។" (ខ២០)។

អ្នកអាចទទួលយកសេចក្តីសន្យានៅក្នុងគម្ពីរសុភាសិត ២២:៦។ មានពេលខ្លះ អ្វីដែលអ្នកអាចធ្វើបានគឺ ថ្វាយកូនរបស់អ្នកដែលមានបញ្ហានោះទៅកាន់ព្រះអម្ចាស់ ហើយទុកចិត្តថាទ្រង់នឹងធ្វើឲ្យការល្អកើតមានឡើង ប៉ុន្តែត្រូវត្រៀមខ្លួនជានិច្ចដើម្បីជួយកូនរបស់អ្នកដោះស្រាយបញ្ហា នៅពេលដែលគេបែរមករកអ្នកដើម្បីជួយគេផងដែរ។ ដូចជាព្រះវរបិតានៃស្ថានបរមសុខ ទ្រង់ទទួលមនុស្សមានបាបដែលបានលន់តួ មិនខ្វល់ថាគេបានធ្វើអ្វី ឪពុកម្តាយជាគ្រិស្តបរិស័ទត្រូវបង្ហាញក្តីស្រលាញ់ និង ចិត្តអាណិតអាសូរទៅកាន់កូនៗរបស់គេដែលបានបះបោរ នៅពេលណាដែលពួកគេស្រែករកជំនួយដូចគ្នាដែរ។

កង្វះ ការបណ្តុះបណ្តាល និង ការប្រៀនប្រដៅ

ជារឿយៗ ទាំងឪពុកទាំងម្តាយ ធ្វើការនៅក្រៅផ្ទះ ហើយពួកគេមានកម្លាំងថាមពលតែបន្តិចបន្តួច ប៉ុណ្ណោះសម្រាប់ទំនួលខុសត្រូវយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាល និង ប្រៀនប្រដៅកូនៗរបស់ពួកគេ។ ពួកគេតែងតែរំពឹងឲ្យ ក្រុមជំនុំ និង សាលារៀនបំពេញតួនាទីទាំងនេះ ដែលព្រះជាម្ចាស់បានប្រទានឲ្យពួកគេធ្វើទៅវិញ។ ការបណ្តុះបណ្តាលកូនជាកិច្ចការលំបាកណាស់។ យើងមិនអាច បណ្តុះបណ្តាលកូនដោយគ្រាន់តែប្រាប់ ពួកគេថាគួររស់របៀបណានោះទេ។ អ្នកត្រូវតែធ្វើកិច្ចការជាមួយពួកគេ ដើម្បីកែតម្រូវកំហុសគ្រប់បែបយ៉ាង ដើម្បីបង្ហាញពួកគេពីអ្វីដែលត្រូវ និង អ្វីដែលខុស ដើម្បីបង្រៀនពួកគេពីអ្វីដែលព្រះ

បន្ទូលរបស់ព្រះជាម្ចាស់បានចែង។ ការបណ្តុះបណ្តាលកូនគឺជាសកម្មភាពដែលត្រូវតែបន្តធ្វើ រហូតដល់ពេលដែលកូនៗបានពេញវ័យគ្រប់គ្រាន់ដើម្បីចាកចេញពីផ្ទះ និង ទទួលយកទំនួលខុសត្រូវជាមនុស្សពេញវ័យម្នាក់។

កង្វះសេចក្តីស្រឡាញ់ និង ការយល់ដឹង

មនុស្សគ្រប់គ្នាត្រូវការក្តីស្រឡាញ់ និង ការថ្នាក់ថ្នម។ កូនៗដែលធំលូតលាស់នៅក្នុងគ្រួសារដែលមិនសូវមានការបង្ហាញក្តីស្រឡាញ់ ក៏មានការលំបាកក្នុងការបង្ហាញក្តីស្រឡាញ់ទៅចំពោះអ្នកដទៃដែរ។ ឪពុកម្តាយគួរញែកពេលវេលាឲ្យបានច្រើនដើម្បីធ្វើការបង្ហាញក្តីស្រឡាញ់ទៅកាន់កូនៗរបស់ពួកគេ។

ឪពុកម្តាយខ្វះការយល់ដឹង នៅពេលដែលពួកគេទាមទាររឿងជាច្រើនពីកូនៗរបស់ពួកគេ ឬ នៅពេលដែលពួកគេ បណ្តោយតាម ឬ មិនហាមឃាត់កូន ហើយតែងតែអនុញ្ញាតឲ្យកូនៗរបស់ពួកគេធ្វើតាមអំពើចិត្ត។ រឿងដែលជ្រុលហួសកម្រិតទាំងពីរនេះ អាចបង្កឲ្យមានបញ្ហាបាន។ កូនៗដែលទទួលការរិះគន់ និង ការចំអកច្រើន នឹងមានអារម្មណ៍ថាតូចទាបជាងគេ និង គ្មានទំនុកចិត្ត ដែលនឹងនៅជាមួយពួកគេរហូតដល់ពួកគេធំពេញវ័យ។ មធ្យោបាយវិជ្ជមាន ក្នុងការបណ្តុះបណ្តាល
កូនៗ នឹងជួយបញ្ចៀសរាល់បញ្ហាទាំងនេះ។

មនុស្សគ្រប់គ្នាឆ្លើយតបបានយ៉ាងល្អ ទៅចំពោះការយល់ស្រប។ ការកែតម្រូវ ចំពោះការធ្វើខុស គួរតែធ្វើឲ្យស្មើគ្នាជាមួយនឹងការសរសើរ ចំពោះការធ្វើអ្វីដែលត្រឹមត្រូវ។ វិន័យសម្រាប់ក្តីស្រឡាញ់ដែលយើងបានរៀននៅក្នុងមេរៀនទី២ (គម្ពីរ១កូរិនថូសជំពូក ១៣) គួរតែយកមកអនុវត្តនៅក្នុងឥរិយាបថរបស់ឪពុកម្តាយ និង នៅក្នុងទង្វើដែលធ្វើទៅលើកូនៗ ព្រមទាំងទៅលើទំនាក់ទំនងដទៃទៀតដែរ។ មនុស្សគ្រប់គ្នាមានសិទ្ធិទទួលបានភាពថ្លៃថ្នូរ និង ការគោរព ដោយមិនគិតពីអាយុនោះទេ។

លំហាត់អនុវត្តន៍

---

១៣ តើប្រយោគមួយណា នៅខាងក្រោមនេះ ដែលនិយាយសង្ខេបបានល្អជាងគេ ពីរបៀបដែលឪពុកម្តាយគួរតែឆ្លើយតបទៅនឹងបញ្ហារបស់កូនៗដែលមិនស្តាប់បង្គាប់ កង្វះការបណ្តុះបណ្តាល និង បញ្ហាកង្វះក្តីស្រឡាញ់។

ក) ឪពុកម្តាយមិនគួរអនុញ្ញាតឲ្យមានការមិនស្តាប់បង្គាប់ទេ ប៉ុន្តែគួរតែយកចិត្តទុកដាក់បណ្តុះបណ្តាលកូនៗរបស់ពួកគេ និង បង្ហាញថាអ្នកស្រឡាញ់ពួកគេ ។

ខ) រឿងសំខាន់បំផុតដែលឪពុកម្តាយធ្វើបានសម្រាប់កូនៗរបស់ពួកគេគឺ ការដាក់ទោសពួកគេនៅពេលដែលពួកគេមិនស្តាប់បង្គាប់។

គ) ដំណោះស្រាយនៅក្នុងព្រះគម្ពីរសម្រាប់បញ្ហានៅក្នុងគ្រួសារ

វគ្គបំណងទី៧. *សង្ខេបនៅក្នុងតារាងមួយ អំពីហានៈ និង ទំនួលខុសត្រូវរបស់សមាជិកម្នាក់នៅក្នុងគ្រួសារ។*

នៅចុងបញ្ចប់នៃមេរៀននេះ ខ្ញុំចង់សង្ខេបយ៉ាងខ្លីអំពី គោលការណ៍មូលដ្ឋាននៅក្នុងព្រះគម្ពីរ ដែលទាក់ទងនឹង ទំនួលខុសត្រូវរបស់ប្តី របស់ប្រពន្ធ របស់ឪពុកម្តាយ និង របស់កូនៗ។ ការធ្វើតាមគោលការណ៍ទាំងនេះ នឹងជួយអ្នកដោះស្រាយបញ្ហាជាច្រើន ដែលកើតឡើងនៅក្នុងគ្រួសារ។ គោលការណ៍ទាំងនោះគឺជាគំរូរបស់ព្រះជាម្ចាស់សម្រាប់គ្រួសារគ្រិស្តបរិស័ទដែលជោគជ័យនៅក្នុងជីវិត។

ទំនួលខុសត្រូវរបស់ប្តី

ផ្តល់ការដឹកនាំ

គំរូដែលនៅក្នុងព្រះគម្ពីរគឺថា ប្តីទទួលបានការដឹកនាំពីព្រះអម្ចាស់សម្រាប់គ្រួសាររបស់គាត់។ ព្រះជាម្ចាស់ដឹកនាំលោក អប្រាហាំឲ្យចាកចេញពីផ្ទះរបស់លោក ហើយចូលទៅទឹកដីដែលព្រះជាម្ចាស់បានជ្រើសរើស (គម្ពីរលោកុប្បត្តិ ១២:១) ។ ព្រះអម្ចាស់បានដឹកនាំលោកយ៉ាកុប ឲ្យត្រឡប់ទៅទឹកដីរបស់ឪពុកលោកវិញ (គម្ពីរលោកុប្បត្តិ ៣១:៣) ។ ព្រះជាម្ចាស់បានដឹកនាំលោកយ៉ូសែប ឲ្យរត់ទៅស្រុបអេស៊ីព្ទ ដើម្បីគ្រួសាររបស់លោក(គម្ពីរម៉ាថាយ ២:១៣)។

ព្រះវិញ្ញាណដ៏វិសុទ្ធ បានដឹកនាំលោកប៉ូលឲ្យបកស្រាយពីក្រិតក្រមនៃសិទ្ធិអំណាច នៅក្នុងគ្រួសាររបស់គ្រិស្តបរិស័ទ៖ "ក៏ប៉ុន្តែ ខ្ញុំចង់អោយបងប្អូនជ្រាបថា ព្រះគ្រិស្តនាំមុខ បុរសគ្រប់រូប បុរសនាំមុខស្ត្រី ហើយព្រះជាម្ចាស់នាំមុខព្រះគ្រិស្ត។" (គម្ពីរ១កូរិនថូស ១១:៣)។ " កុមារកុមារីអើយ ចូរស្តាប់បង្គាប់មាតាបិតា ដោយយល់ដល់ព្រះអម្ចាស់ ធ្វើដូច្នេះទើបត្រឹមត្រូវ។" (គម្ពីរអេភេសូ ៦:១) ។

ដូចជាក្បាលដែលត្រូវដឹងគ្រប់យ៉ាងពីខ្លួនប្រាណទាំងមូល មុនពេលវាអាចមានទំនាក់ទំនងអំពីទិសដៅបាន ប្តីក៏ត្រូវដឹងគ្រប់តម្រូវការប្រពន្ធ និង កូនៗរបស់គាត់ ព្រមទាំងទិសដៅដែលមកពីព្រះជាម្ចាស់ ដើម្បីធ្វើខ្លួនជាអ្នកដឹកនាំខាងឯវិញ្ញាណនៅក្នុងគ្រួសារមួយបានផងដែរ។ បុរសម្នាក់ដែលរស់នៅ ដោយការចុះចូលទាំងស្រុងទៅចំពោះព្រះគ្រិស្ត នឹងបានដឹងពីរបៀបដឹកនាំកិច្ចការនៅក្នុងគ្រួសាររបស់គាត់ តាមរបៀបដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ។ របៀបដឹកនាំនេះរួមបញ្ចូលទាំងការដឹកនាំនៅក្នុងបញ្ហាខាងឯវិញ្ញាណផងដែរ៖ "រីឯខ្ញុំ និងក្រុមគ្រួសាររបស់ខ្ញុំវិញ យើងនឹងគោរពបំរើព្រះអម្ចាស់"
(គម្ពីរយ៉ូស្វេ ២៤:១៥) ។ (សូមមើលនៅក្នុងគម្ពីរកិច្ចការ ១៦:៣១ ផងដែរ)។ ប្រពន្ធ និង កូនរបស់គាត់ដែលជាគ្រិស្តបរិស័ទ ហើយចុះចូលជាមួយនឹងព្រះអម្ចាស់តែមួយ នឹងចិត្តគាំទ្រ សិទ្ធិអំណាចរបស់គាត់។

ផ្តល់ការផ្គត់ផ្គង់

ប្តីមានទំនួលខុសត្រូវក្នុងការផ្គត់ផ្គង់ តម្រូវការខាងសាច់ឈាមសម្រាប់គ្រួសារ និង ផ្តល់ការការពារ សម្រាប់ពួកគេផងដែរ (គម្ពីរ ១ធីម៉ូថេ ៥:៨)។

ផ្តល់ក្តីស្រឡាញ់

ប្តីគឺត្រូវតែស្រឡាញ់ប្រពន្ធរបស់គាត់ *ដូចជាព្រះគ្រិស្តស្រឡាញ់ក្រុមជំនុំ* ដែរ (គម្ពីរអេភេសូ ៥:២៥) ។ តើព្រះយេស៊ូស្រឡាញ់ក្រុមជំនុំយ៉ាងដូចម្តេច? ហេតុអ្វី?

១. គាត់ត្រូវលះបង់ខ្លួនឯងដើម្បីនាង (គម្ពីរអេភេសូ ៥:២៥; គម្ពីររ៉ូម៥:៨)។ នេះគឺជាក្តីស្រឡាញ់ ដែល មានការបូជារបស់ប្តី ដែលគាត់សុខចិត្តរងទុក្ខដើម្បីប្រពន្ធរបស់គាត់បានទទួលការល្អ។

២. ប្រោសអោយក្រុមជំនុំបានទៅជាវិសុទ្ធ (គម្ពីរអេភេសូ ៥:២៦)។ ក្តីស្រឡាញ់ប្តីគួរតែជា ការលើកទឹកចិត្ត និង ការជម្រុញចិត្ត សម្រាប់ប្រពន្ធរបស់គាត់នៅក្នុងដំណើរខាងឯវិញ្ញាណរបស់នាង នៅក្នុងព្រះគ្រិស្ត។

៣. ជំរះនាងអោយបានស្អាតបរិសុទ្ធ ដោយលាងក្នុងទឹក និងដោយសារព្រះបន្ទូល (គម្ពីរអេភេសូ ៥:២៦)។ ក្តីស្រឡាញ់របស់ប្តី គួរតែរួមបញ្ចូលទាំងការចែកចាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាមួយប្រពន្ធរបស់គាត់ ដែលអាចឲ្យអ្នកទាំងពីរបានសំអាតឲ្យបរិសុទ្ធ និង អប់រំតាមរយៈព្រះ បន្ទូលនោះផង។

៤. "នាំក្រុមជំនុំ (ភរិយា) នេះមកថ្វាយព្រះអង្គ(ប្តី)ផ្ទាល់ ....អោយបានទៅជាវិសុទ្ធ* ឥតសៅហ្មង។" (គម្ពីរអេភេសូ ៥:២៧)។ ក្តីស្រឡាញ់ដែលមានគោលដៅចង់បានផលប្រយោជន៍សម្រាប់ វិញ្ញាណរបស់ប្រពន្ធ នឹងឆ្លុះបញ្ចាំងឲ្យឃើញពីប្តី តាមរយៈវិញ្ញាណដែលឥតសៅហ្មងរបស់ ប្រពន្ធ។

៥. ព្រះគ្រិស្តស្រឡាញ់យើង*ជាមុន* (គម្ពីរ១យ៉ូហាន ៤:១៩)។ ប្តីគួរតែជាអ្នកបង្ហាញក្តីស្រឡាញ់ មុនដំបូងបង្អស់។

៦. ដូចជាព្រះកាយរបស់ព្រះអង្គ (គម្ពីរអេភេសូ ៥:២៩) ។ ក្រុមជំនុំគឺជាព្រះកាយរបស់ព្រះគ្រិស្ត (គម្ពីររ៉ូម១២:៥)។ ការបង្ហាញក្តីស្រឡាញ់បែបនេះ រួមបញ្ចូលទាំងអ្វីៗដែលបុរសម្នាក់ធ្វើសម្រាប់ រូបកាយរបស់គាត់ ក្តីស្រឡាញ់ដែលធ្វើឲ្យគាត់ថែទាំ និង ផ្គត់ផ្គង់សម្រាប់ប្រពន្ធរបស់គាត់តាមគ្រប់មធ្យោបាយ។ ក្តីស្រឡាញ់នេះ គឺផ្តល់ទៅតាមរយៈភាពស្មោះត្រង់របស់គាត់ទៅចំពោះនាង (គម្ពីរសុភាសិត ៥:១៥,១៨,១៩; គម្ពីរម៉ាឡាគី ២:១៥-១៦) តាមរយៈការចេះយល់ចិត្ត (គម្ពីរ១ពេត្រុស ៣:៧ គម្ពីរកូឡូស ៣:១៩)និង តាមរយៈការបង្ហាញការកោតសរសើរ (គម្ពីរសុភាសិត ៣១:២៨-៣១)។

លំហាត់អនុវត្តន៍

១៤ តើអ្នកគិតថាហេតុអ្វីបានជាវាមានសារៈសំខាន់យ៉ាងខ្លាំង ដែលប្តីត្រូវស្រឡាញ់ប្រពន្ធរបស់គាត់ នៅក្នុងរបៀបទាំងនេះ?

.....

.....

ទំនួលខុសត្រូវរបស់ប្រពន្ធ

នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី មិនបានបង្រៀនថា ស្ត្រីគឺតូចទាបជាងបុរសនោះឡើយ៖ "...គ្មានបុរសគ្មានស្ត្រីទៀតដែរ គឺបងប្អូនទាំងអស់បានរួមគ្នាមកជាអង្គតែមួយ ក្នុងព្រះគ្រិស្តយេស៊ូ" (គម្ពីរកាឡាទី ៣:២៨)។ បទគម្ពីរនោះក៏បានលើកឡើងអំពី ទាសករ អ្នកមានសេរីភាព សាសន៍យូដា និង សាសន៍ក្រិកផងដែរ។ បទគម្ពីរនេះបានបង្រៀនថា ព្រះគ្រិស្តទទួលមនុស្សទាំងអស់ ឲ្យពួកគេមានកម្រិតស្មើៗគ្នា មិនថាគេមានភាពខុសគ្នាយ៉ាងណាក៏ដោយ។ ភាពជាអ្នកដឹកនាំរបស់ប្តី គឺរឿងដែលទាក់ទងទៅនឹងការទទួលខុសត្រូវ និង ការរៀបចំឲ្យមានរចនាសម្ព័ន្ធដែលមានឋានានុក្រមត្រឹមត្រូវ។ សហគមន៍គ្រប់ទាំងអស់ត្រូវមានការដឹកនាំ ហើយព្រះជាម្ចាស់បានជ្រើសរើសស្វាមីដើម្បីឲ្យធ្វើជាអ្នកដឹកនាំនៅក្នុងគ្រួសារ។

ដើម្បីឲ្យមានអ្នកដឹកនាំមួយបាន ត្រូវតែមានអ្នកដើរតាម។ ប្រពន្ធធ្វើតាមការដឹកនាំរបស់ប្តីនាងដោយការចុះចូលរបស់នាង ៖ "ហេតុនេះ ក្រុមជំនុំគោរពចុះចូលនឹងព្រះគ្រិស្តយ៉ាងណា ភរិយាក៏ត្រូវគោរពចុះចូលនឹងស្វាមីរៀងៗខ្លួន ក្នុងគ្រប់កិច្ចការទាំងអស់យ៉ាងនោះដែរ។" (គម្ពីរអេភេសូ ៥:២៤) ។ ការចុះចូលរបស់ប្រពន្ធ គឺត្រូវធ្វើឲ្យដូចជាការ *ចុះចូលនឹងព្រះជាម្ចាស់* (ជំពូក៥:២២) *ដោយការគោរព* (ជំពូក ៥:៣៣) ហើយ*ស្របតាមរបៀបអ្នកជឿលើព្រះអម្ចាស់* (គម្ពីរកូឡូស ៣:១៨)។ សូមពិចារណាពីការនេះបន្តិច! ការប្តេជ្ញា និង ការចុះចូល ដូចគ្នានឹងទង្វើរបស់យើងទៅកាន់ព្រះជាម្ចាស់ ក៏ត្រូវតែជាទង្វើរបស់អ្នកទៅចំពោះស្វាមីរបស់អ្នកដែរ។ ប្រពន្ធដែលជាគ្រិស្តបរិស័ទម្នាក់ នឹងលើកប្តីរបស់នាងឲ្យបានខ្ពង់ខ្ពស់ នាងនឹងតម្កើងគាត់ ពេញចិត្តនឹងគាត់ និងអ្វីដែលគាត់ធ្វើ ជាងមនុស្សអ្នកដទៃ ព្រមទាំង សរសើរគាត់ផងដែរ។ ហើយប្រសិនបើស្វាមីរបស់នាងមិនមែនជាអ្នកជឿនោះទេ នាងអាចយកឈ្នះគាត់បានដោយសារតែអាកប្បកិរិយារបស់នាង ដែលមិនចាំបាច់*និយាយ*អ្វីនោះទេ (គម្ពីរ ១ពេត្រុស ៣:១)។ នេះមានន័យថារបៀបរស់នៅដែលយោងទៅតាមគោលការណ៍របស់គ្រិស្តបរិស័ទ នឹងអាចឈ្នះ បានចិត្តប្តីដែល មិនមែនជាអ្នកជឿដោយមិនចាំបាច់ត្រូវតែនិយាយអ្វីឡើយ។

គម្ពីរទីតុស ២:៣-៥ បានផ្តល់ឲ្យយើងនូវទំនួលខុសត្រូវផ្សេងទៀតរបស់ប្រពន្ធ។ រឿងទាំងនេះគឺជាអ្វីដែលស្ត្រីៗចំណាស់ ត្រូវតែបង្រៀនទៅកាន់ស្ត្រីៗវ័យក្មេង ប៉ុន្តែស្ត្រីៗវ័យចំណាស់ ត្រូវតែប្រាកដថាជីវិតរបស់ពួកគាត់គឺជាគំរូមួយផងដែរ។ ពួកគាត់ត្រូវតែមានរបៀបរស់នៅដ៏គួរឲ្យគោរព មិនមែនជាអ្នកនិយាយមួលបង្កាច់គេ និងមិនមែនជាអ្នកចំណូលស្រានោះទេ ។ បន្ទាប់មក ពួកគាត់អាចបង្រៀនពួកប្រពន្ធដែលនៅក្មេងបានហើយ។

លំហាត់អនុវត្តន៍

១៥ សូមអានគម្ពីរទីតុស ២:៣-៥ ហើយសរសេររៀបរាប់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក នូវការល្អ ប្រាំពីរយ៉ាងដែលស្ត្រីចាស់ៗ ត្រូវតែបង្រៀនស្ត្រីៗនៅក្មេង?

ទំនួលខុសត្រូវរបស់ឪពុកម្តាយ

ឪពុកម្តាយមានទំនួលខុសត្រូវបណ្តុះបណ្តាលកូនៗរបស់ពួកគេៗ

ការបណ្តុះបណ្តាលត្រូវមានគ្រប់មធ្យោបាយ ទាំងការបង្ហាញ*គំរូ ការបង្រៀន* និង *ការប្រៀនប្រដៅ*នៅពេលណាដែលត្រូវការ។ កូនៗ រៀនសូត្រតាមអ្វីដែលគេមើលឃើញនៅក្នុងមជ្ឈដ្ឋានជុំវិញរបស់ពួកគេ។ ពួកគេក៏រៀនសូត្រដោយទទួលការបង្ហាត់បង្រៀន និង ពេលខ្លះពួកគេរៀនសូត្របានដោយទទួលការប្រៀនប្រដៅ ដោយមានរបៀបវិន័យសមរម្យ។ (គម្ពីរសុភាសិត ២៩:១៥,១៧)។ (សូមមើលនៅក្នុងគម្ពីរសុភាសិត ២២:៦ និង គម្ពីរអេភសូ ៦:៤ ផងដែរ។)

ការប្រៀនប្រដៅកូនៗ ត្រូវតែយុត្តិធម៌

"រីឯបងប្អូនដែលជាឪពុកវិញ កុំធ្វើអោយកូនរបស់ខ្លួនមួម៉ៅនោះឡើយ" (គម្ពីរអេភេសូ ៦:៤)។ "បងប្អូនដែលមានកូនអើយ កុំដុកដាន់កូនរបស់ខ្លួនឡើយ ក្រែងលោវាបាក់ទឹកចិត្ត។" (គម្ពីរកូឡូស ៣:២១)។ មិនត្រូវប្រៀនប្រដៅលើកូនដោយសារតែអ្វី ដែលពួកគេមិនដឹងថាជារឿងដែលខុសនោះទេ ហើយក៏មិនត្រូវប្រៀនប្រដៅពួកគេដោយសារតែកំហឹងរបស់អ្នកដែរ។ ការប្រៀនប្រដៅត្រូវធ្វើដោយមានការទប់ចិត្ត។ កូនៗត្រូវតែដឹងថា នឹងមានផលវិបាកដោយសារសកម្មភាពមួយចំនួន។ នេះមានន័យថា ឪពុកម្តាយត្រូវចំណាយពេលវេលា និង កម្លាំងដែលចាំបាច់សម្រាប់ប្រៀនប្រដៅកូនៗនៅពេលណាដែលពួកគេត្រូវការការប្រៀនប្រដៅតែប៉ុណ្ណោះ ។ ចូរបកស្រាយពីមូលហេតុដែលពួកគេត្រូវទទួលការប្រៀនប្រដៅហើយអ្នកអាចអធិស្ឋានជាមួយគេអំពីការនោះផងដែរ។ (គម្ពីរហេប្រឺ ១២:៦-៩; គម្ពីរ ២ធីម៉ូថេ ៣:១៦-១៧)

ការប្រៀនប្រដៅកូនៗគឺមានន័យដូចជាជីវិតសម្រាប់ពួកគេយ៉ាងដូច្នោះដែរ។ កូនៗមិនអាចនាំខ្លួនគេចូលទៅក្រោមសិទ្ធិអំណាចរបស់ព្រះជាម្ចាស់បានទេ ប្រសិនបើពួកគេមិនធ្លាប់បានរៀនសូត្រពីការនាំខ្លួនគេឲ្យចូលទៅក្រោមសិទ្ធិអំណាចរបស់ឪពុកម្តាយរបស់ពួកគេផងនោះ។ (សូមមើលគម្ពីរសុភាសិត ១៩:១៨; ២៣:១៣-១៤; ២៩:១៧)

ការបណ្តុះបណ្តាល និង ការប្រៀនប្រដៅ ត្រូវធ្វើប្រកបដោយក្តីស្រឡាញ់

ឪពុកម្តាយត្រូវតែកែប្រែឥរិយាបថរបស់ពួកគេ ទៅតាមព្រះវរបិតានៃស្ថានបរមសុខ៖ "ទោះបីព្រះអង្គដាក់ទោសក្តី ព្រះអង្គនៅតែអាណិតមេត្តាដដែល ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ធំពន់ពេកក្រៃ។ ព្រះអង្គមិនសប្បាយព្រះហឫទ័យនឹង ដាក់ទោស ឬធ្វើទណ្ឌកម្មមនុស្សម្នាទេ។" (គម្ពីរបរិទេវ ៣:៣២-៣៣)។

លំហាត់អនុវត្តន៍

១៦ សូមអានគម្ពីរហេប្រឺ ១២:៥-១១ ហើយគូសរង្វង់ជុំវិញ អក្សរនៅពីមុខចម្លើយត្រឹមត្រូវដែលបក ស្រាយអំពីមូលហេតុដែលព្រះជាម្ចាស់ប្រៀនប្រដៅ កូនចៅរបស់ទ្រង់ និងមូលហេតុដែល ឪពុក ម្តាយត្រូវប្រៀនប្រដៅកូនៗរបស់ពួកគេ។

ក) ទ្រង់សព្វព្រះទ័យក្នុងការស្តីបន្ទោសកូនចៅរបស់ទ្រង់។

ខ) ទ្រង់ស្រឡាញ់កូនចៅរបស់ទ្រង់។

គ) ពួកគេជាកូនចៅរបស់ទ្រង់។ (ទ្រង់មានទំនួលខុសត្រូវចំពោះពួកគេ)។

ឃ) ទ្រង់ក្រោធចំពោះពួកគេ ហើយចង់ដាក់ទោសពួកគេ។

ង) ដើម្បីទទួលបានការគោរពរបស់ពួកគេ។

ច) ដើម្បីឲ្យពួកគេបានល្អ ដែលពួកគេអាចទទួលបានភាពវិសុទ្ធរបស់ទ្រង់។

ឆ) ដើម្បីធ្វើឲ្យពួកគេឈឺចាប់។

ជ) ដើម្បីធ្វើឲ្យមានភាពសុចរិត និង សន្តិភាព។

យើងបានឃើញនៅក្នុងបទគម្ពីរនេះរួចមកហើយថា ការឆ្លើយតបរបស់កូនទៅចំពោះការប្រៀនប្រដៅរបស់ឪពុកម្តាយគេ មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងជីវិតរបស់គេទៅថ្ងៃមុខ ក្នុងការចុះចូលទៅចំពោះព្រះជាម្ចាស់ និង ការប្រៀនប្រដៅរបស់ទ្រង់។

ទំនួលខុសត្រូវរបស់កូនៗ

ដំបូងបង្អស់ កូនៗតម្រូវឲ្យគោរព និង ស្តាប់បង្គាប់ឪពុកម្តាយរបស់ពួកគេ (គម្ពីរនិក្ខមនំ ២០:១២; គម្ពីរអេភេសូ ៦:១-៣)។ ព្រះពររបស់ព្រះជាម្ចាស់ គឺស្ថិតនៅជាមួយកូនៗណាដែលស្តាប់បង្គាប់ឪពុកម្តាយរបស់ពួកគេ (គម្ពីរយេរេមា ៣៥:៦-៧,១៨-១៩)។ កូនៗណាដែលស្តាប់បង្គាប់ឪពុកម្តាយរបស់ពួកគេបានច្រើន នោះពួកគេមុខជាអាចបណ្តុះបណ្តាលកូនៗរបស់ពួកគេបានល្អផងដែរ។

ការគោរពឪពុកម្តាយរបស់អ្នក មិនមែនត្រូវបានបញ្ចប់នៅពេលដែលអ្នកបានធំពេញវ័យនោះទេ។ យុវជនវ័យក្មេងម្នាក់ត្រូវតែចងចាំការណែនាំ និង ការបង្ហាត់បង្រៀនរបស់ឪពុក ឬម្តាយរបស់គាត់ នៅពេលដែលគាត់ចាកចេញទៅ ក្នុងពិភពលោកដោយខ្លួនឯង។ យុវជនយុវនារី ដែលទទួលបានផលចំណេញពីការបង្រៀនរបស់ឪពុកម្តាយគេ នោះនឹងនាំឲ្យពួកគេមានអំណរយ៉ាងអស្ចារ្យ។ (គម្ពីរសុភាសិត ២៣:២២-២៥)

នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ មានការដាក់ទោសយ៉ាងធ្ងន់ធ្ងរទៅលើកូនៗណា ដែលមិនស្តាប់បង្គាប់ និង មិនចេះគោរព (សូមមើលគម្ពីរនិក្ខមនំ ២១:១៥ ; គម្ពីរលេវីវិន័យ ២០:៩; គម្ពីរទុតិយកថា ២១:១៨-២១; គម្ពីរសុភាសិត ២៨:២៤; ៣០:១៧)។

លំហាត់អនុវត្តន៍

១៧ ចូរសរសេរ ហាន:នៅក្នុងសមាជិកគ្រួសារនីមួយៗ ហើយសរសេរទំនួលខុសត្រូវចម្បងសម្រាប់សមាជិកនីមួយៗក្នុងគ្រួសារ ដាក់ក្នុងតារាងខាងក្រោមនេះ។

ព្រះគ្រិស្តជា សិរសារបស់គ្រួសារ	
ហាន:	**ទំនួលខុសត្រូវចម្បង**
ក)	
ខ)	
គ)	

នៅពេលដែលមានការព្រងើយកន្តើយចំពោះ សេចក្តីណែនាំដ៏វិសុទ្ធទាក់ទងនឹងទំនួលខុសត្រូវរបស់សមាជិកគ្រួសារទាំងនេះ នោះមុខជាមានបញ្ហាកើតមានឡើងជាមិនខាន។ គំរូរបស់ព្រះជាម្ចាស់គឺពិតជាមានប្រសិទ្ធិភាព ហើយគ្រួសារដែលរស់នៅតាមគោលការណ៍ទាំងនេះ នឹងបានស្គាល់ពីក្តីស្រឡាញ់ ភាពរីករាយ និង ភាពពេញបរិបូរណ៌។ តើនេះគឺជាប្រភេទនៃគ្រួសាររបស់អ្នកមែនទេ? ប្រសិនបើមិនមែននោះទេ តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីឲ្យគ្រួសាររបស់យើងក្លាយទៅជា គ្រួសារដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ? អ្នកអាចចាប់ផ្តើមពីខ្លួនឯងទៅ នៅពេលដែលអ្នកបំពេញទំនួលខុសត្រូវដែលព្រះជាម្ចាស់បានប្រទានឲ្យអ្នកទៅចំពោះគ្រួសាររបស់អ្នកហើយ នោះវានឹងមានភាពងាយស្រួលដើម្បីឲ្យសមាជិកគ្រួសារផ្សេងទៀតដើរតាមជំហានដូចគ្នានោះដែរ។ ការធ្វើការផ្លាស់ប្តូរមួយ ប្រហែលជាមិនងាយស្រួល ឬ បានឆាប់ៗនោះទេ ប៉ុន្តែលទ្ធផលដែលនឹងទទួលបាន គឺពិតជាស័ក្តិសមគួរឲ្យធ្វើណាស់!

លំហាត់អនុវត្តន៍

១៨ ដូចដែលយើងបានធ្វើនៅក្នុងមេរៀនមុនដែរ យើងខ្ញុំសូមលើកទឹកចិត្តអ្នកក្នុងពេលនេះ ឲ្យយកគោលការណ៍នៃមេរៀននេះទៅអនុវត្ត ដើម្បីស្វែងរកដំណោះស្រាយសម្រាប់បញ្ហាដែលអាចមាននៅក្នុងគ្រួសាររបស់អ្នក។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺជាជំនួយដ៏បរិបូរណ៌ហួរហៀរ។ ចូរអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជុំគ្នាក្នុងគ្រួសារ ហើយអនុញ្ញាតឲ្យទ្រង់មានព្រះបន្ទូលមកកាន់ដួងចិត្តរបស់អ្នក។

ការប្រឡងផ្ទាល់ខ្លួន

សំណួរពហុជម្រើសៗ ចូរជ្រើសរើសចម្លើយដែលល្អបំផុតសម្រាប់សំណួរនីមួយៗ។

១ ហានៈរបស់ប្តីចំពោះប្រពន្ធរបស់គាត់អាចប្រៀបធៀបទៅនឹងហានៈរបស់

ក) ម្តាយចំពោះកូនរបស់គាត់។

ខ) ក្រុមជំនុំទៅចំពោះព្រះគ្រិស្ត។

គ) ព្រះគ្រិស្តទៅចំពោះក្រុមជំនុំ។

២ ការបណ្តុះបណ្តាលកូនៗដែលត្រឹមត្រូវ មានរួមបញ្ចូល

ក) ការដាក់ទោស និង ការព្រមព្រៀង

ខ) ការបង្រៀន ការប្រៀនប្រដៅ និង ក្តីស្រឡាញ់

គ) ការបណ្តែតបណ្តោយ

ឃ) ការទិទៀនរិះគន់

៣ ការលែងលះ ត្រូវបានអនុញ្ញាតឲ្យធ្វើបានតែនៅក្នុងករណី

ក) អំពើសហាយស្មន់

ខ) ការរៀបការជាមួយអ្នកមិនជឿ

គ) មានការមិនចុះសម្រុងគ្នា ទៅលើរឿងកូនៗ

ឃ) មានការប្រច័ណ្ឌ

៤ ជនរងគ្រោះខ្លាំងបំផុតនៅក្នុង ការលែងលះគ្នាគឺ

ក) ប្តី

ខ) ប្រពន្ធ

គ) ភាគីដែលត្រូវបានគេបំពាន

ឃ) កូនៗ

៥ ប្រសិនបើអ្នកដែលបានលែងលះប្តីប្រពន្ធ រៀបការម្តងទៀតនៅមុនពេលដែលគាត់ប្រែចិត្តទទួលជឿ នោះក្រោយពេលដែលបានផ្លាស់ប្រែហើយ

ក) ត្រូវត្រឡប់ទៅរកអាពាហ៍ពិពាហ៍ចាស់របស់គាត់។

ខ) បញ្ចប់អាពាហ៍ពិពាហ៍ទីពីររបស់គាត់ ហើយទៅរស់នៅតែម្នាក់ឯង។

គ) បន្តរស់នៅជីវិតអាពាហ៍ពិពាហ៍ថ្មី ក្នុងពេលដែលបានធ្វើការផ្លាស់ប្រែនោះ។

៦ តើមានអ្វីដែលបានបាត់បង់ក្នុងចំណងអាពាហ៍ពិពាហ៍មួយ នៅពេលដែលដៃគូម្ខាងបន្ថោក (មើលងាយ)តម្លៃ របស់ដៃគូម្ខាងទៀត?

ក) ភាពជាអ្នកដឹកនាំ

ខ) ក្តីស្រឡាញ់ និង ការគោរព

គ) ទំនុកចិត្ត

ឃ) ការរួបរួម

៧ បញ្ហាហិរញ្ញវត្ថុនៅក្នុងគ្រួសារមួយ អាចដោះស្រាយបានយ៉ាងងាយ នៅពេលដែលប្តីប្រពន្ធមានការយល់ព្រម

ក) ធ្វើការជាច្រើនម៉ោងថែមទៀត។

ខ) ទុកឲ្យប្រពន្ធជាអ្នកចាត់ចែងលុយកាក់។

គ) ថ្វាយដង្វាយរបស់គេជាមុនសិន។

ឃ) ជៀសវាងការចំណាយដែលមិនបានព្រៀងទុក។

ត្រូវ/ខុស។ ចូរសរសេរអក្សរ **ត** នៅមុខចម្លើយត្រឹមត្រូវ និង សរសេរអក្សរ **ខ** នៅមុខចម្លើយដែលមិនត្រឹមត្រូវ។

.....៨ ម្តាយគួរតែជាអ្នកដឹកនាំខាងឯវិញ្ញាណនៅក្នុងគ្រួសារ។

.....៩ ការប្តេជ្ញាជ្រុលនៅលើសកម្មភាពដែលនៅខាងក្រៅផ្ទះ គឺជាបញ្ហានៅពេលណាដែលវារារាំងមិនឲ្យគ្រួសារបានចំណាយពេលជាមួយគ្នា។

.....១០ កូនៗដែលស្តាប់បង្គាប់ ភាគច្រើនអាចបម្រើព្រះជាម្ចាស់ ជាជាងកូនដែលមិនស្តាប់បង្គាប់។

.....១១ គ្រិស្តបរិស័ទដែលរៀបការជាមួយអ្នកមិនជឿ គឺអាចមានសេរីភាពចេញពេលណាក៏បាន។

.....១២ អាទិភាពទីមួយរបស់បុរសម្នាក់ គឺទៅចំពោះឪពុកម្តាយរបស់គាត់។

.....១៣ ឪពុកម្តាយគួរត្រៀមខ្លួនជានិច្ចដើម្បីជួយកូនណាដែលបានបះបោរ។

.....១៤ ទំនួលខុសត្រូវរបស់ប្តី គឺត្រូវដឹកនាំគ្រួសាររបស់គាត់ និង ធ្វើការផ្គត់ផ្គង់ពួកគេ។

.....១៥ ភាពជាប្រមុខរបស់គ្រួសារត្រូវបង្កើតឡើងដោយក្តីស្រឡាញ់ ដើម្បីជាប្រយោជន៍ឲ្យវាអាចដំណើរការទៅបានយ៉ាងរលូន។

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១០ អ្នកដឹកនាំត្រូវចេះមើលការខុសត្រូវ ក្រុមគ្រួសារ និង ផ្ទះសម្បែងរបស់ពួកគេ ហើយឃើញថា កូនៗរបស់ពួកគេចេះស្តាប់បង្គាប់ និង គោរពពួកគេផងដែរ។ (ខ៤ ,ខ៥ និង ខ១២)។

១ ខ) វាមិនអាចមានការព្រមព្រៀងបាននោះទេ រវាងរឿងទាំងនេះ ព្រោះរឿងនីមួយៗមានគុណតម្លៃផ្ទុយគ្នា។

១១ ខ) ប្រពន្ធ និង កូន (លើកលែងតែមានតម្រូវការរបស់ឪពុកម្តាយ ដែលប្រពន្ធក៏យល់ស្របថាជាអាទិភាពចម្បងដែរ។

២ ព្រោះពួកគេគឺជារូបកាយតែមួយរួចទៅហើយ នោះគឺជាការប្តេជ្ញាចិត្តអស់មួយជីវិត។

១២ ក) ៣) បញ្ហាហិរញ្ញវត្ថុ

ខ) ៤) កង្វះការគោរព

គ) ៧) ការប្រច័ណ្ឌ

ឃ) ១) ការប្តេជ្ញាជ្រុល

ង) ៥) ភាពខុសគ្នាក្នុងការបណ្តុះបណ្តាលកូន

ច) ២) បញ្ហាទាក់ទងនឹងសាច់ញាតិ

ឆ) ៦) កង្វះទំនាក់ទំនង

៣ ក) គ្រិស្តបរិស័ទគួរតែរៀបការជាមួយអ្នកណាដែលជាគ្រិស្តដូចគ្នាប៉ុណ្ណោះ។

ខ) ប្តីគួរតែជាអ្នកដឹកនាំខាងឯវិញ្ញាណនៅក្នុងគ្រួសារ។

១៣ ក) ឪពុកម្តាយមិនគួរអនុញ្ញាតឲ្យមានការមិនស្តាប់បង្គាប់ទេ ប៉ុន្តែគួរតែយកចិត្តទុកដាក់បណ្តុះបណ្តាលកូនៗរបស់ពួកគេ និង បង្ហាញថាអ្នកស្រឡាញ់ពួកគេ ។

៤ ខ) មានបំណងចង់បំពេញឲ្យគ្នាទៅវិញទៅមក។

១៤ ចម្លើយរបស់អ្នក។ សម្រាប់ខ្ញុំ ខ្ញុំអាចឆ្លើយយ៉ាងដូច្នេះ៖ ប្តីទទួលបានតំណែងជាប្រមុខដឹកនាំលើប្រពន្ធរបស់គាត់។ មធ្យោបាយមួយគត់ដែលគាត់អាចបំពេញទំនួលខុសត្រូវនេះបានល្អ គឺមានជាមួយនឹងក្តី*ស្រឡាញ់* ។

៥ គ) ដៃគូប្តីប្រពន្ធ មានសេរីភាពអាចចាកចេញ ប្រសិនបើដៃគូម្ខាងទៀតបានប្រព្រឹត្តបាបក្នុងអំពើសហាយស្មន់។

ឃ) បាបនៃអំពើសហាយស្មន់ អាចនឹងត្រូវបានអត់ទោសឲ្យ ហើយចំណងអាពាហ៍ពិពាហ៍អាចបន្តសាជាថ្មី។

១៥ ស្ត្រីគ្រប់រូបត្រូវចេះស្រឡាញ់ស្វាមី ស្រឡាញ់កូនរបស់ខ្លួន អោយមានចិត្តធ្ងន់ មានចរិយាបរិសុទ្ធ យកចិត្តទុកដាក់នឹងកិច្ចការក្នុងផ្ទះសំបែង មានចិត្តល្អ និងគោរពចុះចូលនឹងស្វាមីរៀងៗខ្លួន។

៦ ខ) ដៃគូដែលរងគ្រោះ អាចលែងលះ និង រៀបការម្តងទៀតបាន។

១៦ ខ), គ), ង), ច) និង ជ) ជាចម្លើយត្រឹមត្រូវ។

៧ ដៃគូប្តីប្រពន្ធនេះ គួរតែបន្តរស់នៅក្នុងស្ថានភាពដែលពួកគេទទួលបានការប្រោសលោះ នោះមានន័យថា ពួកគេគួរបន្តជីវិតអាពាហ៍ជាមួយគ្នា និងទទួលយកភាពតែមួយដែលព្រះជាម្ចាស់បានប្រទានឲ្យពួកគេតាមរយៈការលន់តួ និងការកើតជាថ្មីនៅក្នុងព្រះគ្រិស្ត។

១៧ ក) ប្តី ត្រូវដឹកនាំ ផ្គត់ផ្គង់ ស្រឡាញ់ប្រពន្ធកូន និង បណ្តុះបណ្តាលកូនៗផងដែរ។

ខ) ប្រពន្ធ ត្រូវចុះចូលជាមួយការដឹកនាំរបស់ប្តី ថែទាំផ្ទះសម្បែង ស្រឡាញ់ប្តីនិងកូន និងជួយបណ្តុះបណ្តាលកូនផងដែរ។

គ) កូនៗ ត្រូវស្តាប់បង្គាប់ និង គោរពឪពុកម្តាយ។

៨ គ្រិស្តបរិស័ទ គឺត្រូវបានហាមផ្តាច់មិនឲ្យលែងលះគ្នា។ គ្រិស្តបរិស័ទមិនអាចរៀបការជាមួយអ្នកដែលបានលែងលះគ្នានោះទេ។ អ្នកដែលបានលែងលះមិនអាចការម្តងទៀតបានឡើយ។

១៨ ចម្លើយរបស់អ្នក

៩ ឃ) ការទុកចិត្ត

មេរៀនទី ៦ បញ្ហានៃជីវិតនៅលីវ (អត់គូ)

យើងរាល់គ្នារស់នៅក្នុងសង្គមដែលតម្រូវឲ្យមានគូ ជាសង្គមដែលជាធម្មតាតម្រូវឲ្យរៀបអាពាហ៍ពិពាហ៍។ សង្គមនេះតែងតែមានការរើសអើង ដែលតោងជាប់ភាពជាអ្នកនៅលីវ មនុស្សជាច្រើនហាក់ដូចជាគិតថា ប្រសិនបើនរណាម្នាក់នៅលីវ ច្បាស់ជាមានអ្វីម្យ៉ាងខុសប្លែកជាមួយអ្នកនោះហើយ! គំនិតនេះមិនមែនជាគំនិត ដែលទើបនឹងកើតថ្មីនោះទេ។ នៅក្នុងសម័យសម្ព័ន្ធមេត្រីចាស់ ជីវិតនៅលីវគឺត្រូវបានគេចាត់ទុកថា មិនគួរឲ្យគាប់ចិត្តនោះទេ (សូមមើលគម្ពីរចៅហ្វាយ ១១:៣៨; គម្ពីរអេសាយ ៤:១ និង គម្ពីរយេរេមា ១៦:៩) ។

នៅក្នុងមេរៀនទី៤ យើងបានពិភាក្សាអំពីបញ្ហានៅក្នុងទំនាក់ទំនងសង្គមរួចមកហើយ។ មានបញ្ហាដែលមនុស្សប្រឈមមុខ មិនថាជាមនុស្សនៅលីវ ឬ មនុស្សដែលបានរៀបការហើយនោះទេ។ នៅក្នុងមេរៀនទី៥ យើងបានប្រឈមមុខជាមួយនឹងបញ្ហានៅក្នុងជីវិតគ្រួសារ។ មនុស្សដែលរស់នៅតែឯង ឬ គ្មានគូគេមានបញ្ហាផ្សេងៗ និង ពិសេសៗ ដើម្បីឲ្យគេប្រឈមមុខជាមួយ ដូចជាភាពឯកាខ្លាំង ការបាក់ទឹកចិត្ត ភាពភ័យខ្លាច ការប្រឈមមុខនឹងការសម្រេចចិត្តតែម្នាក់ឯង ការត្រូវការក្តីស្រឡាញ់ និង ការថ្នាក់ថ្នម និងចំណង់ផ្លូវភេទដែលគេត្រូវតែគ្រប់គ្រងឲ្យជាប់ថែមទៀតផង។

ជីវិតនៅលីវ មិនចាំបាច់ត្រូវតែជាបទពិសោធន៍អាក្រក់ទាំងអស់នោះទេ។ មនុស្សនៅលី ត្រូវបានរៀបរាប់នៅក្នុងបទគម្ពីរថា ជាអំណោយយ៉ាងពិសេសសម្រាប់ក្រុមជំនុំ (គម្ពីរម៉ាថាយ ១៩:១២ និង គម្ពីរ១កូរិនថូស ៧:៧)។ នៅក្នុងមេរៀននេះ យើងនឹងស្វែងរកគុណតម្លៃដ៏វិជ្ជមានខ្លះៗ នៃជីវិតនៅលីវ និងស្វែងយល់ពីរបៀបដែលគុណតម្លៃទាំងនេះ ចូលរួមនៅក្នុងជីវិតរបៀបរស់នៅដ៏ជាទីគាប់ចិត្ត និង មានន័យសម្រាប់អ្នកនៅលីវ។យើងក៏នឹងឃើញថា អ្នកនៅលីវមិនចាំបាច់ត្រូវប្រឈមមុខជាមួយបញ្ហារបស់ពួកគេតែឯងនោះទេ។ អ្នកនៅលីវមិនត្រឹមតែទទួលបានជំនួយរបស់អ្នកដោះស្រាយបញ្ហាដ៏វិសុទ្ធ គឺព្រះយេស៊ូគ្រិស្ត តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធប៉ុណ្ណោះទេ ប៉ុន្តែក្រុមជំនុំក៏អាចជាប្រភព ជំនួយ និង កម្លាំងដ៏អស្ចារ្យមួយផងដែរ។

គម្រោងមេរៀន

ក. កំណត់និយមន័យរបស់បញ្ហា
ខ. គុណតម្លៃនៃជីវិតនៅលីវ
គ. ការសម្រេចចិត្តថារៀបការ ឬមិនរៀបការ
ឃ. ប្រឈមមុខជាមួយនឹងបញ្ហាពិសេសៗ
ង. របៀបដែលក្រុមជំនុំអាចជួយបាន

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ យើងអាចនឹង៖

១. ជ្រើសរើសបទគម្ពីរដែលអាចនឹងមានប្រយោជន៍សម្រាប់ការប្រឹក្សាយោបល់អ្នកនៅលីវដែលមានបញ្ហាពិសេសៗ។
២. ជ្រើសរើសយកការថ្លែងដែលត្រឹមត្រូវ ដែលឲ្យគុណតម្លៃទៅលើជីវិតនៅលីវ។
៣. រៀបចំបង្កើតគោលការណ៍សម្រាប់នាំផ្លូវអ្នកដែលកំពុងធ្វើការសម្រេចចិត្តថាគួររៀបការឬអត់។
៤. អនុវត្តតាមការណែនាំដែលនឹងជួយដោះស្រាយបញ្ហារបស់អ្នកនៅលីវ។
៥. ស្គាល់ពីគោលការណ៍ដ៏ពិតដែលក្រុមជំនុំគួរតែធ្វើតាមដើម្បីជួយសមាជិករបស់ខ្លួនដែលនៅលីវ។

សកម្មភាពក្នុងការសិក្សា

១. សិក្សាទៅតាមដំណើរការវិវត្តនៃមេរៀន ដូចដែលអ្នកធ្លាប់បានធ្វើ។
២. មើលនិយមន័យនៃពាក្យសំខាន់ណាដែលអ្នកមិនដឹង។
៣. ធ្វើការប្រឡងផ្ទាល់ខ្លួន និង ផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក។
៤. បន្ទាប់ពីបានធ្វើការប្រឡងផ្ទាល់ខ្លួនរួចហើយ ចូរអំពាវនាវមេរៀនទី ៤-ទី៦ (ជំពូកទីពីរ)។ បន្ទាប់មកចូរធ្វើការប្រឡងតាមជំពូកទីពីរ។

ពាក្យសំខាន់

លះបង់ចោល	បន្ទោកបន្ទាប(ថយចុះ)	ការច្រានចោល
នៅលីវ	ញាតិសាច់ឆ្ងាយ	ជ្រមុជ
ជម្រើសតែមួយគត់	គ្មានស្មារតី	

ក. កំណត់និយមន័យរបស់បញ្ហា

វត្ថុបំណងទី១. *ជ្រើសរើសបទគម្ពីរដែលអាចនឹងមានប្រយោជន៍សម្រាប់ការប្រឹក្សាយោបល់អ្នកនៅលើរដែលមានបញ្ហាពិសេសៗ។*

អ្នកនៅលីវត្រូវបានសង្គមឲ្យនិយមន័យថាជាអ្នកដែលមិនទាន់រៀបការ។ អ្នកទាំងនោះត្រូវបានបែងចែកជាបីប្រភេទ៖

១. មនុស្សដែលមិនធ្លាប់រៀបការ
២. មនុស្សដែលលែងលះគ្នា
៣. មនុស្សមេម៉ាយ និង ពោះម៉ាយ

មនុស្សដែលមិនធ្លាប់រៀបការ

នៅប្រទេសជាច្រើននៅក្នុងពិភពលោក សាច់ញាតិតែងតែផ្តល់ជម្រក និង ការប្រាស្រ័យរាប់អានសម្រាប់មនុស្សពេញវ័យដែលមិនទាន់រៀបការនៅក្នុងគ្រួសារ ប៉ុន្តែបច្ចុប្បន្ននេះមានមនុស្សពេញវ័យជាច្រើននាក់បានចាកចេញពីគ្រួសាររបស់ពួកគេ ហើយទៅរស់នៅឯទីក្រុងដើម្បីស្វែងរកការងារ ឬដោយសារមូលហេតុផ្សេងទៀត។ ជាលើកទីមួយនៅក្នុងជីវិតរបស់ពួកគេ ពួកគេបាននៅឯកា ដាច់ឆ្ងាយពីការការពារ និង សង្គមគ្រួសាររបស់ពួកគេ។

នាងម៉ារី ជីន(Mary Jeanne) មានអាយុ ២៨ ឆ្នាំ ហើយមិនទាន់រៀបការទេ។ នាងបានចាកចេញទៅរស់នៅទីក្រុងដើម្បីស្វែងរកការងារធ្វើ និង រស់នៅតែម្នាក់ឯងនៅក្នុងបន្ទប់ដ៏តូចមួយ។ នាងធ្វើការ ជាលេខាម្នាក់ ហើយនាងរកបានក្រុមជំនុំមួយដើម្បីចូលរួមថ្វាយបង្គំ ប៉ុន្តែនាងមិនសូវជាសប្បាយចិត្តនោះទេ។ នាងនិយាយថា៖ " មិត្តភក្តិរបស់ខ្ញុំភាគច្រើនបានរៀបការអស់ហើយ ដូច្នេះហើយពួកគេមិនសូវរាប់ខ្ញុំចូលក្នុងសកម្មភាពដែលពួកគេធ្វើនោះទេ។ ខ្ញុំចំណាយពេលវេលាភាគច្រើនរបស់ខ្ញុំ នៅតែម្នាក់ឯង លើកលែងតែពេលដែលខ្ញុំធ្វើការ និង នៅក្នុងក្រុមជំនុំប៉ុណ្ណោះ។ មានពេលខ្លះខ្ញុំមានអារម្មណ៍ ឯកាខ្លាំងពេក ខ្ញុំក៏យំរហូតទល់តែគេងលក់។ គ្មាននរណាម្នាក់ពិតជាខ្វល់ខ្វាយអំពីខ្ញុំនោះទេ។ ខ្ញុំចង់ទទួលបានក្តីស្រឡាញ់ ចង់មានគ្រួសារ និង មានកូន"។

នាងស៊ូសាន មានអាយុ៣៨ឆ្នាំ ហើយមិនទាន់រៀបការទេ។ នាងនិយាយថា៖ "ខ្ញុំមិនសូវជាខ្វល់ខ្វាយ រឿងដែលខ្ញុំនៅលីវច្រើនប៉ុន្មានទេ។ ខ្ញុំរីករាយនឹងការងាររបស់ខ្ញុំ ហើយខ្ញុំបានចូលរួមក្នុងសកម្មភាពជាច្រើនរបស់ក្រុមជំនុំ។ ខ្ញុំច្រៀងនៅក្នុងក្រុមភ្លេង ខ្ញុំបង្រៀនថ្នាក់ថ្ងៃអាទិត្យ និង រីករាយនឹងធ្វើការជាមួយមនុស្ស។ ប្រាកដណាស់ ខ្ញុំក៏ចង់រៀបការ និង មានគ្រួសារដែរ។ ខ្ញុំមានឱកាសអាចរៀបការបាន ប៉ុន្តែពួកគេហាក់បីដូចជាមិនត្រូវជាមួយខ្ញុំសោះ។ ខ្ញុំបានថ្វាយអនាគតរបស់ខ្ញុំទៅកាន់ព្រះជាម្ចាស់ ហើយខ្ញុំនឹងទទួលយកផែនការរបស់ទ្រង់សម្រាប់ជីវិតរបស់ខ្ញុំ។ បញ្ហាចម្បងរបស់ខ្ញុំគឺថាមនុស្សម្នាតែងតែបង្អាប់ខ្ញុំអំពីរឿងនៅលីវ ឬប្រាប់ខ្ញុំថា ខ្ញុំគួរតែរៀបការហើយដើម្បីឲ្យមានជីវិតពេញលេញមួយ។ នៅក្នុងសង្គមរបស់យើង ពិតជាសម្ពាធជាច្រើនទៅលើការរៀបការ! វាធ្វើឲ្យខ្ញុំមានអារម្មណ៍ថា មានអ្វីម្យ៉ាងខុសជាមួយខ្ញុំ ហើយមានអារម្មណ៍ថាខ្ញុំមិនគួរសប្បាយចិត្តក្នុងនាមជាអ្នកនៅលីវនេះទេ"។

រ៉ូបឺត ជាយុវជនវ័យក្មេងម្នាក់ ដែលចង់រៀបការ ហើយគាត់មានឱកាសជាច្រើនលើកដើម្បីបង្កើតបានទំនាក់ទំនងដ៏ល្អជាមួយនារីគ្រិស្តបរិស័ទ ប៉ុន្តែរាល់លើក នៅពេលដែលទំនាក់ទំនង នោះអភិវឌ្ឍដល់ចំណុចមួយដែលត្រូវគិតពីការរៀបការច្បាស់លាស់មួយ គាត់បែរជាភ័យខ្លាច ហើយក៏ឈប់ជួបមុខនារីម្នាក់នោះទៅ។ ការបកស្រាយរបស់គាត់ គឺថា " ការរៀបអាពាហ៍ពិពាហ៍ គឺជាទំនួលខុសត្រូវដ៏ធំមួយ ហើយខ្ញុំខ្លាចថាខ្ញុំនឹងធ្វើឲ្យមានកំហុសធ្ងន់ធ្ងរមួយ ឬ ខ្ញុំអាចនឹងគ្មានសមត្ថភាពផ្គត់ផ្គង់គ្រួសាររបស់ខ្ញុំតាមដែលគួរធ្វើនោះឡើយ។ ខ្ញុំមិនប្រាកដក្នុងចិត្តថា ខ្ញុំបានត្រៀមខ្លួនដើម្បីដាក់ជីវិតទាំងស្រុងរបស់ខ្ញុំជាមួយនឹងនរណានោះទេ។

បុរសម្នាក់ទៀតដែលមានអាយុ ៤០ឆ្នាំ គាត់ជ្រើសរើសមិនរៀបការ ព្រោះគាត់ត្រូវមើលថែរក្សាម្តាយដែលមានវ័យចំណាស់ ដែលមានសុខភាពទ្រុឌទ្រោមអស់ជាច្រើនឆ្នាំ។ ទោះបីជាគាត់ចង់រៀបការយ៉ាងណាក៏ដោយ គាត់មានអារម្មណ៍ថាគាត់មិនគួរដាក់បន្ទុកនៃការចំណាយថ្លៃថែទាំ និង ថ្លៃថ្នាំទៅលើប្រពន្ធរបស់គាត់ ដែលគាត់គិតថាវាគឺជាទំនួលខុសត្រូវរបស់គាត់តែម្នាក់ឯងនោះឡើយ។

ឧទាហរណ៍ទាំងបួនខាងលើនេះបង្ហាញពីបញ្ហាពិសេសៗ ដូចជា ការមើលឃើញថាខ្លួនឯងអន់ ការមានអារម្មណ៍ថាត្រូវបានគេព្រងើយកន្តើយ សម្ពាធមកពីការរៀបការ ភាពភ័យខ្លាចនឹងទំនួលខុសត្រូវ ចង់មានគ្រួសារ មិនសូវចាប់អារម្មណ៍ពីការរៀបផែនការសម្រាប់អនាគត និង ចង់ឲ្យគេត្រូវការខ្លួន ទាំងនេះត្រូវបានឆ្លងកាត់ដោយមនុស្សជាច្រើនដែលមិនទាន់រៀបការ។ ចំណែកឯ នារីៗដែលនៅលីវវិញ តែងតែមានអារម្មណ៍ថា មនុស្សម្នាកេងប្រវ័ញ្ចលើពួកគេ ដោយសារតែពួកគេគ្មានប្តីនៅជួយការពារពួកគេបាន។

លំហាត់អនុវត្តន៍

---

១ តើឥរិយាបថណាមួយនៅខាងក្រោមនេះ ដែលមើលទៅហាក់ដូចជាស្រដៀងគ្នាសម្រាប់មនុស្សដែលនៅក្នុងឧទាហរណ៍ទាំងបួនខាងលើនេះ។

ក) ភាពភ័យខ្លាច

ខ) ភាពមិនប្រាកដប្រជា

គ) ភាពសប្បាយរីករាយ

ឃ) អស់សង្ឃឹម

មនុស្សដែលលែងលះគ្នា

យើងបានពិភាក្សាអំពីការលែងលះគ្នា យ៉ាងលំអិតនៅក្នុងមេរៀនទី៥។ នៅក្នុងមេរៀននេះ យើងនឹងបញ្ចាក់បន្ថែមពីបញ្ហាដែលមនុស្សនៅលីវដោយសារការលែងលះគ្នា ត្រូវប្រឈមមុខ។

នាងម៉ាហ្គារែត ត្រូវបានប្តីរបស់នាងលែងលះ ដែលមកដល់ពេលនេះប្តីរបស់នាងបានរៀបការម្តងទៀតរួចហើយ។ នេះគឺជារឿងរបស់នាង៖ "ខ្ញុំធ្លាប់ស្រឡាញ់ប្តីរបស់ខ្ញុំខ្លាំងណាស់ ប៉ុន្តែបន្ទាប់ពីខ្ញុំក្លាយជាគ្រិស្តបរិស័ទ គាត់ចង់ចំណាយពេលកាន់តែច្រើននៅក្រៅផ្ទះ ។ គាត់ចង់ធ្វើរឿងដែលខ្ញុំមានអារម្មណ៍ថាគ្រិស្តបរិស័ទមិនគួរធ្វើ។ ទោះបីជា ខ្ញុំព្យាយាមរក្សាចំណងអាពាហ៍ពិពាហ៍របស់យើងឲ្យមានភាពសប្បាយរីករាយយ៉ាងណា គាត់នៅតែបានសម្រេចិត្តលែងលះខ្ញុំ។ ខ្ញុំមានអារម្មណ៍ក្រៀមក្រំ និង មានអារម្មណ៍ថាមានកំហុស ដែលអាពាហ៍ពិពាហ៍របស់យើងត្រូវបានបែកបាក់យ៉ាងដូចនេះ ហើយខ្ញុំមានអារម្មណ៍ថាត្រូវបានច្រានចេញដោយមនុស្សដែលខ្ញុំទុកចិត្តបំផុត។ ឥឡូវនេះខ្ញុំត្រូវធ្វើការដើម្បីផ្គត់ផ្គង់កូនៗទាំងពីររបស់ខ្ញុំ ហើយខ្ញុំមានអារម្មណ៍ថាមនុស្សគេរិះគន់ខ្ញុំខ្លាំងណាស់ ដោយសារតែខ្ញុំបានលែងលះគ្នា។ ខ្ញុំខ្មាសបងប្អូននៅក្នុងក្រុមជំនុំខ្លាំងណាស់។ តើខ្ញុំធ្វើយ៉ាងណាទើបអាច ឲ្យមានគ្រួសារដ៏រីករាយមួយសម្រាប់កូនៗរបស់ខ្ញុំបាន បើខ្ញុំនៅតែម្នាក់ឯងយ៉ាងដូច្នេះ?"

មនុស្សដែលលែងលះគ្នា អាចមានអារម្មណ៍ថា ត្រូវបានគេធ្វើព្រងើយកន្តើយ ឬ មានអារម្មណ៍ថាត្រូវបានគេមើលងាយយ៉ាងខ្លាំង។ ពួកគេក៏អាចទទួលអារម្មណ៍ទុក្ខសោក អស់សង្ឃឹម ឬ ការផ្លាស់ប្តូររបៀបនៃការរស់នៅភ្លាមៗ ឬ មានទំនួលខុសត្រូវក្នុងការចិញ្ចឹមកូនតែម្នាក់ឯង។ មនុស្សដែលបានលែងលះគ្នា ក៏អាចត្រូវប្រឈមមុខជាមួយនឹងបញ្ហា កំហឹង ភាពល្វីងជូរចត់ ការថ្នាំងថ្នាក់ចិត្ត និង សោកសៅចំពោះការបាត់បង់មួយ។

មនុស្សមេម៉ាយ និង ពោះម៉ាយ

មិត្តរបស់ខ្ញុំម្នាក់ ក្លាយជាមនុស្សមេម៉ាយក្រោយពីដែលប្តីរបស់នាងបានធ្លាក់ខ្លួនឈឺអស់រយៈយ៉ាងយូរ។ នាងបានមើលថែគាត់ជាប់ជានិច្ច នៅក្នុងអំឡុងពេលមួយខែចុងក្រោយនៃជំងឺរបស់គាត់។ នាងនិយាយថា ៖" ជីវិតរបស់ខ្ញុំគឺឥតមានន័យទេ។ ខ្ញុំគ្មានអ្វីដែលមានតម្លៃសម្រាប់ធ្វើ និង គ្មានអ្វីដើម្បីឲ្យរស់ទៀតទេ។ ប្តីរបស់ខ្ញុំគឺជាជីវិតរបស់ខ្ញុំទាំងមូល។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំបានបាត់បង់អត្តសញ្ញាណរបស់ខ្ញុំហើយ។ នៅក្នុងគំនិតរបស់ខ្ញុំមានពេញដោយការចងចាំអំពីជំងឺដ៏ឈឺចុកចាប់របស់ប្តីខ្ញុំ។ កូនៗរបស់ខ្ញុំបានរៀបការអស់ និង មិនរស់នៅក្បែរខ្ញុំទៀតទេ។ គ្មាននរណាម្នាក់ត្រូវការខ្ញុំទៀតឡើយ។

មានបុរសពោះម៉ាយម្នាក់បានប្រាប់ខ្ញុំថា៖ "បញ្ហារបស់ខ្ញុំគឺភាពឯកានៅក្នុងអារម្មណ៍របស់ខ្ញុំ នៅពេលខ្ញុំទៅដល់ផ្ទះដែលទទេ។ ខ្ញុំបានស្រកទម្ងន់ ដោយសារតែខ្ញុំមិនចង់រៀបចំអារម្មណ៍ហើយញុំាតែម្នាក់ឯងនោះទេ។"

ទាំងនេះជាឧទាហរណ៍ខ្លះៗអំពីបញ្ហាដែលមនុស្សមេម៉ាយ ឬពោះម៉ាយត្រូវប្រឈមមុខ៖ ភាពសោក សៅ ភាពឯកា ការផ្លាស់ប្តូររបៀបរស់នៅយ៉ាងខ្លាំង វិបត្តិហិរញ្ញវត្ថុ ឬ ការមើលងាយ (ជាពិសេសសម្រាប់មនុស្សស្រី) គ្មានអ្វីដើម្បីជំរុញឲ្យរស់ ការមានអារម្មណ៍ថាត្រូវបានគេបោះបង់ចោល។ តម្រូវការក្តីស្រឡាញ់ និង ការថ្នាក់ថ្នម គឺជារឿងទូទៅ។ មនុស្សគ្រប់គ្នាចង់ឲ្យមនុស្សត្រូវការខ្លួន។

លំហាត់អនុវត្តន៍

---

២ ចូរអានបណ្តុំខគម្ពីរដែលបានផ្តល់ជូននៅខាងក្រោមនេះ បន្ទាប់មកចូរជ្រើសរើសខគម្ពីរណាខ្លះដែលអ្នកគិតថាជាជំនួយដ៏ល្អបំផុតសម្រាប់មនុស្សដែលមានបញ្ហាដូចតទៅនេះ៖

ក) រងទុក្ខដោយសារតែសកម្មភាពគ្មានធម៌មេត្តារបស់នរណាម្នាក់៖ គម្ពីរទំនុកតម្កើង ៩១:៤; គម្ពីរ១ពេត្រុស ៤:១២-១៩; គម្ពីរហេប្រឺ ២:១៨

.....

ខ) ភាពព្រងើយកន្តើយ៖ គម្ពីរ២កូរិនថូស ១២:៩; គម្ពីរអេសាយ ៥៣:៣; គម្ពីរយ៉ូហាន១:១១; គម្ពីរទំនុកតម្កើង ១៣០:៤-៥។

.....

គ) ភាពភ័យខ្លាច ៖ ទុតិយកថា ៣៣; គម្ពីរ១យ៉ូហាន ១:៩; គម្ពីរយ៉ូស្វេ ១:៩; គម្ពីរ២កូរិនថូស ១២:១០

ឃ) ទុក្ខសោក៖ គម្ពីរទំនុកតម្កើង ១៨:២៩; គម្ពីរទំនុកតម្កើង ៦៦:១០-១២; គម្ពីរ២កូរិនថូស ១:៣-៤,៦

៣ ចូរអានគម្ពីរទំនុកតម្កើង ៦៦:១០-១២

ក) តើនៅពេលណាដែលយើងអាចយកខគម្ពីរនេះទៅប្រើដើម្បីជួយនរណាម្នាក់បានសមរម្យបំផុត?

.....

.....

ខ) តើខគម្ពីរនេះបានប្រយោជន៍យ៉ាងដូចម្តេច?

.....

.....

៤ ចូរអានគម្ពីរអេសាយ ៥៤:៤-១០។

ក) តើនៅពេលណាដែលយើងអាចយកខគម្ពីរនេះទៅប្រើដើម្បីជួយនរណាម្នាក់បានសមរម្យបំផុត?

.....

ខ) តើខគម្ពីរនេះបានប្រយោជន៍យ៉ាងដូចម្តេច?

.....

.....

៥ នៅក្នុងសៀវភៅកត់ត្រាមួយដោយឡែក ចូរសរសេរឈ្មោះមនុស្សនៅលើវបីនាក់ដែលអ្នកធ្លាប់បានស្គាល់ ហើយរៀបរាប់ពីបញ្ហាដែលអ្នកគិតថាពួកគេអាចនឹងប្រឈមមុខ។ (ប្រសិនបើអ្នកនៅលីវ ចូររៀបរាប់ពីបញ្ហាដែលមកពីការនៅលីវរបស់អ្នក)។ ចូរព្យាយាមរកខគម្ពីរដែលអាចជួយនៅក្នុងស្ថានភាពនីមួយៗ ហើយសរសេរវានៅក្បែរតារាងបញ្ហាដែលអ្នកបានរៀបរាប់នោះ។

ខ. គុណតម្លៃនៃជីវិតនៅលីវ

វគ្គបំណែងទី២. *ជ្រើសរើសយកការថ្លែងដែលត្រឹមត្រូវ ដែលឲ្យគុណតម្លៃទៅជីវិតនៅលីវ។*

មុនពេលដែលយើងស្វែងរកដំណោះស្រាយនៃបញ្ហាដែលអ្នកនៅលីវមាន សូមក្រឡេកមើលបន្តិចអំពីគុណតម្លៃនៃជីវិតនៅលីវ ដែលបានបង្ហាញតាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់។ គុណតម្លៃទាំងនេះអាចផ្តល់ឲ្យយើងនូវការយល់ដឹងជ្រៅជ្រះអំពីដំណោះស្រាយដែលអាចកើតមាន។

ជីវិតនៅលីវគឺជាជម្រើសដ៏ប្រសើរមួយដូចការរៀបអាពាហ៍ពិពាហ៍

បើនិយាយអំពីជីវិតនៅលីវ យើងនិយាយអំពីមនុស្សនៅលីវដែលមិនមានទំនាក់ទំនងផ្លូវភេទ ឬ អ្នកដែលនៅមាន*ភាពបរិសុទ្ធ (ព្រហ្មចារី)* ។ យើងនឹងពិភាក្សាអំពីភាពនៅមានភាពបរិសុទ្ធ ឲ្យលំអិតបន្ថែមទៀតនៅក្នុងចំណុចផ្លូវភេទរបស់មនុស្ស នៅក្នុងមេរៀនទី៧។

ដោយសារតែអាចមាន ទុក្ខព្រួយនៅក្នុងពិភពលោកនេះ និង មានបញ្ហារៀងរាល់ថ្ងៃដែលអ្នកមានប្តីប្រពន្ធអាចនឹងប្រឈមមុខ លោកសាវ័កប៉ូលបានណែនាំឲ្យអ្នកនៅលីវគួរតែបន្តនៅលីវទៀត។ អ្នកដែលមិនទាន់រៀបការ មានសេរីភាពផុតពីការព្រួយបារម្ភ និង បញ្ហាដែលអ្នកមានគ្រួសារត្រូវទទួលខុសត្រូវ (គម្ពីរ១កូរិនថូស ៧:២៦-៣២)។ លោកប៉ូលមិនបាននិយាយបែបនេះ ដោយសារតែចង់ដាក់កំហិតឲ្យនរណានៅរស់ក្រោមចំណងនៃភាពនៅលីវនោះទេ ប៉ុន្តែដើម្បីណែនាំថា វាគឺជាការល្អ សម្រាប់អ្នកដែលប្រាថ្នាចង់បន្តភាពនៅលីវរបស់ខ្លួន (គម្ពីរ១កូរិនថូស ៧:៣៥) ។

ជីវិតនៅលើវគឺជាអំណោយពិសេស

ភាពនៅលើវ ឬ នៅភាពបរិសុទ្ធ គឺត្រូវបានរក្សាដោយអ្នកដែលមាន*អំណោយទាន* ជាមួយវា។ខ្ញុំជឿថានេះគឺជាអំណោយដែលព្រះជាម្ចាស់នឹងប្រទានដោយឥតគិតថ្លៃទៅដល់អ្នកនៅលើវទាំងឡាយណាដែលត្រូវការវា មិនថាគាត់ត្រូវការវានៅពេលណា ឬ យូរប៉ុនណានោះឡើយ។ ព្រះយេស៊ូ ព្រមទាំង លោកប៉ូលផង បានថ្លែងពីផ្នែកដែលជា*អំណោយទាន*នៃភាពនៅលើវ និង ជីវិតអាពាហ៍ពិពាហ៍ផងដែរ។ ព្រះជាម្ចាស់ស្រឡាញ់អ្នក និង ខ្ញុំ។ ទ្រង់បានផ្គត់ផ្គង់គ្រប់តម្រូវការរបស់យើង មិនថាជាអ្វី ហើយមិនថាពេលណាក៏ដោយនៅក្នុងជីវិតអ្នក ឲ្យតែអ្នកត្រូវការការផ្គត់ផ្គង់របស់ទ្រង់។ ខាងក្រោមនេះគឺជាព្រះបន្ទូលរបស់ព្រះយេស៊ូតបទៅកាន់សាវ័ករបស់ទ្រង់ នៅពេលដែលពួកគេគិតថាវាជាការល្អជាងដែលមិនរៀបការ៖

> "មនុស្សគ្រប់រូបពុំអាចយល់សេចក្តីនេះបានឡើយ គឺមាន តែអ្នកដែលព្រះជាម្ចាស់ប្រោស ប្រទានអោយយល់ប៉ុណ្ណោះ ទើបអាចយល់បាន។ អ្នកខ្លះ មិនអាចរៀបការបានតាំងពី កំណើតមក។ អ្នកខ្លះទៀតមិនអាចរៀបការបានមកពីត្រូវគេក្រៀវ។ រីឯ*អ្នកខ្លះទៀតមិនរៀបការមកពីយល់ដល់ព្រះរាជ្យនៃស្ថានបរមសុខ។* អ្នកណាមានប្រាជ្ញា ចូរយកពាក្យនេះទៅរិះគិតអោយយល់ចុះ!"
> (គម្ពីរម៉ាថាយ ១៩:១១-១២ ចូរមើលអក្សរទ្រេត)

មនុស្សនៅលើវដែលលះបង់ការរៀបការ ក្នុងការចំណាយពេលវេលារបស់គាត់ដើម្បីកសាងព្រះរាជ្យនៃស្ថានបរមសុខគឺជាអំណោយទានយ៉ាងពិសេសសម្រាប់ក្រុមជំនុំ។ ខ្ញុំបានស្គាល់បុរសនារីដែលមានការលះបង់ខ្ពស់ខ្លះៗដែលពួកគាត់មានឱកាសរៀបការ ប៉ុន្តែបានជ្រើសរើសចំណាយពេលវេលារបស់ពួកគាត់នៅក្នុងព័ន្ធកិច្ចដំណឹងល្អវិញ ដែលមានអ្នកខ្លះបានចុះទៅធ្វើបេសកម្មនៅទីឆ្ងាយពីស្រុកកំណើតរបស់ខ្លួន។ ពួកគេបានធ្វើការជ្រើសរើសបែបនេះ ព្រោះតែពួកគេបានដឹងថា បើមិនធ្វើដូច្នេះទេ ពួកគេមុខជាមិនអាចធ្វើកិច្ចការដែលព្រះជាម្ចាស់បានត្រាស់ហៅឲ្យពួកគេធ្វើនោះបានឡើយ។ លោកសាវ័កប៉ូល គឺជាគំរូយ៉ាងច្បាស់អំពីមនុស្សប្រភេទនេះ។ លោកបានមានប្រសាសន៍ថា៖ "ខ្ញុំចង់អោយមនុស្សទាំងអស់បានដូចខ្ញុំដែរ ក៏ប៉ុន្តែ ម្នាក់ៗបានទទួលព្រះអំណោយទានមួយរៀងៗខ្លួន ពីព្រះជាម្ចាស់ ម្នាក់ទទួលយ៉ាងនេះ ម្នាក់ទៀតទទួលយ៉ាងនោះ។" (គម្ពីរ១កូរិនថូស ៧:៧)

ជីវិតនៅលើវគឺជាឱកាសមួយ

យើងចាំថា នៅក្នុងចំណុចកន្លងទៅនេះ ព្រះយេស៊ូបានថ្លែងទាក់ទងនឹងអ្នកខ្លះដែលមិនរៀបការ "មកពីយល់ដល់ព្រះរាជ្យនៃស្ថានបរមសុខ"។ លោកប៉ូលក៏បានបញ្ជាក់ពីមូលហេតុនៃការជ្រើសរើសជីវិតនៅលើវ នៅក្នុងគម្ពីរ១កូរិនថូស ៧:៣២-៣៥។ លោកបានចង្អុលបង្ហាញថា បុរសដែលមិនទាន់រៀបការម្នាក់ គឺមានសេរីភាពក្នុងការខ្វល់ខ្វាយអំពីខ្លួនគាត់ជាមួយនឹងកិច្ចការរបស់ព្រះអម្ចាស់ ស្របពេលដែលបុរសបានរៀបការ គឺត្រូវបានទាញទៅរកទិសដៅពីរ។ នៅក្នុងរបៀបដូចគ្នានេះដែរ ស្ត្រីដែលបានរៀបការហើយ គឺរវល់ជាមួយនឹងការផ្គាប់ចិត្តប្តីរបស់នាង ចំណែកឯស្ត្រីដែលមិនទាន់រៀបការវិញ មានសេរីភាពដើម្បីថ្វាយខ្លួននាងទាំងស្រុងទៅក្នុងការបម្រើព្រះអម្ចាស់ ដោយគ្មានអ្វីរារាំងនោះទេ។

ប្រាកដណាស់ ដែលគ្រិស្តបរិស័ទទាំងអស់ ត្រូវបានត្រាស់ហៅ ឲ្យថ្វាយជីវិតរបស់គេទាំងស្រុងទៅចំពោះព្រះជាម្ចាស់។ សម្រាប់អ្នកនៅលីវវិញ នេះគឺជាឱកាសដើម្បីបង្ហាញពីការប្តេជ្ញាចិត្តមួយនេះ ដែលឱកាសនេះគ្មានឡើយសម្រាប់អ្នកដែលរៀបការមានទំនួលខុសត្រូវក្នុងការថែទាំងគ្រួសារ។

លំហាត់អនុវត្តន៍

---

៦ ចូរអានគម្ពីរម៉ាថាយ ៦:៣៣ ហើយបកស្រាយពីរបៀបដែលខគម្ពីរនេះពាក់ព័ន្ធទៅនឹងគ្រិស្តបរិស័ទនៅលីវដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍។

.....

.....

.....

៧ ចូរគូសរង្វង់នៅជុំវិញប្រយោគត្រឹមត្រូវ ដែលផ្តល់គុណតម្លៃឲ្យជីវិតនៅលីវ។

ក) មនុស្សដែលមិនទាន់រៀបការគឺមានសេរីភាពផុតពីការព្រួយបារម្ភ និង បញ្ហា។

ខ) ជីវិតនៅលីវ គឺមិនត្រឹមតែអនុញ្ញាតឲ្យមាននោះទេ ប៉ុន្តែលោកប៉ូលក៏បានជម្រុញអ្នកក្រុងកូរិនថូសដែលកំពុងប្រឈមមុខជាមួយបញ្ហានោះ ផងដែរ។

គ) អស់អ្នកដែលនៅលីវ មានលទ្ធភាពចំណាយពេលវេលាកាន់តែច្រើន ក្នុងការបម្រើជាគ្រិស្តបរិស័ទ។

ឃ) មនុស្សគ្រប់រូបសុទ្ធតែទទួលបានអំណោយទានសម្រាប់បន្តលីវនៅលីវ។

ង) បុរសដែលបានរៀបការ ត្រូវបែងចែកការយកចិត្តទុកដាក់របស់គាត់ទៅលើគ្រួសាររបស់គាត់ផង និង កិច្ចការបម្រើរបស់គាត់ចំពោះព្រះជាម្ចាស់ផង។

ច) អ្នកនៅលីវគឺជាអំណោយយ៉ាងពិសេសសម្រាប់ក្រុមជំនុំ។

អស់អ្នកដែលជ្រើសរើសមិនរៀបការដើម្បីថ្វាយជីវិតរបស់គេទាំងស្រុងទៅចំពោះកិច្ចការរបស់ព្រះជាម្ចាស់ គេនឹងបានឃើញថាទ្រង់បន្តជួយពួកគេឲ្យថ្វាយតម្រូវការទាំងអស់របស់គេទៅចំពោះទ្រង់ និងបម្រើទ្រង់ឲ្យអស់ពីចិត្ត ហើយរង្វាន់របស់ទ្រង់សម្រាប់អ្នកដែលបានធ្វើការប្តេជ្ញាចិត្តបែបនោះគឺពិតជាអស្ចារ្យណាស់៖ "អ្នក ណាលះបង់ផ្ទះសំបែង បងប្អូនប្រុសស្រី ឪពុកម្តាយ កូន ឬស្រែចំការ ព្រោះតែខ្ញុំ អ្នកនោះនឹងបានទទួលវិញមួយជាមួយរយ ព្រមទាំងមានជីវិតអស់កល្បជានិច្ច។"
(គម្ពីរម៉ាថាយ ១៩:២៩).

គ. ការសម្រេចចិត្តថារៀបការ ឬមិនរៀបការ

វត្ថុបំណងទី៣. *រៀបចំបង្កើតគោលការណ៍សម្រាប់នាំផ្លូវអ្នកដែលកំពុងធ្វើការសម្រេចចិត្តថាគួររៀបការឬអត់។*

អ្នកដែលនៅលីវខ្លះ មានអារម្មណ៍ថា ពួកគមិនបានជ្រើសរើសចង់នៅលីវនោះទេ។ អ្នកដែលលែងលះគ្នានៅក្នុងឧទាហរណ៍ដែលយើងបានផ្តល់ជូនកន្លងមក មិនបានជ្រើសរើសចង់លែងលះគ្នានោះទេ។ មនុស្សមេម៉ាយ ឬ ពោះម៉ាយ ក៏ពិតជាមិនបានជ្រើសរើសយកភាពមេម៉ាយ ឬ ពោះម៉ាយនោះដែរ។ ទាំងនេះគឺជាបញ្ហា ដែលពួកគេមិនអាចគ្រប់គ្រងបាន។ បុគ្គលដែលមិនបានរៀបការ មិនមែនដោយសារតែគាត់ចង់នៅលីវនោះទេ។

យើងបានបញ្ជាក់រួចមកហើយថា ព្រះគុណរបស់ព្រះជាម្ចាស់គឺល្មមគ្រប់គ្រាន់ណាស់សម្រាប់គ្រប់បញ្ហាដែលយើងប្រឈមមុខ។ ទ្រង់មិនឲ្យយើងទ្រាំទ្រលើសពីសមត្ថភាពដែលយើងអាចទ្រាំទ្របាននោះទេ។ គ្រប់បញ្ហាទាំងអស់ដែលយើងប្រឈមមុខគឺជាឱកាសឲ្យយើងចូលទៅកាន់តែជិតព្រះជាម្ចាស់ និងស្គាល់ពីក្តីស្រឡាញ់ និងព្រះទ័យទុកដាក់របស់ទ្រង់។ ត្រង់នេះជា ពេលវេលាដែលយើងត្រូវស្គាល់ពីបញ្ហារបស់យើង និងថ្វាយបញ្ហាទៅកាន់ព្រះជាម្ចាស់ ហើយទុកចិត្តលើកទ្រង់ថា ទ្រង់ធ្វើកិច្ចការដើម្បីឲ្យយើងបានល្អ។ ទ្រង់នឹងមិនបោះបង់យើងចោលឡើយ។

ការបង្ខំឲ្យរៀបការ មិនថាការបង្ខំខ្លួនឯង ឬ ពីអ្នកដទៃនោះទេ វាតែងតែនាំឲ្យមនុស្សប្រើប្រាស់មធ្យោបាយទុច្ចរិត ដើម្បីបានរៀបការ ឬ យកដៃគូជីវិតមួយដោយខ្លួនឯង ដែលមិនមែនជាដៃគូដែលព្រះរៀបចំ។ សូមកុំជ្រើសរើសអ្វីដែលជារបស់ទីពីរ! បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺឲ្យយើងបានគោរពកោតខ្លាចព្រះជាមុនសិន មិនមែនរៀបការមុន ហើយបានគោរពកោតខ្លាចព្រះជាក្រោយនោះទេ។

ការកំណត់ពេលវេលា គឺជាផ្នែកមួយដ៏សំខាន់នៃផែនការរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់យើង។ អាពាហ៍ពិពាហ៍ដែលរៀបចំឡើងឆាប់ពេក ឬ មុនពេលដែលអ្នកនោះត្រៀមខ្លួនហើយ វាតែងបរាជ័យដោយសារមូលហេតុនេះហើយ។ មានពេលខ្លះ គូដៃអាពាហ៍ពិពាហ៍បានធ្វើខុសចំពោះគ្នាទៅវិញទៅមក ឬ ពួកគេនៅក្មេងខ្ចីពេក សម្រាប់ការទទួលសម្គាធនៃជីវិតអាពាហ៍ពិពាហ៍នោះ។ ព្រះជាម្ចាស់ទ្រង់អាច ហើយទ្រង់នឹងបំពេញតម្រូវការសង្គមរបស់មនុស្សនៅលីវ តាមរយៈសហគមន៍គ្រិស្តបរិស័ទ។ មនុស្សនៅលីវ មិនត្រូវរងសម្គាធពីទំនាក់ទំនងដែលមិនមែនជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នោះទេ។ ពួកយើងទាំងអស់គ្នា មិនថាអ្នករៀបការហើយ ឬ នៅលីវ ត្រូវខិតខំអភិវឌ្ឍ និង រក្សា បុគ្គលិកលក្ខណៈគ្រិស្តបរិស័ទដែលរឹងមាំ និងពេញវ័យ។ យើងបាននិយាយអំពីការនេះរួចមកហើយ នៅក្នុងមេរៀនទី៤ ។ ស្តង់ដាររបស់ព្រះជាម្ចាស់គឺដូចតែគ្នា មិនថាអ្នករៀបការ ឬ នៅលីវនោះទេ។ ដូច្នេះ ប្រសិនបើព្រះជាម្ចាស់ដឹកនាំជីវិតនៅលីវ ឲ្យគេបានរៀបអាពាហ៍ពិពាហ៍ នោះគ្រឹះមូលដ្ឋានសម្រាប់ជីវិតអាពាហ៍ពិពាហ៍នោះនឹងបានស្ថាបនាឡើងយ៉ាងល្អរួចស្រេច។

ស្ត្រីគ្រិស្តបរិស័ទម្នាក់ បានបដិសេធឱកាសរៀបការពីរលើក ព្រោះនាងមិនជឿថាពួកគេគឺជាទិសដៅរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់នាងឡើយ។ ព្រះជាម្ចាស់បានត្រាស់ហៅនាងឲ្យធ្វើព័ន្ធកិច្ចដ៏ពិសេសមួយដែល ប្រហែលជាមិនអាចធ្វើទៅរួចនោះទេប្រសិនបើនាងយល់ព្រមទទួលសំណើរសុំរៀបការទាំងពីរ

នោះ។ នាងបានបម្រើព្រះជាម្ចាសដោយភាពស្មោះត្រង់អស់រយៈពេល ១០ឆ្នាំ ប៉ុន្តែនៅពេលដែលនាងឈានជិតដល់វ័យ ៤០ឆ្នាំ ដែលជាឆ្នាំនៃភាពឯកា ពេញដោយសំដីដ៏ឈឺចាប់ពីមនុស្សគ្មានប្រយោជន៍ជុំវិញខ្លួន បូករួមទាំងគំនិតដែលគិតថាខ្លួនត្រូវប្រឈមមុខការវ័យចាស់ជរាតែម្នាក់ឯង បានធ្វើឲ្យនាងព្រួយបារម្ភយ៉ាងខ្លាំង។ នាងបានជួបបុរសម្នាក់ដែលមិនមែនជាគ្រិស្តបរិស័ទ ហើយនាងបានអនុញ្ញាតឲ្យមានទំនាក់ទំនងមួយកើតមានឡើង។ មិនយូរប៉ុន្មាន នាងបានរៀបការជាមួយគាត់ ទោះបីជាគាត់បានប្រាប់យ៉ាងច្បាស់ហើយថា គាត់មិនចាប់អារម្មណ៍ក្នុងការក្លាយខ្លួនជាគ្រិស្តបរិស័ទឡើយ។ នាងលែងចូលរួមនៅក្នុងព័ន្ធកិច្ចគ្រិស្តបរិស័ទទៀតឡើយ។ នាងបានចំណាយពេលវេលារបស់នាង ដើម្បីព្យាយាមបង្កើតឲ្យមានគ្រួសារដ៏រីករាយ ដែលស្ថិតនៅក្នុងគំនិតមិនស៊ីគ្នា។

លំហាត់អនុវត្តន៍

---

៨ តើស្តង់ដាររបស់ព្រះជាម្ចាស់មួយណាដែលត្រូវបានល្មើសនៅក្នុងឧទាហរណ៍ដែលបានរៀបរាប់ខាងលើនេះ?

.....

ខ្ញុំស្គាល់ស្ត្រីបេសកជនម្នាក់ដែលបានចំណាយជីវិតជាយុវវ័យ និង វ័យកណ្តាលរបស់នាង តែម្នាក់ឯងនៅក្នុងភូមិដាច់ស្រយ៉ាលមួយនៅប្រទេសអាហ្វ្រិក។ ជាច្រើនឆ្នាំមកហើយ គ្មានបេសកជនបុរសណាម្នាក់ទៅតំបន់នោះទេ ដូច្នេះនាងទទួលបន្ទុកតែម្នាក់ឯងនៅក្នុងកិច្ចការសាលាគម្ពីរ និង ការផ្សាយដំណឹងល្អ។ នាងធ្វើការនេះ ដោយសារតែដឹងពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់នាង។ នៅក្នុងវ័យ ៦៤ឆ្នាំរបស់នាង ពេលដែលនាងនៅស្រុកកំណើតរបស់នាង កំពុងតែរៀបចំសម្រាប់ព័ន្ធកិច្ចរបស់នាងលើកចុងក្រោយនៅប្រទេសអាហ្វ្រិក នាងបានជួបនឹងបុរសពោះម៉ាយដែលជាបេសកជនចូលនិវត្តន៍ម្នាក់។ ក្តីស្រឡាញ់របស់ពួកគេចំពោះគ្នាទៅវិញទៅមកបានលូតលាស់ ហើយមិនយូរប៉ុន្មានក្រោយពេលដែលនាងត្រឡប់មកពីការធ្វើបេសកម្មវិញ គាត់បានចាប់ផ្តើមតាមនាង។ ពួកគេបានរៀបការនៅក្នុងទឹកដីមួយកន្លែងដែលបានទទួលយករបស់ផងនាង ហើយឥឡូវពួកគេបានធ្វើការរួមគ្នា ក្នុងការចែកចាយដំណឹងល្អ និង បណ្តុះបណ្តាលអ្នកធ្វើការគ្រិស្តបរិស័ទ។

នៅក្នុងពេលដែលនាងនិយាយរឿងទាំងនេះប្រាប់ខ្ញុំ នាងក៏បាននិយាយថា៖ "ខ្ញុំរំភើបណាស់ដោយសារតែអំណរមួយនេះ!" ព្រះជាម្ចាស់បានប្រទានពរសម្រាប់ការប្តេជ្ញា និង ភាពស្មោះត្រង់របស់នាងតាមរបៀបដ៏ពិសេសមួយ។ ប្រាកដណាស់ ជាច្រើនឆ្នាំដែលនាងបានប្រឈមមុខនឹងភាពឯកា ភាពបាក់ទឹកចិត្ត ភាពព្រងើយកន្តើយ តម្រូវការហិរញ្ញវត្ថុ និង អារម្មណ៍គ្មានភាពកក់ក្តៅជាច្រើន ។ ប៉ុន្តែនាងបានជ្រើសរើសយកគុណតម្លៃដ៏អស់កល្បជានិច្ច ជំនួសឲ្យគុណតម្លៃរបស់លោកីយ៍ ហើយព្រះជាម្ចាស់មិនបានភ្លេចនាងឡើយ។

លំហាត់អនុវត្តន៍

៩ រឿងនេះបានបង្ហាញប្រាប់យើងថា

ក) ព្រះជាម្ចាស់នឹងប្រទានប្តីប្រពន្ធសម្រាប់អ្នកណាដែល ដាក់ទ្រង់ជាទីមួយ។

ខ) បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺ មនុស្សគ្រប់គ្នាត្រូវរៀបការ។

គ) អស់អ្នកដែលដាក់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ជាទីមួយ អាចទុកចិត្តបានថាទ្រង់នឹង បំពេញតម្រូវការរបស់គេនៅក្នុងពេលសមរម្យមួយ មិនថាតម្រូវការនោះជាអ្វីនោះទេ។

តើអ្នកនៅលីវ ស្ត្រីមេម៉ាយបុរសពោះម៉ាយ ឬ អ្នកដែលលែងលះគ្នា គួរស្វែងរកការរៀបការម្តងទៀតដែរឬទេ? យើងបានឃើញហើយថា គ្មានសេចក្តីបង្រៀននៅក្នុងបទគម្ពីរណាមួយដែលហាមឃាត់មិនឲ្យអ្នកនៅលីវដែលមិនដែលរៀបការសោះ បានរៀបអាពាហ៍ពិពាហ៍នោះឡើយ។ លោកសាវ័កប៉ូលលើកទឹកចិត្ត មិនឲ្យស្ត្រីមេម៉ាយនិងបុរសពោះម៉ាយរៀបការម្តងទៀតនោះទេ ប៉ុន្តែបើគេទ្រាំមិនបានគេអាចរៀបការបាន (គម្ពីរ១កូរិនថូស ៧:៨-៩)។

នៅក្នុងមេរៀនទី៥ យើងបានពិភាក្សាអំពីសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរដែលទាក់ទងនឹងការលែងលះគ្នា។ ដូចដែលយើងបានបង្ហាញថា ទោះបីជាសេចក្តីបង្រៀននៅក្នុងគម្ពីរមិនបានបញ្ជាក់ច្បាស់ៗ ចំពោះរឿងនេះក៏ដោយ យើងនៅតែឃើញថា ជាទូទៅការរៀបការម្តងទៀតនៅតែហាមប្រាមសម្រាប់គ្រិស្តបរិស័ទដែលបានលែងលះគ្នា។ ករណីលើកលែងមួយ គឺនៅក្នុងករណីមានភាគីម្ខាង បានបំផ្លាញការរួបរួមនៃចំណងអាពាហ៍ពិពាហ៍ដោយអំពើសហាយស្មន់។ តាមរយៈការនេះ យើងប្រាកដថា៖ ប្រសិនបើអ្នកស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ និង ភាពសុចរិតរបស់ទ្រង់ជាមុន នោះទ្រង់នឹងដឹកនាំអ្នកក្នុងការធ្វើការសម្រេចចិត្ត ព្រមទាំងប្រទានឲ្យអ្នកនូវជីវិតដែលបរិបូរណ៌ និង ពេញលេញ និង គាប់នឹងព្រះហឫទ័យរបស់ទ្រង់ផង។

លំហាត់អនុវត្តន៍

១០ ចូរសរសេរគោលការណ៍មួយ ដើម្បីជួយដឹកនាំអ្នកដែលកំពុងធ្វើការសម្រេចចិត្តថារៀបការ ឬមិនរៀបការ។

.....

.....

.....

ឃ. ប្រឈមមុខជាមួយនឹងបញ្ហាពិសេសៗ

វគ្គបំណែងទី៤. *អនុវត្តតាមការណែនាំដែលនឹងជួយដោះស្រាយបញ្ហារបស់អ្នកនៅលើវ៉ែ។*

តើអ្នកនៅចាំ ឧទាហរណ៍អំពីស្ត្រីនៅលើវ៉ែពីរនាក់ បង្ហាញនៅខាងដើមមេរៀននេះ ដែលមានម្នាក់រីករាយ ហើយម្នាក់ទៀតមិនរីករាយ ទោះបីជារឿងរ៉ាវដែលពួកគេឆ្លងកាត់គឺស្រដៀងគ្នាយ៉ាងណាក្តីនោះទេ? ឧទាហរណ៍ទាំងពីរនេះ អាចបង្ហាញថា បញ្ហារបស់ពួកគេគឺមិនមែនមកពីខាងក្រៅនោះទេ ប៉ុន្តែគឺនៅក្នុងខ្លួនគេឯណោះវិញ។ ខាងក្រោមនេះ ជាការណែនាំខ្លះៗដែលនឹងជួយអ្នកឲ្យរកឃើញដំណោះស្រាយសម្រាប់បញ្ហាដែលអ្នកប្រឈមមុខ ក្នុងនាមជាអ្នកនៅលើវ៉ែម្នាក់។

១. *មើលមកខ្លួនអ្នក*

អ្នកប្រហែលមិនអាចផ្លាស់ប្តូរកាល:ទេស:របស់អ្នកបានឡើយ ប៉ុន្តែអ្នកអាចផ្លាស់ប្តូររបៀបដែលអ្នកយើញទៅកាន់វាវិញ! ចូរចងចាំថា អំណាររបស់ព្រះអម្ចាស់ជាកម្លាំងរបស់អ្នក! "ខ្ញុំអាចទ្រាំបានទាំងអស់ដោយរួមជាមួយព្រះអង្គដែលប្រទានកម្លាំងអោយខ្ញុំ។" (គម្ពីរភីលីព ៤:១៣)។

២. *ស្គាល់ពីតំណែងរបស់អ្នកនៅក្នុងព្រះគ្រិស្ត*

ទ្រង់បានលះព្រះជន្មរបស់ទ្រង់សម្រាប់អ្នក! ទ្រង់ស្រឡាញ់អ្នក ហើយអ្នកបានពោរពេញនៅក្នុងអង្គព្រះគ្រិស្ត (គម្ពីរកូឡូស ២:១០) ។ អ្នកគឺជាអំណោយទានពិសេសរបស់ទ្រង់សម្រាប់ក្រុមជំនុំ។ ចូរចាប់យកឱកាស នៃសេរីភាពពិសេសដែលអ្នកមាន ដើម្បីថ្វាយខ្លួនរបស់អ្នកនៅក្នុងការបម្រើទ្រង់។ ចូរអរព្រះគុណទ្រង់សម្រាប់ការប្រទានឲ្យអ្នកមានឱកាស ដើម្បីបម្រើទ្រង់ ហើយធ្វើឲ្យអស់ពីសមត្ថភាពសម្រាប់ទ្រង់។

៣. *ចូលរួមនៅក្នុងការជួយអ្នកដទៃ*

មានមនុស្សជាច្រើនដែលឯកា និង បាក់ទឹកចិត្តជាងអ្នក និងរងទុក្ខច្រើនជាងអ្នកទៅទៀត។ ចូរស្វែងរកមធ្យោបាយសម្រាលបន្ទុករបស់ពួកគេ។ ធ្វើខ្លួនឲ្យរួសរាយ។ ធ្វើខ្លួនឲ្យវល់ ហើយតែងតែសម្លឹងឆ្ពោះទៅរក*អ៊ីម៉ាជ* ។

មិត្តភក្តិរបស់ខ្ញុំម្នាក់គឺជាស្ត្រីមេម៉ាយ។ អស់រយៈពេលជាច្រើនខែ បន្ទាប់ពីប្តីរបស់នាងបានលាចាកលោកនេះទៅ នាងបានត្រឹមតែរស់នៅតាមការរសាត់អណ្តែតនៃការរស់នៅដដែលៗប៉ុណ្ណោះ។ នាងបានបង្ខំខ្លួនឲ្យក្រោកឡើងនៅពេលព្រឹក ហើយបង្ខំខ្លួនឯងឲ្យធ្វើតាមទម្លាប់ប្រចាំថ្ងៃ។ នាងគ្រាន់តែចង់ឆ្លងឲ្យផុតមួយថ្ងៃ ដើម្បីឲ្យនាងអស់កម្លាំងហើយអាចគេងលក់នៅពេលយប់ប៉ុណ្ណោះ។ យូរៗទៅ នាងចាប់ផ្តើមដឹងខ្លួនថា នេះមិនមែនជាជីវិតដែលគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់នោះទេ។ នាងបានថ្វាយតរិយាបថអាណិតខ្លួនឯងរបស់នាង ហើយទូលសូមឲ្យព្រះជាម្ចាស់ជួយនាងបំពេញជីវិតរបស់នាងជាមួយនឹងសកម្មភាពណាដែលមានប្រយោជន៍វិញ។ ឥឡូវនេះ រៀងរាល់យប់មុនពេលចូលគេង នាងបានសរសេរអ្វីដែលនាងនឹងត្រូវធ្វើនៅថ្ងៃបន្ទាប់។ កិច្ចការដំបូងដែលនាងត្រូវធ្វើ គឺចំណាយពេលតែម្នាក់ឯងជាមួយព្រះជាម្ចាស់ តាមរយៈការអានព្រះគម្ពីរ ការសញ្ជឹងគិត និង អធិស្ឋាន។ នាងញែកពេលខ្លះដែរ សម្រាប់ការងារផ្ទះប្រចាំថ្ងៃរបស់នាង បន្ទាប់មកនាងបានរៀបចំពេលវេលាសម្រាប់សកម្មភាពខ្លះៗដែលនឹងជួយដល់នរណាម្នាក់ ដូចជាការទៅសួរសុខទុក្ខអ្នកជំងឺនៅមន្ទីរពេទ្យ ទៅសួរសុខទុក្ខជំនួសគ្រូគង្វាល ធ្វើម្ហូបមួយ

ចានសម្រាប់អ្នកដែលកំពុងមានជំងឺ និង អ្នកក្រីក្រ ឬជួយការងារអ្នកម្តាយដែលវល់ខ្លាំង។ ឥឡូវនេះ នាងមានអ្វីម្យ៉ាងដើម្បីឲ្យនាងអាចសម្លឹងឆ្ពោះទៅរកវាជារៀងរាល់ថ្ងៃ។ ជីវិតរបស់នាងគឺពេញលេញ និង រីករាយ។ នាងបង្កើតបានមិត្តភក្តិថ្មីរាល់ថ្ងៃ។ នាងបានប្រែស្ថានភាពដែលពេញដោយទុក្ខសោករបស់នាង ឲ្យទៅជាឱកាសដើម្បីបង្កើតបានអ្វីដែលមានគុណតម្លៃអស់កល្បជានិច្ចវិញ។ នាងមិនត្រូវការទេពកោសល្យពិសេសដើម្បីធ្វើការនេះទេ នាងគ្រាន់តែប្រើប្រាស់អំណាយទានដែលព្រះជាម្ចាស់បានប្រទានឲ្យនាងតែប៉ុណ្ណោះ។

អ្នកប្រហែលជាកំពុងតែធ្វើការងារដែលអ្នកមិនពេញចិត្ត ឬ ចំណាយពេលច្រើន ដើម្បីគ្រាន់តែផ្គត់ផ្គង់ជីវិតរបស់អ្នក ហើយមិនមានពេលទំនេរច្រើនដូចស្ត្រីមេម៉ាយនេះផង។ ចូរប្រើការងារដែលអ្នកមានជាឱកាសដើម្បីបង្ហាញពីក្តីស្រឡាញ់របស់ព្រះគ្រិស្ត។ សូមគិតពីរបៀបដែលអ្នកអាចផ្គាប់ព្រះហឫទ័យទ្រង់នៅក្នុងការងាររបស់អ្នក។ នៅពេលដែលអ្នកផ្តោតគំនិតរបស់អ្នកទៅលើទ្រង់ នោះទ្រង់នឹងបំពេញជីវិតរបស់អ្នកជាមួយនឹងអំណរ និង ក្តីសុខសាន្ត។

៤. *ចំណាយពេលរបស់អ្នកឲ្យកាន់តែច្រើន ទៅលើការអានព្រះគម្ពីរ ការសញ្ជឹងគិត និង ការអធិស្ឋាន។*

ខ្ញុំស្គាល់ស្ត្រីមេម៉ាយម្នាក់ ដែលមានពេលខ្លះនាងមកពីធ្វើការវិញទាំងហត់នឿយ ឯកា និង បាក់ទឹកចិត្ត ដោយសារតែមានសម្ពាធមកពីថ្ងៃ ហើយនាងមានអារម្មណ៍ក្រៀមក្រំ និង ឯកាយ៉ាងខ្លាំងដោយសារនឹកប្តីរបស់នាង។ នាងបានរៀនយកឈ្នះលើគ្រាលំបាកទាំងនេះ។ តើអ្វីទៅជា ការព្យាបាលនោះសម្រាប់ការនេះ? គឺការអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ! អានឲ្យឮៗ អានគ្រប់ពេលដែលអ្នកមានឱកាសអាន។ ស្តាប់ព្រះបន្ទូលដែលបានអាននោះនៅក្នុងខ្សែអាត់សម្លេង ឬ នៅក្នុងម៉ាស៊ីនថតសម្លេងទៀត។ ធ្វើយ៉ាងណា ឲ្យព្រះបន្ទូលនោះចូលទៅក្នុងគំនិតរបស់អ្នក ហើយ
កាលៈទេសៈ នឹងត្រូវបានផ្លាស់ប្តូរដោយឫទ្ធានុភាពរបស់ព្រះគ្រិស្តដ៏មានព្រះជន្មរស់! ព្រះបន្ទូលរបស់ទ្រង់នាំឲ្យមានភាពស្ងប់ចិត្តសម្រាប់អ្នកដែលខូចចិត្ត។ ព្រះបន្ទូលនាំឲ្យអ្នកដែលនឿយហត់បានសម្រាក។ ព្រះបន្ទូលផ្តល់ក្តីសង្ឃឹមឲ្យអ្នកអស់សង្ឃឹម។ ព្រះបន្ទូលនឹងលើកអ្នកឲ្យផុតពីបន្ទុករបស់អ្នក និង ផ្តល់ឲ្យអ្នកនូវកម្លាំងសម្រាប់ថ្ងៃស្អែក។សូមឲ្យព្រះជាម្ចាស់មានព្រះបន្ទូលដោយព្រះបន្ទូលរបស់ទ្រង់ និងនៅពេលដែលអ្នកអធិស្ឋាន និង រង់ចាំទ្រង់។ នៅពេលដែលក្តីស្រឡាញ់របស់ទ្រង់ហូរនៅក្នុងអ្នក ទ្រង់នឹងបំពេញដួងចិត្តរបស់អ្នកឲ្យបានហូរហៀរ។

៥. *ចុងក្រោយ យកគោលការណ៍គ្រិស្តបរិស័ទដែលយើងបានផ្តល់ជូននៅជំពូកទីមួយនៃសៀវភៅនេះមកប្រើប្រាស់នៅក្នុងការដោះស្រាយបញ្ហារបស់អ្នក។*

ប្រសិនបើមានដំណោះស្រាយជាក់លាក់ នោះព្រះជាម្ចាស់នឹងឆ្លើយតបជាមួយអ្នក នៅពេលដែលអ្នកប្រឈមមុខជាមួយបញ្ហានោះ។ ប្រសិនបើអ្នករកមិន ឃើញពីដំណោះស្រាយក្នុងពេលនោះទេ ចូរថ្វាយបញ្ហានោះទៅព្រះជាម្ចាស់ ហើយទុកចិត្តថាទ្រង់នឹងធ្វើការសម្រាប់ប្រយោជន៍របស់អ្នក។ អ្នកអាចរស់ក្នុងជីវិតគ្រិស្តបរិស័ទដែល មានជ័យជំនះ និង មានអំណរ មិនថាកាលៈទេសៈដែលអ្នកឆ្លងកាត់នោះជាអ្វីនោះទេ ហើយបើបញ្ហារបស់អ្នកកាន់តែធំ អ្នកនឹងមានទីបន្ទាល់ដ៏កាន់តែអស្ចារ្យសម្រាប់អ្នកដទៃ នៅ

ពេលណាដែលអ្នកអនុញ្ញាតឲ្យព្រះជាម្ចាស់ធ្វើការតាមបំណងព្រះហឫទ័យរបស់ទ្រង់សម្រាប់ជីវិតរបស់អ្នក ជាមួយនឹងតរិយាបថនៃការទុកចិត្ត និង ស្តាប់បង្គាប់។

លំហាត់អនុវត្តន៍

១១ តើការណែនាំណាមួយដែលគួរយកមកប្រើ ដើម្បីជួយស្វែងរកដំណោះស្រាយសម្រាប់បញ្ហាខាងក្រោមនេះ?

ក) តាំងពីប្តីរបស់នាងបានលែងលះនាងមក នាងមើរីម (Miriam) មិនអាចមើលឃើញថា នាងជាមនុស្សដែលមានតម្លៃសម្រាប់ខ្លួនឯងទៀតទេ។ អត្តសញ្ញាណរបស់នាង បានដក់ជាប់ជាមួយនឹងប្តីរបស់នាងដល់ថ្នាក់ បន្ទាប់ពីលែងលះគ្នាហើយ នាងហាក់បីដូចជាគ្មានគោលបំណងអ្វីនៅក្នុងជីវិតរបស់នាងទៀតទេ។ តើមានអ្វីដែលអាចជួយនាងបាន?

.....

.....

ខ) ចច (George) គឺជាបុរសវ័យក្មេងម្នាក់ គាត់មានចិត្តស្រឡាញ់មិត្តរួមថ្នាក់របស់គាត់នៅឯមហាវិទ្យាល័យ។ ពួកគេបានទាក់ទងគ្នា ប៉ុន្តែជិតដល់ពេលដែលពួកគេត្រូវរៀបការ នាងបានប្រាប់គាត់ថា នាងមិនអាចរៀបការជាមួយគាត់ទៅវិញ។ ដើម្បីគេចពីទុក្ខសោករបស់គាត់ ចច បានចូលរួមជាមួយសិស្សមហាវិទ្យាល័យផ្សេងទៀត ដើម្បីស្វែងរកការសប្បាយ គាត់បានចាក់តន្ត្រីខ្លាំងៗនៅពេលដែលគាត់នៅម្នាក់ឯង ហើយគាត់ធ្វើអ្វីដែលគាត់អាចធ្វើបានដើម្បីជៀសវាងពីការគិតអំពីបញ្ហារបស់គាត់។ ប៉ុន្តែគាត់គឺជាគ្រិស្តបរិស័ទម្នាក់ ហើយអ្វីៗទាំងអស់នេះមិនបានធ្វើឲ្យគាត់ស្កប់ចិត្តឡើយ ផ្ទុយទៅវិញគាត់មានអារម្មណ៍មិនស្កប់ និង មិនសប្បាយចិត្តស្មើគ្រប់ពេល។ តើគោលការណ៍មួយណា ដែលអាចជាជំនួយដ៏ល្អសម្រាប់គាត់?

.....

.....

គ) នាងអែន (Anne) ឈឺចាប់ណាស់ ព្រោះតែនាងត្រូវតែត្រឡប់ពីមហាវិទ្យាល័យមកផ្ទះវិញ ដើម្បីថែទាំម្តាយមេម៉ាយរបស់នាង ដែលកំពុងតែមានជំងឺ។ នាងមានអារម្មណ៍ថាជីវិតគឺមិនយុត្តិធម៌ចំពោះនាងនោះទេ។

.....

.....

ឃ) តាំងពីប្តីរបស់នាងចេន (Jane) បានលាចាកលោកទៅ នាងធ្លាក់ខ្លួនទៅពឹងផ្អែកលើគ្រួសារ មិត្តភក្តិ និងអ្នកជិតខាងរបស់នាង ដើម្បីធ្វើអ្វីៗសម្រាប់នាង។ នាងស្ទើរតែមិនដែលចេញពីផ្ទះសោះ ប៉ុន្តែនាងរំពឹងទុកឲ្យ អ្នកដទៃមកសួរសុខទុក្ខនាងញឹកញាប់ ឲ្យគេផ្គត់ផ្គង់អាហារសម្រាប់នាង និង ធ្វើអ្វីតាមតែនាងសុំគេឲ្យធ្វើ។ នាងហាក់បីដូចជាខ្វល់ខ្វាយតែពីខ្លួនឯង។ នាងភ្ជួញភ្ជែរថាអ្នកដទៃមិនខ្វល់ខ្វាយពីនាង ហើយថាគ្មាននរណាម្នាក់រងទុក្ខស្មើនាងនោះទេ។ នាងពិតជាបាក់ទឹកចិត្តខ្លាំងណាស់។

.....

.....

ង) ភីលីពទើបតែបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ និងកំពុងត្រៀមខ្លួនដើម្បីចូលធ្វើព័ន្ធកិច្ច។ ប៉ុន្តែឪពុករបស់គាត់ដែលជាកសិករ ទើបតែបានដួលហើយធ្វើឲ្យបាក់ឆ្អឹងខ្នងរបស់គាត់។ គាត់មិនអាចធ្វើការក្នុងចំការរបស់គាត់អស់រយៈពេលច្រើនខែ។ គាត់បានសុំឲ្យភីលីពត្រឡប់មកជួយគាត់ រហូតដល់គាត់អាចធ្វើការដោយខ្លួនឯងឡើងវិញ។ ភីលីពទើបតែនឹងទទួលបានការ តែងតាំងជាគ្រូគង្វាលជំនួយដោយបេសកជននាំមុខម្នាក់ នៅក្នុងស្តាប័នរបស់គាត់។ គាត់ខ្លាចថា ប្រសិនបើគាត់បដិសេធការតែងតាំងនេះ គាត់នឹងមិនអាចមានឱកាសបែបនេះម្តងទៀតទេ។

.....

.....

៦. របៀបដែលក្រុមជំនុំអាចជួយបាន

វគ្គបំណងទី៥. *ស្គាល់ពីគោលការណ៍ដ៏ពិតដែលក្រុមជំនុំគួរតែធ្វើតាមដើម្បីជួយសមាជិករបស់ខ្លួនដែលនៅលីវ។*

ថ្មីៗកន្លងមកនេះ ខ្ញុំបានអានការផ្សព្វផ្សាយមួយនៅក្នុងព្រឹត្តិប័ត្ររបស់ក្រុមជំនុំមួយ ដែលផ្សាយថា៖ "សូមអញ្ជើញចូលរួមថ្នាក់សិក្សាថ្មីរបស់យើង សម្រាប់អ្នកនៅលីវ ចាប់ពីអាយុ ១៩ ដល់ ៩០ឆ្នាំ មិនថានៅលីវដោយគ្មានជម្រើស ឬតាមការរៀបចំនោះទេ" ។ ដោយ*គ្មានជម្រើស*មានន័យថា អ្នកនៅលីវក៏ដោយសារតែគ្មាននរណាម្នាក់ត្រូវការអ្នក ហើយដោយ*ការរៀបចំ*មានន័យថាអ្នកជ្រើសយកភាពនៅលីវ។ ប្រយោគនេះបានបង្ហាញពីបញ្ហាដ៏ធំគឺការមិនយល់ពីតម្រូវការ និង កិត្តិយសផ្ទាល់របស់អ្នកនៅលីវ។ ក្រុមជំនុំនេះមានបំណងចង់ *ជួយ*អ្នកដែលនៅតែម្នាក់ឯង ប៉ុន្តែគេខ្វះការយល់ដឹងអំពីមនុស្សដែលគេព្យាយាមឈោងចាប់ និង ខ្វះការយល់ដឹងពីរបៀបក្នុងការជួយអ្នកទាំងនោះ។

មានក្រុមជំនុំមួយទៀត បានបើកថ្នាក់សិក្សាសម្រាប់ "គូ និង សេសសល់" ។ *គូ*ប្រាកដណាស់គឺសំដៅទៅលើដៃគូដែលបានរៀបការរួចហើយ។ *សេសសល់*គឺបង្ហាញពីភាពដែលគេទុកចោល ឬ មិនត្រូវការ។

ក្រុមជំនុំ *អាច*មានព័ន្ធកិច្ចដោយមានប្រសិទ្ធិភាព និង សំខាន់ចាំបាច់ណាស់ទៅកាន់អ្នកនៅលីវ។ នៅក្នុងគម្ពីរសំបុត្រទៅក្រុមជំនុំ បានលើកទឹកចិត្តគ្រិស្តបរិស័ទជាច្រើនលើកច្រើនសាឲ្យបម្រើគ្នាទៅវិញទៅមក។ ខាងក្រោមនេះជាឧទាហរណ៍ខ្លះៗ៖

គម្ពីរកាឡាទី ៦:២ *ត្រូវជួយរំលែកទុក្ខធុរៈគ្នាទៅវិញទៅមក ធ្វើយ៉ាងនេះ ទើបបងប្អូនបំពេញតាមក្រឹត្យវិន័យរបស់ព្រះគ្រិស្តទាំងស្រុង។*

គម្ពីរអេភេសូ ៤:៣២ *ត្រូវមានចិត្តសប្បុរស និងចេះអាណិតមេត្តាដល់គ្នាទៅវិញទៅមក។ ត្រូវប្រណីសន្តោសគ្នាទៅវិញទៅមក ដូចព្រះជាម្ចាស់បានប្រណីសន្តោសបងប្អូន ដោយសារព្រះគ្រិស្តដែរ។*

គម្ពីរកាឡាទី ៦:១០	*ហេតុនេះ ពេលយើងមានឱកាសនៅឡើយ យើងត្រូវប្រព្រឹត្តអំពើល្អចំពោះមនុស្សទាំងអស់ ជាពិសេស ចំពោះបងប្អូនរួមជំនឿ។*
គម្ពីរយ៉ាកុប ៥:១៦	*ដូច្នេះ សូមបងប្អូនលន់តួបាបដល់គ្នាទៅវិញទៅមក ព្រមទាំងអធិស្ឋានអោយគ្នាទៅវិញទៅមកផង ដើម្បីអោយបានជាសះស្បើយ។*
គម្ពីររ៉ូម១២:៥, ១០, ១៣,១៥	*យើងក៏ដូច្នោះដែរ យើងមានគ្នាច្រើនរួមជាព្រះកាយតែមួយក្នុងអង្គព្រះគ្រិស្ត ហើយម្នាក់ៗជាសរីរាង្គរបស់គ្នាទៅវិញទៅមក។....ចូរស្រឡាញ់រាប់អានគ្នាទៅវិញទៅមក ទុកដូចជាបងប្អូនបង្កើត។ ត្រូវលើកកិត្តិយសគ្នាទៅវិញទៅមកដោយចិត្តគោរព។....ត្រូវជួយទំនុកបម្រុងប្រជាជនដ៏វិសុទ្ធ*ដែលខ្វះខាត ព្រមទាំងទទួលភ្ញៀវដោយរាក់ទាក់ផង។....ចូរអរសប្បាយជាមួយអស់អ្នកដែលអរសប្បាយ ចូរយំសោកជាមួយអស់អ្នកដែលយំសោក។*
គម្ពីរភីលីព ២:៣-៤	*កុំធ្វើអ្វីដោយចង់ប្រកួតប្រជែងគ្នា ឬដោយរួតបំប៉ោងឡើយ ផ្ទុយទៅវិញ ត្រូវដាក់ខ្លួន ហើយចាត់ទុកអ្នកឯទៀតៗថាប្រសើរជាងខ្លួន។ ក្នុងចំណោមបងប្អូន ម្នាក់ៗកុំគិតតែពីប្រយោជន៍ផ្ទាល់ខ្លួនឡើយ គឺត្រូវគិតដល់ប្រយោជន៍អ្នកដទៃវិញ។*

មានក្រុមជំនុំមួយបានលើកទឹកចិត្តក្រុមគ្រួសារទាំងអស់នៅក្នុងក្រុមជំនុំ "ជ្រើសយក" សមាជិកនៅលីវណាម្នាក់ ហើយឲ្យគេញ៉ាំអាហាររួមជាមួយក្រុមគ្រួសារ ចូលរួមសកម្មភាពលេងកំសាន្ត និង ការចែករំលែកតាមរបៀបផ្សេងៗទៀត។ ក្រុមជំនុំមួយទៀត បានរៀបចំសមាជិកជាក្រុមមានគ្នា ១០ ទៅ ១៥នាក់ រួមបញ្ចូលទាំងសមាជិកមានគ្រួសារ និង នៅលីវ ហើយក្រុមទាំងនេះត្រូវជួបជុំគ្នាជាញឹកញាប់ដើម្បីធ្វើការប្រកបគ្នា និង ចែកចាយ។ ក្រុមទាំងនេះ ត្រូវបានរៀបចំជាថ្មីរៀងរាល់បីខែម្តង ដើម្បីឲ្យគ្រប់គ្នាមានឱកាសស្គាល់មនុស្សដែលគេមិនដែលមានឱកាសបានស្គាល់។

សម្រាប់អ្នកនៅលីវវ័យក្មេង ម៉ោងសិក្សាព្រះគម្ពីរពិសេស ការចែកចាយ និង ការប្រកបគ្នាដែលតម្រង់ឆ្ពោះទៅរកតម្រូវការពិសេសរបស់ពួកគេអាចនឹងមានប្រយោជន៍សម្រាប់គេ។ អ្នកនៅលីវវ័យចំណាស់វិញ អាចមានអារម្មណ៍កាន់តែស្រណុកចិត្តនៅក្នុងថ្នាក់រៀននោះ ជាមួយនឹងអ្នកមានគ្រួសារ និងអ្នកនៅលីវ។

មធ្យោបាយដ៏ល្អបំផុតដើម្បីឲ្យអ្នកមានគ្រួសារអាចជួយបង្កើតនូវការយល់ដឹងពីអារម្មណ៍ និង តម្រូវការពិសេសរបស់អ្នកនៅលើវ។ ត្រូវជៀសវាងការបែងចែកដែលបន្ថោកកិត្តិយស ដូចជា "ក្រមុំចាស់" ឬ "ព្រះពរដែលមិនទានមាននរណាទទួលយក"។ ត្រូវចាត់បញ្ចូលមនុស្សពេញវ័យដែលនៅលើវទៅក្នុងសកម្មភាពសំខាន់ៗរបស់ក្រុមជំនុំ ដែលជាកន្លែងអនុញ្ញាតឲ្យគេអាចប្រើប្រាស់ទេពកោសល្យរបស់គេ។ ត្រូវទាញយកផលប្រយោជន៍ (ប៉ុន្តែកុំបំពាន) ពីសេរីភាពរបស់ពួកគេដើម្បីថ្វាយពេលវេលារបស់ពួកគេកាន់តែច្រើនទៅក្នុងសកម្មភាពព័ន្ធកិច្ច។ ពួកគេអាចជាជំនួយដ៏អស្ចារ្យមួយដល់គ្រូគង្វាល និង អ្នកដឹកនាំដទៃទៀតនៅក្នុងក្រុមជំនុំ។ សូមស្វែងរកជាពិសេស អ្នកណាដែលមានទំនោរចង់ដកខ្លួន និង ភ័យខ្លាច មិនចង់ចូលរួម។ ពួកគេអាចរងនូវការឈឺចាប់ដែលមិនអាចទ្រាំបាន ហើយត្រូវការធ្វើឲ្យទុកចិត្តថាពួកគេទទួលបានក្តីស្រឡាញ់។

បទចម្រៀងដ៏ល្បី មួយបទ បានច្រៀងថា៖

ខ្ញុំគឺជាថ្មដា ខ្ញុំគឺជាកោះ

ថ្មដាមិនចេះឈឺចាប់

កោះមិនដែលយំ

— "ខ្ញុំគឺជាថ្មដា" (និពន្ធដោយ លោកស៊ីម៉ូន និង ហ្គាហ្វាន់ខល)

ពាក្យទាំងនេះស្តាប់ទៅដូចជាការទួញសោករបស់អ្នកនៅលើវម្នាក់ដែលបានឈឺចាប់យ៉ាងខ្លាំងដោយសារដែលទំនាក់ទំនងនៅក្នុងជីវិតពួកគេ។ ព្រះគ្រិស្តបានបង្រៀនយើងថា យើងត្រូវចូលរួមជាមួយពួកមនុស្ស ទោះបីជាត្រូវប្រឈមមុខនឹងការក្បត់ពីអ្នកខ្លះក៏ដោយ។ ផលចំណេញ គឺច្រើនជាងអ្វីដែលអាចនឹងបាត់បង់ទៅទៀត។

អ្នកជឿដែលមានគ្រួសារ ដែលចំណាយពេលវេលាដើម្បីបង្កើតមិត្តភាពជាមួយអ្នកនៅលើវគ្រប់វ័យ នឹងទទួលបានរង្វាន់ជាច្រើន តាមរយៈការបន្ថែមទៅលើជីវិតរបស់ពួកគេនូវតរិយោបថថ្មី និង ការយល់ដឹងថ្មី អំពីស្នាព្រះហស្តជាច្រើនប្រភេទរបស់ព្រះជាម្ចាស់។ មនុស្សគ្រប់រូបត្រូវចងចាំថា មូលដ្ឋានគ្រឹះសម្រាប់ទំនាក់ទំនងរបស់គ្រិស្តបរិស័ទ គឺមិនមែនសង្គម ឬ ឋានៈនៅក្នុងលោកីយ៍របស់បុគ្គលណាម្នាក់នោះទេ ប៉ុន្តែគឺជារឿងដែលគាត់ជាកម្មសិទ្ធិរបស់ព្រះគ្រិស្តឯណោះវិញ។ យើងអាចយល់ដឹង និង បានទទួលព្រះពរ តាមរយៈជីវិតរបស់អ្នកដទៃ!

លំហាត់អនុវត្តន៍

១២ តើប្រយោគណាខ្លះនៅខាងក្រោមនេះ ដែលបង្ហាញពីគោលការណ៍ល្អៗ សម្រាប់ក្រុមជំនុំអាចធ្វើតាម ដើម្បីជួយដល់សមាជិកនៅលើវរបស់ពួកគេ?

ក) រឿងដែលក្រុមជំនុំគួរតែសង្កត់ធ្ងន់ទៅលើ គឺការបំពេញតម្រូវការរបស់ក្រុមអ្នកមានគ្រួសារ។

ខ) អ្នកនៅលើវគួរតែត្រូវបានរាប់បញ្ចូលនៅក្នុងសកម្មភាពជាមួយនឹងអ្នកមានគ្រួសារ។

គ) គួរបែងចែកក្រុមសមាជិកដោយយោងទៅតាម អ្នកនៅលើវ ឬ មានគ្រួសារ ជាជាង ទៅតាមកម្រិតអាយុរបស់ពួកគេ។

ឃ) ត្រូវយកចិត្តទុកដាក់ ដើម្បីជៀសវាងការដាក់ស្លាកលើមនុស្ស ទៅតាមរបៀបដែលអាចនឹងបន្ថោកតម្លៃរបស់គេ ឬ ដាក់ពួកគេចេញពីកិត្តិយសផ្ទាល់ខ្លួនរបស់ពួកគេ។

ង) ព្រះគម្ពីរដាស់តឿនអស់អ្នកដែលជាមនុស្សរបស់ព្រះគ្រិស្ត ឲ្យខ្វល់ខ្វាយអំពីគ្នាទៅវិញទៅមក

ច) សេរីភាពធំធេងរបស់អ្នកនៅលើវអាចជាព្រះពរសម្រាប់ក្រុមជំនុំ ដែលរាប់បញ្ចូលពួកគេនៅក្នុងព័ន្ធកិច្ចសំខាន់ៗ។

ឆ) ទំនាក់ទំនងរបស់គ្រិស្តបរិស័ទ ត្រូវបានបូករួមអស់អ្នកណាដែលជាមនុស្សរបស់ព្រះគ្រិស្ត។

នៅក្នុងជំពូកចុងក្រោយរបស់យើង យើងនឹងសិក្សាអំពីផ្នែកសំខាន់ៗនៃបញ្ហាខ្លះ ដែលយើងរាល់គ្នាត្រូវប្រឈមមុខក្នុងកម្រិតណាមួយនៅក្នុងដំណើរជីវិតរបស់យើង។ យើងសង្ឃឹមថា អ្នកទទួលបានផលប្រយោជន៍ពីការសិក្សានៅក្នុងជំពូកនេះ ហើយសង្ឃឹមថាជំពូកចុងក្រោយ នឹងជួយអ្នកឲ្យយល់ដឹងថា អ្នកវិសេសអស្ចារ្យយ៉ាងណាដែលបានធ្វើជាមនុស្សរបស់ព្រះគ្រិស្ត ហើយបានសម្រាកនៅក្នុងម្លប់នៃស្លាបទ្រង់។ សូមព្រះអម្ចាស់ព្រះទានពរអ្នក ស្របពេលដែលអ្នកបន្តការសិក្សាទៅមុខទៀត។

ការប្រឡងផ្ទាល់ខ្លួន

សំណួរពហុជម្រើសៗ ចូរជ្រើសរើសចម្លើយមួយដែលល្អបំផុតសម្រាប់សំណួរនីមួយៗ។

១ អារម្មណ៍ដែលត្រូវបានគេព្រងើយកន្តើយ ភាគច្រើនកើតមានឡើងនៅក្នុង
   ក) មនុស្សមេម៉ាយ ឬ ពោះម៉ាយ
   ខ) មនុស្សដែលមិនទាន់រៀបការ
   គ) មនុស្សដែលបានលែងលះគ្នា

២ លោកសាវ័កប៉ូលបានមានប្រសាសន៍ថា អ្នកនៅលីវគួរតែបន្តភាពនៅលីវរបស់គេល្អជាង ព្រោះ
   ក) ជីវិតនៅលីវគឺរស់បានយូរជាងអ្នកដែលរៀបការ។
   ខ) ជីវិតនៅលីវគឺសប្បាយរីករាយជាង។
   គ) អាពាហ៍ពិពាហ៍ត្រូវធ្វើឡើង ដើម្បីកុំឲ្យប្រាស់ចាកសីលធម៌តែប៉ុណ្ណោះ។
   ឃ) អ្នកនៅលីវមានឱកាសថ្វាយពេលវេលារបស់គេបានច្រើនទៅចំពោះកិច្ចការរបស់ព្រះជាម្ចាស់ ដោយគ្មានការរំខាននោះទេ។

៣ ជីវិតនៅលីវត្រូវបានគេចាត់ទុកជាអំណោយទានពិសេសមួយ ព្រោះ
   ក) អស់អ្នកដែលជ្រើសយកការចំណាយពេលវេលារបស់គេសម្រាប់ព្រះរាជ្យនៃស្ថានបរមសុខ
   ជា ជាងការរៀបការ គឺជាព្រះពរដ៏ពិតមួយសម្រាប់ក្រុមជំនុំ។
   ខ) មនុស្សគ្រប់គ្នាអាចនៅលីវបានប៉ុន្តែមានមនុស្សមួយចំនួនតូចតែប៉ុណ្ណោះសុខចិត្តធ្វើ។
   គ) មនុស្សដែលបានជ្រើសរើសរក្សាភាពបរិសុទ្ធរបស់ខ្លួនបាន គឺជាការប្រទានមកពីព្រះជាម្ចាស់។

៤ តើអ្វី គួរតែជាអាទិភាពទីមួយនៅក្នុងជីវិតរបស់អ្នកនៅលីវ?
   ក) ការរៀបការជាមួយនឹងគ្រិស្តបរិស័ទ។
   ខ) បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។
   គ) ធ្វើអ្វីដែលគាប់ចិត្តអ្នកដទៃ។
   ឃ) យកឈ្នះភាពឯកា។

៥ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺដំបូងបង្អស់យើងត្រូវតែ
   ក) នៅលីវ
   ខ) គោរពកោតខ្លាចព្រះជាម្ចាស់
   គ) រៀបការ

៦ មូលដ្ឋានគ្រឹះដើម្បីមានអាពាហ៍ពិពាហ៍រឹងមាំគឺ
   ក) ទំនាក់ទំនងសង្គមច្រើនបែប
   ខ) ការធ្វើកិច្ចការនៅក្នុងក្រុមជំនុំបានច្រើនឆ្នាំ។
   គ) ការអភិវឌ្ឍបុគ្គលិកលក្ខណៈគ្រិស្តបរិស័ទដែលរឹងមាំ និង ពេញវ័យ។

៧ តើជម្រើសណាមួយនៅខាងក្រោមនេះជាជម្រើសដែលអាក្រក់បំផុតសម្រាប់ គ្រិស្តបរិស័ទដែលនៅលីវ?

ក) នៅលីវបន្តទៀតទោះបីជាគាត់មានបំណងចង់រៀបការក៏ដោយ។

ខ) រៀបការជាមួយអ្នកមិនជឿ

គ) ស្វែងរកទំនាក់ទំនងជាមួយនឹងគ្រិស្តបរិស័ទផ្សេងទៀតដែលនៅលីវ។

៨ បទគម្ពីរបានបង្រៀនថា ជាទូទៅអាពាហ៍ពិពាហ៍មិនត្រូវបានអនុញ្ញាតនោះទេ សម្រាប់

ក) អ្នកដែលលែងលះគ្នា

ខ) ស្ត្រីមេម៉ាយ ឬ បុរសពោះម៉ាយ

គ) អ្នកនៅលីវ

ឃ) អ្នកនៅភាពបរិសុទ្ធ

៩ តើមួយណាជាជំហានដំបូងបង្អស់ដែលត្រូវធ្វើមុនពេលសម្រេចចិត្តថាគួរតែរៀបការឬ មិនគួរ?

ក) ស្វែងរកដៃគូជាគ្រិស្តបរិស័ទ។

ខ) ធ្វើតាមការណែនាំរបស់គ្រិស្តបរិស័ទដែលចាស់ទុំជាង។

គ) បង្កើតជីវិតមួយដែលមានភាពនឹងនរសម្រាប់ខ្លួនអ្នក។

ឃ) ថ្វាយអ្វីៗទាំងអស់ទៅចំពោះបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់អ្នក។

១០ តើគោលការណ៍ណាមួយខាងក្រោមនេះ ដែលសំខាន់ជាងគេបំផុតដើម្បីដឹកនាំក្រុមជំនុំ ឲ្យបំពេញតម្រូវការរបស់អ្នកនៅលីវ?

ក) គួរតែរៀបចំសមាជិកជាក្រុម ដោយផ្អែកលើភាពមានគ្រួសារ ឬ នៅលីវរបស់ពួកគេ ដើម្បីឲ្យក្រុមជំនុំបំពេញនូវតម្រូវការពិសេសៗសម្រាប់សមាជិកគ្រប់រូបបាន។

ខ) ចូរធ្វើឲ្យអ្នកនៅលីវរួលជាមួយនឹងសកម្មភាពរបស់ក្រុមជំនុំ ហើយពួកគេនឹងបានសប្បាយចិត្ត។

គ) មូលដ្ឋានគ្រឹះសម្រាប់ទំនាក់ទំនងរបស់គ្រិស្តបរិស័ទគឺមិនមែនហាន:ក្នុងសង្គមរបស់បុគ្គលម្នាក់នោះទេ តែវាជារឿងដែលថាគាត់ជាមនុស្សរបស់ព្រះគ្រិស្តនោះវិញ។

១១ **ចម្លើយខ្លីៗ ៗ** ចូររៀបរាប់ ការណែនាំទាំងប្រាំយ៉ាងដែលនឹងជួយអ្នកនៅលីវរកឃើញដំណោះស្រាយសម្រាប់បញ្ហារបស់ពួកគេ។

.....

.....

.....

.....

.....

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

៧ ខ), គ, ង, និង ច) ជាចម្លើយត្រឹមត្រូវ។

១ ខ) ភាពមិនប្រាកដប្រជា (អ្នកប្រហែលជាជ្រើសរើសយកចម្លើយ ក) ភាពភ័យខ្លាច ។ ប៉ុន្តែនាងស៊ូសាន នៅក្នុងឧទាហរណ៍ទីពីរមិនមានភាពភ័យខ្លាចនោះទេ ដោយនាងបានដាក់ការទុកចិត្តរបស់នាងទៅលើព្រះអម្ចាស់សម្រាប់អនាគតរបស់នាង)។

៨ មិនត្រូវយកគ្រិស្តបរិស័ទទៅធ្វើមស្មើជាមួយនឹងអ្នកមិនជឿឡើយ (គម្ពីរ២កូរិនថូស ៦:១៤)។

២ ក) គម្ពីរ១ពេត្រុស ៤:១២-១៩

ខ) គម្ពីរអេសាយ ៥៣:៣; គម្ពីរយ៉ូហាន ១:១១

គ) គម្ពីរទុតិយកថា ៣៣:១២; គម្ពីរយ៉ូស្វេ ១:៩

ឃ) គម្ពីរ២ កូរិនថូស ១:៣-៤, ៦

៩ គ) អស់អ្នកដែលដាក់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ជាទីមួយ អាចទុកចិត្តបានថាទ្រង់នឹងបំពេញតម្រូវការរបស់គេនៅក្នុងពេលសមរម្យមួយ មិនថាតម្រូវការនោះជាអ្វីនោះទេ។

៣ ក) ខគម្ពីរនេះស័ក្តិសមយកទៅប្រើសម្រាប់អ្នកណាដែលឆ្លងបញ្ហាលំបាកដែលមិនមែនជាកំហុសរបស់គាត់ខ្លួនឯងនោះទេ។

ខ) ខគម្ពីរបង្ហាញថា ទោះបីជាព្រះជាម្ចាស់អនុញ្ញាតឲ្យយើងទទួលការសាកល្បងយ៉ាងណាក្តី ក៏ទ្រង់នឹងនាំយើងឲ្យឆ្លងកាត់បញ្ហានោះបានយ៉ាងជោគជ័យ។

១០ ចម្លើយរបស់អ្នក។ ចម្លើយនេះគួរតែរួមបញ្ចូលគំនិតមួយនេះ៖ ជំហានដំបូងនៅក្នុងការសម្រេចចិត្តរៀបការគឺការប្តេជ្ញាចិត្តទាំងស្រុងទៅចំពោះបំណងព្រះហឫទ័យព្រះជាម្ចាស់សម្រាប់ជីវិតរបស់អ្នក។ បន្ទាប់មក អនុញ្ញាតឲ្យព្រះជាម្ចាស់បញ្ជាក់នៅក្នុងដួងចិត្តរបស់អ្នក អំពីអ្វីដែលជាបំណងព្រះហឫទ័យរបស់ទ្រង់សម្រាប់អ្នក។ ទ្រង់នឹងនាំផ្លូវអ្នកទៅក្នុងផ្លូវមួយដែលត្រឹមត្រូវ។

៤ ក) ខគម្ពីរនេះអាចស័ក្តិសមយកទៅប្រើជាមួយស្ត្រីមេម៉ាយ ឬ បុរសពោះម៉ាយ។

ខ) ខគម្ពីរនេះបង្ហាញឲ្យឃើញថា ព្រះជាម្ចាស់ទ្រង់ជ្រាបពីការទួញសោករបស់យើង ហើយទ្រង់មានព្រះទ័យសន្តោសមេត្តាសម្រាប់យើង។ ទ្រង់នឹងនាំយើងឆ្លងកាត់គ្រាលំបាក ទៅក្នុងគ្រាដែលមានអំណរ ប្រសិនបើយើងទុកចិត្តទ្រង់។

១១ ចម្លើយរបស់អ្នក។ ប៉ុន្តែខាងក្រោមនេះជាចម្លើយរបស់ខ្ញុំ៖

ក) នាងមើរីម (Miriam) ត្រូវតែស្គាល់ពីតំណែងរបស់នាងនៅក្នុងព្រះគ្រិស្ត ជាមុនសិន។

ខ) ចច (George) អាចទទួលបានផលប្រយោជន៍ជាច្រើនតាមរយៈការបង្កើនពេលវេលាសម្រាប់ការអានព្រះគម្ពីរ ការសញ្ជឹងគិត និង ការអធិស្ឋានបន្ថែមទៀត ព្រមទាំងមានទំនាក់ទំនងជាមួយអ្នកជឿទាំងពីរភេទផងដែរ។

គ) នាងអែន (Anne) ត្រូវការដកពិសោធន៍មើលពីដួងចិត្តរបស់នាង និង ផ្លាស់ប្តូររបៀបដែលនាងមើលទៅកាន់កាល:ទេស:របស់នាង។ នេះគឺជាពេលដែលនាងអាចបង្ហាញក្តីស្រឡាញ់របស់នាងទៅចំពោះម្តាយរបស់នាង និង បង្កើតភាពជិតស្និទ្ធជាមួយគាត់ផង។

ឃ) នាងចេន (Jane) ទទួលបានប្រយោជន៍តាមរយៈការជួយអ្នកដទៃ។ នាងគួរតែអរព្រះគុណព្រះជាម្ចាស់ ដែលតម្រូវការរបស់នាងត្រូវបានបំពេញ ដែលនាងមានសុភាពល្អ និងអាចបំពេញអ្នកដទៃបានផងដែរ។

ង) ភីលីព (Philip) គួរតែយកគោលការណ៍គ្រិស្តបរិស័ទសម្រាប់ដោះស្រាយបញ្ហាទៅប្រើប្រាស់ដើម្បីដឹងថាអ្វីដែលជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់បញ្ហានេះ។ ប្រហែលជាពេលវេលាដែលចំណាយជាមួយឪពុករបស់គាត់ អាចជាការហ្វឹកហាត់យ៉ាងល្អសម្រាប់គាត់ ជាងការចំណាយពេលជាមួយព័ន្ធកិច្ចដទៃទៅទៀត។ ឬប្រហែលជាគាត់អាចស្វែងរកមនុស្សម្នាក់ដើម្បីធ្វើការជាមួយនឹងឪពុករបស់គាត់។ អ្វីដែលសំខាន់នោះគឺគាត់ស្វែងរកឃើញបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

៥ ចម្លើយរបស់អ្នក។ ខ្ញុំសង្ឃឹមថាអ្នកបានធ្វើការគិតគូរយ៉ាងហ្មត់ចត់ទៅលើសំណួរនេះ ហើយបានព្យាយាមស្វែងរកខគម្ពីរជំនួយខ្លះៗសម្រាប់បញ្ហានៅក្នុងផ្នែកនេះ។

១២ ក) មិនមែនជាគោលការណ៍ល្អ

ខ) ជាគោលការណ៍ល្អ

គ) មិនមែនជាគោលការណ៍ល្អ

ឃ) ជាគោលការណ៍ល្អ

ង) ជាគោលការណ៍ល្អ

ច) ជាគោលការណ៍ល្អ

ឆ) ជាគោលការណ៍ល្អ

៦ ផ្ទុយពីការស្វែងរកការរៀបអាពាហ៍ពិពាហ៍ យើងរាល់គ្នាគួរតែស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ និង បំណងព្រះហឫទ័យរបស់ទ្រង់សម្រាប់ជីវិតរបស់យើងវិញ។ ប្រសិនបើយើងនឹងធ្វើយ៉ាងដូច្នោះមែន ទ្រង់នឹងដាក់បន្ថែមទៅក្នុងជីវិតរបស់យើងនូវអ្វីដែលល្អបំផុតសម្រាប់យើង។ ការទាំងនេះក៏មានការរៀបអាពាហ៍ពិពាហ៍ដែរ ប៉ុន្តែបើវាមិនមែនជាការរៀបអាពាហ៍ពិពាហ៍នោះទេ យើងនឹងនៅតែដឹងថាព្រះជាម្ចាស់ ទ្រង់កំពុងគ្រប់គ្រងជីវិតរបស់យើង និង កំពុងធ្វើកិច្ចការសម្រាប់ប្រយោជន៍របស់យើង។

ការប្រឡងជំពូកទីពីរ

ឥឡូវនេះ ដោយអ្នកបានបញ្ចប់ជំពូកទីពីរ អ្នកអាចឆ្លើយនឹង *សំណួរការប្រឡងជំពូកទីពីរ* បាន។ ចូរពិចារណាមេរៀនពីខាងលើ មុនពេលដែលអ្នកចាប់ផ្តើម។ ធ្វើតាមការណែនាំដ៏ប្រុងប្រយ័ត្ន ដើម្បីធ្វើការប្រឡងបន្ទាប់បន្តទៅជំពូកទីបី។



ជំពូកទី បី
ផ្នែកពិសេសនៃបញ្ហា

<u>មេរៀន</u>

៧ រឿងទាក់ទងផ្លូវភេទទៅតាមផែនការរបស់ព្រះជាម្ចាស់

៨ យកឈ្នះ លើការបាក់ទឹកចិត្ត

៩ ការរងទុក្ខ និង សេចក្តីស្លាប់

១០ ការរក្សាក្តីសង្ឃឹម

មេរៀនទី ៧ រឿងទាក់ទងផ្លូវភេទតាមផែនការរបស់ព្រះជាម្ចាស់

ទំនាក់ទំនងមួយដែលស្រស់ស្អាតជាងគេនៅក្នុងជីវិតនេះ គឺថាមនុស្សប្រុស និង មនុស្សស្រីដែលបានរៀបការ និង បានក្លាយជាសាច់ឈាមតែមួយ។ រឿងដែលទាក់ទងនឹងផ្លូវភេទរបស់មនុស្សគឺជាអំណោយទានពីព្រះជាម្ចាស់ ដែលមិនត្រឹមតែអនុញ្ញាតឲ្យយើងអាចបង្កើតកូន មកនៅក្នុងពិភពលោកនេះបាននោះទេ ប៉ុន្តែក៏បានផ្តល់នូវ ការរួបរួមដែលស្និទ្ធស្នាលបំផុតរវាងមនុស្សប្រុសម្នាក់និង មនុស្សស្រីម្នាក់ដែរ។

បញ្ហាចម្បងៗខ្លះ គឺកើតឡើងនៅពេលដែលបុរស និង ស្ត្រីបំពានទៅលើជីវិតផ្លូវភេទរបស់គេ។ មានមនុស្សជាច្រើននាក់ ព្យាយាមគ្រប់គ្រងជីវិតផ្លូវភេទរបស់គេ ដោយមិនខ្វល់ពីព្រះប្រាជ្ញាញាណដែលព្រះជាម្ចាស់បានបើកបង្ហាញ និង ពីការជួយរបស់ទ្រង់សម្រាប់ឲ្យពួកគេអាចគ្រប់គ្រងរូបកាយរបស់គេនោះឡើយ។ ជាលទ្ធផល ពួកគេបានឃើញខ្លួនគេជាប់នៅក្នុងរបៀបរស់នៅមួយ ដែលមិនវិសុទ្ធ និង ខូចខាតទាំងខាងរូបកាយ និង ខាងផ្លូវចិត្តផងដែរ។

ព្រះជាម្ចាស់មិនបានទុកយើងចោល ដោយគ្មានការណែនាំយ៉ាងជាក់លាក់ដើម្បីគ្រប់គ្រងអារម្មណ៍ផ្លូវភេទដែលមាននៅក្នុងយើងនោះឡើយ។ មិនថាអ្នកបានរៀបការហើយ ឬ នៅលីវនោះទេ ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យអ្នកចេះគ្រប់គ្រងរឿងនេះនៅក្នុងជីវិតរបស់អ្នក។ ការណែនាំដែលព្រះជាម្ចាស់បានផ្តល់ឲ្យនៅក្នុងព្រះបន្ទូលរបស់ទ្រង់ បានកំណត់ព្រំដែនសម្រាប់ទង្វើដែលទាក់ទងនឹងរឿងផ្លូវភេទ។ ការមិនស្តាប់បង្គាប់ គឺនាំឲ្យមានទោស ភាពអាម៉ាស់ ការរងទុក្ខសោក និង អំពើបាបនៅក្នុងជីវិតរបស់អ្នក។ រីឯការស្តាប់បង្គាប់វិញ នឹងជួយឲ្យអ្នកបានបម្រើព្រះអម្ចាស់ជាមួយនឹងអំណរ និង ភាពបរិសុទ្ធ នៅក្នុងជីវិតផ្លូវភេទផ្សេងៗគ្នា ដែលជាអំណោយរបស់ទ្រង់សម្រាប់អ្នក។

នៅក្នុងមេរៀននេះ យើងនឹងពិភាក្សាអំពីព្រំដែនដែលព្រះជាម្ចាស់បានកំណត់សម្រាប់ទង្វើដែលទាក់ទងនឹងផ្លូវភេទ ហើយយើងនឹងឆ្លើយសំណួរដែលសួរថា៖ "តើមានគោលការណ៍នៅក្នុងព្រះគម្ពីរអ្វីខ្លះដែលអាចគ្រប់គ្រងរឿងផ្លូវភេទនៅក្នុងជីវិតរបស់គ្រិស្តបរិស័ទ?"

គម្រោងមេរៀន

ក. ជីវិតផ្លូវភេទ និង ភាពនៅលីវ
ខ. ជីវិតផ្លូវភេទ និង ជីវិតអាពាហ៍ពិពាហ៍
គ. សកម្មភាពផ្លូវភេទត្រូវបានហាមឃាត់
ឃ. ប្រឈមមុខជាមួយនឹងបញ្ហាខាងផ្លូវភេទ

វត្ថុបំណងមេរៀន

នៅពេលដែលយើងបញ្ចប់មេរៀននេះ អ្នកនឹងអាច៖

១. ថ្លែងពីគោលការណ៍នៅក្នុងព្រះគម្ពីរដែលទាក់ទងនឹង ជីវិតផ្លូវភេទ និង ជីវិតដែលនៅលីវ។
២. ស្គាល់ពីគោលការណ៍នៅក្នុងព្រះគម្ពីរដែលទាក់ទងនឹង ជីវិតផ្លូវភេទ និង ជីវិតអាពាហ៍ពិពាហ៍។
៣. ផ្តល់មូលហេតុដែលគ្រិស្តបរិស័ទត្រូវ រារាំងមិនឲ្យធ្វើសកម្មភាពផ្លូវភេទព្រះគម្ពីរបានហាតឃាត់។
៤. បកស្រាយពីរបៀបដែលយើងដឹងថា ការរួមសង្វាសភេទដូចគ្នា គឺជាសកម្មភាពដែលពេញដោយបាប។
៥. ស្វែងរកឥរិយាបថពីក្នុងបទគម្ពីរដែលនឹងផ្តល់នូវដំណោះស្រាយសម្រាប់បញ្ហានៅក្នុងជីវិតផ្លូវភេទ។

សកម្មភាពនៅក្នុងការសិក្សា

១. សូមអានគម្ពីរ១កូរិនថូស ៦:១២-៧:៤០, និងគម្ពីរអេភេសូ ៥:២២-៣៣ ដែលជាខគម្ពីរយោងសម្រាប់មេរៀននេះ។
២. អនុវត្តទៅតាមដំណើរវិវត្តន៍របស់មេរៀនដូចអ្នកធ្លាប់បានធ្វើពីមុនដែរ។
៣. បកមើលនិយមន័យនៃពាក្យសំខាន់ដែលអ្នកមិនស្គាល់នៅក្នុងអក្ខរានុក្រម។
៤. ធ្វើការប្រឡងផ្ទាល់ខ្លួន ហើយផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក។

ពាក្យសំខាន់

ពន្លូត	ការរួមសង្វាសភេទដូចគ្នា	ការបង្កើត
អំពើសហាយស្មន់	ឥតខាន់ស្លា	ជីវិតខាងឯផ្លូវភេទ
ការថោកទាប	ភាពអារ	ច្នៃឲ្យប្រសើរ
ការរួមភេទមុនពេលរៀបការ	ប្តីមួយប្រពន្ធមួយ	រោគស្វាយ
ប្រមេះទឹកបាយ	ការពឹងពាក់គ្នាទៅវិញទៅមក	ជំងឺកាមរោគ
ស្រឡាញ់ភេទខុសគ្នា	មានគភ៌	

ក. ជីវិតផ្លូវភេទ និង ភាពនៅលីវ

វត្ថុបំណងទី១. *ថ្លែងពីគោលការណ៍នៅក្នុងព្រះគម្ពីរដែលទាក់ទងនឹង ជីវិតផ្លូវភេទ និង ជីវិតដែលនៅលីវ។*

វាគឺជាការអនុវត្តទូទៅក្នុងពេលបច្ចុប្បន្ននេះ នៅជាច្រើនកន្លែងក្នុងពិភពលោក ដែលបុរស និង ស្ត្រីមិនទាន់រៀបការ កសាងទំនាក់ទំនងរយៈពេលខ្លីមួយ ឬ ធ្វើរឿងដ៏គ្រោះថ្នាក់ក្នុងគោលបំណងដើម្បីបំពេញ "តម្រូវការ" ខាងផ្លូវភេទរបស់ពួកគេ។ ការរួមរ័កបានក្លាយទៅជារឿងដ៏គួរឲ្យទាក់ទាញដោយសារតែពិភពលោកីយ៍ ពោរពេញទៅដោយយុវជនដែលស្រេកឃ្លាន និង មិនឆ្អែតឆ្អន់ ប្រសិនបើគេមិនបានប្រព្រឹត្តរឿងដែលទាក់ទងនឹងផ្លូវភេទមួយនេះ។ គំរូនៅក្នុងព្រះគម្ពីរអំពី *ភាពនៅលីវ* (មិនទាន់រៀបការ និង មិនប្រព្រឹត្តអំពីទាក់ទងនឹងផ្លូវភេទសោះ) គឺមិនសូវជាមានគេដឹងឮច្រើននោះទេ ហើយតែងតែគ្មាននរណាយកចិត្តទុកដាក់ឡើយ។

តើមនុស្សម្នាក់អាចបន្តភាពនៅលីវរបស់គេបានដែរឬទេ? ប្រាកដណាស់ គេអាច! យើងអាច ចូលទៅរកធនធានដ៏វិសុទ្ធ (ព្រះគម្ពីរ) ដើម្បីបញ្ជៀសនូវការល្បួងនៅក្នុងបញ្ហានេះ ដូចដែលយើងបានធ្វើរួចមកហើយនៅក្នុងផ្នែកផ្សេងៗទៀតនៃជីវិតរបស់យើង។ បទគម្ពីរដែលយើងបានពិភាក្សានៅក្នុងមេរៀនទី ១ គឺគម្ពីរ១កូរិនថូស ១០:១៣ អាចយកទៅប្រើប្រាស់បានចំពោះចំណង់ផ្លូវភេទរបស់យើង ដូចជាចំណង់ចិត្តដទៃទៀតដែរ។ ព្រះជាម្ចាស់ *នឹង* ប្រទានអំណាចឲ្យអ្នកដើម្បីតទល់ជាមួយនឹងសេចក្តីល្បួងឲ្យប្រព្រឹត្តអំពើបាបនេះបាន ហើយការល្បួងទាំងនេះរាប់ទាំងការប្រព្រឹត្តអំពើដែលទាក់ទងនឹងផ្លូវភេទ មុនពេលរៀបការផងដែរ។

លំហាត់អនុវត្តន៍

---

១ យោងទៅតាមគម្ពីរ១កូរិនថូស ១០:១៣ តើព្រះជាម្ចាស់នឹងជួយអ្នកដើម្បីយកឈ្នះលើការល្បួង នៃអំពើបាបខាងឯផ្លូវភេទបានយ៉ាងដូចម្តេច?

.....

ហេតុអ្វីបានជាព្រះជាម្ចាស់ហាមឃាត់មិនឲ្យមានទំនាក់ទំនងផ្លូវភេទក្រៅការរៀបការ? មានមូលហេតុជាច្រើន ហើយមូលហេតុទាំងនោះគឺមានជាប់ទាក់ទងនឹងក្តីស្រឡាញ់ និង ការខ្វល់ខ្វាយព្រះទ័យរបស់ទ្រង់ចំពោះអ្នក។ ទ្រង់សព្វព្រះទ័យចង់ការពារយើងឲ្យផុតពីបញ្ហាធំៗ ដែលយើងឃើញមាននៅក្នុងពិភពលោកសព្វថ្ងៃនេះ៖

១. *កូនឥតខាន់ស្លា* ។ កូនដែលកើតមកដោយឪពុកម្តាយមិនបានរៀបការ គ្មានអភ័យឯកសិទ្ធិទទួលបានការថែទាំ និង ការបំពេញតួនាទីរបស់ឪពុកម្តាយបានទេ។ ពួកគេតែងតែមិនទទួលបានការយកចិត្តទុកដាក់ និង ក្តីស្រឡាញ់នោះទេ។

២. *កំណើនការរំលូតកូន។* មានស្ត្រីដែលមិនបានរៀបការជាច្រើននាក់បានជ្រើសរើសយកការ បញ្ចប់គភ៌របស់ពួកគេដោយការវះកាត់ ជាជាងការផ្តល់កំណើតឲ្យកូនដែលគ្មានការរៀបការត្រឹម ត្រូវនោះ។ ការធ្វើបែបនេះបានបណ្តាយឲ្យមានអារម្មណ៍ថាមានទោសដោយសារតែការសម្លាប់ជីវិត របស់ក្មេងដែលមិនទាន់កើតមកនោះ វាក៏ធ្វើឲ្យមានភាពជ្រួលច្របល់ខាងឯវិញ្ញាណ និង ភាព ឈឺចាប់ខាងឯផ្លូវចិត្តផងដែរ។

៣. *កំណើនជំងឺកាមរោគ។* មនុស្សដែលយកទំនាក់ទំនងផ្លូវភេទ ទៅធ្វើជារឿងធម្មតានៅក្នុងទំនាក់ ទំនងស្នេហា គឺប្រឈមមុខទៅនឹងការឆ្លងជំងឺកាមរោគដូចជា ជំងឺស្វាយ ឬ ប្រមេះទឹកបាយ ដែលអាចប៉ះពាល់ដល់កូនដែលមិនទាន់កើតមកនោះផងដែរ វាធ្វើឲ្យកូននោះខ្វាក់ភ្នែក និង បណ្តាលឲ្យមានបញ្ហាផ្លូវចិត្ត និងផ្លូវកាយ។ ការធ្វើបែបនេះក៏អាចប្រឈមមុខឆ្លងជំងឺអេដស៍ ថែមទៀតផង។

៤. *ស្លាកស្នាមផ្លូវចិត្ត ។* ព្រះជាម្ចាស់មិនមានបំណងព្រះហឫទ័យចង់ឲ្យមានការរួមភេទក្រៅពីទំនាក់ ទំនងអស់កល្បជានិច្ចមួយនោះឡើយ។ នៅពេលដែលគ្មានក្តីស្រឡាញ់រវាងដៃគូរួមភេទ នោះវា នឹងនាំឲ្យមានអារម្មណ៍ព្រងើយកន្តើយ ឬ មានអារម្មណ៍ថាត្រូវបានបំពាន និង មានការថោកទាប។ អារម្មណ៍មានកំហុស ធ្វើឲ្យមានការប៉ះពាល់ផ្លូវចិត្ត និង ការចោទប្រកាន់ខ្លួនឯង។

លំហាត់អនុវត្តន៍

---

២ ការមានអារម្មណ៍ថាមានទោសតែងតែជាស់តឿនយើងថា

ក) គ្មានសង្ឃឹមអ្វីសម្រាប់យើងឡើយ។

ខ) អំពើបាបមិនរំខានដល់យើងនោះទេ។

គ) យើងគួរតែស្តាប់តាមមនសិការដែលព្រះជាម្ចាស់បានប្រទានឲ្យយើង។

ភាពនៅលីវ គឺជាជម្រើសមួយគត់ ផ្ទុយពីការរៀបការ ដែលបានអនុម័ត (អនុញ្ញាត) ដោយព្រះគម្ពីរ ។ នៅក្នុងគម្ពីរ១កូរិនថូស ជំពូក៧ លោកសាវ័កប៉ូលបានណែនាំអស់អ្នកដែលមិនអាចបន្តភាពនៅលីវ ឲ្យ បានរៀបការ។ ការរក្សាភាពបរិសុទ្ធ (ព្រហ្មចារី) នៅក្នុងជីវិតនៅលីវ ហាក់ដូចជាមានបញ្ហាច្រើនសម្រាប់ អស់អ្នកដែលមិនសុខចិត្តរស់នៅតែម្នាក់ឯង និង សម្រាប់អស់អ្នកដែលតែងតែគិត ស្រមៃអំពីការរួមភេទ ឬ អំពីការរៀបការ។ នៅក្នុងមេរៀនទី ៦ យើងបានឃើញថា អ្នកនៅលីវដែលស្មោះស្ម័គ្រជាមួយព្រះគ្រិស្ត ជាអំណោយទានសម្រាប់ក្រុមជំនុំ។ មធ្យោបាយដ៏ល្អបំផុតដើម្បីឲ្យអ្នកនៅលីវម្នាក់អាចសហការជាមួយ ព្រះអម្ចាស់នៅក្នុងការរក្សាភាពបរិសុទ្ធផ្លូវភេទរបស់គេ គឺជាការគ្រប់គ្រងគំនិតរបស់គេ (យ៉ាកុប ១:១៤-១៥)។ នៅក្នុងមេរៀនទី២ យើងបាននិយាយអំពីសារសំខាន់នៃការគ្រប់គ្រងគំនិតរបស់អ្នក ដើម្បីកុំឲ្យអ្នក ធ្លាក់នៅក្នុងការលង្ហែទៅក្នុងអំពើបាប។ ព្រះអម្ចាស់អាចជួយ ហើយទ្រង់ក៏នឹងជួយអ្នកនៅក្នុងបញ្ហានេះ ប្រសិនបើអ្នកបានធ្វើការសម្រេចចិត្តថានឹងរក្សាភាពបរិសុទ្ធរបស់អ្នក។ ចូររស់នៅក្នុងអំណរ និង ការស្តាប់ បង្គាប់ព្រះអម្ចាស់។ ចូរថ្វាយបញ្ហាគ្រប់បែបយ៉ាងរបស់អ្នកទៅកាន់ទ្រង់។ ទ្រង់នឹងជួយអ្នកក្នុងគ្រប់ជំហាន ដែលអ្នកឈាន។

ខគម្ពីរខាងក្រោមនេះនឹងជួយអ្នកប្រឈមមុខជាមួយនឹងតម្រូវការផ្លូវភេទ តាមទស្សនៈវិស័យមួយដែលត្រឹមត្រូវ៖

> ខ្ញុំមានសិទ្ធិនឹងធ្វើអ្វីៗទាំងអស់បាន ក៏ប៉ុន្តែ ការទាំងនោះមិនមែនសុទ្ធតែមានប្រយោជន៍ដល់ខ្ញុំទេ។ ខ្ញុំមានសិទ្ធិនឹងធ្វើអ្វីៗទាំងអស់បាន តែខ្ញុំមិនបណ្តោយអោយអ្វីមួយធ្វើជាចៅហ្វាយលើខ្ញុំបានឡើយ។ អ្នកខ្លះពោលថា «ចំណីអាហារសំរាប់ចំអែតក្រពះ ហើយក្រពះសំរាប់ទទួល ចំណីអាហារ»។ ក៏ប៉ុន្តែ ព្រះជាម្ចាស់នឹងរំលាយ ទាំងចំណីអាហារ ទាំងក្រពះចោល។ រីឯរូបកាយវិញ ពុំមែនសំរាប់ប្រព្រឹត្តអំពើប្រាសចាកសីលធម៌ទេ គឺសំរាប់ថ្វាយទៅព្រះអម្ចាស់ ហើយព្រះអង្គក៏ជាម្ចាស់លើរូបកាយដែរ។.....បងប្អូនមិនជ្រាបទេឬថា រូបកាយរបស់បងប្អូន ជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធដែលគង់នៅក្នុងបងប្អូន ជាព្រះវិញ្ញាណដែលបងប្អូនបានទទួលពីព្រះជាម្ចាស់។ បងប្អូនមិនមែនជាម្ចាស់លើខ្លួនឯងទៀតទេ ដ្បិតព្រះអង្គបានបង់ថ្លៃយ៉ាងច្រើនលើសលប់ ដើម្បីលោះបងប្អូន។ ហេតុនេះចូរប្រើរូបកាយរបស់បងប្អូន ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។
>
> (គម្ពីរ១កូរិនថូស ៦:១២-១៣; ១៩-២០)។

ព្រះជាម្ចាស់ *បាន* ប្រទានមធ្យោបាយដើម្បីគ្រប់គ្រងចំណង់ផ្លូវភេទសម្រាប់យើង មិនមែនអនុញ្ញាតឲ្យធ្វើតាមចិត្តនោះទេ។ មធ្យោបាយនោះត្រូវបានគេហៅថា *ការបំលែង* ដែលមានការប្រមូលសម្ភាធខាងផ្លូវភេទនោះឲ្យទៅជាសកម្មភាពដែលសមរម្យ។ *ការបំលែង* ត្រូវបានគេឲ្យនិយមន័យថាជា " ដំណើរការផ្លូវចិត្តដែល ចំណង់ផ្លូវភេទត្រូវបានបំលែងទៅជា កិច្ចការសង្គមដែលអាចទទួលយកបាន ដោយមិនដឹងខ្លួន។" ភាពស្កប់ស្កល់ដ៏ពិតប្រាកដ អាចរកបាននៅក្នុងការធ្វើការ , ការកំសាន្ត, ក្នុងសង្គម និង សកម្មភាពសាសនា។ ថាមពលខាងផ្លូវភេទ អាចប្រមូលផ្តុំដើម្បីជាប្រយោជន៍នៅក្នុងសិល្បៈ ការតែងនិពន្ធ តន្ត្រី កីឡា ការអធិស្ឋាន ការប្រមូលគ្នារៀនព្រះបន្ទូល ការបម្រើ ឬ សកម្មភាពដ៏មានន័យជាច្រើនផ្សេងទៀតដែលជាទីគាប់ចិត្ត និង គំនិតរបស់អ្នក។

យុវជនក៏ត្រូវតែទទួលបានការលើកទឹកចិត្តឲ្យបន្តភាពសកម្មខាងឯរូបកាយ តាមរយៈការហាត់ប្រាណឲ្យបានទៀងទាត់ ការចូលរួមលេងកីឡា និង ជៀសវាងការមិនធ្វើអ្វីសោះ។ ការធ្វើដូច្នេះ នឹងជួយយុវជនគ្រប់គ្រងចំណងផ្លូវភេទរបស់ខ្លួន និង ជួយឲ្យពួកគេរារាំងគំនិតរវើរវាយ និង ការសម្រេចកាមដោយខ្លួនឯង។ ការជៀសឲ្យផុតពីកម្មវិធីទូរទស្សន៍ និង ខ្សែភាពយន្តដែលបង្ហាញយ៉ាងច្បាស់ៗអំពីរឿងទាក់ទងនឹងផ្លូវភេទ ក៏ចាំបាច់ណាស់ដែរ។ ទោះបីគំរូទាំងនេះ ហាក់បីដូចជាពិបាកយ៉ាងណា វាពិតជាមានប្រសិទ្ធិភាព និង អាចជួយបង្កើតឲ្យមានភាពបរិសុទ្ធបាន។

លំហាត់អនុវត្តន៍

---

៣ ចូរប្រាប់ពីមធ្យោបាយពីរយ៉ាងដែលអាចជួយរក្សាភាពបរិសុទ្ធផ្លូវភេទបាន។

.....

យើងក៏ត្រូវដឹងដែរថា ចំណង់ផ្លូវភេទមិនមែនជាអំពើបាបនោះទេ វាគឺផ្នែកមួយនៃរូបកាយរបស់យើង ដែលត្រូវបានបង្កើតឡើយដោយព្រះជាម្ចាស់ ហើយទ្រង់បានប្រទានជាអំណោយសម្រាប់យើង។ ប៉ុន្តែវាត្រូវតែដាក់នៅក្រោមការគ្រប់គ្រងទាំងស្រុង រហូតដល់ពេលដែលរៀបការរួច។ ព្រះអម្ចាស់អាចប្រទាន ហើយទ្រង់ក៏នឹងប្រទានឲ្យមានជីវិតដ៏ពេញបរិបូរណ៌ និង ជោគជ័យ សម្រាប់អស់អ្នកមិនទាន់រៀបការដែលស្វែងរកព្រះរាជ្យ និង ភាពសុចរិតរបស់ទ្រង់ជាមុនសិន (គម្ពីរម៉ាថាយ ៦:៣៣) ។ បើវាជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលឲ្យអ្នកនៅលីវបន្តទៅទៀតមែន ទ្រង់នឹងជួយអ្នកឲ្យគ្រប់គ្រងផ្នែកមួយនេះនៅក្នុងជីវិតរបស់អ្នក ដើម្បីឲ្យអ្នកអាច "ថ្វាយខ្លួនទៅព្រះអង្គ ទុកជាយញ្ញបូជាដ៏មានជីវិត ដ៏វិសុទ្ធ* ហើយជាទីគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់។ បើបងប្អូនធ្វើដូច្នេះ ទើបហៅថាគោរពបំរើព្រះអង្គតាមរបៀបត្រឹមត្រូវមែន។ មិនត្រូវយកតំរាប់តាមនិស្ស័យលោកីយ៍នេះឡើយ ត្រូវទុកអោយព្រះជាម្ចាស់កែប្រែចិត្តគំនិតបងប្អូន អោយទៅជាថ្មីទាំងស្រុងវិញ។" (គម្ពីររ៉ូម ១២:១-២)។

លំហាត់អនុវត្តន៍

---

៤ តើអ្វីខ្លះ ជាបញ្ហាបួនយ៉ាងដែលអ្នកនៅលីវជៀសវាង?

.....

.....

៥ ដោយយោងទៅតាមអ្វីដែលយើងបានពិភាក្សាគ្នា នៅក្នុងចំណុចនេះ ចូរប្រាប់ពីគោលការណ៍ក្នុងព្រះគម្ពីរដែលទាក់ទងនឹងជីវិតផ្លូវភេទ និង ជីវិតនៅលីវ។

.....

.....

.....

លោកសាវ័កប៉ូលបានទទួលស្គាល់ថា អំណោយទាននៃភាពនៅលីវ គឺមិនមែនសម្រាប់មនុស្សគ្រប់គ្នានោះទេ ប៉ុន្តែអ្នកណាដែលមានវា អាចជាព្រះពរដ៏ពិសេសសម្រាប់ព្រះរាជ្យរបស់ព្រះជាម្ចាស់នៅពេលដែលពួកគេថ្វាយខ្លួនរបស់ពួកគេសម្រាប់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និង ដើម្បីបម្រើទ្រង់ដោយគ្មានការរំខានណាមួយឡើយ។

ខ. ជីវិតផ្លូវភេទ និង ជីវិតអាពាហ៍ពិពាហ៍

វត្ថុបំណងទី២. *ស្គាល់ពីគោលការណ៍នៅក្នុងព្រះគម្ពីរដែលទាក់ទងនឹង ជីវិតផ្លូវភេទ និង ជីវិតអាពាហ៍ពិពាហ៍។*

ទំនាក់ទំនងផ្លូវភេទ គឺជារឿងធម្មតា និង គួរតែឲ្យតម្លៃ នៅក្រោយពេលរៀបការរួច។ អ្នកនិពន្ធកណ្ឌគម្ពីរហេប្រឺបានប្រាប់យើងថា៖ "សូមបងប្អូនទាំងអស់គ្នាលើកតម្លៃការរស់នៅជាស្វាមីភរិយា គឺមិនត្រូវក្បត់ចិត្តគ្នាឡើយ ដ្បិតព្រះជាម្ចាស់នឹងវិនិច្ឆ័យទោសអ្នកប្រព្រឹត្តអំពើប្រាសចាកសីលធម៌ និងផិតក្បត់។" (គម្ពីរហេប្រឺ ១៣:៤) ។

លោកសាវ័កប៉ូល ទទួលស្គាល់ឥទ្ធិពលដ៏ខ្លាំងក្លានៃចំណង់ផ្លូវភេទរបស់មនុស្ស ហើយលោកលើកទឹកចិត្តគ្រិស្តបរិស័ទដែលប្រឈមមុខនឹងបញ្ហាក្នុងការគ្រប់គ្រងចំណង់ចិត្តនេះ ឲ្យទៅរៀបការដើម្បីកុំឲ្យពួកគេត្រូវបានល្បួងធ្លាក់នៅក្នុងអំពើបាបបាន (គម្ពីរ១កូរិនថូស ៧:៩)។

តើបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ជាអ្វី ក្នុងការបង្កើតសកម្មភាពផ្លូវភេទឡើង ទុកជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍នោះ?

ប្រាកដណាស់ បំណងព្រះហឫទ័យមួយ *ការបង្កបង្កើត* (ការបង្កើតកូនចៅ)។ ផែនការរបស់ព្រះជាម្ចាស់គឺឲ្យផែនដីបានពេញដោយមនុស្ស ដូចនេះទ្រង់ក៏ប្រទានឲ្យពួកគេចង់មានការរួបរួមគ្នាខាងសាច់ឈាម ដើម្បីបង្កើតកូនចៅ។

សម្រាប់ភាវៈរស់ភាគច្រើន ទំនាក់ទំនងផ្លូវភេទអាចកើតមានឡើងតែនៅក្នុងពេលដែលសត្វញីអាចពោរពោះបានតែប៉ុណ្ណោះ ប៉ុន្តែព្រះជាម្ចាស់បានបង្កើតមនុស្សប្រុស និងមនុស្សស្រីមកដើម្បីឲ្យពួកគេអាចមានចំណង់ផ្លូវភេទទោះបីជាក្នុងអំឡុងពេលដែលស្ត្រីមិនអាចបង្កកំណើតបានក៏ដោយ។ ដូច្នេះទំនាក់ទំនងផ្លូវភេទ គឺមិនត្រូវកំណត់ ត្រឹមគោលបំណងនៃការបង្កើតកូននោះមកក្នុងពិភពលោកនោះឡើយ។ គោលបំណងមួយទៀតរបស់ការរួមរ័កគឺដើម្បី *ការរួបរួម* ។ការរួបរួមនេះ រាប់បញ្ចូលទាំងការទទួលអារម្មណ៍សប្បាយ នៅក្នុងការទាក់ទងស្នេហាខាងឯផ្លូវភេទផងដែរ។ ព្រះជាម្ចាស់បានប្រទានសិទ្ធិឲ្យប្តី និង ប្រពន្ធអាចរីករាយជាមួយនឹងអារម្មណ៍សប្បាយបានជាប្រចាំ។

ព្រះយេស៊ូបានមានព្រះបន្ទូលអំពីការរួបរួមនៅក្នុងគម្ពីរម៉ាថាយ ១៩:៤-៦។ ក្រោយមកទៀតលោកសាវ័កប៉ូលដកស្រង់ពីព្រះបន្ទូលព្រះយេស៊ូ នៅពេលដែលទ្រង់បានប្រើប្រាស់ លក្ខណៈដ៏អាថ៌កំបាំងនៃការរួបរួមនេះ នៅក្នុងចំណងអាពាហ៍ពិពាហ៍ដើម្បីចង្អុលឲ្យឃើញពីទំនាក់ទំនងខាងឯវិញ្ញាណរវាងព្រះយេស៊ូគ្រិស្ត និង ក្រុមជំនុំរបស់ទ្រង់៖

ហេតុនេះហើយបានជាបុរសត្រូវចាកចេញពីឪពុកម្តាយ ទៅរួមរស់ជាមួយភរិយារបស់ខ្លួន ហើយ

អ្នកទាំងពីរនឹងបានទៅជារូបកាយតែមួយ។ គំរោងការដ៏លាក់កំបាំងនេះមានអត្ថន័យជ្រៅ ណាស់ ខ្ញុំនិយាយសេចក្តីនេះ សំដៅលើព្រះគ្រិស្ត និងក្រុមជំនុំតែប៉ុណ្ណោះ។

(គម្ពីរអេភេសូ ៥: ៣១-៣២)

ចំណុចដែលទាក់ទងនឹងការរួបរួមនេះ ត្រូវបានប្រើប្រាស់ជាការទាស់ប្រឆាំងយ៉ាងខ្លាំងក្លា ទៅនឹងអំពើអសីលធម៌ នៅក្នុងគម្ពីរ១កូរិនថូស ៦:១៥។ លោកប៉ូលបានបកស្រាយថា ក្រោយពេលរួមរ័ក ហើយដៃគូទាំងពីរនាក់បានក្លាយជាសាច់តែមួយ ហើយដោយរូបកាយរបស់អ្នកជឿ ជាសរីរាង្គរបស់ព្រះគ្រិស្ត និងជាដំណាក់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ នោះការរួមរ័កដែលខ្វះសីលធម៌គឺជាសញ្ញាអាក្រក់មួយដែលទាស់នឹងព្រះគ្រិស្ត ក៏ដូចជាទាស់និង ព្រះកាយផងដែរ។

លំហាត់អនុវត្តន៍

៦ តើគោលបំណងនៃការរួមរ័កដែលបង្ហាញនៅក្នុងខគម្ពីរខាងក្រោមនេះ មានអ្វីខ្លះ?

ក) គម្ពីរលោកុប្បត្តិ ១:២៨.....

ខ) គម្ពីរលោកុប្បត្តិ ២:២៤.....

ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានប្រទាននូវការណែនាំយ៉ាងច្បាស់ ទាក់ទងទៅនឹងទំនាក់ទំនងផ្លូវភេទនៅក្នុងចំណងអាពាហ៍ពិពាហ៍។ យើងនឹងសង្ខេបការណែនាំទាំងនោះនៅខាងក្រោមនេះ៖

១. *ចំណងអាពាហ៍ពិពាហ៍គឺជាការរួបរួមរវាងបុរសម្នាក់ និង ស្ត្រីម្នាក់។*

ការនេះមានបង្ហាញនៅក្នុងព្រះបន្ទូលរបស់ព្រះយេស៊ូ (គម្ពីរម៉ាថាយ ១៩:៤-៦) ៖

"ព្រះអង្គមានព្រះបន្ទូលតបថា៖ «អ្នករាល់គ្នាធ្លាប់អានគម្ពីររួចមកហើយថា កាលដើមដំបូងព្រះអាទិករ* បានបង្កើតមនុស្សមក ជាបុរស ជាស្ត្រី រួចព្រះអង្គមានព្រះបន្ទូលថា: "ហេតុនេះហើយបានជាបុរសត្រូវចាកចេញពីឪពុកម្តាយ ទៅរួមរស់ជាមួយភរិយារបស់ខ្លួន ហើយអ្នកទាំងពីរត្រឡប់ទៅជារូបកាយតែមួយ" ។ គេមិនមែនជាបុគ្គលពីរនាក់ទៀតទេ គឺជារូបកាយតែមួយវិញ។"

ដូច្នេះ ទំនាក់ទំនងខាងឯផ្លូវភេទ គឺត្រូវបានអនុញ្ញាត ចំពោះតែបុរសម្នាក់ជាមួយនឹងប្រពន្ធម្នាក់របស់គាត់តែប៉ុណ្ណោះ។ នេះគឺជាទំនាក់ទំនងអស់មួយជីវិតនេះ ។ ប្រសិនបើ រវាងពួកគេទាំងពីរមាននរណាម្នាក់មានទំនាក់ទំនងជាមួយមនុស្សម្នាក់ផ្សេងទៀត អ្នកនោះនឹងត្រូវមានទោសបាបនៃអំពើសហាយស្មន់។

២. *ការពឹងពាក់គ្នាទៅវិញទៅមក គឺជាច្បាប់នៃទំនាក់ទំនងផ្លូវភេទនៅក្នុងចំណងអាពាហ៍ពិពាហ៍។* (គម្ពីរ ១កូរិនថូស ៧:៣-៤)។

ទាំងប្តី ទាំងប្រពន្ធ ត្រូវតែគិតពីសេចក្តីត្រូវការរបស់គ្នាទៅវិញទៅមក ជាមួយនឹងក្តីស្រឡាញ់ ការគោរពគ្នាទៅវិញទៅមក និង ការយោគយល់។ លោកប៉ូលបានមានប្រសាសន៍យ៉ាងច្បាស់ៗថា ប្រពន្ធមិនមែនជាម្ចាស់លើរូបកាយរបស់នាងទេ តែគឺប្តីឯណោះវិញដែលជាម្ចាស់។ នៅក្នុងរបៀបដូចគ្នានេះដែរ ប្តីក៏មិនមែនជាម្ចាស់លើរូបកាយរបស់គាត់ដែរ ប៉ុន្តែប្រពន្ធនោះទេដែលជាម្ចាស់។ ដូច្នេះ" បងប្អូនដែលកោតខ្លាចព្រះគ្រិស្ត ត្រូវគោរពចុះចូលគ្នាទៅវិញទៅមក។" (គម្ពីរអេភេសូ ៥:២១)។

នៅក្នុងគម្ពីរអេភេសូជំពូក៥ ព្រះវិញ្ញាណដ៏វិសុទ្ធបង្គាប់ឲ្យលោកប៉ូល គិតពីការចុះចូល និង ក្តីស្រឡាញ់រវាងព្រះគ្រិស្ត និង ក្រុមជំនុំដោយប្រើគំរូ ដែលបានមកពីចំណងអាពាហ៍ពិពាហ៍ដ៏ផ្អែមល្ហែមមួយ។

បងប្អូនជាស្ត្រីដែលមានស្វាមី ត្រូវគោរពចុះចូលនឹងស្វាមីរៀងៗខ្លួន ដូចជាគោរពចុះចូលនឹងព្រះអម្ចាស់ដែរ ... ហេតុនេះ ក្រុមជំនុំគោរពចុះចូលនឹងព្រះគ្រិស្ត យ៉ាងណា ភរិយាក៏ត្រូវគោរពចុះ

ចូលនឹងស្វាមីរៀងៗខ្លួន ក្នុងគ្រប់កិច្ចការទាំងអស់យ៉ាងនោះដែរ។ ចំពោះបងប្អូនដែលមានប្រពន្ធវិញ ចូរស្រឡាញ់ភរិយា ដូចព្រះគ្រិស្តបានស្រឡាញ់ក្រុមជំនុំដែរ ព្រះអង្គបូជាព្រះជន្មរបស់ព្រះអង្គផ្ទាល់ សំរាប់ក្រុមជំនុំ.... អ្នកណាស្រឡាញ់ភរិយា អ្នកនោះស្រឡាញ់ខ្លួនឯង។....ទោះជាយ៉ាងណាក៏ដោយ បងប្អូនម្នាក់ៗត្រូវស្រឡាញ់ភរិយារៀងៗខ្លួន ដូចស្រឡាញ់ខ្លួនឯងហើយ ភរិយាក៏ត្រូវគោរពស្វាមីរបស់ខ្លួនដែរ។ (គម្ពីរអេភេសូ ៥:២២-២៥, ២៨, ៣៣)

បទគម្ពីរនេះ រៀបរាប់ពីគំនិតនៃ*ការពឹងពាក់គ្នាទៅវិញទៅមក* បានយ៉ាងល្អ។ នៅពេលដែលប្រពន្ធចុះចូលជាមួយប្តីរបស់នាង រាប់បញ្ចូលទាំងការរួមរ័កផង នោះប្តីរបស់នាងអាចនឹងឆ្លើយតបទៅវិញដោយការបង្ហាញក្តីស្រឡាញ់បានច្រើនជាង នៅពេលដែលនាងបដិសេធសិទ្ធិរបស់គាត់មួយនេះ។ តាមរបៀបដូចគ្នានេះដែរ ប្តីដែលបង្ហាញក្តីស្រឡាញ់ នៅក្នុងគ្រប់សកម្មភាពដែលគាត់ធ្វើទៅចំពោះប្រពន្ធរបស់គាត់ គឺអាចទទួលបានការឆ្លើយតបដោយទទួលបានការចុះចូលរបស់ប្រពន្ធទៅនឹងចំណង់របស់គាត់។ អ្នកទាំងពីរត្រូវបំពេញតម្រូវការរបស់គ្នាទៅវិញទៅមក ដោយស្មគ្រចិត្ត។

៣. *ប្តីប្រពន្ធមិនត្រូវតែមការរួមភេទនោះទេ លុះត្រាតែមានការព្រមព្រៀងគ្នាទៅវិញទៅមក។*

ការព្រមព្រៀងនោះ គួរតែក្នុងមួយរយៈពេលខ្លីតែប៉ុណ្ណោះ ហើយក្នុងគោលបំណងសម្រាប់ការធ្វើការអធិស្ឋានតែប៉ុណ្ណោះ (គម្ពីរ១កូរិនថូស ៧:៥)។

ប្រហែលជាមានមូលហេតុដែលសមរម្យ សម្រាប់រយៈពេលដែលគ្មានការរួមរស់ជាមួយគ្នានេះ ដូចជាការត្រូវការធ្វើដំណើរទៅឆ្ងាយដើម្បីធ្វើជំនួញ និង មានជំងឺធ្ងន់ធ្ងរ។ ទោះជាយ៉ាងណាក៏ដោយ ការតមិនរួមរស់ជាមួយគ្នា នៅក្នុងចំណងអាពាហ៍ពិពាហ៍មិនត្រូវធ្វើឡើយបើគ្មានមូលហេតុសមរម្យ និង ដោយគ្មានការព្រមព្រៀងគ្នាទៅវិញទៅមក។

លំហាត់អនុវត្តន៍

---

៧ តើលោកប៉ូលបានព្រមានយ៉ាងដូចម្តេចទាក់ទងនឹងរឿងនេះ (គម្ពីរ១កូរិនថូស ៧:៥)?

.....

---

៤. *ទំនាក់ទំនងផ្លូវភេទ រក្សាការពារចំណងអាពាហ៍ពិពាហ៍។*

ខ្ញុំចង់ដឹងណាស់ថា តើដៃគូប្តីប្រពន្ធមួយគូបានប្រព្រឹត្តអំពើសហាយស្មន់ប៉ុន្មានដង ដោយសារតែដៃគូរបស់គេមិនបានឆ្លើយទៅនឹងតម្រូវការផ្លូវភេទរបស់គេបាន។ ការរួមរ័កជាប្រចាំនៅក្នុងជីវិតអាពាហ៍ពិពាហ៍ អាចការពារអ្នកដៃគូដែលបានរៀបការហើយនោះ មិនបណ្តោយខ្លួនឲ្យធ្លាក់ទៅក្នុងការល្បួងរបស់អារ៉ក្សសាតាំង ដែលចង់ឲ្យងាកទៅរកកន្លែងផ្សេងទៀតដើម្បីបំពេញចំណង់ ដោយសារដែលគេខ្វះនូវការគ្រប់គ្រងខ្លួនឯង ឬ ដោយសារតែចិត្តល្វីងជូរចត់នៅក្នុងគ្រួសារ។

ការរួបរួមផ្នែករូបកាយរវាងប្តី និង ប្រពន្ធដែលស្រឡាញ់ និង គោរពគ្នាទៅវិញទៅមកអាចផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ចំណងអាពាហ៍ពិពាហ៍ដ៏រឹងមាំ និង ការរួបរួមយ៉ាងរឹងមាំនៅក្នុងគ្រួសារ។ ក្តីស្រឡាញ់ និង ការថ្នាក់ថ្នម របស់ឪពុកម្តាយទៅចំពោះគ្នាទៅវិញទៅមក នឹងបានទៅដល់កូនរបស់ពួកគេ ដែលនឹងឆ្លើយតបមកវិញដោយក្តីស្រឡាញ់ និង ការថ្នាក់ថ្នមដូចគ្នាដែរ។

លំហាត់អនុវត្តន៍

---

៨ តើប្រយោគណាខ្លះនៅខាងក្រោមនេះ ដែលស្របតាមគោលការណ៍នៅក្នុងព្រះគម្ពីរ ទាក់ទងទៅនឹងជីវិតផ្លូវភេទ និង ជីវិតអាពាហ៍ពិពាហ៍?។

ក) គោលបំណងដ៏ពិតមួយសម្រាប់ការរួមរ័កគឺការបង្កើតកូនចៅ។

ខ) ចំណងអាពាហ៍ពិពាហ៍គឺជាទំនាក់ទំនងអស់មួយជីវិតរវាងបុរសម្នាក់ និង ស្ត្រីម្នាក់។

គ) ដៃគូប្តីប្រពន្ធគួរតែតមការរួមរស់នៅជាមួយគ្នា តែនៅពេលដែលមានការព្រមព្រៀងគ្នាទៅវិញទៅមកក្នុងរយៈពេលខ្លីមួយតែប៉ុណ្ណោះ។

ឃ) ការចុះចូល និង ក្តីស្រឡាញ់ គឺជាផ្នែកមួយដ៏សំខាន់ នៃការពឹងពាក់គ្នាទៅវិញទៅមកនៅក្នុងចំណងអាពាហ៍ពិពាហ៍មួយ។

ង) ការរួមរ័កផ្តល់នូវការរួបរួមនៅក្នុងចំណងអាពាហ៍ពិពាហ៍ នៅពេលដែលមនុស្សពីរនាក់ក្លាយជាសាច់ឈាមតែមួយ។

ច) ប្តីម្នាក់ និង ប្រពន្ធម្នាក់អាចការពារចំណងអាពាហ៍ពិពាហ៍របស់ពួកគេតាមរយៈការបំពេញបម្រើការផ្លូវភេទសម្រាប់គ្នាទៅវិញទៅមក។

ឆ) ប្រសិនបើប្តីមិនបង្ហាញក្តីស្រឡាញ់ទៅកាន់ប្រពន្ធរបស់គាត់នោះទេ នាងមិនត្រូវបានតម្រូវឲ្យចុះ ចូលជាមួយគាត់ទៀតទេ។

គ. សកម្មភាពផ្លូវភេទត្រូវបានហាមឃាត់

វគ្គបំណងទី៣. *ផ្តល់មូលហេតុដែលគ្រិស្តបរិស័ទត្រូវ រារាំងមិនឲ្យធ្វើសកម្មភាពផ្លូវភេទព្រះគម្ពីរបានហាតឃាត់។*

ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យចំពោះអំពើអសីលធម៌នោះទេ។ ទ្រង់បានប្រទានសេចក្តីណែនាំយ៉ាងច្បាស់ នៅក្នុងព្រះបន្ទូលរបស់ទ្រង់ ទាក់ទងទៅនឹង អ្វីដែលអាចអនុញ្ញាតបាន និង អ្វីដែលមិនអាចអនុញ្ញាតឲ្យធ្វើបាន។ នៅក្នុងសម័យគម្ពីរសម្ពន្ធមេត្រីចាស់ អំពើអសីលធម៌ខាងផ្លូវភេទ ក្នុងចំណោមជនជាតិអ៊ីស្រាអែល គឺត្រូវដាក់ទោសប្រហារជីវិតសម្រាប់អ្នកណាដែលប្រព្រឹត្តវា។

លំហាត់អនុវត្តន៍

៩ សូមអានគម្ពីរលេវីវិន័យ ២០:១០-២១ និង គម្ពីរ១កូរិនថូស ៦:១២-៧: ៤០។ បទគម្ពីរទាំងនេះបង្ហាញយ៉ាងច្បាស់ថា ព្រះជាម្ចាស់អនុញ្ញាតឲ្យមានទំនាក់ទំនងផ្លូវភេទ រវាង..... ប៉ុណ្ណោះ។

ក) មិត្តភក្តិជិតស្និទ្ធ។

ខ) សមាជិកគ្រួសារ។

គ) ប្តី និង ប្រពន្ធ។

គម្ពីរលេវីវិន័យជំពូក២០ ក៏បង្ហាញយ៉ាងច្បាស់ថា ប្តី និង ប្រពន្ធមិនត្រូវជាបងប្អូនជាប់សាច់ឈាមតែមួយនោះទេ។ ទំនាក់ទំនងផ្លូវភេទរវាងបងប្អូនជាប់សាច់ឈាម គឺត្រូវបានគេហៅថា *ស្មន្ធការ* ហើយវាត្រូវបានហាមឃាត់យ៉ាងដាច់ខាត នៅក្នុងបទគម្ពីរ។ វាក៏ត្រូវបានហាមឃាត់ពីសំណាក់អ្នកវិទ្យាសាស្ត្រជាច្រើននៅក្នុងពិភពលោកផងដែរ។

មានទង្វើបីយ៉ាងមិនត្រូវបានអនុញ្ញាតឲ្យធ្វើ ដែលជាបញ្ហាដ៏ធំក្នុងពេលបច្ចុប្បន្ននេះ ហើយយើងនឹងពិភាក្សានៅក្នុងមេរៀននេះ។ ទង្វើទាំងនោះមានដូចជា *អំពើសហាយស្មន់ ការរួមភេទមុនពេលរៀបការ* និង *ការរួមសង្វាសភេទដូចគ្នា*។ គ្រិស្តបរិស័ទត្រូវតែប្រុងប្រយ័ត្នអំពីភាពគ្រោះថ្នាក់នៃសេចក្តីល្បួងនៅក្នុងផ្នែកទាំងនេះ ដើម្បីឲ្យពួកគេអាចគ្រប់គ្រងខ្លួនឯង ឬ ជួយអ្នកដទៃដែលអាចជាប់ទាក់ទងនៅក្នុងអំពើអសីលធម៌បែបនេះ។

អំពើសហាយស្មន់

អំពើសហាយស្មន់គឺជាទំនាក់ទំនងផ្លូវភេទ រវាងបុគ្គលដែលបានរៀបការម្នាក់ជាមួយនឹងម្នាក់ផ្សេងទៀតដែលនៅក្រៅចំណងអាពាហ៍ពិពាហ៍នោះ។ វាអាចជាទំនាក់ទំនងផ្លូវភេទរវាង បុរសដែលបានរៀបការជាមួយនឹងស្ត្រីដែលបានរៀបការម្នាក់ទៀតដែលមិនមែនជាប្រពន្ធរបស់គាត់ ឬ រវាងបុគ្គលដែលបានរៀបការ ជាមួយនឹងបុគ្គលដែលមិនបានរៀបការ។ វាក៏អាចហៅថា ការរួមរ័កនៅក្រៅអាពាហ៍ពិពាហ៍។

ក្រឹត្យវិន័យមួយនៅក្នុងចំណោមក្រឹត្យវិន័យទាំងដប់ប្រការ បានថ្លែងយ៉ាងដូច្នេះថា៖ "កុំប្រព្រឹត្តអំពើផិតក្បត់។" (គម្ពីរនិក្ខមនំ ២០:១៤) ។ ក្រឹត្យវិន័យនេះបានបង្ហាញម្តងហើយម្តងទៀតនៅក្នុងព្រះគម្ពីរ។ (សូមមើលគម្ពីរម៉ាថាយ ៥:២៧-២៨; ១៩:៩; គម្ពីររ៉ូម១៣:៩; គម្ពីរ១កូរិនថូស ៦:៩-១០)។

លំហាត់អនុវត្តន៍

១០ សូមអានគម្ពីរសុភាសិត ៦:៣២ ។ តើខគម្ពីរនេះបាននិយាយយ៉ាងដូចម្តេចអំពីបុរសដែលប្រព្រឹត្តអំពើសហាយស្មន់នេះ?

.....

១១ តើលោកប៉ូលបានផ្តល់មូលហេតុអ្វីនៅក្នុងគម្ពីរ១កូរិនថូស ៦:១៨-២០ សម្រាប់ការជៀសវាងអំពើប្រោសចាកសីលធម៌ ដែលរួមទាំងអំពើសហាយស្មន់ផងនោះ?

.....

ព្រះបន្ទូលរបស់ព្រះយេស៊ូនៅក្នុងគម្ពីរម៉ាថាយ ៥:២៧-២៨ គឺជាការព្រមានមកដល់យើងរាល់គ្នា ដើម្បីឲ្យគ្រប់គ្រងគំនិតរបស់យើងយ៉ាងប្រុងប្រយ័ត្ន និង ជៀសវាងកាលៈទេសៈដែលអាចនាំយើងឲ្យធ្លាក់ទៅក្នុងសេចក្តីល្បួងនៅក្នុងផ្នែកមួយនេះនៃជីវិតរបស់យើង។ ទ្រង់បានមានព្រះបន្ទូលថា ៖ "ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា អ្នកណាមើលស្ត្រីម្នាក់ ហើយមានចិត្តស្រើបស្រាលចង់រួមបវេណីជាមួយនាង អ្នកនោះដូចជាបានប្រព្រឹត្តអំពើផិតក្បត់ជាមួយនាង នៅក្នុងចិត្តរបស់ខ្លួន រួចស្រេចទៅហើយ។" អំពើសហាយស្មន់ជាច្រើនកើតឡើងពីពាក្យសំដី ឬ អាកប្បកិរិយាមិនប្រុងប្រយ័ត្នដែលអាចមើលទៅដូចជាត្រឹមត្រូវណាស់ពីដំបូង ប៉ុន្តែវានឹងវិវត្តន៍ទៅដល់ចំណុចមួយដែលមានការល្បួងកើតមានឡើង។ ព្រះគម្ពីរបានប្រាប់យើងឲ្យ*រត់*ដើម្បីគេចឲ្យផុតយ៉ាងរហ័សបំផុតពីការល្បួងទាំងនេះ (គម្ពីរ១កូរិនថូស ៦:១៨)។ ការត្រៀមខ្លួនខាងឯវិញ្ញាណជាប្រចាំនឹងជួយអ្នកគ្រប់គ្រងខ្លួនអ្នកតាមរបៀបដូចជាគ្រិស្តបរិស័ទ នៅក្នុងគ្រប់ទំនាក់ទំនងរបស់អ្នកជាមួយនឹងសមាជិកឯទៀតៗដែលមានភេទផ្ទុយគ្នា។ (យើងបានពិភាក្សាអំពីការរៀបចំវិញ្ញាណនៅក្នុងមេរៀនទី៣)។

ខ្ញុំស្គាល់បុរសម្នាក់ដែលជាអ្នកដឹកនាំខាងឯវិញ្ញាណដ៏រឹងមាំម្នាក់នៅក្នុងក្រុមជំនុំរបស់គាត់។ គាត់មានចិត្ត អាណិតអាសូរដល់ស្ត្រីមេម៉ាយម្នាក់ដែលមានកូនតូចៗពីរនាក់ ហើយតែងតែយកអាហារឲ្យនាង ឬ ជួយធ្វើការជួសជុលផ្សេងនៅក្នុងផ្ទះរបស់នាងនៅពេលដែលនាងត្រូវការ។ នេះបាននាំឲ្យពួកគេបានស្គាល់គ្នាយ៉ាងជិតស្និទ្ធ ហើយទំនាក់ទំនងស្នេហាក៏កើតមានឡើងម្តងបន្តិចៗ រហូតដល់ពេលមួយពួកគេបានធ្លាក់ចូលទៅក្នុងសេចក្តីល្បួង។ បន្ទាល់របស់បុរសម្នាក់នោះត្រូវបានបំផ្លាញ ទាំងគាត់ និង ស្ត្រីម្នាក់នោះក៏មានភាពអាម៉ាស់នៅក្នុងភ្នែករបស់គ្រួសារ និង មិត្តភក្តិរបស់ពួកគេទាំងពីរ ហើយពួកគាត់ទាំងពីរនាក់ទទួលការឈឺចាប់យ៉ាងខ្លាំង។ ទោះបីជា ពួកគេបានលន់តួ និង បានឈប់ជួបគ្នាទៀតក៏ដោយ ក៏សេចក្តីខ្ជិចខ្ជាំយ៉ាងធំធេងបានកើតមានឡើងនៅក្នុងជីវិតរបស់ពួកគេ និង ជីវិតរបស់អ្នកដទៃរួចស្រេចទៅហើយ។ ការចាប់ផ្តើមមួយដែលជាព័ន្ធកិច្ចខាងឯវិញ្ញាណ បានត្រូវបញ្ចប់ជាមួយនឹងគ្រោះមហន្តរាយ។

លំហាត់អនុវត្តន៍

១២ សូមមើលទៅសំណួរទី១០ និង ទី១១ ម្តងទៀត។ ចូរផ្សារភ្ជាប់សំណួរទាំងពីរនេះ ទៅនឹងស្ថានភាពដែលបានរៀបរាប់នៅក្នុងកថាខណ្ឌខាងលើ។

.....

.....

ការរួមភេទមុនពេលរៀបការ

ការរួមភេទមុនពេលរៀបការ ដែលរាប់បញ្ចូលទំនាក់ទំនងផ្លូវភេទផ្សេងទៀតដែលក្រៅពីរវាងប្តី និងប្រពន្ធ ហើយវាក៏សំដៅទៅលើទំនាក់ទំនងផ្លូវភេទរវាងមនុស្សមិនទាន់រៀបការផងដែរ។ យើងទើបតែបានពិភាក្សាអំពីរឿងនេះ នៅក្នុងមេរៀននៅពេលដែលយើងនិយាយអំពីភាពបរិសុទ្ធរួចមកហើយ។ទំនាក់ទំនងផ្លូវភេទរវាងអ្នកមិនទាន់រៀបការ គឺសំដៅទៅលើ*ការរួមរ័ក្គាមុនពេលរៀបការ* ។

លំហាត់អនុវត្តន៍

---

១៣ តើអ្វីខ្លះ ជាមូលហេតុទាំងបួនយ៉ាងដែលយើងបានផ្តល់ឲ្យសម្រាប់ការរារាំងមិនឲ្យមានការរួមភេទមុនពេលរៀបការ (ឬ ដើម្បីរក្សាភាពបរិសុទ្ធ)?

.....

.....

១៤ ចូរអានគម្ពីរ១កូរិនថូស ៧:២,៨-៩ ។ តើអ្នកដែលមិនទាន់រៀបការត្រូវធ្វើអ្វីខ្លះ ប្រសិនបើពួកគេត្រូវបានល្បួងឲ្យមានទំនាក់ទំនងផ្លូវភេទ?

.....

.....

លោកសាវ័កប៉ូលបានសរុបសេចក្តីនៃគម្ពីរ១កូរិនថូសជំពូក៦ ជាមួយនឹងឃ្លាដូចតទៅនេះ៖ "បងប្អូនមិនមែនជាម្ចាស់លើខ្លួនឯងទៀតទេ ដ្បិតព្រះអង្គបានបង់ថ្លៃយ៉ាងច្រើនលើសលប់ ដើម្បីលោះបងប្អូន។ ហេតុនេះចូរប្រើរូបកាយរបស់បងប្អូន ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ (ខ ១៩ - ២០)។ រូបកាយដែលពេញដោយបាបមិនបានលើកព្រះកិត្តិនាម និង សិរីរុងរឿងដល់ព្រះជាម្ចាស់នោះឡើយ។ អ្នកលើកព្រះកិត្តិនាមទ្រង់ដោយ ការរក្សាខ្លួនរបស់អ្នកឲ្យបរិសុទ្ធ ដោយមិនជាប់ទាក់ទងនឹងអំពើបាបខាងផ្លូវភេទនោះឡើយ។ អ្នកលើកព្រះកិត្តិនាមរបស់ព្រះគ្រិស្ត ដែលបានបង់ថ្លៃលះទោសដើម្បីសង្គ្រោះអ្នក ដោយព្រះកាយរបស់ទ្រង់ តាមរយៈការរងទុក្ខ និង ការសុគត។

លំហាត់អនុវត្តន៍

---

១៥ តើមូលហេតុអ្វីដែលសំខាន់ជាងគេ ក្នុងការរក្សាខ្លួនអ្នកឲ្យនៅបរិសុទ្ធ?

.....

ការរួមសង្វាសភេទដូចគ្នា

វត្ថុបំណងទី៤. *បកស្រាយពីរបៀបដែលយើងដឹងថា ការរួមសង្វាសភេទដូចគ្នា គឺជាសកម្មភាពដែលពេញដោយបាប។*

នៅផ្នែកខ្លះនៃពិភពលោក ការរួមសង្វាសភេទដូចគ្នា (ទំនាក់ទំនងផ្លូវភេទរវាងមនុស្សពីរនាក់ដែលមានភេទដូចគ្នា) គឺត្រូវបានគេផ្សព្វផ្សាយយ៉ាងបើកចំហថាជា "ជម្រើស" មួយនៃជីវិតរស់នៅ។ ប៉ុន្តែនៅក្នុងព្រះគម្ពីរ បានប្រកាសឡើងយ៉ាងច្បាស់ៗថា ការរួមសង្វាសភេទដូចគ្នាគឺជាអំពើបាប។

១. *វាគឺជាអំពើបាប ព្រោះវាផ្ទុយពីគោលការណ៍នៃជីវិតផ្លូវភេទដែលព្រះជាម្ចាស់បានបង្កើតឡើង។* ជីវិតផ្លូវភេទរបស់មនុស្សត្រូវបានរៀបចំឡើងនៅក្នុងស្មាព្រះហស្តរបស់ព្រះជាម្ចាស់ ដើម្បីឲ្យមាន តែប្តីមួយប្រពន្ធមួយ និងសម្រាប់ភេទផ្ទុយគ្នា (បុរសម្នាក់ ជាមួយនឹងនារីម្នាក់)។ នៅពេលដែលមនុស្សជ្រើសយកការរួមសង្វាសភេទដូចគ្នា ពួកគេបានច្រានចោល គោលការណ៍នៃជីវិតផ្លូវភេទដែលព្រះជាម្ចាស់បានបង្កើតឡើងហើយ។ គម្ពីររ៉ូម ១:១៨-៣២ បកស្រាយអំពីរបៀបដែលរឿងនេះកើតមានឡើង៖ ពួកគេធ្វើអំពើដ៏គួរឲ្យអាម៉ាស់ ហើយផ្លាស់ប្តូរសេចក្តីពិតរបស់ព្រះជាម្ចាស់ជាមួយនឹងការកុហក ដូច្នេះព្រះជាម្ចាស់បានបណ្តោយគេទៅតាមចំណង់ដ៏គួរឲ្យអាម៉ាស់របស់គេទៅ។ គម្ពីររ៉ូម១:២៨ បានចែងថា៖ "ដោយពួកគេយល់ថា មិនបាច់ស្គាល់ព្រះជាម្ចាស់យ៉ាងច្បាស់ ព្រះអង្គក៏បណ្តោយគេទៅតាមគំនិតឥតពិចារណារបស់ខ្លួន គឺអោយគេប្រព្រឹត្តអំពើដែលមិនត្រូវប្រព្រឹត្ត។"

២. *វាគឺជាអំពើបាប ព្រោះព្រះគម្ពីរបានចាត់ទុកវាថា ជាអំពើអាក្រក់។* "សូមបងប្អូនកុំយល់ច្រឡំអោយសោះ អស់អ្នកដែលប្រព្រឹត្តអំពើប្រាសចាកសីលធម៌ ពួកថ្វាយបង្គំព្រះក្លែងក្លាយ ពួកមានសហាយស្មន់ ពួកជនពាលពួកអ្នករួមសង្វាសនឹងភេទដូចគ្នា ... ពុំអាចទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់ទុកជាមត៌កបានឡើយ។ (គម្ពីរ១កូរិនថូស ៦:៩-១០)។
(សូមមើលគម្ពីរលេវីវិន័យ ១៨:២២-២៣ និង គម្ពីររ៉ូម ១:២១-២៧)។

៣. *វាគឺជាអំពើបាប ដែលត្រូវទទួលការកាត់ទោសដ៏វិសុទ្ធ។* "ព្រះជាម្ចាស់សំដែងព្រះពិរោធពីស្ថានបរមសុខ*មក ប្រឆាំងនឹងការមិនគោរពប្រណិប័តន៍ ព្រះអង្គប្រឆាំងនឹងអំពើទុច្ចរិតគ្រប់យ៉ាងដែលមនុស្សលោកប្រព្រឹត្ត ទាំងយកអំពើទុច្ចរិតនោះខ្ទប់សេចក្តីពិតមិនអោយលេចចេញមក" (គម្ពីររ៉ូម ១:១៨)។ (សូមមើលគម្ពីរលោកុប្បត្តិ ១៩:៤-១១)។ គម្ពីរលោកុប្បត្តិជំពូក១៩ រៀបរាប់អំពីការវិនិច្ឆ័យដ៏ធ្ងន់ធ្ងររបស់ព្រះជាម្ចាស់ ទៅលើក្រុងសូដុម ជាកន្លែងដែលអំពើបាបនៃការរួមសង្វាសភេទដូចគ្នា រាលដាលពាសពេញ។ (សូមមើលនៅក្នុងគម្ពីរ២ពេត្រុស ២:៦ និង គម្ពីរយូដាស ជំពូក៧)។

នេះមិនមែនជាស្ថានភាពដែលគួរឲ្យអស់ក្តីសង្ឃឹមនោះទេ។ អំពើបាបនៃការរួមសង្វាសភេទដូចគ្នាអាចលាងសំអាត និង លើកលែងទោសឲ្យបាន។ នៅក្នុងក្រុមជំនុំនៃក្រុងកូរិនថូស មានអ្នកដែលធ្លាប់រួមសង្វាសភេទដូចគ្នាពីមុន បានទទួលការប្រោសលោះឲ្យផុតពីចំណងនៃបាប តាមរយៈព្រះលោហិតរបស់

ព្រះយេស៊ូគ្រិស្ត។ នៅក្នុងគម្ពីរ១កូរិនថូស ៦:៩ លោកប៉ូលបានរាប់អ្នកដែលរួមសង្វាសភេទដូចគ្នា ទៅក្នុងចំណោមអស់អ្នកដែលមិនអាចទទួលស្នង ឬទទួលបានព្រះរាជ្យរបស់
ព្រះជាម្ចាស់បាន ប៉ុន្តែនៅក្នុងខទី១១ លោកបានមានប្រសាសន៍ថា៖ "កាលពីដើម បងប្អូនខ្លះក៏ជាមនុស្សប្រភេទនោះដែរ។ ប៉ុន្តែ ព្រះជាម្ចាស់លាងសំអាតបងប្អូន ប្រោសប្រទានអោយបងប្អូនបានវិសុទ្ធ ព្រមទាំងអោយបងប្អូនបានសុចរិត* ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រិស្ត* តាមរយៈព្រះវិញ្ញាណនៃ
ព្រះជាម្ចាស់របស់យើងរួចស្រេចហើយ។"

លំហាត់អនុវត្តន៍

---

១៦ ចូរបំពេញប្រយោគមួយនេះ៖ យើងដឹងថាការរួមសង្វាសភេទដូចគ្នាគឺជាអំពើបាប ព្រោះ

.....

.....

១៧ តើអ្នកនឹងឆ្លើយយ៉ាងដូចម្តេច នៅពេលដែលមានមនុស្សម្នាក់មកប្រាប់អ្នកថា៖ "ខ្ញុំជាមនុស្សដែលរួមសង្វាសជាមួយមនុស្សភេទដូចគ្នា ព្រោះតែព្រះជាម្ចាស់បានបង្កើតខ្ញុំមកយ៉ាងនេះ។ ខ្ញុំមិនអាចផ្លាស់ប្រែបាននោះទេ"?

.....

.....

ឃ. ប្រឈមមុខជាមួយនឹងបញ្ហាខាងផ្លូវភេទ

វត្ថុបំណងទី៥. *ស្វែងរកឥរិយាបថពីក្នុងបទគម្ពីរដែលនឹងផ្តល់នូវដំណោះស្រាយសម្រាប់បញ្ហានៅក្នុងជីវិតផ្លូវភេទ។*

យើងប្រហែលជាមិនអាចបកស្រាយអំពីបញ្ហាខាងឯផ្លូវភេទគ្រប់ប្រភេទ និង របៀបសម្រាប់ដោះស្រាយបញ្ហានីមួយៗនៅក្នុងមេរៀនដ៏ខ្លីនេះបានឡើយ។ បញ្ហាខាងឯផ្លូវភេទខ្លះជាបញ្ហាខាងឯរូបកាយពីធម្មជាតិមក ដែលត្រូវការជំនួយពីគ្រូពេទ្យ។ ប៉ុន្តែជាច្រើនផ្សេងទៀតគឺជាបញ្ហានៃអំពើបាបនោះតែម្តង ហើយដំណោះស្រាយសម្រាប់បញ្ហាទាំងនោះគឺ *ការលន់តួ* និង *ការផ្លាស់ប្រែជីវិតជាថ្មី*។

ព្រះជាម្ចាស់អត់ទោស

នៅពេលប្រឈមមុខជាមួយអ្នកដែលបានជាប់ទាក់ទងជាមួយអំពើបាបខាងផ្លូវភេទហើយ គឺមានសារដ៏សំខាន់មួយសម្រាប់ចែកចាយជាមួយពួកគេ ៖ ព្រះជាម្ចាស់អត់ទោស។

លំហាត់អនុវត្តន៍

១៨ សូមអានគម្ពីរយ៉ូហាន ៨:៣-១១ ហើយឆ្លើយនឹងសំណួរទាំងប៉ុន្មាននេះ។

ក) ហេតុអ្វីបានជាគេនាំស្ត្រីម្នាក់នោះមកគាល់ព្រះយេស៊ូ?

.....

ខ) តើបណ្តាជនចង់ធ្វើអ្វីទៅលើនាង?

.....

គ) តើព្រះយេស៊ូមានឥរិយាបថយ៉ាងដូចម្តេច? .....

ឃ) តើទ្រង់បានមានព្រះបន្ទូលយ៉ាងដូចម្តេចទៅកាន់ស្ត្រីម្នាក់នោះ?

.....

១៩ ឥឡូវនេះសូមអានគម្ពីរលូកា ៧:៣៦-៥០។ តើព្រះយេស៊ូឆ្លើយតបយ៉ាងដូចម្តេចទៅកាន់ វិញ្ញាណនៃការលន់តួ និង ជំនឿរបស់ស្ត្រីម្នាក់នោះ?

.....

មិនថាមនុស្សបានវាយតម្លៃអ្នកយ៉ាងណា មិនថាលទ្ធផលនៃអំពើបាបរបស់អ្នកធ្ងន់ធ្ងរយ៉ាងណា នៅក្នុងព្រះគ្រិស្តតែងតែមានការអត់ទោសជានិច្ច។ ទ្រង់នឹងមិនត្រឹមតែអត់ទោសបាបរបស់អ្នកនោះទេ ប៉ុន្តែទ្រង់នឹងជួយអ្នកឲ្យទទួលបានជីវិតដែលបានផ្លាស់ប្រែជាថ្មីផងដែរ!

គំនិតដែលបានផ្លាស់ប្រែជាថ្មី

អស់អ្នកដែលបានប្រព្រឹត្តអំពើបាបខាងឯផ្លូវភេទ គេអាចប្រាកដនៅក្នុងចិត្តបានថា ព្រះជាម្ចាស់មិនត្រឹមតែអត់ទោសឲ្យពួកគេ នៅពេលដែលពួកគេសារភាពបាបរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ទទួលបានគំនិតដែលបានផ្លាស់ប្រែជាថ្មី នៅពេលដែលពួកគេចុះចូលជាមួយបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ផងដែរ។ ពួកគេមិនស្ថិតនៅក្រោមការកាត់ទោស ដោយសារតែអំពើបាបរបស់ពួកគេទៀតទេ ព្រោះពួកគេត្រូវបានរំដោះឲ្យរួចផុតពីអំពើបាបនោះរួចទៅហើយ។ ខាងក្រោមនេះគឺជាអ្វីដែលព្រះគម្ពីរបានចែង៖

> ឥឡូវនេះ អស់អ្នកដែលចូលរួមជាមួយព្រះគ្រិស្តយេស៊ូ ឥតមានទោសពៃរ៍ទៀតឡើយ ដ្បិតវិន័យរបស់ព្រះវិញ្ញាណដែលផ្តល់ជីវិតក្នុងអង្គព្រះគ្រិស្តយេស៊ូ បានរំដោះខ្ញុំអោយរួចផុតពីបាប និងពីសេចក្តីស្លាប់....ដ្បិតអ្នកដែលរស់នៅតាមនិស្ស័យលោកីយ៍ គិតតែពីអ្វីៗដែលទាក់ទងនឹងលោកីយ៍ រីឯអ្នកដែលរស់នៅតាមព្រះវិញ្ញាណ គិតតែពីអ្វីៗដែលទាក់ទងនឹងព្រះវិញ្ញាណ។ ការគិតខាងលោកីយ៍នាំអោយស្លាប់ រីឯការគិតខាងព្រះវិញ្ញាណនាំអោយមានជីវិត និងសេចក្តីសុខសាន្តវិញ។ (គម្ពីររ៉ូម ៨:១-២, ៥-៦)

បញ្ហាដែលទាក់ទងនឹងរឿងផ្លូវភេទនៅក្នុងជីវិត អាចជាបញ្ហាដ៏រសើប និង គួរឲ្យខ្វល់ខ្វាយខ្លាំងណាស់ ប៉ុន្តែព្រះជាម្ចាស់ទ្រង់មានឫទ្ធានុភាពល្មមគ្រប់គ្រាន់សម្រាប់គ្រប់បញ្ហាទាំងអស់ ប្រសិនបើយើងស្តាប់បង្គាប់តាមព្រះបន្ទូលរបស់ទ្រង់។ ដោយហេតុនេះហើយ ការយល់ដឹងពីគោលការណ៍របស់ព្រះគម្ពីរដែលពាក់ព័ន្ធនឹងបញ្ហាទាំងនោះគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់។ យើងបានផ្តល់ជូនគោលការណ៍ទាំងនេះដល់អ្នក នៅក្នុងមេរៀននេះហើយ។ ចូរយកវាទៅអនុវត្តនៅក្នុងជីវិតរបស់អ្នក ដើម្បីឲ្យអ្នកអាចនឹង "កែប្រែចិត្តគំនិតបងប្អូន អោយទៅជាថ្មីទាំងស្រុងវិញ" (គម្ពីររ៉ូម ១២:២) ដោយការណែនាំដែលទ្រង់បានប្រទានឲ្យ ដើម្បីឲ្យអ្នកនឹងអាចជៀសវាងពីសេចក្តីល្បួង និង លើកព្រះកិត្តិនាមព្រះជាម្ចាស់ ក្នុងនាមអ្នកដំណាក់នៃព្រះវិញ្ញាណដ៏វិសុទ្ធរបស់ទ្រង់។

លំហាត់អនុវត្តន៍

---

២០ ដោយយោងទៅតាមគម្ពីររ៉ូម ៨:៥-៦ តើអ្វីដែលចាំបាច់ ដើម្បីទទួលបានគំនិតថ្មីដែលអាចនាំឲ្យមានជីវិត និង សេចក្តីសុខសាន្តបាន?

.....

ការប្រឡងផ្ទាល់ខ្លួន

សំណួរពហុជម្រើសៗ ចូរជ្រើសរើសចម្លើយមួយដែលត្រឹមត្រូវបំផុត សម្រាប់សំណួរនីមួយៗ។

១ មូលហេតុដ៏សំខាន់ជាងគេសម្រាប់ការរក្សាភាពបរិសុទ្ធរបស់អ្នកគឺដើម្បី
   ក) ជៀសវាងបញ្ហាខាងឯផ្លូវភេទ។
   ខ) លើកព្រះកិត្តិនាមព្រះជាម្ចាស់ជាមួយរូបកាយរបស់អ្នក។
   គ) មានការទទួលពីមនុស្សម្នា។
   ឃ) ស្វែងរកដៃគូដែលបរិសុទ្ធ។

២ មនុស្សនៅលីវគឺជាមនុស្សដែល
   ក) មានទំនាក់ទំនងផ្លូវភេទដោយមិនបានរៀបការ។
   ខ) មិនទាន់រៀបការ និង គ្មានទំនាក់ទំនងផ្លូវភេទ។
   គ) ប្រើប្រាស់ការរួមរ័កទុកគ្រាន់តែជាការកំសាន្ត។
   ឃ) អាចធ្វើការគ្រប់គ្រងខ្លួនឯងបាន។

៣ ទំនាក់ទំនងផ្លូវភេទនៅក្នុងចំណងអាពាហ៍ពិពាហ៍គឺមានគោលបំណងសម្រាប់
   ក) ការបង្កើតកូនចៅ
   ខ) ការរួបរួម
   គ) ទាំងការបង្កើតកូនចៅ និង ការរួបរួមគ្នា។
   ឃ) ការគ្រប់គ្រងឲ្យនៅក្រោមអំណាច។

៤ តើរឿងណាមួយនៅខាងក្រោមនេះ ត្រូវបានយកមកប្រៀបធៀបទៅនឹង ព្រះគ្រិស្ត និង ក្រុមជំនុំ?
   ក) ទំនាក់ទំនងនៃឪពុកម្តាយ និង កូនៗ។
   ខ) អ្នកនៅលីវ និង ការបម្រើគ្រិស្តបរិស័ទ។
   គ) ការបង្កើតកូនចៅ
   ឃ) ទំនាក់ទំនងនៅក្នុងចំណងអាពាហ៍ពិពាហ៍។

៥ នៅក្នុងការប្រឈមមុខជាមួយអ្នកដែលបានទាក់ទងនឹងអំពើអសីលធម៌ខាងឯផ្លូវភេទហើយ ជារឿងសំខាន់ណាស់ដែលត្រូវ
   ក) ធ្វើឲ្យពួកគេមានអារម្មណ៍ថាមានទោស។
   ខ) រកការដោះសារសម្រាប់អំពើបាបរបស់ពួកគេ។
   គ) ជួយគេឲ្យដឹងថាព្រះជាម្ចាស់ទ្រង់អត់ទោស ឲ្យមនុស្សបាបដែលបានលន់តួ។
   ឃ) ប្រាប់ពួកគេឲ្យដឹងថា ពួកគេបានធ្វើខុសធ្ងន់ខ្លាំងយ៉ាងណា។

៦ តើចម្លើយមួយណានៅខាងក្រោមនេះ មិនមែនជាលទ្ធផលដែលបានមកពីអំពើអសីលធម៌ខាង ឯ ផ្លូវភេទ?

ក) ស្លាកស្នាមផ្លូវចិត្ត និង ការរងទុក្ខ

ខ) ជីវិតបរិសុទ្ធ

គ) កូនឥតខាន់ស្លា

ឃ) ជំងឺកាមរោគ

៧ តើសំណួរមួយណា នៅខាងក្រោមនេះ ដែលអ្នកគួរយកទៅសួរខ្លួនឯងនៅពេលអ្នកត្រូវបានល្បួងឲ្យធ្វើអ្វីម្យ៉ាងដែលមិនបានបកស្រាយច្បាស់ៗនៅក្នុងព្រះគម្ពីរ?

ក) តើវានឹងលើកព្រះកិត្តិនាមរបស់ព្រះជាម្ចាស់ដែរឬទេ?

ខ) តើវានឹងនាំឲ្យខ្ញុំបានសប្បាយដែរឬទេ?

គ) តើខ្ញុំនឹងទទួលបានអ្វីខ្លះពីវា?

ឃ) តើខ្ញុំទទួលបានការអនុញ្ញាតឲ្យធ្វើវា ដែរឬទេ?

៨ ចំណង់ផ្លូវភេទគឺ

ក) ជាអំពើបាប។

ខ) អ្វីម្យ៉ាងដែលយើងមិនអាចគ្រប់គ្រងបាន។

គ) ជារឿងគួរឲ្យអាម៉ាស់ណាស់។

ឃ) អំណោយពីព្រះជាម្ចាស់មក។

៩ វិន័យសម្រាប់ទំនាក់ទំនងផ្លូវភេទនៅក្នុងចំណងអាពាហ៍ពិពាហ៍គឺ

ក) ការពឹងពាក់គ្នាទៅវិញទៅមក។

ខ) ភាពនៅលីវ។

គ) ការបង្កើតកូនចៅ។

ចម្លើយខ្លីៗ ។ ចូរឆ្លើយនឹងសំណួរខាងក្រោមនេះ នៅលើបន្ទាត់ដែលបានផ្តល់ឲ្យ។

១០ ចូរប្រាប់មូលហេតុទាំងបីយ៉ាងដែលយើងអាចដឹងថា ការរួមសង្វាសភេទដូចគ្នាគឺជាអំពើបាប។

ក) .....

ខ) .....

គ) .....

១១ ចូរបកត្រឡប់ទៅមើល ខគម្ពីរនៅក្នុងមេរៀននេះ និង មេរៀនទី២ ហើយចូររកខគម្ពីរពីរខ ដែលយើងអាចប្រើសម្រាប់ប្រាប់អ្នកណាដែលនិយាយដូចខាងក្រោមនេះ ថាតើព្រះគម្ពីរបានចែងយ៉ាងដូចម្តេចអំពីបញ្ហានីមួយៗរបស់ពួកគេ។

ក) "យើងគ្មានសមត្ថភាពរៀបចំពិធីមង្គលការបានទេ ប៉ុន្តែយើងទាំងពីរនាក់ស្រឡាញ់គ្នា។ នោះមានន័យថាយើងអាចរួមរ័កបាន"។

.....

.....

ខ) "ហេតុអ្វីខ្ញុំគប្បីព្យាយាមបំពេញតាមចំណង់ប្តីរបស់ខ្ញុំ? គាត់មិនដែលប្រាប់ថាស្រឡាញ់ខ្ញុំ ឬបញ្ហាក្តីស្រឡាញ់មកកាន់ខ្ញុំទេ"។

.....

.....

គ) "ខ្ញុំមានផ្ទៃពោះ ហើយមិត្តប្រុសរបស់ខ្ញុំមិនព្រមរៀបការជាមួយខ្ញុំទេ។ ខ្ញុំចង់ធ្វើការរំលូតកូននេះ"

.....

.....

ឃ) "ខ្ញុំគិតថា ខ្ញុំអាចធ្វើជាមនុស្សដែលរួមសង្វាសជាមួយភេទដូចគ្នា ព្រមទាំងអាចធ្វើជាគ្រិស្តបរិស័ទបានដែរ។"

.....

.....

ង) ខ្ញុំមានជីវិតដែលពេញដោយអំពើបាប ។ ខ្ញុំមិនអាចក្លាយជាគ្រិស្តបរិស័ទបានទេ។ ព្រះជាម្ចាស់នឹងមិនទទួលយកខ្ញុំឡើយ។"

.....

.....

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១១ អ្នកណាដែលប្រព្រឹត្តអំពើសហាយស្មន់ ដែលនាំឲ្យហ្មងសៅដល់រូបកាយរបស់គេ ដែលជាព្រះវិហាររបស់ព្រះជាម្ចាស់ នោះគេក៏បានធ្វើបាបទាស់នឹងព្រះជាម្ចាស់ផងដែរ។

១ ព្រះអង្គនឹងប្រទានមធ្យោបាយអោយបងប្អូនចេញរួច និងអោយបងប្អូនអាចទ្រាំទ្របាន ដោយមិនចុះចាញ់ការល្បួងនោះឡើយ។

១២ បទគម្ពីរដែលបានផ្តល់ជូននៅក្នុងសំណួរទី១0 និង ទី១១ មានរៀបរាប់អំពីរឿងដែលកើតឡើងទៅលើបុរស និង ស្ត្រីដែលនៅក្នុងស្ថានភាពនេះ។

២ គ) យើងគួរតែស្តាប់តាមមនសិការដែលព្រះជាម្ចាស់បានប្រទានឲ្យយើង។

១៣ ដើម្បីជៀសឲ្យផុតពីបញ្ហា កូនឥតខាន់ស្លា ការរំលូតកូន ជំងឺកាមរោគ និង ស្លាកស្នាមផ្លូវចិត្ត ។ (វាក៏ជា អំពើបាបដែលត្រូវទទួលការកាត់ទោសរបស់ព្រះជាម្ចាស់ផងដែរ។)

៣ ដោយការគ្រប់គ្រងគំនិតរបស់ពួកគេ និង ការបង្វែរទិសដៅរបស់គេផងដែរ។

១៤ ពួកគេគួរអនុវត្តការគ្រប់គ្រងខ្លួនឯង ឬ គួរតែរៀបការក៏បាន។

៤ ពួកគេជៀសវាងបញ្ហាដែលបណ្តាលឲ្យមាន កូនឥតខាន់ស្លា បញ្ហាដែលបណ្តាលឲ្យមានការរំលូតកូន ការឆ្លងជំងឺកាមរោគ ឬ ទទួលរងស្លាកស្នាមផ្លូវចិត្ត។

១៥ លើកព្រះកិត្តិនាមព្រះជាម្ចាស់។

៥ ចម្លើយរបស់អ្នកគួរតែរួមបញ្ចូលគំនិតដូចតទៅនេះ៖ ភាពនៅលីវគឺជាជម្រើសមួយទៀតក្រៅពីការរៀបការ។ គ្រិស្តបរិស័ទដែលនៅលីវ ត្រូវបានរំពឹងទុកថានៅមានភាពបរិសុទ្ធ។ រូបកាយរបស់ពួកគេគឺជារបស់ព្រះជាម្ចាស់ និង ជាដំណាក់របស់ព្រះវិញ្ញាណដ៏វិសុទ្ធផងដែរ។ ចំណង់ផ្លូវភេទរបស់ពួកគេ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងគ្រប់ពេលវេលា។

១៦ វាមិនស្របទៅតាមគោលការណ៍នៃជីវិតផ្លូវភេទរបស់ព្រះជាម្ចាស់ ព្រះគម្ពីរបានចាត់ទុកវាថា ជាអំពើអាក្រក់ ហើយវានឹងទទួលការកាត់ទោសពីព្រះជាម្ចាស់។

៦ ក) ការបង្កើតកូនចៅ

ខ) ការរួបរួមជារូបកាយតែមួយ

១៧ ចម្លើយរបស់អ្នក។ ខ្ញុំអាចបង្ហាញពួកគេពីអ្វីដែលព្រះគម្ពីរបានចែងអំពីទង្វើនេះ និង អំពី របៀបដែលពួកគេ *អាច* កែប្រែបានដោយទទួលការលាងជម្រះ ធ្វើឲ្យទៅជាបរិសុទ្ធ និង បានល្អ ត្រឹមត្រូវនៅក្នុងព្រះនាមរបស់ព្រះអម្ចាស់ព្រះយេស៊ូគ្រិស្ត និង នៅក្នុងព្រះវិញ្ញាណរបស់ព្រះជាម្ចាស់។

៧ សាតាំងអាច "ល្បួងអ្នក ព្រោះអ្នកខ្វះការទប់ចិត្តខ្លួនឯង"

៨ ក) នាងត្រូវបានគេតាមទាន់ពេលកំពុងប្រព្រឹត្តអំពើសហាយស្មន់។

ខ) គប់សម្លាប់នាង ដោយធ្វើតាមច្បាប់។

គ) អត់ទោស

ឃ) "ខ្ញុំក៏មិនដាក់ទោសនាងដែរ សុំអញ្ជើញទៅចុះ តែពីពេលនេះតទៅ កុំប្រព្រឹត្តអំពើបាបទៀតឡើយ"

៨ ក) មិនស្រប
ខ) ស្រប
គ) ស្រប
ឃ) ស្រប
ង) ស្រប
ច) ស្រប
ឆ) មិនស្រប

១៩ ទ្រង់អត់ទោសបាបទាំងអស់របស់នាង។

៩ គ) ប្តី និង ប្រពន្ធ។

២០ យើងត្រូវរស់នៅដោយស្របជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ។

១០ គាត់មិនចេះគិតពិចារណា និង នាំឲ្យខ្លួនវិនាស។

មេរៀនទី ៧ ការយកឈ្នះលើការបាក់ទឹកចិត្ត

ខ្ញុំសំរក់ទឹកភ្នែក ទាំងថ្ងៃទាំងយប់ឥតមានល្ហែ។ គេចេះតែពោលមកខ្ញុំគ្រប់ពេលគ្រប់វេលាថា «តើព្រះរបស់ឯងនៅឯណា?»។ ...ខ្ញុំនិយាយមកខ្លួនឯងថា: «ឯងស្រយុតចិត្តធ្វើអ្វី ឯងថ្ងូរធ្វើអ្វី ចូរផ្ញើជីវិតលើព្រះជាម្ចាស់ទៅ!» ខ្ញុំមុខជាសរសើរតម្កើងព្រះអង្គតទៅមុខទៀត ព្រះអង្គសង្គ្រោះខ្ញុំ។ ... ខ្ញុំទូលព្រះជាម្ចាស់ ដែលជាថ្មដារបស់ខ្ញុំថា ហេតុអ្វីបានជាព្រះអង្គបំភ្លេចទូលបង្គំ? ហេតុអ្វីបានជាទូលបង្គំត្រូវរងទុក្ខលំបាក ហើយត្រូវខ្មាំងសត្រូវសង្កត់សង្កិនដូច្នេះ?។ ខ្មាំងសត្រូវនាំគ្នាជេរប្រមាថទូលបង្គំ ធ្វើអោយទូលបង្គំឈឺចុកចាប់សព្វសព៌ាង្គកាយ គេចេះតែពោលមកទូលបង្គំគ្រប់ពេលគ្រប់វេលាថា «តើព្រះរបស់ឯងនៅឯណា?»។ (គម្ពីរទំនុកតម្កើង ៤២:៣,៥,៩-១០)

តើអ្នកនឹកស្មានដល់ទេថា ទាំងនេះគឺពាក្យរបស់មនុស្សម្នាក់ដែលតែងបទចម្រៀងសរសើរតម្កើង និង សម្រាប់អរព្រះគុណព្រះជាម្ចាស់សម្រាប់ក្តីមេត្តា ព្រមទាំងព្រះគុណរបស់ទ្រង់ ដែលប្រកបដោយភាពសប្បាយរីករាយជាច្រើននោះ? តើអាចទៅរួចទេដែលមនុស្សម្នាក់នេះ ស្រែកយំរកព្រះជាម្ចាស់ថា "ហេតុអ្វីបានជាព្រះអង្គបំភ្លេចទូលបង្គំ?" យ៉ាងនេះបាន?

ការស្រែកយំចេញពីចិត្តមួយនេះ បង្ហាញប្រាប់យើងថាវាអាចទៅរួច សម្រាប់មនុស្សដែលស្រឡាញ់ និង ទុកចិត្តព្រះជាម្ចាស់ម្នាក់ អាចឆ្លងកាត់គ្រា នៃការបាក់ទឹកចិត្តយ៉ាងធ្ងន់ធ្ងរ នៅពេលដែលព្រះជាម្ចាស់ហាក់បីដូចជានៅឆ្ងាយ និង ស្ងាត់ជ្រងំ។ ចំណុចដែលសំខាន់នោះគឺថា ស្តេចដាវីឌ ដែលជាអ្នកតែងកំណាព្យនេះ បានទូញយំសូមជំនួយពីព្រះជាម្ចាស់។ លោកមិនបាន បណ្តោយខ្លួនឯងឲ្យលិចលង់នៅក្នុងការស្រណោះខ្លួន និង ក្តីឈឺចាប់នោះឡើយ។ នៅក្នុងការសន្និដ្ឋានរបស់កំណាព្យ លោកបានមានប្រសាសន៍ទៅកាន់ខ្លួនឯងម្តងទៀតថា ៖ "ចូរផ្ញើជីវិតលើព្រះជាម្ចាស់ទៅ!» ខ្ញុំមុខជាសរសើរតម្កើងព្រះអង្គតទៅមុខទៀត ព្រះអង្គសង្គ្រោះខ្ញុំ ហើយព្រះអង្គជាព្រះនៃខ្ញុំ។
(ទំនុកតម្កើង ៤២:១១)

នៅក្នុងមេរៀននេះ យើងនឹងស្គាល់ពីមូលហេតុបង្កឲ្យមានការបាក់ទឹកចិត្ត និង រកឲ្យឃើញធនធានដែលអាចជួយគ្រិស្តបរិស័ទ ជៀសវាង ឬ យកឈ្នះលើគ្រានៃការបាក់ទឹកចិត្ត។ យើងក៏នឹងមើលពីរបៀបជួយអ្នកដទៃទៀត ដែលកំពុងប្រឈមមុខជាមួយនឹងការបាក់ទឹកចិត្តផងដែរ។ យើងអាច សង្ឃឹមលើព្រះជាម្ចាស់ និង ដឹងថាទ្រង់មិនបានបំភ្លេចយើងឡើយ!

គម្រោងមេរៀន

ក. ការកំណត់និយមន័យការបាក់ទឹកចិត្ត
ខ. ការស្វែងរកមូលហេតុ និង ព្យាបាល
គ. ការការពារមិនឲ្យបាក់ទឹកចិត្ត
ឃ. ការជួយអ្នកដទៃ

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះអ្នកអាចនឹង៖
១. ស្វែងរកពាក្យដ៏ត្រឹមត្រូវដែលនិយាយទាក់ទងនឹងនិយមន័យនៃការបាក់ទឹកចិត្ត។
២. រៀបរាប់របៀបបីយ៉ាងដែល ការបាក់ទឹកចិត្តអាចទាក់ទងទៅនឹងជំងឺបាន។
៣. ជ្រើសរើសគោលការណ៍ដែលអាចជួយគ្រិស្តបរិស័ទឲ្យយកឈ្នះលើការបាក់ទឹកចិត្តដែលជាលទ្ធផលបានមកពីភាពតានតឹងផ្លូវចិត្ត។
៤. បកស្រាយពីឥរិយាបថ ដែលគ្រិស្តបរិស័ទម្នាក់ត្រូវប្រកាន់យក ក្រោយពេលមានព្រឹត្តិការណ៍ដ៏ គួរឲ្យខ្លាចកើតឡើងនៅក្នុងជីវិត ដែលបានធ្វើឲ្យគេអស់សង្ឃឹម។
៥. ស្វែងរកឧទាហរណ៍អំពីទោសដែលទាក់ទងនឹងអំពើបាប អំពីទោសដែលបានសន្មត ឬ ទោសដែលបណ្តាលមកពីវប្បធម៌ និង ដំណោះស្រាយសម្រាប់ទោសទាំងនេះ។
៦. យកខគម្ពីរម៉ាថាយ៥:១០-១១ ទៅធ្វើជាដំណោះស្រាយសម្រាប់ភាពជូរចត់ ឬ ការថ្នាំងថ្នាក់ចិត្ត។
៧. ជ្រើសរើសពាក្យត្រឹមត្រូវ ដែលនិយាយទាក់ទងពីរបៀបនៃការការពារមិនឲ្យមានការបាក់ទឹកចិត្ត។
៨. ស្គាល់ពីសកម្មភាពទាំងឡាយណាដែលអាចផ្តល់នូវជំនួយយ៉ាងល្អ ទៅដល់អ្នកដែលកំពុងរងការបាក់ទឹកចិត្ត។

សកម្មភាពនៅក្នុងការសិក្សា

១. សិក្សាទៅតាមដំណើរការវិវត្តន៍របស់មេរៀន ដូចពីមុន។ ត្រូវតែប្រាកដថាអ្នកបានអានខគម្ពីរទាំងអស់ដែលបានផ្តល់ជូន និង ឆ្លើយរាល់សំណួរសិក្សាទាំងអស់។
២. សិក្សានិយមន័យពាក្យសំខាន់ទាំងឡាយណាដែលអ្នកមិនទាន់យល់នៅក្នុងអក្ខរានុក្រម។
៣. ធ្វើការប្រឡងផ្ទាល់ខ្លួន ហើយផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក។

ពាក្យសំខាន់

ការប្រមូលផ្តុំ	ការថ្នាំងថ្នាក់ចិត្ត	ភាពស្ងប់ស្ងាត់
ការកាត់ទោស	ភាពតានតឹង	ភាពក្លៀវក្លា
ការសោកសង្រែង	ចុងក្រោយ	ងាយរងគ្រោះ
ដែលគាប់សង្កត់	ការព្យាបាល	

ក. ការកំណត់និយមន័យការបាក់ទឹកចិត្ត

វត្ថុបំណងទី១. *ស្វែងរកពាក្យដ៏ត្រឹមត្រូវដែលនិយាយទាក់ទងនឹងនិយមន័យនៃការបាក់ទឹកចិត្ត។*

តើការបាក់ទឹកចិត្តជាអ្វី? មានគ្រូពេទ្យម្នាក់បានរៀបរាប់អំពីវាដូចតទៅនេះ៖ " ពិភពលោកទាំងមូលហាក់បីដូចជាស្ថិតនៅក្នុងស្រមោលនៃភាពងងឹតអន្ធការ ។ អ្វីដែលកាន់តែអាក្រក់ជាងនេះទៅទៀតនោះគឺនៅពេលដែលអ្នកគិតថាអ្វីៗអាក្រក់យ៉ាងណា នោះអ្នកនឹងជឿថាវា*ពិតជា*អាក្រក់យ៉ាងនោះដែរ!" គាត់ជឿថា គំនិតអវិជ្ជមាននាំឲ្យមានការបាក់ទឹកចិត្ត។

នៅក្នុងវចនានុក្រម វែបស្ទើ (Webster) បានឲ្យនិយមន័យការបាក់ទឹកចិត្តថា៖ "សណ្ឋានមួយនៃអារម្មណ៍ក្រៀមក្រំ ភាពសោកសង្រេង ជំងឺផ្លូវចិត្តម្យ៉ាងដែលបណ្តាលមកពីភាពក្រៀមក្រំ ភាពអសកម្ម ពិបាកក្នុងការគិតពិចារណា និង ការផ្តោតអារម្មណ៍ និង ការមានអារម្មណ៍សោកសង្រេង ការថយចុះបរិមាណ គុណភាព និងថាមពលនៃសកម្មភាព ការថយចុះនៃភាពក្លៀវក្លា ឬ សកម្មភាពដែលមានប្រយោជន៍។

ជាច្រើនអ្នកនៅក្នុងចំណោមយើងរាល់គ្នា សុទ្ធតែបានឆ្លងកាត់ការបាក់ទឹកចិត្តក្នុងរយៈពេលខ្លីណាមួយ។ ក្នុងពេលមួយរំពេច ជីវិតមើលទៅហាក់បីដូចជាគ្មានអំណរសោះ បញ្ហារបស់យើងបានគ្របដណ្តប់លើយើង ហើយយើងបានលិចទៅក្នុង ភាពស្រណោះខ្លួន ក្តីវេទនា និង ការអស់សង្ឃឹម។

ខាងក្រោមនេះ គឺជាការរៀបរាប់របស់ស្ត្រីម្នាក់អំពីការបាក់ទឹកចិត្ត ដែលនាងបានឆ្លងកាត់នៅក្រោយពេលដែលប្តីរបស់នាងបានលាចាកលោក ដោយមិនបានព្រៀងទុកជាមុន៖

"នៅពេលដែលប្តីរបស់ខ្ញុំបានស្លាប់ទៅ ខ្ញុំមានគ្រួសារ និង មិត្តភក្តិដែលខ្វល់ខ្វាយជាច្រើននាក់នៅក្បែរ ហើយខ្ញុំទទួលបានអារម្មណ៍ដឹងពីព្រះវត្តមានរបស់ព្រះជាម្ចាស់នៅជិតខ្ញុំបង្កើយ។ ទ្រង់ប្រទានកម្លាំងឲ្យខ្ញុំ តាំងពីពេលដែលប្តីរបស់ខ្ញុំមានជំងឺរាំរៃ រហូតដល់ពេលដែលគាត់ទទួលមរណៈភាពទៅ។ មានមនុស្សជាច្រើនបានឃើញថា វាពិតជាទីបន្ទាល់មួយដ៏អស្ចារ្យ ដែលខ្ញុំមានសេចក្តីសុខសាន្ត និង ភាពស្ងប់សុខ ព្រះយេស៊ូប្រទានឲ្យអស់អ្នកដែលទួញសោក។ ទ្រង់*បាន* កំសាន្តចិត្តខ្ញុំ ហើយថែរក្សាខ្ញុំ ព្រមទាំងដឹកនាំខ្ញុំផងដែរ។

"ពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំបានចូលរួមនៅក្នុងព័ន្ធកិច្ចដែលប្រកបដោយភាពសប្បាយរីករាយ និង ជាទីគាប់ចិត្តផងដែរ។ ទោះបីជា ខ្ញុំបានបែកពីគ្រួសារ និង មិត្តសម្លាញ់របស់ខ្ញុំ ជីវិតរបស់ខ្ញុំនៅតែមានហេតុផលដើម្បីរីករាយ ហើយខ្ញុំបន្តរវល់ជាប់ជានិច្ច។ រយៈពេលជិតមួយឆ្នាំបានកន្លងផុតទៅ។ នៅកន្លែងដែលខ្ញុំធ្វើការមានការផ្លាស់ប្តូរបុគ្គលិក ហើយមានអ្នកខ្លះបានជះឥទ្ធិពលដល់ការងាររបស់ខ្ញុំខ្លាំងណាស់ ។ ខ្ញុំក៏ក្លាយទៅជា ឆាប់ប្រតិកម្មជាមួយការរិះគន់គ្រប់បែបយ៉ាង និងមានការថ្នាំងថ្នាក់ចិត្ត នៅពេលដែលខ្ញុំមិនទទួលបានការសរសើរចំពោះការងារដែលខ្ញុំគិតថាខ្ញុំសមតែនឹងទទួលបាន។ ក្រៅពីពេលធ្វើការ ខ្ញុំតែងចំណាយពេលនៅតែម្នាក់ឯង ហើយខ្ញុំក៏ចាប់ផ្តើមមានអារម្មណ៍ថា ឯកា និងត្រូវបានមនុស្សដែលខ្ញុំស្រឡាញ់បំផុតបោះបង់ចោល។

"មកដល់ពេលនេះ មនុស្សម្នាក់ដែលខ្ញុំឲ្យតម្លៃ និង ចង់បានការសរសើរពីគេ បានធ្វើឲ្យខ្ញុំមានការឈឺចាប់យ៉ាងខ្លាំង។ ការឆ្លើយតបរបស់ខ្ញុំចំពោះការនេះ គឺត្រូវដកខ្លួនចេញពីអ្វីគ្រប់យ៉ាងដែលអាចធ្វើឲ្យមានការឈឺចាប់នេះបន្ថែមទៀត។ នេះគឺជាចំណុចចាប់ផ្តើមដំបូងនៃការបាក់ទឹកចិត្តរបស់ខ្ញុំ។ វាជាលើកដំបូងដែលខ្ញុំឆ្លងកាត់ភាពសោកសៅយ៉ាងលើសលប់អំពីការស្លាប់របស់ប្តីខ្ញុំ។ ខ្ញុំមានអារម្មណ៍ថា មិនទទួលបានក្តីស្រឡាញ់ មិនស័ក្តិសម និង មិនសំខាន់។ មើលទៅហាក់បីដូចជា មិនដឹងថារស់នៅដើម្បីអ្វី។ ខ្ញុំមិនចង់អានព្រះគម្ពីរ មិនចង់អធិស្ឋាន ឬ ទទួលដំបូន្មានពីមិត្តភក្តិគ្រិស្តបរិស័ទនោះទេ។ ខ្ញុំគ្រាន់តែចង់ឲ្យគេទុកឲ្យខ្ញុំនៅតែឯង ដើម្បីឲ្យខ្ញុំបានរីករាយនៅក្នុងភាពសោកសៅ និង បណ្តែតបណ្តោយខ្លួននៅក្នុងការស្រណោះខ្លួនតែប៉ុណ្ណោះ។"

ប្រសិនបើអ្នកឆ្លងកាត់ការបាក់ទឹកចិត្ត អ្នកប្រហែលជាអាចស្គាល់ពីអារម្មណ៍ខ្លះៗដែលស្ត្រីម្នាក់នេះរៀបរាប់ហើយ។ ខាងក្រោមនេះគឺជាអាការៈខ្លះដែលតែងតែកើតមាននៅលើមនុស្សម្នាក់ដែលបាក់ទឹកចិត្ត៖

១. គេងមិនលក់ និង អស់កម្លាំង
២. ពិបាកផ្តោតអារម្មណ៍
៣. បាត់បង់ចំណាប់អារម្មណ៍ទៅលើរឿងដែលធ្លាប់តែធ្វើឲ្យរីករាយ រួមទាំងការរួមរ័កផងដែរ។
៤. ចង់នៅតែម្នាក់ឯង
៥. ពិបាកធ្វើការសម្រេចចិត្ត
៦. ឥរិយាបថអវិជ្ជមានអំពីខ្លួនឯង និង អ្នកដទៃ
៧. ជំងឺដែលបង្កឡើងដោយការបាក់ទឹកចិត្ត (ដូចជាដំបៅក្រពះ)
៨. ប៉ះពាល់ដល់សមត្ថភាពធ្វើការសម្រេចចិត្ត (តែងតែជាអារម្មណ៍ឆេវឆាវ និង អសុក្រិត្យ ដូចជាការសម្រេចចិត្តធ្វើអត្តឃាតជាដើម។)
៩. ក្រៀមក្រំ និង អស់សង្ឃឹមខ្លាំង
១០. ការថយចុះ សកម្មភាពជាច្រើន

ប្រាកដណាស់ មានរឿងជាច្រើនកើតឡើងនៅក្នុងជីវិតរបស់យើង ពីមួយថ្ងៃទៅមួយថ្ងៃ ដែលធ្វើឲ្យយើងមានអារម្មណ៍ថាក្រៀមក្រំ ភ័យខ្លាច ឬ មិនប្រាកដចិត្ត។ យើងរាល់គ្នាតែងតែមានថ្ងៃល្អ និង ថ្ងៃអាក្រក់ ថ្ងៃដែលយើងមានអារម្មណ៍ល្អ ហើយអ្វីៗហាក់ដូចជាឥតខ្ចោះនៅក្នុងជីវិតរបស់យើង និង ថ្ងៃខ្លះទៀតដែលអ្វីៗហាក់បីដូចជាខុសឆ្គង។ យើងអាចហៅអារម្មណ៍នេះបានថា *អារម្មណ៍រលក* ។ តាមធម្មតាអារម្មណ៍ទាំងនេះមិននៅជាយូរនោះទេ។ យើងនឹងបានល្អប្រសើរឡើងវិញពីថ្ងៃមិនល្អនោះ ដោយគ្មានលទ្ធផលអាក្រក់នោះទេ។ ចំណែកឯការបាក់ទឹកចិត្តវិញ គឺជាស្ថានភាពមួយនៃគំនិត ដែលគ្របដណ្តប់លើយើងម្តងបន្តិចៗ និងបន្តនៅក្នុងរយៈពេលមួយយ៉ាងយូរ។

យើងត្រូវតែស្គាល់ពីមូលហេតុដែលបង្កឲ្យមានការបាក់ទឹកចិត្ត និង ស្វែងរកមធ្យោបាយដើម្បីយកឈ្នះ និង បង្ការឲ្យផុតពីវា។ នៅក្នុងចំណុចបន្ទាប់នៃមេរៀននេះ យើងនឹងពិភាក្សាអំពីមូលហេតុធំៗ នៃការបាក់ទឹកចិត្ត និង របៀបដើម្បីតតាំងជាមួយវា។

លំហាត់អនុវត្តន៍

១ តើប្រយោគណាខ្លះនៅខាងក្រោមនេះ និយមន័យដ៏ពិតរបស់ការបាក់ទឹកចិត្ត? ចូរគូសរង្វង់ជុំវិញអក្សរដែលនៅមុខប្រយោគត្រឹមត្រូវ។

ក) ការបាក់ទឹកចិត្តគឺសំគាល់ឲ្យឃើញតាមរយៈការខ្វះថាមពល និង ការថយចុះសកម្មភាព។

ខ) អារម្មណ៍ណាដែលក្រៀមក្រំ ឬ ឯកា គឺជាការបាក់ទឹកចិត្ត។

គ) ពេលខ្លះវាមានការចូលរួមពីព្រឹត្តិការណ៍ជាច្រើន ដែលបង្កឲ្យមានការបាក់ទឹកចិត្ត។

ឃ) មនុស្សដែលបាក់ទឹកចិត្ត តែងតែមានគំនិតខ្ពង់ខ្ពស់សម្រាប់ខ្លួនឯង។

ង) ការផ្តាច់ខ្លួន ច្រើនតែជាអាការៈនៃការបាក់ទឹកចិត្ត។

ច) មនុស្សដែលបាក់ទឹកចិត្ត រីករាយនឹងនៅជាមួយមនុស្សដែលសប្បាយចិត្ត។

ឆ) មនុស្សដែលបាក់ទឹកចិត្ត ងាយនឹងធ្វើការសម្រេចចិត្តលឿន និង ធ្វេសប្រហែស។

២ តើរយៈពេលដែលអាការៈបន្តកើតមាន អាចប្រាប់បានថាមនុស្សម្នាក់កំពុងរងការបាក់ទឹកចិត្តដោយរបៀបណា?

.....

.....

ខ. ការស្វែងរកមូលហេតុ និង ការព្យាបាល

ប្រាកដណាស់ មានរឿងជាច្រើនអាចចូលរួមបង្កឲ្យមានការបាក់ទឹកចិត្ត។ នៅក្នុងមេរៀនកន្លងទៅ យើងបានពិភាក្សាគ្នាអំពីបញ្ហាជាច្រើនដូចជាបញ្ហាហិរញ្ញវត្ថុ បញ្ហាជាមួយកូនៗ ភាពឯកា និង ការបែកបាក់ស្នេហា ទាំងអស់នេះអាចនាំឲ្យកើតមានការបាក់ទឹកចិត្ត។ ជាទូទៅ ការបាក់ទឹកចិត្តមិនបង្កឡើងដោយបញ្ហាតែមួយនោះឡើយ ប៉ុន្តែវាបង្កឡើងដោយការបរាជ័យជាច្រើនប្រមូលផ្តុំគ្នា ដែលចុងក្រោយវាធំធេងលើសពីអ្វីដែលមនុស្សម្នាក់អាចទ្រាំទ្របាន។

នៅក្នុងផ្នែកនៃមេរៀនរបស់យើងមួយនេះ យើងនឹងគិតពិចារណាអំពីបញ្ហាទូទៅខ្លះៗ ដែលអាចនាំទៅរកការបាក់ទឹកចិត្ត និង អំពីរបៀបដែលគ្រិស្តបរិស័ទ អាចស្វែងរកឃើញជ័យជម្នះលើបញ្ហាទាំងអស់នេះ។

បញ្ហាជំងឺ

វត្ថុបំណងទី២. *រៀបរាប់របៀបបីយ៉ាងដែល ការបាក់ទឹកចិត្តអាចទាក់ទងទៅនឹងជំងឺបាន។*

ចិត្តវិទូម្នាក់បាននិយាយថា៖ "នៅពេលណាដែលមានអ្នកជំងឺចូលមកជួបខ្ញុំ ក្នុងសភាពបាក់ទឹកចិត្ត ដំបូងបំផុតខ្ញុំបញ្ជូលគាត់ទៅវេជ្ជបណ្ឌិត ដើម្បីធ្វើការពិនិត្យរូបកាយ"។ ការបាក់ទឹកចិត្តអាចជាអាការៈនៃជំងឺផ្លូវកាយ ដែលត្រូវការការយកចិត្តទុកដាក់ ឬវាអាចកើតឡើងដោយសារតែការព្យាយាមដោះស្រាយរឿងជំងឺដ៏ធ្ងន់ធ្ងរនោះ។ វាគឺជាដំណាក់កាលមួយដែលមនុស្សម្នាក់ត្រូវឆ្លងកាត់ នៅពេលដែលគេបានដឹងថាគេមានជំងឺធ្ងន់ធ្ងរដំណាក់កាលចុងក្រោយ។ យើងនឹងពិភាក្សាគ្នាបន្ថែមទៀតនៅក្នុងមេរៀនបន្ទាប់របស់យើង។

មានពេលខ្លះ យើងបណ្តោយឲ្យខ្លួនប្រាណរបស់យើងអស់កម្លាំងល្វើយ ដោយសារការធ្វើការហួសកម្លាំង ដល់ថ្នាក់យើងទៅជាមានជំងឺ និង បាក់ទឹកចិត្ត។ ទោះបីជាអ្នកដែលធ្វើព័ន្ធកិច្ចគ្រិស្តបរិស័ទក៏អាចឆ្លងកាត់ការបាក់ទឹកចិត្ត ដោយសារតែការធ្វើការបង្ខំខ្លួនឯងខ្លាំងពេក និង ភាពហេវហត់។ ខ្ញុំធ្លាប់ឃើញគ្រូគង្វាលជាច្រើន ឬប្រពន្ធរបស់ពួកគេ ដែលស្ទើរតែដល់ដែនកំណត់ទៅហើយក្រោយពេលពួកគេបានព្យាយាមបំពេញព័ន្ធកិច្ចជាច្រើនកន្លែង ដែលតម្រូវឲ្យពួកគេធ្វើការទាំងយប់ទាំងថ្ងៃ។ នៅគម្ពីរម៉ាកុស ៦:៣០-៣១ យើងបានដឹងថា ពេលដែលពួកសាវ័កឆ្លងកាត់ស្ថានភាពដូចគ្នានេះ ព្រះយេស៊ូបានប្រទានការព្យាបាលដោយ*ការសំរាក*៖

"ពួកសាវ័ក*វិលត្រឡប់មកគាល់ព្រះយេស៊ូវិញ រៀបរាប់ទូលព្រះអង្គអំពីកិច្ចការទាំងប៉ុន្មានដែល គេបានធ្វើ និងសេចក្តីទាំងអស់ដែលគេបានបង្រៀន។ មនុស្សជាច្រើនធ្វើដំណើរទៅមក ធ្វើ

អោយព្រះយេស៊ូ និងពួកសិស្ស*រកពេលបរិភោគពុំបានសោះ។ ព្រះយេស៊ូមានព្រះបន្ទូលទៅ

កាន់ពួកសិស្សថា៖ «ចូរនាំគ្នាមករកកន្លែងស្ងាត់ដាច់ឡែកពីបណ្តាជន សំរាកបន្តិចសិន»។"

ខ្លួនប្រាណរបស់យើងត្រូវការការហឹកហាត់បានត្រឹមត្រូវ របបអាហារត្រឹមត្រូវ និង ការសម្រាកគ្រប់គ្រាន់ ដើម្បីអាចបំពេញតួនាទីបានត្រឹមត្រូវដែរ។ គ្មានអ្វីដែលគួរឲ្យឆ្ងល់នោះទេ នៅពេលដែលយើងធ្វេសប្រហែសចំពោះរឿងទាំងនេះ វានឹងមានប្រតិកម្មមួយកើតឡើង យើងនឹងបាត់បង់ភាពមុះមុតរបស់យើង ហើយថែមទាំងចង់បោះបង់ចោលទៀតផង។

ព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺជាធនធានខាងឯវិញ្ញាណសម្រាប់ជួយយើងតតាំងជាមួយការបាក់ទឹកចិត្តនៅពេលដែលយើងមានជំងឺ៖ "ក្នុងពេលមានអាសន្នដូច្នេះ គេស្រែកអង្វរព្រះអម្ចាស់ ព្រះអង្គក៏សង្គ្រោះពួកគេអោយរួចផុត ពីការភ័យបារម្ភ។ ពេលព្រះអង្គមានព្រះបន្ទូល ពួកគេក៏បានជា ព្រះអង្គបានរំដោះគេអោយរួចពីរណ្តៅ។" (គម្ពីរទំនុកតម្កើង ១០៧:១៩-២០)។

ព្រះគម្ពីរគឺមានពេញដោយទីបន្ទាល់ អំពីការប្រោសឲ្យជាតាមរយៈឫទ្ធានុភាពនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ទីបន្ទាល់ទាំងនេះ ជំរុញឲ្យយើងស្រែកអង្វរកព្រះអម្ចាស់នៅក្នុងពេលដែលមានទុក្ខ ហើយអនុញ្ញាតឲ្យព្រះបន្ទូលរបស់ទ្រង់បានធ្វើការបំពេញតម្រូវការរបស់យើង ព្រមទាំងជឿទុកចិត្តថាទ្រង់នឹងបានប្រោសឲ្យជាពីជំងឺនោះផង។

លំហាត់អនុវត្តន៍

៣ ចូរប្រាប់ពីរបៀបបីយ៉ាងដែលការបាក់ទឹកចិត្តអាចជាប់ទាក់ទងទៅនឹងជំងឺ។

.....

.....

.....

៤ តើអ្វីដែលគួរតែជាជំហានដំបូងដើម្បីយកឈ្នះលើការបាក់ទឹកចិត្ត នៅក្នុងករណីទាំងបីនេះ?

.....

.....

.....

ភាពតានតឹង

វត្ថុបំណងទី៣. *ជ្រើសរើសគោលការណ៍ដែលអាចជួយគ្រិស្តបរិស័ទឲ្យយកឈ្នះលើការបាក់ទឹកចិត្ត ដែលជាលទ្ធផល បានមកពីភាពតានតឹងផ្លូវចិត្ត។*

ភាពតានតឹង មានន័យថា "កត្តាផ្លូវកាយ កត្តាគីមី ឬ កត្តាផ្លូវអារម្មណ៍ដែលបណ្តាលឲ្យមានការគាប់សង្កត់ខាងឯរូបកាយ និង ខាងឯផ្លូវចិត្ត ហើយអាចជាកត្តាដែលបណ្តាលឲ្យមានជំងឺផងដែរ"។ បញ្ហាមួយអាចបង្កើតឡើងនៅលើបញ្ហាមួយផ្សេងទៀត រហូតដល់បុគ្គលនោះស្ថិតនៅក្រោមសម្ពាធដែលធ្វើឲ្យមានការឆ្លើយតប (ប្រតិកម្ម) ខាងផ្លូវកាយ ខាងគីមី ឬខាងផ្លូវចិត្តកើតឡើង។ ភាគច្រើន ប្រតិកម្មនោះហើយគឺជាការបាក់ទឹកចិត្ត។

ចិត្តវិទូម្នាក់បាន បង្កើតខ្នាតសម្រាប់វាស់វែងកម្រិតនៃផលប៉ះពាល់ទៅលើមនុស្ស ដែលបណ្តាលមកពីព្រឹត្តិការណ៍ផ្សេងៗដែលកើតមាននៅក្នុងជីវិតរបស់គាត់។ នៅខាងក្រោមនេះ គឺជាព្រឹត្តិការណ៍និងកម្រិតនៃផលប៉ះពាល់ខ្លះៗដែលបង្កើតឡើងដោយចិត្តវិទូម្នាក់នេះ៖

ព្រឹត្តិការណ៍	**កម្រិតនៃផលប៉ះពាល់**
ការស្លាប់ប្តី ឬ ប្រពន្ធ	១០០
ការលែងលះគ្នា	៧៣
ការស្លាប់សមាជិកគ្រួសារជិតស្និទ្ធ	៦៣
របួស ឬ ជំងឺផ្ទាល់ខ្លួន	៥៣
អាពាហ៍ពិពាហ៍	៥០
ការបាត់បង់ការងារ	៤៧
ការផ្លាស់ប្តូរការងារផ្សេង	៣៦
ការផ្លាស់ប្តូរទំនួលខុសត្រូវការងារ	២៩
កូនចាកចេញពីផ្ទះ	២៩

ព្រឹត្តិការណ៍	**កម្រិតនៃផលប៉ះពាល់**
ការសម្រេចការងារផ្លាស់ខ្លួនដែលលើសពីធម្មតា	២៨
ការផ្លាស់ប្តូរកន្លែងរស់នៅ	២០
ការផ្លាស់ប្តូរសកម្មភាពនៅក្នុងក្រុមជំនុំ	១៩
ដំណើរកំសាន្ត	១២
ថ្ងៃបុណ្យណូអែល	១២

ចិត្តវិទូម្នាក់នេះបានសន្និដ្ឋាននៅក្នុងការស្រាវជ្រាវរបស់គាត់ថា ប្រសិនបើមនុស្សម្នាក់បានឆ្លងកាត់ច្រើនជាង៣០០ពិន្ទុនៃព្រឹត្តិការណ៍ដែលផ្លាស់ប្តូរនៅក្នុងជីវិតរបស់គាត់ក្នុងអំឡុងពេលពីរឆ្នាំ នោះគាត់ប្រឈមមុខនឹងការកើតជំងឺធ្ងន់ធ្ងរ (លោកគ្រីន ១៩៧៦, ១៤៦)។

ភាពសោកសៅគឺស្ថិតនៅខ្ពស់ជាងគេនៅក្នុងតារាងកត្តាបង្កឲ្យមានភាពតានតឹង ការរងទុក្ខ និង ការស្លាប់មនុស្សជាទីស្រឡាញ់ គឺជាមូលហេតុដ៏ធំដែលបង្កឲ្យមានភាពសោកសៅ។ ទាំងនេះគឺជាភាពតានតឹងដែលយើងរាល់គ្នាធ្លាប់ប្រឈមមុខនៅក្នុងជីវិតរបស់យើង។ របៀបដែលយើងប្រតិកម្មតបទៅចំពោះភាពតានតឹងទាំងនោះយ៉ាងណា គឺផ្អែកទៅលើការរៀបចំខាងឯវិញ្ញាណរបស់យើង ។ (សូមមើលនៅក្នុងមេរៀនទី៣)។

ក្រោយពេលមានការបាត់បង់ ការសោកសៅមួយរយៈពេល គឺជាដំណើរការធម្មតានោះទេ។ ប៉ុន្តែខ្ញុំមិនជឿថា បុគ្គលម្នាក់ដែលឆ្លងកាត់ភាពតានតឹងត្រូវតែមានជំងឺ ឬ ការបាក់ទឹកចិត្តដោយចៀសមិនបាននោះទេ។ យើងអាចទទួលបានកម្លាំង និង ការកំសាន្តចិត្តពីព្រះវិញ្ញាណដ៏វិសុទ្ធ។ សូមពិចារណាខគម្ពីរខាងក្រោមនេះ៖

គម្ពីរនេហេមា ៨:១០៖ "មិនត្រូវកើតទុក្ខព្រួយឡើយ ព្រោះអំណរដែលមកពីព្រះអម្ចាស់ ជាកម្លាំងរបស់អ្នករាល់គ្នា។"

គម្ពីរយ៉ូហាន១៦:២២៖ "ឥឡូវនេះ អ្នករាល់គ្នាព្រួយចិត្ត ប៉ុន្តែ ខ្ញុំនឹងជួបអ្នករាល់គ្នាសាជាថ្មី អ្នករាល់គ្នានឹងសប្បាយចិត្ត ហើយគ្មាននរណាដកយកអំណរសប្បាយចេញពីចិត្តអ្នករាល់គ្នាបានឡើយ។"

លំហាត់អនុវត្តន៍

---

៥ ចូរជ្រើសរើសចម្លើយដែលល្អបំផុត។ ខគម្ពីរទាំងពីរខាងលើនេះបានប្រាប់យើងថា

ក) វាគឺជារឿងខុសឆ្គងមួយដែលគ្រិស្តបរិស័ទ កើតទុក្ខក្រោយពេលមានការបាត់បង់អ្វីមួយ។

ខ) មានពេលដែលត្រូវកើតទុក្ខ ប៉ុន្តែព្រះអម្ចាស់អាចជំនួសការកើតទុក្ខរបស់យើងជាមួយនឹងអំណររបស់ទ្រង់បាន។

គ) យើងមិនអាចកើតទុក្ខផង ហើយទទួលអំណររបស់ព្រះអម្ចាស់នៅក្នុងពេលតែមួយបាននោះទេ។

ប្រសិនបើអ្នកចាប់ផ្តើមមានសញ្ញានៃភាពតានតឹងនៅក្នុងជីវិតរបស់អ្នក ចូរធ្វើអ្វីដែលអ្នកអាចធ្វើបាន ដើម្បីបំបាត់ស្ថានភាពដែលបណ្តាលឲ្យមានភាពតានតឹងនោះ ។ ប៉ុន្តែប្រសិនបើ គ្មានអ្វីដែលអ្នកអាចធ្វើបាន ដើម្បីសម្រាលបន្ទុករបស់អ្នកនោះទេ ចូរចំណាយពេលរបស់អ្នកបន្ថែមទៀតជាមួយនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ រងចាំព្រះអម្ចាស់ និង អនុញ្ញាតឲ្យទ្រង់ទទួលយកបន្ទុករបស់អ្នក។ ព្រះបន្ទូលរបស់ព្រះយេស៊ូទៅកាន់ពួកសាវ័ករបស់ទ្រង់គឺជាព្រះបន្ទូលនៃសេចក្តីសង្ឃឹមសម្រាប់អ្នកនៅពេលបច្ចុប្បន្ននេះ៖

> កុំរន្ធត់ចិត្តធ្វើអ្វី អ្នករាល់គ្នាជឿលើព្រះជាម្ចាស់ហើយ សុំជឿលើខ្ញុំផង..ខ្ញុំទុកសេចក្តីសុខសាន្តអោយអ្នករាល់គ្នា ខ្ញុំផ្តល់សេចក្តីសុខសាន្តរបស់ខ្ញុំអោយអ្នករាល់គ្នា។ សេចក្តីសុខសាន្តដែលខ្ញុំផ្តល់អោយនេះ មិនដូចសេចក្តីសុខសាន្តដែលមនុស្សលោកអោយទេ។ ចូរកុំរន្ធត់ចិត្ត កុំភ័យខ្លាចអោយសោះ។ (គម្ពីរយ៉ូហាន ១៤:១, ២៧)។

អ្វីដែលយើងអាចរំពឹងបានពីលោកីយ៍នេះ គឺមានតែភាពតានតឹង ការឈឺចាប់ និង ការរងទុក្ខប៉ុណ្ណោះ ប៉ុន្តែព្រះយេស៊ូបានប្រទានការព្យាបាលសម្រាប់បញ្ហាទាំងអស់នេះ៖ គឺសេចក្តីសុខសាន្ត និង អំណររបស់ទ្រង់។ យើងគ្រាន់តែត្រូវទូលសូមតែប៉ុណ្ណោះ។

លំហាត់អនុវត្តន៍

៦ តើគោលការណ៍ណាមួយនៅខាងក្រោមនេះ នឹងជួយគ្រិស្តបរិស័ទឲ្យយកឈ្នះលើការបាក់ទឹកចិត្ត ដែលបណ្តាលមកពីភាពតានតឹងនោះបាន? ចូរជ្រើសរើសចម្លើយដែលល្អបំផុត។

ក) គ្រិស្តបរិស័ទត្រូវទូលសូមព្រះជាម្ចាស់ឲ្យជួយបញ្ឈៀសឲ្យផុតព្រឹត្តិការណ៍ដែលអាចបណ្តាលឲ្យ មានភាពតានតឹងនៅក្នុងជីវិតរបស់គេ។

ខ) គ្រិស្តបរិស័ទត្រូវរៀនគ្រប់គ្រងអារម្មណ៍របស់ពួកគេ ដើម្បីកុំឲ្យព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងជីវិតបង្កើតបានជាការគាប់សង្កត់នៅក្នុងជីវិតរបស់ពួកគេ។

គ) នៅពេលដែលភាពតានតឹងកើនឡើង យើងគួរតែបង្កើនការប្រុងប្រៀបខាងឯវិញ្ញាណជាមួយគ្នាផងដែរ៖ គឺចំណាយពេលឲ្យច្រើនសម្រាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និង សម្រាប់ការអធិស្ឋានផងដែរ។

ឃ) គ្រិស្តបរិស័ទដែលពិតជាប្តេជ្ញាជាមួយព្រះជាម្ចាស់ នឹងមិនទទួលរងភាពតានតឹងឡើយ មិនថាមានព្រឹត្តិការណ៍អ្វីកើតឡើងនៅក្នុងជីវិតរបស់គេនោះទេ។

ភាពភ័យខ្លាច និង ភាពអស់សង្ឃឹម

វត្ថុបំណងទី៤. *បកស្រាយពីឥរិយាបថ ដែលគ្រិស្តបរិស័ទម្នាក់ត្រូវប្រកាន់យក ក្រោយពេលមានព្រឹត្តិការណ៍ដ៏គួរឲ្យខ្លាចកើតឡើងនៅក្នុងជីវិត ដែលបានធ្វើឲ្យគេអស់សង្ឃឹម។*

យើងរស់នៅក្នុងយុគសម័យ នៃភាពភ័យខ្លាច និង ភាពអស់សង្ឃឹម។ ភេរវកម្ម និង ភាពរឹករវាងនយោបាយ បានគម្រាមកំហែងដល់ស្ថេរភាព។ ជំងឺមហារីក គឺជាជំងឺដ៏គួរឲ្យខ្លាចមួយដែលហាក់បីដូចជាជះឥទ្ធិពលទៅលើគ្រប់គ្រួសារទាំងអស់។ អំពើឧក្រិដ្ឋកម្ម កំពុងតែរាលដាល ហើយប្រជាជនស្លូតត្រង់ទទួលរងនូវផលវិបាកទាំងនោះ។ នៅក្នុងប្រទេសជាច្រើននៅលើពិភពលោក មនុស្សញញើតមិនហ៊ានដើរតាមផ្លូវនៅពេលយប់នោះទេ។ យើងភ័យខ្លាចថាយើងនឹងបាត់បង់ការងាររបស់យើង យើងភ័យខ្លាចភាពចាស់ជរា យើងភ័យខ្លាចការឈឺចាប់ យើងភ័យខ្លាចថានឹងមានអ្វីម្យ៉ាងកើតឡើងទៅលើមនុស្សជាទីស្រឡាញ់របស់យើង។

នៅពេលដែលយើងគិតពីភាពភ័យខ្លាចជាប់និច្ច នោះការបាក់ទឹកចិត្តអាចគ្រប់គ្រងលើយើងបាន។ ភាពភ័យខ្លាចទាំងនេះបង្កឲ្យមានការអស់សង្ឃឹម៖ គ្មានហេតុផលអ្វីនឹងឲ្យយើងព្យាយាមបន្តរស់នៅជីវិតមួយនេះ ឬ ព្យាយាមរីករាយទៀតទេ ព្រោះជីវិតនេះមានតែក្តីអស់សង្ឃឹម។ មើលទៅហាក់ដូចជាគ្មានមធ្យោបាយណាជួយឲ្យគេចផុតពីកាល:ទេស:ដ៏វេទនារបស់យើងបាននោះទេ គ្មានរឿងល្អអាចកើតឡើងចំពោះយើងនោះឡើយ។ មកដល់ចំណុចនេះហើយ ដែលមនុស្សកំពុងអស់សង្ឃឹមគឺអាចគិតថាការសម្លាប់ខ្លួន គឺជាមធ្យោបាយគេចផុតពីស្ថានភាពដ៏គួរឲ្យខ្លាចរបស់ពួកគេ។

លំហាត់អនុវត្តន៍

---

៧ តើមានអ្វីខុស ចំពោះទស្សន:ដែលបានរៀបរាប់នៅខាងលើនេះ?

.....

ការព្យាបាលសម្រាប់ភាពភ័យខ្លាចគឺក្តីស្រឡាញ់។ ប្រសិនបើយើងស្រឡាញ់ព្រះជាម្ចាស់ យើងនឹងមានទំនុកចិត្តថាទ្រង់នឹងលើកយើងចេញពីភាពភ័យខ្លាចរបស់យើង។ នៅក្នុងគម្ពីរ១យ៉ូហាន ៤:១៦-១៨ បានប្រាប់យើងថា៖

> ឯយើងវិញ យើងបានស្គាល់ព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ ក្នុងចំណោមយើង ហើយយើងក៏បានជឿ។ ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ អ្នកណាស្ថិតនៅជាប់នឹងសេចក្តីស្រឡាញ់ អ្នកនោះស្ថិតនៅជាប់នឹងព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ក៏ស្ថិតនៅជាប់នឹងអ្នកនោះដែរ។ បើសេចក្តីស្រឡាញ់ពិតជាបានគ្រប់លក្ខណៈនៅក្នុងយើងមែន នោះយើងនឹងមានចិត្តរឹងប៉ឹង នៅថ្ងៃព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សលោក ដ្បិតក្នុងលោកនេះយើងមានរបៀបរស់នៅដូចព្រះយេស៊ូដែរ។ បើយើងមានសេចក្តីស្រឡាញ់ក្នុងខ្លួន យើងឥតមានភ័យខ្លាចទេ តែសេចក្តីស្រឡាញ់ដ៏គ្រប់លក្ខណៈ បណ្តេញការភ័យខ្លាចអោយចេញផុតទៅបានថែមទៀតផង។ អ្នកណានៅភ័យ

ខ្លាច អ្នកនោះតែងតែខ្លាចទទួលទណ្ឌកម្ម ដូច្នេះ សេចក្តីស្រឡាញ់ពុំទាន់បានគ្រប់លក្ខណៈនៅក្នុងខ្លួនគេឡើយ។

នៅពេលណាដែលដួងចិត្តរបស់អ្នកមានពេញដោយភាពភ័យខ្លាច ចូរទូលសូមឲ្យព្រះជាម្ចាស់បានដោះភាពភ័យខ្លាចរបស់យើងចេញ ហើយជំនួសវិញដោយក្តីស្រឡាញ់ដ៏អស់កល្បជានិច្ចរបស់ទ្រង់ ហើយទទួលបានការលើកទឹកចិត្តដោយអ្វីដែលព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់ពួកសាវ័ករបស់ទ្រង់ថា៖ "អ្នករាល់គ្នាជួបនឹងទុក្ខវេទនានៅក្នុងលោក ប៉ុន្តែ ចូរមានសង្ឃឹមឡើង! ខ្ញុំបានឈ្នះលោកនេះហើយ" (គម្ពីរយ៉ូហាន ១៦:៣៣)។

លំហាត់អនុវត្តន៍

---

៨ តើគ្រិស្តបរិស័ទគួរមានឥរិយាបថបែបណា នៅពេលដែលមានព្រឹត្តិការណ៍ដែលគួរឲ្យខ្លាចកើតឡើងនៅក្នុងជីវិត ដែលអាចធ្វើឲ្យពួកគេអស់សង្ឃឹមនោះ?

.....

.....

អារម្មណ៍មានទោស និង ការសោកស្តាយ

វត្ថុបំណងទី៥. *ស្វែងរកឧទាហរណ៍អំពីទោសដែលទាក់ទងនឹងអំពើបាប អំពីទោសដែលបានសន្មត់ ឬ ទោសដែលបណ្តាលមកពីវប្បដិសារី និង ដំណោះស្រាយសម្រាប់ទោសទាំងនេះ។*

ភាពសោកសៅតែងតែមានការចូលរួមពី អារម្មណ៍ថាមានទោស ឬ សោកស្តាយ ដោយសារតែអ្វីមួយដែលយើងបានធ្វើ ឬ អ្វីមួយដែលយើងគួរតែបានធ្វើ។ ខ្ញុំបានជួបជាមួយ ឪពុកម្តាយដែលកើតទុក្ខដោយសារតែកូនដែលបានចាកចេញពីផ្ទះ និង បានពាក់ព័ន្ធជាមួយជីវិតដែលពេញដោយបាប។ ពួកគេប្រមូលយកកំហុសទាំងអស់មកលើខ្លួនគេតាមរបៀបជាច្រើន ដោយសារតែកូនមិនល្អ។ មានបុរសជាឪពុកម្នាក់កើតទុក្ខព្រួយ ដែលគាត់បានអនុញ្ញាតឲ្យកូនប្រុសរបស់គាត់ទិញម៉ូតូមួយគ្រឿង ហើយគាត់មានអារម្មណ៍ថាមានទោសយ៉ាងខ្លាំងនៅពេលដែល មានរថយន្តមួយគ្រឿងបានបុក ហើយបានឆក់យកជីវិតកូនប្រុសរបស់គាត់ នៅពេលគេកំពុងជិះម៉ូតូរបស់គេនោះ។ "ឪពុកនោះបានទួញយំម្តងហើយម្តងទៀតថា៖ "ខ្ញុំគួរតែនិយាយថា*អេ*!" ដូចគ្នាផងដែរ មានមនុស្សជាច្រើនទទួលអារម្មណ៍ថាមានទោសខ្លាំងណាស់ព្រោះតែរឿងអាក្រក់ដែលគេបាននិយាយ ឬបានធ្វើ ដែលធ្វើឲ្យអ្នកដទៃឈឺ
ចាប់។

មានទោសកំហុសពីរយ៉ាងដែលទាក់ទងនៅត្រង់ចំណុចនេះ៖ ទោសពិត ដែលកើតឡើងដោយសកម្មភាពនៃអំពើបាបមួយចំនួន និង ទោសសន្មត់ដោយសារតែអ្វីម្យ៉ាងដែលយើងមិនអាចគ្រប់គ្រងបាន។ ទោសពិតគឺជាទោសត្រឹមត្រូវដែលមានឫសគល់នៅក្នុងទំនាក់ទំនងជាមួយព្រះជាម្ចាស់ ជាមួយអ្នកដទៃ និង ជាមួយនឹងខ្លួនឯង។ វាមានរួមជាមួយនឹងបំណងចិត្តចង់សារភាពយ៉ាងខ្លាំង ហើយវាតែងតែឆ្លើយតបទៅនឹងការអត់ទោស។ ទោសកើតពីការសន្មត (ឬ *មិនសមហេតុផល*) គឺតែងតែមានទំនាក់ទំនងជាមួយនឹងវិន័យ និង ច្បាប់។ ទោសនេះក៏មានរួមជាមួយនឹងបំណងចិត្តចង់សារភាពខ្លាំងផងដែរ ប៉ុន្តែកម្រនឹងឆ្លើយតបទៅនឹងការអត់ទោសណាស់។ កំហុសទាំងពីរបែបនេះ ផ្តល់អារម្មណ៍ដូចគ្នា ប៉ុន្តែពួកវាមានឫសគល់នៅក្នុងបញ្ហាផ្សេងគ្នា ហើយវាឆ្លើយតបជាមួយនឹងការអត់ទោសផ្សេងគ្នាដែរ។ ទោសទាំងពីរប្រភេទនេះ អាចបង្កឲ្យមានការបាក់ទឹកចិត្តបាន ប៉ុន្តែការព្យាបាលរបស់វាគឺមានលក្ខណៈខុសពីគ្នា។

ទោសដែលទាក់ទងនឹងអំពើបាប

គ្រិស្តបរិស័ទមិនចាំបាច់ត្រូវរស់នៅក្នុងជីវិតដែលដាក់ទោសខ្លួនឯងចំពោះអំពើបាបដែលគេបានប្រព្រឹត្តនោះឡើយ។ នៅពេលដែលមនសិការរបស់យើងជេរស្តីយើង យើងមានអ្នកសង្គ្រោះដែលនឹងជួយទូលអង្វរជំនួសយើងនៅចំពោះព្រះភ័ក្ត្រព្រះវរបិតានៅឯស្ថានបរមសុខរួចស្រេចហើយ។ (គម្ពីរ១យ៉ូហាន ២:១-២)។ "ប៉ុន្តែ បើយើងទទួលសារភាពអំពើបាបរបស់យើង នោះព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះស្ម័គ្រ និងសុចរិត* ទ្រង់នឹងអត់ទោសយើងអោយរួចពីបាប ព្រមទាំងជំរះយើងអោយបានបរិសុទ្ធ រួចពីគ្រប់អំពើទុច្ចរិតទាំងអស់ផង។(គម្ពីរ១យ៉ូហាន ១:៩)។

យើងមិនចាំបាច់ត្រូវ រែកពុនបន្ទុកនៃបាបរបស់យើងនោះឡើយ។ ចូរលន់តួបាប ហើយសារភាពបាបរបស់អ្នកទៅចំពោះព្រះជាម្ចាស់ (ហើយបើសិនជាអាច ចូរសារភាពទៅកាន់មនុស្សដែលអ្នកបានធ្វើបាបទាស់នឹងគេ ប្រសិនបើមានអ្នកផ្សេងជាប់ទាក់ទងនឹងរឿងនេះ) ហើយទទួលការអត់ទោសរបស់ព្រះជាម្ចាស់។ បន្ទាប់មក ទទួលយកការពិតដែលថា វាបានចប់សព្វគ្រប់ និង នៅពីក្រោយអ្នក ហើយព្រមទាំងបំភ្លេចវាចោលផងដែរ។

ទោសកើតពីការសន្មត

ខ្ញុំបានឮរឿងរបស់ម្តាយវ័យក្មេងម្នាក់ដែល មានថ្ងៃមួយនាងបាននាំកូនតូចរបស់នាងដើរលេង។ ពេលនោះនាងបានជួបជាមួយនឹងអ្នកជិតខាងម្នាក់ ហើយពួកគេបានឈរនិយាយគ្នានៅលើកចិញ្ចើមផ្លូវ ស្របពេលកូនរបស់នាងបានរត់លេងនៅក្បែរនោះ។ រំពេចនោះ កូនរបស់នាងបានរត់យ៉ាងលឿនទៅកណ្តាលផ្លូវ ហើយត្រូវបានរថយន្តមួយគ្រឿងបុក ធ្វើឲ្យកូននោះបានបាត់បង់ជីវិតភ្លាមៗ។ ម្តាយដែលមានវ័យក្មេងនោះ ត្រូវបានគ្រប់ដណ្តប់ដោយភាពសោកសៅ និង មានអារម្មណ៍ថាមានទោសខ្លាំងណាស់ដែលនាងបណ្តោយឲ្យមានរឿងបែបនេះកើតឡើង។ ជាច្រើនថ្ងៃកន្លងផុតទៅ នាងកាន់តែដកខ្លួនចេញមនុស្សម្នា និង កាន់តែបាក់ទឹកចិត្ត។ នាងមិនអាចទ្រាំទ្រជាមួយនឹង ការជេរស្តីខ្លួនឯងចំពោះឧបទ្ទវហេតុដែលបានកើតឡើងនោះបានទេ។

ពិតណាស់ មានរឿងជាច្រើនកើតឡើងនៅក្នុងជីវិតរបស់យើង ដែលធ្វើឲ្យយើងមានអារម្មណ៍សោកស្តាយយ៉ាងខ្លាំង។ យើងមើលត្រឡប់ក្រោយ និង ឃើញពីអ្វីដែលយើងបានត្រឹមប្រាថ្នាថាអាចបានធ្វើឲ្យបានប្រសើរជាងនោះ។ មនុស្សពោះម៉ាយ ឬ មេម៉ាយ តែងតែសោកស្តាយ ហើយគិតពីរបៀបផ្សេងៗដែលពួកគេគួរតែអាចធ្វើបានឲ្យដៃគូរបស់គេបានសប្បាយរីករាយជាងនោះ។ ឪពុកម្តាយតែងតែមានអារម្មណ៍ថាមានទោស និងសោកស្តាយដោយសារតែពួកគេគិតថាពួកគេ គួរតែអាចបណ្តុះបណ្តាលកូនៗរបស់ពួកគេបានល្អជាងនេះ។

ទាំងនេះគឺសុទ្ធតែជាការខិតខំប្រឹងប្រែងដែលគ្មានប្រយោជន៍ ព្រោះយើងមិនអាចផ្លាស់ប្តូរអតីតកាលបានឡើយ យើងបានត្រឹមតែរៀនពីវា និង ព្យាយាមធ្វើយ៉ាងណា ដៀសឲ្យផុតពីកំហុសដដែលនោះនៅថ្ងៃអនាគតតែប៉ុណ្ណោះ។ ប្រសិនបើហេតុការណ៍ដែលកើតឡើងនៅក្នុងជីវិតរបស់យើង វាស្ថិតនៅឆ្ងាយពីការគ្រប់គ្រងរបស់យើង យើងគួរតែដឹងថា យើងមិនមានទោសអ្វីនោះទេ ហើយដឹងថា ជីវិតរបស់យើងគឺថ្វាយទៅក្នុងការថែរក្សារបស់ព្រះជាម្ចាស់។ បើទ្រង់នឹងអត់ទោសដោយក្តីមេត្តា និង ព្រះគុណ ទោះអំពើបាបរបស់យើងអាក្រក់យ៉ាងណានោះ តើយើងមិនគួរទទួលយកការអត់ទោសរបស់ទ្រង់សម្រាប់ហេតុការណ៍ដែលធ្វើឲ្យយើងពេញដោយការសោកស្តាយ និង ជេរស្តីខ្លួនឯងដែរទេឬអី?

ស្តេចដាវីឌជាអ្នកនិពន្ធគម្ពីរទំនុកតម្កើង បានដឹងថាទ្រង់អាចបែរទៅរកព្រះជាម្ចាស់បានទោះបីកំហុសរបស់ទ្រង់ជាអ្វីក៏ដោយ ហើយទ្រង់ដឹងថាទ្រង់អាចទទួលបានការលាងជម្រះថែមទៀតផង។ ខាងក្រោមនេះជាពាក្យរបស់ទ្រង់ នៅក្នុងគម្ពីរទំនុកតម្កើង ១៣០ :១-៤,៧៖

> ឱព្រះអម្ចាស់អើយ ពីក្នុងរណ្តៅដ៏ជ្រៅ ទូលបង្គំស្រែកអង្វរព្រះអង្គ ព្រះអម្ចាស់អើយ សូមទ្រង់ព្រះសណ្តាប់ទូលបង្គំផង! សូមផ្ទៀងព្រះកាណ៌ស្តាប់ពាក្យ ដែលទូលបង្គំទទូចអង្វរ! ឱព្រះអម្ចាស់អើយ ប្រសិនបើព្រះអង្គចងចាំកំហុស របស់យើងខ្ញុំទុកនោះ គ្មាននរណាម្នាក់អាចរួចខ្លួនបានឡើយ។ ក៏ប៉ុន្តែ ព្រះអង្គតែងតែអត់ទោស អោយយើងខ្ញុំជានិច្ច ដើម្បីអោយយើងខ្ញុំគោរពកោតខ្លាចព្រះអង្គ។ ...អ៊ីស្រាអែលអើយ ចូរទុកចិត្តលើព្រះអម្ចាស់ ដ្បិតព្រះអង្គប្រកបដោយ ព្រះហឫទ័យមេត្តាករុណា ហើយព្រះអង្គសព្វព្រះហឫទ័យរំដោះអ្នកជានិច្ច!

មិនថាមានរឿងអ្វីកើតឡើងនៅក្នុងជីវិតរបស់អ្នកនោះទេ នៅក្នុងព្រះអម្ចាស់តែងតែមានព្រះហឫទ័យរំដោះអ្នកជានិច្ច។ បើទ្រង់ពិតជាមានចិត្តសប្បុរស និង សព្វព្រះទ័យរំដោះអ្នកយ៉ាងនេះ តើអ្នកមិនអាចនឹងអត់ទោសសម្រាប់ខ្លួនឯងដែរទេឬអី? ចូរដាក់ការសោកស្តាយរបស់អ្នក និង ទោសកំហុសដែលមិនសំខាន់របស់អ្នក នៅពីក្រោយអ្នក។ ចូរប្រើប្រាស់វាជាឱកាស សម្រាប់ប្រាប់អ្នកដទៃអំពីការរំដោះដ៏អស្ចារ្យដែលអ្នករកបាននៅពេលដែលអ្នកថ្វាយកំហុសរបស់អ្នកទៅកាន់ព្រះអម្ចាស់ ព្រមទាំងសម្រាប់អ្នក ទទួលបានក្តីស្រឡាញ់ និង ព្រះគុណរបស់ទ្រង់ផង។

លំហាត់អនុវត្តន៍

៩ នៅក្នុងលំហាត់នេះ ចូរផ្គូផ្គងឧទាហរណ៍ និង ដំណោះស្រាយដែលនៅក្នុងជួរខាងឆ្វេង ទៅជាមួយនឹងប្រភេទនៃទោសកំហុសដែលត្រូវជាមួយនឹងដំណោះស្រាយឬឧទាហរណ៍នោះ (នៅជួរខាងស្តាំ)។ ចូរសរសេរលេខនៃជម្រើសរបស់អ្នកនៅក្នុងចន្លោះត្រឹមត្រូវ។

.....ក) បុរសវ័យក្មេងម្នាក់ កំពុងនៅឆ្ងាយពីផ្ទះស្របពេលដែលម្តាយរបស់គាត់បានទទួលមរណភាពដោយមិនបានព្រៀងទុក។

.....ខ) លន់តួ សារភាព និង ទទួលការអត់ទោស។

.....គ) ស្ត្រីដែលមិនទាន់រៀបការម្នាក់បានធ្វើការរំលូតកូនចេញ។

.....ឃ) ម្តាយម្នាក់បង្កើតបានកូនដែលមានកាយសម្បទាមិនប្រក្រតី

.....ង) អត់ទោសឲ្យខ្លួនអ្នក។

១) ទោសដែលបណ្តាលមកពីអំពើបាប

២) ទោសកើតពីការសន្មត ឬ ទោសដែលបណ្តាលមកពីការសោកស្តាយ

ចិត្តល្វីងជូរចត់ និង ការថ្នាំងថ្នាក់ក្នុងចិត្ត

វត្ថុបំណងទី៦. *យកខគម្ពីរម៉ាថាយ៥:១០-១១ ទៅធ្វើជាដំណោះស្រាយសម្រាប់ភាពជូរចត់ ឬ ការថ្នាំងថ្នាក់ចិត្ត។*

គ្មានអ្វីដែលអាចប្លន់យកជ័យជម្នះខាងឯវិញ្ញាណរបស់គ្រិស្តបរិស័ទបានជាងចិត្តល្វីងជូរចត់ និង ការថ្នាំងថ្នាក់ក្នុងចិត្តទាស់ជាមួយនឹងនរណាម្នាក់ដែលធ្វើខុសចំពោះគេនោះឡើយ។ ចិត្តល្វីងជូរចត់ប្រៀបដូចជាដង្កូវដែលស៊ីចូលទៅគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិតរបស់អ្នក ដូច្នេះវាធ្វើឲ្យគ្រប់សកម្មភាពរបស់អ្នកគឺត្រូវបានជំរុញដោយក្តីស្អប់ដ៏ស្អុយរលួយដែលអ្នកមានទៅលើអ្នកណាដែលបំពានមកលើអ្នក។ ចិត្តល្វីងជូរចត់ និង ចិត្តថ្នាំងថ្នាក់ គឺជាខ្នាតពីរយ៉ាងនៃកំហឹង។

ថ្មីៗនេះខ្ញុំបានអានអំពីបុរសជាគ្រិស្តបរិស័ទដ៏ល្អម្នាក់ ដែលជីវិតរបស់គាត់ជាច្រើនឆ្នាំមកនេះពោរពេញដោយបញ្ហាលំបាក។ កូនប្រុសរបស់គាត់បានស្លាប់តាំងពីនៅជាទារក មិនយូរប៉ុន្មានក្រោយមកទៀតផ្ទះរបស់គាត់ត្រូវបានឆេះគ្មានសល់ ហើយគាត់បាត់បង់អ្វីៗគ្រប់យ៉ាងដែលគាត់មាន ក្រោយមកទៀតប្រពន្ធរបស់គាត់បានស្លាប់ក្រោយពីរងការឈឺចាប់ជាយូរដោយសារតែជំងឺដែលបានទាមទារឲ្យមានការចំណាយទៅលើថ្លៃការព្យាបាលអស់ជាច្រើន។ ផលផ្លែនៃព្រះវិញ្ញាណ ត្រូវបានបង្ហាញឲ្យឃើញចេញពីក្នុងជីវិតរបស់គាត់ នៅពេលដែលគាត់ឆ្លងកាត់បញ្ហាគ្រប់បែបយ៉ាង។ អស់រយៈពេលជាច្រើនឆ្នាំ គាត់បានបង្រៀននៅថ្នាក់មនុស្សចាស់ថ្ងៃអាទិត្យ នៅក្នុងក្រុមជំនុំរបស់គាត់ ហើយមានជីវិតជាច្រើនទទួលបានការប៉ះពាល់ ដោយសារតែវិញ្ញាណដ៏ទន់ភ្លន់ និង ជំនឿដ៏រឹងមាំរបស់គាត់។

ថ្ងៃមួយ មានអ្នកជំនួយម្នាក់ដែលបានអង្គុយនៅក្នុងថ្នាក់របស់គាត់ មានអារម្មណ៍ថា ព័ន្ធកិច្ចនៃការបង្រៀនរបស់គាត់ គ្មានប្រសិទ្ធិភាពទៀតទេ។ អ្នកជំនួយម្នាក់នោះបានដើរនិយាយប្រាប់គេថា គ្រូរបស់ពួកគេគ្មានសមត្ថភាពដូចមុននោះទេ ហើយពួកគេគួរតែប្តូរគ្រូថ្មីទៅ។ នៅពេលដែលពាក្យសំដី ថាមានសមាជិកនៅក្នុងថ្នាក់របស់គាត់មិនពេញចិត្តជាមួយការបង្រៀនរបស់គាត់ទៀតនោះ គាត់ក៏កើតមានការឈឺចាប់យ៉ាងខ្លាំង។ ដោយសារតែការនេះ គាត់ក៏ចាប់ផ្តើមកើតមានវិញ្ញាណជូរចត់ និង ថ្នាំងថ្នាក់ជាមួយនឹងបុរសម្នាក់ ដែលនិយាយរិះគន់គាត់នោះ។ គាត់អាចតស៊ូគ្រប់បញ្ហាទាំងអស់របស់គាត់ទាំងអស់មកដល់ចំណុចនេះ ប៉ុន្តែនៅពេលដែលគាត់ត្រូវបានគេវាយប្រហារដោយផ្ទាល់ គាត់មិនអាចទទួលយកវាបាននោះទេ។ គាត់ក៏បានផ្តាច់ខ្លួនចេញពីសកម្មភាពទាំងអស់របស់ក្រុមជំនុំ ហើយមានពេញដោយការបាក់ទឹកចិត្តយ៉ាងខ្លាំង។ គាត់បានអនុញ្ញាតឲ្យចិត្តល្វីងជូរចត់ គាប់សង្កត់មកលើគំនិតរបសគាត់ រហូតដល់គាត់គិតពីវារាល់ថ្ងៃ។ គាត់ធ្លាប់តែជាព្រះពរសម្រាប់ក្រុមជំនុំ តែឥឡូវនេះគាត់បែរទៅជាមនុស្សដែលខាកចិត្តជាមួយនឹងក្រុមជំនុំទៅវិញ។

នៅក្នុងមេរៀនទី៤ យើងបាននិយាយអំពីភាពអយុត្តិធម៌ និងអំពីរបៀបដែលគ្រិស្តបរិស័ទគួរតែឆ្លើយតបទៅនឹងរឿងទាំងអស់នោះ។ប្រសិនបើបុរសម្នាក់នេះធ្វើតាមគម្ពីរម៉ាថាយ៥:១០-១២ នៅក្នុងបញ្ហារបស់គាត់ នោះគាត់ប្រហែលជាអាចជៀសផុតពីចិត្តជូរចត់ និង ការបាក់ទឹកចិត្តដែលកើតមានឡើងនោះបាន។ គម្ពីរអេភេសូ ៤:៣១ បានប្រាប់យើងឲ្យ "កំចាត់ចិត្តជូរចត់ ចិត្តក្តៅក្រហាយ កំហឹង សំរែកឡូឡា ពាក្យជេរប្រមាថ ព្រមទាំងសេចក្តីអាក្រក់គ្រប់បែបយ៉ាង"។ នៅក្នុងគម្ពីរហេប្រឺ១២:១៥ បានចែងថា៖ "ចូរប្រយ័ត្នប្រយែង ក្រែងលោមានបងប្អូនណាម្នាក់ឃ្លាតចេញពីព្រះគុណរបស់
ព្រះជាម្ចាស់។ មិនត្រូវទុកអោយការអាស្រូវចាក់ឫស ដុះឡើងបណ្តាលអោយកើតរឿងរ៉ាវ ហើយបំពុលចិត្តគំនិតបងប្អូនជាច្រើននោះឡើយ។"

លំហាត់អនុវត្តន៍

១០ ចូរជ្រើសរើសចម្លើយត្រឹមត្រូវ។ ចិត្តជូរចត់ និង ចិត្តថ្នាំងថ្នាក់ មិនត្រឹមតែអាចនាំទៅរកការបាក់ទឹកចិត្ត និង ប្លន់យកជ័យជម្នះខាងឯវិញ្ញាណរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែបើយោងទៅតាមការបញ្ជាក់របស់ខគម្ពីរខាងលើ វាក៏ជា

ក) ឥរិយាបថដែលបង្កឲ្យមានបញ្ហា និង នាំឲ្យមនុស្សជាច្រើនរងការឈឺចាប់ផងដែរ។

ខ) អ្វីម្យ៉ាងដែលយើងត្រូវរំពឹងទុកថានឹងកើតមានម្តងហើយម្តងទៀត ព្រោះមនុស្សនឹងធ្វើអ្វីគ្រប់យ៉ាងដើម្បីធ្វើឲ្យយើងឈឺចាប់។

គ) កំហុសរបស់បុគ្គលដែលធ្វើឲ្យមានភាពជូរចត់នេះកើតឡើង។

ដំណោះស្រាយតែមួយគត់សម្រាប់វិញ្ញាណជូរចត់ ឬ ថ្នាំងថ្នាក់ទាស់នឹងនរណាម្នាក់គឺ ការអត់ទោសឲ្យគេ។ ព្រះយេស៊ូបានមានព្រះបន្ទូលប្រាប់សាវ័ករបស់ទ្រង់ថា "បើអ្នករាល់គ្នាអត់ទោសអោយមនុស្សលោក ព្រះបិតារបស់អ្នករាល់គ្នានៅស្ថានបរមសុខ* ក៏អត់ទោសអោយអ្នករាល់គ្នាដែរ។ ប៉ុន្តែ បើអ្នករាល់គ្នាមិនអត់ទោសអោយមនុស្សលោកទេនោះ ព្រះបិតារបស់អ្នករាល់គ្នា ក៏មិនអត់ទោសអោយអ្នករាល់គ្នាដែរ" (គម្ពីរម៉ាថាយ ៦:១៤-១៥) ។ នៅកន្លែងផ្សេងមួយទៀត ទ្រង់បានប្រាប់ពួកគេថា៖ "ចូរស្រឡាញ់ខ្មាំងសត្រូវរបស់ខ្លួន និងធ្វើអំពើល្អដល់អស់អ្នកដែលស្អប់អ្នករាល់គ្នា ត្រូវជូនពរដល់អស់អ្នកដែលប្រទេចផ្តាសាអ្នករាល់គ្នា និងអង្វរព្រះជាម្ចាស់ សូមទ្រង់ប្រទានពរដល់អស់អ្នកដែលបៀតបៀនអ្នករាល់គ្នា" (គម្ពីរលូកា ៦:២៧-២៨)។ បើអ្នកធ្វើតាមការណែនាំនេះ និង អធិស្ឋានសម្រាប់អ្នកដែលបានធ្វើខុសចំពោះអ្នក នោះអ្នកមិនអាចប្រកាន់ចិត្តជូរចត់ទាស់នឹងបុគ្គលនោះ ក្នុងពេលជាមួយគ្នានោះបានទេ។ នៅពេលដែលអ្នកអធិស្ឋានសម្រាប់នរណាម្នាក់ ព្រះអម្ចាស់នឹងប្រទានក្តីស្រឡាញ់ដ៏ពិតដើម្បីឲ្យអ្នកបានផ្តល់ក្តីស្រឡាញ់នោះទៅឲ្យពួកគេផងដែរ។

ចិត្តជូរចត់ ក៏អាចបែរសំដៅទៅទាស់នឹងព្រះជាម្ចាស់ផងដែរ។ ពេលខ្លះ ការនេះកើតឡើង ក៏ដោយសារតែយើងបន្ទោសព្រះជាម្ចាស់សម្រាប់បញ្ហារបស់យើង ដោយមិនស្វែងរកប្រភពពិតរបស់បញ្ហានោះ។ ដូច្នេះ មិនចាំបាច់ឆ្ងល់ទេថា ហេតុអ្វីបានជាមនុស្សដែលផ្ទុកភាពជូរចត់នៅក្នុងចិត្តរបស់គេ ងាយទទួលបានការបាក់ទឹកចិត្តគ្រប់ដណ្តប់ម្ល៉េះ។ ចិត្តជូរចត់ មិនត្រឹមតែប៉ះពាល់ដល់ផ្នែករូបកាយរបស់យើងនោះទេ ប៉ុន្តែវាក៏ធ្វើឲ្យវិញ្ញាណរបស់យើងរីងរៃផងដែរ។ ផលប៉ះពាល់ដ៏ធំបំផុតគឺកើតទៅលើអ្នកណាដែលអនុញ្ញាតឲ្យចិត្តជូរចត់គ្រប់គ្រងពួកគេ ហើយអ្នកដែលបង្កឲ្យមានស្ថានភាពដែលនាំទៅរកចិត្តជូរចត់នោះប្រហែលមិនបានដឹងខ្លួនថា ពួកគេបានធ្វើឲ្យមានការខូចខាតខ្លាំងប៉ុនណានោះទេ។

លំហាត់អនុវត្តន៍

---

១១ សូមអានគម្ពីរម៉ាថាយ ៥:១០-១២ ។ ចូរយកខគម្ពីរនេះទៅប្រើនៅក្នុងបញ្ហានៃចិត្តជូរចត់ និងចិត្តថ្នាំងថ្នាក់ ហើយបកស្រាយពីឥទ្ធិពលដែលខគម្ពីរអាចមានទៅលើបញ្ហានេះ។

.....

.....

គ. ការការពារមិនឲ្យបាក់ទឹកចិត្ត

វត្ថុបំណងទី៧. *ជ្រើសរើសពាក្យត្រឹមត្រូវ ដែលនិយាយទាក់ទងពីរបៀបនៃការការពារមិនឲ្យមានការបាក់ទឹកចិត្ត។*

តើមានមធ្យោបាយអ្វីដើម្បីការពារមិនឲ្យមានការបាក់ទឹកចិត្តដែរឬទេ? តើយើងអាចមើលឃើញការបាក់ទឹកចិត្តនោះចូលមក ហើយឈានជើងដើម្បីគេចពីវាដែរឬទេ? ខ្ញុំជឿថា ពិតជាមានផ្លូវដែលគ្រិស្តបរិស័ទអាចត្រៀមខ្លួនតយុទ្ធជាមួយនឹងការបាក់ទឹកចិត្ត និង អាចស្គាល់ពីអាការៈនៃការបាក់ទឹកចិត្តមុនពេលដែលវាមកគ្របដណ្តប់លើពួកគេបាន។

ខាងក្រោមនេះគឺជាគោលការណ៍ដែលយើងគួរតែចងចាំនៅក្នុងចិត្ត នៅពេលដែលយើងគិតអំពីរបៀបក្នុងការការពារមិនឲ្យបាក់ទឹកចិត្ត៖

១. យើងមិនគួរអនុញ្ញាត ឲ្យអំពើបាបដែលមិនទាន់បានសារភាពបន្តមានវត្តមាននៅក្នុងជីវិតរបស់យើងឡើយ។ អំពើបាបនឹងនាំមកនូវការបាក់ទឹកចិត្ត និង ភាពសោកសៅ។ មធ្យោបាយតែមួយគត់ ដើម្បីបំបាត់ការបាក់ទឹកចិត្ត គឺត្រូវយកអំពើបាបចេញ។

២. ការបាក់ទឹកចិត្តទាំងអស់ មិនមែនសុទ្ធតែអំពើបាបនោះទេ។ ព្រះគ្រិស្តបានជ្រាបយល់ពីការឈឺចាប់ក្នុងព្រះទ័យនៅពេលដែលទ្រង់ព្រះកន្សែងនឹកអាណិតក្រុងយេរូសាឡឹម (គម្ពីរលូកា ១៩:៤១)។ នៅពេលដែលទ្រង់បានយាងទៅឯសួនកេតសេម៉ានី ព្រះគម្ពីរបានចែងប្រាប់យើងថា៖ "ព្រះអង្គនាំលោកពេត្រុស លោកយ៉ាកុប និងលោកយ៉ូហាន ទៅជាមួយ។ ពេលនោះ ព្រះអង្គចាប់ផ្តើមភ័យតក់ស្លុត ព្រមទាំងចុកចាប់អន្ទះសាពន់ប្រមាណ។ ព្រះអង្គមានព្រះបន្ទូលទៅកាន់អ្នកទាំងបីថា៖ «ខ្ញុំព្រួយចិត្តយ៉ាងខ្លាំងស្ទើរតែស្លាប់ អ្នករាល់គ្នានៅទីនេះសិនហើយ ចូរប្រុងស្មារតី"។ (គម្ពីរម៉ាកុស ១៤:៣៣-៣៤) ។ លោកយ៉ូបមិនបាន ប្រព្រឹត្តិអំពើបាបទាស់នឹងព្រះជាម្ចាស់ទេ ប៉ុន្តែលោកបានទទួលការបាក់ទឹកចិត្តយ៉ាងខ្លាំង (គម្ពីរយ៉ូប ជំពូក៣) ។ ប្រសិនបើភាពសោកសៅបែរសំដៅទៅរកខាងក្នុងចិត្តយើង នោះវានឹងបង្កឲ្យមានការបាក់ទឹកចិត្ត។ ប៉ុន្តែបើយើង សម្លឹងទៅរកព្រះជាម្ចាស់នៅពេលដែលយើងមានទុក្ខព្រួយ នោះទ្រង់នឹងជំនួសភាពសោកសៅរបស់យើងដោយក្តីអំណររបស់ទ្រង់វិញ។

៣. ពួកយើងគឺជាភាវៈដែលមានវិញ្ញាណ ក៏ដូចជាភាវៈដែលមានរូបកាយផងដែរ។ ការលះបង់ជ្រុលភាពនឿយហត់ ការសម្រាកច្រើនពេក របបអាហារ និង លំហាត់ប្រាណ ទាំងអស់នេះសុទ្ធតែអាចនាំទៅរកការបាក់ទឹកចិត្ត។ ការធ្វេសប្រហែសនៅក្នុងជីវិតខាងឯវិញ្ញាណរបស់យើង ដូចជាការធ្វេសប្រហែសក្នុងការថ្វាយបង្គំ ការអានព្រះគម្ពីរ ការសញ្ជឹងគិត និង ការអធិស្ឋាន នឹងធ្វើឲ្យយើងទន់ខ្សោយ ហើយធ្វើឲ្យយើងងាយរងគ្រោះទៅនឹងការវាយប្រហាររបស់សាតាំង។

៤. រាល់ពេលដែលយើងមានបញ្ហា យើងគួរស្គាល់ពីមូលហេតុបង្ក ហើយស្វែងរកដំណោះស្រាយដែលសមរម្យ ឲ្យបានឆាប់តាមតែអាចធ្វើទៅបាន។ នៅពេលដែលបញ្ហា មិនមានការដោះ ស្រាយកាន់តែគរច្រើនឡើង នោះយើងងាយនឹងចុះចាញ់ណាស់។

៥. មានវិធីព្យាបាលមួយ ដោយការចេញទៅរកមនុស្សណាដែលកំពុងតែត្រូវការ។ ចូរសម្លឹងមើលទៅខាងក្រៅ ដោយកុំសម្លឹងមើលទៅក្នុង និង រស់នៅតែក្នុងភាពតានតឹង ឬ ការឈឺចាប់របស់អ្នកខ្លួនឯង។ បញ្ហាដែលអ្នកកំពុងប្រឈមមុខ នឹងផ្តល់ឲ្យអ្នកនូវ អារម្មណ៍ពិសេសដើម្បីដឹងពីអស់អ្នកណាដែលកំពុងឈឺចាប់ ហើយអ្នកអាចក្លាយជាការបើកសំដែងពីក្តីស្រឡាញ់របស់ព្រះគ្រិស្ត នៅក្នុងជីវិតរបស់ពួកគេ។ ការបាក់ទឹកចិត្តរបស់អ្នក នឹងត្រូវបានជំនួសវិញដោយអំណរក្នុងការបម្រើព្រះជាម្ចាស់ និង ការជួយអ្នកដទៃ។ ហេតុផលនេះហើយដែលយើងត្រូវតែសកម្មនៅក្នុងសមាគមគ្រិស្តបរិស័ទ ដូចជាក្រុមជំនុំដែលជាកន្លែងអ្នកជឿអាចបង្ហាញ ការខ្វល់ខ្វាយ និង បម្រើគ្នាទៅវិញទៅមក។

៦. មនុស្សដែលអនុវត្តនូវការអត់ទោស នឹងបានយល់ពីសេរីភាពផុតពីភាពតានតឹងរបស់ចិត្តជូរចត់ និង ការថ្នាំងថ្នាក់ ។ ពួកគេពិតជាបានដឹងថា តើក្តីស្រឡាញ់គឺជាអ្វី និងមិនមែនជាអ្វី (គម្ពីរ ១កូរិនថូសជំពូក១៣)។

ក្តីសន្យារបស់ព្រះជាម្ចាស់នៅក្នុងគម្ពីរ១កូរិនថូស១០:១៣ បានជួយខ្ញុំជាច្រើនលើកច្រើនសារ ឲ្យទទួលបានកម្លាំងរបស់ទ្រង់ដើម្បីបានមើលផុតពីគ្រាមានទុក្ខលំបាក ហើយទ្រង់មិនដែលធ្វើឲ្យខ្ញុំខកចិត្តឡើយ៖

> គ្មានការល្បួងណាមួយកើតមានដល់បងប្អូន ក្រៅពីការល្បួងដែលមនុស្សលោកតែងជួបប្រទះនោះឡើយ។ ព្រះជាម្ចាស់មានព្រះហឫទ័យស្មោះត្រង់ ទ្រង់មិនបណ្តោយអោយមារ*ល្បួងបងប្អូនហួសពីកម្លាំងបងប្អូនទេ ប៉ុន្តែ នៅពេលបងប្អូនជួបការល្បួង ព្រះអង្គនឹងប្រទានមធ្យោបាយអោយបងប្អូនចេញរួច និងអោយបងប្អូនអាចទ្រាំទ្របាន។

លំហាត់អនុវត្តន៍

---

១២ តើគោលការណ៍អ្វីខ្លះ ដែលអ្នកអាចទាញចេញពីបទគម្ពីរនេះ ដើម្បីការពារមិនឲ្យមានការបាក់ទឹកចិត្ត?

.....

.....

ពេលខ្លះការប្រឹក្សាយោបល់របស់គ្រិស្តបរិស័ទគឺមានសារៈសំខាន់ណាស់ដើម្បីជួយមនុស្សម្នាក់ឲ្យការពារ និង យកឈ្នះការបាក់ទឹកចិត្តបាន។ ប្រសិនបើអ្នកមិនអាចរកឃើញ ភាពធូរស្រាលតាមរយៈមធ្យោបាយទាំងប៉ុន្មានដែលយើងបានណែនាំនៅត្រង់ចំណុចនេះទេ សូមកុំស្ទក់ស្ទើរក្នុងការស្វែងរកជំនួយពីនរណាដែលបានបណ្តុះបណ្តាលសម្រាប់ផ្តល់ជំនួយប្រភេទនេះ។

លំហាត់អនុវត្តន៍

១៣ ចូរគូសរង្វង់ជុំវិញប្រយោគត្រឹមត្រូវ ដែលទាក់ទងនឹងការបាក់ទឹកចិត្ត។

ក) ការលើកលែងទោស ផ្តល់ឲ្យមានភាពធូរស្រាលផុតពីអារម្មណ៍មានទោស និង ចិត្តជូរចត់។

ខ) បញ្ហាដែលមិនបានដោះស្រាយ ធ្វើឲ្យមានស្ថានភាពមួយដែលការបាក់ទឹកចិត្តអាចកើតឡើងបានយ៉ាងងាយ។

គ) ការធ្វេសប្រហែសខាងឯវិញ្ញាណ ងាយនឹងនាំឲ្យមានការបាក់ទឹកចិត្ត ជាងការធ្វេសប្រហែសខាងឯរូបកាយ។

ឃ) ការបាក់ទឹកចិត្ត តែងតែជាប់ទាក់ទងទៅនឹងអំពើបាប។

ង) យើងអាចយកឈ្នះការបាក់ទឹកចិត្តបានយ៉ាងងាយ បើយើងសម្លឹងមើលទៅកាន់ព្រះជាម្ចាស់ជា ជាងការសម្លឹងមកមើលពីខ្លួនឯង។

ច) ព្រះយេស៊ូបានបង្ហាញយើងពីរបៀប តយុទ្ធជាមួយនឹងការបាក់ទឹកចិត្តតាមរយៈគំរូរបស់ទ្រង់នៅឯសួនកេតសេម៉ានី។

ឆ) ពេលខ្លះការរងទុក្ខផ្ទាល់ខ្លួនរបស់យើង អាចជួយយើងឲ្យបម្រើអស់អ្នកដែលកំពុងរងទុក្ខបានល្អ។

ឃ. ការជួយអ្នកដទៃ

វត្ថុបំណងទី៨. *ស្គាល់ពីសកម្មភាពទាំងឡាយណាដែលអាចផ្តល់នូវជំនួយយ៉ាងល្អ ទៅដល់អ្នកដែលកំពុងរងការបាក់ទឹកចិត្ត។*

នៅពេលដែលលោកយ៉ូបបានរងទុក្ខជាមួយបញ្ហារបស់គាត់ (គម្ពីរយ៉ូបជំពូក១ និង ជំពូក២) ព្រះគម្ពីរបានប្រាប់យើងដូចតទៅនេះ៖

> មិត្តភក្តិបីនាក់របស់លោកយ៉ូប បានឮដំណឹងពីទុក្ខវេទនាដែលកើតមានចំពោះលោក ពួកគេចាកចេញពីស្រុករៀងៗខ្លួន ដោយមូលមតិគ្នាទៅរំលែកទុក្ខ និងជួយលើកទឹកចិត្តលោក។ អ្នកទាំងនោះ គឺលោកអេលីផាសជាអ្នកស្រុកថេម៉ាន លោកប៊ីលដាដជាអ្នកស្រុកស៊ូអា និងលោក សូផារជាអ្នកស្រុកណាអាម៉ា។ ពេលក្រឡេកពីចម្ងាយ អ្នកទាំងបីមើលលោកយ៉ូបលែងស្គាល់ទៀតហើយ។ ដូច្នេះ ពួកគេនាំគ្នាទ្រហោយំ ហែកអាវធំរបស់ខ្លួន និងយកធូលីដីបាចនៅលើក្បាល។ អ្នកទាំងបីអង្គុយផ្ទាល់នឹងដីជាមួយលោក អស់រយៈពេលប្រាំពីរថ្ងៃ ប្រាំពីរយប់ ឥតនិយាយអ្វីមួយម៉ាត់ទៅកាន់លោកឡើយ ព្រោះពួកគេឃើញលោកឈឺចាប់ឥតឧបមា។
>
> (យ៉ូប ២:១១-១៣)

ប្រសិនបើអ្នកបានអានគម្ពីរយ៉ូប អ្នកនឹងឃើញថា មិត្តភក្តិរបស់លោកយ៉ូបមិនបាននៅស្ងៀមស្ងាត់ក្នុងពេលលោកមានទុក្ខនោះទេ។ ផ្ទុយទៅវិញ ពួកគេបានបន្ថែមទៅលើទុក្ខព្រួយរបស់លោក ដោយស្តីបន្ទោស និង ចោទប្រកាន់លោកថា បានប្រព្រឹត្តបាបទាស់នឹងព្រះជាម្ចាស់ថែមទៀតផង។

មធ្យោយដ៏ល្អបំផុតដើម្បីជួយអ្នកដែលរងការបាក់ទឹកចិត្តខ្លាំង គឺដោយការស្រឡាញ់ ឥរិយាបថនៃការយកចិត្តទុកដាក់ ដោយគ្រាន់តែនៅជាមួយគេដើម្បីបង្ហាញពីការគាំទ្រ និង ការខ្វល់ខ្វាយ។ មនុស្សកំពុងរងទុក្ខ មិនត្រូវការនរណាម្នាក់ ដែលនឹងមកបន្ថែមពីលើទុក្ខព្រួយរបស់គេ ដូចជាមិត្តភក្តិរបស់លោកយ៉ូបបានធ្វើនោះទេ។ គេត្រូវការតែមិត្តភក្តិម្នាក់ដែលនឹងមិនវាយតម្លៃគេ ដែលនឹងជួយគេស្វែងរកមូលហេតុនៃការបាក់ទឹកចិត្តរបស់គេ នៅពេលដែលគេត្រៀមខ្លួនប្រឈមមុខជាមួយវា និងគាំទ្រគេនៅពេលដែលគេឈានជំហានដ៏ចាំបាច់ ដើម្បីយកឈ្នះលើស្ថានភាពបាក់ទឹកចិត្តរបស់គេ។

យើងបានរៀបរាប់ការបាក់ទឹកចិត្តថាជា ការបាត់បង់អំណរ ការបាត់បង់ភាពក្លៀវក្លា ការមានអារម្មណ៍សោកសង្រេង និង ជាគ្រានៃភាពអសកម្ម។ មនុស្សដែលបាក់ទឹកចិត្ត តែងតែខ្វះកម្លាំង និងខ្វះបំណងចិត្តចង់ងើបឲ្យផុតពីស្ថានភាពរបស់ពួកគេ។ អ្នកណាដែលនឹងនិយាយទៅកាន់គេថា "ខ្ញុំដឹងថាអ្នកឈឺចាប់ ខ្ញុំចង់ឲ្យអ្នកដឹងថាខ្ញុំខ្វល់ខ្វាយពីអ្នក តើមានអ្វីដែលខ្ញុំអាចជួយអ្នកបានដែរឬទេ?" និង អ្នកណាដែលត្រៀមខ្លួនដើម្បីអធិស្ឋាន ដើម្បីនឹងសម្រក់ទឹកភ្នែក ដើម្បីនឹងបង្ហាញក្តីស្រឡាញ់ មនុស្សបែបនេះប្រហែលជាឧបករណ៍របស់ព្រះជាម្ចាស់ សម្រាប់ស្រោចស្រង់ព្រលឹងនោះឲ្យផុតពីជម្រៅនៃភាពអស់សង្ឃឹម ដើម្បីផ្តល់ព្រះពរជ័យតាមរយៈព្រះគ្រិស្ត។

តួនាទីរបស់អ្នកជួយគឺ ការលើកទឹកចិត្ត និង ផ្តល់ក្តីសង្ឃឹម។ ប្រសិនបើមានអំពើបាបដែលមិនទាន់បានសារភាព សូមអនុញ្ញាតឲ្យព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូល និង ដឹកនាំទៅរកការលន់តួ។ មានការប្រោសលោះមួយនៅក្នុងព្រះគ្រិស្ត។ នៅពេលដែលសម្ពាធនៅក្នុងជីវិតហាក់បីដូចជាលើសពីសមត្ថភាពអ្នកអាចទ្រាំទ្រ ចូរឲ្យយើងរាល់គ្នា រំឭកគ្នាទៅវិញទៅមកជាមួយនឹងបទគម្ពីរទាំងនេះដែលបានមកពីលោកសាវ័កប៉ូល៖

> គេសង្កត់សង្កិនយើងគ្រប់យ៉ាងមែន តែយើងមិនភ័យបារម្ភអ្វីឡើយ យើងទ័លច្រកមែន តែយើងនៅតែទៅមុខរួច គេបៀតបៀនយើងមែន តែព្រះជាម្ចាស់មិនបោះបង់យើងចោលឡើយ គេ វាយដំយើងមែន តែយើងមិនស្លាប់បាត់បង់ជីវិតឡើយ។....ហេតុនេះហើយបានជាយើងមិនបាក់ទឹកចិត្តឡើយ ទោះបីរូបកាយរបស់យើងចេះតែទ្រុឌទ្រោមទៅៗក៏ដោយ ក៏ជំរៅចិត្តយើងកាន់តែចំរើនឡើងជារៀងរាល់ថ្ងៃដែរ ដ្បិតទុក្ខលំបាកបន្តិចបន្តួចដែលយើងជួបប្រទះម្តងម្កាលនោះ ធ្វើអោយយើងមានសិរីរុងរឿងដ៏ប្រសើរលើសលប់ ជាសិរីរុងរឿងនៅស្ថិតស្ថេរអស់កល្បជានិច្ច ដែលរកអ្វីមកប្រៀបផ្ទឹមពុំបាន។ (គម្ពីរ២កូរិនថូស ៤:៨-៩, ១៦-១៧)

លំហាត់អនុវត្តន៍

១៤ តើឥរិយាបថ ឬ សកម្មភាពណាខ្លះនៅខាងក្រោមនេះ អាចផ្តល់នូវជំនួយយ៉ាងល្អ សម្រាប់អ្នកដែលកំពុងរងទុក្ខ? ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវ។

ក) ការខ្វល់ខ្វាយ
ខ) បង្ហាញក្តីស្រឡាញ់
គ) វាយតម្លៃ
ឃ) ឲ្យយោបល់អំពីមូលហេតុដែលគាត់រងការបាក់ទឹកចិត្ត
ង) ស្តាប់
ច) នៅជាមួយ
ឆ) ស្ម័គ្រចិត្តចែករំលែកទុក្ខព្រួយ
ជ) ទុកឲ្យគាត់នៅតែម្នាក់ឯង
ឈ) គាំទ្រគាត់
ញ) ផ្តល់ជំនួយ
ដ) ផ្តល់ការកំសាន្តចិត្ត និង ក្តីសង្ឃឹម
ថ) លើកទឹកចិត្តគាត់

ការប្រឡងផ្ទាល់ខ្លួន

ត្រូវ/ខុស។ ចូរសរសេរអក្សរ ត នៅមុខចម្លើយដែលត្រឹមត្រូវ និង អក្សរខនៅខាងមុខចម្លើយដែលខុស។

.....១ ការបាក់ទឹកចិត្តមានជាប់ទាក់ទងទៅនឹង គំនិត អារម្មណ៍ និង សកម្មភាព អវិជ្ជមាន។

.....២ ការបាក់ទឹកចិត្តគឺជាអារម្មណ៍ទាំងឡាយណា ដែលក្រៀមក្រំ ឬ ការខកចិត្ត ដែលមនុស្សម្នាក់បានឆ្លងកាត់។

.....៣ មនុស្សដែលបាក់ទឹកចិត្តតែងតែធ្វើការសម្រេចចិត្តយ៉ាងរហ័ស។

.....៤ អាការៈទាំងបីយ៉ាងនៃការបាក់ទឹកចិត្តគឺមាន ការគេងមិនលក់ បាត់បង់ចំណាប់អារម្មណ៍ទៅលើរបស់ដែលតែងតែធ្វើឲ្យរីករាយ និង ភាពក្រៀមក្រំយ៉ាងខ្លាំង។

.....៥ ការបាក់ទឹកចិត្តអាចជាអាការៈនៃជំងឺផង និង អាចជាលទ្ធផលដែលមកពីជំងឺផងដែរ។

.....៦ មានទំនាក់ទំនងមួយរវាង បរិមាណនៃភាពតានតឹងដែលប្រមូលផ្តុំនៅក្នុងមនុស្សម្នាក់ និង លទ្ធភាពដែលអាចនាំឲ្យពួកគេរងគ្រោះពីជំងឺធ្ងន់ធ្ងរ និង ការបាក់ទឹកចិត្ត។

.....៧ ពេលខ្លះការបាក់ទឹកចិត្ត កើតឡើងដោយសារតែមនុស្ស ស្តីបន្ទោសខ្លួនឯងសម្រាប់រឿងរ៉ាវដែលកើតឡើងនៅក្នុងជីវិត ដែលពួកគេមិនអាចគ្រប់គ្រងបាន។

.....៨ ការគិតល្អចំពោះខ្លួនឯង គឺមានជួបទាក់ទងនឹងការបាក់ទឹកចិត្ត។

.....៩ តាមរយៈព្រះបន្ទូលរបស់ព្រះយេស៊ូក្នុងគម្ពីរយ៉ូហាន ១៤:១ យើងមានការធានាវ៉ាប់រងថាចិត្តដែលមានបញ្ហា អាចត្រូវបានព្យាបាលបានដោយគ្រាន់តែជឿលើព្រះជាម្ចាស់។

.....១០ មធ្យោបាយដែលល្អបំផុត ដើម្បីកាត់បន្ថយភាពតានតឹង គឺត្រៀមខ្លួនខាងឯវិញ្ញាណ ដើម្បីប្រឈមមុខជាមួយនឹងបញ្ហាជីវិត។

.....១១ ការព្យាបាលសម្រាប់ភាពភ័យខ្លាច គឺកម្លាំងចិត្ត។

.....១២ នៅពេលណាដែលយើងមានអារម្មណ៍ថាមានទោស យើងដឹងថា យើងបានធ្វើអ្វីម្យ៉ាងខុសហើយ។

.....១៣ មនុស្សអាចគេចផុតពីទោសកំហុស ដែលមានភ្ជាប់ជាមួយនឹងការសោកស្តាយចំពោះរឿងពីអតីតកាល នៅពេលដែលពួកគេទទួលស្គាល់ការអត់ទោសបាបរបស់ព្រះគ្រិស្ត ហើយក្រោយមកគេបានអត់ទោសសម្រាប់ខ្លួនឯងផងដែរ។

.....១៤ អស់អ្នកដែលងាយរងរបួសដោយសារតែអារម្មណ៍ថ្នាំងថ្នាក់ ឬ អារម្មណ៍ជូរចត់ គឺជាមនុស្សដែលបានអនុញ្ញាតឲ្យអារម្មណ៍ទាំងនោះបន្តស្ថិតនៅក្នុងដួងចិត្តរបស់ពួកគេ។

.....១៥ មធ្យោបាយដែលល្អបំផុតដើម្បី ដកអារម្មណ៍ជូរចត់ចេញពីក្នុងចិត្តទាស់នឹងនរណាម្នាក់ គឺការអធិស្ឋានឲ្យអ្នកនោះ ។

ចម្លើយខ្លីៗ ។ ចូរបំពេញចន្លោះបន្ទាត់នីមួយៗ ដើម្បីបំពេញអត្ថន័យគោលការណ៍អំពីការការពារមិនឲ្យមានការបាក់ទឹកចិត្តទាំងនេះ ។

១៦ យើងមិនងាយនឹងរងការបាក់ទឹកចិត្តនោះទេ ប្រសិនបើយើងថែទាំ.....
.....និង
.....សុខភាពរបស់យើង។

១៧ យើងមិនអនុញ្ញាតឲ្យមាន.....ដែលមិនទាន់បានសារភាព បន្តស្ថិតនៅក្នុងជីវិតរបស់យើងនោះទេ។

១៨ យើងអាចជួយខ្លួនយើងបាន នៅពេលដែលយើង.....អ្នកដទៃដែលកំពុងត្រូវការ។

១៩ យើងគួរតែព្យាយាម .....បញ្ហានីមួយៗនៅពេលដែលវាកើតឡើង ដើម្បីឲ្យយើងអាចជៀសផុតពីការប្រមូលផ្តុំភាពតានតឹង ។

២០ វាមានសារៈសំខាន់ណាស់ដែលយើងត្រូវ ជំនួសអារម្មណ៍ជូរចត់ និង អារម្មណ៍ថ្នាំងថ្នាក់ ដោយ.....

២១ នៅក្នុងគ្រាមានទុក្ខ យើងត្រូវអនុញ្ញាតឲ្យព្រះជាម្ចាស់ ដកយកការទួញសោករបស់យើង ហើយជំនួសវិញដោយ .....របស់ទ្រង់ ដែលនឹងផ្តល់ឲ្យយើងនូវកម្លាំងដ៏អស្ចារ្យ។

២២ ចូររៀបរាប់របៀបបីយ៉ាងដែលយើងអាចជួយនរណាម្នាក់ដែលកំពុងតែរងទុក្ខដោយសារការបាក់ទឹកចិត្ត។

.....
.....
.....

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

៨ ចម្លើយរបស់អ្នក។ វាគួរតែរួមបញ្ចូលគំនិតទាំងនេះផង៖ ឥរិយាបថដែលមានក្តីស្រឡាញ់ សម្រាប់ព្រះជាម្ចាស់ និង ទុកចិត្តថាទ្រង់នឹងយកឈ្នះលើក្តីភ័យខ្លាចបាន។ យើងអាចមាន ទំនុកចិត្តថានៅក្នុងស្ថានភាពដ៏គួរឲ្យភ័យខ្លាចទាំងអស់ ព្រះគ្រិស្តជាព្រះដែលមានជ័យជម្នះ ទ្រង់គង់នៅជាមួយយើង ហើយក្តីស្រឡាញ់របស់ទ្រង់គាំទ្រយើង។

១ ក), គ), ង) និង ឆ) ជាចម្លើយត្រឹមត្រូវ។

៩ ក) ២) ទោសកើតពីការសន្មត ឬ ទោសដែលបណ្តាលមកពីការសោកស្តាយ
ខ) ១) ទោសដែលបណ្តាលមកពីអំពើបាប
គ) ១) ទោសដែលបណ្តាលមកពីអំពើបាប
ឃ) ២) ទោសកើតពីការសន្មត ឬ ទោសដែលបណ្តាលមកពីការសោកស្តាយ
ង) ២) ទោសកើតពីការសន្មត ឬ ទោសដែលបណ្តាលមកពីការសោកស្តាយ

២ អាការៈនៃការបាក់ទឹកចិត្ត នឹងបន្តកើតមានក្នុងរយៈពេលជាយូរ។ (មនុស្សយើងភាគច្រើនពេលខ្លះមានថ្ងៃដែលមិនសប្បាយចិត្ត។ ការបាក់ទឹកចិត្តគឺជាស្ថានភាពមួយដែលកើតមានឡើងលើយើង ម្តងបន្តិចៗ ហើយនឹងនៅជាប់ក្នុងរយៈពេលជាយូរ។)

១០ ក) ឥរិយាបថដែលបង្កឲ្យមានបញ្ហា និង នាំឲ្យមនុស្សជាច្រើនរងការឈឺចាប់ផងដែរ។

៣ ការបាក់ទឹកចិត្តអាចជា*អាការៈ* នៃបញ្ហាខាងឯរូបកាយ វាអាចជា*លទ្ធផល*នៃបញ្ហាខាងឯរូបកាយ ឬ ជាលទ្ធផលនៃការមើលថែខ្លួនប្រាណមិនបានល្អ។

១១ ចម្លើយរបស់អ្នក។ ប្រសិនបើយើងអាចដឹង និង ចងចាំថា ព្រះអម្ចាស់*ប្រទានពរ*យើងនៅពេលដែលយើងទ្រាំទ្រជាមួយនឹងការប្រមាថមើលងាយ និង ការប្រៀតប្រៀនផ្សេងទៀត ដោយឥរិយាបថដូចជាព្រះគ្រិស្ត នោះយើងក៏ពិតជាអាចទទួលបានអារម្មណ៍មានអំណរសប្បាយ ទោះបីជានៅពេលដែលមនុស្សទាស់ប្រឆាំងជាមួយយើង ដោយសារតែយើងដឹងថា ព្រះគ្រិស្តគឺ ជាព្រះដ៏មានជ័យជម្នះរបស់យើង ហើយទ្រង់នឹងមិនទាស់ប្រឆាំងនឹងយើងឡើយ។ ជ័យជម្នះរបស់យើងលើអារម្មណ៍ជូរចត់ នឹងធ្វើឲ្យយើងក្លាយជាព្រះពរសម្រាប់អ្នកដទៃ។

៤ ទីមួយ ធ្វើការពិនិត្យសុខភាព ដើម្បីឲ្យដឹងថាតើមានបញ្ហាខាងឯរូបកាយដែរឬទេ។ ទីពីរ នៅពេលដែលការបាក់ទឹកចិត្តកើតមានឡើង ជា*លទ្ធផល*បានមកពីការប្រឈមមុខជាមួយបញ្ហាខាងឯរូបកាយ នោះព្រះបន្ទូលរបស់ព្រះជាម្ចាស់នឹងជួយយើង សម្របខ្លួនជាមួយនឹងបញ្ហាដោយឥរិយាបថត្រឹមត្រូវ។ ទីបី ការហាត់ប្រាណ របបអាហារ និង ការសម្រាកឲ្យបានត្រឹម ត្រូវប្រហែលជាអ្វីដែលយើងត្រូវការ ដើម្បីជៀសឲ្យផុតពីការបាក់ទឹកចិត្ត។

១២ ចម្លើយរបស់អ្នក។ បទគម្ពីរនេះបានថ្លែងមកកាន់ខ្ញុំថា៖ មិនថាបញ្ហា ឬ ការសាកល្បងអ្វីដែលខ្ញុំកំពុងឆ្លងកាត់នោះទេ ព្រះជាម្ចាស់បានជួយអ្នកដទៃ តាមរយៈរបៀបដូចគ្នានេះរួចទៅហើយ *ទ្រង់ក៏នឹងជួយខ្ញុំផងដែរ។*

៥ ខ) មានពេលដែលត្រូវកើតទុក្ខ ប៉ុន្តែព្រះអម្ចាស់អាចជំនួសការកើតទុក្ខរបស់យើងជាមួយនឹងអំណាររបស់ទ្រង់បាន។

១៣ ក) ត្រូវ

ខ) ត្រូវ

គ) ខុស

ឃ) ខុស

ង) ត្រូវ

ច) ត្រូវ

ឆ) ត្រូវ (សូមមើលនៅក្នុងគម្ពីរ២កូរិនថូស ១:១-១១)

៦ គ) នៅពេលដែលភាពតានតឹងកើនឡើង យើងគួរតែបង្កើនការប្រុងប្រៀបខាងឯវិញ្ញាណជាមួយគ្នាផងដែរ៖ គឺចំណាយពេលឲ្យច្រើនសម្រាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងសម្រាប់ការ អធិស្ឋានផងដែរ។

១៤ សកម្មភាពទាំងអស់នេះអាចមានប្រយោជន៍ទាំងអស់ លើកលែងតែ ចម្លើយ គ), ឃ), និង ជ)

៧ ទស្សនៈនេះបានមើលរំលងរឿងដែលថា ព្រះជាម្ចាស់ទ្រង់គង់នៅគ្រប់គ្រងលើជីវិតរបស់យើង ហើយទ្រង់នឹងមិនដាក់បន្ទុកឲ្យយើងលើសសមត្ថភាពរបស់យើងនោះទេ។

មេរៀនទី ៧

ការរងទុក្ខ និង សេចក្តីស្លាប់

មានក្មេងប្រុសម្នាក់បានសរសេរសំបុត្រទៅកាន់ព្រះជាម្ចាស់ថា៖ "ឱព្រះជាម្ចាស់អើយ ប្រសិនបើពិតជាមានជីវិតមួយទៀតនៅក្រោយពេលស្លាប់មែន ចុះហេតុអ្វីបានជាយើងចាំបាច់ស្លាប់ធ្វើអ្វី?"

យើងមិនចូលចិត្តនិយាយពីសេចក្តីស្លាប់នោះទេ។ ប្រសិនបើ មានមនុស្សជាទីស្រឡាញ់របស់អ្នកមកនិយាយប្រាប់អ្នកថា " ថ្ងៃនេះខ្ញុំចង់និយាយអំពីអ្វីដែលអ្នកគួរធ្វើ នៅពេលដែលខ្ញុំស្លាប់ទៅ" តើអ្នកសុខចិត្តនៅពិភាក្សាអំពីរឿងនោះទេ? ឬមួយក៏អ្នកព្យាយាមបញ្ឈៀសមិននិយាយអំពីប្រធានបទដែលមិនគួរឲ្យសប្បាយចិត្តមួយនេះទៅវិញ? យើងឃើញថា ការទទួលស្គាល់រឿងដែលថា ថ្ងៃណាមួយ យើង ឬមួយមនុស្សដែលយើងស្រឡាញ់នឹងត្រូវស្លាប់នោះ គឺពិតជាពិបាកទទួលយកណាស់។ យើងអាចនឹងគិតថា ប្រសិនបើយើងបដិសេធមិននិយាយអំពីវានោះ វានឹងមិនកើតឡើងចំពោះយើងឡើយ។

សម្រាប់គ្រិស្តបរិស័ទ សេចក្តីស្លាប់មិនត្រូវបានចាត់ទុកថាជាបញ្ហានោះទេ។ ដូចដែលលោកប៉ូលបានមានប្រសាសន៍ថា៖ "ចំពោះខ្ញុំ បើរស់ ខ្ញុំរស់រួមជាមួយព្រះគ្រិស្ត ហើយបើស្លាប់ ខ្ញុំក៏បានចំណេញដែរ។" (គម្ពីរភីលីព ១:២១)។ សេចក្តីស្លាប់មិនមែនជាទីបញ្ចប់នោះទេ ប៉ុន្តែជាការចាប់ផ្តើមវិញ! ប៉ុន្តែសម្រាប់មនុស្សចាស់ក្តី ឬ ក្មេងក្តី ដំណើរការនៃការស្លាប់គឺពិតជាគួរឲ្យខ្លាចណាស់ ព្រោះយើងខ្លាចការឈឺចាប់ និង ការរងទុក្ខ។

នៅក្នុងមេរៀនទី១ យើងបានស្វែងយល់សំណួរដែលសួរថា៖ "ហេតុអ្វីបានជាគ្រិស្តបរិស័ទរងទុក្ខ?" ហេតុអ្វីបានជាយើងត្រូវឆ្លងកាត់ការឈឺចាប់?" "ហេតុអ្វីបានជាជីវិតពោរពេញទៅដោយភាពសោកសៅ?" ឥឡូវនេះគោលបំណងរបស់យើង គឺចង់ពិភាក្សាអំពីរបៀបដែលការរងទុក្ខ និង សេចក្តីស្លាប់នាំបញ្ហាមកក្នុងជីវិតរបស់មនុស្ស និង អំពីរបៀបដែលគ្រិស្តបរិស័ទគួរប្រឈមមុខជាមួយបញ្ហាទាំងនេះ។ របៀបដែលយើងឆ្លើយតបទៅនឹង បទពិសោធន៍ឈឺចាប់ គឺជារឿងសំខាន់បំផុត នៅពេលដែលយើងគិតអំពីវា នៅក្នុងពន្លឺនៃភាពអស់កល្បជានិច្ច។

គម្រោងមេរៀន

ក. គុណប្រយោជន៍នៃការឈឺចាប់ និង ការរងទុក្ខ
ខ. បញ្ហាដែលទាក់ទងទៅនឹងការរងទុក្ខ និង សេចក្តីស្លាប់
គ. ការជួយអ្នកកំពុងរងទុក្ខ និង អ្នកជិតស្លាប់
ឃ. បញ្ហាដែលទាក់ទងនឹងសេចក្តីស្លាប់
ង. ចក្ខុវិស័យមួយរបស់គ្រិស្តបរិស័ទ

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. លើកឧទាហរណ៍បីយ៉ាងអំពីគុណប្រយោជន៍នៃការឈឺចាប់ និង ការរងទុក្ខ។
២. បកស្រាយអំពីអ្វីដែលជួយឲ្យលោកយ៉ូបអាចរក្សាឥរិយាបថវិជ្ជមានបាន ទោះបីនៅពេលគាត់ស៊ូទ្រាំជាមួយនឹងការឈឺចាប់ដ៏ធំធេងមួយក៏ដោយ។
៣. ធ្វើការប្រៀបធៀបបញ្ហាដែលច្រើនតែកើតឡើងចំពោះអ្នកជំងឺ ទៅជាមួយនឹងបញ្ហាដែលអ្នកធ្លាប់បានឆ្លងកាត់ដោយផ្ទាល់នៅពេលដែលអ្នកឈឺ។
៤. ស្គាល់ពីដំណាក់កាលនៃការប្រឈមជាមួយនឹង ជំងឺដំណាក់កាលចុងក្រោយ និង របៀបដែលដំណឹងល្អអាចធ្វើឲ្យមានការផ្លាស់ប្តូរសម្រាប់អ្នកដែលមានជំងឺដំណាក់កាលចុងក្រោយនោះ។
៥. ជ្រើសរើសពាក្យសំដីពិតប្រាកដ ទាក់ទងនឹងមធ្យោបាយគ្រិស្តបរិស័ទអាចជួយអស់អ្នកដែលកំពុងរងទុក្ខ និង ជិតស្លាប់បាន។
៦. ដោយយោងទៅតាមគម្ពីរ១កូរិនថូស ១៥:៥៥-៥៧ អ្នកអាចធ្វើការបកស្រាយអំពីកម្លាំង និង សេចក្តីសុខសាន្ត ដែលញាតិមិត្តរបស់អ្នកស្លាប់ទទួលបាននៅពេលដែលគ្រិស្តបរិស័ទម្នាក់បានស្លាប់។
៧. ថ្លែងប្រាប់ពីគោលការណ៍មួយផ្អែកទៅលើគំរូរបស់ព្រះគ្រិស្ត ដែលអាចដឹកនាំផ្លូវរបស់គ្រិស្តបរិស័ទនៅពេលដែលពួកគេប្រឈមមុខជាមួយនឹងការរងទុក្ខ និង សេចក្តីស្លាប់។
៨. ស្គាល់ពីគោលការណ៍ចម្បងដែលឆ្លុះបញ្ចាំងពីឥរិយាបថរបស់គ្រិស្តបរិស័ទ ទៅចំពោះការរងទុក្ខ និង សេចក្តីស្លាប់។

សកម្មភាពក្នុងការសិក្សា

១. អានគម្ពីរអេសាយ ៥២:១៣-១៥ និង គម្ពីរអេសាយ ៥៣។ ចូរអានកណ្ឌគម្ពីរយ៉ូប បន្ថែមពីលើទៀតក៏បាន។

២. សិក្សានិង ធ្វើលំហាត់នៅក្នុងមេរៀន ទៅតាមរបៀបដូចមុន។ ត្រូវពិនិត្យមើលនិយមន័យនៃពាក្យសំខាន់ដែលអ្នកមិនស្គាល់ និង ឆ្លើយសំណួរសិក្សាទាំងអស់ មុនពេលទៅមើលចម្លើយដែលយើងបានផ្តល់ជូន។

៣. ធ្វើការប្រឡងផ្ទាល់ខ្លួន ហើយផ្ទៀតផ្ទាត់ចម្លើយរបស់អ្នក។

ពាក្យសំខាន់

ក្តៅក្រហាយ	រោគវិនិច្ឆ័យ	កើតរោគ
ថ្នាំបន្សាប	ប្រពលភាព	អាការរោគ
ដែលត្រូវបានគេស្លាប់ចោល	ការកាត់ផ្តាច់ចេញ	ខ្ពស់បំផុត

ក. គុណប្រយោជន៍នៃការឈឺចាប់ និង ការរងទុក្ខ

វត្ថុបំណងទី១. *លើកឧទាហរណ៍បីយ៉ាងអំពីគុណប្រយោជន៍នៃការឈឺចាប់ និង ការរងទុក្ខ។*

អ្នកប្រហែលជាគិតថា៖ "តើការឈឺចាប់ និង ការរងទុក្ខ អាចមានគុណប្រយោជន៍បានដោយរបៀបណា?" ប្រសិនបើការឈឺចាប់ គឺជាផលនៃអំពើបាបដែលបានចូលមកក្នុងពិភពលោកនេះមែន តើវាមិនមែនជាការអាក្រក់ទាំងស្រុងទេឬអី? តើអាចមានគុណប្រយោជន៍អ្វីទៅ នៅក្នុងរឿងដែលអាក្រក់យ៉ាងនេះ? ប្រាកដណាស់ វាពិតជាមានប្រយោជន៍ខ្លះដែលបានមកពីការឈឺចាប់ ទាំងខាងឯរូបកាយ និង ខាងឯវិញ្ញាណ។

គុណប្រយោជន៍ខាងឯរូបកាយ

តើក្មេងប្រុសតូចម្នាក់ អាចដឹងថាភ្លើងមានគ្រោះថ្នាក់បានដោយរបៀបណា? ដោយការដាក់ដៃរបស់គេទៅជិតភ្លើងនោះ! នៅពេលដែលគេធ្វើដូច្នេះ មានញាណខាងឯរូបកាយមួយដែលយើងហៅថា ការឈឺចាប់ ។ ការឈឺចាប់គឺពិបាកទ្រាំណាស់។ នៅពេលដែលយើងទទួលអារម្មណ៍ ឈឺចាប់ យើងចង់ធ្វើអ្វីម្យ៉ាងដើម្បីបញ្ឈប់វា។ ការឈឺចាប់កើតមានឡើងគឺដើម្បីប្រាប់យើងថា មានបញ្ហាដែលយើងត្រូវប្រឈមមុខជាមួយ។ នៅពេលដែលក្មេងប្រុសនោះមានអារម្មណ៍ឈឺចាប់ ដោយសារតែភ្លើង គេដោះស្រាយបញ្ហានោះ ដោយដកដៃរបស់គេយ៉ាងលឿនចេញពីភ្លើង។ នៅពេលដែលមានការឈឺចាប់ នៅផ្នែកណាមួយនៃរាងកាយរបស់យើង យើងព្យាយាមធ្វើអ្វីដែលយើងអាចធ្វើបានដើម្បីឲ្យបានដឹងថា ហេតុអ្វីបានជាយើងមានអារម្មណ៍ឈឺចាប់ ហើយរកមធ្យោបាយដកវាចេញឲ្យឆាយ។

នៅពេលដែលព្រះជាម្ចាស់បង្កើតមនុស្ស ទ្រង់មិនបានកំណត់ថាយើងត្រូវតែទទួលការឈឺចាប់នោះទេ។ ប៉ុន្តែដោយសារតែអំពើបាប ព្រះជាម្ចាស់បានដាក់ញាណនៃការឈឺចាប់មក ដើម្បីជាការព្រមានពីអ្វីដែលអាចធ្វើបាប និង បំផ្លាញរូបកាយរបស់យើង។ ប្រសិនបើយើងគ្មានការឈឺចាប់នោះទេ យើងមិនអាចការពារខ្លួនយើង ឲ្យផុតពីមេរោគ ជំងឺ ឬ ការវាយប្រហារផ្សេងៗទៀតមកលើរូបកាយរបស់យើងបានទេ។

គុណប្រយោជន៍ខាងឯវិញ្ញាណ

ចំពោះបញ្ហានៃការឈឺចាប់នេះ លោក ស៊ី អែស លូវីស (C.S. Lewis) បាននិយាយថា៖ "ព្រះជាម្ចាស់ខ្សឹបដាក់ត្រចៀកយើង នៅពេលដែលយើងសប្បាយចិត្ត មានព្រះបន្ទូលនៅក្នុងមនសិការរបស់យើង ប៉ុន្តែទ្រង់ស្រែកនៅក្នុងការឈឺចាប់របស់យើង" (១៩៩៦, ៩១) ។ ការឈឺចាប់ធ្វើឲ្យមានការរងទុក្ខ ហើយយើងមិនអាចធ្វើព្រងើយបានឡើយ។

លំហាត់អនុវត្តន៍

---

១. គុណប្រយោជន៍ខាងឯវិញ្ញាណនៃការឈឺចាប់ គឺមានលក្ខណៈស្រដៀង នឹងគុណប្រយោជន៍ខាងឯរូបកាយផងដែរ។ ដោយប្រើពាក្យរបស់អ្នក ចូរបកស្រាយថាតើលក្ខណៈនោះជាអ្វី?

.....

មនុស្សខ្លះ បែរទៅរកព្រះជាម្ចាស់ នៅពេលដែលមានអាសន្នតែប៉ុណ្ណោះ។ នៅពេលដែលអ្វីៗល្អប្រសើរ ពួកគេមានអារម្មណ៍ថាខ្លួនឯងគ្រប់គ្រាន់។ ប៉ុន្តែការរងទុក្ខធ្វើឲ្យពួកគេដឹងខ្លួនថា មានរឿងខ្លះដែលនៅហួសពីអំណាចគ្រប់គ្រងរបស់ពួកគេផ្ទាល់ ហើយ នៅក្នុងភាពជុនដាប ពួកគេបែរទៅរកព្រះជាម្ចាស់ដើម្បីរកជំនួយ។ ពិតណាស់ ព្រះជាម្ចាស់សព្វព្រះហឫទ័យណាស់ នៅពេលដែលយើងទុកចិត្តលើទ្រង់ ហើយថ្វាយបង្គំទ្រង់ ដោយសារតែទ្រង់គឺជាព្រះជាម្ចាស់ និង ស័ក្តិសមទទួលក្តីស្រឡាញ់របស់យើង ប៉ុន្តែវានឹងអស្ចារ្យយ៉ាងណាទៅ សូម្បីតែនៅពេលយើងបែរចេញទៅតាមផ្លូវរបស់យើង ហើយលែងស្គាល់ពីសិទ្ធិរបស់ទ្រង់ដែលជាព្រះអម្ចាស់ និង ម្ចាស់នៃយើងហើយ ទ្រង់នៅតែស្រឡាញ់យើងយ៉ាងខ្លាំង ដែលទ្រង់នឹងនាំយើងចូលទៅកាន់ទ្រង់ តាមមធ្យោបាយគ្រប់បែបយ៉ាងទាំងអស់។ ប្រសិនបើតាមរយៈការឈឺចាប់ និង ការរងទុក្ខនេះ ព្រះជាម្ចាស់អាចឈោងចាប់ខ្ញុំ និង សង្គ្រោះខ្ញុំឲ្យផុតពីអំពើបាប និង សេចក្តីស្លាប់អស់កល្បជានិច្ចបាន តើវាមិនមែនជាគុណប្រយោជន៍ដ៏អស្ចារ្យនៃការរងទុក្ខនោះទេឬអី? ហេតុនេះហើយបានជាលោកសាវ័កប៉ូលអាចនិយាយបានថា៖ "ខ្ញុំយល់ឃើញថា ទុក្ខលំបាកនាបច្ចុប្បន្នកាល ពុំអាចប្រៀបផ្ទឹមនឹងសិរីរុងរឿង ដែលព្រះជាម្ចាស់សំដែងអោយយើងឃើញ នៅអនាគតកាលនោះបានឡើយ។" (គម្ពីររ៉ូម ៨:១៨)

ព្រះជាម្ចាស់ជ្រាបថា ការសម្រេចចិត្តដ៏សំខាន់បំផុតនៅក្នុងជីវិតរបស់យើងគឺត្រូវស្រឡាញ់ និង បម្រើទ្រង់។ ប្រសិនបើយើងមិនអាចធ្វើការសម្រេចចិត្តនោះបានទេ ទីបញ្ចប់របស់យើងនឹងជាការឈឺចាប់ដ៏គួរឲ្យសោកស្តាយជារៀងរហូត។ ប្រសិនបើទ្រង់អាចទទួលបានការយកចិត្តទុកដាក់ និង ការស្តាប់បង្គាប់របស់យើងតាមបំណងព្រះហឫទ័យរបស់ទ្រង់ដោយគ្រាន់តែអនុញ្ញាតឲ្យយើង រងទុក្ខនោះ យើងគួរតែអរព្រះគុណទ្រង់ ដែលទ្រង់ស្រឡាញ់យើងយ៉ាងខ្លាំងដូច្នេះ!

លំហាត់អនុវត្តន៍

---

២ ចូរជ្រើសរើសប្រយោគបំពេញដែលល្អបំផុត។ យើងអាចសំដែងពីផ្នត់គំនិតខាងលើនេះ ដោយនិយាយថា វាអាចធៀបទៅនឹងឪពុកដែលប្រកបដោយក្តីស្រឡាញ់ ដែលនឹង

ក) បង្ហាញក្តីស្រឡាញ់របស់គាត់ ដោយមិនដែលស្តីបន្ទោស ឬ ដាក់ទណ្ឌកម្មកូនប្រុសរបស់គាត់ឡើយ។

ខ) ផ្តល់ឲ្យកូនប្រុសរបស់គាត់នូវអ្វីដែលល្អបំផុត ដើម្បីទទួលបានការស្តាប់បង្គាប់ពីកូនរបស់គាត់។

គ) ប្រៀនប្រដៅកូនប្រុសរបស់គាត់ យ៉ាងច្រើនទៅតាមការគួរ ដើម្បីបង្រៀនគេថាគេគួរមានអាកប្បកិរិយាបែបណា។

គុណប្រយោជន៍ខាងឯវិញ្ញាណមួយទៀត នៃការរងទុក្ខ ដែលយើងបានពិភាក្សាគ្នានៅក្នុងមេរៀនទី១ រួចមកហើយនោះគឺថា អ្នកដែលធ្លាប់បានឆ្លងកាត់ការរងទុក្ខ គឺជាអ្នកកំសាន្តចិត្តដ៏ល្អបំផុត (សូមមើលនៅក្នុងគម្ពីរ២កូរិនថូស ១:៣-៦)។ យើងមានចិត្តគំនិតដូចអស់អ្នកដែលឆ្លងកាត់បទពិសោធន៍ដែលបានឆ្លងកាត់ដែរ។ ក្នុងនាមជាសមាជិកនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត យើងទទួលបញ្ជារឲ្យជួយរំលែកទុក្ខធុរៈគ្នា

ទៅវិញទៅមក(គម្ពីរកាឡាទី ៦:២) ឲ្យយំសោកជាមួយនឹងអ្នកណាដែលយំសោក (គម្ពីររ៉ូម១២:១៥) និង ឲ្យអធិស្ឋានសម្រាប់អស់អ្នកដែលកំពុងឈឺចាប់ (គម្ពីរយ៉ាកុប ៥:១៦)។ លោកសាវ័កប៉ូលបានមាន ប្រសាសន៍អំពីការនេះនៅក្នុងគម្ពីរ១កូរិនថូសជំពូក១២ថា៖ "ទោះបីមានសរីរាង្គច្រើនយ៉ាងណាក៏ដោយ ក៏ សរីរាង្គទាំងអស់ផ្សំគ្នាជារូបកាយតែមួយដែរ។...ប្រសិនបើមានសរីរាង្គណាមួយឈឺចុកចាប់ សរីរាង្គទាំង អស់ក៏ឈឺចុកចាប់ជាមួយដែរ...បងប្អូនជាព្រះកាយរបស់ព្រះគ្រិស្ត ហើយម្នាក់ៗជាសរីរាង្គនៃព្រះកាយនេះ តាមចំណែករៀងៗខ្លួន។" (ខ១២, ២៦,២៧)។

នៅក្នុងមេរៀនទី១ យើងក៏បានឃើញថា ការរងទុក្ខចូលមកក្នុងជីវិតរបស់យើងដើម្បីបន្សុទ្ធយើង និង ស្តែងបញ្ជាក់ពីជំនឿរបស់យើង (គម្ពីរ១ពេត្រុស ១:៦-៧) និងដើម្បីបង្កើតបានជាលក្ខណសម្បត្តិរបស់ព្រះ គ្រិស្តនៅក្នុងយើង (គម្ពីរ២កូរិនថូស ៤:៧-១០)។ នៅពេលដែលយើងមើលទៅក្នុងភាពត្រចះត្រចង់ នៃ ប្រយោជន៍ដ៏អស់កល្បនិច្ចរបស់យើងនោះ គុណប្រយោជន៍ខាងវិញ្ញាណដែលបានមកពីការរងទុក្ខ គឺធ្ងន់ លើសអស់ការឈឺចាប់ និង សេចក្តីវេទនា ដែលយើងត្រូវបានដាក់ឲ្យទទួលរងនោះទៅ ទៀត។

លំហាត់អនុវត្តន៍

---

៣ ចូរលើកឧទាហរណ៍មួយ អំពីគុណប្រយោជន៍នៃការឈឺចាប់ដែលមានតម្លៃទាំងខាងឯរូបកាយ និង ខាងឯវិញ្ញាណ។

.....

៤ ចូរលើកឧទាហរណ៍ពីរផ្សេងទៀតនៃគុណប្រយោជន៍ខាងឯវិញ្ញាណនៃការឈឺចាប់។

.....

.....

ខ. បញ្ហាដែលទាក់ទងទៅនឹងការរងទុក្ខ និង សេចក្តីស្លាប់

ដូចដែលយើងបានឃើញនៅក្នុងមេរៀនមុនៗហើយ ការទុក្ខលំបាកអាចមានទម្រង់ច្រើនបែប។ វា អាចជាការរងទុក្ខខាងឯរូបកាយ ឬ ផ្លូវអារម្មណ៍។ យើងរងទុក្ខដោយសារតែជំងឺ ដោយសារតែភាព អយុត្តិធម៌ ដោយសារតែគ្រោះធម្មជាតិ ដោយសារតែអំពើបាបរបស់យើងផ្ទាល់ និង ដោយសារតែមូល ហេតុជាច្រើនផ្សេងទៀត។ នៅទូទាំងមេរៀននេះ យើងបានពិភាក្សាអំពីបញ្ហាពិសេសៗ ដែលធ្វើឲ្យយើង មានទុក្ខ។ ឥឡូវនេះ យើងផ្តោតគំនិតរបស់យើង ទៅលើបញ្ហាដែលទាក់ទងនឹងការឈឺចាប់ ជំងឺ ការជិត ស្លាប់ និង ការស្លាប់។

ការឈឺចាប់

វត្ថុបំណងទី២. *បកស្រាយអំពីអ្វីដែលជួយឲ្យលោកយ៉ូបអាចរក្សាឥរិយាបថវិជ្ជមានបាន ទោះបីនៅពេលគាត់ស៊ូទ្រាំជាមួយនឹងការឈឺចាប់ដ៏ធំធេងមួយក៏ដោយ។*

វាគឺជារឿងធម្មតា ដែលត្រូវខ្លាចការឈឺចាប់ ហើយព្យាយាមជៀសឲ្យផុតពីវា។ វាគឺជាបទពិសោធន៍មួយដែលជួយបើកភ្នែកឲ្យឃើញកាន់តែច្បាស់ នៅពេលដែលយើងដើរកាត់សាលមន្ទីរពេទ្យ ហើយមើលឃើញពីទុក្ខវេទនា និង ការលំបាកនៃជំងឺរោគា។ គ្រូគង្វាលម្នាក់បាននិយាយប្រាប់ខ្ញុំពីការដែលគាត់ទៅសួរសុខទុក្ខឯមន្ទីរពេទ្យសម្រាប់មនុស្សមានរោគវិកលចរឹត(រោគចិត្ត)។ នៅពេលដែលគាត់បានឃើញព្រលឹងទទួលរងទណ្ឌកម្មដែលត្រូវបានកាត់ផ្តាច់ពីសេចក្តីពិត ដោយមានអ្នកខ្លះត្រូវបានគេចងជាប់ទៅនឹងគ្រែរបស់ពួកគេដើម្បីកុំឲ្យពួកគេធ្វើបាបខ្លួនឯង និងអ្នកដទៃ នោះដួងចិត្តរបស់គាត់ត្រូវបានខ្ទិចខ្ទាំដោយសារតែការឈឺចាប់ និង ទុក្ខសោករបស់ពួកគេ។ ក្រោយមកគាត់ក៏បានទៅឯមន្ទីរពេទ្យយោធាមួយដែលគាត់បានឃើញគ្រែជាជួរតម្រៀបគ្នាហើយពេញដោយបុរសវ័យក្មេង ជាជនរងគ្រោះដោយសារតែសង្គ្រាម។ មានអ្នកខ្លះត្រូវខ្វាក់ភ្នែក អ្នកខ្លះទៀតពិការដៃ ឬ ពិការជើង ហើយអ្នកខ្លះទៀតទៅជាខ្វិន។ សាជាថ្មីម្តងទៀត គាត់ក៏ចុកចាប់ក្នុងចិត្តដោយសារការឈឺចាប់របស់គេ។

ការឈឺចាប់អាចរារាំងមិនឲ្យយើងអាច ដំណើរការប្រក្រតីបាន។ វាអាចប៉ះពាល់ទៅដល់អាកប្បកិរិយារបស់យើង ឥរិយាបថរបស់យើងទៅចំពោះអ្នកដទៃ និង ការដែលយើងមើលមកកាន់ខ្លួនឯង។ ការឈឺចាប់ដែលបន្តនៅជាប់ឃ្យូរ អាចបំបាក់ទឹកចិត្ត និង ធ្វើឲ្យយើងអស់សង្ឃឹម។

កណ្ឌគម្ពីរយ៉ូបផ្តល់ឲ្យយើងនូវឧទាហរណ៍ដ៏ល្អប្រសើរ អំពីបុរសម្នាក់ដែលរងការឈឺចាប់យ៉ាងខ្លាំង។ លោកយ៉ូបគឺជាមនុស្សរបស់ព្រះជាម្ចាស់ដែលគាត់បានបាត់បង់ទ្រព្យសម្បត្តិទាំងអស់របស់គាត់។ កូនៗទាំងអស់របស់គាត់បានស្លាប់នៅក្នុងគ្រោះមហន្តរាយដ៏គួរឲ្យខ្លាច។ បន្ទាប់មក គាត់បានរងទុក្ខខាងឯរូបកាយ ដោយចេញដំបៅដ៏គួរឲ្យខ្លាច។ ការរងទុក្ខរបស់គាត់បាននាំគាត់ឲ្យចូលទៅក្នុងជម្រៅនៃក្តីអស់សង្ឃឹម។ មានពេលខ្លះគាត់មានអារម្មណ៍ថាព្រះជាម្ចាស់នៅឆ្ងាយពីគាត់។ ទោះជាយ៉ាងណា នៅក្នុងរឿងទាំងនេះ គាត់នៅតែ រក្សាជំនឿរបស់គាត់នៅក្នុងព្រះជាម្ចាស់បាន។ គាត់បានថ្វាយបង្គំព្រះជាម្ចាស់ទោះបីនៅក្នុងបញ្ហារបស់គាត់ក៏ដោយ។ (គម្ពីរយ៉ូប ១:២១-២២)។

មិនមែនមនុស្សគ្រប់គ្នាអាចឆ្លើយតបទៅនឹងការឈឺចាប់ ដូចដែលលោកយ៉ូបអាចធ្វើបាននោះទេ។ គេអាចមានកំហឹង ការថ្នាំងថ្នាក់ ក្តីសង្ស័យ និង ភាពភ័យខ្លាច។ អ្នកប្រហែលជាអាចលើកឧទាហរណ៍អំពីគ្រិស្តបរិស័ទអ្នកធ្លាប់ស្គាល់ដែលបានឆ្លើយតបទៅនឹងការឈឺចាប់តាមរបៀបផ្សេងៗ ខ្លះវិជ្ជមាន ហើយខ្លះទៀតអវិជ្ជមាន។

លំហាត់អនុវត្តន៍

៥ ចូរលើកយកការឆ្លើយតបអវិជ្ជមានទៅនឹងការឈឺចាប់ចំនួនប្រាំយ៉ាងដែលអាចកើតមាន។

.....

.....

.....

.....

.....

៦ តើមានអ្វីដែលអាចជួយឲ្យលោកយ៉ូបរក្សាឥរិយាបថសមរម្យបាន ទោះបីជានៅអំឡុងពេលដែលគាត់កំពុងស៊ូទ្រាំជាមួយនឹងការឈឺចាប់ក៏ដោយ។

.....

ជំងឺ

វត្ថុបំណងទី៣. *ធ្វើការប្រៀបធៀបបញ្ហាដែលច្រើនតែកើតឡើងចំពោះអ្នកជំងឺ ទៅជាមួយនឹងបញ្ហាដែលអ្នកធ្លាប់បានឆ្លងកាត់ដោយផ្ទាល់នៅពេលដែលអ្នកឈឺ។*

ជំងឺគឺជាបញ្ហាមួយផ្សេងទៀតដែលជះឥទ្ធិពលមកលើយើងទាំងអស់គ្នា តាមកម្រិតខុសគ្នា។ នៅក្នុងបច្ចេកវិទ្យាវេជ្ជសាស្ត្រមានការរីកចម្រើនដ៏អស្ចារ្យជាច្រើនដែលត្រូវបានបង្កើតឡើង ដើម្បីជួយបង្កើនអត្រារស់រានមានជីវិតរបស់មនុស្ស។ មនុស្សជាតិបានតយុទ្ធ និង យកឈ្នះជំងឺជាច្រើនប្រកបដោយភាពជោគជ័យ ប៉ុន្តែមិនថាមនុស្សក្មេងឬចាស់ មានឬក្រ ល្អឬអាក្រក់ ជំងឺនៅតែធ្វើទុក្ខអ្នកទាំងនោះដូចៗគ្នា។ ខាងក្រោមនេះ ជាបញ្ហាជាក់ច្បាស់ខ្លះៗដែលអាចកើតមានទៅលើអ្នកដែលមានជំងឺ។

១. បញ្ហាហិរញ្ញវត្ថុ (ការចំណាយលើការព្យាបាល និង បញ្ហាអសមត្ថភាពធ្វើការសន្សំលុយ)
២. ព្រួយបារម្ភថាខ្លួនឯងជាបន្ទុកសម្រាប់អ្នកដទៃ។
៣. ខ្លាចស្លាប់ និង ភាពមិនប្រាកដប្រជានៅថ្ងៃមុខ។
៤. ខកខានសកម្មភាពរស់នៅធម្មតា។
៥. ខឹងសម្បារ និង ម៉ូម៉ៅ ដោយសារតែមានជំងឺ។
៦. មានការថ្នាំងថ្នាក់ក្នុងចិត្ត ជាមួយអ្នកដែលមានសុខភាពល្អ។
៧. ខូចខាតផែនការ។

អ្នកទទួលខុសត្រូវមើលថែអ្នកជំងឺក៏អាចជួបនឹងបញ្ហាដូចគ្នានេះដែរ។ បន្ថែមពីលើនេះទៀត ពួកគេអាចទទួលរងការលំបាកផ្សេងទៀត ព្រោះពួកគេមានអារម្មណ៍មិនអាចជួយបន្ថយទុក្ខលំបាករបស់អ្នកដែលមានជំងឺនោះបាន។

លំហាត់អនុវត្តន៍

---

៧ ចូរគូសសញ្ញា (✓) នៅមុខបញ្ហារៀបរាប់នៅខាងលើ ដែលអ្នកធ្លាប់បានឆ្លងកាត់ដោយផ្ទាល់។

ក) ចូររៀបរាប់បញ្ហាដទៃផ្សេងទៀតទាក់ទងទៅនឹងជំងឺ ដែលអ្នកធ្លាប់មានពីមុនមក។

.....

.....

ខ) ប្រសិនបើអ្នករកឃើញដំណោះស្រាយសម្រាប់បញ្ហាណាមួយ ចូរប្រាប់ថាតើវាជាអ្វី។ អ្នក ប្រហែលជាត្រូវប្រើប្រាស់សៀវភៅកត់ត្រារបស់អ្នកប្រសិនបើចម្លើយរបស់អ្នកវែង។

.....

ការស្លាប់

វត្ថុបំណងទី៤. *ស្គាល់ពីដំណាក់កាលនៃការប្រឈមជាមួយនឹង ជំងឺដំណាក់កាលចុងក្រោយ និងរបៀបដែល ដំណឹងល្អអាចធ្វើឲ្យមានការផ្លាស់ប្តូរសម្រាប់អ្នកដែលមានជំងឺដំណាក់កាលចុងក្រោយនោះ។*

វេជ្ជបណ្ឌិតម្នាក់ឈ្មោះ អេលីស្សាប៊ែត ខូបប្លឺ រូស (Elisabeth Kubler-Ross) បានធ្វើការស្រាវជ្រាវជាច្រើនទាក់ទងទៅនឹងបញ្ហានៃឥរិយាបថរបស់អ្នកដែលជិតស្លាប់ដោយជំងឺដំណាក់កាលចុងក្រោយ។ នៅក្នុងសៀវភៅរបស់នាង ដែលនិយាយពីការស្លាប់ និង ការជិតស្លាប់*(On Death and Dying)* នាងនិយាយថា អ្នកបានកំណត់ថាមានឥរិយាបថមួយចំនួនដែលច្រើនកើតមានឡើងចំពោះអស់អ្នកដែលដឹងថាខ្លួនឯងជិតស្លាប់ ហើយឥរិយាបថរបស់គេត្រូវបានផ្លាស់ប្តូរបីបួនដំណាក់កាល។ ដំណាក់ទាំងនេះមានដូចតទៅ៖

ដំណាក់កាលទី១៖ ការបដិសេធ

ការឆ្លើយតបដំបូងបង្អស់គឺ "នេះមិនអាចជាការពិតទេ។ រឿងនេះមិនអាចកើតចំពោះខ្ញុំនោះទេ។" ការបដិសេធគឺជាមធ្យោបាយមួយដើម្បីប្រឈមមុខជាមួយនឹងភាពតក់ស្លុតដែលកើតមានឡើង ដោយការដឹងខ្លួនថាសេចក្តីស្លាប់កំពុងខិតជិតមកដល់។ ជារឿយៗ មនុស្សដែលមានជំងឺ បដិសេធមិនព្រមទៅជួបគ្រូពេទ្យដោយសារតែពួកគេភ័យខ្លាចនូវដំណឹងដែលគ្រូពេទ្យអាចនឹងប្រាប់ពួកគេ។ នេះគឺជាទម្រង់មួយនៃការបដិសេធ។

នេះគឺជាបញ្ហាលំបាកមួយផ្សេងទៀតសម្រាប់គ្រិស្តបរិស័ទ ព្រោះទស្សនៈដែលថាយើងជិតស្លាប់នេះវាផ្ទុយពីការដែលយើងធ្លាប់បានដឹងថា ព្រះគ្រិស្តបានប្រទានការប្រោសឲ្យយើងបានជារួចហើយ តាមរយៈការរងទុក្ខ និង ការសុគតរបស់ទ្រង់ផ្ទាល់។ ខ្ញុំធ្លាប់ជិតស្និទ្ធជាមួយអ្នកដែលដឹងខ្លួនថាគេជិតស្លាប់ប៉ុន្តែគេ

នៅតែទុកចិត្តព្រះជាម្ចាស់ដើម្បីទទួលបានការព្យាបាលរបស់ទ្រង់រហូតដល់ពេលដែលពួកគេផុតដង្ហើមទៅ។ខ្ញុំក៏បានស្គាល់មនុស្សខ្លះទៀត ដែលមានជំងឺដំណាក់កាលចុងក្រោយតែទទួលបានការព្យាបាលយ៉ាងអស្ចារ្យ។ យើងគួរតែលើកទឹកចិត្តអ្នកដែលមានជំងឺដំណាក់កាលចុងក្រោយឲ្យគេអធិស្ឋានសុំការប្រោសជំងឺ និងទុកចិត្តព្រះជាម្ចាស់ជានិច្ច ទោះបីជាមានរឿងអ្វីកើតឡើងក៏ដោយ ហើយយើងគួរតែអធិស្ឋាន និង ជឿទុកចិត្តទ្រង់ជាមួយគេផងដែរ។

ការផ្តាច់ខ្លួនចេញពីអ្នកដទៃគឺតែងតែមានជាប់ទាក់ទងជាមួយនឹងការបដិសេធ អ្នកមានជំងឺអាចនឹងត្រូវការពេលវេលាសម្រាប់ខ្លួនគេ ហើយយើងក៏ត្រូវតែស្វែងយល់ឲ្យច្បាស់ពីតម្រូវការពិសេសៗរបស់អ្នកជំងឺដែលកំពុងប្រឈមមុខជាមួយគំនិតដែលគិតថាគេអាចនឹងត្រូវស្លាប់។

ដំណាក់កាលទី២៖ កំហឹង

ការឆ្លើយតបទីពីរគឺ "ហេតុអ្វីជាខ្ញុំ?" នៅពេលដែលមនុស្សដឹងខ្លួនថា បើគ្មានការអស្ចារ្យនោះទេ ពួកគេនឹងត្រូវស្លាប់ វាមើលទៅហាក់បីដូចជារឿងធម្មតាសម្រាប់ពួកគេក្នុងការទាស់ប្រឆាំងជាមួយនឹងផ្នត់គំនិតមួយនេះ។ យើងមានចំណង់ខ្លាំងនៅក្នុងយើង ដើម្បីរស់រានមានជីវិត វាគឺជាផ្នែកមួយនៅក្នុងនិស្ស័យជាមនុស្ស។ មានមូលហេតុជាច្រើនសម្រាប់កំហឹង៖ ជំងឺបានរំខានដល់សកម្មភាពរបស់យើង ផែនការរបស់យើងទៅថ្ងៃអនាគត ក្តីសុបិនរបស់យើង អ្នកដទៃកំពុងតែរស់នៅក្នុងជីវិតពេញបរិបូរណ៍របស់គេ ចំណែកឯជីវិតយើងវិញត្រូវបានកាត់បន្ថយឲ្យខ្លីទៅវិញ នៅមានរឿងជាច្រើនទៀតដែលយើងចង់ធ្វើនៅក្នុងជីវិតរបស់យើង យើងមិនចង់បែកបាក់ពីមនុស្សជាទីស្រឡាញ់របស់យើងជាដើម។

លំហាត់អនុវត្តន៍

---

៨ តើអ្នកគិតថាវាខុសដែរឬទេ ដែលគ្រិស្តបរិស័ទទាស់ប្រឆាំងជាមួយនឹងការដឹងខ្លួនថាគេត្រូវស្លាប់នោះ? ចូរបកស្រាយចម្លើយរបស់អ្នក។

.....

.....

ដំណាក់កាលទី៣៖ ការតថ្លៃ

មនុស្សដែលជិតស្លាប់ជាច្រើនអ្នកត្រូវឆ្លងកាត់ដំណាក់កាលមួយនេះ។ នេះជាឱកាសសម្រាប់គ្រិស្តបរិស័ទដែលមានពិតជាយកចិត្តទុកដាក់ ក្នុងការជួយពួកគេស្វែងរកការ រំដោះខ្លួនឲ្យផុតពីទោសរបស់ពួកគេ ហើយទទួលយកបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបសពួកគេ មិនថាការប្រោសឲ្យជាគឺជា "ផ្នែកមួយនៃការតថ្លៃ" នោះឬអត់នោះទេ។ ពេលខ្លះមនុស្សមានអារម្មណ៍ថាព្រះជាម្ចាស់កំពុងដាក់ទោសពួកគេ។ ពិតណាស់ ដូចដែលយើងបានឃើញនៅក្នុងមេរៀនមុននេះរួចមកហើយថា ទ្រង់អនុញ្ញាតឲ្យយើងឆ្លងកាត់បញ្ហា ដើម្បីប្រៀនប្រដៅយើង ហើយនាំយើងឲ្យចូលទៅកាន់តែជិតទ្រង់។ ប៉ុន្តែព្រះគុណរបស់ទ្រង់មិនផ្អែកទៅលើការតថ្លៃរបស់យើងជាមួយទ្រង់នោះទេ។

ដំណាក់កាលទី៤៖ ការបាក់ទឹកចិត្ត

នៅពេលមនុស្សដែលជិតស្លាប់មិនអាចបដិសេធជំងឺរបស់គេតទៅទៀត នៅពេលដែលអាការៈរបស់ពួកគេកាន់តែធ្ងន់ធ្ងរទៅៗ ហើយជំងឺក៏កាន់តែវិវត្តទៅមុខ ដល់ពេលមួយពួកគេនឹងទទួលអារម្មណ៍មានការបាត់បង់យ៉ាងធំធេង។ ជំងឺអាចនាំឲ្យមានការផ្លាស់ប្តូរជាច្រើននៅក្នុងជីវិតរបស់ពួកគេ ដូចជាបាត់បង់ការងារ វិបត្តិហិរញ្ញវត្ថុ ការឈឺចាប់ និង ផ្សេងៗទៀត។ ចុងក្រោយពួកគេមិនអាចសម្របខ្លួនបាន ហើយពួកគេក៏លិចចូលទៅក្នុងការបាក់ទឹកចិត្ត។ ការបាក់ទឹកចិត្តនេះ គឺទាក់ទងទៅនឹងអ្វីដែលពួកគេបានឆ្លងកាត់រួចមកហើយ ប៉ុន្តែបើយោងទៅតាមវេជ្ជបណ្ឌិត ខូបប្លឺ រូស (Dr. Kubler-Ross) មានដំណាក់កាលនៃការបាក់ទឹកចិត្តមួយទៀតដែលអ្នកមានជំងឺត្រូវមានឱកាសក្នុងការទួញសោកចំពោះរឿងដែលថាពួកគេនឹងត្រូវបានកាត់ផ្តាច់ចេញពីមនុស្ស និង របស់ជាទីស្រឡាញ់របស់ពួកគេ។ នេះមិនមែនជាពេលដែលត្រូវព្យាយាមធ្វើឲ្យពួកគេសប្បាយចិត្តនោះទេ ប៉ុន្តែវាជាពេលដែលត្រូវលួងលោមពួកគេវិញ ហើយបើចាំបាច់ត្រូវទួញសោកជាមួយពួកគេទៀត។ ដំណាក់កាលនេះ ត្រៀមអ្នកជំងឺសម្រាប់អ្វីដែលនឹងមកដល់ ហើយជួយពួកគេឲ្យទទួលស្គាល់ការពិតដែលថាគេអាចនឹង
ស្លាប់។

ដំណាក់កាលទី៥៖ ការទទួលស្គាល់

ចុងបញ្ចប់ មនុស្សដែលជិតស្លាប់ក៏ឈានទៅដល់ដំណាក់កាលនៃការទទួលស្គាល់ ដែលគេហាក់បីដូចជា ដាក់ខ្លួនពួកគេចុះចូលទៅក្នុងគំនិតនៃការស្លាប់ ហើយបែរទៅជាមិនសូវជាចាប់អារម្មណ៍អំពីអ្វីដែលកើតឡើងនៅជុំវិញពួកគេ។ ពួកគេអាចនឹងទៅជា ចាកចេញ និង ផ្តាច់ខ្លួនគេពីអ្នកដទៃទៀត។ ពួកគេបានរំសាយកំហឹងរបស់ពួកគេ ហើយនៅពេលដែលពួកគេអាចនឹងមិនសប្បាយចិត្តនោះ ពួកគេហាក់បីដូចជាមានសន្តិភាពជាមួយនឹងផ្នត់គំនិតនៃសេចក្តីស្លាប់។ នេះគឺជាពេលដែល អស់អ្នក នៅក្បែរមនុស្សជិតស្លាប់នោះ ត្រូវលួងលោមពួកគេឲ្យកាន់តែខ្លាំងបន្ថែមទៀត។

វាក៏ត្រូវបានគេកត់សំគាល់ឃើញថា មនុស្សខ្លះឆ្លងកាត់ដំណាក់កាលទាំងនេះលើសពីម្តងទៅទៀត ឬ ពួកគេអាចឆ្លងពីដំណាក់កាលនីមួយៗនោះទៅវិញទៅមក។ មានការឆ្លើយតបជារឿយៗមួយផ្សេងទៀតដែលកើតមានឡើងនៅលើមនុស្សជាតិ នោះគឺ *សេចក្តីសង្ឃឹម។* មានឃ្លាចំណាស់មួយបានពោលថា៖ "ក្តីសង្ឃឹមគឺជាប្រភពនៃភាពអស់កល្ប ដែលមាននៅក្នុងដួងចិត្តរបស់មនុស្ស"។ មនុស្សដែលជិតស្លាប់អាចមានក្តីសង្ឃឹមថាគ្រូពេទ្យបានធ្វើរោគវិនិច្ឆ័យខុសអំពីជំងឺរបស់គេ ដែលថាអាការៈអាចនឹងបាត់ទៅវិញ ឬ ថាមិនយូរប៉ុន្មានពួកគេនឹងត្រូវបានជាសះស្បើយពីជំងឺរបស់គេ។ នេះប្រហែលជាការឆ្លើយតបរបស់អ្នកដែលមិនមែនជាគ្រិស្តបរិស័ទ ព្រមទាំងអ្នកដែលជាគ្រិស្តបរិស័ទផងដែរ។ ក្តីសង្ឃឹមគឺជាខ្សែដែលរត់កាត់ដំណាក់កាលនីមួយៗ ហើយរក្សាអារម្មណ៍របស់មនុស្សមិនឲ្យមានភាពតានតឹងខ្លាំងពេក។ ប្រាកដណាស់ គ្រិស្តបរិស័ទក៏ត្រូវបានប្រោសប្រទានឲ្យមានក្តីសង្ឃឹមក្នុងជំនឿលើព្រះជាម្ចាស់។ យើងនឹងនិយាយអំពីក្តីសង្ឃឹមរបស់គ្រិស្តបរិស័ទនៅក្នុងមេរៀនបន្ទាប់របស់
យើង។ វាគឺថ្នាំព្យាបាលដ៏ពូកែសម្រាប់បញ្ហានៅក្នុងជីវិតទាំងអស់។

សត្រូវចុងក្រោយបង្អស់ ដែលនឹងត្រូវរំលាយចោលនោះ គឺសេចក្តីស្លាប់។...ជ័យជំនះបានបំបាត់មច្ចុរាជចោលហើយ....ដោយសារព្រះអម្ចាស់យេស៊ូគ្រិស្ត។ (គម្ពីរ១កូរិនថូស ១៥:២៦,៥៤,៥៧)

បញ្ហាដទៃផ្សេងទៀត

វាក៏មានបញ្ហាជាច្រើននៅក្នុងជីវិតពិតជាក់ស្តែង ដែលកើតមាននៅក្នុងដំណើរនៃការស្លាប់របស់មនុស្ស។ ខាងក្រោមនេះគឺជាបញ្ហាដែលចម្បងៗជាងគេ៖

១. ចង់លាក់ការពិតដែលថាខ្លួនជិតស្លាប់ ។ មានមនុស្សបានប្រាប់មកខ្ញុំថា៖ "ខ្ញុំមិនចង់ប្រាប់ នរណាម្នាក់ថាខ្ញុំជិតស្លាប់នោះទេ ព្រោះនៅពេលដែលមនុស្សបានដឹងពីការនោះ ពួកគេធ្វើមកលើអ្នកខុសប្លែកពីមុន។ ខ្ញុំចង់រក្សាជីវិតធម្មតាឲ្យបានយូរតាមតែអាចធ្វើទៅបាន។"

២. ការព្រួយបារម្ភថានរណានឹងមើលការខុសត្រូវរឿងដែលអ្នកមិនទាន់បានធ្វើ តើនឹងមានរឿងអ្វីកើតឡើងចំពោះគ្រួសារ និងការព្រួយបារម្ភផ្សេងៗទៀតដូចជា ៖ "ត្រូវតែមាននរណាដឹងថាតើសោរទុកនៅកន្លែងណា តើលុយទុកនៅឯណា តើមានធានារ៉ាប់រងប៉ុន្មាន តើក្រដាសបញ្ជីស្នាមសំខាន់ៗរបស់គ្រួសារនៅឯណា"។ មានគិលានុដ្ឋាយិកាម្នាក់បានឲ្យយោបល់ថា "សាកល្បងគិតថាបើអ្នកមិននៅទីនេះ។ តើអ្វីខ្លះដែលគ្រួសាររបស់អ្នកត្រូវដឹង?"

៣. បញ្ហាហិរញ្ញវត្ថុដែលទាក់ទងទៅនឹងថ្លៃព្យាបាល ឬ ការបាត់បង់អ្នករកចំណូល។

៤. ការស្នាក់ស្នើររបស់សមាជិកគ្រួសារក្នុងការពិភាក្សាពីការប្រឈមនឹងការស្លាប់ និង ការដែលវាអាចនឹងប៉ះពាល់ទៅដល់ក្រុមគ្រួសារ អ្នកដែលជិតស្លាប់ត្រូវមានសិទ្ធិដឹងពីភាពធ្ងន់ធ្ងរនៃជំងឺរបស់គាត់ និង មានសិទ្ធិនិយាយពីរឿងនេះជាមួយនឹងគ្រួសារ។

អ្នកប្រហែលជានឹកឃើញបញ្ហាស្រដៀងគ្នា នៅក្នុងស្ថានភាពបែបនេះដែរ។ បន្ថែមពីលើនេះទៅទៀត នៅមានបញ្ហាខាងអារម្មណ៍ និង បញ្ហាខាងវិញ្ញាណ ដែលមនុស្សជិតស្លាប់ និង ក្រុមគ្រួសារត្រូវឆ្លងកាត់ ដូចជារឿងទាក់ទងនឹងការបាត់បង់ ភាពសោកសៅ ឬ សំណួរជាច្រើនអំពីការអធិស្ឋានសុំការព្យាបាលដែលគ្មានការឆ្លើយតបពីព្រះជាម្ចាស់។

លំហាត់អនុវត្តន៍

---

៩ ចូរសរសេរនៅក្នុងតារាងមួយ អំពីអ្វីដែលអ្នកចង់ឲ្យគ្រួសាររបស់អ្នកដឹង នៅក្នុងករណីដែលអ្នកត្រូវស្លាប់។ ចូរសរសេរនៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

ពេលដែលល្អបំផុតដើម្បីពិភាក្សាអំពីបញ្ហាសំខាន់ៗនៅក្នុងគ្រួសារ គឺនៅពេលដែលអ្នកនៅមានសុខភាពល្អ និង អាចធ្វើវាបានដោយគ្មានការលំអៀង និង មិនតាមតែអារម្មណ៍។ ប្រសិនបើអ្នកមានទ្រព្យសម្បត្តិ អ្នកធានាការពារវាសម្រាប់ប្តីប្រពន្ធ និង កូនៗរបស់អ្នក ដោយការធ្វើលិខិតផ្ទេរមរតកមួយ។ ប្តីប្រពន្ធត្រូវរៀបចំផែនការរួមគ្នាមួយ ឲ្យបានល្អតាមតែពួកគេអាចធ្វើទៅបាន សម្រាប់ធានាអនាគតកូនៗរបស់ពួកគេ នៅក្នុងករណីដែលម្នាក់ក្នុងចំណោមពួកគេ ឬ ពួកគេទាំងពីរនាក់អាចស្លាប់។ ទាំងនេះគឺជាបញ្ហាសំខាន់ដែលមិនគួរធ្វេសប្រហែសសោះឡើយ។

លំហាត់អនុវត្តន៍

១០ តើអ្នកអាចរៀបចំយ៉ាងណាឲ្យបានល្អបំផុត សម្រាប់ដោះស្រាយបញ្ហាជាក់ស្តែងដែលទាក់ទង ជាមួយនឹងការស្លាប់?

.....

.....

១១ នៅក្នុងជួរខាងស្តាំ គឺជាដំណាក់កាលដែលមនុស្សអាចនឹងឆ្លងកាត់ នៅពេលដែលពួកគេ ប្រឈមមុខនឹងការពិតដែលថាគេជិតស្លាប់។ នៅក្នុងជួរខាងឆ្វេង គឺជាអាការៈនៃដំណាក់កាលនីមួយៗ។ ចូរផ្គូផ្គងដំណាក់កាលទៅនឹងអាការៈ ដោយសរសេរលេខត្រឹមត្រូវទៅក្នុងចន្លោះបន្ទាត់។

.....ក)	និយាយប្រឆាំងបះបោរជាមួយនឹងការពិត	១)	បដិសេធ
.....ខ)	ជឿថានឹងមានអ្វីម្យ៉ាងកើតឡើងដើម្បី ផ្លាស់ប្តូរស្ថានភាពនោះ	២)	កំហឹង
		៣)	ការតថ្លៃ
.....គ)	ការបោះបង់ ការផ្តាច់ខ្លួន និង មានអារម្មណ៍សុខសាន្ត។	៤)	ការបាក់ទឹកចិត្ត
.....ឃ)	បដិសេធមិនព្រមទទួលយកការពិត	៥)	ការទទួលស្គាល់
.....ង)	សន្យាថានឹងផ្លាស់ប្តូរអាកប្បកិរិយាប្រសិនបើ ព្រះជាម្ចាស់ជួយ។	៦)	សង្ឃឹម
.....ច)	ទួញសោក និង មានអារម្មណ៍បាត់បង់		

ប្រហែលជានៅក្នុងអំឡុងពេលដែលមានទុក្ខខាងឯរូបកាយ ដែលគ្រិស្តបរិស័ទរកឃើញឥទ្ធិពលដ៏ពិតនៃដំណឹងល្អរបស់ព្រះយេស៊ូគ្រិស្តនៅក្នុងជីវិតរបស់ពួកគេ។ នៅក្នុង *បញ្ហានៃការឈឺចាប់*នេះ *(The Problem of Pain,)* លោកស៊ី.អែស. លូវីស (C.S.Lewis) បាននិយាយថា៖ "ខ្ញុំបានឃើញវិញ្ញាណដ៏ស្រស់ស្អាតអស្ចារ្យនៅក្នុងអស់អ្នកដែលធ្លាប់ជាអ្នករងទុក្ខយ៉ាងខ្លាំងខ្លះ" (១៩៧៦, ១០៨) ។ មានទំនុកចម្រៀងដ៏អស្ចារ្យ និង ការចែកចាយព្រះបន្ទូលដ៏មានឥទ្ធិពលជាច្រើន ត្រូវបានសរសេរឡើងដោយពួកសន្ត (មនុស្សវិសុទ្ធ) ដែលឆ្លងកាត់ការឈឺចាប់យ៉ាងខ្លាំង។ អ្នកជឿដែលបានផ្សាព្វផ្សាយអំណរ និងសេចក្តីសុខសាន្ត ហើយបានឆ្លុះបញ្ចាំងអំពីព្រះគ្រិស្ត នៅក្នុងចំណោមបញ្ហាយ៉ាងលំបាករបស់ពួកគេ គឺពិតជាការជំរុញចិត្តដ៏អស្ចារ្យពិតមែន!

លំហាត់អនុវត្តន៍

១២ តើដំណឹងល្អរបស់ព្រះគ្រិស្តបានកែប្រែធ្យោបាយដែលអ្នកប្រើដើម្បីដោះស្រាយបញ្ហាដែលអាចកើតមានឡើងនៅពេលជិតស្លាប់ដោយរបៀបណា?

.....

.....

ក. ការជួយអ្នកកំពុងរងទុក្ខ និង អ្នកជិតស្លាប់

វគ្គបំណែងទី៥. *ជ្រើសរើសពាក្យសំដីពិតប្រាកដ ទាក់ទងនឹងមធ្យោបាយគ្រិស្តបរិស័ទអាចជួយអស់អ្នកដែលកំពុងរងទុក្ខ និង ជិតស្លាប់បាន។*

នៅក្នុងមុខវិជ្ជានេះ យើងបានឃើញរួចមកហើយអំពីរបៀបច្រើនសម្រាប់បម្រើអ្នកដែលកំពុងរងទុក្ខ។ ពេលនេះយើងនឹងសិក្សាឲ្យកាន់តែច្បាស់ ទៅលើមធ្យោបាយដើម្បីជួយអ្នកដែលកំពុងរងការឈឺចាប់ខាងឯរូបកាយ និង ខាងឯអារម្មណ៍ និង អ្នកដែលជិតស្លាប់។

នៅក្បែរ

រឿងដ៏សំខាន់ដែលអ្នកប្រហែលជាអាចធ្វើបានគឺគ្រាន់តែ*នៅក្បែរ*ប៉ុណ្ណោះ។ ភាពជិតស្និទ្ធិរបស់អ្នកសម្លេងដ៏ស្រទន់ និង ការបបោសអង្អែលអាចប្រាប់យ៉ាងខ្លាំងពីក្តីស្រឡាញ់ និងការខ្វល់ខ្វាយ ជាងពាក្យសំដីទៅទៀត។ ធ្វើខ្លួនអ្នកឲ្យទំនេរសម្រាប់អ្នកដែលរងទុក្ខ និង មនុស្សជិតស្លាប់ ព្រមទាំងក្រុមគ្រួសាររបស់គេផងដែរ។ ការទៅសួរសុខទុក្ខខ្លីៗ និង ញឹកញាប់ដល់ក្បែរគ្រែរបស់ពួកគេគឺជាការលើកទឹកចិត្តមួយ។ ប្រសិនបើអ្នកនៅឃ្លាតពេក ការទៅសួរសុខទុក្ខរបស់អ្នកនឹងក្លាយទៅជាបន្ទុកសម្រាប់អ្នកនោះទៅវិញ។ អ្នកអាចបង្ហាញក្តីស្រឡាញ់របស់អ្នកតាមរបៀបជាច្រើន វាអាចជាការធ្វើការងារសម្រាប់គ្រួសារអ្នកនោះ ការមើលថែកូនៗរបស់អ្នកជំងឺ ការអានរឿងនិទានឲ្យគេស្តាប់ ឬ អាចជាការបំពេញតម្រូវការខាងឯសាច់ឈាមរបស់អ្នកនោះផងដែរ។

ស្មោះត្រង់

នៅក្នុងការនិយាយជាមួយអ្នកមានជំងឺ និង អ្នកជិតស្លាប់ ត្រូវឲ្យមានភាពស្មោះត្រង់។ សូមអនុញ្ញាតឲ្យខ្លួនឯងបានបង្ហាញអារម្មណ៍ ប៉ុន្តែក៏ត្រូវឲ្យពួកគេដឹងថា អ្នកបានឃើញថាព្រះគ្រិស្តគឺជាធនធានដ៏អស្ចារ្យនៅក្នុងពេលដែលមានភាពភ័យខ្លាច និង ការបាក់ទឹកចិត្ត។ អនុញ្ញាតឲ្យព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលកំសាន្តចិត្តតាមរយៈមាត់របស់អ្នក។ ចែកចាយបទគម្ពីរដែលផ្តល់កម្លាំង និង លើកទឹកចិត្ត។ អធិស្ឋានជាមួយពួកគេ និង អធិស្ឋានសម្រាប់ពួកគេ។ត្រូវយល់ឲ្យច្បាស់ពីដំណាក់កាលនៃការឆ្លើយតបដែលយើងបានពិភាក្សានៅខាងលើ ហើយកុំព្យាយាមប្រាប់អ្នកជំងឺនោះថាគេខុស ដែលគេមានប្រតិកម្មឆ្លើយតបយ៉ាងដូច្នោះ។

ជាអ្នកដែលឆាប់មានអារម្មណ៍ដឹង

ទោះបីជាគ្រិស្តបរិស័ទត្រូវបានរំដោះឲ្យរួចផុតពីសេចក្តីស្លាប់នោះក៏ដោយ តែវានៅតែជាសត្រូវ ហើយភាពចម្លែករបស់វា អាចធ្វើឲ្យមានភាពមិនស្រណុកក្នុងចិត្តបាន។ អ្នកត្រូវតែឆាប់មានអារម្មណ៍ដឹងពីភាពឯកាដែលលក្ខណៈពិសេសដោយឡែកពីគ្នាដែលអាចកើតមានចំពោះមនុស្សជិតស្លាប់ និង ញាតិមិត្តរបស់អ្នកស្លាប់ផងដែរ។ពួកគេត្រូវការវត្តមានរបស់បងប្អូនប្រុសស្រីនៅក្នុងព្រះគ្រិស្តដើម្បីជួយកាត់បន្ថយអារម្មណ៍ដែលត្រូវបានកាត់ផ្តាច់ពីជីវិតដែលពួកគេធ្លាប់បានស្គាល់។

មនុស្សជិតស្លាប់តែងតែនិយាយថាអ្នកដទៃធ្វើមកលើខ្លួនមិនដូចជាមនុស្សសោះ ហើយធ្វើដូចពួកគេបានស្លាប់ហើយ។ នៅពេលដែលពួកគេត្រូវការការលួងលោម និងការលើកទឹកចិត្តបំផុត បែរជាអ្នកដទៃតែងតែដកខ្លួន និង ចាកចេញពីពួកគេឲ្យប្រឈមមុខនឹងសេចក្តីស្លាប់តែម្នាក់ឯង។ ឬមួយក៏មានគ្រួសារ និង មិត្តភក្តិខ្លះបែរជាពិភាក្សាគ្នាអំពីជំងឺរបស់ពួកគេ អាការៈរបស់ពួកគេ ឬ អាកប្បកិរិយារបស់ពួកគេ ធ្វើដូចពួកគេមិនមានវត្តមាននៅទីនោះយ៉ាងដូច្នោះ។ គ្រិស្តបរិស័ទដែលឆាប់មានអារម្មណ៍ដឹង នឹងមិនអនុញ្ញាតឲ្យមានការនេះកើតឡើងនោះទេ។ ការជាសះស្បើយរបស់អ្នកជំងឺម្នាក់អាចនឹងកើតឡើងបានទោះបីជាគាត់មិនអាចឆ្លើយតបមករកអ្នកវិញក៏ដោយ។ វាគឺជារឿងសំខាន់ណាស់ដែលនៅក្នុងពេលនេះអ្នកត្រូវបង្ហាញទាក់ទងនឹងក្តីសង្ឃឹម និង ការលួងលោមជាមួយគាត់។

លំហាត់អនុវត្តន៍

---

១៣ ចូរគូសរង្វង់នៅពីមុខចម្លើយត្រឹមត្រូវ ដែលបានឆ្លុះបញ្ចាំងពីរបៀបដែលគ្រិស្តបរិស័ទអាចជួយអ្នកដែលកំពុងរងទុក្ខ ឬជិតស្លាប់។ គ្រិស្តបរិស័ទគួរតែ

ក) ចំណាយពេលឲ្យបានច្រើនម៉ោងនៅក្បែរគ្រែរបស់អ្នកជំងឺនោះនិយាយទៅកាន់ពួកគេដើម្បីបង្ហាញថាគេពិតជាយកចិត្តទុកដាក់ចំពោះពួកគេ។

ខ) ត្រូវតែមានភាពស្មោះត្រង់នៅក្នុងការចែកចាយអារម្មណ៍របស់ពួកគេ និង ការខ្វល់ខ្វាយរបស់ពួក គេជាមួយអ្នកជំងឺ ឬអ្នកជិតស្លាប់នោះ។

គ) ត្រូវតែមានពេលទំនេរឲ្យបានច្រើនដើម្បីបម្រើគេតាមអ្វីដែលគេត្រូវការ។

ឃ) ជៀសវាងការនិយាយពិភាក្សាអំពីស្ថានភាពរបស់អ្នកជំងឺនោះជាមួយអ្នកដទៃ នៅចំពោះមុខអ្នកជំងឺនោះ។

ង) ចែកចាយពីបញ្ហាផ្ទាល់ខ្លួនជាមួយអ្នកជំងឺ ដើម្បីឲ្យពួកគេឈប់គិតពីរឿងរបស់ខ្លួនឯង។

ច) និយាយពាក្យដែលប្រកបដោយការលួងលោម និង ក្តីសង្ឃឹម ដោយមានការដឹកនាំពីព្រះ វិញ្ញាណដ៏វិសុទ្ធ។

ឆ) ត្រូវធ្វើជាអ្នកឆាប់មានអារម្មណ៍ដឹងពីតម្រូវការរបស់អ្នកជំងឺ ដែលចង់ឲ្យអ្នកដទៃធ្វើមកលើខ្លួនដូចជាមនុស្សគ្រប់លក្ខណៈយ៉ាងដូច្នោះដែរ ។

ឃ. បញ្ហាដែលទាក់ទងនឹងសេចក្តីស្លាប់

វគ្គបំណងទី៦. *ដោយយោងទៅតាមគម្ពីរ១កូរិនថូស ១៥:៥៥-៥៧ អ្នកអាចធ្វើការបកស្រាយអំពីកម្លាំង និង សេចក្តីសុខសាន្ត ដែលញាតិមិត្តរបស់អ្នកស្លាប់ទទួលបាននៅពេលដែលគ្រិស្តបរិស័ទម្នាក់បានស្លាប់។*

ស្ថានភាពខាងវិញ្ញាណ

បញ្ហាដ៏ធ្ងន់ធ្ងរបំផុតសម្រាប់អ្នកដែលប្រឈមមុខនឹងសេចក្តីស្លាប់គឺបញ្ហានេះ៖ "តើខ្ញុំបានត្រៀមខ្លួនដើម្បីគាល់ព្រះជាម្ចាស់ហើយឬនៅ?" ប្រសិនបើមនុស្សម្នាក់បានដោះស្រាយបញ្ហាអំពើបាបរបស់គាត់រួច

ហើយ ប្រសិនបើគាត់បានកើតសាជាថ្មីនៅក្នុងព្រះគ្រិស្តហើយ នោះសេចក្តីស្លាប់មិនមែនជាបញ្ហាទៀតនោះទេ ដ្បិតព្រះគ្រិស្តបានដោះស្រាយបញ្ហានោះដោយការសុគតរបស់ទ្រង់នៅលើឈើឆ្កាង និង ការមានព្រះជន្មរស់ឡើងពីផ្នូររបស់ទ្រង់រួចទៅហើយ។ ការនេះបានបង្ហាញនៅក្នុងគម្ពីរ១កូរិនថូស ១៥:៥៥-៥៧៖

មច្ចុរាជអើយ តើទ្រនិចរបស់ឯងនៅឯណា?

មច្ចុរាជអើយ តើអំណាចប្រហារជីវិតរបស់ឯង នៅឯណា?

ទ្រនិចនៃសេចក្តីស្លាប់គឺជាអំពើបាប ហើយអំណាចនៃអំពើបាបគឺជាច្បាប់។ ប៉ុន្តែអរព្រះគុណដល់ព្រះជាម្ចាស់ ដែលទ្រង់បានប្រទានជ័យជំនះមកឲ្យយើងតាមរយៈព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង!

គ្រិស្តបរិស័ទអាចប្រកាសរួមជាមួយលោកសាវ័កប៉ូលថា៖ ដូច្នេះហើយ "ចំពោះខ្ញុំ បើរស់ ខ្ញុំរស់រួមជាមួយព្រះគ្រិស្ត ហើយបើស្លាប់ ខ្ញុំក៏បានចំណេញដែរ។...ចិត្តខ្ញុំរារែកទាំងសងខាង គឺម្យ៉ាងខ្ញុំប៉ងប្រាថ្នាចង់លាចាកលោកនេះ ទៅនៅជាមួយព្រះគ្រិស្តនោះប្រសើរជាងឆ្ងាយណាស់។" (គម្ពីរភីលីព ១:២១,២៣)។ គម្ពីរទំនុកតម្កើង១១៦:១៥ ប្រាប់យើងថា "ព្រះអម្ចាស់ព្រួយព្រះហឫទ័យណាស់ នៅពេលប្រជាជនដ៏វិសុទ្ធណាម្នាក់ស្លាប់។"

ការដែលត្រូវគេស្លាប់ចោល

ក្នុងពេលនេះ សេចក្តីស្លាប់គឺ បញ្ហាដ៏ធំសម្រាប់អ្នកដែលនៅរស់ ជាងអ្នកស្លាប់ជាគ្រិស្តបរិស័ទដែលបានចាកចេញទៅនៅជាមួយព្រះអម្ចាស់ទៅទៀត។ ញាតិមិត្តអ្នកស្លាប់នឹងឆ្លងកាត់គ្រាសោកសង្រែង។ ពួកគេអាចមានអារម្មណ៍ថាមានកំហុសដោយសារតែមិនអាចជួយរារាំងសេចក្តីស្លាប់នោះបាន ឬ ដោយសារតែការសោកស្តាយដែលពួកគេអាចនឹងមាន។ ពួកគេនឹងទទួលរងអារម្មណ៍បាត់បង់យ៉ាងខ្លាំង ហើយនឹងត្រូវតែទទួលស្គាល់ការពិតដែលថា បងប្អូនគេបានស្លាប់ហើយ។ ពួកគេនឹងត្រូវការនរណាម្នាក់មកដើម្បីឈរក្បែរ និង យំសោកជាមួយពួកគេ។

មនុស្សយើងភាគច្រើនមានអារម្មណ៍ថា ខ្លួនឯងគ្មានប្រយោជន៍ នៅពេលដែលព្យាយាមកំសាន្តចិត្តញាតិមិត្តរបស់អ្នកស្លាប់។ មនុស្សតែងតែនិយាយអ្វីដែលធ្វើឲ្យមានបញ្ហា ជាជាងធ្វើឲ្យមានការល្អ។ សាជាថ្មីម្តងទៀត វត្តមានរបស់អ្នក ការប៉ះរបស់អ្នក និង ការស្ម័គ្រចិត្តជួយរបស់អ្នក នឹងធ្វើឲ្យសម្រេចការបានច្រើនជាងពាក្យសំដីនោះទៅទៀត។ ក្រោយពីភាពតក់ស្លុតបានកន្លងផុតទៅ ហើយជីវិតក៏បានត្រឡប់ទៅរកទម្លាប់ដូចពីមុន នោះការយកចិត្តទុកដាក់ និង មិត្តភាពរបស់អ្នកនឹងត្រូវការជាចាំបាច់ ដើម្បីជួយញាតិមិត្តរបស់អ្នកស្លាប់ ក្នុងពេលដែលពួកគេកែប្រែការរស់នៅរបស់ពួកគេដោយគ្មានមនុស្សជាទីស្រឡាញ់របស់ពួកគេ។

សម្រាប់អស់អ្នកដែលធ្លាប់មានសមាជិកគ្រួសារជិតស្និទ្ធបាត់បង់ជីវិត នោះគេដឹងថានេះគឺជាពេលដែលព្រះជាម្ចាស់ប្រទានកម្លាំង និង សេចក្តីសុខសាន្តដ៏អស្ចារ្យ នៅពេលដែលយើងស្វែងរកឲ្យទ្រង់ជួយ។ ទ្រង់គាំទ្រយើង នៅក្នុងគ្រប់ការសម្រេចចិត្តទាំងអស់ និង គ្រប់ការគ្រាំគ្រាចិត្តទាំងអស់ ហើយទ្រង់ប្រទានឲ្យយើងនូវក្តីសង្ឃឹមថានៅថ្ងៃមួយយើងនឹងបានជួបជុំជាមួយអ្នកជាទីស្រឡាញ់របស់យើងជារៀងរហូតនៅឯស្ថានបរមសុខ!

លំហាត់អនុវត្តន៍

១៤ យោងទៅតាមគម្ពីរ១កូរិនថូស ១៥:៥៥-៥៧ នៅពេលដែលមានគ្រិស្តបរិស័ទម្នាក់បានស្លាប់ទៅ ចូរបកស្រាយពីកម្លាំង និង សេចក្តីសុខសាន្តដែលញាតិមិត្តរបស់អ្នកស្លាប់ទទួលបាន ។

.....

ខ. ចក្ខុវិស័យមួយរបស់គ្រិស្តបរិស័ទ

ការរងទុក្ខ និង ការសុគតរបស់ព្រះគ្រិស្ត

វត្ថុបំណងទី៧. *ថ្លែងប្រាប់ពីគោលការណ៍មួយផ្អែកទៅលើគំរូរបស់ព្រះគ្រិស្ត ដែលអាចដឹកនាំផ្លូវរបស់គ្រិស្តបរិស័ទ នៅពេលដែលពួកគេប្រឈមមុខជាមួយនឹងការរងទុក្ខ និង សេចក្តីស្លាប់។*

ហោរាអេសាយបានធ្វើការទស្សន៍ទាយទុកមុនអំពីព្រះយេស៊ូគ្រិស្តយ៉ាងដូច្នេះថា៖

ព្រះអម្ចាស់សព្វព្រះហឫទ័យអោយអ្នកបំរើ របស់ព្រះអង្គរងទុក្ខលំបាកដ៏ខ្លោចផ្សា។ ដោយលោកបានបូជាជីវិត ធ្វើជាយញ្ញបូជាលោះបាបសំរាប់អ្នកដទៃ ព្រះអង្គនឹងធ្វើអោយលោកមាន ពូជពង្ស ព្រះអង្គនឹងបន្តអាយុជីវិតរបស់លោក ហើយព្រះអម្ចាស់នឹងសំរេចតាមព្រះហឫទ័យ របស់ព្រះអង្គតាមរយៈលោក។ "ក្រោយពីបានរងទុក្ខលំបាកយ៉ាងខ្លាំងមក ជីវិតរបស់អ្នកបំរើ នឹងមានពន្លឺ មនុស្សជាច្រើននឹងទទួលស្គាល់ ចំណេះដឹងរបស់លោក។ អ្នកបំរើរបស់យើង សុចរិត លោកក៏ប្រោសមហាជនអោយបានសុចរិត ដោយទទួលយកកំហុសរបស់ពួកគេ។(គម្ពីរអេសាយ ៥៣:១០-១១)

ព្រះយេស៊ូមិនបានប្រព្រឹត្តបាបសោះ។ ទ្រង់បានរងទុក្ខ ទាំងមិនបានធ្វើខុសសោះឡើយសម្រាប់អ្នកដែលមានទោស។ ប៉ុន្តែទ្រង់ក៏បានដឹងថា តាំងពីមុនពេលដែលទ្រង់យាងមកលើផែនដីនេះទៅទៀត ថាការយាងមកនេះនឹងជាការរងទុក្ខព្រួយ និង ការឈឺចាប់ដ៏លើលលប់មួយ។ បន្ទាប់ពីព្រះយេស៊ូបានសុគត ហើយមានព្រះជន្មរស់ពីស្លាប់ឡើងវិញ "ព្រះអង្គមានព្រះបន្ទូលថា៖ «ហេតុការណ៍នេះកើតឡើង ស្របតាមសេចក្តីដែលមានចែងទុកក្នុងគម្ពីរមែន គឺព្រះគ្រិស្ត*ត្រូវរងទុក្ខលំបាក ហើយមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី។" (គម្ពីរលូកា២៤:៤៦)។

លំហាត់អនុវត្តន៍

១៥ ចូរអានគម្ពីរកិច្ចការ ៣:១៨ និង គម្ពីរកិច្ចការ ២៦:២២-២៣ ។ តើខគម្ពីរទាំងពីរនេះបាននិយាយ ថាព្រះគ្រិស្តបានធ្វើអ្វី?

.....

សាសន៍យូដាបាននឹងកំពុងរងចាំព្រះមេស្ស៊ីយ៉ាងមកធ្វើជាស្តេចដ៏មានអំណាចចេស្តាដែលមានអំណាចខាងឯនយោបាយដែលនឹងរំដោះពួកគេឲ្យផុតពីការគាប់សង្កត់របស់ពួករ៉ូមាំ។ ពួកគេបានមើលរំលង សេចក្តីពិតដែលហោរានៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់បានថ្លែងថា ទ្រង់នឹងយាងមកក្នុងនាមជាអ្នកបម្រើដែលរងទុក្ខវេទនា។ ដូចមនុស្សជាច្រើនក្នុងពេលបច្ចុប្បន្នដែរ ពួកគេបានបដិសេធរូបភាពនៃការរងទុក្ខលំបាករបស់ព្រះយេស៊ូ ថារឿងដែលគិតទៅធ្វើឲ្យពួកគេមិនសប្បាយចិត្តទៅវិញ។

ទោះបីជាវាគ្រាន់តែជារឿងដែលមានរយៈពេលខ្លីយ៉ាងណា ក៏ភាពធ្ងន់ធ្ងរនៃទុក្ខលំបាករបស់ព្រះយេស៊ូបានធ្វើឲ្យទ្រង់អធិស្ឋាននៅក្នុងសួនកេតសេម៉ានីថា៖ "អ័ប្បា ឱព្រះបិតាអើយ! ព្រះអង្គអាចសំរេចគ្រប់កិច្ចការទាំងអស់បាន សូមដកយកពែងនៃទុក្ខលំបាកនេះចេញអោយឆ្ងាយពីទូលបង្គំទៅ ប៉ុន្តែ សូមកុំតាមបំណងចិត្តទូលបង្គំឡើយ គឺសូមអោយបានសំរេចតាមព្រះហឫទ័យព្រះអង្គវិញ"។ (គម្ពីរម៉ាកុស១៤:៣៦)។ ព្រះយេស៊ូជ្រាបថា ការរងទុក្ខរបស់ទ្រង់មានគោលបំណងមួយ។ ទោះបីជាទ្រង់សព្វព្រះហឫទ័យចង់ជៀសផុតពីទុក្ខលំបាកនេះប្រសិនបើអាចទៅរួច ក៏បំណងព្រះហឫទ័យដ៏ធំរបស់ទ្រង់គឺត្រូវតែបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះវរបិតា។ ទ្រង់ខ្វល់ព្រះទ័យអំពីតម្លៃដ៏អស់កល្បជានិច្ចដែលអាចនឹងបានមកតាមរយៈការរងទុក្ខ និង ការសុគតរបស់ទ្រង់ ជាជាងការឈឺចាប់ និង ការរងទុក្ខក្នុងមួយរយៈពេលខ្លីរបស់ទ្រង់។ ទ្រង់គឺជាគំរូដ៏ល្អឥតខ្ចោះរបស់យើង។

> ត្រូវសម្លឹងមើលទៅព្រះយេស៊ូ ដែលជាដើមកំណើតនៃជំនឿ ហើយធ្វើអោយជំនឿនេះបានគ្រប់លក្ខណៈ។ ព្រះអង្គសុខចិត្តលះបង់អំណរ ដែលបម្រុងទុកសំរាប់ព្រះអង្គ ហើយរងទុក្ខលំបាកនៅលើឈើឆ្កាងឥតខ្លាចខ្មាសសោះឡើយ។ ឥឡូវនេះ ព្រះអង្គគង់នៅខាងស្តាំបល្ល័ង្ករបស់ព្រះជាម្ចាស់។ សូមបងប្អូនគិតពីព្រះអង្គដែលបានស៊ូទ្រាំនឹងមនុស្សបាបដែលប្រឆាំងព្រះអង្គយ៉ាងខ្លាំងនោះទៅ ដើម្បីកុំអោយបងប្អូននឿយណាយបាក់ទឹកចិត្តឡើយ។
> (គម្ពីរហេប្រឺ ១២:២-៣)

លំហាត់អនុវត្តន៍

---

១៦ ចូរប្រាប់ពីគោលការណ៍ដែលផ្អែកទៅលើគំរូរបស់ព្រះគ្រិស្ត ដែលអាចនាំផ្លូវគ្រិស្តបរិស័ទ នៅពេលដែលពួកគេប្រឈមមុខនឹងទុក្ខលំបាក និង សេចក្តីស្លាប់។

.....

.....

.....

ការឆ្លើយតបរបស់គ្រិស្តបរិស័ទ ទៅនឹងទុក្ខលំបាក និងការស្លាប់

វត្ថុបំណងទី៨ *ស្គាល់ពីគោលការណ៍ចម្បងដែលឆ្លុះបញ្ចាំងពីឥរិយាបថរបស់គ្រិស្តបរិស័ទ ទៅចំពោះការរងទុក្ខ និង សេចក្តីស្លាប់។*

ទំនុកចិត្តនៅក្នុងព្រះជាម្ចាស់

រឿងរ៉ាវក្នុងព្រះគម្ពីរអំពីទុក្ខលំបាករបស់លោកយ៉ូប លោកមិនបានទទួលការបកស្រាយថាតើហេតុអ្វីបានជាមានទុក្ខលំបាកកើតឡើងចំពោះលោកយ៉ាងដូច្នេះទេ ប៉ុន្តែលោកជឿជាក់ថាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺល្អ ហើយជឿជាក់ថាព្រះជាម្ចាស់មិនចង់បំផ្លាញលោកនោះទេ តែដើម្បីធ្វើឲ្យលោកបានបរិសុទ្ធស្អាតទៅវិញ។ លោកយ៉ូបបាននិយាយថា៖ "ព្រះជាម្ចាស់ជ្រាបច្បាស់នូវមាគ៌ាដែលខ្ញុំដើរ ប្រសិនបើព្រះអង្គល្បងលមើលខ្ញុំ ព្រះអង្គមុខជាឃើញថា ខ្ញុំប្រៀបបាននឹងមាសសុទ្ធ" (គម្ពីរយ៉ូប២៣:១០)។ លោកយ៉ូបបានបញ្ជាក់ផងដែរថា ក្តីស្រឡាញ់ និង ការជឿទុកចិត្តរបស់លោកចំពោះព្រះជាម្ចាស់ កើតមានឡើងពីការទុកចិត្តព្រះជាម្ចាស់ផ្ទាល់ ហើយមិនមែនកើតឡើងពីទ្រព្យសម្បត្តិ និង ការផ្គាប់ចិត្តដែលព្រះជាម្ចាស់អាចនឹងប្រទានឲ្យលោកនោះទេ ហើយក៏មិនមែនមកពីស្ថានភាពរបស់លោកនោះដែរ។

ព្រះជាម្ចាស់តែងតែរំដោះយើងចេញពីទុក្ខលំបាក ដោយអំណាចព្រះចេស្តា និង ព្រះគុណរបស់ទ្រង់ ប៉ុន្តែទុក្ខលំបាកខ្លះនៅតែបន្តកើតមាន ទោះបីជាមានការអធិស្ឋាន និងការខិតខំប្រឹងប្រែងទាំងប៉ុន្មានរបស់យើង ទៅចំពោះព្រះជាម្ចាស់ក៏ដោយ។ ការរងទុក្ខគឺមានសារៈសំខាន់ណាស់នៅក្នុងផែនការរបស់ព្រះជាម្ចាស់ដើម្បីប្រៀនប្រដៅយើង (គម្ពីរហេប្រឺ ១២:៧-១១) ដើម្បីសាកល្បងយើង (គម្ពីរយ៉ូប ២៣:១០) ដើម្បីត្រៀមយើងសម្រាប់ការបម្រើ (គម្ពីរ២កូរិនថូស ១:៤-៥) និង ដើម្បីបង្កើតបានជារូបភាពរបស់ព្រះគ្រិស្តនៅក្នុងយើង ។ លោកសាវ័កប៉ូលបានមានប្រសាសន៍ថា៖ "បំណងរបស់ខ្ញុំ គឺចង់ស្គាល់ព្រះគ្រិស្ត និងស្គាល់ឫទ្ធានុភាពដែលបានប្រោសព្រះអង្គអោយមានព្រះជន្មរស់ឡើងវិញ ព្រមទាំងចូលរួមជាមួយព្រះអង្គដែលរងទុក្ខលំបាក ហើយអោយបានដូចព្រះអង្គដែលសោយទិវង្គត"
(គម្ពីរភីលីព ៣:១០)

អំណរ

នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មីយើងឃើញពីចំណងដ៏ខ្លាំងក្លាមួយរវាងការរងទុក្ខលំបាក និង អំណរ៖

គម្ពីរយ៉ាកុប ១:២-៣ *បងប្អូនអើយ ទុក្ខលំបាកគ្រប់យ៉ាងដែលបងប្អូន ត្រូវឆ្លងកាត់នោះ សូមចាត់ទុកថា ជាការដែលធ្វើអោយបងប្អូនមានអំណរដ៏បរិបូណ៌វិញ ដោយដឹងថា ការល្បងលមើលជំនឿរបស់បងប្អូន នឹងនាំអោយបងប្អូនចេះស៊ូទ្រាំ។*

គម្ពីរកិច្ចការ ៥:៤១ *ក្រុមសាវ័កចាកចេញពីក្រុមប្រឹក្សាជាន់ខ្ពស់ ទាំងអរសប្បាយ ដ្បិតព្រះជាម្ចាស់បានប្រទានអោយគេមានកិត្តិយសរងទុក្ខទោស ព្រោះតែព្រះនាមព្រះយេស៊ូ។*

គម្ពីរកូឡូស ១:២៤	*ខ្ញុំមានអំណរដោយរងទុក្ខលំបាកសំរាប់បងប្អូន។*
គម្ពីរ១ថែស្សាឡូនិក១:៦	*បងប្អូនបានយកតំរាប់តាមយើង និងយកតំរាប់តាមព្រះអម្ចាស់ គឺទោះបីបងប្អូនជួបប្រទះនឹងទុក្ខវេទនាធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏បងប្អូនបានទទួលព្រះបន្ទូលទាំងមានអំណរ មកពីព្រះវិញ្ញាណដ៏វិសុទ្ធដែរ។*
គម្ពីរ១ពេត្រុស៤:១៣	*ផ្ទុយទៅវិញ ចូរមានចិត្តរីករាយឡើង ព្រោះបងប្អូនរងទុក្ខលំបាកផ្សេងៗរួមជាមួយព្រះគ្រិស្ត*។ បងប្អូនមុខជាមានអំណរសប្បាយយ៉ាងខ្លាំង នៅពេលព្រះអង្គបង្ហាញសិរីរុងរឿងរបស់ព្រះអង្គ។*
គម្ពីរយ៉ូហាន១៦:២២	*អ្នករាល់គ្នាក៏ដូច្នោះដែរ ឥឡូវនេះ អ្នករាល់គ្នាព្រួយចិត្ត ប៉ុន្តែខ្ញុំនឹងជួបអ្នករាល់គ្នាសាជាថ្មី អ្នករាល់គ្នានឹងសប្បាយចិត្ត ហើយគ្មាននរណាដកយកអំណរសប្បាយចេញពីចិត្តអ្នករាល់គ្នាបានឡើយ។*

សូមអានគម្ពីរហេប្រឺ១០:៣៤; គម្ពីរយ៉ាកុប៥:១១; គម្ពីរវិវរណៈ១២:២; គម្ពីររ៉ូម ៨:១៨; គម្ពីរយ៉ូហាន ១៦:២០-២២; គម្ពីរលូកា៦:២១-២៣ផង។

ភាពពេញដោយអំណរ គឺជារបៀបរស់នៅមួយរបស់គ្រិស្តបរិស័ទ។ យើងមិនត្រឹមតែអាចទទួលបានអំណរនៅកណ្តាលចំណោមបញ្ហាប៉ុណ្ណោះទេ ប៉ុន្តែការមានអំណរសប្បាយនៅក្នុងព្រះអម្ចាស់គឺជា*ថ្នាំបន្សាប* សម្រាប់ទុក្ខព្រួយ និង ភាពសោកសៅ (សូមមើលនៅក្នុងគម្ពីរនេហេមា ៨:១០ គម្ពីរទំនុកតម្កើង ៣០:៥ និង គម្ពីរកូឡូស១:១០-១២) ។

គ្រិស្តបរិស័ទដឹងថាទោះបីជាសេចក្តីស្លាប់គឺជារឿងដែលមិនអាចជៀសផុត ដោយសារតែអំពើបាបក៏ដោយ វាបានបង្ក្រាបដោយព្រះគ្រិស្តហើយ (គម្ពីរវិវរណៈ ១:១៧-១៨; គម្ពីរ១កូរិនថូស១៥:១-៨ គម្ពីរយ៉ូហាន ១១:២៦)។ ជំនឿលើព្រះគ្រិស្តមិនបាននាំយើងឲ្យចូលទៅក្នុងកន្លែងដែលគួរឲ្យខ្លាច និង ងងឹតសូន្យសុងនោះឡើយ។ នោះមិនមែនជារូបភាពនៃសេចក្តីស្លាប់នោះទេ សម្រាប់គ្រិស្តបរិស័ទ! អស់អ្នកដែលឈរនៅក្បែរសាកសពមនុស្សជាទីស្រឡាញ់របស់គេ មានអារម្មណ៍ក្រៀមក្រំដែលកើតមកពីការបែកបាក់ ប៉ុន្តែសម្រាប់អ្នកស្លាប់នោះវិញ គឺ មានសិរីរុងរឿង អំណរ ចាប់ផ្តើមកើតឡើង ។

ផ្ទុយទៅវិញ បងប្អូនចូលមកជិតភ្នំស៊ីយ៉ូន មកជិតក្រុងរបស់ព្រះដ៏មានព្រះជន្មរស់ គឺក្រុងយេរូសាឡឹមនៅស្ថានបរមសុខដែលមានទេវតា*រាប់លានរាប់កោដិ និងមានក្រុមជំនុំរបស់ពួកវៀមច្បងដែលមានឈ្មោះកត់ទុកនៅស្ថានបរមសុខកំពុងជួបជុំគ្នាយ៉ាងអធិកអធម។ បងប្អូន ចូលមកជិតព្រះជាម្ចាស់ ដែលវិនិច្ឆ័យមនុស្សទាំងអស់ និងចូលមកជិតវិញ្ញាណក្ខ័ន្ធអ្នកសុចរិត ដែលបានគ្រប់លក្ខណៈ បងប្អូនចូលមកជិតព្រះយេស៊ូ ដែលជាស្ពាននៃសម្ពន្ធមេត្រី*ថ្មី ហើយចូលមកជិតព្រះលោហិតសំរាប់ប្រោះ គឺ

ជាព្រះលោហិតដែលទូលអង្វរ ប្រសើរជាង លោហិតរបស់លោកអេបិលទៅទៀត។ (គម្ពីរហេប្រឺ ១២: ២២-២៤)

ការចុះចូល

នៅពេលដែលមានទុក្ខលំបាកចូលមក យើងក៏អធិស្ឋានសម្រាប់ការរំដោះឲ្យរួចផុតពីទុក្ខលំបាកនោះដូចជាព្រះយេស៊ូដែរ។ ជារឿយៗ ព្រះជាម្ចាស់ប្រទានឲ្យមានការប្រោសលោះដោយព្រះទ័យមេត្តា ប៉ុន្តែនៅតែមានពេលដែលការអធិស្ឋានរបស់យើងមិនត្រូវបានឆ្លើយតបតាមការដែលយើងចង់បាននោះទេ។ គ្រាបែបនេះអាចគ្មានអ្វីទាក់ទងជាមួយនឹងការខ្វះជំនឿនោះទេ។ វាប្រហែលជាត្រូវការជំនឿច្រើនដើម្បីតស៊ូជាមួយនឹងបញ្ហាដ៏ធ្ងន់ធ្ងរ និង ដើម្បីរក្សាវិញ្ញាណត្រឹមត្រូវទៅចំពោះព្រះជាម្ចាស់ ជាជាងដើម្បីធ្វើឲ្យមានការអស្ចារ្យមួយកើតឡើងទៅទៀត។ មិនថាចម្លើយដែលបានទទួលនោះជាអ្វីក៏ដោយ យើងក៏ត្រូវតែបញ្ជាក់ជាមួយព្រះយេស៊ូថា៖ "មិនមែនតាមការចង់បានរបស់ខ្ញុំនោះទេ តែជាអ្វីដែលទ្រង់សព្វព្រះទ័យវិញ" ។

មានមនុស្សម្នាក់បាននិយាយថា៖ "ការសម្តែងឲ្យឃើញពីការចុះចូលទាំងស្រុងទៅចំពោះព្រះជាម្ចាស់ គឺទាមទារឲ្យមានការឈឺចាប់" ការទទួលស្គាល់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ប្រហែលជាអាចផ្ទុយទៅនឹងនិស្ស័យជាមនុស្សរបស់យើង។ វាអាចទាមទារឲ្យមានការស្ម័គ្រចិត្តរងទុក្ខផងដែរ៖

"អ្នកណាមិនយកឈើឆ្កាងរបស់ខ្លួន ហើយមិនមកតាមខ្ញុំទេ អ្នកនោះមិនសមធ្វើជាសិស្សរបស់ ខ្ញុំឡើយ។ អ្នកណាចង់រក្សាទុកជីវិតរបស់ខ្លួន អ្នកនោះនឹងបាត់បង់ជីវិត រីឯអ្នកដែលបាត់បង់ជីវិត ព្រោះតែខ្ញុំ នឹងបានជីវិតនោះមកវិញ"។ (គម្ពីរម៉ាថាយ ១០:៣៨-៣៩)

"ប្រសិនបើបងប្អូនរស់នៅតាមនិស្ស័យលោកីយ៍ បងប្អូននឹងត្រូវស្លាប់ជាមិនខាន ផ្ទុយទៅវិញ ប្រសិនបើបងប្អូនពឹងផ្អែកលើព្រះវិញ្ញាណ ដើម្បីរំលាយរបៀបរស់នៅតាមនិស្ស័យលោកីយ៍បងប្អូនមុខតែមានជីវិត" (គម្ពីររ៉ូម៨:១៣)

គម្ពីររ៉ូម១៤:៧ បង្រៀនយើងថាក្នុងចំណោមយើងរាល់គ្នា គ្មាននរណាម្នាក់រស់នៅសម្រាប់ខ្លួនឯង ហើយក៏មិនមែនស្លាប់ដើម្បីខ្លួនឯងនោះទេ ។ យើងរស់ និងស្លាប់ សម្រាប់ព្រះអម្ចាស់ ហើយដោយធ្វើបែបនេះយើងក៏បានជះឥទ្ធិពលយ៉ាងខ្លាំងក្លាទៅដល់អស់អ្នកដែលនៅជុំវិញយើង។ ប្រសិនបើអ្នកត្រូវបានគ្រាស់ហៅឲ្យទទួលទុក្ខលំបាក ប្រហែលជាបទពិសោធន៍របស់អ្នក (ឬក៏ការឆ្លើយតបរបស់អ្នកទៅចំពោះបញ្ហានោះ) នឹងអាចមានឥទ្ធិពលដែលអាចផ្លាស់ប្តូរជីវិតរបស់នរណាម្នាក់ជាមិនខាន។ (គម្ពីរ២កូរិនថូស ១:៤-៥)

ចក្ខុវិស័យដ៏ល្អវិសុទ្ធ

តើគោលការណ៍នៅក្នុងព្រះគម្ពីរដែលអ្នកទើបតែនឹងបានរៀននៅក្នុងចំណុចនេះ គួរតែអាចផ្លាស់ប្តូរជីវិតរបស់អ្នកបានយ៉ាងដូចម្តេច?

ពេលវេលា៖ នៅក្នុងគម្ពីរទំនុកតម្កើងជំពូក៩០ លោកម៉ូសេដែលជាមនុស្សរបស់ព្រះជាម្ចាស់លោកបានអធិស្ឋានថា៖ "សូមណែនាំយើងខ្ញុំអោយដឹងច្បាស់ថា អាយុជីវិតយើងខ្ញុំកំណត់ត្រឹមណា" (គម្ពីរទំនុក

តម្កើង៩០:១២)។ ការដឹងច្បាស់ថា សេចក្តីស្លាប់នឹងចូលមកក្នុងយើងទាំងអស់គ្នា ធ្វើឲ្យយើងមានការប្រុងប្រយ័ត្នអំពីរបៀបដែលយើងប្រើប្រាស់ពេលវេលាដែលព្រះជាម្ចាស់បានប្រទានឲ្យយើង។ សេចក្តីស្រឡាញ់សម្រាប់ព្រះជាម្ចាស់ និង ការបម្រើអ្នកដទៃគឺជាតម្លៃដ៏អស្ចារ្យដែលនៅស្ថិតស្ថេរអស់កល្បជានិច្ច ហើយ វាក៏ធ្វើឲ្យព្រះជាម្ចាស់គាប់ព្រះហឫទ័យផងដែរ។

គុណតម្លៃ៖ នៅពេលអ្នកដឹងថា អ្វីៗដែលនៅលើផែនដីនេះ គឺអាចនឹងបាត់បង់ ហើយគ្រាន់តែបណ្តោះអាសន្ននោះ មានន័យថាអ្នកឃើញពីរូបភាពពិតរបស់វាហើយ។ របស់ទាំងនោះមានវត្តមាននៅលើផែនដីនេះសម្រាប់យើងប្រើប្រាស់វាតែប៉ុណ្ណោះ ប៉ុន្តែមិនត្រូវប្រកាន់ខ្ជាប់វាខ្លាំងពេកនោះទេ។ ឲ្យតម្លៃទៅលើអ្វីដែលជារបស់លោកីយ៍តែបន្តិចបន្តួចបានហើយ ហើយត្រូវឲ្យតម្លៃទៅលើអ្វីដែលនៅឯស្ថានបរមសុខឲ្យបានច្រើនវិញ។ ភាពសប្បាយរីករាយ និង អំណរ ដ៏ពិតគឺមានសម្រាប់អស់អ្នកដែលស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ជាមុខ ទោះបីកំពុងស្ថិតនៅក្នុងកណ្តាលចំណោមទុក្ខលំបាកយ៉ាងណាក៏ដោយ។

ការកំសាន្តចិត្ត៖ ដោយគ្រាន់តែមានវត្តមានរបស់គេ គ្រិស្តបរិស័ទដែលចេះខ្វល់ខ្វាយ គេអាចបម្រើអ្នកដែលអារម្មណ៍ឈឺចុកចាប់ និង ឯកា ដោយសារតែជំងឺ ជិតស្លាប់ និង ញាតិមិត្តរបស់អ្នកស្លាប់ទៀតផង។

ការប្តេជ្ញាចិត្ត៖ ដោយសារតែអ្នកបានស្គាល់ព្រះគ្រិស្តដែលបានសន្យាថាប្រទានជីវិតអស់កល្បឲ្យអ្នក អ្នកបានធូរស្បើយក្នុងចិត្តផុតពីភាពភ័យខ្លាច និង ការព្រួយបារម្ភអំពីសេចក្តីស្លាប់។ ព្រះយេស៊ូទទួលយកភាពជាមនុស្សដូចយើង "ដោយកូនចៅនោះជាប់សាច់ឈាមជាមួយគ្នា ព្រះអង្គក៏បានយកឋានៈជាមនុស្សរួមជាមួយគេដែរ ហើយព្រះអង្គសោយទិវង្គត ដើម្បីកំទេចមារ*ដែលមានអំណាចលើសេចក្តីស្លាប់ និងដើម្បីរំដោះអស់អ្នកដែលជាប់ជាទាសករមួយជីវិត ព្រោះតែខ្លាចស្លាប់។" (គម្ពីរហេប្រឺ២:១៤-១៥)។ អ្នកអាចថ្វាយខ្លួនអ្នកទាំងស្រុងទៅចំពោះព្រះជាម្ចាស់ ជាព្រះអាទិករដ៏ស្មោះត្រង់របស់អ្នក ដែលផ្គត់ផ្គង់អ្នក ហើយបន្តធ្វើការល្អទៅមុខទៀត (គម្ពីរ១ពេត្រុស ៥:២)។

លំហាត់អនុវត្តន៍

---

១៧ ចូរសរសេរអក្សរ **ស** នៅក្នុងចន្លោះបន្ទាត់ប្រសិនបើប្រយោគខាងក្រោមបញ្ជាក់ពីគោលការណ៍ដែលត្រឹមត្រូវ ឬស័ក្តិសម ដែលនិយាយអំពីឥរិយាបថរបស់គ្រិស្តបរិស័ទទៅចំពោះការរងទុក្ខលំបាក និងការស្លាប់។ ចូរសរសេរ **ខ** នៅក្នុងចន្លោះបន្ទាត់ប្រសិនបើប្រយោគនោះខុស(ខ្សោយ) ឬ មិនពេញលេញ។

.....ក) ការជឿជាក់លើព្រះជាម្ចាស់ គឺផ្អែកទៅលើការរំដោះឲ្យផុតពីការរងទុក្ខ និង ការឈឺចាប់។

.....ខ) ព្រះជាម្ចាស់តែងតែមានបំណងព្រះហឫទ័យ អនុញ្ញាតឲ្យយើងរងទុក្ខលំបាក។

.....គ) ការដើរតាមព្រះគ្រិស្ត គឺរាប់បញ្ចូលទាំងការស្ម័គ្រចិត្តទទួលយកទុក្ខលំបាកដូចជាទ្រង់ដែរ។

.....ឃ) ការអរសប្បាយអាចកើតមាននៅក្នុងទុក្ខលំបាកបាន មិនត្រឹមតែដោយសារផលប្រយោជន៍នាពេលបច្ចុប្បន្ននេះប៉ុណ្ណោះទេ តែក៏ដោយសារសិរីរុងរឿងនាពេលអនាគតផង

.....ង) យើងប្រកាន់យកទ្រព្យសម្បត្តិលោកីយ៍ខ្លាំងយ៉ាងណា យើងក៏ត្រូវបានទាមទារឲ្យរងទុក្ខលំបាកខ្លាំងយ៉ាងនោះដែរ។

.....ច) ប្រសិនបើយើងបានដឹងយ៉ាងជាក់ច្បាស់អំពី លទ្ធភាពនៃការស្លាប់របស់យើង យើងនឹងផ្តល់តម្លៃកាន់តែច្រើនថែមទៀតទៅលើករបៀបដែលយើងប្រើប្រាស់ពេលវេលា។

.....ឆ) ប្រសិនបើយើងឆ្លើយតបទៅនឹងទុក្ខលំបាករបស់យើងតាមរបៀបមួយដូចជាព្រះគ្រិស្ត យើងនឹងអាចមានឥទ្ធិពល ឬ អាចកំសាន្តចិត្តអ្នកដទៃដែលកំពុងរងទុក្ខលំបាកផងដែរ។

.....ជ) គ្រិស្តបរិស័ទត្រូវតែទទួលរងទុក្ខលំបាកយ៉ាងខ្លាំងដើម្បី សបញ្ជាក់ពីជំនឿរបស់គេ និងដើម្បីកំសាន្តចិត្តអ្នកដទៃផងដែរ។

ការប្រឡងផ្ទាល់ខ្លួន

សំណួរពហុជម្រើស។ ចូរជ្រើសរើសចម្លើយដែលល្អជាងគេបំផុតនៅក្នុងសំណួរនីមួយៗ។

១. របៀបមួយដែលការឈឺចាប់ត្រូវបានគេចាត់ទុកថា ជាព្រះពរ គឺថាវា
   ក) ឈឺ
   ខ) គឺជាបទពិសោធន៍របស់មនុស្សទូទៅ។
   គ) ព្រមានយើងអំពីបញ្ហាដែលទាមទារឲ្យមានការយកចិត្តទុកដាក់។
   ឃ) គឺជាមធ្យោបាយដែលព្រះជាម្ចាស់រំឭកយើងថា យើងបានស្នងនិស្ស័យបាបមួយនេះ។

២. ពេលខ្លះព្រះជាម្ចាស់អនុញ្ញាតឲ្យយើងបានទទួលរងការឈឺចាប់ ដោយសារយើង
   ក) បដិសេធទ្រង់នៅពេលដែលទ្រង់មានព្រះបន្ទូលមកកាន់យើងតាមរបៀបផ្សេង។
   ខ) សមតែទទួលរងទុក្ខលំបាក។
   គ) មិនអាចនឹងជួយអ្នកដទៃបាននោះទេ ប្រសិនបើយើងមិនបានរងទុក្ខ។
   ឃ) ថ្វាយបង្គំទ្រង់ ដោយមូលហេតុមិនត្រឹមត្រូវ។

៣. នៅពេលដែលព្រះជាម្ចាស់ជ្រើសរើសប្រៀនប្រដៅយើង ដោយអនុញ្ញាតឲ្យយើងរងទុក្ខលំបាក ក៏ព្រោះតែទ្រង់
   ក) សព្វព្រះហឫទ័យធ្វើឲ្យយើងឈឺចាប់។
   ខ) ក្រោធជាមួយនឹងយើង។
   គ) សព្វព្រះហឫទ័យ ធ្វើឲ្យយើងមានភាពគ្រប់គ្រាន់សម្រាប់ខ្លួនឯង។
   ឃ) ស្រឡាញ់យើងខ្លាំងណាស់។

៤. គុណប្រយោជន៍ខាងឯវិញ្ញាណ នៃការរងទុក្ខលំបាកគឺប្រសើរលើសការឈឺចាប់ទាំងប៉ុន្មានដែលយើងត្រូវទទួលរង ព្រោះតែការរងទុក្ខក្នុងពេលបច្ចុប្បន្នរបស់យើងនាំទៅរក
   ក) សេចក្តីស្លាប់
   ខ) ការយល់ដឹង
   គ) សិរីរុងរឿងនាពេលអនាគត
   ឃ) ភាពធូរស្បើយបណ្តោះអាសន្ន

៥. ទោះបីជាលោកយ៉ូបមានការឆ្លើយតបអវិជ្ជមានមួយចំនួន ទៅនឹងការឈឺចាប់របស់លោកក៏ដោយ ក៏ការឆ្លើយតបដ៏រឹងមាំរបស់លោកគឺ
   ក) ផ្តាសាព្រះជាម្ចាស់
   ខ) រក្សាជំនឿរបស់លោកលើព្រះជាម្ចាស់ ហើយបន្តថ្វាយបង្គំទ្រង់។
   គ) ថ្នាំងថ្នាក់ជាមួយនឹងមិត្តភក្តិរបស់លោក ព្រោះពួកគេមិនរងទុក្ខដូចគ្នា។
   ឃ) បន្ទោសខ្លួនឯងចំពោះអ្វីៗដែលកើតមានឡើងមកលើរូបលោក។

៦ តើមួយណានៅខាងក្រោមនេះ ដែលប្រាប់ពីការឆ្លើយតបរបស់គ្រិស្តបរិស័ទទៅនឹងសេចក្តីស្លាប់ដែលអាចកើតមាន ដោយផ្អែកទៅលើជំនឿរបស់គាត់លើព្រះជាម្ចាស់?

ក) សង្ឃឹម

ខ) បដិសេធ

គ) កំហឹង

ឃ) ការទទួលស្គាល់ការពិត

៧ តើដំណាក់កាលមួយណានៅខាងក្រោមនេះ ត្រូវបានបង្ហាញឲ្យឃើញនៅក្នុងមនុស្សដែលបានសន្យាជាមួយព្រះជាម្ចាស់ថា គេនឹងថ្វាយមួយភាគដប់របស់ពួកគេដោយភាពទៀងត្រង់ប្រសិនបើទ្រង់ប្រោសគេឲ្យបានជា?

ក) កំហឹង

ខ) សង្ឃឹម

គ) បាក់ទឹកចិត្ត

ឃ) ការតវ៉ា

៨ តើនៅក្នុងដំណាក់កាលណាមួយនៅខាងក្រោមនេះដែលមនុស្សប្រឈមមុខជាមួយនឹងភាពសោកសៅរបស់ពួកគេទៅនឹងសេចក្តីដែលអាចកើតមានលើពួកគេ និងការចាកចេញពីគ្រួសាររបស់ពួកគេ ព្រមទាំងផែនការរបស់ពួកគេទាំងអស់សម្រាប់អនាគត?

ក) កំហឹង

ខ) ការបាក់ទឹកចិត្ត

គ) ការបដិសេធ

ឃ) សង្ឃឹម

៩ តើពេលណាដែលជាពេលល្អបំផុតដើម្បីពិភាក្សាជាមួយគ្រួសារអំពីបញ្ហាដែលទាក់ទងទៅ នឹងអ្វីខ្លះដែលអ្នកចង់ឲ្យគ្រួសាររបស់អ្នកបានដឹង ឬ ធ្វើក្នុងករណីដែលអ្នកស្លាប់បាត់ទៅ?

ក) នៅពេលដែលអ្នកជិតស្លាប់។

ខ) ភ្លាមៗបន្ទាប់ពីអ្នកបានដឹងខ្លួនថាអ្នកមានជំងឺដំណាក់កាលចុងក្រោយ។

គ) ក្នុងអំឡុងពេលដែលអ្នកនៅមានសុខភាពល្អ។

ឃ) នៅពេលដែលអ្នកមានអាយុក្បែរ ៧០ឆ្នាំ

១០ តើខាងក្រោមនេះ មួយណាដែលមិនមែនជាមធ្យោបាយល្អក្នុងការជួយអ្នកដែលកំពុងរងទុក្ខលំបាក ឬ ជិតស្លាប់?

ក) មានពេលទំនេរដើម្បីជួយ

ខ) មានភាពស្មោះត្រង់នៅក្នុងការបង្ហាញពីអារម្មណ៍របស់អ្នក

គ) ឆាប់ទទួលអារម្មណ៍ដឹងពីតម្រូវការពិសេសៗរបស់គេ

ឃ) ធ្វើពុតដូចជាពួកគេនឹងអាចជាសះស្បើយពីភាពឈឺចាប់របស់ពួកគេ និងមិនស្លាប់នោះទេ។

ង) អធិស្ឋានដើម្បីឲ្យពួកគេបានប្រោសលោះ និង ប្រោសឲ្យជាពីជំងឺ។

១១ តើការឆ្លើយតបរបស់ព្រះគ្រិស្តទៅចំពោះទុក្ខលំបាក ជាគំរូសម្រាប់យើងបានដោយរបៀបណា?

ក) ទ្រង់រំពឹងថា ព្រះជាម្ចាស់នឹងរំដោះទ្រង់ឲ្យផុតពីទុក្ខលំបាក។

ខ) ទ្រង់អធិស្ឋានសុំការរំដោះឲ្យផុតទុក្ខ តែការប្រទានឲ្យមានការរំដោះនោះ គឺស្រេចតែបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ទ្រង់តែប៉ុណ្ណោះ។

គ) ទ្រង់ទទួលរងទុក្ខលំបាករបស់ទ្រង់ ដោយមិនបង្ហាញឲ្យឃើញពីអារម្មណ៍អ្វីសោះឡើយ។

ឃ) ទ្រង់ភ័យខ្លាចការឈឺចាប់ដែលទ្រង់ត្រូវបានត្រាស់ហៅឲ្យទទួលរង។

១២ តើមួយណានៅក្រោមនេះ ដែលមិនបានបង្ហាញពីការឆ្លើយតបរបស់គ្រិស្តបរិស័ទទៅនឹងទុក្ខលំបាក?

ក) ការដកថយ

ខ) ទំនុកចិត្ត

គ) អំណរ

ឃ) ការចុះចូល

ង) ចក្ខុវិស័យដ៏វិសុទ្ធ

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

៩ ចម្លើយរបស់អ្នក

១ ការឈឺចាប់ អនុញ្ញាតឲ្យយើងដឹងខ្លួនថា យើងមានបញ្ហាដែលត្រូវការដោះស្រាយ។ នៅក្នុងករណីនេះបញ្ហាដែលយើងបានដឹង វាគឺជាបញ្ហាខាងឯវិញ្ញាណ។

១០ តាមរយៈ ការពិភាក្សាពីរឿងទាំងនោះជាមួយសមាជិកគ្រួសារក្នុងពេលនេះ និងផ្តល់មធ្យោបាយគ្រប់បែបយ៉ាងដើម្បីធានាភាពសុខដុមរបស់គ្រួសារ (ដូចជាការទទួលបានការធានារ៉ាប់រង ការធ្វើសំបុត្របណ្តាំ និង ការរៀបចំអាណាព្យាបាលសម្រាប់កូនៗ)

២ គ) ប្រៀនប្រដៅកូនប្រុសរបស់គាត់ យ៉ាងច្រើនទៅតាមការគួរ ដើម្បីបង្រៀនគេថាគេគួរមានអាកប្បកិរិយាបែបណា។

១១ ក) ២) កំហឹង
ខ) ៦) សង្ឃឹម
គ) ៥) ការទទួលស្គាល់
ឃ) ១) បដិសេធ
ង) ៣) ការតថ្លៃ
ច) ៤) ការបាក់ទឹកចិត្ត

៣ ការឈឺចាប់អនុញ្ញាតឲ្យយើង ដឹងថាមានអ្វីមួយមិនប្រក្រតី ឲ្យយើងដឹងថាមានបញ្ហាដែលយើងត្រូវដោះស្រាយ។

១២ ចម្លើយរបស់អ្នក។ ដោយជំនឿរបស់ខ្ញុំលើព្រះគ្រិស្ត ខ្ញុំដឹងថាសេចក្តីស្លាប់មិនមែនជាទីបញ្ចប់នោះទេ ប៉ុន្តែជាការចាប់ផ្តើមវិញ។ ខ្ញុំអាចប្រឈមមុខជាមួយនឹងគំនិតអំពីការស្លាប់ ព្រោះខ្ញុំទុកចិត្តលើព្រះជាម្ចាស់ ដឹងថាទ្រង់ជាអ្នកគ្រប់គ្រងលើជីវិតនិងសេចក្តីស្លាប់របស់ខ្ញុំ។

៤ ចម្លើយណាក៏បានក្នុងចំណោមចម្លើយទាំងនេះ៖ អ្នកណាដែលស្គាល់ការឈឺចាប់ គឺជាអ្នកដែលអាចកំសាន្តចិត្តអ្នកដែលមានការឈឺចាប់ប្រសើរជាងគេ ។ ការរងទុក្ខលំបាកសម្អាតយើងឲ្យបរិសុទ្ធ និង សបញ្ជាក់ពីជំនឿរបស់យើង។ ការរងទុក្ខបង្កើតលក្ខណសម្បត្តិរបស់ព្រះគ្រិស្តនៅក្នុងយើង។

១៣ ខ), គ), ឃ), ច) និង ឆ) គឺជាចម្លើយត្រឹមត្រូវ។

៥ ការរៀបរាប់របស់អ្នកគួរតែមានរួមបញ្ចូលចំណុចប៉ុន្មានដូចតទៅនេះ៖ អាកប្បកិរិយាមិនត្រឹមត្រូវ ឥរិយាបថមិនល្អ ការមើលស្រាលខ្លួនឯង ការអាក់អន់ចិត្ត អស់សង្ឃឹម កំហឹង ការថ្នាំងថ្នាក់ចិត្ត ការសង្ស័យ ភាពភ័យខ្លាច។

១៤ ចម្លើយរបស់អ្នកត្រូវតែស្រដៀងទៅនឹងចម្លើយដូចតទៅនេះ៖ ដោយសារតែយើងបានដឹងថា ព្រះគ្រិស្តបានយកឈ្នះលើសេចក្តីស្លាប់ សម្រាប់អស់អ្នកដែលទទួលកិច្ចការបង់ថ្លៃលោះបាបរបស់ទ្រង់ យើងដឹងថាក្តីស្រឡាញ់មនុស្សជាទីស្រឡាញ់របស់យើងដែលជាគ្រិស្តបរិស័ទនោះបានទៅនៅក្នុងព្រះវត្តមានរបស់ព្រះអង្គហើយបន្ទាប់ពីស្លាប់ទៅ ហើយដឹងថា ថ្ងៃណាមួយយើងអាចជួប គ្នាម្តងទៀតនៅក្នុងព្រះវត្តមានរបស់ទ្រង់។ ការយល់ដឹងបែបនោះបានកាច់ទ្រនិចមច្ចុរាជ ហើយផ្តល់សេចក្តីសុខសាន្តដល់យើងរាល់គ្នា។

៦ លោករក្សាជំនឿរបស់លោកលើព្រះជាម្ចាស់ក្នុងគ្រប់បញ្ហាទាំងអស់។ លោកមិនដែលឈប់ថ្វាយបង្គំព្រះជាម្ចាស់ឡើយ។

១៥ ទ្រង់បានរងទុក្ខលំបាក។

៧ ចម្លើយរបស់អ្នក។ ប្រសិនបើអ្នកនៅតែស្វែងរកដំណោះស្រាយសម្រាប់បញ្ហាក្នុងផ្នែកនេះ ចូរប្រើប្រាស់វិធីដោះស្រាយបញ្ហាដែលយើងបានផ្តល់ជូន ហើយចូររំពឹងឲ្យព្រះជាម្ចាស់ជួយអ្នក!

១៦ ចម្លើយរបស់អ្នកគួរតែស្រដៀងជាមួយនឹងចម្លើយដូចតទៅនេះ៖ ព្រះជាម្ចាស់អាចរំដោះខ្ញុំឲ្យផុត ពីទុក្ខលំបាក និង សេចក្តីស្លាប់ ប្រសិនបើនោះជាបំណងព្រះហឫទ័យរបស់ទ្រង់សម្រាប់ខ្ញុំ។ ខ្ញុំនឹងអធិស្ឋានសុំការប្រោសលោះ ប៉ុន្តែខ្ញុំក៏ទទួលយកអ្វីដែលទ្រង់ជ្រើសរើសសម្រាប់ជាប្រយោជន៍ដ៏អស់កល្បរបស់ខ្ញុំ ទោះបីវាជាការប្រោសលោះ ទុក្ខលំបាក ឬ សេចក្តីស្លាប់ក៏ដោយ។

៨ ចម្លើយរបស់អ្នក។ កំហឹង គឺប្រាកដជាប្រតិកម្មឆ្លើយតបដំបូងគេ ទៅនឹង ការគំរាមកំហែងនៃសេចក្តីស្លាប់ ព្រោះតែសេចក្តីស្លាប់គឺជាសត្រូវមួយរបស់យើង (គម្ពីរ១កូរិនថូស ១៥:២៦) ។ ប៉ុន្តែព្រះគ្រិស្តបានយកឈ្នះលើសេចក្តីស្លាប់ហើយ ដូច្នេះយើងអាចទទួលយកអ្វីៗដែលកើតឡើង ប្រសិនបើយើងថ្វាយជីវិតរបស់យើងទៅក្នុងការថែទាំរបស់ទ្រង់។ ប៉ុន្តែយើងត្រូវតែអធិស្ឋានសុំការប្រោស ឲ្យជាសះស្បើយ ហើយមានជំនឿលើព្រះជាម្ចាស់ យើងត្រូវតែស្វែងរកការប្រោះលោះឲ្យផុតពីសេចក្តីស្លាប់។

១៧ ក) ខ
ខ) ស
គ) ស
ឃ) ស
ង) ខ
ច) ស
ឆ) ស
ជ) ខ

មេរៀន ១០ ការរក្សាក្តីសង្ឃឹម

នៅក្នុងកំណាព្យរបស់លោកដេនតេ ចំណងជើង*អ៊ីនហ្វឺណូ* ដែលភាសាអ៊ីតាលីមានន័យថា ឋាននរគ (Dante's *Inferno*) លោកបានរៀបរាប់អំពីខ្លោងទ្វារនរគ។ សញ្ញាដែលបានបង្ហាញនៅលើមាត់ទ្វារនោះសរសេរថា៖ " អស់អ្នករាល់គ្នាដែលបានចូលទៅខាងក្នុង ចូរលះបង់សង្ឃឹមចោលទៅ" ។

គ្មាននរណាម្នាក់ក្នុងចំណោមយើងរាល់គ្នាដឹងពីចម្លើយពេញលេញ និង ចុងក្រោយបំផុតនៃការរងទុក្ខលំបាកឡើយ។ ព្រះជាម្ចាស់អាចនឹងមិនបង្ហាញឲ្យយើងបានឃើញពីហេតុផលនៃបញ្ហារបស់យើងនោះទេ ប៉ុន្តែទ្រង់បង្គាប់ឲ្យយើងជឿថា បញ្ហាគ្រប់ទាំងអស់គឺសុទ្ធតែមានគោលបំណងរបស់វា ដើម្បីធ្វើអ្វីៗដែលល្អបំផុតសម្រាប់យើង។ ហើយយើងរាល់គ្នាដែលជាអ្នកស្គាល់ និង ស្រឡាញ់ព្រះអម្ចាស់ យើងមានក្តីសង្ឃឹមប្រកបដោយព្រះពរមួយនេះ៖ គឺថាជីវិតនេះប្រៀបដូចជាការរត់ប្រណាំងមួយយ៉ាងដូច្នោះដែរ ហើយនៅចុងបញ្ចប់នៃការប្រណាំងនោះគឺមិនមែនសេចក្តីស្លាប់ ហើយសេចក្តីស្លាប់នោះនឹងគ្រាន់តែនាំយើងឆ្លងច្រកចូលទៅរកជីវិតអស់កល្បជានិច្ច! ពិតជាក្តីសង្ឃឹមដ៏ល្អប្រសើរបំផុតមួយមែន!

> សេចក្តីសង្ឃឹមនេះប្រៀបបីដូចជាយុថ្កាមួយដ៏ជាប់មាំមួន សំរាប់ព្រលឹងរបស់យើង ហើយក៏បានចូលហួសវាំងននទៅក្នុងទីសក្ការៈថែមទៀតផង គឺឆ្ពោះទៅកាន់កន្លែងដែលព្រះយេស៊ូបានយាងចូលទៅមុន ដើម្បីជាប្រយោជន៍ដល់យើង។ (គម្ពីរហេប្រឺ ៦:១៩-២០)

យើងមិនដឹងថានៅថ្ងៃអនាគតនឹងមានរឿងអ្វីកើតឡើងចំពោះយើងនោះទេ។ ប៉ុន្តែយើងគិតថានរណាជាអ្នកគ្រប់គ្រងអនាគតរបស់យើង ហើយទ្រង់បានបង្ហាញមកកាន់យើងថា នៅក្នុងទ្រង់មាន*សេចក្តីសង្ឃឹម*! នៅក្នុងមេរៀននេះ យើងនឹងពិចារណាអំពីអ្វីដែលបទគម្ពីរបានថ្លែងអំពីក្តីសង្ឃឹមរបស់គ្រិស្តបរិស័ទ ហើយយើងនឹងមើលទៅលើរបៀបក្នុងការរក្សាក្តីសង្ឃឹមនោះ។ នៅថ្ងៃណាមួយ គ្រប់បញ្ហាទាំងអស់របស់យើងនឹងនៅក្រោយយើងវិញ ហើយយើងនឹងត្រូវបាននាំឲ្យឆ្លងកាត់ខ្លោងទ្វារនៃស្ថានបរមសុខ គឺជាកន្លែងដែលព្រះយេស៊ូគ្រិស្តជាសេចក្តីសង្ឃឹមដ៏អស់កល្បជានិច្ចរបស់យើង!

គម្រោងមេរៀន

ក. តាមរយៈព្រះគ្រិស្តជាព្រះដ៏មានជ័យជម្នះ
ខ. តាមរយៈការអះអាងបញ្ជាក់
គ. តាមរយៈជំនឿ

វត្ថុបំណងមេរៀន

នៅពេលអ្នកបានបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. តាមរយៈខគម្ពីរដែលបានផ្តល់ជូន អ្នកនឹងស្គាល់ពីរបៀបដែលក្តីសង្ឃឹមរបស់យើងផ្អែកទៅលើព្រះគ្រិស្ត ជាព្រះដ៏មានជ័យជម្នះ ។
២. ស្គាល់ពីការសន្យារបស់ព្រះជាម្ចាស់ មាននៅក្នុងបទគម្ពីរដែលយើងអាចទទួលបាន និងស្គាល់ពីលក្ខខ័ណ្ឌដែលគាំទ្រការសន្យារបស់ទ្រង់។
៣. សរសេរការថ្លែងអះអាងបញ្ជាក់ ដោយយោងទៅតាមគោលការណ៍ព្រះគម្ពីរ អំពីអ្វីដែលព្រះជាម្ចាស់ បានធ្វើនៅអតីតកាល និង អ្វីដែលយើងអាចរំពឹងឲ្យទ្រង់ធ្វើនាពេលអនាគត។
៤. ស្គាល់ពីការថ្លែងដ៏ពិតប្រាកដ ដែលផ្សារភ្ជាប់បញ្ហារបស់យើង ទៅនឹងក្តីសង្ឃឹមដ៏អស់កល្បជានិច្ចថានឹងបានរួបរួមជាមួយព្រះជាម្ចាស់យ៉ាងពេញលេញ។

សកម្មភាពនៅក្នុងការសិក្សា

១. សិក្សាមេរៀនទៅតាមរបៀបធម្មតា។ ត្រូវប្រាកដថាបានអានខគម្ពីរទាំងអស់ដែលបានផ្តល់ជូន ដ្បិតវាមានសារសំខាន់ណាស់ដើម្បីស្វែងយល់មេរៀន។ ចម្លើយរាល់សំណួរសិក្សា ហើយផ្ទៀតផ្ទាត់ចម្លើយរបស់អ្នកជាមួយនឹងចម្លើយដែលយើងបានផ្តល់ជូន។
២. ស្វែងរកនិយមន័យពាក្យនៅក្នុងអក្ខរានុក្រម សម្រាប់ពាក្យសំខាន់ទាំងឡាយណាដែលអ្នកមិនស្គាល់។
៣. ធ្វើការប្រឡងផ្ទាល់ខ្លួន ហើយផ្ទៀតផ្ទាត់ចម្លើយរបស់អ្នក។
៤. បន្ទាប់ពីបានធ្វើការប្រឡងផ្ទាល់ខ្លួនហើយ ចូររំឭកមេរៀនទី៧ ដល់ទី១០ (ជំពូកទីបី)។ បន្ទាប់មកចូរធ្វើការប្រឡងនៅជំពូកទីបី។

ពាក្យសំខាន់

អះអាងបញ្ជាក់	រក្សា	បណ្តោះអាសន្ន
ការកោតសរសើរ	ការឆ្លុះបញ្ចាំង	ចលាចល
ឈ្វេងយល់	ប៉ាន់ប្រមាណ	ភាពពិសេសដាច់ឡែក

ក. តាមរយៈព្រះគ្រិស្តជាព្រះដ៏មានជ័យជម្នះ

វគ្គបំណែងទី១. *តាមរយៈខគម្ពីរដែលបានផ្តល់ជូន អ្នកនឹងស្គាល់ពីរបៀបដែលក្តីសង្ឃឹមរបស់យើងផ្អែកទៅលើព្រះគ្រិស្ត ជាព្រះដ៏មានជ័យជម្នះ ។*

យើងបានចាប់ផ្តើមមុខវិជ្ជានេះដោយបានលើកយកព្រះបន្ទូលរបស់ព្រះយេស៊ូថា៖ "អ្នករាល់គ្នាជួបនឹងទុក្ខវេទនានៅក្នុងលោក ប៉ុន្តែ ចូរមានសង្ឃឹមឡើង! ខ្ញុំបានឈ្នះលោកនេះហើយ។" (គម្ពីរយ៉ូហាន ១៦:៣៣)។ តាមរយៈការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ ទ្រង់បានយកឈ្នះលើអំណាចនៃអំពើបាប និង សេចក្តីស្លាប់។ នៅក្នុងព្រះជន្មរបស់ទ្រង់ ទ្រង់បានយកឈ្នះលើសេចក្តីល្បួងរបស់អារក្ស ដែលជាសត្រូវរបស់ទ្រង់។ ដោយឫទ្ធានុភាពរបស់ទ្រង់ យើងក៏អាចយកឈ្នះលើវាផងដែរ។

ព្រះយេស៊ូមានជ័យជម្នះលើសេចក្តីស្លាប់ និង ស្ថានមច្ចុរាជ (ស្ថាននរក)។ នៅពេលដែលលោកយ៉ូហានជាអ្នកសរសេរកណ្ឌគម្ពីរវិវរណៈបានឃើញព្រះយេស៊ូ លោកបានដួល "សន្លប់បាត់ស្មារតី" នៅទៀបព្រះបាទារបស់ទ្រង់។ ព្រះយេស៊ូបានមានព្រះបន្ទូលថា ៖ "កុំខ្លាចអី! គឺយើងនេះហើយដែលនៅមុនគេ និងនៅក្រោយគេបំផុត យើងបានស្លាប់ តែឥឡូវនេះ យើងមានជីវិតរស់អស់កល្បជាអង្វែងតរៀងទៅ។ យើងមានអំណាចលើសេចក្តីស្លាប់ និងលើស្ថានមច្ចុរាជ។
(គម្ពីរវិវរណៈ ១:១៧-១៨)។

ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញបន្ទាប់ពីទ្រង់ត្រូវបានគេឆ្កាង ហើយបញ្ចុះនៅក្នុងផ្នូរ។ ទ្រង់បានបង្ហាញព្រះកាយទ្រង់ទៅកាន់ពួកសាវ័ក និង មិត្តរបស់ទ្រង់ជាច្រើនលើក ព្រមទាំងទៅកាន់អ្នកដើរតាមទ្រង់ជាង ៥០០នាក់ទៀតនៅក្នុងពេលជាមួយគ្នានោះផងដែរ។ (គម្ពីរ១កូរិនថូស ១៥:១-៨)។

យោងទៅតាមព្រះបន្ទូលរបស់ព្រះយេស៊ូ អស់អ្នកដែលរស់នៅ និង ជឿលើទ្រង់ នោះនឹងមិនស្លាប់ឡើយ។ ព្រះយេស៊ូបានប្រើឱកាសក្នុងពេលដែលទ្រង់ប្រោសលោកឡាសារឲ្យរស់ពីស្លាប់ឡើងវិញ ដើម្បីបង្រៀនមេរៀននេះ។ ព្រះបន្ទូលរបស់ទ្រង់ទៅកាន់នាងម៉ាថានៅពេលនោះ បាននាំឲ្យមានភាពធូរស្បើយ និង សេចក្តីសង្ឃឹមទៅដល់អ្នកជឿគ្រប់គ្នា៖ " ខ្ញុំហ្នឹងហើយដែលប្រោសមនុស្សអោយរស់ឡើងវិញ ខ្ញុំនឹងផ្តល់អោយគេមានជីវិត។ អ្នកណាជឿលើខ្ញុំ ទោះបីស្លាប់ទៅហើយក៏ដោយ ក៏នឹងបានរស់ជាមិនខាន។ រីឯអស់អ្នកដែលកំពុងតែមានជីវិតនៅរស់ ហើយជឿលើខ្ញុំ មិនស្លាប់សោះឡើយ តើនាងជឿសេចក្តីនេះឬទេ?"
(គម្ពីរយ៉ូហាន ១១:២៥-២៦)

វាបានបង្ហាញឲ្យឃើញយ៉ាងច្បាស់នៅក្នុងសេចក្តីបង្រៀននៃបទគម្ពីរនេះថា អស់អ្នកដែលស្រឡាញ់ព្រះគ្រិស្តមិនស្លាប់នោះទេ ពួកគេគ្រាន់តែផ្លាស់ប្តូរទីកន្លែងប៉ុណ្ណោះ។ ពួកគេចាកចេញពីលំនៅបណ្តោះអាសន្នរបស់ពួកគេ (រូបកាយសាច់ឈាមរបស់ពួកគេ) ហើយចូលទៅក្នុងព្រះវត្តមានរបស់ព្រះអម្ចាស់តែម្តង (គម្ពីរ២កូរិនថូស ៥:៦,៨) ។ ដោយព្រះគ្រិស្តបានយកឈ្នះលើសេចក្តីស្លាប់ និង ទីបញ្ចុះមនុស្សស្លាប់ហើយ នោះយើងមានក្តីសង្ឃឹមដ៏អស់កល្បដែល នៅគង់វង្ស និង ប្រាកដប្រជា ជាក្តីសង្ឃឹមអំពីជីវិតអស់កល្បជានិច្ចនៅឯស្ថានបរមសុខជាមួយទ្រង់។

មានបទចម្រៀងចាស់មួយដែលនិពន្ធដោយ លោក អែតវ៉ាទ ម៉ូទ (Edward Mote) មានចំណងជើងថា "ថ្មដារឹងមាំ" ដែលបង្ហាញពីក្តីសង្ឃឹមដែលយើងមាននៅក្នុងព្រះគ្រិស្ត៖

ក្តីសង្ឃឹមរបស់ខ្ញុំ គឺសាងនៅអ្វី ដែលមិនក្រៅពី
ព្រះលោហិត និង ភាពសុចរិតរបស់ព្រះយេស៊ូទេ
ខ្ញុំមិនហ៊ានទុកចិត្តលើរូបកាយដ៏ល្អប្រពៃនោះទេ
ប៉ុន្តែអ្វីៗទាំងអស់គឺផ្អែកទៅលើព្រះនាមព្រះយេស៊ូវិញ

នៅពេលដែលស្បែងងឹតអន្ធការ គ្របបាំងព្រះភ័ក្ត្ររបស់ទ្រង់
ខ្ញុំបានសម្រាក ក្នុងព្រះគុណដែលមិនចេះផ្លាស់ប្រែរបស់ទ្រង់
នៅក្នុងខ្យល់ព្យុះបក់បោក យ៉ាងខ្លាំង
យុថ្ការបស់ខ្ញុំបោះជាប់នឹងស្បែទ្រង់

ពាក្យសច្ចាទ្រង់ សន្យារបស់ទ្រង់ ព្រះលោហិតទ្រង់
ទ្រខ្ញុំឡើងពីទឹកជំនន់ជន់លិច
ពេលអ្វីគ្រប់យ៉ាងនៅជុំវិញព្រលឹងខ្ញុំដួលរលំ
ព្រះអង្គគង់នៅជាក្តីសង្ឃឹម និង ជាការគាំទ្រទាំងអស់របស់ខ្ញុំ។

នៅពេលទ្រង់យាងមកជាមួយនឹងសម្លេងត្រែ
ឱ សូមឲ្យខ្ញុំបានរស់នៅក្នុងទ្រង់ក្នុងពេលនោះផង
គ្របបាំងខ្ញុំដោយក្តីសុចរិតរបស់ទ្រង់តែម្យ៉ាងគត់
បានស្អាតបរិសុទ្ធដើម្បីឈរនៅចំពោះព្រះបល្ល័ង្គទ្រង់

នៅជាមួយព្រះគ្រិស្តខ្ញុំឈរលើថ្មដារឹងមាំ
គ្រប់ទីកន្លែងផ្សេងទៀតសុទ្ធតែជា ខ្សាច់ដែលកំពុងស្រុតចុះ
គ្រប់ទីកន្លែងផ្សេងទៀតសុទ្ធតែជា ខ្សាច់ដែលកំពុងស្រុតចុះ

ការដឹងពីអ្វីដែលព្រះគ្រិស្តបានធ្វើសម្រាប់យើង និង ការដឹងថានៅពេលដែលយើងចាកចេញពីជីវិតមួយនេះទៅ យើងនឹងបានទៅនៅជាមួយទ្រង់ជារៀងរហូត វាបានផ្តល់ឲ្យយើងនូវក្តីសង្ឃឹមដែលទ្រទ្រង់យើង នៅក្នុងគ្រាងងឹតអន្ធការនៃជីវិតរបស់យើង។

លំហាត់អនុវត្តន៍

១ ចូរអានគម្ពីរកិច្ចការ២៤:១៥។ បើផ្អែកទៅលើខគម្ពីរនេះ តើសេចក្តីសង្ឃឹមរបស់យើងផ្អែកទៅលើអ្វី?

.....

២ ចូរអានគម្ពីរ១ពេត្រុស ១:៣។ តើខគម្ពីរនេះថ្លែងថា ប្រភពនៃសេចក្តីសង្ឃឹមរបស់យើងគឺជាអ្វី?

.....

៣ ចូរអានគម្ពីរកូឡូស ១:៥ គម្ពីរទីតុស២:១៣ និង គម្ពីរហេប្រឺ៦:១៩។ តើខគម្ពីរនេះប្រាប់ថា នៅពេលណាដែលយើងអាចនឹងស្គាល់ពីក្តីសង្ឃឹមរបស់យើងបានច្បាស់?

ក) នៅក្នុងបញ្ហាដែលយើងឆ្លងកាត់

ខ) នៅពេលដែលយើងត្រូវបានសង្គ្រោះ

គ) នៅពេលដែលយើងបានរួបរួមជាមួយព្រះគ្រិស្តនៅឯស្ថានបរមសុខ។

ខ. តាមរយៈការអះអាងបញ្ជាក់

វត្ថុបំណងទី២. *ស្គាល់ពីការសន្យារបស់ព្រះជាម្ចាស់ មាននៅក្នុងបទគម្ពីរដែលយើងអាចទទួលបាន និងស្គាល់ពីលក្ខខ័ណ្ឌដែលគាំទ្រការសន្យារបស់ទ្រង់។*

ដូចដែលយើងបានឃើញនៅក្នុងមេរៀនទី២រួចមកហើយ រឿងដំបូងបង្អស់មួយដែលមនុស្សត្រូវបានធ្វើដើម្បីក្លាយជាគ្រិស្តបរិស័ទ គឺការទទួលស្គាល់ថា ព្រះគ្រិស្តដែលមានព្រះជន្មរស់គឺជាព្រះអម្ចាស់នៃជីវិតរបស់គេ។ ការទទួលស្គាល់ ឬ ការអះអាងបញ្ជាក់ ក៏មានសារសំខាន់ណាស់ដែរ នៅក្នុងការរក្សាក្តីសង្ឃឹមរបស់គ្រិស្តបរិស័ទ។ មនុស្សដែលមើលឃើញតែផ្នែកខ្មៅងងឹតរបស់ជីវិត បញ្ហា និង ការល្បួងល ហើយនិយាយពីវាម្តងហើយម្តងទៀត គឺច្បាស់ជាបាក់ទឹកចិត្ត និង មានតែភាពភ័យខ្លាចជាក់ជាមិនខាន។ ប៉ុន្តែអស់អ្នកដែលស្គាល់ពីឫទ្ធានុភាពរបស់ព្រះជាម្ចាស់ដែលជួយគេនៅក្នុងគ្រប់កាល:ទេស:ទាំងអស់ និងអស់អ្នកដែលនិយាយតែពីព្រះពរ និង ការល្អដែលព្រះជាម្ចាស់បានធ្វើនៅក្នុងជីវិតរបស់ពួកគេនោះ មុខជាមានក្តីសង្ឃឹម ទោះបីជាស្ថិតនៅក្នុងកាល:ទេស:ដ៏លំបាកបំផុតក៏ដោយ។

ពេលខ្លះអ្វីដែលយើងមើលឃើញគឺមានតែបញ្ហាដែលយើងប្រឈមមុខតែប៉ុណ្ណោះ។ ខ្ញុំមានមិត្តដែលបានជួយខ្ញុំជាច្រើនលើកច្រើនសា នៅពេលដែលខ្ញុំប្រឈមមុខជាមួយនឹងបញ្ហាលំបាក ដោយគេបានរំឭកខ្ញុំពីការជួយដ៏អស្ចារ្យរបស់ព្រះជាម្ចាស់សម្រាប់ខ្ញុំនៅក្នុងស្ថានភាពស្រដៀងគ្នានេះដែរ នៅអតីតកាល ហើយគេរំឭកខ្ញុំពីព្រះពរទាំងអស់ដែលទ្រង់បានចាក់បង្ហូរមកលើខ្ញុំជាច្រើនឆ្នាំកន្លងមកនេះ។ នៅពេលដែលយើងគិតពីសេចក្តីមេត្តាករុណារបស់ទ្រង់ និងការសន្យាទាំងប៉ុន្មានដែលទ្រង់បានប្រទានឲ្យយើងនៅក្នុងព្រះបន្ទូលរបស់ទ្រង់ ថាទ្រង់គង់ជាមួយយើង និង ថែរក្សាយើង នោះជំនឿរបស់យើងបានលូតលាស់រឹងមាំ ហើយយើងអាចមានជ័យជម្នះលើបញ្ហាគ្រប់បែបយ៉ាង។

រឭកព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់

១. ព្រះបន្ទូលសន្យារបស់ទ្រង់ ដែលមិនប្រែប្រួលឡើយ (គម្ពីរ១ពង្សាវតារក្សត្រ ៨:៥៦)
២. ទ្រង់មានឫទ្ធានុភាព ដើម្បីធ្វើតាមព្រះបន្ទូលសន្យារបស់ទ្រង់ (គម្ពីររ៉ូម ៤:២១)
៣. ទ្រង់សន្យាថានឹងប្រោសលោះ (គម្ពីរទំនុកតម្កើង ៣៤:១៩-២០)
៤. ទ្រង់សន្យាថានឹងគង់នៅជាមួយយើង (គម្ពីរអេសាយ ៤៣:២)
៥. ទ្រង់សន្យាថា ការអធិស្ឋានរបស់យើងនឹងទទួលបានការឆ្លើយតប (គម្ពីរម៉ាកុស ១១:២៤)
៦. ទ្រង់សន្យាថា ជំនឿរបស់យើងនឹងត្រូវបានទទួលស្គាល់ (គម្ពីរលូកា ១៧:៦)
៧. ទ្រង់សន្យាថា នឹងប្រទានពរដល់អ្នកណាដែលចែកទានដោយចិត្តទូលាយ
(គម្ពីរសុភាសិត ៣:៩-១០ គម្ពីរលូកា៦:៣៨ គម្ពីរ២កូរិនថូស ៩:៦)
៨. ទ្រង់សន្យាថានឹងគង់នៅជាមួយអ្នកណាដែលស្គាល់បង្គាប់ (គម្ពីរយ៉ូហាន១៤:២៣)
៩. ទ្រង់សន្យាថានឹងយាងមកជាជំនួយសម្រាប់អ្នកណាដែលស្វែងរកទ្រង់
(គម្ពីរ២របាក្សត្រ ៧:១៤ គម្ពីរលូកា ១១:៩)
១០. ទ្រង់សន្យាថាប្រទានជីវិតអស់កល្បជានិច្ច (គម្ពីរ១យ៉ូហាន ២:២៥ គម្ពីរយ៉ាកុប ២:៥)

ទាំងនេះគ្រាន់តែជាព្រះបន្ទូលសន្យាមួយចំនួនតូចតែប៉ុណ្ណោះនៅក្នុងចំណោមព្រះបន្ទូលសន្យាជាច្រើនទៀតដែលមាននៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ចូរស្វែងរកការសន្យានីមួយៗនៅក្នុងព្រះគម្ពីរ ហើយអានពីព្រះបន្ទូលនោះ។ នៅពេលដែលយើងរំឭកព្រះបន្ទូលសន្យារបស់ទ្រង់ ដួងចិត្តរបស់យើងទទួលបានការជំរុញឲ្យ*ទុកចិត្ត*លើទ្រង់ ហើយយើងមិនអាចធ្វើអ្វីបានក្រៅពីការអះអាងបញ្ជាក់ថា៖ "ព្រះដែលយើងបម្រើ គឺជាព្រះដ៏មានចេស្តា"! ដូច្នេះហើយបានជា បន្ទាប់ពីព្យាការីមីកាបានរំឭកព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ដែលបានចែងថា៖ "អញនឹងឲ្យគេឃើញការអស្ចារ្យ ដូចនៅគ្រាដែលឯងបានចេញពីស្រុកអេស៊ីព្ទមក"(គម្ពីរមីកា ៧:១៥ បកប្រែចាស់) ទៅកាន់សាសន៍អ៊ីស្រាអែលហើយ លោកបានឆ្លើយតបដោយការអះអាងបញ្ជាក់ដូចតទៅនេះថា៖

> បពិត្រព្រះអម្ចាស់! តើមានព្រះណា ដែលមានព្រះហឫទ័យសប្បុរសដូចព្រះអង្គ? ព្រះអង្គលើកលែងទោសអោយយើងខ្ញុំ ព្រះអង្គមិនពិរោធរហូតឡើយ។ ព្រះអង្គមានព្រះហឫទ័យស្រឡាញ់ប្រជារាស្ត្ររបស់ព្រះអង្គដែលនៅសេសសល់ ហើយព្រះអង្គប្រណីសន្តោសដល់ពួកគេ។ ព្រះអង្គមុខជាអាណិតអាសូរយើងខ្ញុំសាជាថ្មី ព្រះអង្គមិនប្រកាន់ទោសរបស់យើងខ្ញុំទេ ព្រះអង្គនឹងយកអំពើបាបទាំងប៉ុន្មាន របស់យើងខ្ញុំ ទៅបោះចោលនៅបាតសមុទ្រ។
> (គម្ពីរមីកា ៧:១៨-១៩)

លំហាត់អនុវត្តន៍

៤ ចូរអានបទគម្ពីរខាងក្រោម ហើយផ្គូផ្គងខគម្ពីរទៅនឹងព្រះបន្ទូលសន្យាដែលមានចែងនៅក្នុងខគម្ពីរនីមួយៗ។

.....ក) ព្រះជាម្ចាស់នឹងឆ្លើយតបការអធិស្ឋានរបស់យើង។

.....ខ) ទ្រង់ប្រទានពរដល់អ្នកណាដែលចែកទាន

.....គ) បើយើងទូលសូមជំនួយ នោះទ្រង់នឹងប្រទានជំនួយឲ្យមកយើង

.....ឃ) ទ្រង់នឹងរំដោះយើងឲ្យរួចផុតពីបញ្ហារបស់យើង

.....ង) ទ្រង់នឹងទទួលស្គាល់ជំនឿរបស់យើង

.....ច) ប្រសិនបើយើងស្តាប់បង្គាប់ទ្រង់ នោះទ្រង់នឹងគង់នៅជាមួយយើង

.....ឆ) ទ្រង់នឹងមិនភ្លេចពីព្រះបន្ទូលសន្យារបស់ទ្រង់ឡើយ

១) គម្ពីរទំនុកតម្កើង ៣៤:១៩-២០

២) គម្ពីរ១ពង្សាវតារក្សត្រ ៨:៥៦

៣) គម្ពីរលូកា ១៧:៦

៤) គម្ពីរម៉ាកុស ១១:២៤

៥) គម្ពីរយ៉ូហាន ១៤:២៣

៦) គម្ពីរសុភាសិត ៣:៩-១០

៧) គម្ពីរលូកា ១១:៩

ព្រះបន្ទូលសន្យាដ៏អស្ចារ្យជាងគេបំផុតមួយរបស់ព្រះជាម្ចាស់ គឺមានចែងនៅក្នុងគម្ពីរទំនុកតម្កើងជំពូក៩១ ។ នៅក្នុងទំនុកតម្កើងនេះ ទ្រង់មានព្រះបន្ទូលថា នឹងផ្តល់ការការពារឲ្យប្រឆាំងជាមួយនឹងអំណាចអាក្រក់ដែលចង់បំផ្លាញយើង។

លំហាត់អនុវត្តន៍

៥ ចូរអានគម្ពីរទំនុកតម្កើងជំពូក៩១។ តើការការពាររបស់ព្រះជាម្ចាស់ ផ្អែកទៅលើអ្វី? (សូមមើលខ១ ខ៩ និង ខ១៤) ។ ចូរជ្រើសរើសចម្លើយដែលល្អបំផុត។

ក) យើងត្រូវស្រែករកព្រះនាមទ្រង់ នៅពេលដែលយើងត្រូវការជំនួយ។

ខ) យើងត្រូវរស់នៅជាប់ជាមួយទ្រង់ និង ស្រឡាញ់ទ្រង់។

គ) យើងត្រូវរឹងមាំ និង តតាំងជាមួយសត្រូវ។

៦ ចូរអានខគម្ពីរខាងក្រោម ហើយបកស្រាយល័ក្ខខ័ណ្ឌដើម្បីទទួលបានព្រះបន្ទូលនៅក្នុងខគម្ពីរនីមួយៗ។

ក) គម្ពីរ២កូរិនថូស ១៦:៩.....

ខ) គម្ពីរទំនុកតម្កើង ៣៤:៧.....

គ) គម្ពីរយ៉ូហាន ១៥:៧.....

ឃ) គម្ពីរម៉ាកុស ១១:២៤.....

ង) គម្ពីរ១យ៉ូហាន ៣:២១-២២.....

៧ ចូរអានគម្ពីរទំនុកតម្កើង ៩១:១៥ គម្ពីរអេសាយ ៥៨:៩; ៦៥:២៤ និងគម្ពីរសាការី ១៣:៩។ តើមានព្រះបន្ទូលអ្វីខ្លះដែលបានចែកជូននៅក្នុងខគម្ពីរនីមួយៗខាងលើនេះ?

.....

ពិចារណាគំរូដែលមាននៅក្នុងព្រះគម្ពីរ

វត្ថុបំណងទី៣. *សរសេរការថ្លែងអះអាងបញ្ជាក់ ដោយយោងទៅតាមគោលការណ៍ព្រះគម្ពីរ អំពីអ្វីដែលព្រះជាម្ចាស់ បានធ្វើនៅអតីតកាល និង អ្វីដែលយើងអាចរំពឹងឲ្យទ្រង់ធ្វើនាពេលអនាគត។*

មានគំរូជាច្រើននៅក្នុងព្រះគម្ពីរអំពីការអះអាងបញ្ជាក់ល្អៗ នៅក្នុងពេលប្រឈមមុខជាមួយបញ្ហាធំៗ។ ដោយនិយាយថាការអះអាងបញ្ជាក់ល្អៗ ខ្ញុំមិនមែនសំដៅទៅលើការប្រកាសថាអ្វីៗគឺខុសពីធាតុពិតរបស់វានោះទេ។ ខ្ញុំចង់សំដៅទៅលើការស្គាល់សេចក្តីមេត្តារបស់ព្រះជាម្ចាស់ និងឫទ្ធានុភាពរបស់ទ្រង់ក្នុងការជួយយើងនៅគ្រប់កាល:ទេស:ទាំងអស់ ហើយស្គាល់ពីឫទ្ធានុភាពដែលរំដោះយើងពីវិញ្ញាណអាក្រក់ ការពារយើងនៅពេលមានគ្រោះថ្នាក់ កំសាន្តចិត្តយើងនៅក្នុងពេលមានទុក្ខព្រួយ។ ការអះអាងបញ្ជាក់បែបនេះគឺផ្អែកទៅលើអ្វីដែលព្រះជាម្ចាស់ បានធ្វើ *រួចមកហើយ* និង ជំនឿរបស់យើង ដែលថាទ្រង់នឹង *បន្ត* ធ្វើសកម្មភាពនៅក្នុងពេលអនាគត ដូចដែលទ្រង់បានធ្វើនៅក្នុងអតីតកាលផងដែរ។

លំហាត់អនុវត្តន៍

៨ ចូរអានគម្ពីរដានីយ៉ែល ៣:១៣-១៨ ។ តើឃ្លាអះអាងបញ្ជាក់អ្វីដែលបានធ្វើឡើងនៅក្នុងខគម្ពីរមួយនេះ?

.....

.....

នៅក្នុងខគម្ពីរហាបាគូក ៣:១៧-១៩ ។ លោកព្យាការីបានធ្វើការអះអាងបញ្ជាក់នេះអំពីការទុកចិត្តលើព្រះជាម្ចាស់៖

> ដើមឧទុម្ពរលែងផ្កា ទំពាំងបាយជូរលែងមានផ្លែ ដើមអូលីវលែងផ្តល់ប្រេង ស្រែចំការលែងផ្តល់គោគផលជាអាហារ លែងមានចៀមនៅតាមវាលស្មៅ ហើយក៏លែងមានគោក្នុងក្រោលទៀតដែរ។ *រីឯខ្ញុំវិញ ខ្ញុំនឹងសប្បាយរីករាយ ហើយមានអំណរដ៏លើសលប់ ដោយព្រះជាម្ចាស់សង្គ្រោះខ្ញុំ។ ព្រះជាអម្ចាស់នៃខ្ញុំ ជាកម្លាំងរបស់ខ្ញុំ ព្រះអង្គប្រទានអោយខ្ញុំរត់លឿនដូចឈ្លូស ព្រះអង្គប្រទានអោយខ្ញុំដើរនៅលើទីខ្ពស់ៗ។* (អក្សរទ្រេតគឺសម្រាប់ខ្ញុំ)

ឃ្លានៃការអះអាងបញ្ជាក់ដែលល្អបំផុតមួយនៅក្នុងព្រះគម្ពីរ គឺមានចែងនៅក្នុងគម្ពីរទំនុកតម្កើងជំពូក២៣។ ស្តេចដាវីឌបានស្គាល់អំណរនិងទុក្ខព្រួយ ជ័យជម្នះនិងបរាជ័យ សន្តិភាពនិងគ្រោះថ្នាក់។ ជាច្រើនលើកច្រើនសា ទ្រង់បានរត់គេចពីសត្រូវរបស់ទ្រង់។ ទ្រង់បានស្គាល់អ្វីដែលជាការប្រព្រឹត្តអំពើបាបទាស់នឹងព្រះជាម្ចាស់ ហើយទទួលបានការអត់ទោស។ ជីវិតរបស់ទ្រង់គឺជាជីវិតដែលប្រកបដោយបញ្ហាភាពចលាចល ភាពសោកសៅ ការសម្លាប់ ការស្តាយក្រោយ ការសង្ស័យ និង ទំនាស់។ គម្ពីរទំនុកតម្កើងគឺពេញទៅដោយការអង្វររបស់ទ្រង់ទៅកាន់ព្រះអម្ចាស់សម្រាប់ជំនួយ និងសេចក្តីមេត្តាករុណា។ប៉ុន្តែគម្ពីរទំនុកតម្កើងជំពូក២៣គឺជាបទគម្ពីរអះអាងបញ្ជាក់ដ៏ល្អបំផុត ដែលគេឃើញមាននៅក្នុងព្រះគម្ពីរ។ ខគម្ពីរនេះឆ្លើយតបទៅនឹងផ្នែកជាច្រើននៅក្នុងជីវិត ដែលត្រូវការជំនួយរបស់ព្រះអម្ចាស់។

គម្ពីរទំនុកតម្កើងជំពូក២៣

ការអះអាងបញ្ជាក់

ព្រះអម្ចាស់ជាគង្វាលខ្ញុំ ខ្ញុំនឹងមិនខ្វះអ្វី
សោះឡើយ។
ព្រះអង្គអោយខ្ញុំសំរាកនៅតាមវាលស្មៅខៀវខ្ចី
ព្រះអង្គនាំខ្ញុំឆ្ពោះទៅកន្លែងស្ងាត់ នៅក្បែរមាត់ទឹក។
ព្រះអង្គប្រទានអោយខ្ញុំមានកម្លាំងឡើងវិញ
ព្រះអង្គនាំខ្ញុំដើរក្នុងផ្លូវដ៏សុចរិត ដោយយល់ដល់
ព្រះកិត្តិនាមរបស់ព្រះអង្គ។
ទោះបីទូលបង្គំដើរកាត់ជ្រលងភ្នំ នៃសេចក្តីស្លាប់
ក៏ដោយ ក៏ទូលបង្គំមិនខ្លាចអ្វីសោះឡើយ
ដ្បិតព្រះអង្គគង់នៅជាមួយទូលបង្គំ ព្រះអង្គការពារ
និងរក្សាទូលបង្គំជានិច្ច។
ព្រះអង្គរៀបចំពិធីជប់លៀងអោយទូលបង្គំ
នៅមុខបច្ចាមិត្តរបស់ទូលបង្គំ ព្រះអង្គបានចាក់ប្រេង
លើទូលបង្គំ ដើម្បីលើកកិត្តិយសទូលបង្គំ ហើយ
ព្រះអង្គបានបំពេញពែង ទូលបង្គំយ៉ាងហូរហៀរ។
ខ្ញុំដឹងជាក់ច្បាស់ណាស់ថា ព្រះអង្គនឹងប្រទាន
សុភមង្គលអោយទូលបង្គំ ហើយព្រះអង្គប្រណី
សន្តោសទូលបង្គំ យ៉ាងស្មោះស្ម័គ្រជារៀងរាល់
ថ្ងៃអស់មួយជីវិត។ ដរាបណាខ្ញុំនៅមានជីវិត
ខ្ញុំនឹងវិលត្រឡប់ មកក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ជានិច្ច។

អ្វីដែលព្រះជាម្ចាស់ប្រទានឲ្យយើង

ការផ្គត់ផ្គង់
ភាពស្កប់ស្កល់
សេចក្តីសុខសាន្ត
ការធ្វើឲ្យថ្មីឡើង
ការនាំផ្លូវ
ការការពារ
ការកំសាន្តចិត្ត
ការធានារ៉ាប់រងនៅក្នុងពេលមាន
គ្រោះថ្នាក់
ការទទួលស្គាល់ និង ព្រះពរ

ព្រះពរច្រើនរាប់មិនអស់
សេចក្តីមេត្តា និង
សេចក្តីស្រលាញ់ អស់កល្បជានិច្ច
សេចក្តីសង្ឃឹមអស់កល្បជានិច្ច

លំហាត់អនុវត្តន៍

៩ ចូរអានគម្ពីរទំនុកតម្កើង ៦៦:១៦-១៨។ តើខគម្ពីរទាំងនេះគឺជាទីបន្ទាល់ឬ ការអះអាងបញ្ជាក់អំពីអ្វី?

.....

១០ តើការបើកសម្តែងជាក់លាក់ពីរដែលព្រះជាម្ចាស់បានមានព្រះបន្ទូលក្នុងខគម្ពីរនេះមានអ្វីខ្លះ?

.....

១១ តើមានលក្ខខ័ណ្ឌអ្វីខ្លះ ដើម្បីទទួលបានការបើកសម្តែងទាំងពីរនេះ?

.....

១២ តើទីបន្ទាល់របស់លោកប៉ូលនៅក្នុងខគម្ពីរ២ធីម៉ូថេ ៣:១១ គឺអ្វី?

.....

១៣ តើការអះអាងទាំងពីរដែលលោកប៉ូលបានធ្វើឡើងនៅក្នុងគម្ពីរ២ធីម៉ូថេ ៤:១៦-១៨ មានអ្វីខ្លះ?

ក) នៅអតីតកាល៖ .....

ខ) នៅអនាគត៖ .....

១៤ ចូរសរសេរនៅក្នុងសៀវភៅកត់ត្រារបស់អ្នក ពីការអះអាងបញ្ជាក់ផ្ទាល់ខ្លួនរបស់អ្នកសម្រាប់អ្វីដែលព្រះអម្ចាស់បានធ្វើ សម្រាប់អ្នកនៅអតីតកាល និង ដោយយោងតាមការអះអាងនោះ ចូរសរសេរពីអ្វីដែលអ្នកអាចរំពឹងទុកថាព្រះអង្គនឹងធ្វើអ្វីទៀតសម្រាប់អ្នកនៅថ្ងៃអនាគត។ បន្ទាប់មកចូរចែកចាយការអះអាងនេះជាមួយមនុស្សម្នាក់ផ្សេងទៀត។ ចូរចាប់ផ្តើមឃ្លារបស់អ្នក ជាមួយនឹងពាក្យថា៖*អនុញ្ញាតចូលមក ហើយសូមឲ្យខ្ញុំបានប្រាប់អ្នកពីអ្វីដែលព្រះជាម្ចាស់បាន ធ្វើសម្រាប់ខ្ញុំ។*

គ. តាមរយៈជំនឿ

វត្ថុបំណងទី៤. *ស្គាល់ពីការថ្លែងដ៏ពិតប្រាកដ ដែលផ្សារភ្ជាប់បញ្ហារបស់យើង ទៅនឹងក្តីសង្ឃឹមដ៏អស់កល្បជានិច្ចថានឹងបានរួបរួមជាមួយព្រះជាម្ចាស់យ៉ាងពេញលេញ។*

ការរក្សាក្តីសង្ឃឹមគឺផ្អែកទៅលើជំនឿដ៏រឹងមាំលើព្រះជាម្ចាស់។ គម្ពីរហេប្រឺជំពូក១១ ត្រូវបានគេហៅថា *ជំពូកនៃជំនឿ* នៅក្នុងព្រះគម្ពីរ។ នៅក្នុងខទី១បានចែងថា៖ "ជំនឿធ្វើអោយយើងមានអ្វីៗដែលយើងសង្ឃឹមថានឹងបាន និងធ្វើអោយស្គាល់ជាក់ច្បាស់នូវអ្វីៗដែលយើងមើលពុំឃើញ។"

ចូរអានគម្ពីរហេប្រឺជំពូក១១ទាំងមូល។ នៅក្នុងផ្នែកដំបូងនៃជំពូកនេះបានកត់ត្រាអំពីជ័យជម្នះរបស់ជនប្រុសស្រីដែលមានជំនឿយ៉ាងអស្ចារ្យលើព្រះជាម្ចាស់។ ជំនឿរបស់ពួកគេបានបើកសំដែងឫទ្ធានុភាពរបស់ព្រះជាម្ចាស់ដែលបានធ្វើការតាមរយៈជីវិតរបស់ពួកគេ។

លំហាត់អនុវត្តន៍

---

១៥ តើខទី៣៥ ដល់ខទី៣៨ ខុសគ្នាពី ខទី៤ ដល់ខទី៣៤ យ៉ាងដូចម្តេច?

.....

.....

១៦ យោងទៅតាមខទី៤០ ហេតុអ្វីបានជាអ្នកទាំងនោះមិនទទួលបានការប្រោសលោះ?

.....

.....

អ្នកទាំងនោះមិនបានទទួលការកោតសរសើរ ដោយសារពួកគេមានជ័យជម្នះលើសត្រូវរបស់ពួកគេ ពួកគេនោះ *ប៉ុន្តែគឺដោយសារតែពួកគេស្គាល់ជាក់ច្បាស់នូវអ្វីៗដែលយើងមើលពុំឃើញ។* (ខ១) ។ តើពួកគេសង្ឃឹមថាបានអ្វី? ព្រះជាម្ចាស់បានមានព្រះបន្ទូលសន្យាថានឹងប្រទានជីវិតអស់កល្បជានិច្ចនៅជាមួយទ្រង់នៅឯស្ថានបរមសុខ! គួរកត់សំគាល់ផងដែរថា បទពិសោធន៍របស់ជនប្រុសស្រីដែលពេញដោយជំនឿទាំងនេះ គឺមានលក្ខណៈដោយឡែកពីគ្នា។ គ្មានមនុស្សណាម្នាក់មានបទពិសោធន៍ដូចគ្នានោះឡើយ។ តាមរយៈបញ្ហា និង ជ័យជម្នះផ្សេងៗរបស់ពួកគេនោះហើយ ដែលយើងអាចឃើញព្រះហស្តរបស់ព្រះជាម្ចាស់ធ្វើការនៅក្នុងជីវិតរបស់ពួកគេ ហើយយើងអាចមានជំនឿថាទ្រង់នឹងធ្វើការនៅក្នុងជីវិតរបស់យើងតាមរបៀបដូចគ្នានេះដែរ។

នៅក្នុងសៀវភៅរបស់លោកស៊ី អេស លូវីស (C.S.Lewis) ដែលមានចំណងជើងថា *បញ្ហានៃការឈឺចាប់ (The Problem of Pain)* បាននិយាយអំពីភាពដោយឡែកពីគ្នានៃព្រលឹងនីមួយៗ។ លោកបានលើកឡើងថា ប្រសិនបើព្រះជាម្ចាស់មិនត្រូវការប្រើប្រាស់ភាពខុសគ្នារបស់យើងនេះទេ នោះទ្រង់ប្រហែលជាមិនចាំបាច់បង្កើតឲ្យមានព្រលឹងជាច្រើនយ៉ាងនេះទេ។ យើងគឺជាដំណាក់របស់ព្រះជាម្ចាស់ (គម្ពីរ២កូរិនថូស ៦:១៦)។ ព្រះជាម្ចាស់គង់នៅក្នុងអ្នកនិង ខ្ញុំ។ ខ្ញុំគឺជាដំណាក់របស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ជ្រាបអំពីខ្ញុំតាំងពីមុនពេលខ្ញុំចាប់កំណើតមកម៉្លេះ (គម្ពីរទំនុកតម្កើង ១៣៩:១៣-១៦)។ ទ្រង់បានបង្កើតខ្ញុំមកយ៉ាងអស្ចារ្យ។ ទ្រង់បង្កើតខ្ញុំឡើងដើម្បីឲ្យគាប់ព្រះទ័យទ្រង់។ ជីវិត និង ដួងចិត្តទាំងមូលរបស់ខ្ញុំចង់បានតែទ្រង់មួយ ប៉ុន្តែខ្ញុំគ្រាន់តែអាចមើលឃើញយ៉ាងខ្លីមួយពព្រិចភ្នែក នៃអ្វីដែលមាននៅក្នុងព្រះដ៏វិសុទ្ធតែប៉ុណ្ណោះ (គម្ពីរ១កូរិនថូស ១៣:១២) ។ យើងបានត្រឹមតែប៉ាន់ប្រមាណអំពីរបស់ដ៏អស្ចារ្យ ដែលទ្រង់បានរៀបចំសម្រាប់នៅឯផ្ទះនៅស្ថានបរមសុខរបស់យើងតែប៉ុណ្ណោះ។ ប៉ុន្តែតើវាមិនអាចទៅរួចទេឬអីដែលតាមរយៈបញ្ហា ទឹកភ្នែក អំណរ ទុក្ខព្រួយ និង ជ័យជម្នះរបស់ខ្ញុំនៅលើផែនដីនេះ ព្រះជាម្ចាស់កំពុងតែសូនច្នៃខ្ញុំ ធ្វើយ៉ាងណាឲ្យខ្ញុំអាចនឹងស័ក្តិសមជាមួយនឹងកន្លែងពិសេសរបស់ខ្ញុំនៅក្នុងព្រះរាជ្យរបស់ព្រះអង្គនោះ? តើវាមិនអាចទៅរួចទេឬអី ដែលការប្រមូលផ្តុំបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំ ទោះបីល្អឬអាក្រក់បានបង្ហាញខ្ញុំបានឃើញពីព្រះជាម្ចាស់តាមតែរបៀបដែលខ្ញុំអាចយល់បាននោះ? តើវាមិនអាចទៅរួចទេឬអី ដែលតាមរយៈបទពិសោធន៍នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់គេមួយនេះ ព្រះជាម្ចាស់ប្រទានឲ្យមនុស្សទទួលបានការយល់ដឹងពីលក្ខណៈរបស់ព្រះជាម្ចាស់ ដែលមានតែពួកគេតែប៉ុណ្ណោះដែលអាចបកស្រាយបាននោះ?

លោកស៊ី អេស លូវីស (C.S.Lewis)បានលើកឡើងថា៖ "កន្លែងរបស់អ្នកឯស្ថានបរមសុខនឹងហាក់បីដូចជាត្រូវបានបង្កើតឡើងសម្រាប់អ្នក តែម្នាក់គត់ ព្រោះតែអ្នកត្រូវបានបង្កើតឡើងមកសម្រាប់កន្លែងនោះដែរ ពីថ្មេរមួយទៅថ្មេរមួយដូចជាស្រោមដៃដែលត្រូវបានដេរសម្រាប់ដៃយ៉ាងដូច្នោះ។" លោកក៏បានបញ្ជាក់បន្ថែមទៀតថា ប្រសិនបើមនុស្សគ្រប់គ្នាស្គាល់ព្រះជាម្ចាស់ និង ថ្វាយបង្គំទ្រង់តាមរបៀបដូចគ្នានេះដែរ "ចម្រៀងអបអរសាទជ័យជម្នះរបស់ក្រុមជំនុំ នឹងមិនមានពិធោរណ៌នោះឡើយ វានឹងដូចជាវង់ភ្លេងមួយដែលឧបករណ៍ភ្លេងទាំងអស់លេងក្នុងសម្លេងដូចគ្នា។"
(១៩៩៦, ១៣២-១៤២)។

នៅក្នុងគម្ពីរវិវរណៈ ២:១៧ ពាក្យខាងក្រោមនេះគឺត្រូវបានសរសេរឡើងសម្រាប់ក្រុមជំនុំ៖ "អ្នកណាមានជ័យជំនះ យើងនឹងអោយនំម៉ាណាដ៏លាក់កំបាំងទៅអ្នកនោះ ព្រមទាំងប្រគល់ក្រួសពណ៌សមួយដុំអោយដែរ នៅលើដុំក្រួសនោះ មានចារឹកឈ្មោះមួយថ្មី ដែលគ្មាននរណាម្នាក់ស្គាល់ឡើយ ក្រៅតែអ្នកដែលបានទទួលនោះចេញ"

សូមមើលពីវាទៅមើល! រង្វាន់សម្រាប់អ្នកមានជ័យជម្នះនៅក្នុងជីវិតគឺឈ្មោះថ្មីមួយដែលមានតែព្រះជាម្ចាស់ និង អ្នកនោះប៉ុណ្ណោះដែលអាចស្គាល់! ឈ្មោះនោះគឺជានិមិត្តសញ្ញា រវាងព្រះជាម្ចាស់និង អ្នក អំពីអ្វីទាំងអស់ដែលជាខ្លួនអ្នក អ្វីដែលអ្នកបានទទួលរង គ្រប់ទាំងជ័យជម្នះដែលអ្នកទទួលបាន និង គ្រប់ទាំងអស់ដែលអ្នកប្រែក្លាយទៅជា តាមរយៈឫទ្ធានុភាពរបស់ព្រះយេស៊ូគ្រិស្ត ធ្វើការនៅក្នុងអ្នក!វានឹងបញ្ជាក់បង្ហាញពីការប្រកប និង ការរួបរួមផ្ទាល់ខ្លួនរបស់អ្នកជាមួយនឹងព្រះអាទិកររបស់អ្នក ដែលនឹងមានលក្ខណៈខុសគ្នាពីអ្នកដែលមានជ័យជម្នះដទៃផ្សេងទៀត។ គិតទៅវាពិតជាអស្ចារ្យណាស់ដែលថា នៅឯស្ថានបរមសុខ ទំនាក់ទំនងរវាងយើងជាមួយប្រជាជនបរិសុទ្ធគ្រប់យុគសម័យទាំងអស់ រួមបញ្ចូលទាំងអស់អ្នកមានជំនឿអស្ចារ្យដែលត្រូវបានរៀបរាប់នៅក្នុងគម្ពីរហេប្រឺជំពូក១១នោះ ក៏នឹងត្រូវបានរាប់បញ្ចូលទាំងការចែករំលែកទៅឲ្យគ្នាទៅវិញទៅមក អំពីការបើកសំដែងរបស់ព្រះជាម្ចាស់មកកាន់*យើង*ដែរ! ដូចខ្ញុំបានចែកចាយជាមួយអ្នក ហើយអ្នកក៏បានចែកចាយមកកាន់ខ្ញុំដែរ យើងទាំងអស់គ្នានឹងទទួលបានការយល់ដឹងកាន់តែច្រើនឡើង អំពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់អ្នក ដែលជាស្តេចលើអស់ទាំងស្តេច និង ជាម្ចាស់លើអស់ទាំងម្ចាស់។

នៅក្នុងគម្ពីរ១កូរិនថូស ២:៩ យើងបានដឹងថា " អ្វីៗដែលភ្នែកមើលមិនឃើញ អ្វីៗដែលត្រចៀកស្តាប់មិនឮ និងអ្វីៗដែលចិត្តមនុស្សនឹកមិនដល់នោះ ព្រះជាម្ចាស់បានរៀបចំទុក សំរាប់អស់អ្នកដែលស្រឡាញ់ព្រះអង្គ"។ នៅពេលដែលខ្ញុំគិតអំពីរឿងល្អៗដែលព្រះជាម្ចាស់បានរៀបចំសម្រាប់យើងទាំងអស់គ្នា ជំនឿរបស់ខ្ញុំក៏បានកាន់តែរឹងមាំឡើង ហើយខ្ញុំអាចទទួលយកគ្រប់បញ្ហា និង ទុក្ខលំបាកទាំងអស់ដែលទ្រង់ឲ្យខ្ញុំឆ្លងកាត់ដើម្បីជាការត្រៀមខ្លួនសម្រាប់ទីកន្លែងដ៏អស់កល្បជានិច្ចរបស់ខ្ញុំនៅជាមួយទ្រង់ ។ នៅក្នុងគម្ពីរយ៉ូហាន១៤:១-៣ ព្រះយេស៊ូបានកំសាន្តចិត្តពួកសាវ័ករបស់ទ្រង់ជាមួយនឹងព្រះបន្ទូលដូចតទៅនេះ៖ "កុំរន្ធត់ចិត្តធ្វើអ្វី អ្នករាល់គ្នាជឿលើព្រះជាម្ចាស់ហើយ សុំជឿលើខ្ញុំផង។ ក្នុងដំណាក់របស់ព្រះបិតាខ្ញុំ មានលំនៅជាច្រើន។ បើពុំដូច្នោះទេ ខ្ញុំមិនបានប្រាប់អ្នករាល់គ្នាថា ខ្ញុំទៅរៀបចំកន្លែងទុកអោយអ្នករាល់គ្នាឡើយ។ ពេលខ្ញុំទៅរៀបចំកន្លែងទុកអោយអ្នករាល់គ្នារួចហើយ ខ្ញុំនឹងត្រឡប់មកវិញ យកអ្នករាល់គ្នាទៅជាមួយខ្ញុំ ដើម្បីអោយអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅ។"

លំហាត់អនុវត្តន៍

១៧ តើប្រយោគណាខ្លះនៅខាងក្រោមនេះ ដែលផ្សារភ្ជាប់បញ្ហា និង រងទុក្ខលំបាកនៅលើលោកីយ៍ ទៅនឹងក្តីសង្ឃឹមរបស់គ្រិស្តបរិស័ទថានឹងបានប្រកបរួបរួមជាមួយព្រះជាម្ចាស់អស់កល្បជានិច្ច។ ចូរគូសរង្វង់នៅជុំវិញអក្សរក្នុងចម្លើយត្រឹមត្រូវ។

ក) មនុស្សគ្រប់រូបដែលមានរៀបរាប់នៅក្នុងគម្ពីរហេប្រឺជំពូក១១ បានទទួលការប្រោសលោះឲ្យរួចផុតពីបញ្ហារបស់ពួកគេនៅលើលោកីយ៍ទាំងស្រុង។

ខ) មនុស្សដែលមានជំនឿនៅក្នុងគម្ពីរហេប្រឺជំពូក១១ អាចប្រឈមមុខជាមួយទុក្ខលំបាករបស់ពួកគេយ៉ាងអង់អាច ព្រោះក្តីសង្ឃឹមរបស់ពួកគេស្ថិតនៅជាប់យ៉ាងរឹងមាំលើព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ទៅចំពោះពួកគេអំពីជីវិតអស់កល្បជានិច្ច។

គ) ឈ្មោះថ្មីដែលយើងនឹងទទួលបាននៅស្ថានបរមសុខ គឺជារង្វាន់សម្រាប់ការយកឈ្នះលើបញ្ហា និង ការល្បួង របស់ជីវិតលោកីយ៍នេះ និង ការដាក់ជំនឿរបស់យើងលើព្រះគ្រិស្តយេស៊ូផងដែរ។

ឃ) មានតែព្រះជាម្ចាស់ និង ខ្ញុំប៉ុណ្ណោះដែលស្គាល់ឈ្មោះរបស់ខ្ញុំនៅស្ថានបរមសុខ។

ង) យើងអាចទទួលបានការបើកសំដែងយ៉ាងពេញលេញរបស់ព្រះជាម្ចាស់នៅក្នុងជីវិតមួយនេះប្រសិនបើយើងជាអ្នកដែលមានជ័យជម្នះ។

ច) ការព្យាបាលដួងចិត្តដែលមានបញ្ហា គឺការទុកចិត្តព្រះជាម្ចាស់ និង អ្វីដែលទ្រង់មានព្រះបន្ទូលសន្យា។

នៅក្នុងគម្ពីរ១កូរិនថូស ១៣:១២ លោកសាវ័កបានមានប្រសាសន៍ថា ៖ "សព្វថ្ងៃនេះយើងស្គាល់ព្រះជាម្ចាស់មិនច្បាស់ទេ គឺស្គាល់ព្រាលៗដូចជាមើលក្នុងកញ្ចក់ នៅពេលខាងមុខ ទើបយើងឃើញព្រះអង្គទល់មុខគ្នា។" នៅក្នុងពេលនេះ ដួងចិត្តរបស់យើងទន្ទឹងរង់ចាំការរួបរួមយ៉ាងពេញលេញជាមួយព្រះអង្គសង្គ្រោះរបស់យើង នៅឯស្ថានបរមសុខ ដែលការប្រកបរួបរួមនោះនឹងបានពេញលក្ខណៈ។ គម្ពីរវិវរណៈ ១:៧ ប្រាប់យើងថា៖ "មើល៍! ព្រះអង្គយាងមក នៅកណ្តាលពពក*។ មនុស្សទាំងអស់នឹងឃើញព្រះអង្គ"។ នៅពេលដែលថ្ងៃនោះមកដល់ ខ្ញុំនឹងអាចមើលឃើញទ្រង់ ដោយផ្តាល់ភ្នែករបស់ខ្ញុំផ្ទាល់ មិនមែនដោយភ្នែករបស់អ្នកដទៃនោះទេ។ ទម្រាំដល់ពេលនោះ ជំនឿរបស់ខ្ញុំនឹងជួយឲ្យខ្ញុំប្រាកដអំពីអ្វីដែលខ្ញុំសង្ឃឹម និង ប្រាកដជាក់ច្បាស់ជាមួយអ្វីដែលខ្ញុំមើលមិនឃើញ។

ក៏ប៉ុន្តែ សូមនឹកចាំពីគ្រាដំបូង ដែលបងប្អូនទើបនឹងទទួលពន្លឺពីព្រះជាម្ចាស់ថ្មីៗ។ ពេលនោះ បងប្អូនបានតស៊ូយ៉ាងខ្លាំង ហើយបងប្អូនក៏បានរងទុក្ខលំបាកជាច្រើន ពេលខ្លះបងប្អូនត្រូវគេប្រមាថមើលងាយ ធ្វើបាបនៅមុខប្រជុំជន និងពេលខ្លះទៀត បងប្អូនរួមទុក្ខជាមួយអ្នកដែលត្រូវគេធ្វើបាបដែរ។ បងប្អូនបានរួមទុក្ខជាមួយអស់អ្នកដែលជាប់ឃុំឃាំង បងប្អូនសុខចិត្តអោយគេរឹបអូសយកទ្រព្យសម្បត្តិរបស់បងប្អូនដោយរីករាយ ដ្បិតបងប្អូនដឹងថា បងប្អូនមានសម្បត្តិសួគ៌ ដែលប្រសើរជាង ហើយនៅស្ថិតស្ថេរហូត។ ហេតុនេះ សូមបងប្អូនកុំលះបង់ចិត្តរឹងបឹង ដែល នឹងធ្វើអោយបងប្អូនទទួលរង្វាន់យ៉ាងធំនោះឡើយ គឺត្រូវមានចិត្តស៊ូទ្រាំ ដើម្បីធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងទទួលផលតាមព្រះបន្ទូលសន្យា ៣៧ ដ្បិតនៅតែបន្តិចទៀត គឺក្នុងពេលឆាប់ៗខាងមុខ ព្រះអង្គដែលត្រូវយាងមក ទ្រង់នឹងយាងមកដល់ជាមិនខាន ព្រះអង្គមិនបង្អង់ឡើយ។ «រីឯអ្នកសុចរិតជាកូនចៅរបស់យើងវិញ គេនឹងមានជីវិតរស់ដោយសារជំនឿ តែបើគេថយក្រោយ យើងលែងពេញចិត្តនឹងគេហើយ»។ ចំពោះយើងវិញ យើងមិនមែនជាអ្នកថយក្រោយអោយត្រូវវិនាសបាត់បង់នោះទេ គឺយើងជាអ្នកជឿដើម្បីសង្គ្រោះជីវិត។ (គម្ពីរហេប្រឺ១០:៣២- ៣៩)

ដើម្បីជាការបញ្ចប់ការសិក្សារបស់អ្នកនៅក្នុងសៀវភៅនេះ តើអ្នកអាចអានកំណាព្យខាងក្រោមនេះជាមួយខ្ញុំបានឬទេ?

វានឹងមានតម្លៃលើសអ្វីៗទាំងអស់ នៅពេលដែលយើងឃើញព្រះយេស៊ូ។

បញ្ហារបស់លោកីយ៍នឹងមើលឃើញតូចតាច នៅពេលដែលយើងឃើញទ្រង់។

គ្រាន់តែក្រឡេកឃើញព្រះភ័ក្ត្រទ្រង់មួយភ្លែត ទុក្ខព្រួយទាំងអស់នឹងត្រូវបានលុបចេញអស់

ដូច្នេះចូររត់ប្រណាំងប្រកបដោយភាពអង់អាច រហូតដល់យើងបានឃើញទ្រង់។

–និពន្ធឡើងដោយ អ្នកស្រី អ៊ីស្ថើ ឃើរ រ៉ាស្ទ័យ (Esther Kerr Rusthoi)

ការប្រឡងផ្ទាល់ខ្លួន

ត្រូវ/ខុស ប្រសិនបើប្រយោគត្រឹមត្រូវ ចូរសរសេរអក្សរ ត នៅក្នុងចន្លោះបន្ទាត់។ ចូរសរសេរអក្សរ ខ ប្រសិនបើប្រយោគមិនត្រឹមត្រូវ។

.....១ ពាក្យថា "ព្រះគ្រិស្តព្រះដ៏មានជ័យជម្នះ" រំឭកយើងថាព្រះគ្រិស្តបានឈ្នះលើសេចក្តីស្លាប់ និង ទីបញ្ចុះសព សម្រាប់ទ្រង់ផ្ទាល់ និង សម្រាប់យើងផងដែរ។

.....២ នៅពេលដែលរូបកាយសាច់ឈាមនេះស្លាប់ទៅ គ្រិស្តបរិស័ទនឹងបានចូលទៅក្នុងព្រះវត្តមានរបស់ព្រះអម្ចាស់មួយរំពេច។

.....៣ នៅពេលដែលព្រះគ្រិស្តមានព្រះបន្ទូលថា នរណាដែលរស់នៅ និង ជឿលើទ្រង់ នោះនឹងមិនស្លាប់ឡើយ ទ្រង់សំដៅទៅលើការស្លាប់ខាងឯរូបកាយ។

.....៤ ក្តីសង្ឃឹមលើព្រះគ្រិស្តព្រះដ៏មានជ័យជម្នះ គឺផ្អែកទៅលើការដឹងថា ដោយសារការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ យើងមានជីវិតអស់កល្បជានិច្ចនៅឯស្ថានបរមសុខជាមួយទ្រង់។

.....៥ *ការអះអាងបញ្ជាក់ត្រឹមត្រូវ* សំដៅលើការប្រកាសថា ព្រះជាម្ចាស់បានឆ្លើយតបការអធិស្ឋានរបស់យើងហើយ តាំងពីមុនពេលដែលយើងរកឃើញចម្លើយនោះម៉្លេះ។

.....៦ មធ្យោបាយមួយដើម្បីបញ្ជាក់ពីឫទ្ធានុភាពរបស់ព្រះជាម្ចាស់ក្នុងការជួយអ្នកនៅក្នុងគ្រប់កាលៈទេសៈទាំងអស់ គឺការអំឭក និង ជឿតាមព្រះបន្ទូលសន្យារបស់ព្រះអង្គ។

.....៧ ព្រះបន្ទូលសន្យាខ្លះរបស់ព្រះជាម្ចាស់ ត្រូវបានធ្វើឡើងជាមួយនឹងល័ក្ខខ័ណ្ឌដែលយើងត្រូវបំពេញទៅតាមការកំណត់ណាមួយ ដើម្បីឲ្យយើងអាចទទួលបានព្រះបន្ទូលសន្យានោះ។

.....៨ គម្ពីរទំនុកតម្កើងជំពូក២៣ ត្រូវបានសរសេរឡើងដោយ អ្នកនិពន្ធដាវីឌ នៅក្នុងពេលដែលលោកកំពុងអស់សង្ឃឹម ព្រោះតែការអធិស្ឋានរបស់លោកមិនទទួលបានការឆ្លើយតប។

.....៩ យើងអាចអះអាងយ៉ាងជាក់ច្បាស់ នូវអ្វីដែលយើងអាចរំពឹងទុកឲ្យព្រះជាម្ចាស់ធ្វើនៅថ្ងៃអនាគត ព្រោះទ្រង់បានបង្ហាញឫទ្ធានុភាពរបស់ទ្រង់មកកាន់យើងកាលពីអតីតកាលរួចមកហើយ។

.....១០ ជំនឿរបស់ជនប្រុសស្រីដែលត្រូវបានរៀបរាប់នៅក្នុងគម្ពីរហេប្រឺជំពូក១១ គឺផ្អែកទៅលើជ័យជម្នះដែលពួកគេទទួលបានពេញមួយជីវិតរបស់គេ។

.....១១ ភាពស្រស់ស្អាតមួយនៃស្ថានបរមសុខ គឺជាការចែកចាយទៅវិញទៅមក រវាងពួកមនុស្សវិសុទ្ធ (ពួកសន្ត) អំពីសម្ព័ន្ធភាពខុសៗគ្នារបស់ពួកគេជាមួយនឹងព្រះជាម្ចាស់ នៅពេលដែលពួកគេទុកចិត្តលើទ្រង់គ្រប់ស្ថានភាពទាំងអស់នៅក្នុងជីវិតរបស់ពួកគេ។

.....១២ ឈ្មោះថ្មីដែលយើងម្នាក់ៗនឹងទទួលបានពីព្រះអាទិករបស់យើងនៅស្ថានបរមសុខ នឹងជារង្វាន់សម្រាប់ជ័យជម្នះដែលយើងមាននៅក្នុងជីវិតនេះ មិនថាលើបញ្ហាអ្វីក៏ដោយដែលយើងបានឆ្លងកាត់។

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

៩ អំពីអ្វីដែលព្រះជាម្ចាស់បានធ្វើសម្រាប់អ្នកនិពន្ធគម្ពីរទំនុកតំកើងជំពូកនេះ។

១ ផ្អែកលើការដែលថា នឹងអាចមានការប្រោសឲ្យរស់ពីស្លាប់ឡើងវិញ។

១០ សេចក្តីអធិស្ឋានដែលទទួលបានការឆ្លើយតប និង ការផ្តល់ក្តីស្រឡាញ់។

២ ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូគ្រិស្ត។

១១ អ្នកនិពន្ធគម្ពីរទំនុកតំកើងបានដាក់អំពើបាបទាំងអស់ចេញពីចិត្តរបស់គាត់។

៣ គ) នៅពេលដែលយើងបានរួបរួមជាមួយព្រះគ្រិស្តនៅឯស្ថានបរមសុខ។

១២ គឺថាព្រះអម្ចាស់បានសង្គ្រោះលោកពីបញ្ហា និង ការបៀតបៀនគ្រប់បែបយ៉ាង។

៤ ក) ៤) គម្ពីរម៉ាកុស ១១:២៤

ខ) ៦) គម្ពីរសុភាសិត ៣:៩-១០

គ) ៧) គម្ពីរលូកា ១១:៩

ឃ) ១) គម្ពីរទំនុកតម្កើង ៣៤:១៩-២០

ង) ៣) គម្ពីរលូកា ១៧:៦

ច) ៥) គម្ពីរយ៉ូហាន ១៤:២៣

ឆ) ២) គម្ពីរ១ពង្សាវតារក្សត្រ ៨:៥៦

១៣ ក) ព្រះអម្ចាស់បានគង់ខាងខ្ញុំ និង ប្រទានឲ្យខ្ញុំមានកម្លាំង។

ខ) ព្រះអម្ចាស់នឹងសង្គ្រោះខ្ញុំឲ្យរួចពីការវាយប្រហាររបស់វិញ្ញាណអាក្រក់ និង យកខ្ញុំទៅព្រះរាជ្យនៃស្ថានបរមសុខរបស់ទ្រង់ដោយសុវត្ថិភាព។

៥ ខ) យើងត្រូវរស់នៅជាប់ជាមួយទ្រង់ និង ស្រឡាញ់ទ្រង់។

១៤ ចម្លើយរបស់អ្នក។ នេះប្រហែលជាលំហាត់ ដ៏សំខាន់ជាងគេបំផុតមួយដែលអ្នកធ្វើនៅក្នុងមេរៀននេះ។

៦ ក) ដួងចិត្តដែលថ្វាយទៅកាន់ព្រះជាម្ចាស់ទាំងស្រុង។

ខ) ការកោតខ្លាចព្រះជាម្ចាស់ (ថ្វាយព្រះកិត្តិនាម គោរព និង ចុះចូល)

គ) ស្ថិតនៅជាប់ជាមួយព្រះគ្រិស្ត និង អនុញ្ញាតឲ្យទ្រង់គង់នៅក្នុងអ្នក។

ឃ) ការជឿជាក់ (ជំនឿ) ថាអ្នកនឹងទទួលបានអ្វីដែលអ្នកទូលសូម

ង) ការស្តាប់បង្គាប់ព្រះបន្ទូលរបស់ទ្រង់ និង ធ្វើអ្វីដែលគាប់ព្រះហឫទ័យទ្រង់។

១៥ ខ៣៥ ដល់ ខ៣៨ ប្រាប់យើងអំពីជនប្រុសស្រីប្រកបដោយជំនឿរឹងមាំ ដែល*មិន* បានទទួលការប្រោសលោះឲ្យរួចពីបញ្ហា និង ការបៀតបៀនរបស់ពួកគេទទួលរងនោះទេ ប៉ុន្តែជាអ្នកដែលទទួលរងទុក្ខ ឬ ថ្វាយជីវិតរបស់ពួកគេដើម្បីបម្រើព្រះជាម្ចាស់វិញ។

៧ ព្រះជាម្ចាស់នឹងឆ្លើយតបមកយើង នៅពេលណាដែលយើងស្រែករកព្រះនាមរបស់ទ្រង់។

១៦ ដោយសារតែព្រះជាម្ចាស់បានរៀបចំផែនការដ៏ល្អប្រសើរ (សម្រាប់យើងទាំងអស់គ្នា)។ (ការប្រោសលោះយ៉ាងពិតប្រាកដរបស់ពួកគេមិនផ្អែកទៅលើ ការស្រាកស្រាន្តរយៈពេលខ្លីពីបញ្ហានៅក្នុងលោកីយ៍នេះទេ)។

៨ "បពិត្រព្រះរាជា ព្រះដែលទូលបង្គំយើងខ្ញុំគោរពបំរើ ពិតជាអាចរំដោះទូលបង្គំយើងខ្ញុំ គឺព្រះអង្គនឹងរំដោះយើងខ្ញុំអោយរួចពីភ្លើងដ៏សន្ធោសន្ធៅ និងអោយយើងខ្ញុំ រួចពីព្រះហស្តរបស់ព្រះករុណា ជាមិនខាន។" (ខ១៧)

១៧ ក) ខុស (អ្នកខ្លះត្រូវបានគេសម្លាប់។ ការប្រោសលោះរបស់ពួកគេគឺមានលក្ខណៈផ្សេង)

ខ) ត្រូវ

គ) ត្រូវ

ឃ) ត្រូវ

ង) ខុស

ច) ត្រូវ

សូមចូលរួមអបអរសាទរ

ឥឡូវនេះអ្នកបានបញ្ចប់មេរៀននៅក្នុងជំពូកចប់សព្វគ្រប់ហើយ។ យើងសង្ឃឹមថាវាជាជំនួយ ដ៏ល្អសម្រាប់អ្នក។ ចូររំឭកមេរៀនទាំងអស់នៅក្នុងជំពូកទី៣ ហើយធ្វើ*ការប្រឡងជំពូកទីបីនេះ* ។ នៅពេលដែលអ្នកបញ្ចប់ការប្រឡងនេះ ចូរធ្វើតាមការណែនាំដោយប្រុងប្រយ័ត្ន ដើម្បីដាក់ស្នើការដាក់ពិន្ទុសម្រាប់ការប្រឡងរបស់អ្នក។

អក្ខរានុក្រម

នៅក្នុងប្រអប់ជួរឈរដែលនៅខាងស្តាំដៃមានផ្តុំកលេខមេរៀននៅក្នុងសៀវភៅសិក្សាដោយខ្លួនឯងនេះ ដែលពាក្យនោះត្រូវបានយកមកប្រើដំបូងគេបង្អស់។

ពាក្យគន្លឹះ	និយមន័យ	មេរៀន
ការកាត់ផ្តាច់ចេញ isolation	សភាពមួយដែលត្រូវបានដាក់នៅកន្លែងផ្សេងពីអ្នកដទៃ, ភាពឯកា	៩
ការកាត់ទោស condemnation	ភាពដែលត្រូវបានគេចោទប្រកាន់ ឬ ប្រកាសថា ខុសឆ្គង ឬ មានទោស	៨
ការកោតសរសើរ commended	ការនិយាយអំពីនរណាម្នាក់ដោយលើកតម្កើង	១០
ការចុះចាញ់ retreat	ការយកចេញពីរឿងអ្វីម្យ៉ាងដែលពិបាក គ្រោះថ្នាក់ ឬ មិនស្រណុកចិត្ត	៣
ការចុះចូល submissive	ការស្របតាមអ្នកដទៃ	៥
ការចោទប្រកាន់ accusation	ការចោទថាមានទោស ឬ បន្ទោស	៣
ការច្រានចោល rejected	ការដេញចេញ, ការបដិសេធ, ការបោះចោល	៦
ការឆ្លុះបញ្ចាំង reflection	ការបង្កើតរូបភាពមួយ ដោយកញ្ចក់ , ដែលឲ្យរូបភាព និង លក្ខណដូចរូបមួយនោះមកវិញ	១០
ការជំទាស់ dissension	មិនយល់ស្របចំពោះគំនិត	២
ការដកចេញ withdrawal	ការដកថយ ឬ ការថយចេញទៅនៅកន្លែងដែលមានតែឯង	៣
ការថ្នាំងថ្នាក់ចិត្ត resentment	អារម្មណ៍ខឹង មិនពេញចិត្ត ដែលបណ្តាលមកពីអ្វីមួយដែលខុសឆ្គង ការដៀលត្មៃ ឬ ភាពអយុត្តិធម៌	៨
ការទទួលស្គាល់ acknowledge	ការកត់សំគាល់ពីអ្វីមួយ , ការស្គាល់សិទ្ធិ, សិទ្ធិអំណាច, ឬ ហ៊ាន:	២
ការបង្កើត procreation	ការផលិតឲ្យមានកូនចៅជំនាន់ក្រោយ	៧
ការបណ្តាយខ្លួន self-indulgence	ការធ្វើឲ្យដោយស្របតាមបំណងចិត្ត សេចក្តីស្រេកឃ្លាន ឬ ភាពអន្ទះសារ	៤

ការបៀតបៀន persecution — អំពើ ឬ ការប្រព្រឹត្តិ ដែលធ្វើឲ្យមានទុក្ខវេទនា ព្រោះតែជំនឿ, ជាពិសេសទៅលើអ្នកដែលមានដើមកំណើត សាសនា ឬ ជំនឿក្នុងសង្គមផ្សេងពីខ្លួន — ១

ការបំបិទ prohibited — ហាមឃាត់, ការពារមិនឲ្យធ្វើអ្វីមួយ, រារាំងមិនឲ្យធ្វើបាន — ៥

ការប្រមាថ profane — មិនវិសុទ្ធ, មិនបរិសុទ្ធ, មិនគោរព — ៤

ការប្រមូលផ្តុំ accumulation — ពូនឡើង ឬ គរឡើង , ជាដំណើរការនៃការកើនឡើងចំនួន ឬ បរិមាណ — ៨

ការពិន័យ penalty — គុណវិបត្តិ, ការបាត់បង់ ឬ ភាពលំបាកនៅក្នុងសកម្មភាពខ្លះៗ, ការរងទុក្ខ ឬ តម្លៃដែលត្រូវបង់ថ្លៃសម្រាប់សកម្មភាពមួយ — ២

ការពឹងពាក់គ្នាទៅវិញទៅមក mutuality — ជាលក្ខណៈ ឬ សភាពដែលការឲ្យនឹង ការទទួលមានកម្រិតស្មើៗគ្នា — ៧

ការព្យាបាលរោគ therapy — ការព្យាបាលជំងឺខាងឯរូបកាយ, អ្វីមួយដែលនាំឲ្យមានការកែតម្រូវ — ៨

ការរួមភេទមុនពេលរៀបការ fornication — ទំនាក់ទំនងផ្លូវភេទដែលក្រៅពីរវាងបុរសម្នាក់ និងប្រពន្ធរបស់គាត់, ការរួមភេទរវាងមនុស្សដែលមិនទាន់រៀបការ — ៧

ការរួមសង្វាសភេទដូចគ្នា homosexuality — ទាក់ទងនឹងចំណង់ផ្លូវភេទទៅចំពោះសមាជិកដែលមានភេទដូចខ្លួនឯង — ៧

ការសម្របសម្រួល adjustments — សកម្មភាព ឬ ដំណើរការនៃការនាំឲ្យមានភាពស្គប់ស្គល់ , ការតម្រូវតាម — ៣

ការសោកសង្រេង dejection — ភាពក្រៀមក្រំ , ក្បត់ខ្សោយខាងឯវិញ្ញាណ — ៨

ការស៊ូទ្រាំ perseverance — សកម្មភាព ឬ ស្ថានភាព នៃការប្រកាន់យ៉ាងខ្ជាប់ខ្ជួន, ការរក្សាជំហរមួយ — ១

ការអោនលំទោន meek — ការអត់ទ្រាំជាមួយនឹងភាពអយុត្តិធម៌ ទប់ចិត្ត និង គ្មានការពេញចិត្ត , មិនហិង្សា ឬ មិនខ្លាំង — ២

កើតរោគ stricken — បញ្ហា ជាមួយនឹងជំងឺ , អភ័ព្វ ឬ ទុក្ខវេទនា — ៩

កំណាច aggressive — មានទំនោរចង់គ្រប់គ្រងលើគេ ដែលជារឿយៗមានខ្វល់ខ្វាយពីសិទ្ធិរបស់អ្នកដទៃ — ៣

ក្តៅក្រហាយ afflicted — មួម៉ៅខ្លាំង ដែលធ្វើឲ្យមានទុក្ខបន្តដល់អ្នកដទៃ — ៩

ក្មេងខ្ចី immaturity — ភាពដែលនៅខ្វះការលូតលាស់ ឬ ការអភិវឌ្ឍពេញលេញ — ៤

ខាងឯផ្លូវចិត្ត psychological	គតិ, នាំទៅកាន់បំណងចិត្ត ឬ ឆ្ពោះទៅកាន់គំនិត, ទាក់ទងទៅនឹងគំនិត និង អាកប្បកិរិយា	២
ខ្ពស់បំផុត ultimate	ចុងក្រោយ, ទីបំផុត, មូលដ្ឋាន, ដំណើរការចុងក្រោយបំផុត	៩
គុណប្រយោជន៍ benefit	សកម្មភាពប្រកបដែលក្តីមេត្តា , អ្វីម្យ៉ាងដែលជំរុញឲ្យមានភាពសុខស្រួល , ពរជ័យ, គុណសម្បត្តិ	១
គោរពតាមconformed	នាំទៅរកភាពត្រូវគ្នា ឬ កិច្ចការព្រមព្រៀងមួយ	១
គោលការណ៍ principles	ច្បាប់ ឬ ក្រិតក្រមនៅក្នុងការប្រព្រឹត្តិ	២
គ្មានស្មារតី insensitivity	ជាសភាពមួយដែលគ្មានអារម្មណ៍ , មិនអើពើ	៦
គ្រោះមហន្តរាយ disaster	ភាពអភ័ព្វដ៏ធំ និងភ្លាមៗ , ភាពវឹកវរ, ហេតុការណ៍ ឬ ព្រឹត្តិការណ៍ដែលអាក្រក់	១
ងាយរងគ្រោះ vulnerable	ដែលអាចរងរបួស , ដែលបើកចំហសម្រាប់ការវាយប្រហារ	៨
ចរិយាមារយាទ conduct	អាកប្បកិរិយា , ការបង្ហាញផ្លូវ	៣
ចលាចល turmoil	ការច្របូកច្របល់, ស្ថានភាព ឬ សភាពដែលមានការរំខានខ្លាំង	១០
ចិត្តសប្បុរស generosity	ភាពសប្បុរស នៅក្នុងវិញ្ញាណ ឬ កាយវិការ	៤
ចិត្តអាសូរ compassionate	មានមេត្តាធម៌ , ភាពខ្វល់ខ្វាយ	៣
ចុងក្រោយ terminal	ទាក់ទងនឹងចុងបញ្ចប់, ដូចជាសេចក្តីស្លាប់ជាដើម	៨
ចំណែកថ្នាក់ categories	កម្រិត, ក្រុម, ប្រភេទ	៣
ចំណុះ capacity	សមត្ថភាពក្នុងការកាន់ជាប់ ទទួលបាន ឬ ផ្ទុក, រង្វាស់នៃបរិមាណ	១
ចំរាញ់ refined	ធ្វើឲ្យសុទ្ធ, ធ្វើឲ្យប្រសើរឡើង ឬ ធ្វើឲ្យល្អឥតខ្ចោះ ដោយការតម្រឹម និង ការដុសខាត	១
ច្នៃឲ្យប្រសើ (ការធ្វើឲ្យប្រែទៅជា) sublimation	បង្វែរទិសដៅនៃថាមពល ពីគោលបំណងមួយទៅក្នុងគោលបំណងមួយទៀតដែលខ្ពង់ខ្ពស់ជាង ទាំងឯខាងសីលធម៌ ឬ ខាងឯវប្បធម៌	៧
ច្រាស់ contrary	ផ្ទុយ	៣

ឆាប់ប្រតិកម្ម sensitive	ងាយនឹងឆ្លើយតប (ដូចជាទៅកាន់បង្ហាញ ឬតម្រូវការរបស់អ្នកដទៃ) , ការខ្វល់ខ្វាយ	២
ជនរងគ្រោះ victims	អ្នកដែលរងរបួស ត្រូវបានបំផ្លាញ ឬធ្វើឲ្យខូចខាត ដោយស្ថានភាពណាមួយដែលគេមិនអាចនឹងគ្រប់គ្រងបាន	៥
ជំងឺកាមរោគ venereal disease	ជំងឺឆ្លងដែលភាគច្រើនតាមរយៈទំនាក់ទំនងផ្លូវភេទ	៧
ជម្រើស alternatives	សំណើរ ឬ ជម្រើសពីរឬ ច្រើនដែលទាមទារឲ្យធ្វើការជ្រើសរើស	៣
ជម្រើសតែមួយគត់ default	ការជ្រើសរើសដែលត្រូវបានធ្វើឡើង ដោយគ្មានជម្រើសផ្សេងៗ	៦
ជម្លោះ discord	គ្មានការព្រមព្រៀង ឬ ភាពត្រូវរ៉ូវគ្នា	៥
ជាប់ទោស bondage	ទាសភាព, ភាពខ្វះសិទ្ធិផ្ទាល់ខ្លួន	២
ជីវិតខាងឯផ្លូវភេទ sexuality	លក្ខណៈ ឬ សភាពនៃភេទ	៧
ជ្រមុជ submerge	ទៅក្រោម, បាត់ពីភ្នែក, លិច (ដូចនៅក្នុង ភាពក្រីក្រ ឬ សេចក្តីវេទនា) , លាក់ខ្លួន	៦
ឈ្វេងយល់ comprehend	យល់ដឹង	១០
ញាណដឹង insight	អំណាច ឬ សកម្មភាពក្នុងការមើលឃើញទៅក្នុងស្ថានការណ៍ , សកម្មភាពដែលមើលឃើញទៅក្នុងលក្ខណៈរបស់អ្វីមួយ	២
ញាតិសាច់ឆ្ងាយ extended family	សមាជិកគ្រួសារដែលលើសពីគ្រួសារគោល (ឪពុកម្តាយ និងកូនៗ)	៦
ដកចេញ deprived	ហាមឃាត់, ត្រូវបានបំបាត់ចោល ឬ យកចេញ	៣
ដែលគាប់សង្កត់ depressive	ការសង្កត់ចុះ, ធ្វើឲ្យក្រៀមក្រំ, បំបាក់ទឹកចិត្ត	៨
ដែលត្រូវបានគេស្លាប់ចោល bereaved	ត្រូវបានដកហូតចេញទៅដោយសារសេចក្តីស្លាប់	៩
ដំណោះស្រាយ solution	សកម្មភាព ឬ ដំណើរការក្នុងការដោះស្រាយបញ្ហា , ចម្លើយ	១
ឋានៈ status	តំណែង ឬ សក្តិ ដែលទាក់ទងជាមួយនឹងអ្នកដទៃ ឬ ការមើលឃើញរបស់អ្នកដទៃ	៤
បន្ថោកបន្ទាប(ថយចុះ) demeaning	បន្តយកម្រិត	៦
ថោកទាប	ច្រឡោះបោះ, អាក្រក់, ដែលធ្វើឲ្យអាក់អន់ចិត្ត	៤

vulga		
ថ្នាំបន្សាប antidote	របស់ដែលបន្ធូរបន្ថយ ការពារ ឬ ប្រឆាំងនឹងអ្វីមួយ	៩
ទស្សនៈវិស័យ perspective	ជាសមត្ថភាពក្នុងការមើលទៅដល់សារៈសំខាន់ និង ទំនាក់ទំនងនៃរបស់អ្វីមួយ	២
ទាក់ទង interact	ការធ្វើសកម្មភាពទៅលើនរណាម្នាក់, មានទំនាក់ទំនងដ៏មានន័យជាមួយនរណាម្នាក់	១
ធំពេញវ័យ maturing	ដំណើរការនៃការលូតលាស់ ឬ ការអភិវឌ្ឍ	១
នៅលីវ celibate	បុគ្គលដែលមិនទាន់រៀបការ និង អ្នកដែលមិនប្រលូកនៅក្នុងសកម្មភាពរួមសង្វាស់	៦
បង្កកំហឹង exasperate	ធ្វើឲ្យមានការមួរម៉ៅ ឬ ការរំខាន , ធ្វើឲ្យខឹង	៥
បង្អាប់ humiliate	បន្ទាបឲ្យទាបនៅក្នុងភ្នែករបស់នរណាម្នាក់ផ្ទាល់ ឬឲ្យទាបនៅក្នុងភ្នែករបស់អ្នកដទៃ, បញ្ចុះ	៥
បន្ថោកតម្លៃ belittle	ធ្វើឲ្យមើលឃើញថាតូចតាច ឬ អន់ជាង	៥
ការថោកទាប degraded	ត្រូវបានកាត់បន្ថយឲ្យនៅទាបជាងកម្រិតធម្មតា, ដកចេញពីឋានៈ ឋានន្តរៈសក្តិ ឬ ការកាន់តំណែង	៧
បន្សុទ្ធ purified	ធ្វើឲ្យរួចផុតពីទោសកំហុស ឬ ភាពមានខ្វោះ, ភាពមិនស្អាតស្អំ	១
បណ្តោយតាម indulgent	រៀបរាប់ពីបុគ្គលម្នាក់ដែលស្របតាមបំណងចិត្តរបស់មនុស្សម្នាក់ទៀត , ធ្វើអំពីសប្បុរសទៅលើនរណាម្នាក់	៥
បណ្តោះអាសន្ន temporary	នៅជាប់តែមួយរយៈពេលខ្លី	១០
ប៉ាន់ប្រមាណ speculate	ការសញ្ជឹងគិតលើ ឬ ការថ្លឹងថ្លែងមើល លើប្រធានបទមួយ, ការសន្និដ្ឋាន	១០
បំពាន Offense	អំពើមួយនៃការជិះជាន់, អំពើនៅក្នុងការឈ្លានពាន, អំពើដែលធ្វើឲ្យមិនពេញចិត្ត	៣
បោះបង់ចោល abandoned	ចាកចោល, ដែលគ្មានមនុស្ស, ទុកចោលទាំងស្រុងនៅសេចក្តីមេត្តាករុណារបស់នរណាម្នាក់ ឬអ្វីមួយ	៦
ប្តីប្រពន្ធ spouse	មនុស្សដែលរៀបការរួច, ប្រពន្ធរបស់បុរសម្នាក់ ឬ ប្តីរបស់ស្ត្រីម្នាក់	៥
ប្តីមួយប្រពន្ធមួយ	ទាក់ទងទៅនឹងអាពាហ៍ពិពាហ៍តែជាមួយបុគ្គលតែម្នាក់	៧

monogamous		
ប្រឈមមុខ	ធ្វើឲ្យជល់មុខគ្នា , ទាល់មុខគ្នា	៣
confronted		
ប្រតិកម្មតប	សកម្មភាពមួយដែលបណ្តាលឲ្យមានការទាស់យ៉ាងខ្លាំងទៅ	៣
reaction	ជាមួយនឹងសកម្មភាពមួយផ្សេងទៀត	
ប្រពលភាព	កម្រិតកម្លាំងដ៏ខ្លាំងក្លា, កម្លាំង ឬ ថាមពល	៩
intensity		
ប្រមេះទឹកបាយ	ជំងឺកាមរោគ, រោគមួយដែលកើតមានតាមរយៈការរួមភេទ, ជា	៧
gonorrhea	ពិសេសជាមួយនឹងដៃគូច្រើន	
ផលលំបាក	ឥទ្ធិពល , លទ្ធផលនៃស្ថានភាពណាមួយ	៣
consequences		
ផ្នឹម	ការភ្ជាប់គ្នា	៥
Yoked	បញ្ឈប់ការមានផ្ទៃពោះមុនពេលកំណត់;	៧
ពន្លូតកូន	ដើម្បីបំផ្លាញទារក	
abort		
ភាពក្លៀវក្លា	កម្លាំងកាយ និង ចិត្តដែលអភិវឌ្ឍយ៉ាងខ្ពង់ខ្ពស់	៨
vitality		
ភាពក្រីក្រ poverty	ភាពខ្វះខាតលុយ ឬ សម្ភារដែលជាកម្មសិទ្ធិរបស់ខ្លួន	៤
ភាពជ្រុលនិយម	ទស្សនៈវិស័យ និង អាកប្បកិរិយា ដែលកំណត់ដោយភាព	៣
fanaticism	សោមនស្សរីករាយ ឬ ភក្តីភាពជ្រួលហួសហេតុ	
ភាពតានតឹង stress	កត្តាខាងឯរូបកាយ ខាងផ្លូវចិត្ត ឬខាងអារម្មណ៍ដែលធ្វើឲ្យមាន	៨
	ការកៀបសង្កត់ខាងឯរូបកាយ ឬខាងផ្លូវចិត្ត	
ភាពតូចទាប	សមត្ថភាព ឬ ភាពដែលមានតម្លៃតិចជាង , សារៈសំខាន់តិច	៤
inferiority	ជាង ឬ គុណសម្បត្តិតិចជាង	
ភាពបោកប្រាស់	ភាពមិនស្មោះត្រង់ ឬខុសឆ្គង, ព្យាយាមធ្វើការបោកប្រាស់	៤
deceitfulness		
ភាពឆឹតក្បត់	ភាពមិនស្មោះត្រង់នៅក្នុងចំណងអាពាហ៍ពិពាហ៍	៥
infidelity		
ភាពពិសេសដាច់ឡែក	សភាព ដែលគ្មានអ្វីស្មើ, សភាពដែលមិនដូចគេផ្សេង	១០
uniqueness		
ភាពមុឹងម៉ាត់	ស្ថានភាពនៃការរស់នៅ ឬ ការធ្វើការដោយផ្អែកទៅលើជំនឿ	៥
consistency	ផ្ទាល់ខ្លួនរបស់បុគ្គលណាម្នាក់។	
ភាពល្វីងជូរចត់	ភាពតូចចិត្ត បណ្តាលមកពីការឈឺចាប់ ឬ ទុក្ខព្រួយ, ភាព	៣
bitterness	តានតឹង នៅក្នុងគំនិត	
ភាពស្ងប់ស្ងាត់	សភាព ឬ លក្ខណៈដែលមានសន្តិភាព ឬ ស្ងប់ ភាពនឹងនរ ឬ	៨
tranquillity	ស្រឡះ	

ភាពអសីលធម៌ immorality	ភាពឃោរឃៅ មិនទៀងត្រង់ជាមួយនឹងភាពបរិសុទ្ធ ឬ អាកប្បកិរិយាត្រឹមត្រូវ	១
ភាពអារ infertile	មិនអាចបង្កើតបាន, ភាពគ្មានកូន	៧
មនសិការ conscience	អារម្មណ៍មានសីលធម៌នៅក្នុងខ្លួនរបស់មនុស្សម្នាក់ផ្ទាល់, ចេតនា ឬ បុគ្គលិកលក្ខណៈ ដែលរួមជាមួយនឹងអារម្មណ៍ចង់ធ្វើរឿងត្រឹមត្រូវ ឬ រឿងល្អ។	២
មានគភ៌ pregnant	ការផ្ទុកទារកដែលមិនទាន់កើតនៅក្នុងខ្លួន	៧
មិនចេះខឹង unoffendable	សមត្ថភាពក្នុងការទទួលយកការវាយប្រហារដោយមិនខឹង ឬ ការអន់ចិត្ត	៣
មេត្តាធម៌ compassion	ការជ្រាបដឹងប្រកបដោយចិត្តអាណិតអាសូរ អំពីភាពតានតឹងរបស់មនុស្សម្នាក់ទៀត ដែលចូលរួមដោយបំណងចិត្តចង់ជួយ	១
រក្សា maintain	ប្រកាន់យកសភាពដើម, បន្ត ឬ ទុកនៅមួយកន្លែង	១០
រចនាសម្ព័ន្ធ structure	អ្វីដែលបង្កើតបានជាផ្នែក ដែលពឹងផ្អែកលើគ្នាទៅវិញទៅមក	៥
រឹតបន្តឹង restricted	ហាមឃាត់, កំណត់នៅក្នុងដែនខណ្ឌមួយ ឬ កម្រិតមួយ	៥
អាការរោគ symptoms	ភស្តុតាងបង្ហាញពីជំងឺ ឬ ការរំខានខាងរូបកាយផ្សេងទៀត ; អ្វីម្យ៉ាងដែលបញ្ជាក់ពីវត្តមាននៃអ្វីម្យ៉ាងទៀត	៩
រោគស្វាយ syphilis	ជាកាមរោគដែលមានលក្ខណៈឆ្លង ដែលតែងតែឆ្លងតាមរយៈការរួមភេទ	៧
រោគវិនិច្ឆ័យ diagnosis	ជាសិល្បៈ ឬ សកម្មភាពក្នុងការកំណត់អត្តសញ្ញាណជំងឺ តាមរយៈរោគសញ្ញា និង អាការរោគ	៩
រំខាន disrupt	កាត់ផ្តាច់,បណ្តាលឲ្យដាច់ចេញ	៥
ល្មោភ covet	ចង់បាន ការច្រណែន ចំណង់ចិត្តដ៏ខ្លាំងហួសហេតុ ចំពោះអ្វីដែលជារបស់អ្នកដទៃ	២
វ័យជំទង់ adolescence	សភាព ឬ ដំណើរការនៃការលូតលាស់ឡើង, គ្រាមួយនៅក្នុងជីវិតដែលខិតទៅរកភាពពេញវ័យ	៥
សងសឹក revenge	ធ្វើឲ្យមានរបួសដើម្បីការតបនឹងការរងរបួស	៣
សារភាព confess	ទទួលស្គាល់, ការលាត់ត្រដាងកំហុសរបស់នរណាម្នាក់	២
សញ្ញឹងគិត(សង្រួមចិត្ត) meditation	សកម្មភាព ឬដំណើរការនៃការគិត , ការសញ្ជប់សញ្ជឹង, ការពិចារណាដែលប្រកបដោយការអធិស្ឋាន	៣

សន្ទុះចិត្ត impulse	ទំនោរចិត្តភ្លាមៗឆ្ពោះទៅរកសកម្មភាពដែលមិនបានរៀបចំផែនការទុកមុន	៣
សេចក្តីលោភលន់ greed	ចំណង់ចិត្តជ្រុលហួសហេតុចំពោះទ្រព្យសម្បត្តិ និងចង់ឈ្នះ	៤
ស្រឡាញ់ភេទខុសគ្នា heterosexual	ទាក់ទងជាមួយនឹងមនុស្សភេទខុសគ្នា, ស្រឡាញ់ទាក់ទាញជាមួយនឹងមនុស្សដែលមានភេទផ្ទុយគ្នា	៧
អធិធម្មជាតិ supernatural	ដែលទាក់ទងនឹងព្រះជាម្ចាស់, ទាក់ទងនឹងកម្រិតមួយដែលលើសពីអ្វីដែលមនុស្សអាចមើលឃើញ ឬ សង្កេតឃើញនៅក្នុងពិភពធម្មជាតិ	៣
អយុត្តិធម៌ injustice	ការខូចប្រយោជន៍ដោយមិនសមហេតុផល , មិនស្មើភាព , អំពើមិនសមរម្យ	៤
អាទិភាព priorities	របស់ដែលសំខាន់ទីមួយ	១
អាសអាភាស obscene	គួរឲ្យខ្ពើមសម្រាប់អារម្មណ៍ , ធ្វើឡើងដើម្បីបង្កឲ្យមានភាពស្រើបស្រាល ឬ អំពើអាក្រក់	៤
អំពើសហាយស្មន់ adultery	ទំនាក់ទំនងផ្លូវភេទ ដោយចេតនារវាងបុរសដែលរៀបការរួចជាមួយនឹងមនុស្សម្នាក់ផ្សេងទៀតក្រៅពីប្រពន្ធរបស់គាត់ ឬ រវាងស្ត្រីដែលរៀបការរួចជាមួយនឹង មនុស្សម្នាក់ទៀតដែលមិនមែនជាប្តីរបស់នាង	៧
អះអាងបញ្ជាក់ affirm	ការថ្លែងប្រាប់ដែលវិជ្ជមាន , ការគាំទ្រថាជាការពិត ឬ ត្រូវបានបញ្ជាក់ច្បាស់	១០
អ្នកបម្រើ steward	បុគ្គលម្នាក់ដែលរៀបចំការងារយ៉ាងសកម្ម, បុគ្គលម្នាក់ដែលបម្រើអ្នកដទៃ	៤
ឥតខាន់ស្លា illegitimate	កូនដែលកើតមកដោយឪពុកម្តាយមិនបានរៀបការស្របច្បាប់	៧
ឥរិយាបថ attitude	ជាអារម្មណ៍ ឬ ចិត្តដែលមានទៅលើរឿងមួយ ឬ ស្ថានភាពមួយ	២
ឧត្តមភាព superiority	លក្ខណសម្បត្តិ ឬ សភាព ដែលមានឋានៈ ខ្ពស់ ឬ សំខាន់ជាងគេ	៤

ឯកសារយោង

Cho, Dr. David Yonggi. 1980. *Solving Life's Problems*. Alachua, FL: Bridge-Logos.

Duncan, David D. 2011. *Alive In Christ*. 4th ed. Springfield, MO: Global University.

Greene, William W., Jr. 1976. *Introduction to Psychology*. Brussels: International Correspondence Institute.

Howard, Rick. 2007. *Christian Maturity*. 4th ed. Springfield, MO: Global University.

Kubler-Ross, Elisabeth. 1969. *On Death and Dying*. New York: Macmillan Publishing Co., Inc.

Lewis, C. S. 1996. *The Problem of Pain*. New York: HarperCollins.

Simon, Paul. I Am a Rock. *The Paul Simon Songbook*. CBS 201797. Originally released in 1965.

ចម្លើយសម្រាប់ការប្រឡងផ្ទាល់ខ្លួន

មេរៀនទី១

១ ខ) បញ្ហា

២ ក) ស្តាប់បង្គាប់ព្រះជាម្ចាស់ និង ព្រះបន្ទូលរបស់ទ្រង់។

៣ ឃ) អំណរ

៤ គ) ល្បួងយើង

៥ ក) មនុស្សគ្រប់គ្នាសុទ្ធតែមានទោសនៃបាបផ្ទាល់ខ្លួន។

៦ ក) ការឆ្លើយតបដែលខុស

៧ ខ) គុណតម្លៃដ៏អស់កល្ប

៨ ខ) បន្តទៅមុខជាមួយគោលបំណងរបស់អ្នក និង មិនបោះបង់ចោលឡើយ។

៩ គ) ល្បួងឲ្យយើងធ្វើអំពើអាក្រក់

១០ ឃ) កំហុសក្នុងការវិនិច្ឆ័យ ឬ គ) ឥទ្ធិពលមកពីខាងក្រៅ

១១ ច) ព្រះជាម្ចាស់កំពុងធ្វើការជាមួយយើង

១២ ខ) អំពើបាបផ្ទាល់ខ្លួន

១៣ ង) ជម្រើសដែលបានពិចារណាយ៉ាងប្រុងប្រយ័ត្ន

១៤ ខ) អំពើបាបផ្ទាល់ខ្លួន

១៥ គ) ឥទ្ធិពលមកពីខាងក្រៅ ឬ ក) ពិភពលោកដែលខូតខាតដោយអំពើបាប

១៦ ក) ពិភពលោកដែលខូតខាតដោយអំពើបាប

មេរៀនទី២

១ គ) ព្រះយេស៊ូគឺជាព្រះអម្ចាស់។

២ ខ) បញ្ហាអំពើបាប

៣ ក) វាផ្តល់មធ្យោបាយដើម្បីឲ្យខ្ញុំបានរួចពីការផ្តន្ទាទោសនៃសេចក្តីស្លាប់បាន។

៤ ឃ) ការស្តាប់តាមព្រះបន្ទូលរបស់ទ្រង់។

៥ គ) បទបន្ទូល

៦ ត

៧ ខ

៨ ខ

៩ ត

១០ ត

១១ ខ

១២ ខ

១៣ ត

១៤ ខ

១៥ ត

១៦ ត

មេរៀនទី៣

១ ក) នាងគ្មានប្រាក់សម្រាប់ការសិក្សានៅមហាវិទ្យាល័យរបស់នាងទេ។

ខ) ប្រភពនៃបញ្ហាគឺការសម្រេចចិត្តរបស់ឪពុកម្តាយរបស់នាង ដែលប្រើប្រាស់លុយរបស់ពួកគេសម្រាប់ការសិក្សារៀនសូត្រកូនប្រុសរបស់ពួកគេ។ នេះគឺជាការសម្រេចចិត្តដែលស្ថិតនៅក្រៅពីការគ្រប់គ្រងរបស់អាឡែន។

គ) អាឡែនបានឆ្លើយតបដោយការចុះចាញ់។ ការឆ្លើយតបរបស់នាងមានពេញដោយ ការច្រណែន ភាពអាត្មានិយម និង ការស្រណោះខ្លួនឯង។ ការឆ្លើយតបរបស់នាងមានតែនាំបញ្ហាបន្ថែមឲ្យនាង ដោយនាំឲ្យមានបញ្ហាធ្ងន់ធ្ងរ ទាក់ទងជាមួយជំងឺផ្លូវចិត្ត។

ឃ) ប្រសិនបើអាឡែនថ្វាយបញ្ហានេះទៅកាន់ព្រះអម្ចាស់ ទ្រង់អាចនឹងជួយនាងស្វែងរកដំណោះស្រាយតាមសុភនិច្ឆ័យ(គំនិតត្រឹមត្រូវ)បាន ដូចជាការងារសម្រាប់បង់ថ្លៃមហាវិទ្យាល័យដូចជាមនុស្សផងទាំងពួងគេធ្វើយ៉ាងដូច្នោះដែរ។ ប្រហែលជាទ្រង់អាចនឹងប្រទានដំណោះស្រាយដ៏អស្ចារ្យមួយសម្រាប់បញ្ហាដែលអាឡែនមិនស្មានដល់ក៏ថាបាន។

ង) អាឡែនគួរតែទុកចិត្តលើព្រះជាម្ចាស់ដើម្បីឲ្យទ្រង់បានធ្វើការសម្រាប់ផលប្រយោជន៍នាង ដូចទ្រង់បានសន្យានៅក្នុងគម្ពីររ៉ូម ៨:២៨។

២ ក) ច័រដាន គួរតែចាប់ផ្តើមតាមរបៀបដោះស្រាយរបស់គ្រិស្តបរិស័ទ៖ ការរៀបចំខាងវិញ្ញាណតាមរយៈការអានព្រះគម្ពីរ ការអធិស្ឋាន និងការស្ម័គ្រចិត្តស្វែងយល់ និង ធ្វើតាមបំណងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ បន្ទាប់មកគាត់គួរតែអាចជៀសវាងការឆ្លើយតបដែលខុសឆ្គង ហើយគាត់អាចចាប់ផ្តើមស្វែងរកដំណោះស្រាយតាមបែបគ្រិស្តបរិស័ទ។ ការធ្វើដូច្នេះ អាចជាការលើកតម្កើងសិរីរុងរឿងដល់ព្រះជាម្ចាស់។

ខ) ច័រដាន និង ដាវីឌក្លាយជាសត្រូវនឹងគ្នា ហើយការនេះបានជះឥទ្ធិពលអាក្រក់ទៅលើក្រុមជំនុំរបស់ពួកគេទាំងមូល។ វាក៏ក្លាយជាទីបន្ទាល់មិនល្អទៅកាន់ មិត្តទាំងឡាយរបស់ពួកគេដែលមិនមែនជាគ្រិស្តបរិស័ទ ។

គ) លទ្ធផលចុងក្រោយគួរណាតែ ក្នុងចិត្តរបស់ចំរដានមានពេញដោយការសរសើរតម្កើងដែលព្រះជាម្ចាស់បានប្រទានឲ្យគាត់មានជ័យជម្នះខាងឯវិញ្ញាណក្នុងការប្រឈមមុខជាមួយស្ថានភាពរបស់គាត់ មិនខ្វល់ថាគាត់ទទួលបានលុយរបស់គាត់មកវិញឬអត់ក៏ដោយ ។ ការនេះគួរតែបានជាការតម្កើងសិរីរុងរឿងព្រះជាម្ចាស់។

ឃ) ចំរដានគួរតែបានស្គាល់ថាប្រភពនៃបញ្ហានោះ ជាអ្វីដែលគាត់មិនអាចគ្រប់គ្រងបាន ។ បន្ទាប់គាត់គួរតែបានថ្វាយបញ្ហានោះទៅកាន់ព្រះជាម្ចាស់ ហើយទូលសូមការនាំផ្លូវពីព្រះជាម្ចាស់ក្នុងការស្វែងរកដំណោះស្រាយមួយ។ គាត់គួរតែបានចូលទៅមើលក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីមើលថាតើមានការណែនាំអ្វីខ្លះគាត់អាចនឹងរកឃើញនៅក្នុងព្រះបន្ទូលនោះ ដែលអាចយកមកប្រើប្រាស់នៅក្នុងស្ថានភាពរបស់គាត់។ ប្រហែលជាគាត់អាចទៅប្រឹក្សាយោបល់ជាមួយគ្រូគង្វាលរបស់គាត់នៅក្នុងពេលនោះ ហើយគ្រូគង្វាលរបស់គាត់អាចនឹងលើកយកគម្ពីរ១កូរិនថូស៦:១-៨ ឲ្យគាត់បានពិចារណាផងដែរ។ បន្ទាប់មកទៀត ប្រហែលជាចំរដានអាចនឹងទៅជួបដាវីឌជាមួយនឹងឥរិយាបថដូចជាព្រះគ្រិស្ត ហើយការឆ្លើយតបរបស់ដាវីឌអាចនឹងប្រសើរជាងនេះ។ បើទោះបីជាដាវីឌ នៅតែបដិសេធមិនព្រមឲ្យលុយមកគាត់វិញក៏ដោយ ចំរដាននៅតែអាចទទួលបានជ័យជម្នះលើបញ្ហារបស់គាត់តាមរយៈការថ្វាយវាទៅកាន់ព្រះជាម្ចាស់ ហើយទុកចិត្តថាព្រះជាម្ចាស់ធ្វើការសម្រាប់ផលប្រយោជន៍របស់គាត់នៅក្នុងស្ថានភាពមួយនេះ។

៣ ក) វិធីសាស្ត្រខ អាចនឹងយកមកប្រើប្រាស់បាន៖ ស្គាល់បញ្ហា ថ្វាយបញ្ហានោះទៅកាន់ព្រះជាម្ចាស់ និង រំពឹងថាព្រះជាម្ចាស់ធ្វើការដើម្បីប្រយោជន៍របស់អ្នក។

ខ) លោកចែម និង អ្នកស្រីអែសធើរ ឃើញថាបញ្ហារបស់ពួកគេគឺការមិនអាចមានកូន។ ពួកគេបានថ្វាយបញ្ហារបស់ពួកគេទៅកាន់ព្រះជាម្ចាស់ ហើយរំពឹងថាទ្រង់នឹងធ្វើការសម្រាប់ប្រយោជន៍របស់ពួកគេ។ ដំណោះស្រាយរបស់ព្រះជាម្ចាស់នៅក្នុងពេលនេះគឺមិនបានប្រទានឲ្យពួកគេមានកូននោះទេ ប៉ុន្តែទ្រង់បានធ្វើឲ្យពួកគេក្លាយជាឪពុកម្តាយខាងឯវិញ្ញាណសម្រាប់ក្មេងជាច្រើនវិញ នោះគឺតម្លៃអស់កល្បជានិច្ចដែលប្រសើរជាងអ្វីទាំងអស់។ លទ្ធផលចុងក្រោយ ទោះបីជាពួកគេមិនមានកូនបង្កើតផ្ទាល់ខ្លួនក៏ដោយ ដួងចិត្តរបស់ពួកគេនៅតែពោរពេញដោយការសរសើរតម្កើង សម្រាប់កូនៗជាច្រើនដែលព្រះជាម្ចាស់បានអនុញ្ញាតឲ្យពួកគេនាំចូលទៅក្នុងព្រះរាជ្យរបស់ទ្រង់។

៤ ចម្លើយរបស់អ្នក

មេរៀនទី៨

១ គ) ការចង់បានអ្វីដែលជារបស់អ្នកដទៃ។
២ ក) ការបម្រើគ្នាទៅវិញទៅមក។
៣ ឃ) ឫទ្ធានុភាពរបស់ព្រះជាម្ចាស់។
៤ ខ) មានអារម្មណ៍តូចទាបជាងគេ។
៥ ក) ស្ថិតស្ថេរគង់វង្ស។
៦ ឃ) គឺមិនច្រណែន។

៧ ខ) សរសើរតម្កើងព្រះគ្រិស្ត
៨ ឃ) ដាក់ព្រះរាជ្យរបស់ព្រះជាម្ចាស់ជាទីមួយ ហើយចែកទានជាមួយនឹងចិត្តសប្បុរស។
៩ គ) ការប្តេជ្ញាចិត្តរបស់អ្នកទាំងស្រុងទៅចំពោះព្រះរាជ្យរបស់ព្រះជាម្ចាស់។
១០ ក) ទទួលយកភាពអយុត្តិធម៌តាមរបៀបដូចជាព្រះគ្រិស្ត ហើយទុកចិត្តថាព្រះជាម្ចាស់នឹងប្រទានឲ្យ អ្នកមានជ័យជម្នះលើភាពអយុត្តិធម៌នោះ។
១១ ខ
១២ ខ
១៣ ត
១៤ ខ
១៥ ខ
១៦ ត
១៧ ត
១៨ ត
១៩ ត
២០ ខ

មេរៀនទី៩

១ គ) ព្រះគ្រិស្តទៅចំពោះក្រុមជំនុំ។
២ ខ) ការបង្រៀន ការប្រៀនប្រដៅ និង ក្តីស្រឡាញ់
៣ ក) អំពើសហាយស្មន់
៤ ឃ) កូនៗ
៥ គ) បន្តរស់នៅជីវិតអាពាហ៍ពិពាហ៍ថ្មី ក្នុងពេលដែលបានធ្វើការផ្លាស់ប្រែនោះ។
៦ ខ) ក្តីស្រឡាញ់ និង ការគោរព
៧ គ) ថ្វាយតង្វាយមួយភាគដប់របស់គេជាមុនសិន។

៨ ខ

៩ ត

១០ ត

១១ ខ

១២ ខ

១៣ ត

១៤ ត

១៥ ត

មេរៀនទី៦

១ គ) មនុស្សដែលបានលែងលះគ្នា

២ ឃ) អ្នកនៅលីវមានឱកាសថ្វាយពេលវេលារបស់គេបានច្រើនទៅចំពោះកិច្ចការរបស់ព្រះជាម្ចាស់ ដោយគ្មានការរំខាននោះទេ។

៣ ក) អស់អ្នកដែលជ្រើសយកការចំណាយពេលវេលារបស់គេសម្រាប់ព្រះរាជ្យនៃស្ថានបរមសុខ ជាជាងការរៀបការ គឺជាព្រះពរដ៏ពិតមួយសម្រាប់ក្រុមជំនុំ។

៤ ខ) បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

៥ ខ) គោរពកោតខ្លាចព្រះជាម្ចាស់

៦ គ) ការអភិវឌ្ឍបុគ្គលិកលក្ខណៈគ្រិស្តបរិស័ទដែលរឹងមាំ និង ពេញវ័យ។

៧ ខ) រៀបការជាមួយអ្នកមិនជឿ

៨ ក) អ្នកដែលលែងលះគ្នា

៩ ឃ) ថ្វាយអ្វីៗទាំងអស់ទៅចំពោះបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់អ្នក។

១០ គ) មូលដ្ឋានគ្រឹះសម្រាប់ទំនាក់ទំនងរបស់គ្រិស្តបរិស័ទគឺមិនមែនហាន:ក្នុងសង្គមរបស់បុគ្គលម្នាក់នោះទេ តែវាជារឿងដែលថាគាត់ជាមនុស្សរបស់ព្រះគ្រិស្តនោះវិញ។

១១ (តាមលំដាប់លំដោយណាក៏បាន) មើលមកខ្លួនអ្នក ហើយទទួលស្គាល់ថាព្រះអម្ចាស់ជាអំណាចរបស់អ្នក ហើយជាកម្លាំងរបស់អ្នក។ ស្គាល់ពីតំណែងរបស់អ្នកនៅក្នុងព្រះគ្រិស្ត។ ចូលរួមនៅក្នុងការជួយអ្នកដទៃ។ ចំណាយពេលរបស់អ្នកឲ្យកាន់តែច្រើន ទៅលើការអានព្រះគម្ពីរ ការសញ្ជឹងគិត និង ការអធិស្ឋាន។ យកគោលការណ៍របស់គ្រិស្តបរិស័ទមកប្រើប្រាស់នៅក្នុងការដោះស្រាយបញ្ហា។

មេរៀនទី៧

១ ខ) លើកព្រះកិត្តិនាមព្រះជាម្ចាស់ជាមួយរូបកាយរបស់អ្នក។

២ ខ) មិនទាន់រៀបការ និង គ្មានទំនាក់ទំនងផ្លូវភេទ។

៣ គ) ទាំងការបង្កើតកូនចៅ និង ការរួបរួមគ្នា។

៤ ឃ) ទំនាក់ទំនងនៅក្នុងចំណងអាពាហ៍ពិពាហ៍។

៥ គ) ជួយគេឲ្យដឹងថាព្រះជាម្ចាស់ទ្រង់អត់ទោស ឲ្យមនុស្សបាបដែលបានលន់តួ។

៦ ខ) ជីវិតបរិសុទ្ធ

៧ ក) តើវានឹងលើកព្រះកិត្តិនាមរបស់ព្រះជាម្ចាស់ដែរឬទេ?

៨ ឃ) អំណោយពីព្រះជាម្ចាស់មក។

៩ ក) ការពឹងពាក់គ្នាទៅវិញទៅមក។

១០ ក) វាទាស់ជាមួយនឹងគោលការណ៍របស់ព្រះជាម្ចាស់ទាក់ទងជាមួយនឹងជីវិតផ្លូវភេទ ដែលមានតែបុរសម្នាក់ និងស្ត្រីម្នាក់តែប៉ុណ្ណោះ។

ខ) ព្រះគម្ពីរបានហៅថា អំពើអាក្រក់។

គ) វានឹងទទួលការវិនិច្ឆ័យទោសរបស់ព្រះ។

១១ ចម្លើយរបស់អ្នកផ្ទាល់។ ខាងក្រោមនេះជាចម្លើយខ្លះៗ៖

ក) គម្ពីរ១កូរិនថូស ៦:១២-១៣, ១៩-២០ និង ជំពូក៧

ខ) គម្ពីរ១កូរិនថូស ៧:៣-៤ គម្ពីរអេភេសូ ៥:២២-២៣

គ) គម្ពីរនិក្ខមនំ ២០:១៣ គម្ពីរ១កូរិនថូសជំពូក៦ និង ជំពូក៧ គម្ពីរយ៉ូហាន ៨:១១

ឃ) គម្ពីររ៉ូម ១:១៨-៣២ គម្ពីរលេវីនិយ ១៨:២២-២៣ គម្ពីរ២ពេត្រុស២:៦-១០

ង) គម្ពីរម៉ាថាយ ៥:៦ គម្ពីរ១កូរិនថូស ៦:១១ គម្ពីរលូកា ៧:៥០

មេរៀនទី៨

១ ត

២ ខ

៣ ខ

៤ ត

៥ ត

៦ ត

៧ ត

៨ ខ

៩ ត

១០ ត

១១ ខ

១២ ខ

១៣ ត

១៤ ត

១៥ ត

១៦ វិញ្ញាណ និង រូបកាយ

១៧ អំពើបាប

១៨ ជួយ *ឬ* ឈោងចាប់

១៩ ដោះស្រាយ

២០ ការអត់ទោស

២១ អំណរ

២២ (ចម្លើយមួយក្នុងចំណោមចម្លើយទាំងនេះ) បង្ហាញពីការខ្វល់ខ្វាយ ផ្តល់ក្តីស្រឡាញ់ឲ្យ ស្តាប់គេ ញែកពេលទំនេរសម្រាប់គេ ចែករំលែកទុក្ខព្រួយ ផ្តល់ជំនួយ ផ្តល់ការគាំទ្រ ផ្តល់ការកំសាន្តចិត្ត ក្តីសង្ឃឹម និង ការលើកទឹកចិត្ត។

មេរៀនទី៩

១ គ) ព្រមានយើងអំពីបញ្ហាដែលទាមទារឲ្យមានការយកចិត្តទុកដាក់។

២ ក) បដិសេធទ្រង់នៅពេលដែលទ្រង់មានព្រះបន្ទូលមកកាន់យើងតាមរបៀបផ្សេង។

៣ ឃ) ស្រឡាញ់យើងខ្លាំងណាស់។

៤ គ) សិរីរុងរឿងនាពេលអនាគត

៥ ខ) រក្សាជំនឿរបស់លោកលើព្រះជាម្ចាស់ ហើយបន្តថ្វាយបង្គំទ្រង់។

៦ ក) សង្ឃឹម

៧ ឃ) ការតប្តៀ

៨ ខ) ការបាក់ទឹកចិត្ត

៩ គ) ក្នុងអំឡុងពេលដែលអ្នកនៅមានសុខភាពល្អ។

១០ ឃ) ធ្វើពុតដូចជាពួកគេនឹងអាចជាសះស្បើយពីភាពឈឺចាប់របស់ពួកគេ និងមិនស្លាប់នោះទេ។ (នេះគឺជាការមិនស្មោះត្រង់ ប៉ុន្តែអ្នក*អាច*អធិស្ឋានទូលសូមការប្រោសឲ្យជាសម្រាប់ពួកគេ និងលើកទឹកចិត្តពួកគេឲ្យទុកចិត្តថាព្រះជាម្ចាស់នឹងមើលថែពួកគេ ។ សូមមើលចម្លើយ ង)។

១១ ខ) ទ្រង់អធិស្ឋានសុំការរំដោះឲ្យផុតទុក្ខ តែការប្រទានឲ្យមានការរំដោះនោះ គឺស្រេចតែបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ទ្រង់តែប៉ុណ្ណោះ។

១២ ក) ការដកថយ

មេរៀនទី១០

១ ត
២ ត
៣ ខ
៤ ត
៥ ខ
៦ ត
៧ ត
៨ ខ
៩ ត
១០ ខ
១១ ត
១២ ត

ការប្រឡងតាមជំពូក

ការណែនាំ

នៅពេលដែលអ្នកបានបញ្ចប់ការសិក្សារបស់អ្នកទៅតាមជំពូកនីមួយៗហើយ ចូរឆ្លើយសំណួរប្រឡងតាមជំពូក ដោយប្រើប្រាស់ក្រដាសចម្លើយទៅតាមលំហាត់ប្រឡងជំពូកនីមួយៗ ដើម្បីកត់ត្រាចម្លើយរបស់អ្នក។

សូមអានសំណួរនីមួយៗដោយយកចិត្តទុកដាក់។ មានចម្លើយតែមួយគត់ដែលល្អជាងគេសម្រាប់សំណួរនីមួយៗ។ ចូរជាត់ពណ៌ខ្មៅទៅលើប្រអប្បោះចម្លើយដែលអ្នកជ្រើសរើស។ *ត្រូវតែប្រាកដថាលេខនៅក្នុងក្រដាសចម្លើយដូចទៅនឹងលេខនៅក្នុងសំណួរដែលអ្នកឆ្លើយ។*

ឧទាហរណ៍

១ ការកើតជាថ្មីគឺមានន័យថា

ក) មានអាយុតិច

ខ) ទទួលយកព្រះយេស៊ូជាព្រះសង្គ្រោះ

គ) ចាំផ្តើមឆ្នាំថ្មី

ឃ) ស្វែងរកក្រុមជំនុំផ្សេងមួយទៀត

ចម្លើយដែលត្រឹមត្រូវគឺ **ខ) ទទួលយកព្រះយេស៊ូជាព្រះសង្គ្រោះ** ដូច្នេះអ្នកត្រូវជាត់ពណ៌ខ្មៅនៅក្នុងចន្លោះអក្សរ ខ យ៉ាងដូច្នេះ៖



ការប្រគល់ ចម្លើយការប្រឡង

នៅពេលដែលអ្នកបានបញ្ចប់មុខវិជ្ជានេះ និង បានឆ្លើយសំណួរការប្រឡងទាំងអស់ហើយ សូមផ្ញើក្រដាសចម្លើយរបស់អ្នកទៅឲ្យគ្រូ ឬ ការិយាល័យដែលនៅក្នុងតំបន់របស់អ្នកដើម្បីធ្វើការកែសម្រួល។

ក្រដាសចម្លើយការប្រឡងតាមដំណាក

CS6161 KHM ការដោះស្រាយបញ្ហាជីវិត

ព័ត៌មានរបស់សិស្ស

ឈ្មោះ.....

លេខសំគាល់របស់សិស្ស.....

(សូមរក្សាចន្លោះនេះឲ្យនៅទទេ បើអ្នកមិនស្គាល់លេខរបស់អ្នក)

អាសយដ្ឋាន.....

.....

.....

ប្រទេស.....

អ៊ីម៉ែល.....

ចូរដាក់ពណ៌ខ្មៅដោយប្រុងប្រយ័ត្ននៅក្នុងចន្លោះចម្លើយត្រឹមត្រូវ សម្រាប់សំណួរដែលមានលេខដូចគ្នា។

ដំណាកទីមួយ

១	ក	ខ	គ	ឃ	១១	ក	ខ	គ	ឃ
២	ក	ខ	គ	ឃ	១២	ក	ខ	គ	ឃ
៣	ក	ខ	គ	ឃ	១៣	ក	ខ	គ	ឃ
៤	ក	ខ	គ	ឃ	១៤	ក	ខ	គ	ឃ
៥	ក	ខ	គ	ឃ	១៥	ក	ខ	គ	ឃ
៦	ក	ខ	គ	ឃ	១៦	ក	ខ	គ	ឃ
៧	ក	ខ	គ	ឃ	១៧	ក	ខ	គ	ឃ
៨	ក	ខ	គ	ឃ	១៨	ក	ខ	គ	ឃ
៩	ក	ខ	គ	ឃ	១៩	ក	ខ	គ	ឃ
១០	ក	ខ	គ	ឃ	២០	ក	ខ	គ	ឃ

សម្រាប់ការិយាល័យរបស់សាកលវិទ្យាល័យ តែប៉ុណ្ណោះ

ថ្ងៃទី .....ពិន្ទុ.....

ជំពូកទី៣

១	ក	ខ	គ	ឃ	១១	ក	ខ	គ	ឃ
២	ក	ខ	គ	ឃ	១២	ក	ខ	គ	ឃ
៣	ក	ខ	គ	ឃ	១៣	ក	ខ	គ	ឃ
៤	ក	ខ	គ	ឃ	១៤	ក	ខ	គ	ឃ
៥	ក	ខ	គ	ឃ	១៥	ក	ខ	គ	ឃ
៦	ក	ខ	គ	ឃ	១៦	ក	ខ	គ	ឃ
៧	ក	ខ	គ	ឃ	១៧	ក	ខ	គ	ឃ
៨	ក	ខ	គ	ឃ	១៨	ក	ខ	គ	ឃ
៩	ក	ខ	គ	ឃ	១៩	ក	ខ	គ	ឃ
១០	ក	ខ	គ	ឃ	២០	ក	ខ	គ	ឃ

សម្រាប់ការិយាល័យរបស់សាកលវិទ្យាល័យ តែប៉ុណ្ណោះ

ថ្ងៃទី .....ពិន្ទុ.....

ជំពូកទី៤

១	ក	ខ	គ	ឃ	១១	ក	ខ	គ	ឃ
២	ក	ខ	គ	ឃ	១២	ក	ខ	គ	ឃ
៣	ក	ខ	គ	ឃ	១៣	ក	ខ	គ	ឃ
៤	ក	ខ	គ	ឃ	១៤	ក	ខ	គ	ឃ
៥	ក	ខ	គ	ឃ	១៥	ក	ខ	គ	ឃ
៦	ក	ខ	គ	ឃ	១៦	ក	ខ	គ	ឃ
៧	ក	ខ	គ	ឃ	១៧	ក	ខ	គ	ឃ
៨	ក	ខ	គ	ឃ	១៨	ក	ខ	គ	ឃ
៩	ក	ខ	គ	ឃ	១៩	ក	ខ	គ	ឃ
១០	ក	ខ	គ	ឃ	២០	ក	ខ	គ	ឃ

សម្រាប់ការិយាល័យរបស់សាកលវិទ្យាល័យ តែប៉ុណ្ណោះ

ថ្ងៃទី .....ពិន្ទុ.....

ការប្រឡងជំពូកទីមួយ

១ យោងតាមគម្ពីរលោកុប្បត្តិ ៣:១៦-១៩ ទុក្ខលំបាករបស់មនុស្ស និង គ្រោះធម្មជាតិកើតមានឡើងដោយសារ

ក) ព្រះជាម្ចាស់ព្រះពិរោធជាមួយនឹងសាតាំង។

ខ) ព្រះជាម្ចាស់ព្រះពិរោធជាមួយនឹងលោកអដាំ និង នាងអេវ៉ា

គ) បណ្តាសារដែលជាលទ្ធផលនៃអំពើបាប។

ឃ) កំហឹង និង គំនុំរបស់សាតាំងទៅចំពោះព្រះជាម្ចាស់។

២ ចាប់តាំងពីពេលដែលលោកអដាំ និង នាងអេវ៉ាមិនស្តាប់បង្គាប់ព្រះជាម្ចាស់មក មនុស្សគ្រប់គ្នាបានកើតមកជាមួយនឹង

ក) សមត្ថភាពដើម្បីច្រានចោលអំពើបាប និងរស់នៅក្នុងជីវិតមួយដ៏ល្អឥតខ្ចោះ។

ខ) ចិត្តបរិសុទ្ធដែលធ្វើឲ្យយើងមានលក្ខណៈមួយដែលគ្មានបាបសោះឡើយ។

គ) គ្មានអំណាចអ្វីដើម្បីនឹងប្រឆាំងជាមួយនឹងការល្បួងឲ្យប្រព្រឹត្តអំពើបាបបានសោះ។

ឃ) និស្ស័យបាបដែលជំរុញឲ្យជ្រើសរើសប្រព្រឹត្តអំពើបាប។

៣ យើងមានទំនួលខុសត្រូវចំពោះអំពើបាបរបស់យើងដោយខ្លួនឯង ព្រោះយើង

ក) គ្មានអំណាចក្នុងការស្តាប់បង្គាប់ព្រះជាម្ចាស់ ហើយ នឹងតែងតែជ្រើសយកអំពើបាប។

ខ) គួរឲ្យទុកចិត្តបាន ក្នុងការសម្រេចចិត្តថាធ្វើអំពើល្អ ឬ ធ្វើអំពើអាក្រក់។

គ) អាចខិតខំធ្វើការយ៉ាងលំបាកជាមួយវាបាន និង រស់នៅជីវិតដែលគ្មានបាបសោះ។

ឃ) មិនស្មោះត្រង់ ក្នុងការសារភាពនៅពេលដែលយើងបានប្រព្រឹត្តអំពើបាប។

៤ យោងទៅតាមគម្ពីរ ១ពេត្រុស ១:៦-៧ ហេតុអ្វីបានជាព្រះជាម្ចាស់អនុញ្ញាតឲ្យមានបញ្ហា និងទុក្ខព្រួយកើតមាននៅក្នុងជីវិតរបស់យើង?

ក) ដើម្បីដាក់ទោសយើងសម្រាប់អាកប្បកិរិយាមានបាប ឬ សម្រាប់ជំនឿខ្សោយ។

ខ) ដើម្បីធ្វើឲ្យយើងកោតខ្លាចទ្រង់ និង ឫទ្ធានុភាពរបស់ទ្រង់ផង។

គ) ដើម្បីបន្សុទ្ធ និង ពង្រឹងជំនឿរបស់យើងឲ្យរឹងមាំ។

ឃ) ដើម្បីបន្ថែមក្តីស្រឡាញ់របស់ទ្រង់សម្រាប់យើង។

៥ គម្ពីររ៉ូម៨:១៧ បានចែងថាហេតុផលមួយដែលព្រះជាម្ចាស់អនុញ្ញាតឲ្យយើងរងទុក្ខ គឺដើម្បីបើកបង្ហាញ

ក) ភាពទន់ខ្សោយរបស់យើង។

ខ) សិរីរុងរឿងរបស់ព្រះគ្រិស្តនៅក្នុងយើង។

គ) សម្រាប់អស់អ្នកដែលស័ក្តិសមទទួលការសង្គ្រោះ។

ឃ) ឫទ្ធានុភាពរបស់ទ្រង់ដើម្បីដាក់ទោសយើងសម្រាប់អំពើបាបរបស់យើង។

៦ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ក្នុងការល្បងលយើងគឺដើម្បីធ្វើឲ្យយើង
   ក) បរាជ័យ។
   ខ) ព្រួយបារម្ភ។
   គ) រងទុក្ខ។
   ឃ) ខិតខំព្យាយាម។

៧ បញ្ហាសំខាន់ជាងគេបំផុតដែលខ្ញុំនឹងត្រូវប្រឈមមុខជាមួយនៅក្នុងជីវិតរបស់ខ្ញុំគឺ
   ក) ភាពអាត្មានិយមរបស់ខ្ញុំ។
   ខ) បញ្ហាអំពើបាបរបស់ខ្ញុំ។
   គ) ចំណង់ផ្លូវភេទរបស់ខ្ញុំ។
   ឃ) ការខ្វះការទប់ចិត្តខ្លួនឯង។

៨ យោងតាមសេចក្តីបង្រៀនរបស់ព្រះយេស៊ូនៅលើភ្នំ ក្រឹត្យវិន័យទាំងដប់ប្រការ
   ក) លែងត្រូវការការគោរពប្រណិបត្តិតាមទៀតហើយ។
   ខ) មិនអាចមានអ្នកគោរពតាមបានឡើយតាំងពីដើមរៀងមក។
   គ) អាចនឹងគោរពតាមបាន តាមរយៈការទុកចិត្តលើព្រះគ្រិស្ត។
   ឃ) គឺជាមគ្គទេសក៏តាំងពីដើមរៀងមក មិនមែនជាក្រឹត្យវិន័យនោះទេ។

៩ ក្រឹត្យវិន័យទាំងដប់ប្រការ ទាក់ទងទៅនឹងអ្វីដែលយើងធ្វើ ហើយសុភមង្គលពិតរបស់ព្រះគ្រិស្ត ទាក់ទងទៅនឹងអ្វី
   ក) ដែលគួរតែជាយើង។
   ខ) ដែលយើងមាន។
   គ) ដែលយើងចង់បាន។
   ឃ) ដែលយើងជឿ។

១០ ចូរអានគម្ពីរម៉ាកុស ១២:២៨-៣១ ។ តើអ្វី ជាគ្រឹះមូលដ្ឋាននៃក្រឹត្យវិន័យដ៏អស្ចារ្យរបស់ព្រះជាម្ចាស់សម្រាប់យើង?
   ក) ក្តីស្រឡាញ់
   ខ) ជំនឿ
   គ) បំណងចិត្ត
   ឃ) ព្រះពរ

១១ ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់យើង តាមរយៈបទគម្ពីរ ហើយយើងទូលទៅកាន់ទ្រង់វិញ
   ក) តាមរយៈការយល់សប្តិ និង និមិត្ត។
   ខ) តាមរយៈការអធិស្ឋាន
   គ) តាមរយៈភាពស្ងៀមស្ងាត់
   ឃ) យ៉ាងឮៗ។

១២ សម្រាប់បញ្ហាសាមញ្ញៗភាគច្រើន មធ្យោបាយដើម្បីដោះស្រាយបញ្ហាដែលយើងត្រូវការគឺ
- ក) ការអធិស្ឋាន និង ការតបអាហារយ៉ាងម៉ត់ចត់
- ខ) សុភនិច្ឆ័យ និង ហេតុផល។
- គ) ព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធទាំងអស់។
- ឃ) ព្រះបន្ទូលដែលប្រកបដោយប្រាជ្ញារបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

១៣ ដើម្បីគ្រប់គ្រងអាកប្បកិរិយារបស់អ្នក ដំបូងបំផុតអ្នកត្រូវគ្រប់គ្រងគំនិតរបស់អ្នក និង
- ក) គំនិតរំពឹងរបស់អ្នក។
- ខ) អារម្មណ៍របស់អ្នក
- គ) សំដីរបស់អ្នក។
- ឃ) ចិត្តរបស់អ្នក។

១៤ ការដោះស្រាយបញ្ហាតាមរបៀបដូចជាព្រះគ្រិស្ត ទាមទារឲ្យយើង
- ក) ស្ម័គ្រចិត្តបដិសេធថាគ្មានបញ្ហានោះទេ។
- ខ) ត្រៀមខាងឯវិញ្ញាណ គ្រប់ពេលវេលា។
- គ) ឯករាជ្យ និង ចរចេសរឹងរូស
- ឃ) ត្រូវបានធ្វើឲ្យល្អឥតខ្ចោះដោយព្រះវិញ្ញាណដ៏វិសុទ្ធ។

១៥ ចូរអានគម្ពីររ៉ូម ១២:១៩។ នៅពេលដែលយើងត្រូវគេបំពាន ជំនួសឲ្យការខឹង យើងគួរតែ
- ក) ថ្វាយបញ្ហានោះទៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់ ហើយទុកឲ្យទ្រង់ឆ្លើយតបជំនួសយើងវិញ។
- ខ) អធិស្ឋានសុំឲ្យមានការសងសឹក លើមនុស្សដែលបានធ្វើខុសចំពោះយើង។
- គ) រៀបចំផែនការឲ្យបានម៉ត់ចត់ដើម្បី ធ្វើការសងសឹកដ៏យុត្តិធម៌មួយ។
- ឃ) អួតប្រាប់គេអំពីផែនការសងសឹករបស់យើង។

១៦ ការរត់គេចពីបញ្ហាគឺ
- ក) តែងតែជាអំពើកំសាក និង មិនត្រឹមត្រូវនោះទេ។
- ខ) ហៅថាការដកថយ ឬ ការដកខ្លួនចេញ។
- គ) តែងតែជាចម្លើយដែលបានមកពីក្នុងព្រះគម្ពីរ។
- ឃ) ហៅថាការបដិសេធ ឬ ការប្រកែក។

១៧ ការធ្វើអ្វីមួយដើម្បីធ្វើបាបអ្នកដែលបានធ្វើបាបអ្នកគឺហៅថា
- ក) ការសងសឹក
- ខ) ការដកខ្លួនចេញ
- គ) ការចោទប្រកាន់
- ឃ) គ្មានមនសិការ

១៨ ទាក់ទងនឹងការដោះស្រាយបញ្ហារបស់គ្រិស្តបរិស័ទ អំណាចឆន្ទៈរបស់មនុស្សគឺ

ក) ជាការដោះស្រាយដែលមិនត្រឹមត្រូវ

ខ) ពេលខ្លះមានប្រយោជន៍ នៅពេលមានការអធិស្ឋានរួមជាមួយដែរ។

គ) មធ្យោបាយដ៏ល្អបំផុតសម្រាប់គ្រិស្តបរិស័ទដោះស្រាយបញ្ហា។

ឃ) ជាមធ្យោបាយតែមួយគត់ដែលចាំបាច់ក្នុងការដោះស្រាយបញ្ហាភាគច្រើន។

១៩ ជំហានដំបូងនៅក្នុងការដោះស្រាយបញ្ហាជាលក្ខណៈប្រព័ន្ធគឺត្រូវ

ក) ស្គាល់បញ្ហាឲ្យបានច្បាស់បំផុតតាមតែអាចធ្វើទៅបាន។

ខ) ថ្វាយបញ្ហាទៅកាន់ព្រះជាម្ចាស់។

គ) ពិចារណាដំណោះស្រាយទាំងអស់ដែលអាចមាន។

ឃ) លះបង់ចោលការស្វែងរកដំណោះស្រាយ។

២០ ចូរអានគម្ពីរ១ពេត្រុស ៥:៧ ។ តើជំហានទីពីរ នៅក្នុងការដោះស្រាយបញ្ហាជាលក្ខណៈប្រព័ន្ធគឺអ្វី?

ក) គិតប្រកបដោយភាពច្នៃប្រឌិត។

ខ) គិតពីដំណោះស្រាយដែលអាចទៅរួច។

គ) ថ្វាយបញ្ហាទៅកាន់ព្រះអម្ចាស់។

ឃ) ទទួលស្គាល់ថាគ្មានដំណោះស្រាយសម្រាប់បញ្ហានោះទេ។

ការប្រឡងជំពូកទីពីរ

១ បញ្ហាដ៏ធំមួយនៅក្នុងទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃគឺភាពលោភលន់ ឬអាចហៅថា
   ក) ការផ្តល់ប្រាក់
   ខ) ទ្រឹស្តីសេដ្ឋកិច្ច
   គ) សេចក្តីលោភ
   ឃ) ការសន្សំសំចៃ

២ យើងអាចបកស្រាយភាពលោភលន់បានល្អបំផុត ថាជា
   ក) ការចង់បានអ្វីដែលអ្នកដទៃមាន។
   ខ) ការប្រៀបធៀបខ្លួនអ្នកទៅជាមួយនឹងអ្នកដទៃ។
   គ) ការព្យាយាមដើម្បីឲ្យអស់ពីសមត្ថភាពរបស់អ្នក។
   ឃ) អំពើធឹតក្បត់នៅក្នុងអាពាហ៍ពិពាហ៍

៣ យោងទៅតាមគម្ពីរលូកា ២២:២៥-២៦ បញ្ហាដែលកើតមកពីការស្វែងរកឋានៈអាចដោះស្រាយបានដោយ
   ក) តរិយាបថនៃក្តីស្រឡាញ់ និង ការបម្រើអ្នកដទៃ។
   ខ) ការបូជាខ្លួនឯង និង ការរងទុក្ខ។
   គ) ឲ្យអ្វីៗទាំងអស់ដែលយើងមានទៅដល់អ្នកក្រីក្រ។
   ឃ) ធ្វើជាឥសីកាន់សីល។

៤ ការយកឈ្នះលើអារម្មណ៍ដែលធ្វើឲ្យយើង និង អ្នកដទៃឈឺចាប់ នៅក្នុងទំនាក់ទំនង គឺជាបញ្ហា នៃ
   ក) លែងខ្វល់ពីអារម្មណ៍របស់អ្នកដទៃ។
   ខ) ភាពពេញវ័យរបស់គ្រិស្តបរិស័ទ ដែលកើតមាននៅក្នុងពេលណាមួយ។
   គ) អនុញ្ញាតឲ្យព្រះវិញ្ញាណដ៏វិសុទ្ធរំដោះយើងឲ្យផុតពីអំពើបាប។
   ឃ) រៀនច្រានចោលអារម្មណ៍ និង ភាពទន់ខ្សោយ។

៥ តួនាទីនៃអំណាចឆន្ទៈរបស់មនុស្សនៅក្នុងភាពពេញវ័យរបស់គ្រិស្តបរិស័ទគឺ
   ក) ធ្វើឲ្យយើងអសមត្ថភាពក្នុងការប្រព្រឹត្តអំពើបាប។
   ខ) ធ្វើការសម្រេចចិត្តស្តាប់បង្គាប់ព្រះជាម្ចាស់។
   គ) ធ្វើឲ្យគំនិតរបស់យើងមានអំណាច
   ឃ) ធ្វើឲ្យយើងវេទនា

៦ ទោះបីមាន ឬក្រ យើងត្រូវចាំថា យើងគឺ
   ក) ជាអ្នកគ្រប់គ្រងប្រាក់ដែលព្រះជាម្ចាស់ប្រទានមកឲ្យយើង។
   ខ) ត្រូវបានចាត់តាំងឲ្យទទួលបានទ្រព្យសម្បត្តិលើលោកីយ៍។
   គ) ត្រូវលះបង់ទ្រព្យសម្បត្តិទាំងអស់ដើម្បីព្រះគ្រិស្ត។
   ឃ) ត្រូវថ្វាយ១០ភាគរយប៉ុណ្ណោះទៅព្រះជាម្ចាស់។

៧ ចូរអានគម្ពីររ៉ូម ១២:១៧-២១។ តើយើងត្រូវឆ្លើយតបយ៉ាងដូចម្តេចនៅពេលដែលយើងទទួលរងភាពអយុត្តិធម៌?

ក) ជាមួយក្តីស្រឡាញ់

ខ) ជាមួយភាពមួរម៉ៅ

គ) ជាមួយភាពល្វីងជូរចត់

ឃ) ជាមួយការគំនុំសងសឹក

៨ បញ្ហានៅក្នុងចំណងអាពាហ៍ពិពាហ៍ និង ក្នុងគ្រួសារជាច្រើនអាចនឹងមិនកើតមានឡើងទេ ប្រសិនបើគ្រិស្តបរិស័ទ

ក) មិនរៀបការជាមួយសមាជិកនៅក្នុងក្រុមជំនុំផ្សេង។

ខ) រៀបការ ជាមួយអ្នកមិនជឿ ហើយផ្លាស់ប្រែពួកគេ។

គ) គ្រប់គ្នាជ្រើសរើសនៅលីវ។

ឃ) មិនរៀបការជាមួយនឹងអ្នកមិនជឿ។

៩ ប្រសិនបើអ្នកជឿ និង អ្នកមិនជឿរៀបការជាមួយគ្នា អ្នកជឿមានទំនួលខុសត្រូវក្នុងការ

ក) ស្វែងរកការលែងលះភ្លាមៗ។

ខ) បង្ខិតបង្ខំគ្រួសារឲ្យទៅព្រះវិហារ។

គ) បង្ខំឲ្យដៃគូដែលជាអ្នកមិនជឿ ទទួលយកព្រះគ្រិស្ត។

ឃ) ធ្វើអ្វីៗដែលគាត់អាចធ្វើបានដើម្បីឲ្យអាពាហ៍ពិពាហ៍អាចដំណើរការទៅមុខបាន។

១០ គម្ពីរ១កូរិនថូស ៧:៥ បង្រៀនថា ការរួមភេទ និង ការតមនៅជាមួយគ្នា ក្នុងជីវិតប្តីប្រពន្ធត្រូវសម្រេចដោយ

ក) ចំណង់របស់ប្តី

ខ) ការព្រមព្រៀងគ្នាទៅវិញទៅមក

គ) ចំណង់របស់ប្រពន្ធ

ឃ) ការបង្កើតកូនចៅ

១១ ចូរអានគម្ពីរម៉ាថាយ ១៩:៩ ។ តើព្រះយេស៊ូមានព្រះបន្ទូលថា ការលែងលះគ្នាអាចធ្វើទៅបាននៅពេលណា?

ក) គ្រិស្តបរិស័ទមិនត្រូវបានអនុញ្ញាតឲ្យធ្វើការលែងលះគ្នាឡើយ។

ខ) គ្រិស្តបរិស័ទអាចលែងលះគ្នាបានតែនៅពេលមានវិបត្តិហិរញ្ញវត្ថុតែប៉ុណ្ណោះ។

គ) គ្រិស្តបរិស័ទត្រូវបានអនុញ្ញាតឲ្យលែងលះគ្នាបាន តែនៅពេលមានភាពសហាយស្មន់តែប៉ុណ្ណោះ។

ឃ) គ្រិស្តបរិស័ទ ត្រូវបានអនុញ្ញាតឲ្យលែងលះគ្នា ប្រសិនបើពួកគេ " ឈប់ស្រឡាញ់គ្នាហើយ"

១២ ការប្រច័ណ្ឌគឺតែងតែបណ្តាលមកពីខ្វះ
   ក) ការគោរព និង ការទុកចិត្តគ្នា។
   ខ) ការណែនាំរឿងផ្លូវភេទ។
   គ) ធនធានហិរញ្ញវត្ថុ។
   ឃ) ឱកាស។

១៣ ការបណ្តុះបណ្តាលកូនត្រឹមត្រូវគឺរួមមាន
   ក) ការបង្រៀន ការប្រៀនប្រដៅ និង ការស្រឡាញ់។
   ខ) ការដាក់ទោស និង ការសរសើរ។
   គ) ការលើកទឹកចិត្តជាលុយ។
   ឃ) ភាពបណ្តែតបណ្តោយ។

១៤ ទំនួលខុសត្រូវ ទាំងបីរបស់ប្តីដែលនៅក្នុងព្រះគម្ពីរនៅក្នុងគ្រួសារ គឺ ផ្តល់ការដឹកនាំ ការផ្គត់ផ្គង់ និង
   ក) ប្រៀនប្រដៅប្រពន្ធ និង កូនៗរបស់គាត់។
   ខ) ឲ្យកាដូថ្លៃៗទៅដល់គ្រួសាររបស់គាត់។
   គ) តាមដានសកម្មភាពប្រពន្ធរបស់គាត់យ៉ាងយកចិត្តទុកដាក់។
   ឃ) ស្រឡាញ់ប្រពន្ធរបស់គាត់ដូចជាព្រះគ្រិស្តស្រឡាញ់ក្រុមជំនុំដែរ។

១៥ អ្នកនៅលីវនៅក្នុងសង្គមរបស់យើង ចែកជាបីប្រភេទ៖ អ្នកដែលមិនធ្លាប់រៀបការ
   ក) អ្នកដែលលែងលះគ្នា និង អ្នកដែលជាពោះម៉ាយ ឬមេម៉ាយ
   ខ) អ្នកដែលមិនធ្លាប់រៀបការ និង អ្នកដែលមិនខ្វល់ខ្វាយ
   គ) អ្នកដែលលែងលះគ្នា និង អ្នកដែលចែកផ្លូវគ្នាស្របច្បាប់
   ឃ) អ្នកដែលមិនចង់រៀបការ និង អ្នកដែលរស់នៅជាមួយគ្នាទាំងនៅលីវ

១៦ លោកប៉ូលបានមានប្រសាសន៍នៅក្នុងគម្ពីរ១កូរិនថូសជំពូក៧ ថាគុណប្រយោជន៍មួយនៃភាពនៅលីវ គឺសេរីភាព
   ក) ដើម្បីរស់នៅក្នុងជីវិតក៏អាថ៌កំបាំងមួយ។
   ខ) ដើម្បីសកម្មខាងរឿងផ្លូវភេទ។
   គ) ផុតពីសម្ពាធរបស់គ្រួសារ។
   ឃ) ផុតពីទំនួលខុសត្រូវទាំងអស់។

១៧ ក្នុងចំណោមអំណោយទានពិសេសរបស់ព្រះជាម្ចាស់ទៅកាន់ក្រុមជំនុំ គឺមានអ្នកនៅលីវដែលសុខចិត្តលះបង់ការរៀបការ ដើម្បី
   ក) រស់នៅក្នុងភាពក្រីក្រ និង ការមួម៉ៅក្នុងចិត្ត។
   ខ) បង្រៀនថ្នាក់អ្នកលីវនៅថ្ងៃអាទិត្យ។
   គ) ថ្វាយជីវិតពួកគេសម្រាប់កិច្ចការរបស់ព្រះជាម្ចាស់។
   ឃ) ប្រមូលយកទ្រព្យ និង អំណាចផ្ទាល់ខ្លួន។

១៨ អ្នកដែលចង់រៀបការខ្លាំង ប៉ុន្តែមិនអាចរៀបការជាមួយគ្រិស្តបរិស័ទបានគួរតែ

ក) រៀបការជាមួយអ្នកមិនជឿ។

ខ) លះបង់ចោលជម្រើសរៀបការ។

គ) បន្តនៅលីវ ប៉ុន្តែមិនចាំបាច់មានភាពបរិសុទ្ធទេ។

ឃ) បន្តនៅមានភាពបរិសុទ្ធ(នៅលីវ) និង ទុកចិត្តលើព្រះជាម្ចាស់។

១៩ មធ្យោបាយមួយដើម្បីបំបាត់ភាពឯកា និង ការស្រណោះខ្លួន គឺត្រូវ

ក) ប្រាប់នរណាម្នាក់អំពីវា។

ខ) នៅក្បែរមនុស្សម្នា។

គ) ជួយអ្នកដទៃដែលមានតម្រូវការខ្លាំងជាងយើង។

ឃ) សម្រេចចិត្តថា នឹងនៅឯកាជារៀងរហូត។

២០ ក្រុមជំនុំជាច្រើនជួយអ្នកនៅលីវដោះស្រាយបញ្ហារបស់ពួកគេតាមរយៈ

ក) គ្រួសារដែល "ទទួលយក" អ្នកនៅលីវដើម្បីផ្តល់មិត្តភាពឲ្យគេ។

ខ) រៀបចំកម្មវិធី "ដេញថ្លៃ" ចាប់គូសម្រាប់អ្នកនៅលីវ។

គ) ឈ្មោះដែលគួរឲ្យចាប់អារម្មណ៍សម្រាប់អ្នកនៅលីវ ដូចជា "អ្នកមានគូ និង អ្នកនៅសល់"

ឃ) កាត់បន្ថយការចូលរួមនៅក្នុងក្រុមជំនុំរបស់ពួកគេ ឲ្យនៅក្នុងក្រុមសម្រាប់អ្នកនៅលីវសុទ្ធតែប៉ុណ្ណោះ។

ការប្រឡងជំពូកធីបី

១ នៅក្នុងរឿងជីវិតផ្លូវភេទ ជម្រើសដែលមាននៅក្នុងព្រះគម្ពីរតែមួយគត់ក្នុងការរៀបអាពាហ៍ពិពាហ៍ គឺ
   ក) ភាពបរិសុទ្ធ
   ខ) ការរួមមកតែមួយ
   គ) ការបង្កើតកូនចៅ
   ឃ) រួមភេទមុនរៀបការ

២ ការណែនាំសម្រាប់រឿងផ្លូវភេទនៅក្នុងចំណងអាពាហ៍ពិពាហ៍អាចសរុបមកជាពាក្យថា
   ក) ការបង្កើតកូនចៅ
   ខ) ការផ្លាស់ប្តូរ
   គ) ការអត់ទោស
   ឃ) ការពឹងពាក់គ្នាទៅវិញទៅមក

៣ ទំនាក់ទំនងផ្លូវភេទជាធម្មតា នៅក្នុងចំណងអាពាហ៍ពិពាហ៍គឺដើម្បី
   ក) ធ្វើជាការធានាសុវត្ថិភាពឲ្យចំណងអាពាហ៍ពិពាហ៍នោះ។
   ខ) បង្វែរយើងមិនឲ្យបម្រើព្រះជាម្ចាស់។
   គ) បង្កើតជម្លោះ
   ឃ) បង្ហាញពីភាពខ្វះខាតជំនឿ

៤ យោងទៅតាមគម្ពីររ៉ូម ១:២៤-២៨ ការរួមសង្វាសភេទដូចគ្នា គឺ
   ក) ជាអំពើបាប។
   ខ) ជាជម្រើសមួយនៅក្នុងការរស់នៅ។
   គ) ជារឿងធម្មតាបំផុតសម្រាប់អ្នកខ្លះ។
   ឃ) អ្វីម្យ៉ាងដែលគ្មាននរណាម្នាក់យល់នោះទេ។

៥ បញ្ហាខាងឯផ្លូវភេទ ដែលជាលទ្ធផលនៃអំពើបាបអាចដោះស្រាយបានតាមរយៈ
   ក) ការប្រឹក្សាយោបល់ និង ការព្យាបាលដោយឱសថ។
   ខ) បំភ្លេចវាចោល តែមិនអត់ទោសឲ្យនោះ។
   គ) ការលន់តួ និង ការអត់ទោស។
   ឃ) ឱសថ និង ការវះកាត់

៦ ភាពខុសគ្នាដ៏ចម្បងបំផុត រវាងការបាក់ទឹកចិត្ត និង ភាពក្រៀមក្រំធម្មតាគឺថា
   ក) ភាពក្រៀមក្រំ មិនមែនជាផ្នែកមួយនៃការបាក់ទឹកចិត្តនោះទេ។
   ខ) ការបាក់ទឹកចិត្តទាមទារការព្យាបាលដោយឱសថ
   គ) ភាពក្រៀមក្រំធម្មតា នឹងបាត់ទៅវិញឆាប់ៗ
   ឃ) ការបាក់ទឹកចិត្ត នឹងបាត់ទៅវិញឆាប់ៗ

៧ ជំងឺខាងរូបកាយ និង ការបាក់ទឹកចិត្តគឺ
   ក) តែងតែទាក់ទងគ្នា។
   ខ) មិនទាក់ទងគ្នានោះទេ។
   គ) ទាំងពីរបណ្តាលមកពីអំពើបាប។
   ឃ) បណ្តាលមកពីការខ្វះជំនឿ។

៨ ចូរអានគម្ពីរ១យ៉ូហាន៤:១៦-១៨ ។ តើថ្នាំបន្សាបរបស់ព្រះជាម្ចាស់សម្រាប់ភាពភ័យខ្លាចជាអ្វី?
   ក) អំណាចឆន្ទៈរបស់មនុស្ស
   ខ) សេចក្តីស្រឡាញ់របស់ទ្រង់។
   គ) សុទិដ្ឋិនិយម
   ឃ) ការសង្ស័យ

៩ ទោសកំហុស មិនថាមកពីអំពើបាប ឬ ការស្តាយក្រោយក៏ដោយ គឺសុទ្ធតែអាចយកចេញបាន នៅពេលដែលយើងទទួល
   ក) ការណែនាំ។
   ខ) ការដាក់ទោស។
   គ) ការអត់ទោស។
   ឃ) ការបាក់ទឹកចិត្ត។

១០ មធ្យោបាយដ៏ល្អបំផុតមួយដើម្បីជួយអ្នកដែលមានការបាក់ទឹកចិត្តគឺត្រូវ
   ក) មានវត្តមាននៅក្បែរ និង ផ្តល់ក្តីស្រឡាញ់។
   ខ) ប្រាប់ថាពួកគេត្រូវលន់តួ។
   គ) អធិស្ឋានដើម្បីឲ្យព្រះជាម្ចាស់អត់ទោសឲ្យពួកគេ។
   ឃ) ផ្តន្ទាទោសការខ្វះខាតជំនឿរបស់ពួកគេ។

១១ មូលហេតុមួយដែលការឈឺចាប់អាចជាព្រះពរ គឺថា
   ក) វាអាចបំផ្លាញយើងទាំងខាងផ្លូវចិត្ត និង ខាងរូបកាយ។
   ខ) វាអាចរំឭកយើងថាមានបញ្ហាដែលត្រូវដោះស្រាយ។
   គ) វាគឺជារឿងទូទៅ ជាស្ថានភាពមួយដែលមិនអាចជៀសបាន ។
   ឃ) វាធ្វើឲ្យមិត្តភក្តិ និងគ្រួសាររបស់យើងអាណិតអាសូរយើង។

១២ ចូរអានគម្ពីរយ៉ូប ១:២១-២២ ។ តើឥរិយាបថរបស់លោកយ៉ូបទៅចំពោះទុក្ខព្រួយ និង ការបាត់បង់?
   ក) លោកបដិសេធមិនទទួលស្គាល់អ្វីដែលកើតមានឡើងចំពោះលោកនោះទេ។
   ខ) លោកមានភាពល្វើងជូរចត់ និង ថ្នាំងថ្នាក់ទៅចំពោះព្រះជាម្ចាស់។
   គ) លោកនៅតែបន្តថ្វាយបង្គំព្រះជាម្ចាស់ប្រកបដោយជំនឿ។
   ឃ) លោកលែងទទួលស្គាល់ព្រះជាម្ចាស់ ហើយបាត់បង់គ្រួសាររបស់លោក។

១៣ គ្រិស្តបរិស័ទអាចនឹងឆ្លងកាត់ដំណាក់កាលទី១ គឺការបដិសេធចំពោះការស្លាប់ ព្រោះគំនិតដែលទាក់ទងនឹងការស្លាប់

ក) គួរឲ្យភ័យខ្លាចណាស់ ទោះបីចំពោះគ្រិស្តបរិស័ទក៏ដោយ។

ខ) គឺមិនអាចទទួលយកបាននោះទេ ព្រោះអ្នកជឿទាំងអស់ គឺសុទ្ធតែមានជីវិតអស់កល្បហើយនៅពេលនេះ។

គ) កាត់បន្ថយអ្វីដែលគេជឿថាជាផែនការរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់ពួកគេ។

ឃ) ហាក់បីដូចជាផ្ទុយពីការយល់របស់ពួកគេដែលថា ព្រះគ្រិស្តបានប្រទានការប្រោសឲ្យជារួចស្រេចហើយ។

១៤ ពេលវេលាដ៏ល្អបំផុតដើម្បីពិភាក្សាអំពីបញ្ហាជាក់ស្តែង និង បញ្ហាគ្រួសារ ទាក់ទងទៅនឹងការស្លាប់នោះគឺ

ក) នៅក្នុងដំណាក់កាល "តថ្លៃ" ចំពោះការស្លាប់។

ខ) នៅពេលដែលអ្នកមានអាយុ៧០ឆ្នាំភ្លាម។

គ) នៅពេលដែលអ្នកនៅមានសុខភាពល្អ។

ឃ) មិនត្រូវឆាប់ពេកនោះទេ។

១៥ បញ្ហាដ៏ធំបំផុតសម្រាប់អ្នកដែលដឹងខ្លួនថាពួកគេកំពុងតែជិតស្លាប់គឺ

ក) ការសុំការអត់ទោសចំពោះអ្វីដែលពួកគេបានធ្វើ។

ខ) ការរៀបចំកិច្ចការហិរញ្ញវត្ថុរបស់ពួកគេឲ្យបានត្រឹមត្រូវ។

គ) ការធ្វើបណ្តាំផ្សេងៗ

ឃ) រៀបចំខ្លួនដើម្បីចូលគាល់ព្រះជាម្ចាស់។

១៦ យោងទៅតាមគម្ពីរហេប្រឺ ១២:២-៣ ព្រះគ្រិស្តរងទុក្ខ និង សុគតដើម្បី

ក) ជាការជំរុញចិត្តយើងឲ្យបរិភោគអាហារធ្វើឲ្យមានសុខភាពល្អ។

ខ) ប្រាប់យើងថាការស្លាប់នឹងជាការលំបាក។

គ) រំដោះយើងពីទុក្ខព្រួយទាំងអស់។

ឃ) លើកទឹកចិត្តយើង។

១៧ ការយកចិត្តទុកដាក់តែលើព្រះពរ និងព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ ជាជាងបារម្ភពីបញ្ហា គឺហៅថា

ក) ភាពឆោតល្ងង់

ខ) ការជឿជាក់

គ) ការអះអាងបញ្ជាក់

ឃ) ការលន់តួ

១៨ គម្ពីររ៉ូម ៤:២១ បង្រៀនយើងថា ព្រះជាម្ចាស់មានឫទ្ធានុភាពដើម្បីធ្វើ
   ក) អ្វីដែលអធិស្ឋានបង្គំឲ្យទ្រង់ធ្វើ។
   ខ) អ្វីដែលយើងអនុញ្ញាតឲ្យទ្រង់ធ្វើប៉ុណ្ណោះ។
   គ) អ្វីដែលទ្រង់បានសន្យាថានឹងធ្វើ។
   ឃ) អ្វីដែលយើងបង្គំឲ្យទ្រង់ធ្វើ។

១៩ ការអះអាងបញ្ជាក់នៅក្នុងព្រះគម្ពីរ គឺផ្អែកលើអ្វីដែលព្រះជាម្ចាស់បានធ្វើរួច និង ជំនឿរបស់យើង ដែលថា
   ក) យើងស័ក្តិសមទទួលជំនួយពីទ្រង់។
   ខ) យើងអាចបញ្ចុះបញ្ចូលទ្រង់ឲ្យថែរក្សាយើងបាន។
   គ) ទ្រង់នឹងបន្តសកម្មភាពរបស់ទ្រង់នៅក្នុងពេលអនាគតទៀត។
   ឃ) ទ្រង់នឹងមិនប្រទានព្រះពររបស់ទ្រង់មកយើងនៅពេលអនាគតទេ។

២០ គម្ពីរហេប្រឺជំពូក១១ បង្រៀនយើងថា មានចំណងយ៉ាងមាំរវាងជំនឿរបស់យើង និង
   ក) ក្តីសង្ឃឹមរបស់យើង
   ខ) កំហឹងរបស់យើង
   គ) ការអស់សង្ឃឹមរបស់យើង
   ឃ) ចំណង់ចិត្តរបស់យើង។

អថសានកថា

យើងសង្ឃឹមថាការសិក្សាមួយនេះបានធ្វើឲ្យអ្នកគិតអំពីទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះជាម្ចាស់។ បន្ទាប់ពីបានសិក្សាមេរៀននេះរួច និង បានឆ្លើយគ្រប់សំណួរទាំងអស់ តើអ្នកធ្លាប់បានសួរខ្លួនឯងទេថា " តើខ្ញុំពិតជាគ្រិស្តបរិស័ទពិតប្រាកដម្នាក់ ដែរឬទេ? តើខ្ញុំស្គាល់ព្រះជាម្ចាស់ដែរឬទេ? តើទ្រង់ពិតជាគង់នៅក្នុងជីវិតរបស់ខ្ញុំ ដែរឬទេ?" យើងចង់ផ្តល់ឲ្យអ្នកនូវឱកាសក្នុងពេលនេះ ដើម្បីមានទំនាក់ទំនងជាមួយព្រះជាម្ចាស់។

យើងទាំងអស់គ្នាសុទ្ធតែធ្លាប់បានប្រព្រឹត្តខុស។ យើងធ្លាប់ធ្វើឲ្យខ្លួនឯង ព្រមទាំងអ្នកដទៃឈឺចាប់។ ព្រះគម្ពីរហៅការនោះថា ជាអំពើបាប ហើយយើងរាល់គ្នាសុទ្ធតែមានទោស៖ "គ្រប់ៗគ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប ហើយគ្មានសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជាមួយ" (គម្ពីររ៉ូម ៣:២៣) ។ អំពើបាបរបស់យើងបានរារាំងយើងមិនឲ្យស្គាល់ព្រះជាម្ចាស់ ថាជាឪពុកដែលពេញដោយក្តីស្រឡាញ់។ ប៉ុន្តែព្រះជាម្ចាស់ស្រឡាញ់យើងណាស់ ទោះបីយើងមានបាបក្តី។ ទ្រង់ស្រឡាញ់យើងខ្លាំងណាស់ បានជាទ្រង់ចាត់បុត្រារបស់ទ្រង់មកសុគតសម្រាប់យើងរាល់គ្នា។ " ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក ដើម្បីអោយអស់អ្នកដែលជឿលើព្រះបុត្រា មានជីវិតអស់កល្បជានិច្ច គឺមិនអោយគេវិនាសឡើយ។"
(គម្ពីរយ៉ូហាន៣:១៦)។ នៅពេលដែលទ្រង់សុគត ព្រះយេស៊ូបានទទួលយក ការដាក់ទោសដែលយើងសមនឹងទទួលបាន ដោយសារបាបរបស់យើង។

តើអ្នកចង់ធ្វើឲ្យប្រាកដថា ព្រះយេស៊ូជាព្រះសង្គ្រោះរបស់អ្នកដែរឬទេ? វាសាមញ្ញណាស់៖

- ទទួលស្គាល់ថាអ្នកជាមនុស្សបាបទុគ៌ត ដែលបែកចេញពីព្រះជាម្ចាស់ ហើយទូលសូមឲ្យទ្រង់លើកលែងឲ្យអ្នក។
- ជឿលើព្រះយេស៊ូ ឲ្យអស់ពីដួងចិត្តរបស់អ្នក ហើយធ្វើឲ្យទ្រង់ជ្រាបថា អ្នកពិតជាបានទទួលទ្រង់ជាព្រះសង្គ្រោះរបស់អ្នកមែន។

  អ្នកអាចទូលទៅកាន់ព្រះជាម្ចាស់ដោយប្រើពាក្យផ្ទាល់ខ្លួនរបស់អ្នក ដោយថាតាមការអធិស្ឋាននូវលក្ខណៈបែបនេះ៖

បពិត្រព្រះយេស៊ូ ទូលបង្គំដឹងថាទូលបង្គំជាមនុស្សមានបាប។ សូមទ្រង់ប្រណីសន្តោសឲ្យទូលបង្គំផង។ ទូលបង្គំជឿថាទ្រង់គឺជាបុត្រដ៏អស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ ។ ទូលបង្គំសូមអរព្រះគុណទ្រង់សម្រាប់ការសុគតនៅលើឈើឆ្កាងសម្រាប់បាបរបស់ទូលបង្គំ។ សូមយាងមកគង់ក្នុងជីវិតរបស់ទូលបង្គំ។ ព្រោសឲ្យទូលបង្គំទៅជាមនុស្សដែលពិតប្រាកដនៅក្នុងជីវិតរបស់ទូលបង្គំ។ សូមសោយរាជ្យជាព្រះអម្ចាស់នៃជីវិតរបស់ទូលបង្គំនៅថ្ងៃនេះ។ សូមអរព្រះគុណទ្រង់សម្រាប់ការសង្គ្រោះទូលបង្គំ។

ប្រសិនបើអ្នកអធិស្ឋានតាមសេចក្តីអធិស្ឋាននេះ ហើយមានបំណងរកវាដាក់នៅក្នុងចិត្តរបស់អ្នក ពិតមែន នោះបាបរបស់អ្នកត្រូវលើកលែង ហើយអ្នកមានជីវិតអស់កល្បជានិច្ចផងដែរ។ ព្រះយេស៊ូគឺជាព្រះអម្ចាស់នៃជីវិតរបស់អ្នក។ ព្រះគម្ពីរបានថ្លែងថា " បើយើងទទួលសារភាពអំពើបាបរបស់យើង នោះព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះស្ម័គ្រ និងសុចរិត* ទ្រង់នឹងអត់ទោសយើងអោយរួចពីបាប ព្រមទាំងជំរះយើងអោយបានបរិសុទ្ធ រួចពីគ្រប់អំពើទុច្ចរិតទាំងអស់ផង" (គម្ពីរ១យ៉ូហាន ១:៩)។

ក្រមួចសំណួរសម្រាប់សិស្ស

សូមអាន និងបំពេញសំណួរនៅក្នុងទំព័រខាងក្រោម ហើយដាក់ស្នើវា មិនថាអ្នកជាសិស្សដែលចុះឈ្មោះ ឬ គ្រាន់តែជាអ្នកដែលចង់អភិវឌ្ឍខ្លួនឯង។ សូមព្រះជាម្ចាស់ប្រទានពរអ្នក ស្របពេលដែលដំណើរនៃជំនឿរបស់អ្នកបន្តទៅមុខ!

សំណួរសម្រាប់និស្សិត

CS6161KHM ការដោះស្រាយបញ្ហាជីវិត

ឈ្មោះរបស់អ្នក.....

អាសយដ្ឋាន.....

.....

អ៊ីម៉ែល.....

លេខទូរស័ព្ទ(មិនដាក់ក៏បាន).....

១ តើអ្នកអធិស្ឋានដើម្បីទទួលយកព្រះយេស៊ូជាព្រះអម្ចាស់ និងជាព្រះសង្គ្រោះ ជាលើកដំបូងនៅក្នុងពេលដែលអ្នកកំពុងសិក្សាមុខវិជ្ជានេះឬ?

❑ បាទ/ចាស ❑ ទេ

បើមែន សូមចែករំលែករឿងរបស់អ្នក.....

.....

.....

២ តើមុខវិជ្ជានេះបានជួយអ្នកឲ្យនាំនរណាម្នាក់ចូលទៅកាន់ព្រះគ្រិស្តដែរឬទេ?

❑ បាទ/ចាស ❑ ទេ

៣ តើមុខវិជ្ជានេះបានពង្រឹងកម្លាំងអ្នកក្នុងនាមជាគ្រិស្តបរិស័ទដែរឬទេ?

❑ បាទ/ចាស ❑ ទេ

បើពិតមែន តើវាដោយរបៀបណា? .....

.....

.....

៤ តើអ្នកអាចនឹងណែនាំមុខវិជ្ជានេះទៅកាន់អ្នកដទៃបានដែរឬទេ?

❑ បាទ/ចាស ❑ ទេ

សូមឲ្យព័ត៌មាននៃមិត្តភក្តិម្នាក់របស់អ្នក ហើយយើងនឹងទាក់ទងគេអំពីរបៀបដែលគេអាចរៀនរបស់ទាំងនេះបាន។

ឈ្មោះមិត្តរបស់អ្នក.....

អាសយដ្ឋាន.....

.....

អ៊ីម៉ែល.....

លេខទូរស័ព្ទ (មិនឲ្យក៏បាន).....

ឥឡូវនេះដោយសារអ្នកបានបញ្ចប់ការសិក្សាមុខវិជ្ជានេះ យើងលើកទឹកចិត្តអ្នកឲ្យចាប់ផ្តើមសិក្សាមុខវិជ្ជាបន្ទាប់ទៀត នៅក្នុងកម្មវិធីនេះ ឬសុំគ្រូរបស់អ្នក ឲ្យណែនាំមុខវិជ្ជាសិក្សាមួយផ្សេងទៀត។

GLOBAL UNIVERSITY
ACCESSIBLE | ACCREDITED | AFFORDABLE
DISTANCE LEARNING

1.800.443.1083 • web: www.globaluniversity.edu
www.globalreach.org • facebook.com/globaluniversity
1211 s. glenstone ave. • springfield, mo • 65804 • USA

កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ

សិក្សាអំពីភាពជាអ្នកដឹកនាំក្នុងគ្រិស្តបរិស័ទ

មុខវិជ្ជានេះនឹងជួយអ្នកឲ្យ...

- ស្វែងរកឃើញពីប្រភពនៃបញ្ហានៅក្នុងជីវិតរបស់គ្រិស្តបរិស័ទ។
- រៀនយកដំណោះស្រាយនៅក្នុងព្រះគម្ពីរទៅប្រើប្រាស់ នៅក្នុងបញ្ហារបស់អ្នក។
- ស្គាល់ពីទំនាក់ទំនងរវាងការរងទុក្ខ និង ការលូតលាស់ខាងឯវិញ្ញាណ
- ជួយអ្នកដទៃដែលបានឆ្លងកាត់បញ្ហា

សៀវភៅផ្សេងទៀតនៅក្នុងកម្មវិធីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ មានដូចជា៖

- ភាពពេញវ័យរបស់គ្រិស្តបរិស័ទ
- ការអធិស្ឋាន និង ការថ្វាយបង្គំ
- គ្រិស្តបរិស័ទដែលមានទំនួលខុសត្រូវ

សូមទំនាក់ទំនងអ្នកតំណាងក្នុងកម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ របស់អ្នក សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបយកសៀវភៅទាំងនេះទៅសិក្សា

កម្មវិធិសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ រួមមាន ១៨ មុខវិជ្ជា
ចែកជាបីវគ្គ វគ្គនីមួយៗមាន៦ មុខវិជ្ជា
ការដោះស្រាយបញ្ហាជីវិត ជាមុខវិជ្ជាទី៦ ក្នុងវគ្គទី១

PN 01.26.01
CS6161KHM